សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

# នីតិកិច្ចសន្យាពិសេស
# ភាគ១



លោកស្រី ប៉ូលី បញ្ញា និង លោក ព្រុំ រិទ្ធី

បោះពុម្ពលើកទី១ ឆ្នាំ២០២១

ក្រសួង អប់រំ យុវជន និងកីឡា

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ

និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

# នីតិកិច្ចសន្យាពិសេសភាគ១

អ្នកនិពន្ធ

លោកស្រីប៉ូលី បញ្ញា និងលោក ព្រុំ រិទ្ធី

ក្រោមការគាំទ្រនៃ មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

( មូលនិធិ ស.គ.ន. )

២០២១

# បុព្វកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយដែលចាប់ឬសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សារជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ៨%ក្នុងមួយឆ្នាំ។ លើសពីនេះទៀតអត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣% នៅឆ្នាំ២០០៤មកនៅទាបជាង១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្របដណ្តប់ ក៏កំពុងលេចរូបរាងឡើង ដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹងនិងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវ និងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគ លើការស្រាវជ្រាវនិងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូង និងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផល ប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ៥%នៃការវិនិយោគទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០%នៃប្រជាជនពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគ លើការស្រាវជ្រាវនិងអភិវឌ្ឍរួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូងដែលស្មើនឹងប្រមាណ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ២០០២នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labour and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-

Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សាំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទា ក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជា មូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ធាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយពុទ្ធិ គឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ពិសេសគឺគ្រឹះស្ថានឧត្តមសិក្សា

ត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតប ចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជាស្ពាន នៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះ រួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិកនិងសារគមនាគមន៍ ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរេខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ធនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក។ លក្ខណៈសម្បត្តិនៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និងជាពិសេសគឺការបណ្តុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្សនិងនិស្សិតអាចទទួលបានពីគ្រូ នៅគ្រឹះស្ថានសិក្សាដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ ក្នុងមួយឆ្នាំមានសៀវភៅជាង២,២លានចំណងជើង ត្រូវបានសរសេរនិងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន

៤៤០ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន៣០៥ពាន់ និងប្រទេសរុស្ស៊ីមាន ១២០ពាន់ចំណងជើង។

ខណៈពេលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើនជម្រើសសម្រាប់សិស្ស-និស្សិត និងសាធារណៈជនរួមមានការអានសៀវភៅ ការអានលើឧបករណ៍ អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗ ដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើបចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស-និស្សិត និងសាធារណៈជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀតបច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ ជាពិសេសការអប់រំ តាមប្រព័ន្ធអេឡិចត្រូនិក និងការអប់រំពីចម្ងាយដើម្បីលើកកម្ពស់អំណាន តាមរយៈការផលិតមាតិកាឌីជីថលដែលមានភាពចំរុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំជាមួយការចែកសន្លឹក

កិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្តុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សា ឱ្យកាន់តែ មានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

១. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា

២. គ្រឹះស្ថានឧត្តមសិក្សា សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ

៣. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យត្រូវរៀបចំដំណើរការរៀន បង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន

៤. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថលជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចទទួលបាន និង

ស្វែងរកប្រភពសម្រាប់អំណានកាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន

៥. និស្សិតគ្រប់កម្រិតសិក្សាត្រូវខិតខំនិងចំណាយពេលអាន និងចាត់ទុកវប្បធម៌ និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ

៦. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាលសូមជួយជំរុញនិងបង្កលក្ខណៈកាន់តែច្រើនថែមទៀត ជាពិសេសការលៃលកចំណាយនៅក្នុងគ្រួសារ សម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការ វិនិយោគមួយដ៏សំខាន់ សម្រាប់បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា “មូលនិធិ ស.គ.ន.” និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា “RCI Fund”។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន. បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមានឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម ៤.០ (Digitalization for IR.4.0) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ (21st Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពវូបនីយកម្ម លើទិសដៅនៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់ការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះ ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សាមានគោលដៅដូចខាងក្រោម ៖

១. ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិត នៅកម្រិតឧត្តមសិក្សា
២. លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀន និងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់
៣. បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈ និងបទពិសោធន៍សម្រាប់ឋានៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ
៤. រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បី

បង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀននិងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិតត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច២ច្បាប់នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិ ស.គ.ន រួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំថវិកាមូលនិធិ ដើម្បីរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា សូមរួសរាន់ចូលរួម ដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូចនិងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

## សេចក្តីបញ្ជាក់
## នៃមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះ ជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោងរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ ឬរូបភាព ដែលមាននៅក្នុងសៀវភៅនេះ គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡាឡើយ។

## ចំណាប់អារម្មណ៍រួម

នេះជាកិត្តិយស និងមោទនភាពសម្រាប់រូបខ្ញុំ ដែលមានឱកាសផ្តល់ចំណាប់អារម្មណ៍រួម ចំពោះស្នាដៃដំបូងនៃការរៀបរៀង **និពន្ធ និងកែលម្អសៀវភៅ** នៅកម្រិតឧត្តមសិក្សារបស់អស់លោក លោកស្រី ជាមន្ត្រីរាជការ សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ជាច្រើនឆ្នាំកន្លងមកនេះ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សផ្នែកនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបច្ចុប្បន្នធនធានមនុស្សទាំងនោះ បាន និងកំពុងចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍប្រទេសជាតិ។ លទ្ធផលសម្រេចបានដ៏ប្រសើរនេះ កើតចេញតាមរយៈការផ្តល់សេវាអប់រំបណ្តុះបណ្តាលប្រកបដោយគុណភាពនៅថ្នាក់ឧត្តមសិក្សា និងក្រោយឧត្តមសិក្សា ការបង្កើនសមត្ថភាពមុខជំនាញបច្ចេកទេសដល់សាស្ត្រាចារ្យបង្រៀន ការធ្វើសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សាក្នុង និងក្រៅប្រទេស អង្គការជាតិ-អន្តរជាតិ ព្រមទាំងនិងស្ថាប័នពាក់ព័ន្ធនានា ក្នុងគោលបំណងតែមួយគត់គឺធ្វើឲ្យកាន់តែល្អប្រសើរនូវការសិក្សា ការបង្រៀន និងការស្រាវជ្រាវ ការបោះពុម្ពផ្សាយ និងការជំរុញឲ្យមាននវានុវត្តន៍។

ក្នុងឆ្នាំសិក្សា២០២០-២០២១ ទោះបីជាស្ថិតក្នុងបរិបទនៃការរីករាលដាលនៃជម្ងឺកូវីដ-១៩ សាកលវិទ្យាល័យ នៅតែបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការចូលរួមលើកកម្ពស់សកម្មភាពស្រាវជ្រាវ ក្នុងនោះតាមសេចក្តីប្រកាសព័ត៌មានស្តីពី **ការផ្តល់ថវិកាមូលនិធិស្រាវជ្រាវគំនិតច្នៃប្រឌិត និងនវានុវត្តន៍ សម្រាប់ការរៀបរៀង និពន្ធ និងកែលម្អ**

**សៀវភៅនៅកម្រិតឧត្តមសិក្សា** របស់ក្រសួងអប់រំ យុវជន និងកីឡា កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបានធ្វើការផ្សព្វផ្សាយជូនដំណឹង និងលើកទឹកចិត្តដល់មន្ត្រីរាជការ សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យឲ្យចូលរួមដាក់ពាក្យសុំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីចូលរួមលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្តន៍ ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំស្របតាមការវិវត្តនៃបរិបទសង្គម សេដ្ឋកិច្ច បច្ចេកវិទ្យា និងឆ្លើយតបទៅនឹងបច្ចុប្បន្នភាពនៃតម្រូវការទីផ្សារការងារ។ ជាលទ្ធផល នៅជំហានចាប់ផ្តើមដំបូងនេះ សាកលវិទ្យាល័យទទួលបានស្នាដៃរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាចំនួន១២ចំណងជើង។

សៀវភៅសិក្សាទាំង១២ចំណងជើងដែលជាស្នាដៃរបស់អ្នកនិពន្ធទាំងអស់ ត្រូវបានចាត់ទុកជាធនធានសិក្សាដ៏សំខាន់របស់សាកលវិទ្យាល័យ ខ្ញុំសូមធ្វើការកោតសរសើរដោយស្មោះ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងយ៉ាងសកម្ម ប្រកបដោយមនសិការវិជ្ជាជីវៈរបស់អស់លោក លោកស្រី មន្ត្រីរាជការ សាស្ត្រាចារ្យទាំងអស់របស់សាកលវិទ្យាល័យក្នុងការចូលរួមរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងបង្កើនធនធានសិក្សាជាខេមរភាសាសម្រាប់និស្សិត និងការត្រៀមខ្លួនដើម្បីធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សា គឺជាធនធានសិក្សាដ៏ចាំបាច់មិនអាចខ្វះបានដែលគាំទ្រដល់ការបង្រៀន និងរៀនរបស់សាស្ត្រាចារ្យ និងនិស្សិត ហើយត្រូវមានបរិមាណគ្រប់គ្រាន់ឆ្លើយតបទៅនឹងកម្មវិធីបណ្តុះបណ្តាល និងតម្រូវការនៃការសិក្សា

ស្រាវជ្រាវ។ សៀវភៅដែលជាស្នាដៃនិពន្ធរបស់អស់លោក លោកស្រី មន្ត្រីរាជការ សាស្ត្រាចារ្យទាំងអស់ ពិតជាមានសារសំខាន់ និងជាវិភាគទានដ៏មានសារៈប្រយោជន៍សម្រាប់និស្សិតកំពុងសិក្សា អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ ក៏ដូចជាសម្រាប់តម្កល់ទុកនៅបណ្ណាល័យរបស់សាកលវិទ្យាល័យសម្រាប់និស្សិតអាន និងស្វែងយល់ផងដែរ។

ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា អស់លោក លោកស្រី មន្ត្រីរាជការ សាស្ត្រាចារ្យទាំងអស់នឹងបន្តចូលរួមរៀបរៀង និពន្ធ និង កែលម្អសៀវភៅសិក្សានេះនៅដំណាក់កាលជាបន្តបន្ទាប់ទៀតនាពេលខាងមុខ។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា** និងថ្នាក់ដឹកនាំពាក់ព័ន្ធគ្រប់កម្រិត ដែលបានផ្តួចផ្តើមបង្កើតមូលនិធិ ស.គ.ន នេះឡើង ដែលជាការផ្តល់ឱកាសឲ្យសាកលវិទ្យាល័យ បានចូលរួមចំណែកក្នុងការលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវនៅកម្ពុជា។

ថ្ងៃពុធ ៨រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១

**សាកលវិទ្យាធិការ**

**បណ្ឌិត លុយ ចណ្ណា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និង
វិទ្យាសាស្ត្រសេដ្ឋកិច្ច

**លិខិតបញ្ជាក់**

ខ្ញុំបាទឈ្មោះ **លុយ ចណ្ណា** ជាសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមគោរពបញ្ជាក់ជូន**
**ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី នៃក្រសួងអប់រំ យុវជន និងកីឡា**

សៀវភៅដែលមានចំណងជើង នីតិកិច្ចសន្យាពិសេស ដែលនិពន្ធតាក់តែងឡើងដោយ បណ្ឌិត ព្រុំ រិទ្ធី និង លោកស្រី ប៉ូលី បញ្ញា សម្រាប់ដំណើរការរៀន និងបង្រៀន និងតម្កល់ទុកនៅក្នុងបណ្ណាល័យនៃសាកលវិទ្យាល័យ។

តាងនាមឲ្យគណៈគ្រួតពិនិត្យ យើងខ្ញុំសង្កេតឃើញថា៖ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ ដែលមាននៅក្នុងសៀវភៅនេះ ជាពាក្យពេចន៍ ឃ្លាប្រយោគរបស់អ្នកនិពន្ធទាំងពីរនាក់នេះ ដោយឡែកគំនិត និងខ្លឹមសារ មិនមានការខុសអំពីខ្លឹមសារលំនាំដើម នៃឯកសារនោះទេ។

សៀវភៅនេះ បានសរសេរជាភាសាខ្មែរ ដែលធ្វើឲ្យមានលក្ខណៈងាយយល់ អាចយកទៅអនុវត្តបាន។

អាស្រ័យហេតុនេះ សូមផ្នែកពាក់ព័ន្ធ មេត្តាជ្រាបជាព័ត៌មានតាមការគួរ ។

ថ្ងៃសៅរ៍ ៦កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១
**សាកលវិទ្យាធិការ**

**បណ្ឌិត លុយ ចណ្ណា**

# សេចក្តីថ្លែងអំណរគុណ

## សូមថ្លែងអំណរគុណចំពោះ៖

- **ក្រសួង អប់រំ យុវជន និងកីឡា** ដែលបានលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្តន៍ ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ ដើម្បីឆ្លើយតបនឹងតម្រូវការនៃការវិវត្តស្របតាមបរិបទសង្គម សេដ្ឋកិច្ច និងបច្ចេកវិទ្យា តាមរយៈការបង្កើនបរិមាណនៃធនធានសិក្សាជាខេមរៈភាសា ជូនដល់និស្សិតដែលកំពុងសិក្សា និងការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា ក្នុងចក្ខុវិស័យ **«មុខវិជ្ជាសិក្សាមួយសៀវភៅមួយ»**។
- **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ដែលបានគាំទ្រសកម្មភាពរបស់មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ជាពិសេសគឺលើកទឹកចិត្តនិងជំរុញឲ្យមានការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា នៅកម្រិតឧត្តមសិក្សា។
- **មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍(ស.គ.ន.)** នៃក្រសួង អប់រំ យុវជន និងកីឡា ដែលបានផ្តួចផ្តើម និងលើកកម្ពស់ការរៀបរៀង និពន្ធ និងកែលម្អធនធានសិក្សាជាខេមរៈភាសានៅកម្រិតឧត្តមសិក្សា។
- **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានចូលរួមអនុវត្តស្របតាមទិសដៅ និងចក្ខុវិស័យរបស់ក្រសួង អប់រំ យុវជន និងកីឡា ជាពិសេស គឺការគាំទ្រសកម្មភាពមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ (មូលនិធិស.គ.ន.) ដោយអំពាវនាវ ផ្តល់ឱកាសលើកទឹកចិត្ត និងជំរុញការចូលរួមពីបុគ្គលិកអប់រំ និងសាស្ត្រាចារ្យវេលាកាលក្នុងសាកលវិទ្យាល័យ ឲ្យបានរួមចំណែកកសាងធនធានសិក្សាជា

ខេមរៈភាសា ដើម្បីឆ្លើយតបនិងបច្ចុប្បន្នភាពកម្មវិធីបណ្តុះបណ្តាលក្នុងសាកលវិទ្យាល័យ។

- **ក្រុមប្រឹក្សាវិទ្យាសាស្ត្រនៃសាកលវិទ្យាល័យ** ដែលជាផ្នែកមួយដ៏សំខាន់និងមិនអាចខ្វះបាន ក្នុងការត្រួតពិនិត្យវាយតម្លៃ និងផ្តល់យោបល់ស្ថាបនាលើស្នាដៃសៀវភៅ ដែលធ្វើឲ្យស្នាដៃមួយនេះកាន់តែមានភាពល្អប្រសើរឡើង និងមានខ្លឹមសារពេញលេញ។
- **ភាគីពាក់ព័ន្ធទាំងអស់** ដែលបានផ្តល់ឯកសារនានាគាំទ្រដល់ការរៀបរៀងនិងនិពន្ធសៀវភៅនេះ។
- **ក្រុមគ្រួសារទាំងមូល** ដែលបានផ្តល់ឱកាសដល់យើងខ្ញុំក្នុងការរៀបរៀងនិងនិពន្ធសៀវភៅនេះ។

# អារម្ភកថា

**សៀវភៅនីតិកិច្ចសន្យាពិសេសភាគ១** នេះត្រូវបានតាក់តែងឡើងដើម្បីជាឯកសារជំនួយស្មារតីដល់និស្សិត និងអ្នកសិក្សាស្រាវជ្រាវដែលមានចំណាប់អារម្មណ៍ ចង់សិក្សាស្វែងយល់ឲ្យកាន់តែស៊ីជម្រៅ ទៅលើប្រភេទ និងលក្ខណៈពិសេសនៃកិច្ចសន្យានីមួយៗ ស្របតាមខ្លឹមសារនៃវិធានច្បាប់សារធាតុផ្នែកឯកជន ឬខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ និងខ្លឹមសារនៃវិធានពិសេសៗដ៏ទៃផ្សេងទៀត ដែលមានអានុភាពអនុវត្តទៅលើប្រភេទផ្សេងៗ នៃកិច្ចសន្យាពិសេសៗមួយចំនួននៅកម្ពុជា។ បន្ថែមពីនេះ ការតែងនិពន្ធ**សៀវភៅនីតិកិច្ចសន្យាពិសេសភាគ១** គឺជាការរួមចំណែកកសាងនូវឯកសារជាខេមរៈភាសា ក្នុងទិសដៅ ដើម្បីសម្រេចឲ្យបានជោគជ័យស្របតាមទស្សនៈវិស័យ និងគោលបំណងរបស់ក្រសួង អប់រំ យុវជន និងកីឡា ក្នុងការលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្តន៍ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ ស្របតាមការវិវត្តនៃបរិបទសង្គមសេដ្ឋកិច្ច បច្ចេកវិទ្យា និងដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារក៏ដូចជាការខិតខំប្រឹងប្រែងចូលរួមអនុវត្តឲ្យបាន ស្របតាមផែនការយុទ្ធសាស្ត្រសាកលវិទ្យាល័យ ក្នុងការបំពេញតួនាទីជាសាកលវិទ្យាល័យតាមរយៈការបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសាជូនដល់និស្សិតដែលកំពុងសិក្ស និងការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សាស្របតាមចក្ខុវិស័យ «**មុខវិជ្ជាសិក្សាមួយសៀវភៅមួយ**» ។

ជាចុងក្រោយ យើងខ្ញុំមានសេចក្តីសង្ឃឹម និងរំពឹងយ៉ាងមុតមាំថា ស្នាដៃនេះជាជម្រើសទី១របស់និស្សិត និងអ្នកសិក្សាស្រាវជ្រាវទាំងអស់ដែលមានបំណងចង់សិក្សាស្វែងយល់អំពីប្រភេទផ្សេងៗនៃកិច្ចសន្យា។

ថ្ងៃសុក្រ ៧កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១

**អ្នកនិពន្ធ**

**លោកស្រី ប៉ូលី បញ្ញា និង លោក ព្រុំ រិទ្ធី**

# នីតិកិច្ចសន្យាពិសេស

## សេចក្តីសង្ខេបនៃមេរៀននីតិកិច្ចសន្យាពិសេស

ជារៀងរាល់ថ្ងៃមិនថានៅកម្ពុជាឬក៏នៅបរទេស ទំនាក់ទំនងដែលកើតមានញឹកញាប់ មិនចេះឈប់ឈរ នៅក្នុងវិស័យឯកជន កំណត់បានជាកិច្ចសន្យា ដែលគឺជាប្រភេទនៃទំនាក់ទំនងគតិយុត្ត បម្រើឲ្យសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងសង្គមគ្រប់សម័យកាល និងអាចចាត់ទុកបានថាជាកិច្ចប្រតិបត្តិការដ៏សំខាន់ផងដែរ ក្នុងការជម្រុញឲ្យសេដ្ឋកិច្ចជាតិដំណើរការកាន់តែល្អប្រសើរ។ បច្ចុប្បន្នដោយគួបផ្សំជាមួយនឹងការវិវត្តនៃវិស័យបច្ចេកវិទ្យា ព័ត៌មានវិទ្យា ដែលជំរុញឲ្យកិច្ចប្រតិបត្តិការជាច្រើននៅជុំវិញទាក់ទងទៅនឹងកិច្ចសន្យាមានភាពងាយស្រួលជាងមុន រហ័សជាងមុន ជាពិសេស គឺគេសង្កេតឃើញមានទំនាក់ទំនងកិច្ចសន្យាអន្តរប្រទេសក៏មានសន្ទុះកាន់តែពុះកញ្ជ្រោលយ៉ាងខ្លាំង។

កិច្ចប្រតិបត្តិការទាំងឡាយដែលបានរៀបរាប់ខាងលើ អាចជាសកម្មភាពពាណិជ្ជកិច្ច ឬជាកិច្ចស៊ីវិលធម្មតា ដែលអាចសង្កេតឃើញមាននៅក្នុងទំនាក់ទំនងនៃកិច្ចសន្យាជាច្រើន មានដូចជានៅក្នុងទំនាក់ទំនងនៃកិច្ចសន្យាលក់ទិញ ភតិសន្យា កិច្ចសន្យាដឹកជញ្ជូន ឬកិច្ចសន្យាម៉ៅការ។ទន្ទឹមនឹងសន្ទុះសកម្មភាពកិច្ចការជំនួញកើតមានជារៀងរាល់ថ្ងៃជាមួយគ្នានេះបញ្ហាប្រឈមជាច្រើនក៏កើតមានដូចគ្នា ជាពិសេសគឺបញ្ហាប្រឈមជុំវិញលក្ខខណ្ឌសុពលភាពនៃការបង្កើតកិច្ចសន្យា ឬជាបញ្ហាដែលកើតចេញពីការមិនអនុវត្តកាតព្វកិច្ចរបស់គូភាគី ឬអាចមានករណី

ដែលតតិយជនបានធ្វើការតតាំងដើម្បីទាមទារសិទ្ធិលើវត្ថុ ឬករណីដែលភាគីអនុវត្តសិទ្ធិសុំមោឃភាព និងសុំរំលាយកិច្ចសន្យាជាដើម។

បន្ថែមពីនេះតាមនិយមន័យនៃក្រមរដ្ឋប្បវេណី កិច្ចសន្យា គឺកើតចេញពីឆន្ទៈរបស់គូភាគី សំដៅដល់បុគ្គលពីរ ឬច្រើន ដោយចងភ្ជាប់ចំណងគតិយុត្តរវាងពួកគាត់តាមរយៈការសំដែងឆន្ទៈរួមគ្នា ក្នុងការផ្លាស់ប្តូរបេតិកភណ្ឌ ឬតាមរយៈការប្រគល់វត្ថុនិងការបង់ប្រាក់ មានដូចជាកិច្ចសន្យាលក់ទិញ ភតិសន្យា ឬក៏ជាការផ្តល់សេវាជាមួយនិងកម្រៃដែលបានមកពីការផ្តល់សេវាផ្សេងៗ ដូចជាកិច្ចសន្យាដឹកជញ្ជូន ឬក៏កិច្ចសន្យាម៉ៅការជាដើម។ ជាទូទៅកិច្ចសន្យាមួយអាចប្រព្រឹត្តទៅបានដោយប្រក្រតី លុះត្រាតែកិច្ចសន្យានោះបានបំពេញនូវលក្ខខណ្ឌជាច្រើនដូចជាលក្ខខណ្ឌគ្រឹះរួមមានដូចជា(ការព្រមព្រៀង សមត្ថភាពគូភាគី កម្មវត្ថុ និងមូលហេតុ) លក្ខខណ្ឌទម្រង់ និង/ឬ ទាក់ទងនឹងភាពចាំបាច់នៃការចុះបញ្ជី។ នៅក្នុងករណីគូភាគីមិនអនុវត្តកាតព្វកិច្ចស្របតាមកិច្ចសន្យា ឬកិច្ចព្រមព្រៀងដែលបណ្តាលឲ្យភាគីម្ខាងទៀតទទួលរងនូវព្យសនកម្ម ឬអាចកំណត់បានថា ជាមូលហេតុដែលនាំឲ្យភាគីខូចប្រយោជន៍ គឺភាគីដែលទទួលរងនូវការខូចខាតផលប្រយោជន៍ អាចមានសិទ្ធិទាមទារនូវសំណងខូចខាតដោយមូលហេតុកំហុសរបស់ភាគីម្ខាងទៀត។

ម្យ៉ាងទៀតការសិក្សាក្នុងផ្នែកនីមួយៗ នៃមេរៀននីតិកិច្ចសន្យា គឺមានបំណងចង់បង្ហាញឲ្យឃើញពីខ្លឹមសារសំខាន់ៗ នៃវិធានគតិយុត្តនានា ដែលមានទំនាក់ទំនងជាមួយនឹងកិច្ចសន្យា ហើយជាពិសេសទៅទៀតនោះ គឺការសិក្សាលម្អិតអំពីវិធានពិសេសនៃកិច្ចសន្យានីមួយៗ ថាមូលហេតុអ្វី? ដោយសារអ្វី? បានជាកិច្ចសន្យានីមួយៗការបង្កើតឬការ

ប្រតិបត្តិកិច្ចសន្យាទាំងនោះត្រូវស្ថិតនៅក្រោមវិធានគ្រប់គ្រងផ្សេងៗគ្នា។ ចំណែកវិធានរួមនៃនីតិកាតព្វកិច្ចក៏បានដើរតួនាទីសំខាន់ ដើម្បីចូលរួមបំពេញបន្ថែមនូវភាពខ្វះចន្លោះ ក្នុងករណីដែលកិច្ចសន្យារបស់គូភាគីមិនបានចែងគ្រប់ជ្រុងជ្រោយអំពីសិទ្ធិ និងករណីយកិច្ចរបស់ពួកគាត់ ឬករណីដែលវិធានពិសេសពុំបានកំណត់ច្បាស់លាស់។

ម្យ៉ាងទៀត យើងអាចកំណត់បានថា គឺដើម្បីដោះស្រាយបញ្ហាប្រឈមដែលកើតមានជុំវិញកិច្ចសន្យា គេត្រូវធ្វើការពិនិត្យទៅលើខ្លឹមសារនៃកិច្ចសន្យា ឬខ្លឹមសារនៃកាតព្វកិច្ច ដែលខ្លឹមសារទាំងនោះ មិនអាចផ្ទុយទៅនឹងវិធានច្បាប់ដែលមានជាធរមាន ហើយក៏មិនអាចផ្ទុយនឹងការអនុវត្តវិធានពិសេស និងវិធានរួមនៃនីតិកិច្ចសន្យាផងដែរ។ ការកំណត់បែបនេះក្នុងគោលដៅ គឺដើម្បីបង្ករភាពងាយស្រួលដល់គូភាគី ក្នុងការស្វែងរកដំណោះស្រាយនាពេលអនាគត។ បន្ថែមពីនេះ នីតិកិច្ចសន្យាពិសេសនិងធ្វើការសិក្សាជុំវិញកិច្ចសន្យា ដែលមានចែងក្នុងក្រមរដ្ឋប្បវេណីមានដូចជាការលក់ទិញ ការដូរ ប្រទានកម្ម ការខ្ចីបរិភោគ ភតិសន្យា ប្រវាស់ ការខ្ចីប្រើអាណ្ណត្តិ កិច្ចសន្យាម៉ៅការ កិច្ចសន្យាការងារ បញ្ញើ កិច្ចសន្យាក្រុមហ៊ុន។ ដោយឡែកចំពោះកិច្ចសន្យាដឹកជញ្ជូន ក្រមរដ្ឋប្បវេណីកម្ពុជាពុំបានចែងដែលជាមូលហេតុ គឺច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីចែងបន្ថែមពីការអនុវត្តក្រឹត្យច្បាប់លេខ៣៨ ឆ្នាំ១៩៨៨ ស្តីពីការអនុវត្តបន្តចំពោះបញ្ញត្តិស្តីពីកិច្ចសន្យាដឹកជញ្ជូន។ ក្នុងចំណោមកិច្ចសន្យាខាងលើ មានកិច្ចសន្យាមួយចំនួន ដែលគេសង្កេតឃើញថាបានប្រើប្រាស់ច្រើនជាងគេ នៅក្នុងទំនាក់ទំនងនៃជីវភាពសង្គមមានដូចជា កិច្ចសន្យាលក់ទិញ កិច្ចសន្យាដឹកជញ្ជូន ភតិសន្យា ក៏ដូចជាកិច្ចសន្យាម៉ៅការ ជាពិសេសនៅក្នុងបរិបទនៃសម័យកាលជំងឺកូវីត-១៩នេះ កិច្ចសន្យាដឹកជញ្ជូន គឺជាកិច្ចសន្យាដែល

ផ្តល់ភាពចាំបាច់បំផុតដើម្បីធានានិរន្តរ៍ភាព និងសុខមាលភាពរបស់អ្នកប្រើប្រាស់ ក៏ដូចពាណិជ្ជករក្នុងការលក់ទិញទំនិញផ្សេងៗ ដែលជាតម្រូវការប្រចាំថ្ងៃរបស់ភាគីអ្នកប្រើប្រាស់។

ដូច្នេះសៀវភៅសិក្សា **ស្តីពីនីតិកិច្ចសន្យាពិសេសភាគ១** នឹងធ្វើការសិក្សាស៊ីជម្រៅទៅលើរបបគតិយុត្តនៃកិច្ចសន្យា ជាពិសេសគឺផ្តោតទៅលើកិច្ចសន្យាសំខាន់ៗមួយចំនួន ដោយផ្អែកទៅលើខ្លឹមសារនៃច្បាប់សារធាតុ និងវិធានពិសេសជុំវិញការបង្កើត និងការអនុវត្តកិច្ចសន្យា។ បន្ថែមពីនេះ សៀវភៅសិក្សាគោលស្តីពីនីតិកិច្ចសន្យាពិសេសភាគ១នេះ គឺបានផ្តល់នូវគុណប្រយោជន៍សម្រាប់អ្នកសិក្សា អ្នកស្រាវជ្រាវផ្នែកច្បាប់ អ្នកវិជ្ជាជីវៈ និងសៀវភៅនេះក៏មានភាពចាំបាច់ នៅក្នុងជីវភាពនៃការរស់នៅប្រចាំថ្ងៃរបស់អ្នកប្រើប្រាស់ ក៏ដូចជាពាណិជ្ជករ ដោយធ្វើការ សិក្សាបែងចែកអំពីៈ របបគតិយុត្តនៃកិច្ចសន្យា(មេរៀនទី១),កិច្ចសន្យាលក់ទិញ(មេរៀនទី២), កិច្ចសន្យាការងារ(មេរៀនទី៣), ភតិសន្យា(មេរៀនទី៤), កិច្ចសន្យាម៉ៅការ(មេរៀនទី៥), កិច្ចសន្យាអាណ្ណត្តិ (មេរៀនទី៦) និងកិច្ចសន្យាដឹកជញ្ជូន(មេរៀនទី៧)។

# មាតិកា

សេចក្តីផ្តើម ........................................................................................ 1

១. ការសិក្សាពីនិយមន័យ និងទស្សនៈជុំវិញការបង្កើតកិច្ចសន្យា ............................... 1

២. ការសិក្សាពីកម្មវត្ថុ និងទស្សនៈជុំវិញការបង្កើតកិច្ចសន្យា .................................. 6

២.១. កម្មវត្ថុត្រូវតែមាន ................................................................................ 7

២.២. កម្មវត្ថុត្រូវតែកំណត់ ឬអាចកំណត់បាន ......................................................... 7

២.៣. កម្មវត្ថុត្រូវតែជាក់លាក់ឬច្បាស់លាស់ ........................................................... 8

២.៤. កម្មវត្ថុត្រូវតែស្របច្បាប់ និងទំនៀមទម្លាប់ដ៏ល្អប្រពៃ ........................................... 8

៣. ការសិក្សាពីកាតព្វកិច្ច និងទស្សនៈជុំវិញនៃការបង្កើតកិច្ចសន្យា .......................... 10

៤. សញ្ញាណទូទៅនៃការបង្កើតកិច្ចសន្យា និងខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជា ......... 11

មេរៀនទី១៖ របបគតិយុត្តនៃកិច្ចសន្យា ................................................................ 15

១.អំពីកាតព្វកិច្ច និងបង្កើតកិច្ចសន្យា ............................................................ 16

២.អំពីប្រភពនៃកាតព្វកិច្ច ........................................................................... 17

ផ្នែកទី១៖ ដំណាក់កាលមុនពេលកិច្ចសន្យា ....................................................... 21

កថាខណ្ឌ១៖ សំណើ ..................................................................................... 22

១.ប្រភេទផ្សេងៗនៃសំណើ ............................................................................ 23

២.សុពលភាពនៃសំណើ .............................................................................. 27

៣.ការដកសំណើ ....................................................................................... 28

កថាខណ្ឌ២៖ ស្ទីការ....32
១. ប្រភេទផ្សេងៗនៃស្ទីការ....32
២.សុពលភាពនៃស្ទីការ....35
៣.សកម្មភាពដែលចាត់ទុកថាជាស្ទីការ....36
ផ្នែកទី២៖ ដំណាក់កាលបង្កើតកិច្ចសន្យា....37
កថាខណ្ឌ១៖ លក្ខខណ្ឌគ្រឹះ....37
១.ការព្រមព្រៀង និងវិការៈនៃការបង្ហាញឆន្ទៈ....38
១.១. ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ....42
១.២. ការឆបោក....47
១.៣. ព័ត៌មានមិនពិត....49
១.៤ ការរំលោភបំពានលើស្ថានភាព....50
១.៥. ការគម្រាមកំហែង....50
១.៦. អំពើកេងចំណេញហួសហេតុ....51
១.៧ អំពីការរំលោភបំពានលើស្ថានភាព និងអំពើកេងចំណេញហួសហេតុ....52
១.៨. ឋបនីយផ្លូវចិត្ត....52
១.៩. ការបង្ហាញឆន្ទៈមិនពិត....54
២.សមត្ថភាពនៃកិច្ចសន្យា....55
៣.កម្មវត្ថុ និងមូលហេតុនៃកិច្ចសន្យា....56
កថាខណ្ឌ២.លក្ខខណ្ឌទម្រង់....57
ផ្នែកទី៣. ដំណាក់កាលក្រោយពេលកិច្ចសន្យា....59

កថាខណ្ឌ១.គោលការណ៍កំណត់អានុភាពនៃកិច្ចសន្យា ....................................60
កថាខណ្ឌ២. ការសង្គ្រោះចំពោះការបំពានកិច្ចសន្យា .........................................61
១.បទប្បញ្ញត្តិទូទៅស្តីពីការមិនអនុវត្តកាតព្វកិច្ច .................................................61
១.១. ការយឺតយ៉ាងក្នុងការអនុវត្តកាតព្វកិច្ច......................................................62
១.២. អលទ្ធភាពក្នុងការអនុវត្ត .....................................................................64
១.៣. ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ.................................................64
១.៤. ករណីផ្សេងទៀតដែលមិនអនុវត្តកាតព្វកិច្ច................................................65
១.៥. ពហុមធ្យោបាយសង្គ្រោះ.........................................................................65
២. ការឲ្យអនុវត្តកាតព្វកិច្ចដោយបង្ខំ ..........................................................66
៣.សំណងនៃការខូចខាត .............................................................................66
៤.ការរំលាយកិច្ចសន្យា..............................................................................67
កថាខណ្ឌ៣. ការមោឃៈភាព និងការលុបចោល ...............................................69
១.អំពីបញ្ញត្តិដែលអនុវត្តដោយបង្ខំ និងបញ្ញត្តិដែលអនុវត្តតាមការស្ម័គ្រចិត្ត .............71
២.អំពីករណីការព្រមព្រៀងរបស់ភាគីផ្ទុយនឹងបញ្ញត្តិនៃក្រមរដ្ឋប្បវេណី....................72
២.១.អ្នកដែលមានសិទ្ធិលុបចោល..................................................................74
២.២. វិធីលុបចោល ឬការផ្តល់សច្ចានុម័ត .......................................................75
២.៣. អ្នកមានសិទ្ធិផ្តល់សច្ចានុម័ត និងលក្ខខណ្ឌនៃការផ្តល់សច្ចានុម័ត .................76
២.៤. សច្ចានុម័តដែលច្បាប់បានកំណត់ ..........................................................77
មេរៀនទី២៖ កិច្ចសន្យាលក់ទិញ.......................................................................80
ផ្នែកទី១. ដំណាក់កាលមុនពេលបង្កើតកិច្ចសន្យាលក់ទិញ ....................................82

កថាខណ្ឌ១.ការសន្យាលក់ទិញជាមុនដោយឯកតោភាគី ....................................83

កថាខណ្ឌ២. ប្រាក់កក់ ........................................................................................85

កថាខណ្ឌ៣. ការលក់ដោយមានការភ្លក់សាក ..................................................86

កថាខណ្ឌ៤. ការលក់ដោយមានការប្រើសាក ..................................................87

កថាខណ្ឌ៥. ថ្លៃលក់ទិញ ..................................................................................88

កថាខណ្ឌ៦. សោហ៊ុយក្នុងការលក់ទិញ ...........................................................89

កថាខណ្ឌ៧. ភាគីនៃកិច្ចសន្យាលក់ទិញ ...........................................................90

កថាខណ្ឌ៨.វត្ថុដែលអាចលក់បាន .....................................................................91

ផ្នែកទី២.លក្ខខណ្ឌបង្កើតកិច្ចសន្យាលក់ទិញ .................................................91

កថាខណ្ឌ១. លក្ខខណ្ឌគ្រឹះនៃការបង្កើតការលក់ទិញ ........................................92

១. ការព្រមព្រៀងបង្កើតការលក់ទិញ ..................................................................93

២. សមត្ថភាពគូភាគីនៃការលក់ទិញ ..................................................................93

៣.កម្មវត្ថុនិងមូលហេតុនៃការលក់ទិញ ..............................................................94

កថាខណ្ឌ២.លក្ខខណ្ឌទម្រង់នៃការបង្កើតការលក់ទិញ .......................................94

ផ្នែកទី៣.អានុភាពនៃកិច្ចសន្យាលក់ទិញ ...........................................................95

កថាខណ្ឌ១. សិទ្ធិ និងករណីយកិច្ចអ្នកលក់ ......................................................95

កថាខណ្ឌ២. សិទ្ធិ និងករណីយកិច្ចអ្នកទិញ ......................................................96

មេរៀនទី៣៖ កិច្ចសន្យាការងារ ........................................................................97

ផ្នែកទី១. ការបង្កើតកិច្ចសន្យាការងារ ...........................................................101

កថាខណ្ឌ១. ការព្រមព្រៀងដោយគិតប្រាកដ និងដោយសេរី ..............................101

១. វិការៈនៃការព្រមព្រៀងតាមខ្លឹមសារក្រឹត្យច្បាប់លេខ៣៨ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវនៅក្រៅកិច្ចសន្យា ....... 103
២. វិការៈនៃការព្រមព្រៀងតាមគោលការណ៍ក្រមរដ្ឋប្បវេណីកម្ពុជា ....... 105
៣. ការបកស្រាយអំពីការភាន់ច្រឡំតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណី ....... 106
៣.១. ការភាន់ច្រឡំចំណុចសំខាន់ ....... 106
៣.២. ការភាន់ច្រឡំចំណុចដែលភាគីយល់ឃើញថាសំខាន់ ....... 107
៣.៣. ការភាន់ច្រឡំរួម ....... 108
កថាខណ្ឌ២. កិច្ចសន្យាការងារត្រូវតែមានកម្មវត្ថុស្របច្បាប់ និងអាចអនុវត្តបាន ....... 109
កថាខណ្ឌ៣. មូលហេតុរបស់ភាគីនៃកិច្ចសន្យាការងារ ....... 110
កថាខណ្ឌ៤. សមត្ថភាពរបស់ភាគីនៃកិច្ចសន្យាការងារ ....... 110
ផ្នែកទី២. អំពីអានុភាពនៃកិច្ចសន្យាការងារ ....... 112
១. អានុភាពចំពោះគូភាគី ....... 114
១.១. បង្ខំឲ្យគូភាគីត្រូវតែប្រតិបត្តិ ....... 114
១.២. គូភាគីប្រតិបត្តិក្នុងនាមឪពុកគំរូ,គូភាគីត្រូវប្រតិបត្តិ ដោយគោលការណ៍ សុច្ចរិត និងភាពស្មោះត្រង់ ....... 115
១.៣. គូភាគីត្រូវប្រតិបត្តិដោយមិនអាចប្រកែកបាន ....... 117
២. អានុភាពចំពោះតតិយជន ....... 117
៣. អានុភាពចំពោះចៅក្រម ....... 119
ផ្នែកទី៣. អំពីប្រភេទ និងលក្ខណៈពិសេសនៃកិច្ចសន្យាការងារ ....... 120
កថាខណ្ឌ១.លក្ខណៈពិសេសនៃកិច្ចសន្យាការងារ ....... 120

១. កិច្ចសន្យាការងារមានលក្ខណៈជាកិច្ចសន្យាមូលា ........................................ 121
២. កិច្ចសន្យាការងារមានលក្ខណៈជាកិច្ចសន្យាអញ្ញមញ្ញ .................................... 121
៣. កិច្ចសន្យាការងារមានលក្ខណៈជាកិច្ចសន្យាប្រតិបត្តិបន្ត ................................122
៤. កិច្ចសន្យាការងារមានលក្ខណៈជាប្រភេទកិច្ចសន្យារាប់អានបុគ្គល....................122
៥. កិច្ចសន្យាការងារមានលក្ខណៈជាកិច្ចសន្យាដែលប៉ះពាល់ទៅលើសិទ្ធិបុគ្គល ......122
៦. កិច្ចសន្យាការងារមានលក្ខណៈជាកិច្ចសន្យាសញ្ញកម្ម ..................................123
កថាខណ្ឌ២. ប្រភេទនៃកិច្ចសន្យាការងារ .......................................................123
១. កិច្ចសន្យាកាងារមានថិរវេលាកំណត់ .........................................................123
១.១ កិច្ចសន្យាការងារមានថិរវេលាពិតប្រាកដ .................................................124
១.២. កិច្ចសន្យាការងារមានថិរវេលាមិនពិតប្រាកដ ...........................................124
២. កិច្ចសន្យាការងារគ្មានគំណាត់ថិរវេលា.........................................................124
កថាខណ្ឌ៣. អំពីការទទួលខុសត្រូវនៃកិច្ចសន្យាការងារ ....................................125
១. អំពីការទទួលខុសត្រូវរបស់និយោជកចំពោះលក្ខខណ្ឌទូទៅនៃការងារ...............130
១.១. ទំនួលខុសត្រូវនិយោជកចំពោះលក្ខខណ្ឌទូទៅនៃកិច្ចសន្យាការងារ............... 131
១.១.១. ទំនួលខុសត្រូវរបស់និយោជកចំពោះការកំណត់ប្រាក់ឈ្នួល.....................132
១.១.២. ទំនួលខុសត្រូវនិយោជកចំពោះប្រាក់ឈ្នួលអតិប្បរមាត្រូវជានា.................133
១.១.៣. ទំនួលខុសត្រូវនិយោជិតចំពោះការធានានិងឯកសិទ្ធិនៃប្រាក់ឈ្នួល ដែលនៅជំពាក់....................................................................................................134
១.១.៤. ទំនួលខុសត្រូវនិយោជកចំពោះការកាត់ប្រាក់ឈ្នួល ..............................134
១.១.៥. ទំនួលខុសត្រូវរបស់និយោជកចំពោះប្រាក់ធនានុគ្រោះ ...........................135

១.១.៦. ទំនួលខុសត្រូវនិយោជកចំពោះថិរវេលាធ្វើការ ថិរវេលាប្រចាំថ្ងៃ និងប្រចាំសប្ដាហ៍ ........ 136
២. ការទទួលខុសត្រូវរបស់និយោជកចំពោះលក្ខខណ្ឌដោយឡែកនៃការងារ ........ 136
២.១. ទំនួលខុសត្រូវនិយោជកចំពោះថិរវេលាធ្វើការ ........ 137
២. ២.ទំនួលខុសត្រូវរបស់និយោជកចំពោះភាគឈ្នួលនៃវត្ថុ ........ 138
២.៣. ទំនួលខុសត្រូវនិយោជកចំពោះការផ្ដល់វត្ថុឲ្យសម្រាប់គ្រួសារ ........ 139
២. ៤. ទំនួលខុសត្រូវនិយោជកចំពោះគេហដ្ឋាន និងប្រាក់បំណាច់ ........ 141
២.៥. ទំនួលខុសត្រូវនិយោជកចំពោះការផ្គត់ផ្គង់ទឹកស្អាត ........ 142
២.៦. ទំនួលខុសត្រូវរបស់និយោជកចំពោះការផ្គត់ផ្គង់ភស្តុភារ ........ 143
២.៧. ទំនួលខុសត្រូវនិយោជកចំពោះការផ្គត់ផ្គង់បង្គន់អនាម័យ ........ 143
២.៨. ទំនួលខុសត្រូវនិយោជកចំពោះមរណៈភាពនិងការរំលាយ សាកសពរបស់កម្មករនិយោជិត ........ 143
២.៩. ទំនួលខុសត្រូវនិយោជកចំពោះកន្លែងផ្ញើក្មេង ........ 144
២.១០.ទំនួលខុសត្រូវនិយោជកចំពោះសាលារៀន ........ 144
កថាខណ្ឌ៤. សិក្សាអំពីកិច្ចសន្យាការងារហ្វឹកហ្វឺនកូនជាង ........ 145
១. របបគតិយុត្តនៃកិច្ចសន្យាហ្វឹកហ្វឺនកូនជាង ........ 146
១.១. លក្ខខណ្ឌសុពលភាពនៃការបង្កើតកិច្ចសន្យាហ្វឹកហ្វឺនកូនជាង ........ 146
១.២. ភាគីនៃកិច្ចសន្យាហ្វឹកហ្វឺនកូនជាង ........ 147
១.៣ កាតព្វកិច្ចរបស់គ្រូទទួលភារៈហ្វឹកហ្វឺនកូនជាង ........ 149
១.៤. សិទ្ធិនិងកាតព្វកិច្ចរបស់កូនជាងចំពោះកិច្ចសន្យាហ្វឹកហ្វឺនកូនជាង ........ 150

១.៥. ការរំលាយកិច្ចសន្យាហ្វឹកហ្វឺនកូនជាង ........ 150
២. កាតព្វកិច្ចនិយោជកចំពោះកិច្ចសន្យាហ្វឹកហ្វឺនកូនជាង ........ 152
២.១. កាតព្វកិច្ចនិយោជកចំពោះក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ........ 152
២.២. ការត្រួតពិនិត្យការហ្វឹកហ្វឺនកូនជាង ........ 153
មេរៀនទី៤៖ ភតិសន្យា ........ 154
ផ្នែកទីមួយ៖ លក្ខណៈនៃភតិសន្យា ........ 158
កថាខណ្ឌ១៖ ភតិសន្យាគឺជាកិច្ចសន្យាកើតឡើងពីការព្រមព្រៀង ........ 158
១. ការបង្កើត និង ភស្តុតាងនៃកិច្ចសន្យា ........ 158
២. ការចុះកិច្ចសន្យា ........ 160
២.១. សមត្ថភាពគូភាគី ........ 160
២.២. ករណីទ្រព្យរួម ........ 161
២.៣. ករណីវត្ថុអ្នកដទៃ ........ 161
កថាខណ្ឌ២៖ ភតិសន្យាគឺជាកិច្ចសន្យាមូលា ........ 161
កថាខណ្ឌ៣៖ ភតិសន្យាជាកិច្ចសន្យាអនុវត្តបន្តបន្ទាប់ ........ 162
កថាខណ្ឌ៤៖ ភតិសន្យាគឺជាកិច្ចសន្យាអញ្ញមញ្ញ ........ 163
១. ករណីយកិច្ចរបស់ភតិបតី ........ 164
១.១. ករណីយកិច្ចប្រគល់វត្ថុ ........ 164
១.២. ករណីយកិច្ចធានា ........ 167
២. ស្ថានភាពភតិកៈ ........ 169
២.១. ការគ្រប់គ្រងវត្ថុដោយសុចរិត ........ 169

២.២. ការខូចខាត ........................................................................................ 171

២.៣. ការបង់ថ្លៃឈ្នួលភតិកៈ ..................................................................................172

៣. ការមិនអនុវត្តករណីយកិច្ចក្នុងភតិសន្យា ....................................................173

៤. ឧបាទេសកម្មភាគីនៃកិច្ចសន្យា ..................................................................173

ផ្នែកទី២៖ ភតិសន្យាពិសេស .............................................................................175

កថាខណ្ឌ១៖ កិច្ចសន្យាជួលបន្ទប់ស្នាក់នៅកម្មករ សិស្ស និស្សិត ..........................175

១. វិធានគ្រប់គ្រងភតិសន្យាស្នាក់នៅ ..............................................................176

១.១ លក្ខខណ្ឌទាក់ទងនឹងគូភាគី ......................................................................176

១.២. លក្ខខណ្ឌទាក់ទងនឹងវត្ថុ ...........................................................................180

១.៣.ថេរៈវេលានៃភតិសន្យា ............................................................................... 181

១.៤. លក្ខខណ្ឌតតាំង ........................................................................................182

២. សិទ្ធិ និង ករណីយកិច្ចរបស់អ្នកជំនាញ និង កម្មករ សិស្ស និស្សិត ..................183

២.១. ការប្រគល់វត្ថុ និង ការបង់ថ្លៃឈ្នួល ...........................................................184

២.២. ករណីយកិច្ចគ្រប់គ្រងវត្ថុ ថែរក្សាវត្ថុជួល និង សណ្តាប់ធ្នាប់ ........................185

៣. ការរំលាយកិច្ចសន្យាជួលបន្ទប់ស្នាក់នៅ ......................................................187

៣.១. មូលហេតុនៃការរំលាយកិច្ចសន្យាជួលបន្ទប់ស្នាក់នៅ ..................................188

៣.២. អានុភាពនៃការរំលាយកិច្ចសន្យាជួលបន្ទប់ស្នាក់នៅកម្មករ សិស្ស និស្សិត ..... 191

កថាខណ្ឌ២៖ កិច្ចសន្យាជួលរយៈពេលវែង ឬ សិទ្ធិជួលអចិន្ត្រៃយ៍ ........................193

១. លក្ខខណ្ឌសុពលភាពនៃសិទ្ធិជួលអចិន្ត្រៃយ៍ ................................................194

១.១. វត្ថុនៃសិទ្ធិជួលអចិន្ត្រៃយ៍ ............................................................................194

១.២. រយៈពេលនៃសិទ្ធិជួលអចិន្ត្រៃយ៍ ........ 195
១.៣. ភស្តុតាងបញ្ជាក់អត្ថិភាពនៃសិទ្ធិជួលអចិន្ត្រៃយ៍ ........ 197
១.៤. អត្ថិភាពនៃសិទ្ធិតតាំងជាមួយតតិយជន ........ 198
២. អានុភាពនៃសិទ្ធិជួលអចិន្ត្រៃយ៍ ........ 200
២.១. ការផ្ទេរការកាន់កាប់ និងសិទ្ធិកម្មសិទ្ធិ ........ 200
២.២. ការបង់ថ្លៃឈ្នួល ........ 201
២.៣. អនុប្បទានសិទ្ធិជួលអចិន្ត្រៃយ៍ ........ 203
២.៤. ប្រាតិភោគសិទ្ធិជួលអចិន្ត្រៃយ៍ ........ 205
៣. ការបញ្ចប់សិទ្ធិជួលអចិន្ត្រៃយ៍ ........ 207
៣.១. មូលហេតុនៃការបញ្ចប់សិទ្ធិជួលអចិន្ត្រៃយ៍ ........ 208
៣.២. អានុភាពនៃការបញ្ចប់សិទ្ធិជួលអចិន្ត្រៃយ៍ ........ 212
មេរៀនទី៥ ៖ កិច្ចសន្យាម៉ៅការ ........ 214
កថាខណ្ឌ១៖ ចំណាត់ថ្នាក់កិច្ចសន្យាម៉ៅការ ........ 216
១. កាតព្វកិច្ចឲ្យធ្វើ ........ 216
១.១. កិច្ចសន្យាម៉ៅការ និង ភតិសន្យា ........ 217
១.២. កិច្ចសន្យាម៉ៅការ និង កិច្ចសន្យាបញ្ញើ ........ 218
១.៣. កិច្ចសន្យាទិញលក់ និង កិច្ចសន្យាម៉ៅការ ........ 219
២. កាតព្វកិច្ចឲ្យធ្វើកិច្ចសម្ភារៈ ........ 223
២.១. ការបែងចែករវាងកិច្ចសន្យាម៉ៅការ និង អាណ្ណត្តិ ........ 223
២.២. ការបញ្ចូលគ្នារវាងកិច្ចសន្យាម៉ៅការ និង អាណ្ណត្តិ ........ 224

៣. កាតព្វកិច្ចឲ្យធ្វើកិច្ចសម្ភារៈដោយគ្មានចំណងអធិនភាព ..............................225

កថាខណ្ឌ២៖ ការកកើតកិច្ចសន្យាម៉ៅការ ....................................................226

១. ជំនួបឆន្ទៈគូភាគី ...........................................................................226

២. ការកំណត់តម្លៃ ..............................................................................228

២.១. តម្លៃមិនអាចកំណត់បាន .................................................................228

២.២. របៀបនៃការកំណត់តម្លៃ .................................................................230

កថាខណ្ឌ៣៖ អានុភាពនៃកិច្ចសន្យាម៉ៅការ ...................................................231

១. ករណីយកិច្ចគូភាគី ..........................................................................231

១.១. ករណីយកិច្ចរបស់អ្នកម៉ៅការ .............................................................231

១.២. ករណីយកិច្ចរបស់ម្ចាស់ការ ................................................................236

២. ហានិភ័យក្នុងកិច្ចសន្យាម៉ៅការ .............................................................238

៣. ការអនុវត្តកិច្ចសន្យាដោយអ្នកម៉ៅការបន្ត ..................................................239

កថាខណ្ឌ៤៖ ការបញ្ចប់កិច្ចសន្យាម៉ៅការ ......................................................240

១. មូលហេតុនៃការបញ្ចប់កិច្ចសន្យាម៉ៅការ ...................................................240

១.១. កំហុសរបស់អ្នកមៅការ ...................................................................241

១.២. ការរំលោយដោយគ្មានមូលហេតុរបស់ម្ចាស់ការ .........................................241

២. អានុភាពនៃការបញ្ចប់កិច្ចសន្យាម៉ៅការ ....................................................242

មេរៀនទី៦៖ កិច្ចសន្យាដឹកជញ្ជូន ...............................................................245

កថាខណ្ឌ១៖ ចំណាត់ថ្នាក់កិច្ចសន្យាដឹកជញ្ជូន ...............................................246

១. កិច្ចសន្យាអញ្ញមញ្ញ កិច្ចសន្យាមូលា .........................................................246

២. កិច្ចពាណិជ្ជកម្ម និង កិច្ចចម្រុះ ....................................................................247
៣. កិច្ចសន្យាម៉ៅការពិសេស ...........................................................................248
៤. ការបែងចែងភាពខុសគ្នារវាងកិច្ចសន្យាដឹកជញ្ជូន និង កិច្ចសន្យាដទៃទៀត ........249
៤.១. កិច្ចសន្យាម៉ៅការទូទៅ ............................................................................249
៤.២. កិច្ចសន្យាបញ្ញើ ......................................................................................250
៤.៣. ភតិសន្យា ...............................................................................................250
៤.៤. អន្តរការី ..................................................................................................251
កថាខណ្ឌ២៖ កិច្ចសន្យាដឹកជញ្ជូនទំនិញ ........................................................252
១. លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាដឹកជញ្ជូនទំនិញ .........................................252
១.១. ភាគីនៃកិច្ចសន្យា ....................................................................................253
១.២. ឯកសារដឹកជញ្ជូន ...................................................................................254
១.៣. តម្លៃ .........................................................................................................255
២. អានុភាពនៃកិច្ចសន្យាដឹកជញ្ជូនទំនិញ .........................................................257
២.១. នីតិវិធីក្នុងដឹកជញ្ជូន ...............................................................................257
២.២. ទំនួលខុសត្រូវរបស់អ្នកដឹកជញ្ជូន .............................................................260
កថាខណ្ឌ៣៖ កិច្ចសន្យាដឹកជញ្ជូនអ្នកដំណើរ ...................................................263
១. ការទទួលខុសត្រូវអ្នកដឹកជញ្ជូន ..................................................................264
១.១. ករណីយកិច្ចសុវត្ថិភាពអ្នកដំណើរ ..............................................................264
១.២. ករណីយកិច្ចដឹកជញ្ជូនឲ្យទាន់ពេលវេលា ...................................................265
១.៣. អាជ្ញាយុកាលនៃការទាមទារសំណងព្យសនកម្ម ...........................................266

២. ការរួចផុតពីការទទួលខុសត្រូវ ....................................................................267
២.១. ករណីប្រធានសក្តិ .........................................................................................267
២.២. កំហុសអ្នកដំណើរ .........................................................................................268
មេរៀនទី៧៖ អាណ្ណត្តិ ..........................................................................................269
កថាខណ្ឌ១៖ លក្ខណៈទូទៅនៃអាណត្តិ ..........................................................272
១. ការប្រព្រឹត្តទៅនៃការតំណាងសម្រាប់ការចុះកិច្ចគតិយុត្ត ..................................273
២. ការបង្កើតកិច្ចសន្យា .......................................................................................275
២.១. ឆន្ទៈគូភាគី .....................................................................................................275
២.២. សមត្ថភាព .......................................................................................................279
កថាខណ្ឌ២៖ អានុភាពនៃអាណត្តិ ....................................................................281
១. ទំនាក់ទំនងរវាងអាណត្តិទាយក និង អាណត្តិគាហក .......................................282
១.១. ករណីយកិច្ចរបស់អាណត្តិគាហក ....................................................................282
១.២. ករណីយកិច្ចរបស់អាណត្តិទាយក .....................................................................287
២. អានុភាពនៃអាណត្តិចំពោះទំនាក់ទំនងរវាងគូភាគី និង តតិយជន ......................288
២.១. ទំនាក់ទំនងរវាង អាណត្តិទាយក និង តតិយជន ...........................................289
២. ទំនាក់ទំនងរវាងអាណត្តិគាហក និង តតិយជន ..............................................290
៣. ការបញ្ចប់អាណត្តិ ...........................................................................................291
៣.១. ការបញ្ចប់អាណត្តិដោយស្វ័យប្រវត្តិ ..............................................................291
៣.២. ការបញ្ចប់អាណត្តិដោយឯកតោភាគី ..............................................................292

# សេចក្តីផ្តើម

តើមុខវិជ្ជានីតិកិច្ចសន្យាពិសេសសិក្សាអំពីអ្វី? និងបានផ្តល់នូវគុណប្រយោជន៍អ្វីខ្លះសម្រាប់និស្សិត ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវ? ជាទូទៅការសិក្សាមុខវិជ្ជានីតិកិច្ចសន្យាពិសេស ជាបឋមនិស្សិត ឬអ្នកសិក្សា ស្រាវជ្រាវអាចកំណត់នូវចំណុចស្វែងយល់ថា នីតិ និងកិច្ចសន្យាមានខ្លឹមសារយ៉ាងដូចម្តេច?។ **នីតិ** សំដៅលើសំណុំវិធាន ឬជាបណ្តុំនៃលិខិតបទដ្ឋានគតិយុត្ត ដែលបង្កើតឡើងក្នុងគោលដៅដើម្បីសម្របសម្រួលទំនាក់ទំនងសង្គម និងអត្ថន័យពាក្យ **កិច្ចសន្យា** សំដៅដល់ការព្រមព្រៀងរវាងបុគ្គលពីរ ឬ ច្រើននាក់ ដែលតាមរយៈកិច្ចព្រមព្រៀង ភាគីអាចកំណត់គោលដៅនៃការបង្ហាញឆន្ទៈថា ដើម្បីបង្កើត កែប្រែ រំលត់សិទ្ធិ និងករណីយកិច្ច មួយចំនួនទាក់ទិននឹងគូភាគី។

យោងតាមអត្ថន័យខាងលើនេះ អាចសន្និដ្ឋានបានថា កិច្ចសន្យា ជាច្បាប់របស់គូភាគី ប៉ុន្តែបញ្ហាចោទថា ហេតុអ្វីបានជាកំណត់ថា **កិច្ចសន្យាជាច្បាប់របស់គូភាគី** តាមការបកស្រាយខ្លឹមសារ ដោយផ្អែកលើវត្ថុបំណងរបស់ភាគីក្នុងការបង្កើតកិច្ចសន្យា មានន័យថា កិច្ចសន្យា ត្រូវបានបង្កើតឡើងក្នុងគោលបំណងមួយច្បាស់លាស់ តាមរយៈនោះភាគីអាចបង្ហាញពីតម្រូវការរបស់ភាគីចំពោះការបង្កើតកិច្ចសន្យា និងអាចស្តែងឡើងក្រោមទម្រង់ ដូចជាការកំណត់នូវលក្ខខណ្ឌដែលភាគីចង់បាន ឬអាចសន្និដ្ឋថា ការបង្កើតកិច្ចសន្យា គឺដើម្បីសម្របសម្រួល ទំនាក់ទំនងភាគីនៅក្នុងជីវភាពឯកជន។

បន្ថែមពីនេះការកំណត់អំពីវត្ថុបំណង ឬតម្រូវការច្បាស់លាស់របស់ភាគីនៃកិច្ចសន្យា ក៏បានបង្ហាញឲ្យឃើញនូវចំណុចផ្សេងទៀតដែលអាចធ្វើការសិក្សាវិភាគរួមមានដូចជា នៅពេលបង្កើតកិច្ចសន្យា ភាគីបានបង្ហាញនូវអ្វី

ដែលភាគីចង់បានពិតប្រាកដដូចជា ភាគីបានកំណត់អំពីលក្ខខណ្ឌនៃការការពារផលប្រយោជន៍នៅក្នុងកិច្ចសន្យា មានន័យថា ក្រៅពីការទទួលខុសត្រូវរបស់ភាគីនៃកិច្ចសន្យា គឺការបង្កើតកិច្ចសន្យាត្រូវធ្វើឡើង ក្នុងគោលដៅដើម្បីការពារផលប្រយោជន៍ ឬក៏ជាការធានាឲ្យបាននូវតុល្យភាពនៃផលប្រយោជន៍របស់ភាគី និងការពារចំពោះការបំពានសិទ្ធិបុគ្គល ហើយករណីមានការបំពានកើតឡើង ភាគីក៏មានសិទ្ធិក្នុងការទាមទារឲ្យទទួលបាននូវការទទួលខុសត្រូវដែលបច្ចុប្បន្នបញ្ញត្តិនៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ បានសន្មតថាជាប្រភេទនៃការសង្គ្រោះចំពោះការបំពានកិច្ចសន្យា។

ទស្សនៈជុំវិញទាំងអស់នេះអាចកំណត់បានថា ការបង្កើតកិច្ចសន្យាដែលជាវត្ថុបំណងភាគី គឺតម្រូវឲ្យស្របទៅនឹងខ្លឹមសារក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ និងវិធានពិសេសដ៏ទៃផ្សេងទៀត ដែលសំដៅដល់បណ្តុំវិធាន ឬបណ្តុំនៃលិខិតបទដ្ឋានគតិយុត្ត ដែលបានដើរតួរនាទីសំខាន់ ក្នុងការកំណត់អំពីប្រភេទនៃទំនាក់ទំនងគតិយុត្តរបស់ភាគី ដោយប្រែប្រួលទៅតាមប្រភេទនិងលក្ខណៈពិសេសនៃកិច្ចសន្យានីមួយៗ និងអាចកំណត់បានថា ជាវិធានរួមដែលមានអានុភាពអនុវត្តនៅក្នុងទំនាក់ទំនងនៃជីវភាពឯកជន។ បន្ថែមពីនេះនិស្សិត ឬអ្នកសិក្សាស្រាវជ្រាវ ក៏អាចធ្វើចំណាត់ថ្នាក់នៃទំនាក់ទំនងគតិយុត្តនោះថា គឺជាវិធាននៃនីតិឯកជន ឬជាវិធាននៃនីតិសាធារណៈ។ ប៉ុន្តែការបកស្រាយខាងលើ បានបង្ហាញឲ្យឃើញថាការបង្កើតកិច្ចសន្យា គឺគូភាគីមានសិទ្ធិសេរីភាពពេញលេញក្នុងការសម្រេចចិត្ត ដើម្បីបង្កើតកិច្ចសន្យា ឬសម្រេចចិត្តបង្កើតទំនាក់ទំនងគតិយុត្ត ដែលទំនាក់ទំនងទាំងអស់នោះត្រូវតែស្របទៅនឹងគោលការណ៍នៃវិធានរួមផ្នែកឯកជន ឬស្របទៅនឹងបញ្ញត្តិនៃច្បាប់សារធាតុ។

ជារួមដើម្បីឲ្យនិស្សិត ឬអ្នកសិក្សាស្រាវជ្រាវអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការសិក្សាស្វែងយល់ឲ្យកាន់តែស៊ីជម្រៅលើលក្ខណៈពិសេស និងប្រភេទផ្សេងៗនៃកិច្ចសន្យានីមួយៗ សាកលវិទ្យាល័យ បានតម្រូវឲ្យនិស្សិតសិក្សាមុខវិជ្ជានីតិកិច្ចសន្យាពិសេស។

**មុខវិជ្ជានីតិកិច្ចសន្យាពិសេស** នឹងធ្វើការសិក្សាអំពីរបបគតិយុត្តនៃកិច្ចសន្យាពិសេសនីមួយៗ ដោយផ្អែកតាមច្បាប់សារជាតុ ឬក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧។ ក្នុងនោះនិស្សិត ឬអ្នកសិក្សាស្រាវជ្រាវអាចស្វែងយល់ អំពីប្រភេទផ្សេងៗ និងលក្ខណៈពិសេសនៃកិច្ចសន្យាពិសេសនីមួយៗ រួមមាន ការលក់ទិញ ការដូរ ប្រទានកម្ម ការខ្ចីបរិភោគ ភតិសន្យា ការខ្ចីប្រើ អាណត្តិ កិច្ចសន្យាម៉ៅការ កិច្ចសន្យាការងារ បញ្ញើ កិច្ចសន្យាក្រុមហ៊ុន កិច្ចសន្យាធនលាភសាមយិកមួយជីវិត ការធានាលើសិទ្ធិលើការបញ្ចាំ និងហ៊ីប៉ូតែក។

បន្ថែមពីនេះមុខវិជ្ជានីតិកិច្ចសន្យាពិសេស ក៏មានបំណងឲ្យនិស្សិតយល់ដឹងច្បាស់ថា តើដូចម្ដេចជារបបគតិយុត្តនៃការបង្កើតកិច្ចសន្យាពិសេសនីមួយៗ ដោយធ្វើការសិក្សាប្រៀបធៀបកិច្ចសន្យាទៅតាមលក្ខណៈពិសេស និងប្រភេទផ្សេងៗនៃកិច្ចសន្យា ជាពិសេសគឺកាតព្វកិច្ចនិងការទទួលខុសត្រូវរបស់ភាគីនៃកិច្ចសន្យាពិសេសនីមួយៗ ដោយផ្អែកតាមខ្លឹមសារច្បាប់សារជាតុ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដែលបំពេញបន្ថែមទៅលើទំនាក់ទំនងនៃកិច្ចសន្យាផ្នែកឯកជន។ លើសពីនេះនិស្សិតក៏អាចស្វែងយល់បន្ថែមអំពីបញ្ហាគតិយុត្តចំបងៗ ដែលមានចោទជាទ្រឹស្ដី រួមមានការបកស្រាយច្បាប់ករណីសិក្សាជុំវិញការអនុវត្តជាក់ស្ដែងរួមមាន លទ្ធផលនៃដំណោះស្រាយដោយផ្អែកតាមអត្ថន័យ និងគោលគំនិតនៃវិធានច្បាប់សារជាតុ ឬជាការកំណត់នូវវិធីសាស្ត្រមូលដ្ឋានក្នុងការបកស្រាយគតិយុត្ត ដោយបានបង្ហាញនូវ

គោលគំនិតសំខាន់ៗនៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ តាមរយៈការសិក្សាជុំវិញទំនាក់ទំនងនៃកិច្ចសន្យា លក្ខណៈពិសេស ប្រភេទកិច្ចសន្យា និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដ៏ទៃផ្សេងទៀត ដែលអាចកំណត់បានថាជាវិធានពិសេសនៃកិច្ចសន្យា។

ជាចុងក្រោយ និស្សិតអាចទទួលបានសមត្ថភាពមូលដ្ឋានក្នុងការផ្តល់ប្រឹក្សាយោបល់ជុំវិញបញ្ហាប្រឈមមួយចំនួន ដែលទាក់ទិនទៅនឹងកិច្ចសន្យានីមួយៗ ឬអាចកំណត់លទ្ធភាព ឬផ្តល់ជាមធ្យោបាយ ដែលបង្ហាញឲ្យឃើញនូវនីតិវិធីមូលដ្ឋាននៃការដោះស្រាយនូវបញ្ហាគតិយុត្តចំបងៗ ជុំវិញកិច្ចសន្យាពិសេសនីមួយៗ ជាពិសេសគោលដៅចំបងដែលសាកលវិទ្យាល័យចង់បាន គឺនិស្សិតអាចមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរៀបរៀង ឬតាក់តែងកិច្ចសន្យាបានដោយប្រែប្រួលទៅតាមប្រភេទនៃកិច្ចសន្យាពិសេសនីមួយៗ។

## ១. ការសិក្សាអំពីនិយមន័យ និងទស្សនៈជុំវិញការបង្កើតកិច្ចសន្យា

ជាទូទៅ បើធ្វើការសិក្សាជុំវិញទស្សនៈនៃការបង្កើតកិច្ចសន្យា ក្នុងនោះយើងអាចធ្វើការចោទសួរថាតើ ដូចម្តេចដែលហៅថាកិច្ចសន្យា? និងកិច្ចសន្យាត្រូវបង្កើតក្នុងគោលដៅបែបណាដើម្បីអ្វី? តើកិច្ចសន្យាការបង្កើតមានទម្រង់យ៉ាងដូចម្តេច?បើពិនិត្យទៅលើនិយមន័យនៃកិច្ចសន្យា ដោយផ្អែកលើខ្លឹមសារមាត្រានៃក្រឹត្យច្បាប់លេខ៣៨ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវនៅក្រៅកិច្ចសន្យា និងនិយមន័យនៃកិច្ចសន្យាតាមខ្លឹមសារច្បាប់សារជាតុ ឬបញ្ញត្តិនៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ កិច្ចសន្យា មានន័យថា ជាការព្រម

ព្រៀង រវាងបុគ្គលពីរ ឬច្រើន ដើម្បីបង្កើតកែប្រែ ឬរំលត់សិទ្ធិ និងកាតព្វកិច្ច មួយចំនួនទាក់ទិននឹងគូភាគី និងអាចធ្វើការសន្មតថាជាច្បាប់របស់គូភាគី។

បន្ថែមពីនេះតាមរយៈខ្លឹមសារ ឬនិយមន័យខាងលើ ថាតើអ្វីដែលអាចធ្វើការកត់សម្គាល់បាននៅទីនេះ គឺពាក្យដែលបញ្ជាក់អត្ថន័យថា ជាការព្រមព្រៀងរវាងភាគីមានន័យយ៉ាងដូចម្ដេច? ជាទូទៅនៅក្នុងអត្ថន័យនៃការបង្កើតកិច្ចសន្យា **ការព្រមព្រៀង** គឺសំដៅដល់ការព្រមព្រៀងដែលគ្មានវិការៈ ក្នុងនោះអាចសន្មតបានថា ការបង្កើតការព្រមព្រៀង គឺទាមទារឲ្យមានការចូលរួមរវាងបុគ្គលនៃទំនាក់ទំនងចាប់ពី២នាក់ ចំណុចដែលលើកឡើងនេះ អាចជាបញ្ហាចោទ ថាតើការបង្កើតកិច្ចសន្យាអាចធ្វើឡើងដោយមានការចូលរួមពីឆន្ទៈរបស់បុគ្គលតែម្នាក់ឬទេ?។ ជាទូទៅកិច្ចសន្យាបើយោងតាមនិយមន័យខាងលើបានបញ្ជាក់ឲ្យឃើញថា **កិច្ចសន្យា** ការបង្កើតអាចសន្មតទាមទារឲ្យមានការចូលរួមរវាងបុគ្គលចាប់ពី២នាក់ ក្នុងន័យនេះគេអាចសន្មតបានថា គូភាគីបានបង្ហាញឆន្ទៈថាយល់ព្រមក្នុងការបង្កើតកិច្ចសន្យា ឬក្នុងពេលព្រមគ្នានោះ មានការជួបគ្នា រវាងសំណើ និងស្វីការ និងអាចកំណត់បានម្យ៉ាងទៀតថា កិច្ចសន្យាគឺជាការបង្ហាញឆន្ទៈរួម ដើម្បីបង្កើតនូវទំនាក់ទំនងគតិយុត្ត ដែលជាប្រភពនៃការបង្កើតសិទ្ធិ និងករណីយកិច្ច។

ជារួមការបកស្រាយនិយមន័យ និងទស្សនៈជុំវិញការបង្កើតកិច្ចសន្យា អាចសន្មតបាននូវលក្ខខណ្ឌមួយចំនួនជុំវិញការបង្កើតកិច្ចសន្យា ដូចជាការបង្ហាញឆន្ទៈចូលរួមរវាងបុគ្គលពីរ ឬច្រើន និងភាគីមានវត្ថុបំណង ច្បាស់លាស់ ឬជាក់លាក់ដោយបង្ហាញអំពីអ្វីៗ ដែលភាគីចង់បាន ឬបង្ហាញអំពីតម្រូវការនៃការបង្កើតទំនាក់ទំនងគតិយុត្តរួមមាន ការកំណត់អំពីប្រភេទផ្សេងៗនៃទំនាក់ទំនងដែលភាគីចង់បាននៅពេលបង្កើតកិច្ចសន្យា និងទំនាក់ទំនងទាំងអស់

នោះអាចកំណត់អំពីទម្រង់ និងលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាដោយប្រែប្រួលទៅតាមប្រភេទផ្សេងៗ និងលក្ខណៈពិសេសនៃកិច្ចសន្យានីមួយៗ។

## ២. ការសិក្សាពីកម្មវត្ថុ និងទស្សនៈជុំវិញការបង្កើតកិច្ចសន្យា

តើអ្វីជាកម្មវត្ថុដែលភាគីចង់បាននៅពេលបង្កើតកិច្ចសន្យា? ជាទូទៅកម្មវត្ថុនៃកិច្ចសន្យា ភាគីអាចធ្វើការសន្មតថាជាអ្វីៗ ដែលមាននៅពេលបង្កើតកិច្ចសន្យា កម្មវត្ថុ អាចជាវត្ថុដែលភាគីចង់បាន ឬកម្មវត្ថុនៃកិច្ចសន្យាអាចកំណត់បានថា ជាកម្មវត្ថុនៃកាតព្វកិច្ច ដែលជាតម្រូវការរបស់ភាគីនៃទំនាក់ទំនងគតិយុត្ត និងកម្មវត្ថុតម្រូវឲ្យកំណត់នៅក្នុងកិច្ចសន្យា កម្មវត្ថុត្រូវតែអាចកំណត់បាន កម្មវត្ថុត្រូវតែជាក់លាក់ ឬច្បាស់លាស់ និងត្រូវតែមានហើយស្របទៅតាមច្បាប់និងទំនៀមទម្លាប់ដ៏ល្អប្រពៃ ដែលមិនបង្ករផលប៉ះពាល់ទៅដល់របៀបរៀបរយ និងសណ្តាប់ធ្នាប់សាធារណៈ នៅពេលភាគីបានព្រមព្រៀងកំណត់កម្មវត្ថុក្នុងការបង្កើតកិច្ចសន្យា។

តើមូលហេតុអ្វី?បានកម្មវត្ថុនៃកិច្ចសន្យាត្រូវតែមាន និងកម្មវត្ថុត្រូវតែកំណត់នៅពេលបង្កើតកិច្ចសន្យា បើយោងទៅលើតម្រូវការរបស់ភាគីនៃកិច្ចសន្យា និងការបង្ហាញឆន្ទៈដើម្បីបង្កើតទំនាក់ទំនងគតិយុត្តរបស់ភាគី គឺដើម្បីមានភាពងាយស្រួលក្នុងការកំណត់ថាមាន ការករកើតនូវកាតព្វកិច្ច ដែលជាប្រភពនៃសិទ្ធិ និងករណីកិច្ចនាពេលអនាគត ឬ អាចកំណត់បានថាការកំណត់អំពីកម្មវត្ថុ ដែលនូវផ្តល់ភាពងាយស្រួលដល់ភាគី ដើម្បីកំណត់អំពីប្រភេទទំនួលខុសត្រូវ។

## ២.១. កម្មវត្ថុត្រូវតែមាន

មូលហេតុអ្វីបានជាភាគីលើកឡើងថា កម្មវត្ថុត្រូវតែមាននៅពេលបង្កើតកិច្ចសន្យា? ពីព្រោះការបង្កើត កិច្ចសន្យាដោយគ្មានកម្មវត្ថុ គឺមិនអាចសម្រេចបានទេ។ ម្យ៉ាងវិញទៀតចំពោះទំនាក់ទំនងគតិយុត្តដែលកើតមាន គឺបានបង្ហាញអំពីតម្រូវការរបស់ភាគី និងអាចកំណត់ជាកម្មវត្ថុនៃកិច្ចសន្យាអាចជាវត្ថុ ឬជាប្រភេទផ្សេងៗនៃកាតព្វកិច្ច ដោយអាស្រ័យទៅតាមជម្រើសរបស់គូភាគីនៃកិច្ចសន្យា។

## ២.២. កម្មវត្ថុត្រូវតែកំណត់ ឬអាចកំណត់បាន

មូលហេតុអ្វីបានជាភាគីលើកឡើងថាកម្មវត្ថុត្រូវតែកំណត់នៅពេលបង្កើតកិច្ចសន្យា? ជាទូទៅការករកើតទំនាក់ទំនងគតិយុត្ត គឺជាប្រភពនៃការករកើតនូវកាតព្វកិច្ច និងភាគីនៃទំនាក់ទំនងមានសិទ្ធិទាមទារភាគីម្ខាងទៀតឲ្យបំពេញករណីយកិច្ចចំពោះខ្លួន ដូចនេះការទាមទារឲ្យកម្មវត្ថុត្រូវតែកំណត់ ឬអាចកំណត់បាន គឺជាមូលហេតុដែលផ្តល់សិទ្ធិសេរីភាពឲ្យភាគីក្នុងការជ្រើសរើសប្រភេទផ្សេងៗនៃកាតព្វកិច្ច មានន័យថា គឺគូភាគីមានលទ្ធភាពគ្រប់គ្រាន់ក្នុងការកំណត់អំពីទំហំនៃការប្រតិបត្តិកិច្ចសន្យាដែលត្រូវសម្រេចនាពេលអនាគត និងភាគីក៏អាចមានលទ្ធភាពកំណត់អំពីទំហំនៃការខូចខាតដែលអាចកើតមានដោយសារមូលហេតុផ្សេងៗ នាពេលអនាគត និងក៏ដូចជាការកំណត់អំពីទំនួលខុសត្រូវផ្សេងៗនៅក្នុងកិច្ចសន្យា។

## ២.៣. កម្មវត្ថុត្រូវតែជាក់លាក់ឬច្បាស់លាស់

មូលហេតុអ្វីបានជាភាគីលើកឡើងថា កម្មវត្ថុត្រូវតែជាក់លាក់ ឬច្បាស់លាស់នៅពេលបង្កើតកិច្ចសន្យា? កម្មវត្ថុត្រូវជាក់លាក់ ឬច្បាស់លាស់ ដោយសារ បើយោងតាមខ្លឹមសារនៃវិធានច្បាប់សារធាតុ បានកំណត់អំពីប្រភេទផ្សេងៗនៃកាតព្វកិច្ច ក្នុងនោះភាគី ផ្អែកតាមគោលការណ៍ស្វ័យភាពនៃឆន្ទៈសេរីរបស់បុគ្គលឯកជន ភាគីមានសិទ្ធិសេរីភាពពេញលេញក្នុងការកំណត់អំពីជម្រើសផ្សេងៗនៃកាតព្វកិច្ចដែលភាគីចង់បាន និងម្យ៉ាងទៀតការកំណត់អំពីកម្មវត្ថុជាក់លាក់ ឬច្បាស់លាស់ ជាផ្នែកមួយនៃការការពារផលប្រយោជន៍គូភាគីនៃទំនាក់ទំនង ឬគូភាគីនៃកិច្ចសន្យា ករណីមានការបំពាន ឬការមិនអនុវត្តកាតព្វកិច្ច ក្នុងនោះភាគីអាចមានភាពងាយស្រួលកំណត់ពីទំហំនៃការខូចខាត និងកំណត់ពីទំនួលខុសត្រូវភាគីនៃកិច្ចសន្យា។

## ២.៤. កម្មវត្ថុត្រូវតែស្របច្បាប់ និងទំនៀមទម្លាប់ល្អ

ករណីនេះគេអាចធ្វើការសិក្សាបែងចែកអំពី **កម្មវត្ថុត្រូវតែស្របច្បាប់ និងកម្មវត្ថុត្រូវតែស្របទៅនឹងទំនៀមទម្លាប់ល្អ។** ជាទូទៅទោះបីការបង្កើតកិច្ចសន្យាឯកជន បានផ្ដល់សិទ្ធិសេរីភាពឲ្យភាគីក្នុងការសម្រេចចិត្ត ដើម្បីបង្កើតទំនាក់ទំនង និងដោយផ្អែកលើគោលការណ៍ស្វ័យភាពនៃឆន្ទៈសេរីរបស់បុគ្គលឯកជនយ៉ាងណា គឺការបង្កើតកិច្ចសន្យា ត្រូវតែស្របទៅតាមការកម្រិត ឬទម្រង់និងលក្ខខណ្ឌដែលច្បាប់បានតម្រូវ ដែលការកំណត់បែបនេះ គឺដើម្បីហាមឃាត់កុំឲ្យ បុគ្គលប្រើប្រាស់សិទ្ធិសេរីភាពឯកជនរបស់ខ្លួនលើសព្រំដែនកំណត់ ឬដោយបំពានទៅលើសិទ្ធិបុគ្គលដ៏ទៃ ឬតាមរយៈកិច្ចសន្យា ភាគីអាចបង្ករភាពវឹកវរ ជ្រួលច្របល់ ឬភាពអានាធិបតេយ្យនៅក្នុងសង្គម។

បន្ថែមពីនេះ យោងតាមខ្លឹមសារនៃវិធានច្បាប់កម្ពុជា **ការកំណត់អំពីកម្មវត្ថុត្រូវតែស្របច្បាប់** គឺត្រូវតែអនុវត្តទៅលើគ្រប់ប្រភេទនៃកិច្ចសន្យាទាំងអស់ មានន័យថា ករណីកម្មវត្ថុនៃកិច្ចសន្យាជាវត្ថុ និងភាគីត្រូវកំណត់អំពីវត្ថុដែលជាកម្មវត្ថុនៅក្នុងកិច្ចសន្យា គឺកម្មវត្ថុត្រូវតែស្របច្បាប់ ឧទាហរណ៍ដូចជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញ ដែលហាមឃាត់ដាច់ខាតដូចជា ការជួញដូរថ្នាំញៀន ការជួញដូរអាវុធខុសច្បាប់ ឬការជួញដូរមនុស្សជាដើម។ បន្ថែមពីនេះករណីកម្មវត្ថុនៃកិច្ចសន្យាជាប្រភេទផ្សេងៗនៃកាតព្វកិច្ច ដូចជាកិច្ចសន្យាដែលមានការផ្តល់សេវាផ្សេងៗ គឺត្រូវតែជាសេវាស្របច្បាប់ ឧទាហរណ៍ដូចជាកិច្ចសន្យាការងារ ដែលជាការបំពេញបេសកកម្មការងារ ដោយភាគីមិនអាចបង្កើតកិច្ចសន្យា ដែលមានខ្លឹមសារ គឺជាការឃុបឃិតដើម្បីបង្ករការខូចខាត ឬបំពានទៅលើសិទ្ធិបុគ្គលផ្សេងទៀតទេ គឺខ្លឹមសារនៃកាតព្វកិច្ចទាំងអស់នេះទោះបីជាមានការព្រមព្រៀងរបស់គូរភាគីក៏ដោយ តែច្បាប់ក៏បានកំណត់ថាកម្មវត្ថុនៃកិច្ចសន្យាទាំងឡាយណាដែលផ្ទុយច្បាប់ ឬជាកម្មវត្ថុនៃកិច្ចសន្យាដែលមានខ្លឹមសារផ្ទុយច្បាប់ និងត្រូវធ្វើការហាមឃាត់ដាច់ខាត។

**ករណីកម្មវត្ថុកិច្ចសន្យាត្រូវស្របទៅនឹងទំនៀមទម្លាប់ល្អ** ស្របតាមខ្លឹមសារវិធាននៃច្បាប់កម្ពុជា ចំណុចនេះគេអាចសិក្សា អំពីទស្សនៈដែលសង្គមអាចទទួលយកបាន ថាមិនមានការបំពានទៅនឹងសិទ្ធិបុគ្គល ឧទាហរណ៍ ដូចជាការបង្កើតកិច្ចសន្យាការងារ ដែលតម្រូវឲ្យនិយោជិត ឬកម្មករនិយោជិតស្លៀកសំលៀកបំពាក់ហែលទឹកបម្រើការងារនៅក្នុងភោជនីយដ្ឋាន។ ករណីខាងលើនេះ គេសង្កេតឃើញថា លក្ខខណ្ឌដែលភាគីនិយោជក ឬថៅហ្វាយនាយបានកំណត់នៅក្នុងកិច្ចសន្យាការងារគឺមានប្រការដែលចែងអំពីការស្លៀកឯកសណ្ឋាន ដែលភាគីនិយោជកបានតម្រូវឲ្យភាគីនិយោជិត ស្លៀកសំលៀក

បំពាក់ហែលទឹកបម្រើការងារក្នុងភោជនីយដ្ឋាន ករណីខាងលើនេះ នៅក្នុងសង្គមកម្ពុជាបានមើលឃើញអំពី *ការស្លៀកសំលៀកបំពាក់ហែលទឹកមប្រើការងារក្នុងភោជនីយដ្ឋាន* បានគិតថាជាទង្វើខុសសីលធម៌ និងសង្គមកម្ពុជាបានគិតថាជាការបំពានទៅនឹងទំនៀមទម្លាប់ដ៏ល្អប្រពៃ។ ដូចនេះប្រការ ដែលកំណត់ក្នុងកិច្ចសន្យាការងារខាងលើ មិនអាចអនុវត្តបានទេ និងយោងតាមខ្លឹមសារនៃវិធានច្បាប់កម្ពុជា គឺបានបញ្ញត្តិអំពីគោលការណ៍ នៃការការពារផលប្រយោជន៍ដល់ភាគីដែលជាកូនថៅ ឬភាគីនិយោជិត និងអនុវត្តដូចគ្នាចំពោះបញ្ញត្តិនៃច្បាប់ការងារកម្ពុជា ដោយសម្រេចថា កិច្ចសន្យាការងារខាងលើនេះត្រូវចាត់ទុកជាមោឃៈ តែមោឃៈផ្នែកខ្លះដែលផ្ទុយទៅបញ្ញត្តិអនុវត្តដោយបង្ខំ និងមិនតម្រូវឲ្យមោឃភាពកិច្ចសន្យាទាំងស្រុងទេ។ ការកំណត់បែបនេះក្នុងគោលដៅដើម្បីការងារផលប្រយោជន៍ភាគីនិយោជិតដែលទទួលរងការបំពានពីភាគីថៅហ្វាយនាយ ឬនិយោជក។ ដូចនេះកិច្ចសន្យាការងារខាងលើ ត្រូវបានមោឃភាពចំពោះប្រការដែលកំណត់អំពី*ការស្លៀកសំលៀកបំពាក់ហែលទឹកមប្រើការងារក្នុងភោជនីយដ្ឋាន* ក្រៅពីនេះ គឺទទួលស្គាល់អានុភាព។

## ៣. ការសិក្សាពីកាតព្វកិច្ច និងទស្សនៈជុំវិញការបង្កើតកិច្ចសន្យា

ជាទូទៅមានចំណោទជាច្រើនកើតមាននៅជុំវិញទំនាក់ទំនង និងការបកស្រាយជុំវិញបង្កើតកិច្ចសន្យានិងកាតព្វកិច្ចក្នុងនោះរួមមាន ការចោទសួរថាអ្វីទៅជាកាតព្វកិច្ច? តើកាតព្វកិច្ចនិងត្រូវបានបង្កើតនៅពេលណា?តើមូលហេតុនិងលក្ខខណ្ឌណាខ្លះ ដែលគេអាចកំណត់បានថាកាតព្វកិច្ចត្រូវបានបង្កើត? កាតព្វកិច្ច និងកិច្ចសន្យាមានទំនាក់ទំនងដូចម្ដេច? តើកាតព្វកិច្ច

មានប៉ុន្មានប្រភេទអ្វីខ្លះ?និងករណីកាតព្វកិច្ចបានបង្កើត តើភាគីនៃកាតព្វកិច្ចមានទំនួលខុសត្រូវអ្វីខ្លះ?

**កាតព្វកិច្ច** យោងតាមអត្ថន័យមាត្រានៃក្រមរដ្ឋប្បវេណីកម្ពុជា បានកំណត់ថា គឺជាទង្វើនៃការបង្ហាញឆន្ទៈរបស់បុគ្គល ក្នុងគោលបំណងបង្កើតទំនាក់ទំនងគតិយុត្ត សំដៅលើទំនាក់ទំនងបុគ្គល ដែលមានអានុភាពបង្កើតសិទ្ធិ និងករណីកិច្ច។[1]ឧទាហរណ៍ដូចជា ទំនាក់ទំនងគតិយុត្ត ដែលកើតមានតាមរយៈកិច្ចសន្យាលក់ទិញ, កិច្ចសន្យាការងារ, កិច្ចសន្យាម៉ៅការសាងសង់ជាដើម។ បន្ថែមពីនេះចំពោះទំនាក់ទំនងរវាង កាតព្វកិច្ចនិងកិច្ចសន្យា គឺគេអាចសន្មតបានថា កាតព្វកិច្ចកើតចេញពីឆន្ទៈសេរីរបស់បុគ្គល ដែលស្តែងឡើងក្រោមទម្រង់ជាកិច្ចសន្យាដែលអាចកំណត់បានថា កាតព្វកិច្ច មានប្រភពមកពីកិច្ចសន្យា និងកាតព្វកិច្ច មានប្រភពមកពីទង្វើផ្សេងៗទៀតដែលអាចកើតឡើងពីទង្វើនៅក្រៅឆន្ទៈបុគ្គល។ មានន័យថា កាតព្វកិច្ច របស់បុគ្គលអាចកើតឡើងពីកិច្ចសន្យា និងអាចកើតមានតាមរយៈការគ្រប់គ្រងដោយការឈឺឆ្អាល, សេចក្តីចម្រើនឥតហេតុ និង កាតព្វកិច្ចដែលកើតឡើងតាមបញ្ញត្តិច្បាប់។[2]

## ៤. សញ្ញាណទូទៅនៃការបង្កើតកិច្ចសន្យា និងខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជា

ជាទូទៅកិច្ចសន្យា គឺសំដៅទៅលើការព្រមព្រៀងរវាងបុគ្គលពីរឬច្រើន ដែលបង្កើតឡើងក្នុងគោលដៅដើម្បី បង្កើត កែប្រែរំលត់សិទ្ធិ និង

[1]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា៣០៨ (តទៅហៅថា ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧)។

[2]ម.៣០៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

កាតព្វកិច្ចមួយចំនួនដែលទាក់ទិនទៅនឹងគូភាគី។ ក្នុងន័យខាងលើនេះ គឺបញ្ញត្តិនៃក្រមរដ្ឋប្បវេណីកម្ពុជាចង់បង្ហាញឲ្យឃើញថា កិច្ចសន្យាកើតពីឆន្ទៈសេរីរបស់បុគ្គលពីរ ឬច្រើន ដែលតាមរយៈកិច្ចព្រមព្រៀងនោះ ភាគីនៃកិច្ចសន្យាអាចមានគោលបំណងឬវត្ថុបំណងផ្សេងគ្នា ដើម្បីបំពេញតម្រូវការរៀងៗខ្លួន ដែលតាមរយៈទំនាក់ទំនងនេះ គេអាចសន្មតបានថា កិច្ចសន្យាគឺជាច្បាប់របស់គូភាគី។

ជាទូទៅកិច្ចសន្យានៅក្នុងជីវភាពឯកជន ការបង្កើតអាចមានទម្រង់ច្រើនយ៉ាង និងច្រើនប្រភេទ អាស្រ័យទៅតាមជម្រើសរបស់គូភាគីមានន័យថា កិច្ចសន្យាអាចបង្កើតឡើងដោយផ្ទាល់មាត់ ដោយតាមព្រមព្រៀង និងនៅពេលជាមួយគ្នានោះ គូរភាគីបានបង្ហាញឆន្ទៈត្រូវគ្នា ឬកិច្ចសន្យាអាចបង្កើតឡើងដោយលិខិតជាលាយលក្ខណ៍អក្សររួមមាន ដូចជាលិខិតឯកជន ឬលិខិតយថាភូត ក្នុងគោលដៅដើម្បីការពារផលប្រយោជន៍គូភាគីនៃកិច្ចសន្យា ដែលតាមរយៈកិច្ចសន្យា គេសង្កេតឃើញមានកំណត់អំពីប្រភេទនៃកាតព្វកិច្ច និងការទទួលខុសត្រូវ និងករណីដែលភាគីមិនអនុវត្តកាតព្វកិច្ច និងអាចមានការកំណត់អំពីទំហំនៃសំណងខូចខាត ដែលកើតមាននាពេលអនាគត។ បន្ថែមពីនេះនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ គេអាចសង្កេតពីការប្រតិបត្តិរបស់បុគ្គលក្នុនៅងជីវភាពឯកជន ដូចជាការសិក្សាអំពីអំពីស្ថានភាពដែលអាចកំណត់ថា តើមានការបង្កើតកិច្ចសន្យាដែរឬទេ ករណីខាងលើនេះ គឺអាចកំណត់បានថា មានកិច្ចសន្យាឬមិនមាន គឺអាស្រ័យទៅតាមទម្លាប់នៃទំនាក់ទំនងរបស់ភាគី ឬទង្វើនៃការប្រតិបត្តិរបស់ភាគី ដោយប្រែប្រួលទៅតាមប្រភេទផ្សេងៗនៃករណីសិក្សានីមួយៗ។

ប៉ុន្តែទោះបីជា ការបង្កើតកិច្ចសន្យា បានផ្តល់សិទ្ធិសេរីភាពពេញលេញដល់គូភាគីក្នុងការសម្រេចចិត្តយ៉ាងណាក៏ដោយ ក៏ករណីសិក្សាមួយចំនួននៅជុំវិញការប្រតិបត្តិឬការអនុវត្តប្រចាំថ្ងៃ បានបង្ហាញឲ្យឃើញថាមានការបំពានសិទ្ធិ និងអំពើរកេងចំណេញដែលតែងតែកើតមានជាញឹកញាប់ ហើយបុគ្គលទទួលរងនូវការខូតខាតជាប្រចាំ។ ដូចនេះ ដើម្បីទប់ស្កាត់នូវរាល់ការបំពានដែលកើតមាន តាមរយៈការផ្តល់សិទ្ធិសេរីភាពហួសហេតុដល់បុគ្គលក្នុងការបង្កើតទំនាក់ទំនងនៃជីវភាពឯកជន ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ ក៏បានដើរតួនាទីដ៏សំខាន់ ដើម្បីកំណត់អំពីវិធានមូលដ្ឋាន និងគោលការណ៍គ្រឹះមួយចំនួន ដែលតម្រូវឲ្យបុគ្គលត្រូវតែបំពេញចំពោះការបង្កើតទំនាក់ទំនងគតិយុត្ត ឬការបង្កើតកិច្ចសន្យា ក្នុងគោលដៅដើម្បីជានាការពារផលប្រយោជន៍បុគ្គលឲ្យបានគ្រប់ជ្រុងជ្រោយឬក៏ដូចជាការគ្រប់គ្រង និងសម្របសម្រួលទំនាក់ទំនងសង្គមកុំឲ្យមានភាពអនាធិបតេយ្យ ដោយឈរលើមូលដ្ឋានធានា និងការគោរពការពារផលប្រយោជន៍បុគ្គលឯកជនជាពិសេសគឺការពារនូវរាល់ទំនាក់ទំនងរវាងបុគ្គលនៅក្នុងជីវភាពឯកជន។

ជាទូទៅក្រមរដ្ឋប្បវេណីកម្ពុជា ត្រូវបានចាត់ទុកជាវិធាននៃច្បាប់សារធាតុនិង/ឬជាវិធានមូលដ្ឋានផ្នែកឯកជនឬជាវិធានដែលបានដាក់អនុវត្តនៅក្នុងទំនាក់ទំនងផ្នែកឯកជន ឬអាចកំណត់បានថាជាវិធាននៃនីតិឯកជនតួយ៉ាងដូចជា ការបង្កើតកិច្ចសន្យា ដែលបានផ្តល់សិទ្ធិសេរីភាពដល់បុគ្គលក្នុងការបង្កើតទំនាក់ទំនងគតិយុត្ត តែក៏តម្រូវឲ្យបុគ្គលទាំងនោះត្រូវគិតអំពីខ្លឹមសារនៃវិធានច្បាប់សារធាតុ មានន័យថា ទំនាក់ទំនងគតិយុត្តដែលបុគ្គល ឬភាគីនៃកិច្ចសន្យាបានបង្កើតយ៉ាងណា គឺកុំឲ្យផ្ទុយនឹងខ្លឹមសារនៃវិធានច្បាប់សារធាតុ ឬខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧។

បន្ថែមពីនេះ ដើម្បីសិក្សាស្វែងយល់ឲ្យបានច្បាស់អំពីខ្លឹមសារនៃវិធានច្បាប់សារធាតុ និងក៏ដូចជាសិក្សាលំអិតអំពីលក្ខខណ្ឌដែលមានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជា រួមមានដូចជា លក្ខខណ្ឌទម្រង់ទូទៅនៃបង្កើតកិច្ចសន្យា និងលក្ខខណ្ឌផ្សេងៗ នៃការបង្កើតកិច្ចសន្យាពិសេសនីមួយៗដូចដែលបានបង្ហាញខាងលើ ដូចនេះដើម្បីសិក្សាខ្លឹមសារខាងលើឲ្យបានស៊ីជម្រៅ គឺអាចសិក្សាបែងចែកជា៖ របបគតិយុត្តនៃកិច្ចសន្យា(មេរៀនទី១), កិច្ចសន្យាលក់ទិញ(មេរៀនទី២),កិច្ចសន្យាការងារ(មេរៀនទី៣), ភតិសន្យា (មេរៀនទី៤), កិច្ចសន្យាម៉ៅការ(មេរៀនទី៥), កិច្ចសន្យាអាណត្តិ(មេរៀនទី៦) និង កិច្ចសន្យាដឹកជញ្ជូន (មេរៀនទី៧) ស្របតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជា ឬសិក្សាអំពីទំនាក់ទំនងគតិយុត្តពិសេសដែលបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជា និង/ឬវិធានពិសេសផ្សេងៗទៀត ដែលមានបកស្រាយនៅក្នុងមេរៀនបន្តបន្ទាប់។

# មេរៀនទី១

## របបគតិយុត្តនៃកិច្ចសន្យា

នីតិកិច្ចសន្យា គឺសំដៅលើសំណុំវិធានគតិយុត្ត ឬជាបណ្តុំនៃលិខិតបទដ្ឋានគតិយុត្ត ដែលមានអត្ថន័យគ្រប់គ្រង សម្របសម្រួលទំនាក់ទំនងរវាងបុគ្គលនៃកិច្ចសន្យា ដោយប្រែប្រួលទៅតាមប្រភេទ និងលក្ខណៈពិសេសនៃកិច្ចសន្យានីមួយៗ។ ប៉ុន្តែបញ្ហាចោទនៅទីនេះ ថាតើនីតិកិច្ចសន្យា ត្រូវបានចាត់ទុកថាជាវិធាននៃនីតិឯកជន ឬជាវិធាននៃនីតិសាធារណៈ? បើយោងតាមគោលការណ៍ទូទៅ ដែលមានកំណត់នៅក្នុងខ្លឹមសារនៃច្បាប់សារធាតុផ្នែកឯកជន ឬក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ និងយោងតាមខ្លឹមសារដែលកំណត់ពីនិយមន័យនៃកិច្ចសន្យា គឺគេអាចចាត់ទុកបានថា **នីតិកិច្ចសន្យា** ជាវិធាននៃនីតិឯកជនដោយសន្មតបានថា **កិច្ចសន្យា គឺជាច្បាប់របស់គូភាគី**។ ប៉ុន្តែបើសិនជាយើងសិក្សាអំពីប្រភេទផ្សេងៗ និងលក្ខណៈពិសេស នៃកិច្ចសន្យានីមួយៗ តួរយ៉ាងដូចជា កិច្ចសន្យារដ្ឋបាល គេអាចកំណត់បានថាមានប្រភេទនៃទំនាក់ទំនងគតិយុត្តពិសេសមួយចំនួន ឬប្រភេទនៃកិច្ចសន្យាពិសេសមួយចំនួន គឺស្ថិតក្រោមការគ្រប់គ្រងក្រោមវិធាននៃនីតិសាធារណៈ។

បន្ថែមពីនេះដើម្បីធ្វើការសិក្សាវិភាគ អំពីបញ្ហាដែលបានលើកឡើងខាងលើឲ្យបានច្បាស់ និងក៏ដូចជា បង្ករលក្ខណៈងាយស្រួលដល់អ្នកសិក្សាអ្នកស្រាវជ្រាវ ក្នុងការតាក់តែងកិច្ចសន្យាដោយប្រែប្រួលទៅតាមប្រភេទ និងលក្ខណៈពិសេសនៃកិច្ចសន្យានីមួយៗនាពេលអនាគត តាមរយៈនោះអាចធ្វើការសិក្សាអំពីទំនាក់ទំនងរវាង កាតព្វកិច្ច និងកិច្ចសន្យា និងប្រភេទផ្សេងៗនៃកាតព្វកិច្ច។

## ១.អំពីកាតព្វកិច្ច និងការបង្កើតកិច្ចសន្យា

ដើម្បីសិក្សាស្វែងយល់អំពីទំនាក់ទំនងរវាងកាតព្វកិច្ច និងការបង្កើតកិច្ចសន្យា ក្នុងនោះមានសំណួរជុំវិញជាច្រើនបានចោទឡើងថា តើអ្វីទៅជាកាតព្វកិច្ច? តើកាតព្វកិច្ចត្រូវបានបង្កើតនៅពេលណា? តើក្នុងមូលហេតុនិងលក្ខខណ្ឌណាខ្លះ ដែលនាំឲ្យបង្កើតបានជាកាតព្វកិច្ច? តើកាតព្វកិច្ច និងកិច្ចសន្យាមានទំនាក់ទំនងនិងគ្នាយ៉ាងដូចម្តេច?

ជាទូទៅចំពោះខ្លឹមសារនៃកាតព្វកិច្ច ស្របតាមរយៈខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ គេអាចកំណត់បានថា កាតព្វកិច្ច គឺជាទង្វើនៃការបង្ហាញឆន្ទៈរបស់បុគ្គល ក្នុងគោលបំណងបង្កើតទំនាក់ទំនងគតិយុត្ត គឺសំដៅដល់ទំនាក់ទំនងបុគ្គល ដែលមានអត្ថន័យបង្កើតសិទ្ធិ និងករណីយកិច្ច។[3] ប៉ុន្តែបញ្ហាចោទនៅទីនេះ តើអ្វីទៅជាកាតព្វកិច្ច ដែលកើតចេញពីទំនាក់ទំនងគតិយុត្តរវាងបុគ្គលនិងបុគ្គល? និងតើបុគ្គលចាំបាច់ត្រូវតែបង្ហាញឆន្ទៈរួមដើម្បីបង្កើតកាតព្វកិច្ចឬយ៉ាងណា? និងតើកាតព្វកិច្ចមានប្រភពមកពីណា?

អនុលោមតាមមាត្រា៣០៨នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ បានកំណត់និយមន័យនៃកាតព្វកិច្ច និងលក្ខណៈវិនិច្ឆ័យជាច្រើនចំពោះការបង្កើតកាតព្វកិច្ចមានន័យថា កាតព្វកិច្ច គឺជាការបង្ហាញឆន្ទៈដើម្បីបង្កើតទំនាក់ទំនងគតិយុត្តមានន័យថា ជាការបង្ហាញឆន្ទៈរបស់បុគ្គលក្នុងការបង្កើតសិទ្ធិ និងករណីយកិច្ច ដែលជាការបង្ហាញឆន្ទៈត្រូវគ្នារវាងភាគីនៃទំនាក់ទំនង រួមមាន៖ ម្ចាស់បំណុល និងកូនបំណុល។ ម្ចាស់បំណុលនៃកាតព្វកិច្ច ត្រូវបានកំណត់ថាជាបុគ្គលដែលមានសិទ្ធិទាមទារឲ្យកូនបំណុលបំពេញនូវតាវកាលិកចំពោះ

---
[3] ម.៣០៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ខ្លួន និងភាគីកូនបំណុលត្រូវមានករណីយកិច្ច ចំពោះម្ចាស់បំណុល។ ដូចនេះ កាតព្វកិច្ច គឺជាប្រភពនៃការបង្កើតកិច្ចសន្យា ប៉ុន្តែមិនមែនគ្រប់រាល់ការបង្ហាញឆន្ទៈទាំងអស់ អាចកំណត់ថាជាកាតព្វកិច្ច និងជាប្រភពនៃការបង្កើតកិច្ចសន្យាទាំងអស់នោះទេ ពីព្រោះការបង្ហាញឆន្ទៈរបស់បុគ្គល ត្រូវតែមានចេតនាក្នុងការបង្កើតនូវទំនាក់ទំនងគតិយុត្ត មានន័យថា ជាចេតនានៃការបង្កើតសិទ្ធិ និងករណីកិច្ច និងអាចកំណត់បានថាជាប្រភពនៃកាតព្វកិច្ច ដែលគឺជាការបង្ហាញឆន្ទៈត្រូវគ្នា និងគេអាចសន្មតថា មានកិច្ចព្រមព្រៀងពិតប្រាកដមួយនិងកើតឡើងនាពេលអនាគតដ៏ខ្លី ទើបអាចកំណត់ថាបង្កើតកាតព្វកិច្ច។ ប៉ុន្តែបញ្ហាចោទទីនេះថាតើកាតព្វកិច្ចមានអ្វីខ្លះ និងមានប្រភពយ៉ាងដូចម្តេច? ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលបានលើកឡើងខាងលើ យើងគួរធ្វើការសិក្សាលំអិតអំពីប្រភពនៃកាតព្វកិច្ច។

## ២.អំពីប្រភពនៃកាតព្វកិច្ច

អនុលោមតាមមាត្រា៣០៨នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ បានឲ្យនិយមន័យកាតព្វកិច្ចថា ជាការបង្ហាញឆន្ទៈរបស់បុគ្គល ដើម្បីបង្កើតនូវទំនាក់ទំនងគតិយុត្ត ដែលតាមរយៈនោះ ការបង្ហាញឆន្ទៈកើតមានស្របតាមលក្ខណៈវិនិច្ឆ័យ និងស្របតាមមាត្រា៣០៩ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ដោយគេអាចកំណត់បានថា ការបង្ហាញឆន្ទៈដើម្បីបង្កើតទំនាក់ទំនងគតិយុត្តតាមរយៈកិច្ចសន្យា អាចធ្វើឡើងដោយសកម្មភាពឯកតោភាគី អាចធ្វើឡើងដោយការគ្រប់គ្រងដោយការឈឺឆ្អាល ដោយសេចក្តីចម្រើនឥតហេតុ ដោយអំពើអនីត្យានុកូល និងដោយបញ្ញត្តិច្បាប់។

ដូចនេះយោងតាមគោលគំនិត ដែលបានលើកឡើងខាងលើ គេអាចកំណត់បានថា កាតព្វកិច្ចមានប្រភពមកពីកិច្ចសន្យា និងកាតព្វកិច្ចមានប្រភពមកពីទង្វើផ្សេងៗទៀត ដែលកើតមាននៅក្រៅឆន្ទៈបុគ្គល និងអាចកំណត់បានថាកាតព្វកិច្ចកើតមានរួមមានដូចជា កាតព្វកិច្ចកើតមានដោយទង្វើដែលជាការគ្រប់គ្រងដោយការឈឺឆ្អាល ជាសេចក្តីចម្រើនដោយឥតហេតុ ជាអំពើអនីត្យានុកូល និង/ឬកាតព្វកិច្ចដែលកើតមានតាមបញ្ញត្តិច្បាប់។

✓ <u>**ការសិក្សាអំពីកិច្ចសន្យា និងការបង្ហាញឆន្ទៈ**</u>

តើអ្វីជាការបង្ហាញឆន្ទៈ? តើការបង្ហាញឆន្ទៈបែបណាទើបកំណត់បានថាជាកិច្ចសន្យា? តើការបង្ហាញឆន្ទៈមានអត្ថន័យខុស ឬដូចកិច្ចសន្យា? ជាទូទៅចំពោះការសិក្សាជុំវិញនិយមន័យនៃកិច្ចសន្យា ដែលលើកឡើងថា កិច្ចសន្យា សំដៅទៅលើការព្រមព្រៀងរវាងបុគ្គលពីរ ឬច្រើន ក្នុងគោលដៅដើម្បីបង្កើត កែប្រែ រំលត់សិទ្ធិ និងកាតព្វកិច្ចដែលទាក់ទិននឹងគូភាគី ក្នុងន័យនេះ គេអាចកំណត់បានថា កិច្ចសន្យាការបង្កើតតម្រូវឲ្យមានការចូលរួមពីឆន្ទៈរបស់បុគ្គលចាប់ពី២នាក់។[4] ប៉ុន្តែបញ្ហាចោទនៅទីនេះ តើកិច្ចសន្យា និងការបង្ហាញឆន្ទៈមានទំនាក់ទំនងគ្នាយ៉ាងដូចម្តេច?**ការបង្ហាញឆន្ទៈ** បានកំណត់ថាជា ការបង្ហាញឆន្ទៈរបស់ភាគីដែលមានបំណងបង្កើតនូវអានុភាពគតិយុត្ត ហៅថាការបង្ហាញឆន្ទៈ និងការបង្ហាញឆន្ទៈមានអានុភាពនៅពេលដំណឹងនៃការបង្ហាញឆន្ទៈបានដល់ភាគីម្ខាងទៀត។

[4] គោលការណ៍ទូទៅនៃការបកស្រាយតាមនិយមន័យនៃកិច្ចសន្យា ការបង្កើតកិច្ចសន្យាទាមទារឲ្យមានចូលរួមរវាងឆន្ទៈរបស់បុគ្គលចាប់ពី២នាក់ តែករណីលើកលែងចំពោះកិច្ចសន្យាបង្កើតក្រុមហ៊ុន ស្របតាមខ្លឹមសារនៃវិធានពិសេស គេសង្កេតឃើញមានក្រុមហ៊ុនមួយចំនួនការបង្កើត មានការចូលរួមពីឆន្ទៈរបស់បុគ្គលតែម្នាក់ ដូចជាករណីក្រុមហ៊ុនឯកបុគ្គលទទួលខុសត្រូវមានកម្រិត។

ក្នុងអត្ថន័យខាងលើនេះ បើសិក្សាធៀបទៅនិងនិយមន័យនៃកិច្ចសន្យា ការបង្ហាញឆន្ទៈ ដែលមានគោលបំណងច្បាស់លាស់ក្នុងការបង្កើតសិទ្ធិ និងករណីយកិច្ច គេកំណត់បានថា មានអានុភាពគតិយុត្តនិងត្រូវបានចាត់ទុកថាជាកិច្ចសន្យា។[5]

✓ **<u>កិច្ចសន្យា និងកិច្ចឯកតោភាគីនៃឆន្ទៈ</u>**

តើកិច្ចសន្យា និងកិច្ចឯកតោភាគីនៃឆន្ទៈ យោងតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជា មានទំនាក់ទំនងគ្នាយ៉ាងដូចម្តេច? កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នា ព្រមបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច ក្នុងន័យនេះសន្មតបានថា កិច្ចសន្យាគឺកើតចេញពីឆន្ទៈត្រូវគ្នារបស់បុគ្គលចាប់ពី២នាក់ ក្នុងនោះបុគ្គលអាចមានឆន្ទៈព្រមព្រៀងក្នុងការបង្កើត កែប្រែ ឬរំលត់នូវសិទ្ធិ និងកាតព្វកិច្ច ដែលទាក់ទិននឹងបុគ្គល។[6]

ម្យ៉ាងទៀតសកម្មភាពឯកតោភាគី គឺជាសកម្មភាពដែលកើតចេញពីទង្វើរបស់បុគ្គលតែម្ខាងឬភាគីតែម្ខាងតែការបកស្រាយយោងតាមខ្លឹមសារក្រមរដ្ឋប្បវេណីកម្ពុជា មានការបកស្រាយផ្សេងទៀតនៅជុំវិញសំណើ ដែលគឺជាការបង្ហាញឆន្ទៈ ដើម្បីបង្កើតទំនាក់ទំនងគតិយុត្ត ឬ ជាការសុំបង្កើតកិច្ចសន្យានៅពេលមានការធ្វើស្វីការតបវិញ និងកំណត់បានថាមានកិច្ចសន្យា។ បន្ថែមពីនេះ តាមខ្លឹមសារនៃច្បាប់សារធាតុ ក៏គេអាចធ្វើការបកស្រាយបានថា ជាការសន្យាឯកតោភាគី ដែលទាមទារនូវការបំពេញលក្ខខណ្ឌមួយចំនួនព្រមទាំងមានការធ្វើស្វីការតប និងកំណត់ថាមានការបង្កើតកិច្ចសន្យា។

---

[5] ម.៣១០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[6] ម.៣១១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

✓ **<u>កិច្ចសន្យា និងការសិក្សាអំពីប្រភេទនៃកាតព្វកិច្ច</u>**

កាតព្វកិច្ច តាមខ្លឹមសារមាត្រានៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ យើងអាចកំណត់បានថា កាតព្វកិច្ចត្រូវបានកំណត់ថា កាតព្វកិច្ចកើតចេញពីឆន្ទៈរបស់បុគ្គល ដែលជាប្រភេទកាតព្វកិច្ចកើតចេញពីប្រភេទផ្សេងៗនៃកិច្ចសន្យា និងកាតព្វកិច្ចត្រូវបានកំណត់ថា កាតព្វកិច្ចកើតចេញពីទង្វើនៅក្រៅឆន្ទៈរបស់បុគ្គលមានន័យថា ជាប្រភេទនៃកាតព្វកិច្ចដែលកើតចេញពីទង្វើនៅក្រៅឆន្ទៈបុគ្គល ដែលតាមរយៈនោះគេសង្កេតឃើញមានប្រភេទនៃកាតព្វកិច្ចកើតមានដោយការគ្រប់គ្រងដោយការឈឺឆ្អាល ដោយសេចក្តីចម្រើនដោយឥតហេតុ ដោយអំពីអនីត្យានុកូល និងកាតព្វកិច្ចកើតឡើងដោយបញ្ញត្តិច្បាប់។ ដូចនេះយើងអាចកំណត់បានថា កាតព្វកិច្ចនិងកិច្ចសន្យាមានទំនាក់ទំនងគ្នាយ៉ាងស្អិតរមួត ដោយកិច្ចសន្យា គឺជាប្រភពនៃកាតព្វកិច្ច។

បន្ថែមពីនេះ ជារួមតើរបបគតិយុត្តនៃកិច្ចសន្យាសិក្សាអំពីអ្វី? តើនិស្សិត និងអ្នកសិក្សាស្រាវជ្រាវ អាចយល់ដឹងអំពីចំណុចមូលដ្ឋានអ្វីខ្លះ?

របបគតិយុត្តនៃកិច្ចសន្យា សំដៅទៅលើសំណុំវិធាន ឬជាបណ្តុំនៃលិខិតបទដ្ឋានគតិយុត្ត ដែលធ្វើការសិក្សាជុំវិញនូវ លក្ខខណ្ឌនៃការបង្កើត កែប្រែ រំលត់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនៃកិច្ចសន្យា ដោយក្នុងនោះស្របបតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ គឺគេអាចធ្វើការសិក្សាបែងចែកជាបីដំណាក់កាលរួមមាន៖ដំណាក់កាលមុនពេលកិច្ចសន្យា (ផ្នែកទី១), ដំណាក់កាលកិច្ចសន្យា(ផ្នែកទី២) និងដំណាក់កាលក្រោយពេលកិច្ចសន្យា(ផ្នែកទី៣)។

## ផ្នែកទី១.ដំណាក់កាលមុនពេលកិច្ចសន្យា

តើដំណាក់កាលមុនពេលកិច្ចសន្យាធ្វើការសិក្សាអំពីអ្វី? មូលហេតុអ្វីតម្រូវសិក្សាអំពីដំណាក់កាលមុនពេលកិច្ចសន្យា? ជាទូទៅដំណាក់កាលមុនពេលកិច្ចសន្យា គឺជាដំណាក់នៃការចរចាដំបូង ដើម្បីបង្កើតកិច្ចសន្យា ឬអាចកំណត់បានថាដំណាក់កាលផ្តួចផ្តើមនៃការបង្កើតទំនាក់ទំនងគតិយុត្ត ដែលប្រែប្រួលទៅតាមប្រភេទ និងលក្ខណៈពិសេសផ្សេងៗ ដែលជាតម្រូវការរបស់ភាគី ឬបុគ្គលនៃទំនាក់ទំនង និងអាចកំណត់បានអំពីវត្ថុបំណងរបស់ភាគីនៅមុនពេលបង្កើតទំនាក់ទំនងគតិយុត្តនាពេលអនាគត។

ការសិក្សាអំពីដំណាក់មុនពេលកិច្ចសន្យា អាចឲ្យដឹងអំពីបុព្វហេតុដំបូងនៃការបង្កើតទំនាក់ទំនងគតិយុត្ត ដូចជា ការប្រើប្រាស់ភាសាដែលជាជម្រើសរបស់ភាគីនៃទំនាក់ទំនង ការកំណត់ពីវិធានទំនៀមទម្លាប់ប្រចាំតំបន់នៅក្នុងជីវភាពនៃការរស់នៅប្រចាំថ្ងៃ ឬអាចសិក្សាអំពីទម្លាប់នៃជីវភាពកិច្ចការជំនួញ ឬភាគីអាចកំណត់អំពីជម្រើសផ្សេងៗនៃការអនុវត្តកាតព្វកិច្ច ឬជាការអនុវត្តកាតព្វកិច្ចតាមច្បាប់ នៅពេលកិច្ចសន្យាត្រូវបានបង្កើតពេលអនាគត។ ម្យ៉ាងទៀតការសិក្សាអំពីដំណាក់មុនពេលកិច្ចសន្យា គឺអាចបង្ហាញអ្នកសិក្សាស្រាវជ្រាវ និងអ្នកសិក្សាឲ្យទទួលបាននូវចំណេះដឹងមូលដ្ឋានចំបងៗ ក្នុងការតាក់តែងកិច្ចសន្យា និងវិធីនៃការដោះស្រាយនូវបញ្ហាគតិយុត្តចំបងមួយចំនួនដែលកើតមាននៅដំណាក់មុនពេលកិច្ចសន្យា។

បន្ថែមពីនេះ ថ្វីត្បិតតែកិច្ចសន្យាមិនទាន់បានបង្កើតនៅក្នុងពេលជាមួយគ្នានៅដំណាក់កាលនៃការចរចា ប៉ុន្តែករណីសិក្សាជាច្រើនបានបង្ហាញឲ្យឃើញនូវចំណុចវិវាទ ដែលអាចកើតមាននៅជុំវិញដំណាក់កាលនៃការចរចា

រួមមានវិវាទស្តីពីតុល្យភាពនៃផលប្រយោជន៍ វិវាទកើតមានជុំវិញការបំពានសិទ្ធិរបស់បុគ្គលឯកជន និងការខូចខាតដែលអាចកើតមានចំពោះភាគីនៅដំណាក់កាលនៃការចរចា។ ដូចនេះដើម្បីសិក្សាស្វែងយល់ និងរកដំណោះស្រាយចំពោះបញ្ហាប្រឈមដែលបានលើកឡើងខាងលើ និងធ្វើការសិក្សាឲ្យបានកាន់តែស៊ីជម្រៅ អំពីខ្លឹមសារមាត្រាក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ គឺយើងអាចសិក្សាអំពីសំណើ(កថាខណ្ឌទី១)និងស្វីការ(កថាខណ្ឌទី២)។

## កថាខណ្ឌ១.សំណើ

ដូចម្តេចដែលហៅថាសំណើ? និងសំណើ ទាមទារឲ្យបំពេញនូវលក្ខខណ្ឌអ្វីខ្លះទើបកំណត់បានថា នៅពេលមានការធ្វើស្វីការតបវិញ ឬសំណើបានជួបជាមួយនិងការបង្ហាញឆន្ទៈថាយល់ព្រម អាចចាត់ទុកបានថាមានការបង្កើតកិច្ចសន្យា? ជាទូទៅបើយោងតាមខ្លឹមសារនៃវិធានច្បាប់សារជាតុ ឬក្រមរដ្ឋប្បវេណីកម្ពុជា សំណើ ត្រូវបានកំណត់ថា ជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើង ដោយក្នុងនោះបុគ្គលបានបង្ហាញឆន្ទៈដើម្បីភ្ជាប់ខ្លួនជាមួយនិងចំណាងគតិយុត្ត និងកំណត់បានថាជាកិច្ចសន្យា ក្នុងករណីដែលមានការធ្វើស្វីការរបស់ភាគីម្ខាងទៀតចំពោះ សំណើ។[7] ក្នុងន័យនេះអាចកំណត់បានថា សំណើគឺជាការបង្ហាញឆន្ទៈដើម្បីបង្កើតទំនាក់ទំនងគតិយុត្ត និងគេអាចកំណត់ថាមានកិច្ចសន្យានៅពេលមានការឆ្លើយតបថាយល់ព្រម ឬនៅពេលមានការធ្វើស្វីការតបវិញចំពោះលក្ខខណ្ឌនៃសំណើ។

ប៉ុន្តែទោះបីជាវិធាននៃច្បាប់សារជាតុ បានកំណត់បែបនេះក៏ដោយ តែការសិក្សាជុំវិញដំណាក់កាលមុនពេលនៃការបង្កើតកិច្ចសន្យា គេនៅតែ

[7] ម.៣៣៧.១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

សង្កេតឃើញមានបញ្ហាប្រឈមជាច្រើន ដោយក្នុងនោះភាគីក៏បានធ្វើការកត់សម្គាល់ថា តើការដាក់សំណើមានអានុភាពនៅពេលណា? តើភាគីអាចដកសំណើបាននៅពេលណា? និងការដកសំណើត្រូវធ្វើឡើងយ៉ាងដូចម្តេចដើម្បីកុំឲ្យមានការខូចខាតកើតមាន ឬមិនបង្កើតជាបន្ទុកផ្សេងៗដល់ភាគីនៅពេលដកសំណើ?

ម្យ៉ាងវិញទៀតបើយោងតាមមាត្រា៣៣៧.២ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ គេអាចកំណត់បានថា សំណើមានអានុភាពនៅពេលសំណើបានដល់ភាគីម្ខាងទៀត មានន័យថា ការសុំបង្កើតកិច្ចសន្យារបស់អ្នកដាក់សំណើ គឺបានកំណត់អានុភាពនៅពេលដំណឹងនៃការបង្ហាញឆន្ទៈបានដល់ភាគីម្ខាងទៀត ឬនៅពេលដំណឹងនៃការសុំបង្កើតកិច្ចសន្យាបានដល់ភាគីម្ខាងទៀត។ ក្រៅពីនេះការកំណត់ថាកិច្ចសន្យា កើតមាននៅពេលណា គឺលុះត្រាតែមានការជួបគ្នារវាង សំណើ និងស្វីការ និងការដកសំណើអាចកំណត់បានថា ធ្វើបានតាមវិធីណា ឬយ៉ាងដូចម្តេច គឺប្រែប្រួលទៅតាមប្រភេទផ្សេងៗនៃសំណើ(១)និងសុពលភាពនៃសំណើ(២)។

## ១.ប្រភេទផ្សេងៗនៃសំណើ

សំណើ គឺជាការបង្ហាញឆន្ទៈដើម្បីបង្កើតទំនាក់ទំនងគតិយុត្ត នៅពេលមានការធ្វើស្វីការតបវិញ និងកំណត់បានថាកិច្ចសន្យាត្រូវបានបង្កើត ឬអាចកំណត់បានម្យ៉ាងទៀតថា សំណើ គឺជាការសុំបង្កើតកិច្ចសន្យា នៅពេលមានការធ្វើស្វីការតបវិញ និងកំណត់បានថាមានការបង្កើតកិច្ចសន្យា។

បន្ថែមពីនេះ ការបង្ហាញឆន្ទៈ នៅក្នុងការបង្កើតទំនាក់ទំនងគតិយុត្ត ដែលចាត់ទុកថាជាសំណើ ករណីខ្លះមានកំណត់អំឡុងពេលដកសំណើ និង ករណីខ្លះមិនមានកំណត់អំឡុងពេលក្នុងការដកសំណើ។

ហេតុដូចនេះបញ្ហាដែលបានចោទឡើង ចំពោះករណីដែលអ្នកទទួល សំណើមិនបានធ្វើស្ទីការតបវិញ ឬមិនមានលក្ខខណ្ឌដាក់លាក់ណាមួយ ដែល ភាគីអាចកំណត់បានអំពីការធ្វើស្ទីការតបវិញ ឬការយឺតយ៉ាវ អំពីការធ្វើស្ទីការ តើអ្នកដាក់សំណើអាចដកសំណើបាននៅពេលណា? ទាំងនេះ គឺជាបញ្ហា ប្រឈមដែលកើតមាននៅជុំវិញដំណាក់កាលមុនពេលកិច្ចសន្យា ប៉ុន្តែដើម្បី ងាយស្រួលក្នុងការកំណត់លក្ខខណ្ឌឲ្យបានច្បាស់លាស់ គឺក្រមរដ្ឋប្បវេណី កម្ពុជា បានធ្វើការបែងចែកប្រភេទផ្សេងៗនៃសំណើរួមមាន៖ សំណើដែលមាន កំណត់អំឡុងពេលសម្រាប់ស្ទីការនិងការដកសំណើ និងសំណើដែលគ្មាន កំណត់អំឡុងពេលសម្រាប់ស្ទីការ និងការដកសំណើ។

- ✓ **សំណើដែលមានកំណត់អំឡុងពេលសម្រាប់ធ្វើស្ទីការ និងការដក សំណើ**

សំណើដែលមានកំណត់អំឡុងពេល សំដៅទៅដល់ការបង្ហាញឆន្ទៈ របស់បុគ្គលដើម្បីបង្កើតទំនាក់ទំនងគតិយុត្តឬ ជាការបង្ហាញឆន្ទៈរបស់បុគ្គល ដើម្បីសុំបង្កើតកិច្ចសន្យា ដោយតាមរយៈការបង្ហាញឆន្ទៈនោះ អ្នកស្នើបាន កំណត់នូវអំឡុងពេលសម្រាប់ធ្វើស្ទីការនិងការដកសំណើ។[8]

បន្ថែមពីនេះ សំណើដែលមានកំណត់អំឡុងពេល បើយោងតាម គោលគំនិតមាត្រា៣៣៨.១នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ បានកំណត់

[8] ម.៣៣៨.១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ថា បើករណីមិនច្បាស់ថា អ្នកស្នើកំណត់ពេលផ្សេង ការគិតអំពីអំឡុងពេលសម្រាប់ធ្វើស្វីការ គឺត្រូវតែគិតចាប់ពីថ្ងៃជូនដំណឹងអំពីសំណើ។

ករណីនេះ សំណើដែលមានកំណត់អំឡុងពេលសម្រាប់ធ្វើស្វីការ និងការដកសំណើ គឺបានផ្តល់ជាគុណប្រយោជន៍ សម្រាប់អ្នកទទួលសំណើ ដោយមូលហេតុថា សំណើដែលមានកំណត់អំឡុងពេល និងករណីមិនទាន់ផុតអំឡុងពេលកំណត់ អ្នកដាក់សំណើ មិនអាចដកសំណើវិញបានទេ ប្រសិនបើ អ្នកទទួលសំណើ ពុំទាន់ធ្វើការឆ្លើយតបឬធ្វើស្វីការតបវិញ។[9]

ម្យ៉ាងវិញទៀត ករណីអ្នកស្នើមិនបានទទួលដំណឹងអំពីស្វីការ ក្នុងអំឡុងពេលសម្រាប់ធ្វើស្វីការ គឺគេអាចសន្មត់បានថា សំណើត្រូវបាត់បង់អានុភាព មានន័យថាសំណើនោះ ត្រូវបាត់បង់អានុភាពដោយស្វ័យប្រវត្តិ នៅពេលផុតអំឡុងពេលសម្រាប់ធ្វើស្វីការ និងក្នុងករណីដំណឹងអំពីការបដិសេធសំណើបានដល់អ្នកស្នើក្នុងអំឡុងពេលសម្រាប់ស្វីការ សំណើនោះ ក៏ត្រូវបាត់បង់អានុភាពដែរ។ ដូចនេះគេអាចកំណត់បានថា ករណីសំណើមានកំណត់អំឡុងពេលសម្រាប់ស្វីការ អ្នកដាក់សំណើ អាចដកសំណើនៅអំឡុងពេលនៃការដាក់សំណើ និងសំណើបានដល់ និង/ឬអ្នកទទួលសំណើមិនធ្វើស្វីការ។ អំឡុងពេលនៃការដកសំណើ ជាគោលការណ៍ចំពោះអំឡុងពេលសន្មត់ក្នុងការដកសំណើ គឺគិតចាប់ពីថ្ងៃដែលបានជូនដំណឹង ករណីភាគីមិនច្បាស់ថាអ្នកស្នើកំណត់ពេលផ្សេង។

---

[9] ម.៣៣៨.២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ការកំណត់ដូចនេះ គឺដើម្បីការពារផលប្រយោជន៍អ្នកទទួលសំណើក្នុងការធ្វើស្នីការតបវិញ និងការពារអ្នកដាក់សំណើដែលមានកំណត់អំឡុងពេលសម្រាប់ស្នីការ មិនឲ្យដកសំណើមុនពេលកំណត់មកដល់។

### ✓ សំណើមិនកំណត់អំឡុងពេលសម្រាប់ធ្វើស្នីការ និងការដកសំណើ

សំណើមិនកំណត់អំឡុងពេលសម្រាប់ធ្វើស្នីការ និងការដកសំណើ គឺសំដៅដល់ការបង្ហាញឆន្ទៈរបស់បុគ្គលដើម្បីបង្កើតទំនាក់ទំនងគតិយុត្ត ឬជាការបង្ហាញឆន្ទៈរបស់បុគ្គលដើម្បីសុំបង្កើតកិច្ចសន្យា ដោយតាមរយៈការបង្ហាញឆន្ទៈនោះ អ្នកស្នើ មិនបានកំណត់នូវអំឡុងពេលសម្រាប់ធ្វើស្នីការ និងការដកសំណើ។[10] ប្រសិនបើយោងគោលគំនិតមាត្រានៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ការសិក្សាជុំវិញប្រភេទនៃសំណើ ដែលមិនកំណត់អំឡុងពេលសម្រាប់ធ្វើស្នីការនិងការដកសំណើ ត្រូវបានធ្វើការសិក្សាបែងចែកទៅតាមប្រភេទផ្សេងៗ នៃករណីសិក្សាជុំវិញការបង្កើតសំណើដែលអាចស្ថិតក្នុងកាលៈទេសៈផ្សេងគ្នា ដូចជាការដាក់សំណើនៅពេលជាមួយគ្នាដែលភាគីកំពុងជួបពិភាក្សាគ្នា និងការដាក់សំណើដោយភាគីដែលស្ថិតក្នុងស្ថានភាពមិនបានដឹងខ្លួន ថាភាគីដាក់សំណើ ឬសុំបង្កើតកិច្ចសន្យា ដូចនេះ ការកំណត់អំពីអំឡុងពេលនៃការដកសំណើ ក៏ត្រូវធ្វើការសិក្សាអំពីកាលៈទេសៈជុំវិញចំពោះការបង្កើតសំណើ មានន័យថា ការសិក្សាអំពីវិធីនៃការបង្កើតសំណើ គឺអាចបង្ហាញឲ្យឃើញនូវជាតុផ្សំមួយចំនួន និងការសិក្សាបែបនេះក៏បង្កនូវលក្ខណៈងាយស្រួលដល់ភាគី ក្នុងការកំណត់អំពីអំឡុងពេលនៃការដកសំណើ។

[10]ម.៣៣៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ករណីដូចជា សំណើ ត្រូវបានធ្វើឡើងដោយគ្មានកំណត់អំឡុងពេលសម្រាប់ធ្វើស្វីការ រវាងភាគីដែលកំពុងតែនិយាយគ្នា នៅក្នុងស្ថានភាពដែលអាចធ្វើភ្លាមៗបាន ប្រសិនបើភាគីទទួលសំណើ មិនបានយល់ព្រមភ្លាមៗទេ សំណើត្រូវបានបង់អានុភាព។ ម្យ៉ាងវិញទៀតករណី សំណើកើតឡើងក្នុងអំឡុងពេលដែលភាគីកំពុងតែនិយាយគ្នា ដោយគ្មានកំណត់អំឡុងពេលសម្រាប់ធ្វើស្វីការទេ អ្នកស្នើមិនអាចដកសំណើនោះក្នុងអំឡុងពេលសមរម្យបានឡើយ និងការដកសំណើមានអានុភាព នៅពេលដែលការជូនដំណឹងអំពីការដកសំណើបានដល់ភាគីម្ខាងទៀត និងមុនពេលភាគីម្ខាងទៀតបានជូនដំណឹងអំពីស្វីការ។[11]

## ២.សុពលភាពនៃសំណើ

តើសំណើមានសុពលភាពនៅពេលណា? យោងតាមគោលគំនិតមាត្រានៃក្រមរដ្ឋប្បវេណីកម្ពុជា ចំពោះការកំណត់អំពីនិយមន័យនៃសំណើ សំណើ គឺជាការបង្ហាញឆន្ទៈរបស់បុគ្គលដើម្បីបង្កើតទំនាក់ទំនងគតិយុត្ត ឬសំណើ គឺជាការសុំបង្កើតកិច្ចសន្យាដោយមានការធ្វើស្វីការតបវិញ ដែលត្រូវបានសន្មត់ថាមានកិច្ចសន្យាកើតឡើង។ ទាំងនេះ គឺគេអាចធ្វើការបកស្រាយដោយផ្អែកទៅតាមទ្រឹស្តីស្វ័យភាពនៃឆន្ទៈសេរីរបស់បុគ្គលឯកជន មានន័យថា ការបង្ហាញឆន្ទៈរបស់បុគ្គលក្នុងការបង្កើតសំណើ ជាគោលការណ៍គឺកំណត់ថាជាការបង្ហាញឆន្ទៈរបស់បុគ្គលដោយគ្មានវិការៈនៃការបង្ហាញឆន្ទៈ គឺជាការបង្ហាញឆន្ទៈដែលពិតប្រាកដ មិនមានការគៀបសង្កត់ពីមជ្ឈដ្ឋានផ្សេង មិនមានការប្រើប្រាស់ហិង្សា ការរំលោភបំពានលើស្ថានភាព ការភាន់ច្រលំ...ជាដើម។

---

[11]ម.៣៣៩.២ និងម.៣៣៩.៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

បន្ថែមពីនេះ ក្នុងអត្ថន័យនេះដែរ គេអាចធ្វើការសិក្សាវិភាគអំពីលក្ខខណ្ឌនៃការសុំបង្កើតកិច្ចសន្យា ថាតើការសុំបង្កើតកិច្ចសន្យាគឺទាមទារឲ្យបុគ្គលបំពេញនូវលក្ខខណ្ឌអ្វីខ្លះ ?ទើបគេអាចធ្វើការសន្មតបានថានៅពេលមានការធ្វើស្ទីការតបវិញ ឬការបង្ហាញឆន្ទៈថាយល់ព្រម គឺមានកិច្ចសន្យាមួយកើតឡើង។

ដូចនេះសុពលភាពភាពនៃសំណើ ក្រៅពីការបង្ហាញឆន្ទៈគ្មានវិការៈគឺទាមទារនូវលក្ខខណ្ឌជាច្រើនយ៉ាងទៀត ដោយប្រែប្រួលទៅតាមប្រភេទ និងលក្ខណៈពិសេសនៃកិច្ចសន្យានីមួយៗដែលភាគីចង់បាន និងបង្កើតកិច្ចសន្យានាពេលអនាគត ឧទាហរណ៍៖ ដូចជាសំណើបង្កើតកិច្ចសន្យាលក់ទិញ សំណើបង្កើតកិច្ចសន្យាក្រុមហ៊ុន សំណើបង្កើតកិច្ចសន្យាធានារ៉ាប់រង...ជាដើម ដែលទាមទារឲ្យលក្ខខណ្ឌនៃសំណើត្រូវតែបំពេញ ឬសំណើក៏ត្រូវធ្វើការបែងចែកខុសគ្នាដែរ ប៉ុន្តែជាគោលការណ៍ និង/ឬមូលដ្ឋានគ្រឹះនៃការបង្កើតកិច្ចសន្យាដែលមុននិងទាមទារនូវលក្ខខណ្ឌពិសេសដែលភាគីចង់បាន គឺភាគីតាមរយៈគោលការណ៍ស្វ័យភាពនៃឆន្ទៈសេរីរបស់បុគ្គលឯកជន អ្នកដាក់សំណើត្រូវតែបង្ហាញថាខ្លួនមានភាពប្រាកដជាក់លាក់ចំពោះបុគ្គលម្ខាងទៀត មានន័យថាអ្នកដាក់សំណើត្រូវតែបង្ហាញថា ខ្លួនមានឆន្ទៈពិតប្រាកដក្នុងការបង្កើតទំនាក់ទំនងគតិយុត្តនាពេលអនាគត ឬបុគ្គលបានបង្ហាញឆន្ទៈចង់ក្លាយជាភាគីនៃកិច្ចសន្យានាពេលអនាគត ទើបគេអាចកំណត់បានថា នៅពេលមានការធ្វើស្ទីការតបវិញគឺមានកិច្ចសន្យា។

## ៣.ការដកសំណើ

តើការដកសំណើត្រូវធ្វើឡើងតាមវិធីណា និងយ៉ាងដូចម្តេច ?

ជាទូទៅសំណើ បើយោងតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ គេបានសង្កេតឃើញថាបុគ្គល ដែលជាអ្នកដាក់សំណើបានដើតួរនាទីសំខាន់ក្នុងការបង្ហាញឆន្ទៈដើម្បីបង្កើតទំនាក់ទំនងគតិយុត្ត ឬជាការបង្ហាញឆន្ទៈដើម្បីសុំបង្កើតកិច្ចសន្យានាពេលអនាគត ដោយប្រែប្រួលទៅតាមប្រភេទផ្សេងៗនៃសំណើ។ យ៉ាងណាមិញ ការដាក់សំណើក៏អាចធ្វើទៅតាមប្រភេទផ្សេងៗ និងលក្ខណៈពិសេសនៃកិច្ចសន្យា ដែលបុគ្គលមានបំណងចង់បង្កើតនាពេលអនាគត និងម្យ៉ាងវិញទៀត ដោយសំណើត្រូវបានធ្វើការបែងចែកច្រើនប្រភេទរួមមាន សំណើដែលកំណត់អំឡុងពេលនៃការធ្វើស្ទីការ និងសំណើដែលគ្មានកំណត់អំឡុងពេលពិតប្រាកដនៃការធ្វើស្ទីការ ហេតុដូចនេះ ការដកសំណើភាគី គេអាចកំណត់ទៅតាមប្រភេទនៃសំណើ។ ក្នុងអត្ថន័យដែលបានលើកឡើងខាងលើនេះ បានបង្ហាញឲ្យឃើញថា **ករណីសំណើ ដែលមានកំណត់អំឡុងពេលពិតប្រាកដនៃការដកសំណើ** គឺអ្នកដាក់សំណើមានភាពងាយស្រួលក្នុងការដកសំណើ ប្រសិនបើអំឡុងពេលកំណត់បានមកដល់ ហើយអ្នកទទួលសំណើមិនបានធ្វើការឆ្លើយតប ឬធ្វើស្ទីការតបវិញ។

បន្ថែមពីនេះ ចំពោះ**ករណីសំណើដែលមិនមានកំណត់អំឡុងពេលក្នុងការធ្វើស្ទីការតបវិញ ឬសំណើដែលកំណត់អំឡុងពេលនៃការធ្វើស្ទីការ តែអំឡុងពេលដែលកំណត់នោះជាអំឡុងពេលមិនពិតប្រាកដ** ដែលបានបង្កើតជាបញ្ហាប្រឈមចំពោះអ្នកដាក់សំណើ ថាតើអ្នកដាក់សំណើអាចដកសំណើបាននៅពេលណា និងកំណត់អំឡុងពេលយ៉ាងដូចម្ដេច ក្នុងការធ្វើការដកសំណើត្រលប់មកវិញ ករណីអ្នកទទួលសំណើមិនធ្វើការឆ្លើយតប និងអ្នកដាក់សំណើមិនអាចសន្មតបានថាអ្នកទទួលសំណើនិងស្ទីការត្រលប់មកវិញ។

ហេតុនេះហើយទើបក្រមរដ្ឋប្បវេណីកម្ពុជា បានកំណត់អំពីប្រភេទនៃសំណើ និងលក្ខណៈវិនិច្ឆ័យ មួយចំនួនដើម្បីកំណត់លទ្ធភាពឲ្យភាគីដែលជាអ្នកដាក់សំណើអាចមានសិទ្ធិក្នុងការដកសំណើ ក្នុងនោះគេអាចធ្វើការសិក្សាបែងចែកទៅតាមប្រភេទនៃសំណើរវាងការដកសំណើដែលមានកំណត់អំឡុងពេលនៃការធ្វើស្នីការ និងការដកសំណើដែលមិនកំណត់អំឡុងពេលនៃការធ្វើស្នីការ។

✓ **ការដកសំណើដែលកំណត់អំឡុងពេលនៃការធ្វើស្នីការៈ**

បើយោងតាមគោលគំនិតមាត្រានៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ គេអាចកំណត់បានថា ការដកសំណើដែលមានកំណត់អំឡុងពេលនៃការធ្វើស្នីការ ភាគីឬអ្នកដាក់សំណើអាចដកសំណើត្រលប់មកវិញបាននៅពេលដែលអំឡុងពេលកំណត់នៃការធ្វើស្នីការបានមកដល់ ហើយអ្នកទទួលសំណើមិនបានធ្វើការឆ្លើយតប ឬមិនបានធ្វើស្នីការតបវិញ។[12]

បន្ថែមពីនេះករណីភាគីមិនបានកំណត់ច្បាស់លាស់ថា អំឡុងពេលសម្រាប់ស្នីការត្រូវចាប់ផ្តើមគិតពីពេលណា ករណីនេះក្នុងគោលដៅការពារផលប្រយោជន៍អ្នកដាក់សំណើ ក្រមរដ្ឋប្បវេណីបានកំណត់ឲ្យភាគី អាចគិតពីអំឡុងពេល ដោយគិតចាប់ពីថ្ងៃដែលជូនដំណឹងអំពីសំណើ និងសំណើក៏ត្រូវបាត់បង់អានុភាព ដោយស្វ័យប្រវត្តិនៅពេលផុតអំឡុងពេលសម្រាប់ធ្វើស្នីការ និងសំណើត្រូវបាត់បង់អានុភាពដូចគ្នាចំពោះករណី ដែលអ្នកទទួលសំណើបានបដិសេធចំពោះសំណើក្នុងអំឡុងពេលនៃការធ្វើស្នីការនោះ។

---

[12] ម.៣៣៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

✓ **ការដេកសំណើដែលមិនកំណត់អំឡុងពេលនៃការធ្វើស្នីការះ**

ករណីសំណើដែលមិនកំណត់អំឡុងពេលនៃការធ្វើស្នីការ ការដេកសំណើ ភាគីអាចសិក្សាវិភាគពីវិធីបង្កើតសំណើ ដោយក្នុងនោះគេសង្កេតឃើញថា សំណើអាចត្រូវបានបង្កើតនៅក្នុងពេលជាមួយគ្នា ដែលភាគីកំពុងនិយាយគ្នាក្នុងស្ថានដែលអាចធ្វើបានភ្លាមៗ ប្រសិនបើភាគីទទួលសំណើមិនបានយល់ព្រមភ្លាមទេ គឺសំណើនោះត្រូវបាត់បង់អានុភាព។[13] ម្យ៉ាងវិញទៀត យោងតាមគោលការណ៍ទូទៅ សម្រាប់សំណើដែលមិនកំណត់អំឡុងពេលនៃការធ្វើស្នីការ អ្នកស្នើមិនអាចដកសំណើនោះវិញក្នុងអំឡុងពេលសមរម្យទេ។

ការកំណត់បែបនេះ ក្នុងគោលដៅដើម្បីការពារតុល្យភាពនៃផលប្រយោជន៍របស់ភាគីនៃទំនាក់ទំនង និងជៀងវាងការបកស្រាយពីអំឡុងពេលសមរម្យដើម្បីយកជាប្រយោជន៍រៀងៗខ្លួន។ តែផ្ទុយទៅវិញករណីដែលដំណឹងនៃការដេកសំណើនោះបានដល់អ្នកទទួលសំណើនៅក្នុងពេលជាមួយគ្នា និងដំណឹងនៃការដេកសំណើបានដល់អ្នកទទួលសំណើ គេអាចចាត់ទុកបានថាការដេកសំណើមានអានុភាព ពីព្រោះដំណឹងដែលអ្នកទទួលសំណើបានទទួលគឺជាដំណឹងនៃការដេកសំណើ និងមិនបានធ្វើឲ្យអ្នកទទួលសំណើខូចខាតផលប្រយោជន៍ទេ។

---

[13] ម.៣៣៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

## កថាខណ្ឌ២.ស្វីការ

ដូចម្តេចដែលហៅថាស្វីការ? ស្វីការមានអានុភាពនៅពេលណា និងស្វីការអាចធ្វើឡើងតាមវិធីណាខ្លះ? បើយោងតាមគោលគំនិតមាត្រានៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ស្វីការ សំដៅដល់ការបង្ហាញឆន្ទៈដែលទទួលយកសំណើ ឬយល់ព្រមចំពោះសំណើនោះ។[14] ជាទូទៅស្វីការមានអានុភាពនៅពេលដំណឹងនៃការយល់ព្រមបានដល់អ្នកស្នើ ប៉ុន្តែនៅពេលជាមួយគ្នាប្រសិនបើ ដំណឹងនៃការដកស្វីការបានដល់អ្នកស្នើនៅពេលព្រមគ្នានឹងស្វីការដល់ ឬមុនពេលស្វីការដល់នោះ អានុភាពនៃស្វីការមិនត្រូវកើតឡើយ។ បន្ថែមពីនេះតើស្វីការ ត្រូវបែងចែកជាប៉ុន្មានប្រភេទមានអ្វីខ្លះ?

## ១. ប្រភេទផ្សេងៗនៃស្វីការ

ស្វីការ បើយោងតាមគោលគំនិតមាត្រានៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ស្វីការ មិនបានបែងចែកជាប្រភេទផ្សេងៗទេ ក្រៅពីនិយមន័យដែលបានកំណត់ថា ស្វីការ គឺសំដៅដល់ការយល់ព្រមទៅលើសំណើ។ ប៉ុន្តែក្នុងន័យនេះចំពោះទំនាក់ទំនងរបស់ភាគីនៅដំណាក់កាលមុនពេលកិច្ចសន្យាសង្កេតឃើញមានចំណុចវិវាទ ដែលអាចកើតមាននៅអំឡុងពេលធ្វើស្វីការហេតុដូចនេះដើម្បីការពារផលប្រយោជន៍ភាគីនៃទំនាក់ទំនង ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ បានធ្វើការសិក្សាបែងចែកអំពីស្ថានភាពនៃការមកដល់យឺតនៃស្វីការនិងស្ថានភាពនៃស្វីការដែលមានបន្ថែម ឬកែប្រែលក្ខខណ្ឌនៃសំណើដោយធ្វើការសិក្សាដូចខាងក្រោមរួមមាន៖

---

[14] ម.៣៣៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

✓ **ការមកដល់យឺតនៃស្ទីការ**

យោងតាមគោលការណ៍ទូទៅ ការកំណត់អំពីអំឡុងពេលធ្វើស្ទីការស្របតាមលក្ខខណ្ឌសំណើ ករណីសំណើដែលមានកំណត់អំឡុងពេលនៃការធ្វើស្ទីការ និងតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ការមកដល់យឺតនៃស្ទីការត្រូវចាត់ទុកថាស្ទីការនោះបាត់បង់អានុភាពដោយស្វ័យប្រវត្តិ។[15]

ផ្ទុយទៅវិញ គោលការណ៍នៃក្រមរដ្ឋប្បវេណីកម្ពុជា បានធ្វើការបកស្រាយដោយឈរលើគោលការណ៍ សុច្ចរិត និងភាពស្មោះត្រង់ ដោយកំណត់លទ្ធភាពឲ្យភាគីអាចបង្ហាញអំពីមូលហេតុ ឬបង្ហាញភស្តុតាងមួយចំនួន ជុំវិញការមកដល់យឺតនៃស្ទីការ មានន័យថា ការមកដល់យឺតនៃស្ទីការ អ្នកស្នើ ឬអ្នកទទួលសំណើអាចបង្ហាញ ភស្តុតាងអំពីស្ថានភាពជាក់លាក់ ឬមានលទ្ធភាពអាចបង្ហាញថាអ្នកស្នើអាចដឹងថាភាគីម្ខាងទៀតជូនដំណឹងអំពីស្ទីការយឺតយាវគឺស្ទីការនោះមានសុពលភាព។ បន្ថែមពីនេះ ការមកដល់យឺតនៃស្ទីការ អ្នកស្នើអាចចាត់ទុកថា ស្ទីការដែលបានមកដល់អ្នកស្នើក្រោយពេល ឬផុតអំឡុងពេលសម្រាប់ស្ទីការគឺជាសំណើថ្មី ប៉ុន្តែករណីដែលបានលើកឡើងនេះ អនុវត្តបានលុះត្រាតែភាគីនៅតែមានបំណងពិតប្រាកដក្នុងការបង្កើតទំនាក់ទំនងគតិយុត្ត។ ដូចនេះអាចសន្នតបានថា ករណីភាគីអាចដឹងអំពីការមកដល់យឺតនៃស្ទីការ ឬ ករណីអ្នកធ្វើសំណើធ្វេសប្រហែសក្នុងការជូនដំណឹងអំពីការមកដល់យឺតនៃស្ទីការ ស្ទីការនោះមានសុពលភាព។

---

[15] ម.៣៤១.១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

✓ **ស្វីការមានបន្ថែមការកែប្រែលក្ខខណ្ឌនៃសំណើ**

ស្វីការ គឺកំណត់ថាការឆ្លើយតបថាយល់ព្រមចំពោះសំណើ និងជាគោលការណ៍ស្របតាមខ្លឹមសារ នៃក្រមរដ្ឋប្បវេណីកម្ពុជា ការធ្វើស្វីការស្របតាមខ្លឹមសារនៃសំណើសន្មតបានថាមានបង្កើតកិច្ចសន្យា។ តែករណីស្វីការដែលមានការបន្ថែមការកែប្រែលក្ខខណ្ឌលើសំណើ ឬកែប្រែសារជាតុផ្សេងនៃសំណើមិនត្រូវក្លាយជាស្វីការសុពលទេ តែស្វីការនោះមានសុពលភាពជាសំណើថ្មី។[16] ដូចនេះការសន្មតចំពោះការបង្កើតកិច្ចសន្យា គឺលុះត្រាតែអ្នកធ្វើសំណើដើមធ្វើស្វីការចំពោះសំណើថ្មីនោះ។

បន្ថែមពីនេះ ខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជា ក៏បានកំណត់អំពីលទ្ធភាពអ្នកទទួលសំណើ ក្នុងការបន្ថែមឬកែប្រែលក្ខខណ្ឌនៃសំណើ យ៉ាងណាការធ្វើស្វីការដោយមានបន្ថែមការកែប្រែលក្ខខណ្ឌនៃសំណើដែលភ្ជាប់ជាមួយនឹងស្វីការមិនធ្វើឲ្យមានការកែប្រែសាជាតុនៃសំណើត្រូវបានចាត់ទុកថាជាសំណើថ្មី និងស្វីការដែលមានបន្ថែមលក្ខខណ្ឌនោះមានសុពលភាពលុះត្រាតែអ្នកស្នើមិនតវ៉ាភ្លាម។ ក្នុងន័យនេះបង្ហាញថា កិច្ចសន្យាដែលត្រូវបានកើតឡើងដោយស្វីការនោះត្រូវតែស្របតាមអត្ថន័យនៃសំណើដើម និងលុះត្រាតែអ្នកស្នើបានទទួលស្វីការដោយមានបន្ថែមលក្ខខណ្ឌនោះមិនធ្វើការតវ៉ាភ្លាមៗ។

---

[16] ម.៣៤២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

## ២.សុពលភាពនៃស្ទីការ

សុពលភាពនៃស្ទីការ គឺជាលក្ខខណ្ឌកំណត់អានុភាពស្ទីការនិងសន្មតបានថាមានការបង្កើតកិច្ចសន្យា ប៉ុន្តែអ្វីដែលបញ្ហាចោទនៅទីនេះ ថាតើស្ទីការមួយកំណត់អានុភាព ឬកំណត់បានថាមានសុពលភាពទាមទារឲ្យបំពេញនូវលក្ខខណ្ឌអ្វីខ្លះ?

ជាទូទៅនិយមន័យនៃស្ទីការ តាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជាបានកំណត់ថា ស្ទីការ គឺជាការ យល់ព្រមទៅនឹងសំណើ ក្នុងន័យនេះបង្ហាញឲ្យឃើញថា បុគ្គលដែលជាអ្នកទទួលសំណើបានបង្ហាញឆន្ទៈ ថាយល់ព្រមចំពោះសំណើ ឬលក្ខខណ្ឌដែលអ្នកដាក់សំណើបានស្នើ។

ចំណុចដូចបានបង្ហាញខាងលើភាគី អាចធ្វើការពិចារណាអំពីការបង្ហាញឆន្ទៈថាយល់ព្រមចំពោះ សំណើ ដោយឈរលើកទ្រឹស្តីស្វ័យភាពនៃឆន្ទៈសេរីរបស់បុគ្គលឯកជនក្នុងការសម្រេចចិត្តនិងការបង្ហាញឆន្ទៈថាយល់ព្រមដោយមិនមានវិការៈនៃការបង្ហាញឆន្ទៈ គឺអាចចាត់ទុកបានថា ស្ទីការមានសុពលភាព។

បន្ថែមពីការបកស្រាយអំពីសុពលភាពនៃស្ទីការ អាចសិក្សាជុំវិញប្រភេទនៃសំណើ ដោយបានធ្វើការ បែកខាងលើអំពីសំណើដែលមានកំណត់អំឡុងពេលនៃការធ្វើស្ទីការ និងសំណើដែលមិនកំណត់អំឡុងពេលនៃការធ្វើសិក្សាដោយប្រែប្រួលទៅតាមលក្ខខណ្ឌ និងលក្ខណៈពិសេសនៃសំណើដែលភាគីចង់បានចំពោះការបង្កើតកិច្ចសន្យានាពេលអនាគត។

ដូចនេះសុពលភាពនៃស្ទីការ គឺទាមទារនូវលក្ខខណ្ឌនៃការបង្ហាញឆន្ទៈថាយល់ព្រមដោយគ្មានវិការៈ នៃការបង្ហាញឆន្ទៈ និងក្រៅពីអំឡុងពេលដែលបានកំណត់ គឺទាមទារនូវការបំពេញលក្ខខណ្ឌ ដោយប្រែប្រួល ទៅតាមប្រភេទផ្សេងៗនិងលក្ខណៈពិសេសនៃសំណើ ដោយខ្លឹមសារនៃសំណើប្រែប្រួលស្របតាមករណីសិក្សានីមួយៗ។

## ៣.សកម្មភាពដែលចាត់ទុកថាជាស្ទីការ

តើសកម្មភាពណាខ្លះរបស់បុគ្គលដែលត្រូវបានចាត់ទុកថាជាស្ទីការ?

ស្ទីការ ជាទូទៅកំណត់ថាជាការយល់ព្រមទៅនឹងសំណើ ឬជាការយល់ព្រមនឹងការស៊ុំបង្កើតកិច្ចសន្យា មានន័យថាបើបុគ្គលបានធ្វើការឆ្លើយតបថាយល់ព្រមតែម្តង ភាគីអ្នកដាក់សំណើ ឬអ្នកស្នើ មិនពិបាកក្នុងការសិក្សាជុំវិញពីទង្វើឬសកម្មភាពរបស់អ្នកទទួលសំណើទេ ពីព្រោះបញ្ហាប្រឈមជុំវិញទំនាក់ទំនងនៃការអនុវត្ត ក្នុងកាលៈទេសៈមួយចំនួន គឺពិបាកក្នុងការសន្មតអំពីការធ្វើស្ទីការរបស់អ្នកទទួលសំណើ។[17]

ដូចនេះក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ បានកំណត់ករណីមួយចំនួនដែលបង្ហាញថា សកម្មភាព នោះជាស្ទីការមានន័យថា ក្នុងករណីមួយចំនួនដែលកើតមានជាញឹកញាប់នៅក្នុងជីវភាពកិច្ចការជំនួញ ករណីនេះមិនចាំបាច់ឲ្យមានដំណឹងអំពីស្ទីការ ដោយសារការបង្ហាញឆន្ទៈរបស់អ្នកស្នើ

[17] ម.៣៤៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ឬដោយសារទំនៀមទម្លាប់នៃកិច្ចការជំនួញ កិច្ចសន្យាគឺត្រូវកើតឡើងនៅពេលដែលមានសកម្មភាពដែលទទួលស្គាល់ថាជាស្វីការ។

## ផ្នែកទី២.ដំណាក់កាលបង្កើតកិច្ចសន្យា

តើដំណាក់កាលបង្កើតកិច្ចសន្យាសិក្សាអំពីអ្វី? ជាទូទៅនៅពេលសំណើ និងស្វីការត្រូវគ្នា បង្កើតបាន ជាកិច្ចសន្យា។[18] ប៉ុន្តែបញ្ហាចោទទីនេះ គឺស្ថិតនៅក្នុងដំណាក់កាលនៃកិច្ចសន្យា គឺសុពលភាពនៃកិច្ចសន្យាដែលភាគីត្រូវតែបំពេញស្របតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ និងអាចធ្វើការសិក្សាអំពីលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា ដោយសិក្សាបែកចែកអំពីការព្រមព្រៀង និងវិការៈនៃការព្រមព្រៀង សមត្ថភាពនៃកិច្ចសន្យា កម្មវត្ថុ និងមូលហេតុនៃកិច្ចសន្យា និងលក្ខខណ្ឌទម្រង់ដែលត្រូវទាមទារដោយប្រែប្រួលទៅតាមប្រភេទលក្ខណៈពិសេសនៃកិច្ចសន្យានីមួយៗ។

### កថាខណ្ឌ១.លក្ខខណ្ឌគ្រឹះ

ជាទូទៅការសិក្សាអំពីលក្ខខណ្ឌគ្រឹះនៃការបង្កើតកិច្ចសន្យា និស្សិតអាចបានយល់ពីលក្ខខណ្ឌមូលដ្ឋានដែលចាំបាច់ដាច់ខាត និងតម្រូវឲ្យភាគីត្រូវតែបំពេញនៅពេលបង្កើតកិច្ចសន្យារួមមានដូចជាៈ ការព្រមព្រៀងដែលគ្មានវិការៈ សមត្ថភាពភាគីនៃការបង្កើតកិច្ចសន្យា ព្រមទាំងកម្មវត្ថុនិងមូលហេតុនៃការបង្កើតកិច្ចសន្យា។

[18] ម.៣៣៦.១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

## ១.ការព្រមព្រៀង និងវិការៈនៃការបង្ហាញឆន្ទៈ

ការព្រមព្រៀង គឺជាលក្ខខណ្ឌដែលទាមទារតម្រូវឲ្យមាននៅពេលបង្កើតកិច្ចសន្យា ដូចបានសិក្សាកន្លងមកអំពីសំណើ និងស្វីការដែលស្ថិតនៅដំណាក់កាលនៃការចរចារដើម្បីបង្កើតកិច្ចសន្យា។ បន្ថែមពីនេះការសិក្សាអំពីលក្ខខណ្ឌសុពលភាពនៃការបង្កើតកិច្ចសន្យា ស្របតាមខ្លឹមសារនៃច្បាប់សារជាតុ ឬក្រមរដ្ឋប្បវេណីកម្ពុជា ក្នុងគោលដៅការពារផលប្រយោជន៍ភាគីនៃកិច្ចសន្យាចំពោះលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាយ៉ាងណាកុំឲ្យមានការបំពាន ឬការគៀបសង្កត់ខាងឆន្ទៈ និងការបង្ខិតបង្ខំតាមវិធីផ្សេងក្នុងការចុះហត្ថលេខាកិច្ចសន្យា។ ហេតុដូចនេះ វិធាននៃច្បាប់សារជាតុ បានដើរតួរនាទីសំខាន់ក្នុងការកំណត់អំពីលក្ខខណ្ឌឲ្យភាគីត្រូវតែបំពេញ ដូចបានកំណត់ថា ការព្រមព្រៀងត្រូវគិតប្រាកដ និងសំដៅដល់ការព្រមព្រៀងដែលគ្មានវិការៈនៃការព្រមព្រៀង។

វិការៈនៃការព្រមព្រៀង គឺជាលក្ខខណ្ឌធ្វើការឲ្យកិច្ចសន្យាគ្មានសុពលភាព ដូចនេះការបង្កើតកិច្ចសន្យា បើយោងតាមគោលការណ៍ស្វ័យភាពនៃឆន្ទៈសេរីរបស់បុគ្គលឯកជន ភាគីត្រូវមានសិទ្ធិសេរីភាពពេញលេញក្នុងការសម្រេចចិត្តដើម្បីបង្កើតកិច្ចសន្យា សំដៅដល់ការព្រមព្រៀងដែលគ្មានវិការៈនៃការបង្ហាញឆន្ទៈ ករណីកិច្ចសន្យាបង្កើតដោយវិការៈនៃការបង្ហាញឆន្ទៈ តបតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ភាគីអាចអះអាងអំពីការលុបចោលដោយមូលហេតុវិការៈនៃការបង្ហាញឆន្ទៈ។ ប៉ុន្តែបញ្ហាចោទនៅទីនេះ តើអ្វីជាវិការៈនៃការបង្ហាញឆន្ទៈ? តើអ្វីទៅជាជាតុនៃវិការៈក្នុងការបង្ហាញឆន្ទៈដែលជាមូលហេតុនៃការលុបចោលកិច្ចសន្យា?

ដើម្បីឆ្លើយតបនិងបញ្ហាដែលបានលើកឡើងខាងលើ សូមបង្ហាញករណីសិក្សាមួយចំនួនជុំវិញវិការៈ នៃការបង្ហាញឆន្ទៈ ដើម្បីសិក្សាស្វែងយល់បន្ថែមចំពោះស្ថានភាពដែលវិការៈដែលកើតមាននៅក្នុងទំនាក់ទំនង នៃកិច្ចសន្យាដូចខាងក្រោម៖

**<u>ករណីសិក្សាទី១៖</u>**លោក **ក** បានទិញដីX តម្លៃ៣០០០០ដុល្លារសហរដ្ឋអាមេរិកក្នុងគោលដៅចង់បានចំណេញ តែក្នុងរយៈពេលមួយខែក្រោយមកគាត់បានដំណឹងថាទីតាំងដីX នោះរដ្ឋាភិបាលមានគម្រោងរៀបចំជាកន្លែង ចាក់សំរាម បានលឺដូចនេះ លោក ក មានបំណងលក់ដី X នោះចេញ។ ក្រោយមកលោក **ក** បានលឺថាលោក **ខ** មានបំណងចង់ទិញដី ហើយគាត់ក៏បានធ្វើទំនាក់ទំនងទៅលោក **ខ** និងរៀបរាប់អំពីទីតាំងនៃដីX នោះ ព្រមទាំងបានលើកឡើងថា ដីX នោះលោក មិនអាចប្រើប្រាស់ឲ្យអស់លទ្ធភាពទេ ទើបលោក ចង់លក់វាចេញក្នុងតម្លៃ៣០០០០ ដុល្លារ សហរដ្ឋអាមេរិក តើលោក **ខ** យល់យ៉ាងណា? លោក **ក** បានលើកឡើងថា លោកពិតជាចង់បានដីXនោះ ប៉ុន្តែលោកមានប្រាក់ត្រឹម២០០០០ដុល្លារសហរដ្ឋអាមេរិកទេ តើលោក **ក** យល់យ៉ាងណា? លោក **ក** ដោយគិតថាដីមិនអាចប្រើប្រាស់អស់លទ្ធភាពទេ ក៏បានយល់ព្រមលក់ដីX ឲ្យទៅលោក **ខ** ក្នុងតម្លៃ២០០០០ដុល្លារសហរដ្ឋអាមេរិក។ មួយសប្តាហ៍ក្រោយមក លោក **ក** បានទទួលដំណឹងតាមការចុះផ្សាយលើទំព័រការសែតក្នុងស្រុកមួយថា ទីតាំងដីXនោះ រដ្ឋាភិបាលបានចុះហត្ថលេខាជាមួយ នឹងក្រុមហ៊ុនវិនិយោគបរទេសដើម្បីអភិវឌ្ឍន៍ជារមណីយដ្ឋានទេសចរណ៍។

លោក **ក** បានទាក់ទងទៅលោក **ខ** ដោយពន្យល់លោក **ខ** ថាលោក **ខ** លោកមានការយល់ច្រឡំ និងសុំលុបចោលកិច្ចសន្យាលក់ទិញដីX ហើយសុំឱ្យលោក ខ ប្រគល់ដី X នោះត្រឡប់មកវិញ។ លោក **ខ** បានលើកឡើងថាដីX នោះអ្នកឯងបានលក់ឲ្យខ្ញុំហើយ និងបច្ចុប្បន្ន ខ្ញុំកំពុងរៀបចំផ្ទេរសិទ្ធិឲ្យ កូនប្រុសរបស់ខ្ញុំជាចំណងដៃក្នុងថ្ងៃរៀបការ។ បានលឺដូចនេះលោក **ក** បានមកប្រឹក្សាជាមួយអ្នក ថាតើគាត់គួរធ្វើយ៉ាងណាដើម្បីលុបចោលកិច្ចសន្យាទិញលក់ដី X នោះ បើគាត់បានស៊ើបដឹងថា កូនរបស់លោក **ខ** ជាបុគ្គលិកធ្វើការនៅក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យមួយ។ តើអ្នកយល់ថាអ្វីជាវិការៈនៃការបង្ហាញឆន្ទៈ?

**<u>ករណីសិក្សាទី២៖</u>** លោក **ក** មានដីxមួយកន្លែង តម្លៃ៣០០០០ដុល្លារសហរដ្ឋអាមេរិក។ លោក **ក** បានជំពាក់បំណុលលោក **គ** ចំនួនទឹកប្រាក់៤០០០០ដុល្លារសហរដ្ឋអាមេរិក បច្ចុប្បន្ន លោកមានការលំបាកខាងសេដ្ឋកិច្ចជាខ្លាំង និងមានការបារម្ភថា បើគ្មានដំណោះស្រាយអ្វីទេ លោក **គ** ប្រាកដជារឹមអូសដីXជាមិនខាន។ លោក ក បាននឹកឃើញអំពីគំនិតមួយ ហើយប្រឹក្សាជាមួយលោក **ខ** បានបង្កើតស្ថានភាពមិនពិត ដោយលក់ដីX ទៅឲ្យលោក **ខ** និងបានផ្ទេរសិទ្ធិទៅឲ្យលោក **ខ** តាមការចុះបញ្ជី។ មួយខែក្រោយមក លោក **ខ** បានលក់ដីX នោះទៅឲ្យលោក **ឃ** និងផ្ទេរសិទ្ធិតាមការចុះបញ្ជី។ លោក **ក** បានមកប្រឹក្សាជាមួយអ្នក តើគាត់គួរធ្វើយ៉ាងណាដើម្បីទាមទារដីX នោះត្រឡប់មកវិញ។ តើម្ចាស់បំណុល **គ** អាចទទួលបាន ការការពារបែបណា?

តើករណីសិក្សាដែលបានលើកឡើងខាងលើនេះ តើអ្នកយល់យ៉ាងណាចំពោះស្ថានភាពវិការៈនៃការបង្ហាញឆន្ទៈនៃកិច្ចសន្យា តើភាគីអាចអះអាងអំពីការលុបចោលកិច្ចសន្យាឬទេ?

ជាទូទៅការបង្ហាញឆន្ទៈត្រូវគ្នាដោយគ្មានវិការៈរវាងសំណើ និងស្ទីការសន្មតថាមានបង្កើតកិច្ចសន្យា មានន័យថាកិច្ចសន្យាមានអានុភាពនៅពេលដែលការបង្ហាញឆន្ទៈរបស់ភាគីនោះគ្មានវិការៈ។ ផ្ទុយទៅវិញករណី ការបង្ហាញឆន្ទៈមានវិការៈ គឺភាគីនៃកិច្ចសន្យាអាចអះអាងអំពីការលុបចោល ឬមោឃៈ។ ហេតុដូចនេះ ការសិក្សាពីលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា គឺភាគីទាមទារឲ្យបំពេញនូវលក្ខខណ្ឌដែលទាក់ទងទៅនឹងការព្រមព្រៀង កម្មវត្ថុ មូលហេតុ និងសមត្ថភាព។ ចំពោះការព្រមព្រៀងគ្មានវិការៈ បើយោងតាមទ្រឹស្តីស្វ័យភាពនៃឆន្ទៈសេរីរបស់បុគ្គល គឺសំដៅដល់ការបង្ហាញឆន្ទៈដោយគ្មានវិការៈ មានន័យថាការយល់ព្រមរបស់ភាគីមិនគ្រប់គ្រាន់ក្នុងការបង្កើតកិច្ចសន្យាទេ ប្រសិនបើការយល់ព្រមមានវិការៈនៃការបង្ហាញឆន្ទៈ។

✓ **ការបង្ហាញឆន្ទៈមានវិការៈ៖**

ដើម្បីការពារផលប្រយោជន៍ភាគីនៃកិច្ចសន្យា ក៏ដូចជាបុគ្គលឯកជនវិធាននៃច្បាប់សារធាតុផ្នែកឯកជន បានបញ្ញត្តិលំអិតអំពីវិការៈនៃការបង្ហាញឆន្ទៈ។[19]ការបង្ហាញឆន្ទៈដែលមានវិការៈ បើយោងតាមខ្លឹមសារមាត្រា៣៤៥នៃក្រមរដ្ឋប្បវេណីកម្ពុជា ភាគីអាចអះអាងអំពីការលុបចោលកិច្ចសន្យាដោយមូលហេតុនៃការបង្ហាញឆន្ទៈមានវិការៈ មានន័យថា ភាគីអាចលើកមូលហេតុវិការៈនៃការបង្ហាញឆន្ទៈ ដើម្បីអះអាងអំពីការលុបចោលកិច្ចសន្យាទោះបីជាបុគ្គលដែលជាភាគីនោះសុចរិត ឬទុច្ចរិតក៏ដោយ។

[19] ម.៣៤៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

✓ **ធាតុនៃវិការៈនៃការបង្ហាញឆន្ទៈរួមមាន៖**

## ១.១. ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ

តើអ្វីទៅជាការភាន់ច្រឡំ ?រាល់ការបកស្រាយទាំងឡាយណាដែលមិនច្បាស់លាស់ ឬស្រពិចស្រពិល ត្រូវបានចាត់ទុកថាជាការភាន់ច្រឡំ។ ការភាន់ច្រឡំ គឺជាវិការៈនៃការបង្ហាញឆន្ទៈ និងជាមូលហេតុ ដែលធ្វើឲ្យ កិច្ចសន្យាត្រូវលុបចោល ឬចាត់ទុកជាមោឃៈ ជាទូទៅការភាន់ច្រឡំ យោងតាមគោលគំនិតមាត្រាក្រមរដ្ឋប្បវេណីកម្ពុជាត្រូវបានបែងចែកជាប្រភេទផ្សេងៗនៃការភាន់ច្រឡំរួមមាន៖ ការភាន់ច្រឡំចំណុចសំខាន់នៃកិច្ចសន្យា ការភាន់ច្រឡំអំពីចណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬជាការភាន់ច្រឡំចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា និងការភាន់ច្រឡំរួម។[20]

**ការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា៖**

ការភាន់ច្រឡំចំណុចសំខាន់សំដៅលើការភាន់ច្រឡំចំណុចសំខាន់ដែលទ្រទ្រង់ចំពោះលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា និងយោងតាមគោលគំនិតនៃមាត្រា៣៤៦.១នៃក្រមរដ្ឋប្បវេណីកម្ពុជា លក្ខខណ្ឌនៃការភាន់ច្រឡំដែលជាមូលហេតុអាចអះអាងអំពីការលុបចោលកិច្ចសន្យា គឺជាការភាន់ច្រឡំចំណុចសំខាន់នៃកិច្ចសន្យា។[21] មានន័យថា ករណីមានការភាន់ច្រឡំ

---

[20] ម.៣៤៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[21] ម.៣៤៦.១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ធាតុសំខាន់ៗនៃកិច្ចសន្យា គឺភាគីអាចលើកមូលហេតុនៃការបង្ហាញឆន្ទៈមានវិការៈដើម្បីអះអាងអំពីការលុបចោលកិច្ចសន្យា។

ដូចនេះជាគោលការណ៍ ចំពោះការភាន់ច្រឡំទៅលើធាតុសំខាន់ ឬការភាន់ច្រឡំចំណុចសំខាន់នៃកិច្ចសន្យា គឺកំណត់ថាជាមូលហេតុនៃការលុបចោលកិច្ចសន្យា។ មានន័យថា តាមន័យយើងអាចធ្វើការបកស្រាយដោយប្រែប្រួលទៅតាមប្រភេទផ្សេងៗនៃករណីសិក្សានីមួយៗ ដូចខាងក្រោម គឺបើការភាន់ច្រឡំធាតុបន្ទាប់បន្សំនៃកិច្ចសន្យា មិនមែនជាមូលហេតុ ១០០%នៃការលុបចោលកិច្ចសន្យានោះទេ គឺអាស្រ័យលើការយល់ព្រមរបស់ភាគីនៅក្នុងទំនាក់ទំនងនៃកិច្ចសន្យា មានន័យថាភាគីអាចយល់ព្រមទទួលយកនូវការភាន់ច្រឡំដែលជាធាតុបន្ទាប់បន្សំនៃកិច្ចសន្យា។

**ឧទាហរណ៍៖** ការទិញក្រមាដែលច្រឡំពណ៌ រវាងពណ៌ក្រហម និងពណ៌ខៀវ ពេលខ្លះភាគីអាចទទួលយកពណ៌ដែលច្រឡំ ករណីបែបនេះគឺអាស្រ័យទៅលើគូភាគីនៃកិច្ចសន្យា ថាតើគូភាគីយល់ព្រម ឬមិនយល់ព្រមទទួលយកក្រមាដែលខុសពណ៌?។

## ការភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ឬចំណុចដែលខ្លួនយល់ថាសំខាន់ នៅក្នុងការបង្កើតកិច្ចសន្យា៖

គោលគំនិតនៃមាត្រា៣៤៦.២ ចែងអំពីករណីដែលអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំអំពីចំណុច ដែលខ្លួនឯងយល់ដោយអត្តនោម័តថាសំខាន់។ មានន័យថា ភាគីអាចមានការភាន់ច្រឡំធាតុបន្ទាប់បន្សំ ឬជាចំណុចបន្ទាប់បន្សំដែលមិនទ្រទ្រង់លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា។

ប៉ុន្តែក្នុងន័យនេះ ដើម្បីការពារផលប្រយោជន៍ភាគីពីការបំពានសិទ្ធិ ក្រមរដ្ឋប្បវេណីកម្ពុជា បានកំណត់អំពីការការពារចំពោះស្ថានភាពខាងលើមានន័យថា ទោះបីជាបុគ្គលទូទៅបានយល់ថាវាជាធាតុមិនសំខាន់ប៉ុន្តែធាតុបន្ទាប់បន្សំនោះមានលក្ខណៈ ផ្សាភ្ជាប់ទៅនឹងបុគ្គល ដូចនេះដើម្បីបង្ការកុំឲ្យភាគីម្ខាងទៀតទទួលនូវខូចខាតផលប្រយោជន៍ <u>លក្ខខណ្ឌនៃការលុបចោលកិច្ចសន្យាដោយមូលហេតុនៃការភាន់ច្រឡំទៅលើធាតុបន្ទាប់បន្សំ អាចអនុវត្តបាន នៅពេលភាគីម្ខាងទៀតបានដឹងថា</u>វាសំខាន់ចំពោះភាគីម្ខាងទៀតនៃកិច្ចសន្យា។

គោលគំនិតនៃមាត្រាខាងលើនេះ ភាគីអាចលុបចោលកិច្ចសន្យាដោយមូលហេតុនៃការភាន់ច្រឡំលើចំណុចនៃកិច្ចសន្យាដែលភាគីអត្តនោម័តថាសំខាន់បានលុះត្រាតែភាគីម្ខាងទៀតអាចដឹង អំពីការភាន់ច្រឡំនោះ មានន័យថាមូលហេតុនៃការបង្កើតកិច្ចសន្យា គឺមានលក្ខណៈផ្សារភ្ជាប់ទៅនឹងធាតុអត្តនោម័ត ការសម្រេចចិត្តចុះកិច្ចសន្យាពីព្រោះធាតុអត្តនោម័ត ដូចជា<u>កិច្ចសន្យាទិញរថយន្តកើតមានដោយសាររថយន្តមានពណ៌ក្រហម។</u>

**ដើម្បីស្វែងយល់អំពីការភាន់ច្រឡំ ដែលជាមូលហេតុនៃការអះអាងអំពីការលុបចោលកិច្ចសន្យា សូមបង្ហាញករណីសិក្សាខាងក្រោម ដើម្បីធ្វើការត្រិះរិះពិចារណាជុំវិញប្រភេទនៃវិកាៈនៃការបង្ហាញឆន្ទៈ៖**

<u>**ករណីសិក្សាទី៣៖**</u> លោក **ក** បានទិញក្រមាសូត្រខ្មែរ ពណ៌មាសមួយមានតម្លៃ ១៥០ដុល្លារសហរដ្ឋអាមេរិកពីលោក**ខ** នៅហាងលក់វត្ថុអនុស្សាវរីយ៍មួយជិតផ្សារទួលទំពូង ដើម្បីជូនប្រពន្ធគាត់ក្នុងឱកាសជួបជុំគ្រួសារ ញ៉ាំបាយឆ្លងឆ្នាំសាកល ។

នៅពេលមកដល់ផ្ទះ លោក **ក** បានយកក្រមាសូត្រមាសទៅជូនប្រពន្ធ **គ** គាត់ ហើយប្រាប់ថា ប្រពន្ធ **គ** ថាបងបានទិញក្រមាសូត្រមាសដែលអូនពេញចិត្ត ជូនអូនក្នុងឱកាសឆ្លងឆ្នាំសាកល ប្រពន្ធបានបើកប្រអប់ក្រមាមើល ឃើញ ក្រមាអំបោះពណ៌បៃតង។ តើករណីនេះលោក **ក** អាចសុំ លុបចោលកិច្ចសន្យា បាន ឬទេ ?មូលហេតុអ្វី ?

**<u>ករណីសិក្សាទី៤៖</u>**

លោក **ក** បានបញ្ជាទិញរថយន្តX ពីក្រុមហ៊ុនលោក **ខ** ដែលមាន បញ្ជាក់តម្លៃតាងដោយF និងមានពណ៌ក្រហម ដើម្បីប្រើប្រាស់ក្នុងកិច្ចការ ជំនួញ។ មួយខែក្រោយមក លោក **ខ** បានទាក់ទងទៅលោក **ក** ថារថយន្តបាន មកដល់ សូមអញ្ជើញមកបំពេញបែបបទដើម្បីទទួលយករថយន្ត។ នៅពេល លោក **ខ** បានឃើញរថយន្តដែលខ្លួនបញ្ជាទិញនោះប្រែជាពណ៌ខ្មៅ ក៏មាន ប្រតិកម្មភ្លាមថា ខ្លួនបានបញ្ជាទិញរថយន្តF ពណ៌ក្រហម មិនមែនពណ៌ខ្មៅទេ ដូចនេះលោក **ខ** សូមលុបចោលកិច្ចសន្យាទិញលក់។ ប៉ុន្តែលោក **ខ** បានលើក ឡើងថាលោក **ក** បានចុះកិច្ចសន្យាបញ្ជាទិញហើយ ដូចនេះត្រូវតែយក និង បង់ថ្លៃជូនក្រុមហ៊ុន ម្យ៉ាងពណ៌រថយន្តមិនបានបញ្ជាក់ក្នុងកិច្ចសន្យាបញ្ជាទិញ ទេ? តើអ្នកយល់យ៉ាងណាចំពោះករណីសិក្សាខាងលើ ?

**<u>ការភាន់ច្រឡំរួម៖</u>** ក្នុងករណីដែលភាគីទាំងសងខាងមានការភាន់ច្រឡំអំពី ចំណុចសំខាន់ៗនៃកិច្ចសន្យា ឬចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាង បានយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា ទោះបីជាភាគីម្ខាងទៀត មិនមានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតនៃកិច្ចសន្យាក៏

ដោយ ក៏ភាគីដែលបានភាន់ច្រឡំនោះ អាចអះអាងអំពីលុបចោលកិច្ចសន្យា ដោយហេតុថាការបង្ហាញឆន្ទៈមានវិការៈ(ការភាន់ច្រឡំរួមគ្នា)។[22]

ការភាន់ច្រឡំជាមូលហេតុនៃការលុបចោលកិច្ចសន្យា ឬជាលក្ខខណ្ឌនៃការលុបចោលកិច្ចសន្យាករណី មានការភាន់ច្រឡំកើតឡើង គឺមិនចាំបាច់ទាមទារឲ្យភាគីម្ខាងទៀតបានដឹងអំពីការភាន់ច្រឡំបានកើតឡើងទេ គឺអាចលុបចោលកិច្ចសន្យាបាន ដោយមូលហេតុវិការៈនៃការបង្ហាញឆន្ទៈ។ ផ្ទុយទៅវិញគោលការណ៍ដែលលើកឡើងខាងលើ អនុវត្តចំពោះគូភាគីនៃកិច្ចសន្យា តែមិនអនុវត្តចំពោះតតិយជនសុច្ចរិត និងគ្មានកំហុស។

<u>**ករណីសិក្សាទី៥៖**</u> លោក **ក** បានលក់ផ្ទាំងគំនូរមួយផ្ទាំងទៅឲ្យលោក **ខ** ដោយគិតនិងជឿជាក់ថា ផ្ទាំងគំនូរនោះបានគូរដោយវិចិត្រករXដែលមានឈ្មោះល្បី។ តែការពិតផ្ទាំងគំនូរមួយផ្ទាំងនោះ ត្រូវបានគូរ ដោយវិចិត្រករZ។ ករណីនេះភាគីនៃកិច្ចសន្យាមានការភាន់ច្រឡំរួមគ្នា ទោះបីជាភាគីម្ខាងទៀតគ្មានលទ្ធភាពគ្រប់គ្រាន់ និងដឹងអំពីការភាន់ច្រលំរបស់ភាគីម្ខាងទៀតក៏ដោយ ប្រសិនបើភាគីមានការភាន់ច្រឡំអំពីចំណុចសំខាន់នៃ កិច្ចសន្យាគឺភាគីអាចអះអាងអំពីការលុបចោលកិច្ចសន្យា។ តើអ្នកយល់យ៉ាងណាចំពោះគោលគំនិតនៃការភាន់ច្រឡំរួម? តើអ្នកណាជាអ្នកមានសិទ្ធិស្នើសុំលុបចោល កិច្ចសន្យា?

[22] ម.៣៤៦.៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

## ១.២. ការឆបោក

តើដូចម្តេចដែលហៅថាការឆបោក? ការឆបោកទាមទារនូវលក្ខខណ្ឌអ្វីខ្លះ? ជាទូទៅសកម្មភាពបោកបញ្ឆោត ឬបំភ្លៃការពិត សំដៅដល់សកម្មភាពប្រាប់អង្គហេតុមិនពិត ឬសកម្មភាពលាក់អង្គហេតុ ឬបំភ្លៃអង្គហេតុ ប៉ុន្តែចាំបាច់ត្រូវស្ថិតនៅក្នុងកម្រិតដែលមិនត្រូវបានអនុញ្ញាតដោយសង្គម។

ចេតនានៃការឆបោក គឺដើម្បីឲ្យការឆបោកកើតមាន លុះត្រាតែអ្នកឆបោកបានដឹងថាអង្គហេតុដែលខ្លួននិយាយនោះជាអង្គហេតុមិនពិត។[23]

ប៉ុន្តែករណីដែលអ្នកប្រាប់អង្គហេតុមិនពិតដោយមិនដឹងថាខុសពីការពិតទេនោះអ្នកប្រាប់អង្គហេតុ មិនមានចេតនាឆបោកទេ។ ហេតុដូចនេះការឆបោកមិនកើតមានទេ។ ការឆបោក គឺជាស្ថានភាពដែលបុគ្គល (ភាគីម្ខាងនៃកិច្ចសន្យាឬតតិយជន) បានធ្វើឲ្យភាគីម្ខាងទៀតយល់ច្រឡំទៅលើអង្គហេតុ និងបង្ហាញឆន្ទៈដោយសារសកម្មភាពបំភ្លៃអង្គហេតុ ឬជាសកម្មភាពលាក់បាំងអង្គហេតុពិត។ យោងតាមគោលគំនិតមាត្រាក្រមរដ្ឋប្បវេណី ភាគីដែលបង្ហាញឆន្ទៈថាមានការឆបោក អាចលុបចោលកិច្ចសន្យាទោះបីការឆបោកត្រូវបានធ្វើឡើងដោយភាគីម្ខាង ឬដោយទង្វើរបស់តតិយជន។ ប៉ុន្តែបញ្ហាចោទនៅទីនេះថាតើអ្នកណាជាអ្នកបង្ហាញឆន្ទៈដើម្បីលុបចោលកិច្ចសន្យា? ហើយអ្នកណាជាអ្នកឆបោក និងអ្នកណាជាអ្នកត្រូវបានគេឆបោក? តើគេធ្វើការការពារតតិយជនអំពីការឆបោកបានយ៉ាងដូចម្តេច?

---

[23] ម.៣៤៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**ដើម្បីសិក្សាស្វែងយល់អំពីការឆបោក សូមបង្ហាញករណីសិក្សាមួយចំនួនស្តីពីការឆបោក ដើម្បីធ្វើការ ត្រិះរិះពិចារណា ជុំវិញគោលគំនិតនៃក្រមរដ្ឋប្បវេណីចំពោះបញ្ញត្តិស្តីពីការឆបោកដូចខាងក្រោម៖**

**ករណីសិក្សាទី៦៖** B បានគិតថាចង់បានដី X ដែលជាកម្មសិទ្ធិរបស់ A។ ប៉ុន្តែA ហាក់មិនចង់លក់ដី X នោះទេ ហេតុនេះ B បាននិយាយបោកប្រាស់Aថា ដីX នោះកាលពីមុនបានសាងសង់រោងចក្រផលិតឱសថហើយ បច្ចុប្បន្នក៏នៅមានសារធាតុពុលចេញពីដីដែរ។ A បានជឿសម្តីរបស់ B ហើយក៏យល់ព្រមលក់ដីទៅឲ្យB។ ថ្ងៃបន្ទាប់ A បានដឹងពីការបោកប្រាស់របស់ B តើ A អាចលុបចោលកិច្ចសន្យាលក់ទិញដោយមូលហេតុនៃការឆបោកបានទេ?

**ករណីសិក្សាទី៧៖** Bបានទៅពិភាក្សាជាមួយC ដែលជាមិត្តភក្តិថា ខ្ញុំកំពុងមានបញ្ហាដោយសារ A មិនយល់ព្រម លក់ដី X មកឲ្យខ្ញុំសោះ។ C គិតថានឹងជួយ B ហើយបាននិយាយបោកប្រាស់Aថា ដី X កាលពីមុន បានសាងសង់ រោងចក្រផលិតឱសថ ហើយបច្ចុប្បន្នក៏នៅមានសារធាតុពុលចេញពីដីដែរ។ ហេតុនេះ A បានសម្រេចចិត្តលក់ដី X ឲ្យទៅ B ។ B មិនបានដឹងអំពីការណ៍ដែល C បោកប្រាស់Aទេ ប៉ុន្តែស្រាប់តែ A បានប្រាប់ថាព្រមលក់ដី X ទៅឲ្យ B ភ្លាមនោះ B ក៏បានគិតថា C បានជួយអ្វីមួយជាមិនខាន។ តើ A អាចលុបចោលកិច្ចសន្យាជាមួយ B ដោយ មូលហេតុនៃការឆបោកបានដែរឬទេ?

## ១.៣. ព័ត៌មានមិនពិត

នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបានបង្ហាញដោយភាគីម្ខាងនោះខុសពីការពិត ប៉ុន្តែប្រសិនបើភាគី នោះដឹងថា ហេតុនោះមិនមែនជាការពិតខ្លួននឹងមិនបង្ហាញឆន្ទៈទេ ភាគីនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ។[24]មាត្រាខាងលើនេះ គេធ្វើការការពារតតិយជនដោយផ្អែកទៅលើស្ថានភាពនៃព័ត៌មានមិនពិត ដែលបង្ហាញដោយភាគីម្ខាងទៀត។ ករណីភាគីបង្ហាញនូវព័ត៌មានមិនពិតដោយចេតនាត្រូវក្លាយជាការឆបោក អនុវត្តមាត្រា៣៤៧នៃក្រមរដ្ឋប្បវេណី។ មានន័យថា ករណីភាគីម្ខាងទៀតមិនមានចេតនាបង្ហាញអំពីព័ត៌មានមិនពិត ដូចនេះកិច្ចសន្យាមិនអាចលុបចោលដោយសារការឆបោកទេ ប៉ុន្តែករណីនេះកិច្ចសន្យាអាចលុបចោលដោយសារមូលហេតុនៃការភាន់ច្រឡំ។

**កំណត់សំគាល់អំពីព័ត៌មានមិនពិតនិងការភាន់ច្រឡំ៖**

ករណីព័ត៌មានមិនពិតត្រូវបានបង្ហាញដោយភាគី ម្ខាងទៀត គឺអាចមានករណីច្រើន ដែលអ្នកបង្ហាញឆន្ទៈនោះមានការភាន់ច្រឡំ ហេតុដូច្នេះការលុបចោលកិច្ចសន្យាអាចអនុញ្ញាតដោយហេតុផលនៃការភាន់ច្រឡំ។ ប៉ុន្តែមូលហេតុនៃការលុបចោលកិច្ចសន្យាដោយសារការភាន់ច្រឡំ គឺត្រូវតែបំពេញលក្ខខណ្ឌនៃមាត្រា៣៤៦.១នៃក្រមរដ្ឋប្បវេណី មានន័យថាភាគីត្រូវបង្ហាញថាការភាន់ច្រឡំត្រូវទាក់ទងនឹងចំណុចសំខាន់ៗនៃកិច្ចសន្យានិងភាគីម្ខាងទៀតអលទ្ធភាពក្នុងការដឹងពីការភាន់ច្រឡំនេះ។

---

[24] ម.៣៤៨.១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

## ១.៤ ការរំលោភបំពានលើស្ថានភាព

ករណីភាគីម្ខាងនៃកិច្ចសន្យាបានប្រើឋានៈ ឬតួនាទីរបស់ខ្លួនដែលមានជាអាទិភាពខាងផ្នែកសេដ្ឋកិច្ច ឬសង្គមដើម្បីបង្ខំឲ្យភាគីម្ខាងទៀតចុះកិច្ចសន្យា។[25] ការរំលោភបំពានលើស្ថានភាព ទោះបីមិនមែនជា ការគម្រាមកំហែង ប៉ុន្តែបានបង្ហាញឲ្យឃើញអំពីស្ថានភាពមួយ ដែលបង្ខំភាគីធ្វើសម្រេចចិត្តខុសពីឆន្ទៈពិតប្រាកដ។ ជាគោលការណ៍ ការរំលោភបំពានលើស្ថានភាពសំដៅដល់ការប្រើប្រាស់ឋានៈខុសស្ថានភាពដោយបង្ខំឲ្យភាគីចុះហត្ថលេខាលើកិច្ចសន្យា ទើបចាត់ទុកថាជាការរំលោភបំពានលើស្ថានភាព ដែលជាមូលហេតុនៃការលុបចោលកិច្ចសន្យាមានន័យថាជាការប្រើប្រាស់ឋានៈមិនត្រឹមត្រូវ។

## ១.៥. ការគម្រាមកំហែង

បុគ្គលដែលបង្ហាញឆន្ទៈដោយសារមានការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬពីតតិយជន អាចអះអាងអំពីការលុបចោលនូវកិច្ចសន្យាបានដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ។[26] ការបង្ហាញឆន្ទៈដោយសារការគម្រាមកំហែង ក៏ជាការបង្ហាញឆន្ទៈដែលអ្នកបង្ហាញឆន្ទៈគ្មានបំណងដែរ ហេតុដូច្នេះ មាត្រានេះបានការពារអ្នកបង្ហាញឆន្ទៈ ដោយអនុញ្ញាតឲ្យអ្នកបង្ហាញឆន្ទៈលុបចោលកិច្ចសន្យា ដែលខុសគ្នាអំពីករណីឆបោក ក្នុងករណីនៃការគម្រាមកំហែងដែលធ្វើដោយតតិយជន ក្រមនេះបានអនុម័តយកជំហរដែលកិច្ចសន្យាអាចលុបចោលបាន ទោះបីជាភាគីម្ខាងទៀតគ្មានលទ្ធភាពដឹងពីការគម្រាមកំហែងក៏ដោយ។

---

[25] ម.៣៤៩.១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[26] ម.៣៥០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

**សូមបង្ហាញអំពីករណីសិក្សាមួយចំនួនស្តីពីការគម្រាមកំហែងដើម្បីធ្វើការត្រិះរិះពិចារណាជុំវិញគោលគំនិតនៃក្រមរដ្ឋប្បវេណីចំពោះបញ្ញត្តិស្តីពីការគម្រាមកំហែងដូចខាងក្រោម៖**

**ករណីសិក្សាទី៨៖** B ចង់ទិញដី X ដែលជាកម្មសិទ្ធិរបស់A ហើយBក៏បានដាក់សំណើទៅAប៉ុន្តែត្រូវបាន A បដិសេធ។ B បានមកពិភាក្សាជាមួយ C ដែលជាមិត្តភក្តិ។ C បានដឹងថា Aកំពុងផិតក្បត់ជាមួយស្រីផ្សេង ដែលមិនមែនជាប្រពន្ធ។ ហេតុនេះ C គិតថានឹងជួបB ដោយនិយាយគំរាមទៅ A ថា ប្រសិនបើមិនលក់ដី X ឲ្យទៅ B ទេ ខ្ញុំនឹងនិយាយអំពីការផិតក្បត់របស់អ្នកប្រាប់ប្រពន្ធរបស់អ្នក។ ហេតុនេះ A គ្មានវិធីផ្សេង ក៏បានលក់ដី X ទៅឲ្យ B។ ក្រោយមក B បានលក់ដី X ឲ្យទៅ D។ ក្នុងករណីនេះតើ A អាចលុបចោលកិច្ចសន្យាលក់ទិញ ដោយមូលហេតុនៃការគម្រាមកំហែង ហើយអះអាងចំពោះ D និងឲ្យ D ប្រគល់ដី X ត្រឡប់វិញបានដែរ ឬទេ?

## ១.៦. អំពើកេងចំណេញហួសហេតុ

ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យាដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬភាពល្ងង់ ឬការខ្វះការពិសោធន៍ ហើយបានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតនោះអាចលុបចោលកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ[27]។ ក្នុងករណីដែលភាគីម្ខាង បានធ្វើកិច្ចសន្យាដោយឆ្លៀតឱកាស ដែលភាគីម្ខាងទៀតកំពុងជួបការលំបាកខាងផ្នែក

[27] ម.៣៥១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

សេដ្ឋកិច្ច ឬភាពល្ងង់ ឬខ្វះពិសោធន៍ហើយបានកេងចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីអាចលុបចោលកិច្ចសន្យាបានដោយបង្ហាញឆន្ទៈមានវិការៈ។ យោងតាមគោលគំនិតមាត្រា៣៥១នៃក្រមរដ្ឋប្បវេណីបានបញ្ញត្តិអំពីការកេងចំណេញហួសហេតុ គឺមានតែភាគីទទួលរងការខូចខាតផលប្រយោជន៍ប៉ុណ្ណោះដែលអាចអះអាងអំពីការលុបចោលកិច្ចសន្យា។

## ១.៧អំពីការរំលោភបំពានលើស្ថានភាពនិងអំពើកេងចំណេញហួសហេតុ

ការបែងចែកអំពីការរំលោភបំពានលើស្ថានភាព និងអំពើកេងចំណេញហួសហេតុ គឺទី១នៅក្នុងស្ថានភាពដែលភាគីបានប្រើប្រាស់ឋានៈមិនត្រឹមត្រូវក្នុងការបង្ខំភាគីឲ្យចុះហត្ថលេខាកិច្ចសន្យា ដោយឆ្លៀតឱកាសនៅពេលដែលភាគីមានការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬផ្នែកសង្គម ឬបានប្រើប្រាស់នូវស្ថានភាពមិនត្រឹមត្រូវផ្សេងទៀត ដែលភាគីមិនអាចប្រឆាំងតបបាន។ ទី២គឺ នៅក្នុងស្ថានភាពដែលភាគីស្ថិតក្នុងភាពទន់ខ្សោយផ្នែកសេដ្ឋកិច្ចឬភាពល្ងង់ដោយខ្វះបទពិសោធន៍ បានកេងចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យា( ទំនាក់ទំនងរវាងអាជីវករនិងអ្នកប្រើប្រាស់ )។

## ១.៨. ឋបនីយផ្លូវចិត្ត

ឋបនីយផ្លូវចិត្ត គឺជាការបង្ហាញឆន្ទៈដែលធ្វើដោយដឹងថា ការបង្ហាញឆន្ទៈនោះមិនពិតទេ។ ឧទាហរណ៍៖ ករណីAការបង្ហាញឆន្ទៈធ្វើប្រទានកម្ម ទៅឲ្យ B ដែលការពិតA មិនមានឆន្ទៈបែបនេះទេ[28]។

[28] ម.៣៥២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

យោងតាមគោលការណ៍ទូទៅការបង្ហាញឆន្ទៈមានវិការៈភាគីអាចលុបចោលកិច្ចសន្យាបាន។ដូចនេះបើA បានបង្ហាញឆន្ទៈមានវិការៈ មានន័យថាA អាចលុបចោលប្រទានកម្មបាន ចុះបើករណីយកិច្ចសន្យាប្រទានកម្មត្រូវបានលុបចោល ហើយព្រមគ្នានោះបានធ្វើឲ្យB ខូចប្រយោជន៍យ៉ាងខ្លាំងហើយ B មិនបានដឹងថាការបង្ហាញឆន្ទៈរបស់Aនោះមិនពិតទេ។ ដូចនេះតើគួរការពារA ឬ B?

**សូមបង្ហាញអំពីករណីសិក្សាមួយចំនួនស្តីពីវិបនីយផ្លូវចិត្តដើម្បីធ្វើការត្រិះរិះពិចារណាជុំវិញគោលគំនិតនៃក្រមរដ្ឋប្បវេណីចំពោះបញ្ញត្តិស្តីពីវិបនីយផ្លូវចិត្តដូចខាងក្រោម៖**

**<u>ករណីសិក្សាទី៩៖</u>** Aជាសង្សាររបស់B ប៉ុន្តែក្រោយមក A បានស្រលាញ់C ហើយក៏ទៅនិយាយសុំបែកគ្នាជាមួយB។ ប៉ុន្តែB មិនព្រមបែកគ្នាឡើយ។ A បាននិយាយលេងសើចថា ប្រសិនបើព្រមបែកគ្នាខ្ញុំឲ្យលុយ ១០០០ដុល្លារ។ B បានលឺបែបនេះហើយ បានជឿថា A និយាយមែន ក៏សម្រេចបែកគ្នាជាមួយA។ តើB អាចទាមទារឲ្យA បង់ប្រាស់១០០០ដុល្លារបានដែរ ឬទេ?

**<u>ករណីសិក្សាទី១០៖</u>** A បាននិយាយលេងសើចជាមួយBថា ប្រសិនបើព្រមបែកគ្នាខ្ញុំឲ្យប្រាក់៥០០០ដុល្លារ។ B បានដឹងថាA មិនមានលុយច្រើនបែបនេះទេ ហេតុនេះB ដឹងថាA កំពុងនិយាយលេងសើច។ ក្រោយមកA និងB បែកគ្នា ហើយបានកន្លងផុតរយៈពេល១ឆ្នាំ។ ដោយសារB ត្រូវបានក្រុមហ៊ុនបណ្តេញចេញ ធ្វើឲ្យមានបញ្ហាជីវភាព ក៏ស្រាប់តែនឹកឃើញទារលុយ ៥០០០ដុល្លារពីរA។ តើAអាចបដិសេធបានដែរ ឬទេ?

**<u>ករណីសិក្សាទី១១៖</u>** Aជាសង្សាររបស់B ប៉ុន្តែក្រោយមកA បានស្រលាញ់C ហើយក៏និយាយសុំបែកគ្នាជាមួយB។ ប៉ុន្តែBមិនព្រមបែកគ្នាឡើយ។ A បាននិយាយលេងសើចថា ប្រសិនបើព្រមបែកគ្នា ខ្ញុំឲ្យឡានLexus នេះ។ Bបានលឺបែបនេះ ដឹងថាA កំពុងនិយាយលេងសើច ហើយគិតចង់ធ្វើឲ្យA មានបញ្ហា ក៏បានបើកឡាន Lexus តាមអំពើចិត្ត និងលក់ទៅឲ្យ D ដែលជាមិត្តភក្តិក្នុងតម្លៃ១០០០០ដុល្លារ។ ប្រសិនបើA ទាមទារD ឲ្យប្រគល់ឡាន Lexus តើD អាចបដិសេធបានទេ?

## ១.៩. ការបង្ហាញឆន្ទៈមិនពិត

កិច្ចសន្យាដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិតដែលត្រូវបានធ្វើឡើងដោយការឃុបឃិតជាមួយនឹងភាគីម្ខាងទៀតត្រូវចាត់ទុកមោឃៈ។[29]

**សូមបង្ហាញអំពីករណីសិក្សាមួយចំនួនស្តីពីការបង្ហាញឆន្ទៈមិនពិត ដើម្បីធ្វើការត្រិះរិះពិចារណាជុំវិញគោលគំនិតនៃក្រមរដ្ឋប្បវេណីចំពោះបញ្ញត្តិស្តីពីការបង្ហាញឆន្ទៈមិនពិតដូចខាងក្រោម៖**

**<u>ករណីសិក្សាទី១២៖</u>** A ជំពាក់បំណុលជាច្រើន ហើយបារម្ភខ្លាចម្ចាស់បំណុលដាក់ពាក្យសុំអនុវត្តដោយបង្ខំទៅលើទ្រព្យសម្បត្តិរបស់ខ្លួន។ ហេតុនេះ ដើម្បីជៀសផុតពីការអនុវត្តដោយបង្ខំទៅលើដីX ដែលជាកម្មសិទ្ធិរបស់ខ្លួន A ក៏សម្រេចចិត្តក្លែងធ្វើជាលក់ដីទៅឲ្យB ដែលជាមិត្តភក្តិ។

---

[29] ម.៣៥៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ដូចនេះ A បានទៅពិភាក្សាជាមួយB និងបានផ្ទេរការចុះបញ្ជីកម្មសិទ្ធិលើដីX ទៅឲ្យB។

ក្រោយមក A បានសងបំណុលទាំងអស់ទៅម្ចាស់បំណុលរួចរាល់ ហើយលែងមានការបារម្ភពីការអនុវត្តដោយបង្ខំដែរ ក៏បាននិយាយទៅកាន់B ឲ្យផ្ទេរការចុះបញ្ជីដីX មកឲ្យខ្លួនវិញ។ ប៉ុន្តែ B មិនព្រមផ្ទេរការចុះបញ្ជីដីX ទៅឲ្យA វិញទេ។ តើA អាចអះអាងអំពីការមោឃភាពនៃកិច្ចសន្យារវាងA និងB និងទាមទារឲ្យB ផ្ទេរការចុះបញ្ជីមកខ្លួនវិញដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិតឬទេ?

## ២.សមត្ថភាពនៃកិច្ចសន្យា

សមត្ថភាពរបស់ភាគីនៃកិច្ចសន្យា គឺជាលក្ខខណ្ឌចាំបាច់មួយដែលទាមទារនៅពេលបង្កើតកិច្ចសន្យា ការកំណត់បែបនេះក្នុងគោលដៅដើម្បីការពារផលប្រយោជន៍ភាគីនៃកិច្ចសន្យា ជៀសវាសការបំពានផ្សេងៗ និងការកេងប្រវ័ញ្ចដោយប្រការណាមួយ ហេតុដូចសមត្ថភាពក្នុងការត្រិះរិះពិចារណា និងការបង្ហាញឆន្ទៈរបស់បុគ្គល ជាធាតុសំខាន់មួយដែលច្បាប់តម្រូវនៅពេលបង្កើតកិច្ចសន្យា។ ជាទូទៅ សមត្ថភាពរបស់គូភាគីនៃកិច្ចសន្យា ស្របតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ សំដៅទៅលើបុគ្គល ដែលមានសមត្ថភាពតាមផ្លូវច្បាប់ ដោយធ្វើការបែងចែករវាង រូបវន្តបុគ្គល និងនីតិបុគ្គល។ សម្រាប់រូបវន្តបុគ្គល គឺជានីតិជនដែលមានអាយុចាប់ពី១៨ឆ្នាំ ជាសមត្ថជន មិនមែនជាជនដែលមានបញ្ហាវិបាល្លាសខាងបញ្ញាស្មារតី ឬអាចជាអនីតិជនដែលទទួលបានអត្តាធិនភាព មានន័យថាជាជនដែលទទួលបានសិទ្ធិតាមរយៈការស្នើសុំ។

បន្ថែមពីនេះចំពោះករណីនីតិបុគ្គល សំដៅដល់នីតិបុគ្គលដែលមានបុគ្គលភាពគតិយុត្ត ចំពោះការចុះហត្ថលេខាលើបង្កើតកិច្ចសន្យា គឺត្រូវបានធ្វើតាមរយៈរូបវន្តបុគ្គលដែលតំណាងឲ្យនីតិបុគ្គល ចំពោះការបង្កើតកិច្ចសន្យាដែលទាមទារឲ្យមានសំណុំឯកសារបញ្ជាក់អំពីទំហំនៃសិទ្ធិតំណាងក្នុងការបង្កើតទំនាក់ទំនងគតិយុត្ត។

## ៣.កម្មវត្ថុ និងមូលហេតុនៃកិច្ចសន្យា

តើអ្វីជាកម្មវត្ថុ និងមូលហេតុនៃកិច្ចសន្យា? ជាទូទៅបើយោងតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជា កម្មវត្ថុត្រូវបានកំណត់ជាវត្ថុស្របច្បាប់ដែលមាននៅពេលចុះកិច្ចសន្យា ឬកម្មវត្ថុអាចជាកាតព្វកិច្ចស្របតាមតម្រូវការរបស់ភាគីនៃកិច្ចសន្យា។ មូលហេតុនៃកិច្ចសន្យា សំដៅទៅលើវត្ថុបំណងរបស់ ភាគីនៃកិច្ចសន្យា ដោយបានថាភាគីអាចមានមូលហាតុរៀងខ្លួនក្នុងការបង្កើតកិច្ចសន្យា ប៉ុន្តែយ៉ាងណាកម្មវត្ថុ និងមូលហេតុនៃកិច្ចសន្យាត្រូវតែស្របច្បាប់និងទំនៀមទម្លាប់ល្អប្រពៃ។

បន្ថែមពីនេះ យោងតាមគោលគំនិតនៃមាត្រា៣៥៤នៃក្រមរដ្ឋប្បវេណីកម្ពុជា អាចបែងចែកអំពីភាពផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ និងភាពផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អ។

***<u>ភាពផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ៖</u>*** មាត្រាខាងលើបានចែងថាទោះបីជាការបង្ហាញឆន្ទៈរបស់ភាគីទាំងពីរត្រូវបានធ្វើដោយគ្មានមូលហេតុនៃមោឃភាព ឬការលុបចោលក៏ដោយ ក៏កិច្ចសន្យាត្រូវចាត់ទុកជាមោឃៈដែរ ប្រសិនបើអត្ថន័យនៃកិច្ចសន្យាផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ

សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ។ បញ្ញត្តិអនុវត្តដោយបង្ខំជាបញ្ញត្តិដែលបដិសេធអានុភាពនៃសកម្មភាពដែលផ្ទុយនឹងបញ្ញត្តិនេះ។គំនិតដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ គឺកម្រិតទំហំនៃសេរីភាពក្នុងការធ្វើកិច្ចសន្យា។ កិច្ចសន្យាដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំត្រូវចាត់ទុកជាមោឃៈ។

<u>ភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ៖</u> តើសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អជាអ្វី?សណ្តាប់ធ្នាប់សាធារណៈ គឺសំដៅទៅលើសណ្តាប់ធ្នាប់ប្រទេសឬសង្គម។ ទំនៀមទម្លាប់ល្អ គឺសំដៅគោលគំនិតជាសីលធម៌ទូទៅនៅក្នុងសង្គម។ កិច្ចសន្យា ដែលមានខ្លឹមសារផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ជាកិច្ចសន្យាគ្មានសុពលភាព។ចំពោះបញ្ហានៃការមោឃភាពមួយផ្នែក ជាទូទៅការមោឃភាពកិច្ចសន្យាបានធ្វើឲ្យប៉ះពាល់បុគ្គលជាច្រើន ដែលមានផលប្រយោជន៍ ដែលធ្វើសកម្មភាពដោយគិតថាកិច្ចសន្យានោះមានសុពលភាព។ ដូចនេះដើម្បីកាត់បន្ថយផលប៉ះពាល់ នៃបញ្ហាមោឃភាពឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន វាជាការសមរម្យដែលត្រូវទុកជាមោឃៈផ្នែកដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ប៉ុណ្ណោះ។

## កថាខណ្ឌ២.លក្ខខណ្ឌទម្រង់

តើលក្ខខណ្ឌទម្រង់ចាំបាច់ដាច់ខាត ត្រូវតែមាននៅពេលបង្កើតកិច្ចសន្យាឬទេមូលហេតុអ្វី? យោងតាមវិធានច្បាប់កម្ពុជា លក្ខខណ្ឌទម្រង់អាចតម្រូវឲ្យមានចំពោះកិច្ចសន្យាមួយចំនួនដែលមានតម្លៃថ្លៃ ក្នុងគោលដៅ

ដើម្បីការពារផលប្រយោជន៍របស់គូភាគីនៃកិច្ចសន្យា។ ម្យ៉ាងទៀតករណីភាគីម្ខាងមិនអនុវត្តកាតព្វកិច្ច ភាគីអាចយកលក្ខខណ្ឌទម្រង់នេះមកធ្វើជាមូលហេតុនៃការអះអាង ដើម្បីទាមទារឲ្យទទួលបាននូវការការពារផលប្រយោជន៍ស្របច្បាប់។

ការសិក្សាពីខ្លឹមសារនៃច្បាប់កម្ពុជាកន្លងមក ចំពោះកិច្ចសន្យាដែលមានតម្លៃថ្លៃ គឺមានកំណត់ក្នុងមាត្រានៃក្រឹត្យច្បាប់លេខ៣៨ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវនៅក្រៅកិច្ចសន្យា និងបន្តរ មកទៀត មានការកំណត់អំពីលក្ខខណ្ឌទម្រង់ដែលប្រែប្រួលទៅតាមប្រភេទ និងលក្ខណៈពិសេសនៃកិច្ចសន្យានីមួយៗ ដូចមានកំណត់នៅក្នុងខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ។

ជាទូទៅនៅក្នុងជីវភាពឯកជនការបង្កើតកិច្ចសន្យាមិនទាមទាតម្រូវឲ្យបំពេញនូវលក្ខខណ្ឌទម្រង់ទេ តែលក្ខខណ្ឌតតាំង ការពារផលប្រយោជន៍គឺទាមទារឲ្យគូភាគីគិតអំពីលក្ខខណ្ឌទម្រង់ស្របច្បាប់។កិច្ចសន្យាការបង្កើតអាចធ្វើឡើងដោយផ្ទាល់មាត់ ឬជាលិខិតលាយលក្ខណ៍អក្សរដោយប្រែប្រួលទៅតាមប្រភេទ និងលក្ខណៈពិសេសនៃកិច្ចសន្យា ក្នុងគោលដៅដើម្បីការពារផលប្រយោជន៍គូភាគីនៃកិច្ចសន្យា។

បន្ថែមពីនេះលក្ខខណ្ឌទម្រង់នៃការបង្កើតកិច្ចសន្យា ស្របតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជាអាស្រ័យតាមជម្រើសរបស់ភាគី អាចធ្វើឡើង

ជាលិខិតឯកជន[30] ឬជាលិខិតយថាភូត[31]។ ប៉ុន្តែចំពោះករណីបង្កើតកិច្ចសន្យាពិសេសមួយចំនួនដូចជាកិច្ចសន្យាលក់ទិញអចលនវត្ថុ គឺទាមទារបំពេញជាទម្រង់លិខិតយថាភូត។ ហេតុដូចនេះ ដើម្បីបង្កើតកិច្ចសន្យាទាមទារឲ្យភាគីត្រូវបំពេញនូវលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់រួមមាន ការព្រមព្រៀងដែលគ្មានវិការៈនៃការព្រមព្រៀង ភាគីត្រូវមានសមត្ថភាពដែលច្បាប់ទទួលស្គាល់ កិច្ចសន្យាការបង្កើតត្រូវមានកម្មវត្ថុ និងមូលហេតុត្រូវតែស្របច្បាប់និងទំនៀមទម្លាប់ដ៏ល្អប្រពៃ និងលក្ខខណ្ឌទម្រង់ត្រូវបំពេញដោយប្រែប្រួលទៅតាមប្រភេទ និងលក្ខណៈពិសេសនៃកិច្ចសន្យានីមួយៗ ទើបកំណត់ថាកិច្ចសន្យា មានអានុភាពអនុវត្ត ឬមានសុពលភាព។

បន្ថែមពីនេះនៅពេលកិច្ចសន្យាមួយកំណត់អានុភាព តើភាគីនៃកិច្ចសន្យាត្រូវប្រតិបត្តិកិច្ចសន្យាយ៉ាងដូចម្តេច? ករណីភាគីមិនប្រតិបត្តិ តើភាគីម្ខាងទៀតអាចទាមទារឲ្យទទួលបានការការពារអ្វីខ្លះ? ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលបានលើកឡើងខាងលើ អាចធ្វើការសិក្សាអំពីដំណាក់កាលក្រោយពេលកិច្ចសន្យា។

## ផ្នែកទី៣. ដំណាក់កាលក្រោយពេលកិច្ចសន្យា

ដំណាក់កាលក្រោយពេលកិច្ចសន្យាធ្វើការសិក្សាអំពីអ្វី? តើមូលហេតុអ្វីតម្រូវឲ្យសិក្សាអំពីដំណាក់កាលក្រោយពេលកិច្ចសន្យា? ជាទូទៅ

---

[30]លិខិតឯកជន៖ កិច្ចសន្យាដែលធ្វើជាលិខិតឯកជន គឺសំដៅទៅលើទម្រង់ជាលាយលក្ខណ៍អក្សរដែលធ្វើឡើងដោយការព្រមព្រៀងរវាងគូភាគីនៃកិច្ចសន្យា។

[31]លិខិតយថាភូត៖ យោងតាមខ្លឹមសារនៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី លិខិតយថាភូតសំដៅដល់លិខិតដែលធ្វើឡើងដោយសារការី ឬមន្ត្រីមានសមត្ថកិច្ច។

មានសំណួរមួយចំនួនជុំវិញដំណាក់កាលក្រោយពេលកិច្ចសន្យា ដោយធ្វើការចោទសួរថា បន្ទាប់ពីកិច្ចសន្យាមួយកំណត់អានុភាព ឬមានសុពលភាព តើភាគីទទួលបានសិទ្ធិ និងករណីយកិច្ចអ្វីខ្លះ និងកិច្ចសន្យានោះមានអានុភាពយ៉ាងដូចម្តេច? ដើម្បីឆ្លើយតបទៅនឹងបញ្ហាដូចបានលើកឡើងខាងលើ យើងអាចធ្វើការសិក្សាបែងចែក អំពីគោលការណ៍កំណត់អានុភាពនៃកិច្ចសន្យា(កថាខណ្ឌ១), ការសង្គ្រោះចំពោះការបំពានកិច្ចសន្យា(កថាខណ្ឌ២) និង មោឃភាព និងការលុបចោល(កថាខណ្ឌ៣)។

## កថាខណ្ឌ១.គោលការណ៍កំណត់អានុភាពនៃកិច្ចសន្យា

តើកិច្ចសន្យាអនុវត្តនៅពេលណា? តើភាគីនៃកិច្ចសន្យាត្រូវអនុវត្តកិច្ចសន្យាយ៉ាងដូចម្តេច? និងករណីភាគីមិនអនុវត្តកាតព្វកិច្ច ឬធ្វេសប្រហែសក្នុងការអនុវត្តកាតព្វកិច្ច តើមានមូលហេតុដែលនាំឲ្យមានការទទួលខុសត្រូវដែរឬទេ? យោងតាមគោលការណ៍ទៅ កិច្ចសន្យាសំដៅលើការព្រមព្រៀងរវាងបុគ្គលពីរ ឬច្រើន ដែលបង្កើត កែប្រែរំលត់សិទ្ធិ និងកាតព្វកិច្ចមួយចំនួនដែលទាក់ទិននិងគូភាគី និងកិច្ចសន្យាមួយកំណត់អានុភាព គឺបានបង្កើតសិទ្ធិនិងករណីយកិច្ចនៅពេលសំណើត្រូវគ្នាជាមួយនិងស្ទីការ ឬអាចកំណត់បានថាកិច្ចសន្យាមានអានុភាពនៅពេលកិច្ចសន្យានោះមានសុពលភាព។

បន្ថែមពីនេះចំពោះការអនុវត្តកិច្ចសន្យា ភាគីអាចមានការព្រមព្រៀងដើម្បីកំណត់អំឡុងពេលចាប់ផ្តើម និងការបញ្ចប់អាស្រ័យទៅតាមជម្រើសរបស់គូរភាគី។ ម្យ៉ាងទៀត ដោយធ្វើការបកស្រាយថាកិច្ចសន្យា គឺជាច្បាប់របស់គូភាគី ដូចនេះអាចកំណត់បានថាកិច្ចសន្យាមានអានុភាព

ចំពោះគូភាគី និងកិច្ចសន្យាអាចមានអានុភាពចំពោះតតិយជន ករណីភាគីមានការព្រមព្រៀងបន្ថែមឲ្យតតិយជនមានសិទ្ធិ ឬមានផលប្រយោជន៍ពាក់ព័ន្ធនៅក្នុងកិច្ចសន្យា។ ករណីមានវិវាទពាក់ព័ន្ធនឹងការបកស្រាយកិច្ចសន្យាក្នុងគោលដៅការពារផលប្រយោជន៍គូរភាគី ច្បាប់សារធាតុក៏បានកំណត់ឲ្យចៅក្រមមានសិទ្ធិចូលរួមអន្តរាគមន៍ក្នុងការបកស្រាយកិច្ចសន្យា ដូចនេះអាចកំណត់បានថាកិច្ចសន្យាមានអានុភាពចំពោះចៅក្រម។

## កថាខណ្ឌ២. ការសង្គ្រោះចំពោះការបំពានកិច្ចសន្យា

តើការសង្គ្រោះចំពោះការបំពានកិច្ចសន្យាកើតមាននៅពេលណា? ហើយទម្រង់ណាខ្លះដែលចាត់ទុកថាជាការបំពាន? និងករណីដែលមានការបំពានកើតឡើង តើភាគីអាចមានសិទ្ធិទាមទារឲ្យទទួលបាននូវការសង្គ្រោះយ៉ាងដូចម្តេច?

## ១.បទប្បញ្ញត្តិទូទៅស្តីពីការមិនអនុវត្តកាតព្វកិច្ច

ជាទូទៅការបំពានកើតមាននៅពេលដែលភាគីមិនអនុវត្តកាតព្វកិច្ចដែលកើតពីកិច្ចសន្យា ប៉ុន្តែបញ្ហាចោទនៅទីនេះ ថាតើទម្រង់ណាខ្លះ ដែលចាត់ទុកថាជាការមិនអនុវត្តនូវកាតព្វកិច្ចដែលចាត់ទុកថាជាការបំពាន និងភាគីដែលទទួលរងការបំពាន គឺមានសិទ្ធិទាមទារទទួលបាននូវការសង្គ្រោះក្នុងករណីដែលមានការបំពានកើតឡើង។ យោងតាមខ្លឹមសារមាត្រានៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ បានកំណត់ថាការបំពានសំដៅដល់ការមិនអនុវត្តកាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យា ហើយទម្រង់នៃការមិនអនុវត្តកាតព្វកិច្ចមានដូចជា៖ ករណីកូនបំណុលមិនអនុវត្តកាតព្វកិច្ចឲ្យទាន់ពេល

កំណត់ត្រូវអនុវត្តដោយសារការយឺតយ៉ាវក្នុងការអនុវត្ត(ក), ករណីអលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច(ខ), ករណីកូនបំណុលមិនបានអនុវត្តឲ្យបានពេញលេញតាមខ្លឹមសារនៃកាតព្វកិច្ច(គ) និងករណីផ្សេងទៀតដែលគ្មានការអនុវត្តតាមខ្លឹមសារនៃកាតព្វកិច្ច។[32]ក្នុងន័យនេះ ការកំណត់ថាភាគីមិនអនុវត្តកាតព្វកិច្ចដែលកើតពីកិច្ចសន្យា លុះត្រាតែភាគីមិនបានអនុវត្តស្របទៅតាមទម្រង់ណាមួយ ទើបចាត់ទុកថាមិនអនុវត្តកាតព្វ ជាហេតុនាំឲ្យមានការបំពាន និងភាគីទទួលរងនូវការបំពានមានសិទ្ធិទាមទារឲ្យទទួលបាននូវការសង្គ្រោះចំពោះការបំពានកិច្ចសន្យា។

បន្ថែមពីនេះម្ចាស់បំណុលដែលទទួលរងនូវការបំពាននៅក្នុងករណីដែលភាគីមិនអនុវត្តកាតព្វកិច្ច គឺមានសិទ្ធិទាមទារឲ្យអនុវត្តដោយបង្ខំ សិទ្ធិទាមទារសងសំណងនៃការខូតខាត និងសិទ្ធិទាមទាររំលាយកិច្ចសន្យាដោយយោងតាមបញ្ញត្តិចាប់ពីផ្នែកទី២ ដល់ផ្នែកទី៤នៃជំពូកទី៤នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧។

## ១.១. ការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច

ជាទូទៅការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យាត្រូវចាត់តទុកថាមានការបំពាន ដែលនាំឲ្យភាគីទទួលរងនូវការបំពានមានសិទ្ធិទាមទារឲ្យទទួលបាននូវការសង្គ្រោះ។[33] បន្ថែមពីនេះ ដើម្បីងាយស្រួលកំណត់អំពីការយឺតយ៉ាវ ក្នុងការមិនអនុវត្តកាតព្វកិច្ចរបស់ភាគីនៃកិច្ចសន្យា ក្រមរដ្ឋប្បវេណីកម្ពុជាក៏បានបញ្ញត្តិអំពីទម្រង់ផ្សេងៗអំពីការយឺតយ៉ាវ

[32] ម.៣៩០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[33] ម.៣៩១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

នៃការមិនអនុវត្តកាតព្វកិច្ចដោយធ្វើការបែងចែកទៅតាមប្រភេទផ្សេងៗ និងលក្ខណៈនៃកិច្ចសន្យានីមួយៗមានដូចជា៖

- ✓ **ប្រសិនបើមានកំណត់ពេលពិតប្រាកដសម្រាប់អនុវត្តកាតព្វកិច្ចនៅពេលដល់ការកំណត់នោះ៖**

ករណីនេះអនុវត្ត ចំពោះប្រភេទនៃកិច្ចសន្យាកំណត់ពេលពិតប្រាកដសម្រាប់អនុវត្តកាតព្វកិច្ច ករណីនេះភាគីមានភាពងាយស្រួលក្នុងការកំណត់អំពីទម្រង់នៃការមិនអនុវត្តកាតព្វកិច្ច ដោយភាគីអាសន្មតបានថាករណីដល់ពេលកំណត់អនុវត្តហើយ ភាគីមានការយឺតយ៉ាវ ចាត់ទុកថា មានការបំពានកើតឡើង និងភាគីដែលទទួលរងនូវការបំពានមានសិទ្ធិទាមទារឲ្យទទួលបានការសង្គ្រោះចំពោះការបំពានដែលកើតមាន។

- ✓ **ប្រសិនបើមានកំណត់ពេលមិនពិតប្រាកដសម្រាប់ការអនុវត្តកាតព្វកិច្ចនៅពេលកូនបំណុលនោះដឹងថាដល់ពេលកំណត់៖**

ករណីនេះអនុវត្តចំពោះប្រភេទនៃកិច្ចសន្យា ដែលមានកំណត់ពេលមិនពិតប្រាកដសម្រាប់ការអនុវត្តកាតព្វកិច្ច និងការយឺតយ៉ាវក្នុងការអនុវត្តកើតមាននៅពេល កូនបានដឹងថាដល់ពេលកំណត់អនុវត្តហើយ តែនៅតែមិនអនុវត្តកាតព្វកិច្ច ដោយចាត់ទុកថាការបំពានកើតមាន ភាគីមានសិទ្ធិទាមទារឲ្យទទួលបាននូវការសង្គ្រោះចំពោះការបំពានដែលកើតមាន។

- ✓ **ប្រសិនបើមិនបានកំណត់ពេលសម្រាប់អនុវត្តកាតព្វកិច្ចនៅពេលកូនបំណុលនោះបានទទួលការទាមទារឲ្យអនុវត្ត៖**

ករណីនេះ អនុវត្តចំពោះកិច្ចសន្យាដែលមិនកំណត់ពេលសម្រាប់ការអនុវត្តកាតព្វកិច្ច ដោយនៅពេលដល់កំណត់អនុវត្តហើយ កូនបំណុល

ទទួលបាននូវការទាមទារឲ្យអនុវត្តកាតព្វកិច្ច តែកូនបំណុលនៅតែមិនអនុវត្តកាតព្វកិច្ច ចាត់ទុកថាជាការយឺតយ៉ាវក្នុងការអនុវត្ត ដូចនេះការបំពានកើតមាន ភាគីដែលទទួលរងនូវការបំពានមានសិទ្ធិទាមទារឲ្យទទួលបាននូវការសង្គ្រោះ។

## ១.២. អលទ្ធភាពក្នុងការអនុវត្ត

តើអ្វីទៅជាអលទ្ធភាពក្នុងការអនុវត្ត ជាទូទៅចំពោះទំនាក់ទនងគតិយុត្តមួយកំណត់អនុភាព ភាគីត្រូវតែប្រតិបត្តិកាតព្វកិច្ចដោយគោរពគោលការណ៍សុច្ចរិត និងភាពស្មោះត្រង់ ករណីភាគីមិនមានលទ្ធភាពក្នុងការអនុវត្តទេ ការអនុវត្តកាតព្វកិច្ចត្រូវក្លាយជាអលទ្ធភាព ដោយត្រូវបានវាយតម្លៃថាមិនអាចធ្វើកើតតាមស្ថានភាពសង្គម ឬសេដ្ឋកិច្ច។ ដូចនេះអលទ្ធភាពក្នុងការអនុវត្ត ត្រូវចាត់ទុកថាការបំពានកើតមាន ដូចនេះភាគីដែលទទួលរងនូវការបំពាន មានសិទ្ធិទាមទារឲ្យទទួលបាននូវការសង្គ្រោះចំពោះការបំពានកិច្ចសន្យា[34]។

## ១.៣. ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ

តើអ្វីទៅជាការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ? ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញសំដៅ លើករណីដែលកូនបំណុលបានអនុវត្តកាតព្វកិច្ច តែការផ្តល់តាវកាលិកមិនពេញលេញ ឬករណីដែលបានអនុវត្ត

[34] ម.៣៩២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ដែលមួយផ្នែកនៃកាតព្វកិច្ច ឬករណីផ្សេងៗទៀត ដែលគ្មានការអនុវត្តកាតព្វកិច្ចឲ្យបានពេញលេញតាមខ្លឹមសារកាតព្វកិច្ចនៃកិច្ចសន្យា។[35]

ជាទូទៅការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ ត្រូវបានចាត់ទុកថាជាការមិនអនុវត្តកាតព្វកិច្ចនិងចាត់ទុកថាការបំពានកើតមាន និងភាគីដែលទទួលរងនូវការបំពាន មានសិទ្ធិទាមទារឲ្យទទួលបាននូវការសង្គ្រោះចំពោះការបំពានកិច្ចសន្យា។

## ១.៤. ករណីផ្សេងទៀតដែលមិនអនុវត្តកាតព្វកិច្ច

ក្រៅពីទម្រង់នៃកាតព្វកិច្ចដូចបានរៀបរាប់ខាងលើ ក៏អាចមានករណីបំពានផ្សេងទៀតដែលកើតមាន និងត្រូវបានចាត់ទុកថាជាការបំពាន និងភាគីអាចធ្វើការបកស្រាយ ដើម្បីទាមទារឲ្យទទួលបាននូវការសង្គ្រោះចំពោះការបំពានកិច្ចសន្យា ដោយប្រែប្រួលទៅតាមប្រភេទនិងលក្ខណៈពិសេសនៃកិច្ចសន្យានីមួយៗ។[36]

## ១.៥. ពហុមធ្យោបាយសង្គ្រោះ

ជាទូទៅការសង្គ្រោះកើតមាននៅពេលមានការបំពានកើតមាន និងការបំពានកើតមាននៅពេលដែលភាគីមិនអនុវត្តកាតព្វកិច្ច ទៅតាមទម្រង់ណាមួយដូចបានបញ្ញត្តិនៅក្នុងមាត្រានៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧។ បន្ថែមពីនេះ យោងតាមគោលគំនិតនៃក្រមរដ្ឋប្បវេណី ភាគីទទួលរងនូវការបំពាន គឺមានសិទ្ធិទាមទារឲ្យទទួលបាននូវការសង្គ្រោះតាមវិធីច្រើនយ៉ាង

[35] ម.៣៩៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[36] ម.៣៩៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ដូចជា ការទាមទារឲ្យអនុវត្តកាតព្វកិច្ចដោយបង្ខំ, ការទាមទារសំណងខូចខាត និងការទាមទារនូវការរំលាយកិច្ចសន្យា[37]។

ម្យ៉ាងទៀតចំពោះករណីដែលមធ្យោបាយសង្គ្រោះមានច្រើនយ៉ាង គឺអនុញ្ញាតឲ្យភាគីដែលទទួលរងនូវការបំពានអាចជ្រើសរើសនូវមធ្យោបាយណាមួយ ឬច្រើន កុំឲ្យតែមធ្យោបាយនោះមានភាពផ្ទុយគ្នា។

## ២. ការឲ្យអនុវត្តកាតព្វកិច្ចដោយបង្ខំ

ជាទូទៅករណីមានបំពានកើតមាន ភាគីទទួលរងនូវការបំពានមានសិទ្ធិទាមទារឲ្យទទួលបាននូវការសង្គ្រោះតាមវិធីច្រើនយ៉ាង តែករណីការឲ្យអនុវត្តកាតព្វកិច្ចដោយបង្ខំដោយតុលាការ ត្រូវបានអនុវត្តចំពោះករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចតាមការស្ម័គ្រចិត្ត លើកលែងតែកាតព្វកិច្ចមួយចំនួនមានលក្ខណៈមិនអាចអនុវត្តដោយបង្ខំបាន និងនីតិវិធីអនុវត្តដោយបង្ខំត្រូវអនុវត្តតាមក្រមនីតិវិធីរដ្ឋប្បវេណី។[38]

## ៣.សំណងនៃការខូចខាត

តើសំណងនៃការខូចខាតកើតមាននៅពេលណា ?ជាទូទៅសំណងនៃការខូតខាត កើតមាននៅពេលដែលភាគីមិនអនុវត្តកាតព្វកិច្ច និងចាត់ទុកថាជាការបំពាន ចំពោះភាគីដែលទទួលរងនូវការបំពានដោយមូលហេតុនៃការមិនអនុវត្តនូវកាតព្វកិច្ច មានសិទ្ធិទាមទារសំណងនៃការខូចខាត។[39]

---

[37] ម.៣៩៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[38] ម.៣៩៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[39] ម.៣៩៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ប៉ុន្តែបញ្ហាចោទនៅទីនេះ ថាតើការទាមទារសំណងនៃការខូតខាតតម្រូវឲ្យបំពេញនូវលក្ខខណ្ឌអ្វីខ្លះ?

យោងតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជា ចំពោះទ្រឹស្តីសំណងនៃការខូចខាតក្នុងករណីដែលកូនបំណុលមិនបានអនុវត្តកាតព្វកិច្ច គឺម្ចាស់បំណុលអាចទាមទារសំណងនៃការខូចខាតដែលកើតឡើង ដោយសារការមិនអនុវត្តកាតព្វកិច្ចនោះបាន។ ប៉ុន្តែ ក្នុងករណីដែលកូនបំណុលមានសំអាងបញ្ជាក់ថា ខ្លួនគ្មានកំហុស ចំពោះការមិនអនុវត្តកាតព្វកិច្ចនោះទេ កូនបំណុលត្រូវរួចផុតពីការទទួលខុសត្រូវក្នុងការសងសំណងខូចខាត។

ម្យ៉ាងទៀតក្នុង ករណីដែលកូនបំណុលឱ្យអ្នកដទៃទៀតធ្វើជាអ្នកជំនួយដើម្បីឱ្យជួយអនុវត្តកាតព្វកិច្ច កូនបំណុលនោះមិនអាចរួចផុតពីការទទួលខុសត្រូវក្នុងការសងសំណងខូចខាតបាន លើកលែងតែកូនបំណុលនោះមានសំអាងបញ្ជាក់ថា ខ្លួនគ្មានកំហុសក្នុងការជ្រើសតាំង និងការត្រួតពិនិត្យអ្នកជំនួយទេ ហើយអ្នកជំនួយនោះក៏គ្មានកំហុសដែរ។

## ៤.ការរំលាយកិច្ចសន្យា

តើការរំលាយកិច្ចសន្យាកើតមាននៅពេលណា? យោងតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជាបានកំណត់ថា ភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញអាចរំលាយកិច្ចសន្យាបានភ្លាមៗ ក្នុងករណីដែលភាគីម្ខាងទៀតបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ[40]។

[40] ម៤០៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ដូចនេះលក្ខខណ្ឌនៃការរំលាយកិច្ចសន្យា កើតមាននៅពេលមានការបំពានធ្ងន់ធ្ងរ ប៉ុន្តែបញ្ហាចោទទីនេះដូចម្តេចដែលហៅថាការបំពានធ្ងន់ធ្ងរ និងភាគីទទួលរងនូវការបំពានធ្ងន់ធ្ងរនោះមានសិទ្ធិរំលាយកិច្ចសន្យា?

✓ **ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ៖**

យោងតាមខ្លឹមសារមាត្រានៃក្រមរដ្ឋប្បវេណីកម្ពុជា ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ សំដៅទៅលើករណីដែលភាគីម្ខាងមិនអាចសម្រេចនូវគោលបំណងនៃកិច្ចសន្យាបាន ដោយសារការបំពានរបស់ភាគីម្ខាងទៀតនិងត្រូវចាត់ទុកថាមានការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ[41]ក្នុងករណីដូចជា៖

ក.ភាគីម្ខាងនៃកិច្ចសន្យា បានដាស់តឿនភាគីម្ខាងទៀតដែលមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ ដោយមានកំណត់អំឡុងពេលសមរម្យដើម្បីឱ្យអនុវត្តកាតព្វកិច្ចហើយកាតព្វកិច្ចមិនត្រូវបានអនុវត្តក្នុងអំឡុងពេលនោះ។

ខ.ភាគីម្ខាងនៃកិច្ចសន្យាមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ក្នុងកិច្ចសន្យា ក្នុងករណីដែលគោលបំណងនៃកិច្ចសន្យាមិនបានសម្រេចសោះបើភាគីមិនអនុវត្តកាតព្វកិច្ចតាមពេលកំណត់នោះ។

គ.ភាគីម្ខាងនៃកិច្ចសន្យា មិនអាចអនុវត្តករណីយកិច្ចផ្តល់តាវកាលិកចម្បងរបស់ខ្លួនបានទេ។ ឃ. ការបំពានកិច្ចសន្យាមានភាពហួសហេតុ ដែលធ្វើឱ្យបាត់បង់នូវទំនុកចិត្តរវាងគូភាគី ហើយមិនអាចជឿជាក់ថា នឹងអនុវត្តកាតព្វកិច្ចនាអនាគតបាន។ ដូចនេះភាគីនៃកិច្ចសន្យាដែលទទួលរងនូវការបំពានដូចករណីដែលបានកំណត់ខាងលើ ត្រូវចាត់ទុកថាទទួលរងនូវការបំពានធ្ងន់ធ្ងរ និងមានសិទ្ធិក្នុងការរំលាយកិច្ចសន្យា។

---

[41] ម.៤០៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

## កថាខណ្ឌ៣. ការមោឃៈភាព និងការលុបចោល

គោលការណ៍ទូទៅគេបានសង្កេតឃើញថា ទំនាក់ទំនងរវាងសិទ្ធិ និងករណីយកិច្ចរបស់បុគ្គលត្រូវបានបង្កើតឡើងតាមរយៈកិច្ចសន្យា។

មានន័យថាយោងតាមអានុភាពនៃកិច្ចសន្យា យើងអាចកំណត់ថា អ្នកមានសិទ្ធិ គឺជាម្ចាស់បំណុល និងអ្នកមានករណីយកិច្ច គឺជាកូនបំណុល និងគ្រប់រាល់ការបង្កើតកិច្ចសន្យាត្រូវតែពិនិត្យអំពីលក្ខខណ្ឌសុពលភាពនៃការបង្កើតកិច្ចសន្យា ដើម្បីកំណត់ថាកិច្ចសន្យានោះមានអានុភាពគតិយុត្តរឺមិនមាន។ ឧទាហរណ៍ដូចជាករណីដែលបានភាគីបង្កើតកិច្ចសន្យា ដែលមានអត្ថន័យប្រឆាំងទៅនឹងផលប្រយោជន៍របស់ជាតិទាំងមូល.... ដែលអានុភាពកិច្ចសន្យាត្រូវបានបដិសេធ ដែលជាលក្ខខណ្ឌ យើងត្រូវពិចារណាអំពីមោឃភាព និងការលុបចោល។ មានន័យនេះដែល គឺអាចធ្វើការបដិសេធអានុភាពនៃកិច្ចសន្យាតាមរយៈមោឃភាព ឬការលុបចោល។

- **ភាពខុសគ្នារវាងមោឃភាព និងការលុបចោល៖**

តើមោឃភាព និងការលុបចោលមានលក្ខណៈដូច និងខុសគ្នាយ៉ាងដូចម្តេច? ជាទូទៅមោឃភាព គឺជាទណ្ឌកម្មចំពោះលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យានិងការលុបចោលយោងតាមបញ្ញត្តិក្រមរដ្ឋប្បវេណីកម្ពុជាបានកំណត់អំពីលក្ខខណ្ឌមួយចំនួន ដែលផ្តល់លទ្ធភាពឲ្យគូភាគីអាចសុំអះអាងអំពីការលុបចោលកិច្ចសន្យា ប៉ុន្តែទោះជាលក្ខខណ្ឌនៃការមោឃៈភាព និងការលុបចោលត្រូវបានកំណត់ផ្សេងគ្នា តែចំណុចរួមដែលភាគីមើលឃើញ គឺការមោឃភាព និងការលុបចោល ដែលបានធ្វើឲ្យកិច្ចសន្យានោះបាត់បង់អានុភាពតាមផ្លូវច្បាប់។ ប៉ុន្តែដើម្បីសិក្សាឲ្យបានច្បាស់អំពីភាពខុសគ្នារវាងមោឃភាព និងការលុបចោល គឺគួរពិចារណាលើចំណុចមួយចំនួនដូចខាង

ក្រោមរួមមាន៖ តើអ្នកណាអាចធ្វើការអះអាងអំពីមោឃភាព និងការលុបចោលបាន, តើការមោឃភាព និងការលុបចោលអាចផ្តល់សច្ចានុម័តបាន ឬទេ? តើការមោឃភាព និងកាលុបចោលមានកម្រិតពេលវេលាដែរ ឬទេ?

ដើម្បីធ្វើការឆ្លើយតបទៅនឹងបញ្ហាដែលបានលើកខាងលើ គឺយើងអាចសិក្សាបន្ថែមអំពីខ្លឹមសារលំអិត និងគោលគំនិតចំបងនៃមាត្រា៣៥៦នៃក្រមរដ្ឋប្បវេណីកម្ពុជាដែលបានកំណត់អំពីសកម្មភាពក្នុងផ្នែកទី៣ (មោឃភាព និងការលុបចោល) ក្នុងនោះសកម្មភាព គឺបានសំដៅទៅលើកិច្ចសន្យា ឬសកម្មភាពឯកតោភាគី។ ចំណុចដែលបានលើឡើងខាងលើនេះ សូមធ្វើការកត់សម្គាល់អំពីខ្លឹមសារជាមូលដ្ឋាន និងការសិក្សាស្វែងយល់សម្រាប់អ្នកអានមាត្រានៃក្រមរដ្ឋប្បវេណីនៅក្នុងផ្នែកទី៣ ដោយឲ្យធ្វើការវិភាគ និងពិចារណាបន្ថែមអំពីខ្លឹមសារនៃពាក្យកិច្ចសន្យា និងសកម្មភាពឯកតាភាគីដែលបានប្រើប្រាស់នៅត្រង់ចំណុចនៃផ្នែកទី៣ខាងលើ ដើម្បីងាយស្រួលក្នុងការស្វែងយល់អំពីអត្ថន័យ ឬគោលគំនិតនៃមាត្រាដែលកំណត់នៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ស្តីពីមោឃៈភាព និងការលុបចោល។

✓ **អំពីការមោឃភាព៖**

បើយោងគោលគំនិតនៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ការមោឃៈភាពសំដៅលើសកម្មភាព ដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ជនណាក៏អាចអះអាងនូវការមោឃភាពនៃកិច្ចសន្យានោះបាន។[42] ក្នុងន័យនេះចង់បង្ហាញឲ្យឃើញថា ដោយសារលក្ខខណ្ឌទម្រង់ និងលក្ខខណ្ឌដែលត្រូវទាមទារដោយក្រមមិនត្រូវបានបំពេញដូចនេះកិច្ចសន្យាត្រូវចាត់ទុកជាមោឃៈ។ បន្ថែមពីនេះ

[42] ម.៣៥៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ក្នុងគោលដៅដើម្បីការពារផលប្រយោជន៍រួម ឬផលប្រយោជន៍សាធារណៈជនទូទៅ គឺជនណាក៏អាចអះអាងអំពីការមោឃៈភាពបានដែរ។

ដូចនេះបើផ្អែកទៅតាមខ្លឹមសារនៃមាត្រាខាងលើ សកម្មភាពដែលចាត់ទុកមោឃភាពរួមមានដូចជា៖ សកម្មភាពផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ, សកម្មភាពដែលផ្ទុយនឹងសណ្តាប់ធ្នាប់និងទំនៀមទម្លាប់ល្អ និងសកម្មភាពដែលផ្ទុយនឹងទម្រង់ដែលត្រូវបានទាមទារដោយច្បាប់។ ក្រៅពីនេះ គេសង្កេតឃើញថា សកម្មភាពផ្សេងទៀតត្រូវបានចាត់ទុកជាមោឃៈគឺតាមរយៈការបង្ហាញឆន្ទៈមិនពិត ឬការតំណាងដោយគ្មានសិទ្ធិ។ បន្ថែមពីនេះ ចំពោះសកម្មភាពដែលបានត្រូវចាត់ទុកជាមោឃៈ គឺមិនតម្រូវទាល់តែភាគីទើបអាចអះអាងអំពីការមោឃភាពទេ គឺបុគ្គលណាក៏អាចអះអាងអំពីការមោឃភាពបានដែរ។ ផ្ទុយទៅវិញចំពោះការលុបចោល បើយោងតាមខ្លឹមសារមាត្រានៃក្រមរដ្ឋប្បវេណីកម្ពុជាបានអនុញ្ញាត គឺចំពោះតែអ្នកដែលមានសិទ្ធិលុបចោលប៉ុណ្ណោះទើបអាចលុបចោលបាន។[43]

## ១.អំពីបញ្ញត្តិដែលអនុវត្តដោយបង្ខំ និងបញ្ញត្តិដែលអនុវត្តតាមការស្ម័គ្រចិត្ត

ជាទូទៅបើយោងសិក្សាស្វែងយល់អំពីគោលដៅនៃវិធានច្បាប់សារធាតុ គឺវិធានច្បាប់នេះបានកំណត់អំពីវិធានមូលដ្ឋានដើម្បីដោះស្រាយវិវាទ ឬសម្របសម្រួលទំនាក់ទំនង ដែលកើតមាននៅក្នុងទំនាក់ទំនងនៃជីវភាពឯកជន និងដែលមិនមែនជាវិធានដើម្បីកំណត់អំពីទំនាក់ទំនងរវាងរដ្ឋ និងប្រជាជននោះទេ។ ដូចជាករណីយកិច្ចសន្យាដែលមានអត្ថន័យផ្ទុយទៅនឹងគោលការណ៍ដែលមានចែងនៅក្នុងច្បាប់សារធាតុ ប្រសិនបើភាគីមានការ

[43] ម.៣៥៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ព្រមព្រៀងនោះ គេអាចកំណត់បានថា កិច្ចសន្យាគឺជាច្បាប់របស់គូភាគី ដែលមានប្រសិទ្ធិភាពអាចអនុវត្តបាន។ មានន័យថាទោះបីជាគោលការណ៍ ដែលកំណត់ដោយភាគីនៃកិច្ចសន្យានោះមានអត្ថន័យ ឬខ្លឹមសារផ្ទុយនឹង បញ្ញត្តិនៃច្បាប់សារធាតុក៏ដោយ តែគោលការណ៍នោះមានអានុភាពអនុវត្ត។ ប៉ុន្តែបញ្ញត្តដែលអនុវត្តតាមការស្ម័គ្រនេះមានអានុភាពអនុវត្តលុះត្រាតែមិន ធ្វើឲ្យខូចប្រយោជន៍រួម ឬបង្កជាផលប៉ះពាល់ដល់សង្គមធ្ងន់ធ្ងរ។

ឧទាហរណ៍៖ បញ្ញត្តិនៃមាត្រា៥១៨នៃក្រមរដ្ឋប្បវេណី បានចែងថា អ្នកលក់អាចរំលាយកិច្ចសន្យាលក់ទិញ ដោយការសងប្រាក់ស្មើនឹង២ដងនៃ ប្រាក់កក់ទៅអ្នកទិញ។ ប៉ុន្តែប្រសិនប្រើនៅក្នុងជីវភាពឯកជន ភាគីទាំងពីរ គឺអ្នកលក់ និងអ្នកទិញបានព្រមព្រៀងកំណត់ថា កិច្ចសន្យាអាចរំលាយបាន ដោយអ្នកលក់ដោយអ្នកលក់ត្រូវកំណត់សងប្រាក់ស្មើនឹង៣ដងនៃប្រាក់កក់ ទៅអ្នកទិញក៏អាចអនុវត្តបានដែរ។ ករណីអាចទទួលស្គាល់អានុភាពនៃការ អនុវត្តដោយហេតុថាការទទួលស្គាល់កិច្ចសន្យាបែបនេះ មិនបង្កការរំខាន ដល់អ្នកណាម្នាក់ឡើយ(បញ្ញត្តិអនុវត្តតាមការស្ម័គ្រចិត្ត)។

ប៉ុន្តែការកំណត់បែបនេះ ក៏តម្រូវឲ្យភាគីនៃកិច្ចសន្យាត្រូវធ្វើការកត់ សម្គាល់ផងដែរថា៖ មិនមែនគ្រប់រាល់បញ្ញត្តិផ្នែករដ្ឋប្បវេណីទាំងអស់សុទ្ធតែ ជាបញ្ញត្តិដែលអនុវត្តតាមការស្ម័គ្រចិត្តនោះទេ។

## ២.អំពីករណីការព្រមព្រៀងរបស់ភាគីផ្ទុយនឹងបញ្ញត្តិនៃក្រមរដ្ឋប្បវេណី

តើករណីណាខ្លះ ដែលការព្រមព្រៀងរបស់ភាគីផ្ទុយនឹងបញ្ញត្តិនៃក្រម រដ្ឋប្បវេណី? ជាទូទៅ បើយើងពិនិត្យទៅលើខ្លឹមសារដែលគោលការណ៍គ្រឹះ ឬជាគោលការណ៍ស្របតាមខ្លឹមសារមាត្រានៃក្រមរដ្ឋប្បវេណីកម្ពុជា គឺការ

ព្រមព្រៀងភាគីត្រូវតែស្របទៅនឹងបញ្ញត្តិនៃក្រមរដ្ឋប្បវេណីកម្ពុជា។ ប៉ុន្តែ ទោះជាបញ្ញត្តិបែបនោះក៏ដោយ តែការបង្កើតកិច្ចសន្យានៅក្នុងទ្រឹស្តី និង គំនិតទូទៅ គឺគេបានផ្តល់សិទ្ធិសេរីភាពដល់គូរភាគីក្នុងការសម្រេចចិត្តដើម្បី បង្កើតកិច្ចសន្យា ប៉ុន្តែសិទ្ធិសេរីភាពនៃការសម្រេចចិត្តនេះស្ថិតនៅក្នុងកាលៈ ទេសៈ និងស្ថានភាពមួយចំនួន គេសង្កេតឃើញថា ភាគីបានបង្កើតការព្រម ព្រៀងដែលមានខ្លឹមសារផ្ទុយទៅនឹងបញ្ញត្តិនៃក្រមរដ្ឋប្បវេណី។ ដូចនេះ បញ្ហាដែលចោទឡើងនៅទីនេះ ថាតើការព្រមព្រៀងរបស់ភាគីដែលផ្ទុយនឹង បញ្ញត្តិនៃក្រមរដ្ឋប្បវេណីនេះ តើមានអានុភាពអនុវត្តឬទេ?

ឧទាហរណ៍ មាត្រា១៣៥ នៃក្រមរដ្ឋប្បវេណីកម្ពុជាបានចែងថា ការផ្ទេរ សិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង និងមិនមានអានុភាពបើសិនមិន បានចុះបញ្ជី។ការកំណត់បែបនេះ ក្នុងគោលដៅដើម្បីផ្តល់ការធានាសម្រាប់ ភាគី និងក៏ដូចជាផ្តល់នូវសុវត្ថិភាពកិច្ចការជំនួញលើវិស័យអចនវត្ថុទាំងអស់ ដោយយកការចុះបញ្ជីជាល័ក្ខខ័ណ្ឌចំបង ដែលធ្វើឲ្យកិច្ចសន្យាមានប្រសិទ្ធិ ភាព។ មានន័យថាបញ្ញត្តិនេះ បានកំណត់អំពីលក្ខណៈវិនិច្ឆ័យសម្រាប់ដោះ ស្រាយវិវាទរវាងគូភាគី ដែលមានមុខងារសម្រាប់ការអនុវត្តនៃប្រព័ន្ធច្បាប់ របស់ប្រទេសដែលហៅថាប្រព័ន្ធនៃការទទួលស្គាល់សិទ្ធិស្របច្បាប់តាមការ ចុះបញ្ជី។ ដូចនេះប្រសិនបើអនុញ្ញាតឲ្យមានការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ ដែលធ្វើឡើងដោយគូភាគី ដោយផ្អែកលើការព្រមព្រៀងតែមួយមុខ នោះ ប្រព័ន្ធនៃការចុះបញ្ជីនឹងបាត់បង់មុខងារ។ ក្នុងន័យនេះការព្រមព្រៀងរបស់ ភាគី អាចបង្កជាការរំខានដល់សាធារណជនទូទៅករណីមានភាគីណាមួយ ទុច្ចរិត។ ភាគីគឺតម្រូវឲ្យគោរពមាត្រា១៣៥នៃក្រមរដ្ឋប្បវេណីដោយមិនអាច ប្រឆាំងបាន។ មានន័យថាកិច្ចសន្យាដែលផ្ទុយពីនេះត្រូវចាត់ទុកជាមោឃៈ។ បញ្ញត្តិបែបនេះត្រូវបានចាត់ទុកថាជាបញ្ញត្តិដែលអនុវត្តដោយបង្ខំ។

បន្ថែមពីនេះដើម្បីដឹងថាបញ្ញត្តិណាមួយជាបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬជាបញ្ញត្តិដែលអនុវត្តតាមការស្ម័គ្រចិត្ត ចាំបាច់ត្រូវធ្វើការវិនិច្ឆ័យដោយផ្អែកលើគោលបំណងនិងគោលដៅនៃបញ្ញត្តិទាំងនោះ និងជាទូទៅយើងអាចសង្កេតឃើញថា ក្នុងផ្នែកសិទ្ធិលើបំណុលមានបញ្ញត្តិដែលអនុវត្តតាមការស្ម័គ្រចិត្តច្រើន ហើយក្នុងផ្នែកសិទ្ធិប្រត្យក្ស និងញាតិមានបញ្ញត្តិដែលអនុវត្តដោយបង្ខំច្រើន។

- ✓ **អំពីការលុបចោល៖**

គេសង្កេតឃើញថា បើសកម្មភាពមួយត្រូវបានចាត់ទុកថាមោឃភាព ទោះបីជាភាគីមិនបានអះអាងអំពីការមោឃភាព ក៏ សត្យានុម័តខាងក្រៅ គឺចាត់ទុកថាមោឃភាព[44]។ម្យ៉ាងទៀតចំពោះសកម្មភាពដែលអាចលុបចោលបាន គឺនៅតែមានសុពលភាពរហូតដល់អ្នកមានសិទ្ធិលុបចោល លុបចោលសកម្មភាពនោះ(មាត្រា៣៥៨កថាខណ្ឌទី១នៃក្រមរដ្ឋប្បវេណី)។ នៅក្នុងករណីដែលអ្នកមានសិទ្ធិលុបចោលបានលុបចោល សកម្មភាពនោះត្រូវបានចាត់ទុកជាមោឃតាំងពីដំបូង។ មានន័យថាការលុបចោលមានអានុភាពប្រតិសកម្មភាពតាមមាត្រា៣៥៨កថាខណ្ឌទី២នៃក្រមរដ្ឋប្បវេណី។ បន្ថែមពីនេះក្នុងករណីដែលមានសិទ្ធិលុបចោលបានផ្តល់សច្ចានុម័ត សកម្មភាពនឹងមានសុពលភាពជាស្ថាពរ តាមមាត្រា៣៥៨កថាខណ្ឌទី៣នៃក្រមរដ្ឋប្បវេណី។

## ២.១.អ្នកដែលមានសិទ្ធិលុបចោល

តើអ្នកណាជាអ្នកមានសិទ្ធិលុបចោលនូវសកម្មភាព? យោងតាមគោលគំនិតមាត្រានៃក្រមរដ្ឋប្បវេណីកម្ពុជា អ្នកដែកមានសិទ្ធិអះអាងអំពីការលុបចោល ក្នុងករណីការបង្ហាញឆន្ទៈមានវិការៈ ដូចជាការភាន់ច្រឡំ និង

[44]ម.៣៥៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ការឆបោក...ជាដើម អ្នកបង្ហាញឆន្ទៈមានវិការៈ អ្នកតំណាងដែលច្បាប់បាន
កំណត់សន្តតិជន អ្នកដែលទទួលបន្តឋានៈក្នុងកិច្ចសន្យា ហិត្តូបត្ថម្ភកៈ
អច្ច័យលាភីត្រូវតែកំណត់ថា ជាអ្នកមានសិទ្ធិសុំអះអាងអំពីការលុបចោលនូវ
សកម្មភាព។[45]

## ២.២. វិធីលុបចោល ឬការផ្ដល់សច្ចានុម័ត

ការលុបចោលនិងសច្ចានុមតិ ត្រូវធ្វើឡើងតាមរយៈការជូនដំណឹង
ទៅភាគីម្ខាងទៀត។ ការជូនដំណឹងធ្វើឡើងដោយផ្ទាល់មាត់ ឬជាលិខិត
លាយលក្ខណ៍អក្សរ។ អានុភាពនៃការលុបចោល និងសច្ចានុមតិកើតមាន
ឡើងនៅពេលការជូនដំណឹងបានដល់ភាគីម្ខាងទៀត។[46]

តើបណ្ដឹងទាមទារការលុបចោលកិច្ចសន្យា អាច ឬមិនអាច?
យោងតាមក្រឹត្យច្បាប់លេខ៣៨នៃក្រមរដ្ឋប្បវេណី បណ្ដឹទាមទារលុបចោល
លកិច្ចសន្យាអាចកើតឡើងដោយខ្លួនវាផ្ទាល់។ ប៉ុន្តែអត្ថន័យក្រមរដ្ឋប្បវេណី
និងក្រមនីតិវិធីបណ្ដឹងទាមទារលុបកិច្ចសន្យា គឺមិនអាចសម្រេចគោល
បំណងចំបង ដែលជាការទាមទារសំណងសាច់ប្រាក់និងសំណងជាកម្មវត្ថុ
បានទេ។ ដោយសារតែចុងក្រោយ គឺនៅតែត្រូវដាក់ពាក្យបណ្ដឹងដើម្បី
ទាមទារសំណងជាសាច់ប្រាក់និងសំណងជាកម្មវត្ថុម្ដងទៀត។

---

[45]ម.៣៥៩.២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[46]ម.៣៦០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

**សូមបង្ហាញអំពីករណីសិក្សាដើម្បីសិក្សាស្វែងយល់ និងធ្វើការត្រិះរិះពិចារណាអំពីការលុបចោល និងវិធីនៃការលុបចោល៖**

**ករណីសិក្សាទី១៣៖** ករណីយកិច្ចសន្យាទិញលក់ដី X ក្រោយពេលអ្នកទិញបានបង់ប្រាក់រួច កិច្ចសន្យាក៏ត្រូវលុបចោលដោយមូលហេតុការភាន់ប្រឡំ។ ក្នុងករណីនេះ នៅក្រៅតុលាការនៅពេលដែល អ្នកទិញបានជូនដំណឹងអំពីការភាន់ច្រឡំទៅកាន់អ្នកលក់ អានុភាពនៃការលុបចោលនឹងកើតមានឡើង។ ប៉ុន្តែប្រសិនបើ អ្នកលក់មិនព្រមទទួលស្គាល់ការលុបចោលរបស់អ្នកទិញ ហើយមិនព្រមសងប្រាក់ អ្នកទិញចាំបាច់ត្រូវដាក់ពាក្យប្តឹង។ករណីនេះ អ្នកទិញមិនមែនដាក់ពាក្យបណ្តឹងទាមទារលុបចោលកិច្ចសន្យានោះទេ គឺចាំបាច់ដាក់ពាក្យបណ្តឹងដើម្បីទាមទារសំណងជាសាច់ប្រាក់។ ដូចនេះការលុបចោលកិច្ចសន្យា គឺជាវិធីសាស្ត្រក្នុងការការពារការវាយប្រហារក្នុងវិវាទ ប៉ុន្តែមិនមែនជាគោលបំណងនៃពាក្យបណ្តឹងទេ។

## ២.៣. អ្នកមានសិទ្ធិផ្តល់សច្ចានុម័ត និងលក្ខខណ្ឌនៃការផ្តល់សច្ចានុម័ត

**ដើម្បីសិក្សាស្វែងយល់អំពីអ្នកមានសិទ្ធិផ្តល់សច្ចានុម័ត និងលក្ខខណ្ឌនៃការផ្តល់សច្ចានុម័តសូមដាក់ជូននូវករណីសិក្សាដូចខាងក្រោមដើម្បីធ្វើការត្រិះរិះពិចារណា៖**

**ករណីសិក្សាទី១៤៖** ក ត្រូវបាន ខបោកបញ្ឆោតថាដីX ច្បាស់ជាឡើងថ្លៃក្នុងរយៈពេល១ឆ្នាំ។ ក៏បានបង្កើតកិច្ចសន្យាទិញដីX ពី ខ និងធ្វើជាលិខិតយថាភូត។ ខ បានសួរទៅកាន់ ក ថា អាចលុបចោលកិច្ចសន្យាពីឥឡូវបាន តើគិតយ៉ាងណា?។

នៅពេលនោះ ក មិនទាន់បានដឹងអំពីការបោកបញ្ឆោតរបស់ខ រួចក៏តបថា ទេមិនចាំបាច់លុបចោលទេ។ ក្រោយមករយៈពេលបានកន្លងផុតទៅមួយឆ្នាំតំលៃដីX មិនឡើងថ្លៃ ក គិតថាត្រូវបានខ បោកប្រាស់ក៏បានដាក់ពាក្យបណ្តឹងលុបចោលកិច្ចសន្យាដោយមូលហេតុឆបោក និងទាមទារសំណងសាច់ប្រាក់ពីខ។ ក្នុងវិវាទ **ខ បានអះអាងថាដោយសារតែ ក បាន ផ្តល់សច្ចានុមតិថា** មិនចាំបាច់លុបចោលកិច្ចសន្យា ហេតុនេះកិច្ចសន្យាមិនអាចលុបចោលបានទេ។ ការអះអាងរបស់របស់ ខ មិនអាចទទួលយកបានទេ។ ពីព្រោះនៅពេលដែល ក ឆ្លើយតបទៅ ខ ក មិនបានដឹងថាមានមូលហេតុនៃការលុបចោល ហេតុនេះសកម្មភាពរបស់របស់ ក មិនក្លាយជាការផ្តល់សច្ចានុមតិទេ។

បន្ថែមពីនេះករណីកង្វះសមត្ថភាពខាងឆន្ទៈឬការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព អាចផ្តល់សច្ចានុមតិបាននៅក្រោយពេលដែលស្ថានភាពដែលជាមូលហេតុនៃការលុបចោលត្រូវរលត់ ស្របតាមខ្លឹមសារមាត្រា៣៦១.១នៃក្រមរដ្ឋប្បវេណីកម្ពុជា។ ឧទាហរណ៍៖ ករណីអនីតិជន បើមិនទាន់ដល់នីតិភាព មិនអាចផ្តល់សច្ចានុម័តបានទេ។ ប៉ុន្តែចំពោះករណីមានអ្នកតំណាងដែលច្បាប់បានកំណត់ និងហិតូបត្ថម្ភកៈ ទោះជាអ្នកបង្ហាញឆន្ទៈអសមត្ថភាពខាងឆន្ទៈ ឬអសមត្ថភាពខាងសកម្ម ភាពក៏ដោយក៏អាចផ្តល់សច្ចានុមតិបាន ស្របតាមមាត្រា៣៦១.២នៃក្រមរដ្ឋប្បវេណីកម្ពុជា។

## ២.៤. សច្ចានុម័តដែលច្បាប់បានកំណត់

ក្រៅពីការផ្តល់សច្ចានុម័ត ដូចបានកំណត់នៅក្នុងខ្លឹមសារនៃមាត្រា៣៦១នៃក្រមរដ្ឋប្បវេណីកម្ពុជា គេសង្កេតឃើញថា សកម្មភាពមួយចំនួន

ត្រូវចាត់ទុកថាជាការផ្តល់សច្ចានុម័ត ដូចជាការអនុវត្តកាតព្វកិច្ចទាំងមូល ឬមួយផ្នែកដែលកើតឡើងដោយសារសកម្មភាពដែលអាចលុបចោលបាន ឬការដាក់ប្រាតិភោគដើម្បីធានាកាតព្វកិច្ច និងការអនុវត្តសិទ្ធិដែលទទួលបានពីសកម្មភាពដែលអាចលុបចោលបាន ឬការទាមទារឲ្យភាគីម្ខាងទៀតត្រូវអនុវត្ត។

សច្ចានុម័តដែលច្បាប់បានកំណត់ ទោះបីជាមិនមានការជូនដំណឹងច្បាស់លាស់ ក៏ដោយ ប្រសិនបើមានអង្គហេតុថា ភាគីម្ខាងទៀតនឹងរំពឹងទុកថា កិច្ចសន្យានឹងមិនត្រូវបានលុបចោលទេ ការរំពឹងទុកបែបនេះចាំបាច់ត្រូវតែការពារ។

**ដើម្បីសិក្សាស្វែងយល់អំពីសច្ចានុម័តដែលច្បាប់បានកំណត់ សូមបង្ហាញករណីសិក្សាដើម្បីធ្វើការត្រិះរិះពិចារណា៖**

**_ករណីសិក្សាទី១៥៖_** ក មានបំណងទិញរថយន្ត Lexus ពីអ្នកស្គាល់គ្នាម្នាក់ លោក ខ ប៉ុន្តែបានច្រឡំទិញ រថយន្តCRV ទៅវិញ។ ក បានគិតថាចង់លុបចោលកិច្ចសន្យាដោយកិច្ចសន្យាដោយមូលហេតុនៃការភាន់ច្រឡំ ប៉ុន្តែមិត្តស្រីរបស់គាត់ គ បាននិយាយថា ខ្ញុំចូលចិត្តរថយន្ត CRV ជាងរថយន្ត Lexus។ ក មិនក៏បានលុបចោលកិច្ចសន្យាហើយប្រគល់ប្រាក់ទៅឲ្យ ខ ។ ប៉ុន្តែក្រោយមក ក បានបែកគ្នាជាមួយ គ ហើយ ចាប់ផ្តើមសេពគប់ជាមួយមិត្តស្រីថ្មី ឃ។ ដោយសារតែមិត្តស្រី ឃ បាននិយាយថារថយន្ត Lexus ឡូយជាងរថយន្ត CRV ។ ក គិតថារថយន្ត Lexus ក៏បានជូនដំណឹងលុបចោលកិច្ចសន្យាទៅ ខ និងទាមទារសំណងជាសាច់ប្រាក់។ តើអ្នកយល់យ៉ាងណាចំពោះសច្ចានុម័តដែលច្បាប់បានកំណត់ ?

**ករណីសិក្សាទី១៦៖** ក មានបំណងទិញរថយន្ត Lexus ពីអ្នកស្គាល់គ្នា ខ ប៉ុន្តែបានប្រទ្បំទិញរថយន្តCRV ទៅវិញ។ ក បានគិតថា នឹងសួរយោបល់ពីមិត្តស្រីគាត់ថា គួរតែលុបចោល កិច្ចសន្យាដោយមូលហេតុនៃការភាន់ប្រទ្បំទេ រួចទើបធ្វើការសម្រេចចិត្ត។

ហើយនៅពេលដែល ត្រូវបាន ខ ទាមទារឲ្យបង់ប្រាក់ ក បាននិយាយថា ខ្ញុំបង់ប្រាក់ឲ្យជាមុនសិន ប៉ុន្តែប្រសិនបើមិនស្រីរបស់ខ្ញុំនិយាយថា ចង់ជិះរថយន្ត Lexus កិច្ចសន្យានឹងត្រូវលុបចោល រួចក៏បានបង់ប្រាក់។

ក្រោយមក បន្ទាប់ពីស្តាប់គំនិតមិត្តស្រី គ រួចនាងបានឆ្លើយថា ចង់ជិះរថយន្តLexus ជាងរថយន្ត CRV។ ពេលនោះ ក ក៏បានជូនដំណឹងលុបចោលកិច្ចសន្យាទៅខ និងទាមទារសំណាងជាប្រាក់។ ករណី នេះ ខមិនអាចបដិសេធសំណាងជាប្រាក់បានទេ។ តើយល់យ៉ាងចំពោះសិទ្ធិអះអាងអំពីការលុបចោល និងការផ្តល់សច្ចានុម័ត?។

# មេរៀនទី២

# កិច្ចសន្យាលក់ទិញ

នៅក្នុងជីវភាពនៃការរស់នៅប្រចាំថ្ងៃ កិច្ចសន្យាដែលប្រើប្រាស់ញឹកញាប់ជាងគេ គឺកិច្ចសន្យាលក់ទិញ ឬការលក់ទិញ ពីព្រោះការលក់ទិញបានដើរតួនាទីយ៉ាងសំខាន់ដើម្បីបំពេញសេចក្តីត្រូវការរបស់មនុស្ស ឬបុគ្គលគ្រប់ស្រទាប់វណ្ណៈក្នុងសង្គមទាំងប្រជាពលរដ្ឋទូទៅ អាជីវករ ពាណិជ្ជករ អ្នកជំនួញ និងអ្នកវិនិយោគ ក្រោមទម្រង់ជាការបំពេញកិច្ចស៊ីវិល និងពាណិជ្ជកិច្ច។ ដូចបានលើកឡើងខាងលើដោយសារតែការលក់ទិញត្រូវបានបង្កើតដោយបុគ្គលច្រើនប្រភេទ មានភាពងាយស្រួល ដោយប្រែប្រួលទៅតាមប្រភេទ លក្ខណៈ និងកម្មវត្ថុ ស្របតាមតម្រូវការដែលភាគីចង់បាន។ ហេតុដូចនេះហើយ ការលក់ទិញ ឬកិច្ចសន្យាលក់ទិញនេះ ត្រូវបានចាត់ទុកជាកិច្ចសន្យាដែលមានប្រជាប្រិយភាពជាងគេ បើធៀបទៅនឹងប្រភេទនៃកិច្ចសន្យាពិសេសជាច្រើនទៀត ដោយបុគ្គលនិយមប្រើប្រាស់ អនុវត្តដោយសេរីជាប្រចាំ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ គេសង្កេតឃើញថាជុំវិញទំនាក់ទំនងនៃការលក់ទិញ និងកិច្ចប្រតិបត្តិជាប្រចាំក្រោមការវិវត្តនៃបរិបទសង្គម និងសេដ្ឋកិច្ច ដែលផ្តល់សិទ្ធិសេរីភាពពេញលេញដល់បុគ្គលក្នុងការបង្កើតទំនាក់ទំនង ក៏ជាមូលហេតុនាំឲ្យការលក់ទិញជួបប្រទះនូវបញ្ហាប្រឈមជាច្រើនជុំវិញកិច្ចប្រតិបត្តិលក់ទិញ ជាពិសេស គឺការអនុវត្តសិទ្ធិរវាងភាគីអ្នកលក់ និងអ្នកទិញ។ ដូចនេះដើម្បីការពារផលប្រយោជន៍ភាគីនៃកិច្ចសន្យាលក់ទិញ និងការពារសុវត្ថិភាពកិច្ចការជំនួញ ក៏ដូចជារក្សាបាននូវតុល្យភាពផលប្រយោជន៍រវាងអ្នកលក់និងអ្នកទិញគឺក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ បានធ្វើចំណាត់ថ្នាក់ការលក់ទិញ គឺដោយកំណត់លក្ខណៈនៃការលក់ទិញ

ប្រភេទផ្សេងៗនៃកាតព្វកិច្ចជុំវិញលក្ខណៈពិសេសនៃការលក់ទិញ និងធ្វើការបែងចែកច្បាស់លាស់អំពីសិទ្ធិ និងករណីយកិច្ចរបស់អ្នកលក់ និងអ្នកទិញ ដែលត្រូវលើកយកមកសិក្សា និងបកស្រាយនៅផ្នែកខាងក្រោម។ តើការលក់ទិញ ឬកិច្ចសន្យាលក់ទិញមានអត្ថន័យយ៉ាងដូចម្តេច? កិច្ចសន្យាលក់ទិញ បើយោងតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ គឺសំដៅលើកិច្ចសន្យាមួយដែលភាគីម្ខាងហៅថា អ្នកលក់ មានករណីយកិច្ចត្រូវផ្ទេរសិទ្ធិ ឬសិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិឲ្យទៅភាគីម្ខាងទៀតហៅថាអ្នកទិញដែលមានករណីយកិច្ចចេញថ្លៃជាប្រាក់ឲ្យអ្នកលក់។

យោងតាមខ្លឹមសារដែលបានលើកឡើងខាងលើ បានបង្ហាញឲ្យឃើញអំពីទំនាក់ទំនងគតិយុត្តិរវាងភាគី២ គឺភាគីអ្នកលក់ និងភាគីអ្នកទិញ ដោយធ្វើការកត់សម្គាល់បានថា អ្នកលក់ត្រូវតែជាបុគ្គលដែលមានសិទ្ធិពេញលេញទៅលើទ្រព្យដែលជាកម្មវត្ថុនៃការលក់ ដោយហេតុថានៅពេលការលក់ទិញកំណត់អានុភាព អ្នកលក់មានកាតព្វកិច្ចត្រូវផ្ទេរសិទ្ធិលើទ្រព្យដែលជាកម្មវត្ថុលក់នោះទៅឲ្យភាគី អ្នកទិញនៅពេលដែលអ្នកទិញបានបង់ប្រាក់ថ្លៃលក់គ្រប់ចំនួនទៅអ្នកលក់។

ប៉ុន្តែបញ្ហាចោទនៅទីនេះ តើអ្វីដែលត្រូវសិក្សាជុំវិញសិទ្ធិរបស់អ្នកលក់ គឺអះអាងអំពីសិទ្ធិដែលមានលើទ្រព្យដែលជាកម្មវត្ថុនៃការលក់ និងថាអ្នកលក់តម្រូវបំពេញសំណុំឯកសារភ្ជាប់អ្វីខ្លះ ដើម្បីអះអាងថាជាបុគ្គលមានសិទ្ធិពេញលេញក្នុងការបង្កើតលក់ទិញ ដែលមិនមែនជាការលក់ទ្រព្យអ្នកដទៃ និងអ្នកទិញក៏ដូចគ្នា គឺទាមទារនូវលក្ខខណ្ឌដែលបានបង្ហាញថាខ្លួនជាបុគ្គលដែលមានសមត្ថភាពពេញលេញនៅក្នុងការបង្កើតការលក់ទិញ ដើម្បីធានាថាកិច្ចសន្យាអាចសម្រេចបាន។

ដើម្បីធ្វើការសិក្សាអំពីកិច្ចសន្យាលក់ទិញឲ្យបានស៊ីជម្រៅ គឺគេអាចកំណត់ការសិក្សាបែងចែកជាបីដំណាក់កាលរួមមានៈដំណាក់កាលមុនពេលបង្កើតកិច្ចសន្យាលក់ទិញ(ផ្នែកទី១), អំពីលក្ខខណ្ឌបង្កើតកិច្ចសន្យាលក់ទិញ(ផ្នែកទី២) និងអានុភាពនៃកិច្ចសន្យាលក់ទិញ(ផ្នែកទី៣)។

## ផ្នែកទី១. ដំណាក់កាលមុនពេលបង្កើតកិច្ចសន្យាលក់ទិញ

មូលហេតុអ្វីបានចាំបាច់តម្រូវឲ្យធ្វើការសិក្សាអំពីដំណាក់កាលមុនពេលការបង្កើតកិច្ចសន្យាលក់ទិញ? ជាទូទៅការសិក្សាអំពីដំណាក់កាលមុនពេលបង្កើតកិច្ចសន្យាលក់ទិញ ក្នុងនោះអ្នកសិក្សាអាចស្វែងយល់អំពីមូលហេតុដំបូងដែលនាំឲ្យកិច្ចសន្យាលក់ទិញត្រូវបានបង្កើត យល់ដឹងអំពីវត្ថុបំណងដែលភាគីនៃកិច្ចសន្យាលក់ទិញចង់បាន និងអាចយល់ដឹងពីវិធានដែលភាគីយកជាមូលដ្ឋានក្នុងការចរចារដើម្បីត្រៀមនិងបង្កើតកិច្ចសន្យាលក់ទិញនាពេលអនាគត។ ម្យ៉ាងវិញទៀតក្រៅពីសិក្សាស្វែងយល់អំពីបុព្វហេតុដំបូងនៃការបង្កើតកិច្ចសន្យាលក់ទិញ ក្នុងនាមជាអ្នកសិក្សា ឬអ្នកជំនាញនៃវិស័យច្បាប់ ក៏ត្រូវសិក្សាស្វែងយល់បន្ថែមអំពីចំណុចដែលខ្វះខាតនៅក្នុងការព្រមព្រៀង ភាពខ្វះចន្លោះ ដែលអាចធ្វើឲ្យភាគីនៃកិច្ចសន្យាអាចទទួលរងនូវការខូចខាតផលប្រយោជន៍នាពេលអនាគត ដូចនេះដើម្បីអាចកំណត់បានអំពីលទ្ធភាពនៃចំណុចវិវាទមួយចំនួនដែលអាចកើតឡើងនៅមុនពេលកិច្ចសន្យាលក់ទិញត្រូវបានបង្កើត ដូចជាករណីការបំពានកើតមានតាមរយៈទំនាក់ទំនងដែលបានលើកឡើងខាងលើ តើអ្នកទទួលរងការបំពានអាចទទួលបាននូវការពារផលប្រយោជន៍យ៉ាងដូចម្តេច?។ បន្ថែមពីនេះផ្អែកតាមករណីសិក្សាជាច្រើន នៅជុំវិញដំណាក់កាលបង្កើតកិច្ចសន្យាលក់ទិញក្នុងគោលដៅដើម្បីការពារផលប្រយោជន៍គូរភាគីនៅដំណាក់កាលមុនពេល

បង្កើតកិច្ចសន្យាលក់ទិញ ក្រមរដ្ឋប្បវេណីកម្ពុជាកំណត់ពីវិធានមូលដ្ឋានមួយចំនួន ដើម្បីការពារផលប្រយោជន៍ភាគី អាចកំណត់បានថាជាវិធានមូលដ្ឋានដែលបង្កើតដើម្បីធានា ផ្តល់សុវត្ថិភាពដល់គូភាគីនៃទំនាក់ទំនងដោយចូលរួមផ្តល់ជាដំណោះស្រាយដល់គូភាគី ពេលកើតមានវិវាទនៅដំណាក់កាលមុនពេលកិច្ចសន្យាលក់ទិញ ក្នុងនោះអាចធ្វើការសិក្សាអំពីការសន្យាលក់ទិញជាមុនដោយឯកតោភាគី,ប្រាក់កក់, ការលក់ទិញដោយមានការភ្លក់សាក, ការលក់ទិញដោយមានការប្រើសាក, ថ្លៃលក់ទិញ , សោហ៊ុយក្នុងការលក់ទិញ, ភាគីនៃកិច្ចសន្យាលក់ទិញ និងវត្ថុដែលអាចជាកម្មវត្ថុនៃការលក់ទិញបាន។

## កថាខណ្ឌ១.ការសន្យាលក់ទិញជាមុនដោយឯកតោភាគី

តើដូចម្តេចដែលហៅការសន្យាលក់ទិញជាមុនដោយឯកតោភាគី? ការសន្យាជាមុនដោយឯកតោភាគី ចំពោះការលក់ទិញត្រូវបានចាត់ទុកថាជាការបង្ហាញឆន្ទៈដើម្បីបង្កើតទំនាក់ទំនងគតិយុត្ត ឬជាការសុំបង្កើតកិច្ចសន្យាលក់ទិញដែលធ្វើឡើងដោយភាគីម្ខាងនៃកិច្ចសន្យាលក់ទិញ ឬអាចចាត់ទុកបានជាសំណើលក់ទិញ គឺនៅពេលមានការធ្វើស៊ីការតបវិញអាចកំណត់បានថាកិច្ចសន្យាលក់ទិញត្រូវបានបង្កើត។ ប៉ុន្តែនៅក្នុងស្ថានភាពនៃការប្រតិបត្តិ ការសន្យាលក់ទិញជាមុនដោយឯកតោភាគី អាចធ្វើឲ្យអ្នកដាក់សំណើនោះទទួលរងនូវការខូចប្រយោជន៍ដោយសារអ្នកទទួលសំណើមិធ្វើការឆ្លើយតប ឬអវត្តមាន ដែលបង្កជាបញ្ហាប្រឈមជុំវិញ និងធ្វើឲ្យកិច្ចសន្យាលក់ទិញមិនអាចសម្រេចបាន។

ករណីនេះ អ្នកដាក់សំណើលក់ទិញជាមុនដោយឯកតោភាគី បានលើកឡើងថា តើការសន្យាជាមុនដោយឯកតោភាគីនោះមានអានុភាពចាប់តាំងពីពេលណា?ការសន្យាលក់ទិញជាមុនដោយឯកតាភាគី មានអានុភាពចាប់តាំងពីពេលដែលភាគីម្ខាងទៀតបានបង្ហាញឆន្ទៈបំពេញការទិញ ឬលក់ចំពោះអ្នកសន្យា។[47] ដូចនេះចំណុចដែលយកមកពិចារណា គឺការបង្ហាញឆន្ទៈបំពេញការទិញ ឬការបង្ហាញឆន្ទៈបំពេញការលក់ តើមានលក្ខខណ្ឌឬមូលហេតុណាខ្លះ ដែលភាគីអាចកំណត់ថាមានការធ្វើស្ទីការចំពោះសំណើលក់ទិញដែលបានព្រមព្រៀងកន្លងមក មានន័យថាចំណុចដែលបានធ្វើការកត់សម្គាល់ចំពោះការសន្យាលក់ទិញជាឯកតោភាគី គឺការអនុវត្តរបស់ភាគីដែលបានស្នើចំពោះការបង្កើតកិច្ចសន្យានាពេលអនាគត។

យោងតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជា បានបញ្ញត្តិសម្រាប់អំឡុងពេលនៃការបង្ហាញឆន្ទៈបានកំណត់ ចំពោះលក្ខខណ្ឌដែលបានព្រមព្រៀង ចំពោះការសន្យាជាមុនដោយឯកតោភាគី អ្នកសន្យាជាមុន គឺអាចដាស់តឿនឲ្យភាគីម្ខាងទៀតបង្ហាញឆន្ទៈថាយល់ព្រម ឬមិនយល់ព្រមបំពេញការទិញ ឬលក់ក្នុងអំឡុងពេលនោះ និងក្នុងករណីដែលភាគីម្ខាងទៀតមិនបង្ហាញឆន្ទៈនៅក្នុងអំឡុងពេលកំណត់ ការសន្យាជាមុននោះត្រូវបាត់បង់អានុភាព។

[47] ម.៥១៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

## កថាខណ្ឌ២. ប្រាក់កក់

ដូចម្តេចដែលហៅថាប្រាក់កក់? ប្រាក់កក់ចាំបាច់ត្រូវតែមាននៅពេលបង្កើតការលក់ទិញឬទេ? ប្រាកកក់ គឺជាលក្ខខណ្ឌដែលផ្តល់នូវផលប្រយោជន៍ដល់គូភាគីក្នុងដំណាក់កាលនៃការចរចារ ដើម្បីបង្កើតការលក់ទិញ ដែលហាមឃាត់ភាគីមិនឲ្យធ្វើការផ្លាស់ប្តូរ ឬកែប្រែការបង្ហាញឆន្ទៈថាមិនបង្កើតការលក់ទិញវិញ។ ការអនុញ្ញាតឲ្យមានប្រាកកក់ គឺលក្ខខណ្ឌដែលចងគូភាគីទៅនឹងការសម្រេចចំពោះការលក់ទិញ មានន័យ ដើម្បីឲ្យអ្នកលក់អាចជឿជាក់ថាការលក់ទិញពិតជាអាចសម្រេចបានតាមលក្ខខណ្ឌស្នើរបស់ភាគីអ្នកទិញ គឺភាគីតម្រូវឲ្យមានបង់ប្រាក់កក់ និងម្យ៉ាងទៀតលក្ខខណ្ឌនៃការបង់ប្រាក់កក់ ក៏មានអានុភាពក្នុងការរារាំងអ្នកលក់មិនឲ្យផ្លាស់ប្តូរ ឬកែប្រែឆន្ទៈឈប់លក់វិញ។

ការកំណត់អំពីប្រាក់កក់ តាមខ្លឹមសារមាត្រានៃក្រមរដ្ឋប្បវេណី អ្នកទិញក៏អាចរំលាយកិច្ចសន្យាលក់ទិញដោយផ្លាស់ប្តូរ កែប្រែឆន្ទៈឈប់ទិញវិញបាន គឺដោយអ្នកទិញត្រូវបោះបង់ប្រាក់កក់ និងអ្នកអាចរំលាយកិច្ចសន្យាលក់ទិញដោយកែប្រែឆន្ទៈឈប់លក់វិញបាន ដោយសងប្រាក់កក់ទៅភាគីអ្នកវិញដោយចំនួនប្រាក់កក់គុណនិងពីរ[48]។បន្ថែមពីនេះនៅក្នុងជីវភាពកិច្ចការជំនួញ ចំពោះការកំណត់ប្រាក់កក់ភាគី អាចមានការព្រមព្រៀងផ្សេងពីនេះ ដោយកំណត់ប្រាក់កក់គុណនិងបី ឬច្រើនជាងក្នុងគោលដៅចងភាគីទៅនឹងកាតព្វកិច្ច ដោយរារាំងការកែប្រែឆន្ទៈនាពេលអនាគត។

---

[48] ម.៥១៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ករណីខាងនេះជាបញ្ញត្តិអនុវត្តតាមការស្មគ្រចិត្ត ដែលផ្ទុយទៅនឹងខ្លឹមសារនៃក្រមរដ្ឋប្បវេណី ដែលកំណត់ការរំលាយកិច្ចសន្យា ដោយទាមទារឲ្យសងប្រាកកក់គុណនិង៣។ ការព្រមព្រៀងបែបនេះ គឺទទួលស្គាល់អានុភាពអនុវត្ត ពីព្រោះកិច្ចសន្យាជាច្បាប់របស់គូភាគី និងមិនបានធ្វើឲ្យខូចប្រយោជន៍រួម។

## កថាខណ្ឌ៣. ការលក់ដោយមានការភ្លក់សាក

កម្មវត្ថុនៃការលក់មួយចំនួន គឺភាគីទាមទារឲ្យមានការភ្លក់សាក ដោយសារទំនិញថ្មី ឬមុខទំនិញមានច្រើនប្រភេទ ហើយបុគ្គលមានរសនិយមផ្សេងៗគ្នា ដូច មុននឹងសម្រេចចិត្តដើម្បីបង្កើតការលក់ទិញ ភាគីមានសិទ្ធិភ្លក់រសជាតិ ដោយចង់ដឹងពីរសជាតិនិងគុណភាពនៃមុខទំនិញជាកម្មវត្ថុនៃការលក់ទិញនាពេលអនាគត។ ការលក់ដោយមានការភ្លក់សាកតាមខ្លឹមសារមាត្រានៃក្រមរដ្ឋប្បវេណី គឺបានកំណត់ថាកម្មវត្ថុនៃការលក់មួយចំនួនមានទំនៀមទម្លាប់ឲ្យភ្លក់សាកមុន នឹងធ្វើការសម្រេចចិត្តទិញ គឺនៅក្រោយពេលភ្លក់សាក។[49] ករណីនេះ អ្នកលក់អាចដាស់តឿនអ្នកទិញបន្ទាប់ពីការភ្លក់សាកបានកន្លងផុតនៅក្នុងអំឡុងពេលសមរម្យ តែអ្នកលក់មិនមានសិទ្ធិបង្ខំអ្នកទិញត្រូវតែទិញបន្ទាប់ពីការភ្លក់សាកនោះទេ ករណីអ្នកទិញមិនធ្វើការឆ្លើយតបចំពោះសំណើលក់ទេ គឺគេកំណត់បានថាសំណើលក់ត្រូវបាត់បង់អានុភាព។ មានន័យថា សិទ្ធិនៅក្នុងកាសម្រេចចិត្តដើម្បីបង្កើតការលក់ទិញចំពោះកម្មវត្ថុនៃការលក់ទិញ ដែលអនុញ្ញាតឲ្យមានការភ្លក់សាក គឺកំណត់អានុភាពនៅក្រោយពេលភ្លក់សាក និងអ្នកទិញបានបង្ហាញឆន្ទៈ

[49] ម.៥១៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

យល់ព្រម និងករណីអ្នកទិញមិនបានឆ្លើយតបច្បាស់ក្នុងអំឡុងពលនោះ ត្រូវចាត់ទុកថាអ្នកទិញបដិសេធ។

## កថាខណ្ឌ៤. ការលក់ដោយមានការប្រើសាក

ការលក់ដោយមានការប្រើសាក ចំពោះកម្មវត្ថុនៃការលក់ទិញមួយចំនួន គឺបានអនុញ្ញាតឲ្យអ្នកទិញអាចប្រើសាកមុននឹងធ្វើការសម្រេចចិត្តបង្កើតការលក់ទិញនាពេលអនាគត តែការលក់ដោយការប្រើសាកនេះអាចអនុវត្តបានចំពោះតែមុខទំនិញមួយចំនួនប៉ុណ្ណោះ។ ប៉ុន្តែបញ្ហាចោទទីនេះបានលើកឡើងថា ការលក់ទិញដោយមានការភ្លក់សាក បើយោងទៅតាមគោលគំនិតមាត្រានៃក្រមរដ្ឋប្បវេណីកម្ពុជា ការលក់ដោយមានការភ្លក់សាកមានអានុភាព នៅពេលអ្នកទិញបានបង្ហាញឆន្ទៈយល់ព្រមក្នុងអំឡុងពេលប្រើសាក ឬអំឡុងពេលប្រើសាកនោះបានកន្លងហួស។[50] ម្យ៉ាងទៀតករណីអ្នកទិញ មិនបានបង្ហាញឆន្ទៈថាយល់ព្រមក្នុងអំឡុងពេលប្រើសាក ឬអំឡុងពេលប្រើសាកនោះបានកន្លងហួស គឺគេចាត់ទុកថា អ្នកទិញបានបដិសេធចំពោះសំណើលក់នោះ។ ម្យ៉ាងវិញទៀតករណីសំណើលក់ដោយមានការប្រើសាកមិនបានកំណត់អំឡុងពេល អ្នកស្នើអាចដាស់តឿនអ្នកទិញឲ្យធ្វើការឆ្លើយតបច្បាស់អំពីការយល់ព្រម និងមិនយល់ព្រមដោយកំណត់អំឡុងពេលមធ្យមបាន។

---

[50] ម.៥២០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ករណីអ្នកទិញមិនបានឆ្លើយតប ក្នុងអំឡុងពេលនោះ ហើយបន្តប្រើសាកវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យានោះ ក្នុងគោលដៅការពារផលប្រយោជន៍អ្នកលក់ គឺចាត់ទុកថាអ្នកទិញយល់ព្រមចំពោះសំណើលក់។

## កថាខណ្ឌ៥. ថ្លៃលក់ទិញ

តើថ្លៃលក់ទិញ គឺចាំបាច់ត្រូវតែមាននៅពេលបង្កើតកិច្ចសន្យាលក់ទិញដែរឬទេ?ជាទូទៅយោងតាមខ្លឹមសារក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ចំពោះថ្លៃលក់ទិញ គឺជាលក្ខខណ្ឌចាំបាច់មួយ ដែលត្រូវតែមាននៅពេលបង្កើតកិច្ចសន្យាលក់ទិញ ករណីការលក់ទិញ ដែលមិនមាន និងមិនកំណត់ថ្លៃលក់ទិញ គឺកិច្ចសន្យាដែលត្រូវបង្កើតនោះ និងចាត់ទុកថាជាប្រទានកម្ម ឬអំណោយ ដោយសារការផ្ទេរសិទ្ធិលើទ្រព្យ ដែលកម្មវត្ថុនៃការលក់ទិញនោះមិនទទួលបានតម្លៃតបស្នងជាប្រាក់ថ្លៃលក់ទិញត្រឡប់ទេ។

ដូចនេះថ្លៃលក់ទិញ គឺសំខាន់ និងត្រូវតែមាននៅពេលបង្កើតកិច្ចសន្យាលក់ទិញ។ប៉ុន្តែអ្វីដែលជាបញ្ហាចោទនៅទីនេះ តើភាគីត្រូវកំណត់ថ្លៃលក់ទិញយ៉ាងដូចម្តេច? ជាទូទៅកិច្ចសន្យាត្រូវបានកំណត់ថាជាច្បាប់របស់គូភាគី កិច្ចសន្យាការបង្កើត ដោយផ្អែកលើគោលការណ៍ស្វ័យភាពនៃឆន្ទៈសេរីរបស់បុគ្គលឯកជន ដូចនេះភាគីនៃកិច្ចសន្យាលក់ទិញ គឺមានសិទ្ធិសេរីភាពពេញលេញក្នុងការសម្រេចចិត្តដើម្បីកំណត់អំពីថ្លៃលក់ទិញ ប៉ុន្តែជាការកំណត់ថ្លៃលក់ទិញត្រូវបានផ្តល់សិទ្ធិសេរីភាពឲ្យភាគីជាអ្នកកំណត់ក៏ដោយ តែពេលខ្លះ ភាគីនៅតែជួបប្រទះបញ្ហាប្រឈមជុំវិញការកំណត់ថ្លៃលក់ទិញ ដោយថ្លៃលក់ទិញត្រូវតែកំណត់យ៉ាងណា ដើម្បីកុំឲ្យខ្លួនទទួលរងនៅការខូចខាតផលប្រយោជន៍។

ថ្លៃលក់ទិញ ការកំណត់គឺដើម្បីកុំឲ្យទទួលរងនូវការខូចខាតផលប្រយោជន៍ភាគីត្រូវតែកំណត់នៅក្នុងកិច្ចសន្យា និងវិធីនៃការកំណត់ថ្លៃលក់ទិញគឺធ្វើទៅតាមតម្លៃទំនិញណាមួយនៅទីផ្សារក្នុងពេលបច្ចុប្បន្ន ឬអនាគត ឬអាចផ្អែកទៅលើការវាយតម្លៃ ដែលធ្វើឡើងដោយតតិយជនដែលត្រូវបានជ្រើសរើសតាមរបៀបកំណត់របស់គូភាគី។[51] ម្យ៉ាងទៀត ករណីការវាយតម្លៃរបស់តតិយជនត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ ឬផ្ទុយទៅនឹងគោលការណ៍សមភាព គឺភាគីទទួលរងនៅការខូចខាតផលប្រយោជន៍អាចធ្វើការតវ៉ាចំពោះតម្លៃនោះបាន។

## កថាខណ្ឌ៦. សោហ៊ុយក្នុងការលក់ទិញ

ក្រៅពីថ្លៃលក់ទិញដែលសំខាន់និងត្រូវតែកំណត់ឬអាចកំណត់បាននៅពេលបង្កើតកិច្ចសន្យាលក់ទិញដោយផ្អែកតម្លៃទ្រព្យតាមទីផ្សារ ដែលជាការព្រមព្រៀងរបស់គូភាគីក្នុងការបង្កើតកិច្ចសន្យាលក់ទិញ ភាគីនៅពេលបង្កើតកិច្ចសន្យាក៏ត្រូវគិតពីសោហ៊ុយក្នុងការលក់ទិញដែលមាន នៅពេលបង្កើតកិច្ចសន្យាលក់ទិញ មូលហេតុអ្វី ដោយសារនិយមន័យនៃក្រមរដ្ឋប្បវេណីកម្ពុជាបានកំណត់ថា ការលក់ទិញ គឺសំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាងហៅថា អ្នកលក់ មានករណីយកិច្ចត្រូវផ្ទេរសិទ្ធិ ឬសិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិឲ្យទៅភាគីម្ខាងទៀតហៅថា អ្នកទិញដែលមានករណីយកិច្ចចេញថ្លៃជាប្រាក់ឲ្យអ្នកលក់។ ដូចនេះវិធីនៃការផ្ទេរសិទ្ធិលើទ្រព្យដែលកម្មវត្ថុនៃកិច្ចសន្យាភាគីត្រូវចំណាយសោហ៊ុយផ្សេងៗ ឬកម្មវត្ថុនៃកិច្ចសន្យាលក់ទិញមួយចំនួន ភ្ជាប់ជាមួយសោហ៊ុយនៃការដឹកជញ្ជូន។

---

[51] ម.៥២១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ដូចនេះនៅក្នុងការចរចារបង្កើតកិច្ចសន្យាលក់ទិញ ភាគីត្រូវតែធ្វើការពិចារណាបន្ថែមក្រៅពីថ្លៃលក់ទិញ គឺមានសោហ៊ុយក្នុងការលក់ទិញ ថាតើភាគីណាជាអ្នកទទួលបន្ទុកសោហ៊ុយក្នុងការលក់ទិញ និងជៀងវាងការខូចខាតផលប្រយោជន៍ឬបង្កជាបញ្ហាវិវាទនាពេលអានាគត ភាគីត្រូវកំណត់ក្នុងកិច្ចសន្យាឲ្យបានច្បាស់ តើភាគីណាជាអ្នកទទួលបន្ទុកសោហ៊ុយក្នុងការលក់ទិញ។ ករណីបើគ្មានការព្រមព្រៀងផ្សេងទេ ការទទួលបន្ទុក សាហ៊ុយក្នុងការលក់ទិញដែលច្បាប់កំណត់ចំពោះសោហ៊ុយធ្វើលិខិត ឬសោហ៊ុយផ្សេងៗដែលត្រូវចំណាយក្នុងការធ្វើកិច្ចសន្យាលក់ទិញ គឺភាគីត្រូវចេញតម្លៃស្មើគ្នា។[52]

## កថាខណ្ឌ៧. ភាគីនៃកិច្ចសន្យាលក់ទិញ

តើអ្នកណាជាភាគីនៃកិច្ចសន្យាលក់ទិញ? បើយោងតាមនិយមន័យ ការលក់ទិញ គឺសំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាងហៅថា អ្នកលក់ មានករណីយកិច្ចត្រូវផ្ទេរសិទ្ធិ ឬសិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិឲ្យទៅភាគីម្ខាងទៀតហៅថា អ្នកទិញដែលមានករណីយកិច្ចចេញថ្លៃជាប្រាក់ឲ្យអ្នកលក់។ ការពិចារណាចំពោះភាគីនៃកិច្ចសន្យាលក់ទិញ សម្រាប់ភាគីអ្នកលក់ អាចកំណត់បានថា អ្នកមានសិទ្ធិគឺជាបុគ្គលដែលមានករណីត្រូវផ្ទេរសិទ្ធិ ឬសិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការលក់ទិញ។ ក្នុងន័យនេះ អាចកំណត់បានថា ភាគីនៃកិច្ចសន្យាលក់ទិញ សម្រាប់ភាគីអ្នកលក់ គឺជាកម្មសិទ្ធិករនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការលក់ទិញ កាលបើភាគីអ្នកលក់មិនមានការកំណត់ផ្សេង។

[52] ម.៣៩៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

បន្ថែមពីនេះ ភាគីនៃកិច្ចសន្យាលក់ទិញ[53] បើយោងតាមខ្លឹមសារក្រមរដ្ឋប្បវេណីកម្ពុជា សំដៅលើរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយដែលអាចលក់ទិញបាន លើកលែងតែក្នុងករណីដែលច្បាប់ហាមឃាត់។

## កថាខណ្ឌ៨.វត្ថុដែលអាចលក់បាន

តើវត្ថុណាខ្លះអាចលក់បាន និងអាចយកជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញបាន? ជាទូទៅវត្ថុដែលអាចលក់បាន ឬជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញបាន គឺសំដៅទៅលើវត្ថុ ឬសិទ្ធិទាំងឡាយណា ទោះបីជាកើតមានឡើងនាពេលអនាគតក៏ដោយ ក៏អាចយកធ្វើជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញបានដែរ លើកលែងតែវត្ថុ ឬសិទ្ធិនោះមានលក្ខណៈមិនអាចធ្វើអនុប្បទាន ឬច្បាប់ហាមឃាត់មិនឲ្យធ្វើអនុប្បទាន។[54] ឧទាហរណ៍ដូចជា អាវុធខុសច្បាប់ ថ្នាំញៀនគ្រប់ប្រភេទ ការជួញដូរមនុស្ស មិនមែនជាវត្ថុនៅក្នុងពាណិជ្ជកម្ម និងមិនអាចជាវត្ថុដែលអាចលក់បានទេ។

## ផ្នែកទី២.លក្ខខណ្ឌបង្កើតកិច្ចសន្យាលក់ទិញ

ជាទូទៅការលក់ទិញមានច្រើនប្រភេទ ដោយប្រែប្រួលទៅតាមប្រភេទ កម្មវត្ថុ និងលក្ខណៈពិសេសនៃការលក់ទិញ ប៉ុន្តែប្រភេទនៃការលក់ទិញ ដែលកំណត់ជាមូលដ្ឋាននៃការសិក្សា ដោយមិនលំអិតទៅលើការលក់ទិញជុំវិញកិច្ចស៊ីវិលទេ ដែលសិក្សាសំដៅទៅដល់ការលក់ទិញដែលមានតម្លៃថ្លៃខាងសេដ្ឋកិច្ច ដោយកំណត់អំពីប្រភេទផ្សេងៗនៃកម្មវត្ថុលក់ដែល

[53] ម.៥២៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[54] ម.៥២៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

មានដូចជាចលនវត្ថុ និងអចលនវត្ថុ មានកំណត់អំពីប្រភេទផ្សេងៗនៃកាតព្វកិច្ចដែលជាជម្រើសរបស់ភាគីនៃកិច្ចសន្យាលក់។ បន្ថែមពីនេះ ដើម្បីបង្កើតកិច្ចសន្យាលក់ទិញ តើបុគ្គលទាមទារឲ្យបំពេញនូវលក្ខខណ្ឌអ្វីខ្លះ? អនុលោមតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជា ការបង្កើតកិច្ចសន្យាលក់ទិញដូចទៅនឹងការបង្កើតកិច្ចសន្យាទូទៅ ដែលទាមទារឲ្យមានការព្រមព្រៀងរវាងភាគីទាំងសងខាងក្នុងការបង្កើតទំនាក់ទំនងគតិយុត្ត[55] ប៉ុន្តែការលក់ទិញមានច្រើនភេទ ក្រៅពីបញ្ញត្តិក្នុងវិធានទូទៅនៃច្បាប់សារធាតុកិច្ចសន្យាលក់ទិញក៏មានបញ្ញត្តិនៅក្នុងវិធានពិសេសនៅក្នុងវិស័យជំនួញជាច្រើនទៀត។ ដូចនេះលក្ខខណ្ឌតម្រូវចំពោះការបង្កើតកិច្ចសន្យាលក់ទិញអាចតម្រូវឲ្យបំពេញលក្ខខណ្ឌបន្ថែមទៀត។

បន្ថែមពីនេះ ចំពោះលក្ខខណ្ឌទម្រង់នៃការបង្កើតកិច្ចសន្យាលក់ទិញ ភាគីអាចកំណត់ការធ្វើជាលិខិតយថាភូត ឬជាលិខិតឯកជនជាលក្ខខណ្ឌសម្រាប់ការបង្កើតបាន។

## កថាខណ្ឌ១. លក្ខខណ្ឌគ្រឹះនៃការបង្កើតការលក់ទិញ

ជាទូទៅលក្ខខណ្ឌគ្រឹះនៃការបង្កើតកិច្ចសន្យាលក់ទិញ ដូចគ្នាទៅនឹងការបង្កើតកិច្ចសន្យាទូទៅដែលទាមទារឲ្យភាគីត្រូវតែបំពេញនូវលក្ខខណ្ឌដូចជា ការព្រមព្រៀងបង្កើតការលក់ទិញ, សមត្ថភាពគូភាគីនៃការបង្កើតការលក់ទិញ និងកម្មវត្ថុ និងមូលហេតុនៃការបង្កើតការលក់ទិញ។

[55] ម.៥១៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

## ១. ការព្រមព្រៀងបង្កើតការលក់ទិញ

ការព្រមព្រៀងបង្កើតការលក់ទិញសំដៅដល់ការព្រមព្រៀងដែលគិតប្រាកដ ដោយផ្អែកលើគោលការណ៍ស្វ័យភាពនៃឆន្ទៈសេរីរបស់បុគ្គលឯកជនក្នុងការសម្រេចចិត្តដើម្បីបង្កើតទំនាក់ទំនងគតិយុត្ត ឬបង្កើតការលក់ទិញនាពេលអនាគត។ ការព្រមព្រៀងសំដៅដល់ការព្រមព្រៀងដែលគ្មានវិការៈនៃការព្រមព្រៀង ឬគ្មានវិការៈនៃការបង្ហាញឆន្ទៈ ករណីកិច្ចសន្យាលក់ទិញបង្កើតឡើងដោយវិការៈនៃការបង្ហាញឆន្ទៈ កិច្ចសន្យា ត្រូវចាត់ទុកជាមោឃៈ និងភាគីអាចសុំអះអាងអំពីការមោឃភាព ឬលុបចោល។

## ២. សមត្ថភាពគូភាគីនៃការលក់ទិញ

តើសមត្ថភាពគូភាគីនៃការលក់ទិញសំខាន់នៅពេលបង្កើតកិច្ចសន្យាលក់ទិញ ឬទេ? ជាទូទៅស្របតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជា ភាគីដែលមានសមត្ថភាពក្នុងការបង្កើតកិច្ចសន្យាលក់ទិញ គឺសំដៅទៅលើរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមិនត្រូវបានហាមឃាត់ដោយច្បាប់ ឬជាជនដែលមានសមត្ថភាពតាមផ្លូវច្បាប់ សម្រាប់រូបវន្តបុគ្គល សំដៅដល់នីតិជនដែលមានអាយុចាប់ពី១៨ឆ្នាំ មិនមានបញ្ហាវិបល្លាសខាងស្មារតី ឬជាអនីតិជនដែលមានអត្តាធិនភាព ជាជនទទួលបានសិទ្ធិតាមរយៈការស្នើសុំ។ សម្រាប់នីតិបុគ្គលដែលជាភាគីនៃកិច្ចសន្យាលក់ទិញ ការបង្កើតកិច្ចសន្យាលក់ទិញ គឺត្រូវធ្វើតាមរយៈអ្នកតំណាង ហើយតម្រូវឲ្យភ្ជាប់មកជាមួយនូវសំណុំឯកសារបញ្ជាក់អំពីទំហំនៃសិទ្ធិតំណាងបង្កើតកិច្ចសន្យាលក់ទិញ។

## ៣.កម្មវត្ថុនិងមូលហេតុនៃការលក់ទិញ

ជាទូទៅកម្មវត្ថុនៃកិច្ចសន្យាលក់ទិញត្រូវតែមាន ត្រូវតែកំណត់បាន ត្រូវតែអនុវត្តបាន និងត្រូវតែកំណត់នៅពេលបង្កើតកិច្ចសន្យាលក់ទិញ តើមូលហេតុអ្វីតម្រូវឲ្យមានការកំណត់ច្បាស់លាស់អំពីកម្មវត្ថុនៅក្នុងកិច្ចសន្យាលក់ទិញ បង្ករភាពងាយស្រួលដល់ភាគី ក្នុងការកំណត់អំពីប្រភេទផ្សេងៗនៃកាតព្វកិច្ចដែលត្រូវប្រតិបត្តិតាមរយៈកិច្ចសន្យាទិញលក់ដែលកើតមាននាពេលអនាគត។ ម្យ៉ាងទៀត មូលហេតុនៃការលក់ទិញ អាចជាវត្ថុបំណងដែលភាគីចង់បាន ឧទាហរណ៍ អ្នកលក់ អាចមានបំណងស្វែងរកប្រាក់ចំណេញ និងអ្នកទិញអាចមានបំណងដើម្បីបំពេញសេចក្តីត្រូវការផ្ទាល់ខ្លួន។ បន្ថែមពីនេះបើយោងតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជា កម្មវត្ថុ និងមូលហេតុនៃការលក់ទិញ គឺត្រូវតែស្របច្បាប់ និងស្របទៅនឹងទំនៀមទម្លាប់ដ៏ល្អប្រពៃ។

## កថាខណ្ឌ២.លក្ខខណ្ឌទម្រង់នៃការបង្កើតការលក់ទិញ

ជាទូទៅកិច្ចសន្យាលក់ទិញ ការបង្កើតអាចធ្វើឡើងតាមការព្រមព្រៀងរវាងអ្នកលក់និងអ្នកទិញតាមទម្រង់ផ្ទាល់មាត់ ឬកិច្ចសន្យាលក់ទិញអាចធ្វើជាទម្រង់លិខិតលាយលក្ខណ៍អក្សរ អាស្រ័យទៅតាមជម្រើសរបស់គូភាគី។ ប៉ុន្តែចំពោះប្រភេទនៃការលក់ទិញមួយចំនួន ច្បាប់សារជាតុ ឬវិធានពិសេសបានកំណត់អំពីលក្ខខណ្ឌនៃការការពារផលប្រយោជន៍ ដែលតម្រូវឲ្យភាគីត្រូវធ្វើជាលិខិតលាយលក្ខណ៍អក្សរ។

ដូចនេះការបង្កើតកិច្ចសន្យាលក់ទិញ គឺប្រែប្រួលទៅតាមប្រភេទផ្សេងៗគ្នា ដោយប្រែប្រួលទៅតាមប្រភេទនិងលក្ខណៈពិសេសនៃការលក់ទិញ ដោយមានបែងចែករវាងការលក់ទិញចលនវត្ថុ និងអចលនវត្ថុ។

## ផ្នែកទី៣.អានុភាពនៃកិច្ចសន្យាលក់ទិញ

ជាទូទៅកិច្ចសន្យាលក់ទិញមានសុពលភាព គឺបានកំណត់នូវអានុភាពគតិយុត្តដែលជាអានុភាពនៃការបង្កើតសិទ្ធិ និងករណីយកិច្ចសម្រាប់ភាគីអ្នកលក់និងភាគីអ្នកទិញ។ តាមរយៈនោះគេអាចកំណត់បានថាអានុភាពនៃកិច្ចសន្យាលក់ទិញ បើធ្វើការបកស្រាយទៅតាមនិយម័យនៃការលក់ទិញ គឺអ្នកលក់ មានកាតព្វកិច្ចត្រូវផ្ទេរសិទ្ធិទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការលក់ទៅឲ្យអ្នកទិញ និងអ្នកទិញមានកាតព្វកិច្ចនៃការបង់ប្រាក់ថ្លៃលក់គ្រប់ចំនួនទៅឲ្យអ្នកលក់វិញ។

អានុភាពនៃកិច្ចសន្យាលក់ទិញ តាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជាអាចសិក្សាបែងចែករវាងសិទ្ធិនិងករណីយកិច្ចអ្នកលក់(កថាខណ្ឌ១) និងសិទ្ធិនិងករណីយកិច្ចរបស់អ្នកទិញ(កថាខណ្ឌ២)។

### កថាខណ្ឌ១. សិទ្ធិ និងករណីយកិច្ចអ្នកលក់

នៅពេលកិច្ចសន្យាលក់ទិញកំណត់អានុភាព អ្នកលក់មានសិទ្ធិទាមទារឲ្យអ្នកលក់ប្រគល់ថ្លៃលក់ទិញគ្រប់ចំនួនស្របតាមខ្លឹមសារដូចបានកំណត់នៅក្នុងកិច្ចព្រមព្រៀង។ ម្យ៉ាងវិញទៀតរយៈសិទ្ធិដែលទទួលបានការពារអ្នកលក់ក៏មានករណីយកិច្ចមួយចំនួនដូចជា ករណីយកិច្ចប្រគល់វត្ថុ

ករណីយកិច្ចផ្ទេរកម្មសិទ្ធិ, ករណីយកិច្ចពន្យល់, ករណីយកិច្ចធានាចំពោះវិការៈនៃវត្ថុ និងករណីយកិច្ចគ្រប់គ្រងវត្ថុ។

## កថាខណ្ឌ២. សិទ្ធិ និងករណីយកិច្ចអ្នកទិញ

ជាទូទៅនៅពេលកិច្ចសន្យាលក់ទិញកំណត់អានុភាព អ្នកទិញមានសិទ្ធិទាមទារឲ្យអ្នកលក់ផ្ទេរសិទ្ធិនូវទ្រព្យសម្បត្តិ ដែលកំណត់ថាជាកម្មវត្ថុនៃការលក់ទិញស្របតាមខ្លឹមសារកាតព្វកិច្ចដែលកើតពីកិច្ចសន្យាលក់ទិញ។

បន្ថែមពីនេះក្រៅពីសិទ្ធិទទួលបាន អ្នកទិញក៏មានករណីយកិច្ចមួយចំនួនត្រូវបំពេញរួមមាន ករណីយកិច្ចទទួលវត្ថុ ដែលជាកម្មវត្ថុនៃការលក់ទិញ និងករណីយកិច្ចបង់ប្រាក់គ្រប់ចំនួនទៅឲ្យភាគីអ្នកលក់។

## មេរៀនទី៣

## អំពីកិច្ចសន្យាការងារ

ក្រោមក្របខណ្ឌនីតិរដ្ឋតម្រូវឲ្យបុគ្គល ស្វែងយល់ពីវិធានជាច្រើន ក្នុងគោលបំណងដើម្បីសម្របសម្រួលទំនាក់ទំនងនៃជីវភាពរស់នៅប្រចាំថ្ងៃ និងវិធានទាំងនោះ អាចរួមមានវិធានដែលកើតចេញពីឆន្ទៈសេរីរបស់បុគ្គល និងកើតចេញពីកិច្ចឯកជន ដើម្បីបំពេញសេចក្តីត្រូវការប្រចាំថ្ងៃរបស់ពួកគេ ក្នុងនោះវិធានដែលអនុវត្តញឹកញាប់ជាងគេ គឺជាវិធាននៃកិច្ចសន្យា។

វិធាននៃកិច្ចសន្យា គឺជាវិធានរួមនៃនីតិឯកជន កើតចេញពីកិច្ចឯកជនរបស់បុគ្គល កើតចេញពីឆន្ទៈសេរីរបស់គូភាគី និងគេអាចសន្មតបានថាជាច្បាប់របស់គូភាគី។ ដូចនេះកិច្ចសន្យា គឺជាការព្រមព្រៀងរវាងបុគ្គលពីរ រឺច្រើន ដើម្បីបង្កើត កែប្រែ រំលត់សិទ្ធិ និងកាតព្វកិច្ចមួយចំនួនដែលទាក់ទិននឹងខ្លួន[56] ។ កិច្ចសន្យាត្រូវបែងចែកជាច្រើនប្រភេទ អាចជាប្រភេទនៃកិច្ចសន្យាពិសេស ដែលមានលក្ខណៈពិសេស ប្រែប្រួលទៅតាមកម្មវត្ថុ និងជម្រើសរបស់ភាគីផ្សេងគ្នា ប៉ុន្តែអ្វីដែលជាបញ្ហាចោទទាំងទំនាក់ទំនង និងការបង្កើតនៅទីនេះគឺកិច្ចសន្យាការងារ។

---

[56] ក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច. ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវនៅក្រៅកិច្ចសន្យា ឆ្នាំ១៩៨៨។

**តើអ្វីទៅជាកិច្ចសន្យាការងារ? ដើម្បីបង្កើតកិច្ចសន្យាការងារឲ្យមានសុពលភាព ថាតើបុគ្គលត្រូវបំពេញនូវលក្ខខណ្ឌអ្វីខ្លះ?**

ការងារ គឺសំដៅទៅលើការសម្តែងចេញនូវគ្រប់សកម្មភាពរបស់បុគ្គល ដែលប្រើប្រាស់ទាំងកម្លាំងកាយ និងកម្លាំងប្រាជ្ញា ដើម្បីប្តូរមកវិញនូវប្រាក់កម្រៃ។ ការងារត្រូវបានបែងចែកជាពីរប្រភេទ រួមមានការងារជាប់ពាក់ព័ន្ធ និងការងារដោយឯករាជ្យ។

ការងារជាប់ពាក់ព័ន្ធ គឺសំដៅទៅលើការងារ ដែលមានទំនាក់ទំនងរវាងចៅហ្វាយនាយ និងកូនចៅ មានន័យថា ភាគីម្ខាងជាកូនចៅបានប្រើប្រាស់អស់ទាំងកម្លាំងកាយ និងកម្លាំងប្រាជ្ញា ដើម្បីបំពេញការងារជូនភាគីម្ខាងទៀត ដែលជាចៅហ្វាយនាយ ដើម្បីទទួលបានមកវិញនូវប្រាក់កម្រៃ។

ការងារដោយឯករាជ្យ គឺសំដៅទៅលើការងារដែលមិនមានទំនាក់ទំនងរវាងចៅហ្វាយនាយ និងកូនចៅ មានន័យថាបុគ្គលបានបំពេញការងារដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន បុគ្គលមានសិទ្ធិសេរីភាពពេញលេញក្នុងការសម្រេចចិត្តចំពោះសកម្មភាពការងាររបស់ខ្លួន ដោយមិនស្ថិតនៅក្នុងស្ថានភាពចំនុះ និងបុគ្គលមានសិទ្ធិគ្រប់យ៉ាង ដើម្បីចាត់ចែងកិច្ចការដោយខ្លួនឯង ស្ថានភាពនេះ គឺមានលក្ខណៈប្រថុយប្រថានចំពោះលទ្ធផលការងារដែលកើតេចញពីទង្វើរបស់ខ្លួន ដោយបុគ្គលអាចទទួលបាននូវការខាតបង់ ឬជាលាភសក្ការៈនាពេលអនាគត ចំពោះសកម្មភាពកើតចេញពីទង្វើរបស់ខ្លួន។

ដូចនេះកិច្ចសន្យាការងារ គឺជាវិធានដែលមានអានុភាពគ្រប់គ្រង លើប្រភេទនៃការងារជាប់ពាក់ព័ន្ធ។ កិច្ចសន្យាការងារ គឺសំដៅទៅលើការព្រមព្រៀងរវាងភាគីដោយក្នុងនោះរួមមាន ភាគីម្ខាង ជាថៅហ្វាយនាយ (និយោជក) និងភាគីម្ខាងទៀត ជាកូនចៅ(និយោជិត) បានសន្យាថា បំពេញការងារជូននិយោជក ដើម្បីជាប្រយោជន៍និយោជក ក្នុងនាម និយោជក ដើម្បីប្តូរមកវិញនូវប្រាក់កម្រៃប្រចាំខែ។

## តើកិច្ចសន្យាការងារបែបណាដែលស្ថិតក្រោមការគ្រប់គ្រងនៃច្បាប់ការងារកម្ពុជា?

ជាទូទៅច្បាប់ការងារកម្ពុជាគឺជាបណ្តុំវិធានគតិយុត្ត ដែលបង្កើត ក្នុងគោលបំណងដើម្បីគ្រប់គ្រង និងសម្របសម្រួលទំនាក់ទំនងរវាងភាគីនៃ កិច្ចសន្យាការងារ។[57]ម្យ៉ាងទៀតដើម្បីអាចកំណត់បានថា ច្បាប់ការងារកម្ពុជា មានអានុភាពអាចអនុវត្តបាន ឬមិនបាន គេបានធ្វើការសិក្សាវិភាគទៅ លើលក្ខខណ្ឌមួយចំនួនរួមមានទី១គឺទំនាក់ទំនងរបស់ភាគីនៃកិច្ចសន្យា ជាប្រភេទការងារជាប់ពាក់ព័ន្ធ ដោយតម្រូវឲ្យមានកិច្ចសន្យាការងារ និងទី២ កិច្ចសន្យាការងារនោះត្រូវតែបានអនុវត្តនៅកម្ពុជា។ មានន័យថាទោះបីជា កិច្ចសន្យាការងារបង្កើតពីបុគ្គលដែលមានជាតិសាសន៍ពីរផ្សេងគ្នា រឺក៏ជាជន បរទេសទាំងពីរភាគីក៏ដោយ ប៉ុន្តែសកម្មភាពការងារត្រូវអនុវត្តនៅកម្ពុជា សន្មតបានថាច្បាប់ការងារកម្ពុជា មានអានុភាពគ្រប់គ្រងទៅលើសកម្មភាព ទាំងនោះ។

[57]ម.១ ច្បាប់ស្តីពីការងារកម្ពុជា ឆ្នាំ១៩៩៧។

ប៉ុន្តែបញ្ហាចោទនៅទីនេះ គឺការបង្កើតកិច្ចសន្យាការងារដើម្បីបង្កើតកិច្ចសន្យាការងារឲ្យមានសុពលភាព តើបុគ្គលត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ? កិច្ចសន្យាការងារជាទូទៅត្រូវបានចាត់ទុក ជាប្រភេទនៃកិច្ចសន្យាពិសេស និងថាតើលក្ខខណ្ឌសុពលភាពនៃការបង្កើត ដូចគ្នាទៅនឹងការបង្កើតកិច្ចសន្យាទូទៅ រឺទេ?។

អនុលោមតាមមាត្រាខាងលើ កិច្ចសន្យាការងារត្រូវធ្វើឡើងក្រោមទម្រង់ដែលភាគីបានព្រមព្រៀងគ្នា មានន័យថា កិច្ចសន្យាការងារត្រូវបង្កើតដោយឆន្ទៈសេរីរបស់គូភាគី គឺជាឆន្ទៈព្រមព្រៀងរវាងបុគ្គលពីរ ឬច្រើននាក់ដើម្បីបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ចមួយ ឬច្រើនដែលទាក់ទិននឹងខ្លួន។[58] គោលការណ៍ដែលបញ្ញត្តិខាងលើនេះអាចសន្មតបានថា កិច្ចសន្យាការងារមានលក្ខខណ្ឌបង្កើតដូចជាការបង្កើតកិច្ចសន្យាទូទៅ។ ដូចនេះកិច្ចសន្យាការងារមានសុពលភាព លុះត្រាតែកាតព្វកិច្ចកើត ចេញពីកិច្ចសន្យា គឺកើតចេញពីការព្រមព្រៀងគិតប្រាកដ និងដោយសេរី កើតចេញពីជនដែលមានសមត្ថភាពចុះកិច្ចសន្យានិងមានកម្មវត្ថុជាក់លាក់អាចអនុវត្តបានស្របច្បាប់របៀបរៀបរយសាធារណៈ និងទំនៀមទម្លាប់ដ៏ល្អប្រពៃ។[59]

អត្ថន័យខាងលើនេះ យើងអាចធ្វើការសិក្សាវិភាគលើចំណុចមួយចំនួនដូចជា៖ ការបង្កើតកិច្ចសន្យាការងារ(ផ្នែកទី១), ប្រភេទផ្សេងៗនៃកិច្ចសន្យាការងារ(ផ្នែកទី២)។

---

[58] ម.១ ក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច. ឆ្នាំ១៩៨៨។

[59] ម.៣ ក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច. ឆ្នាំ១៩៨៨។

## ផ្នែកទី១. ការបង្កើតកិច្ចសន្យាការងារ

### កថាខណ្ឌ១. ការព្រមព្រៀងដោយសេរី និងពិតប្រាកដ

មានន័យថាកិច្ចសន្យាការងារត្រូវតែ បង្កើតដោយការព្រមព្រៀងពិតប្រាកដ រវាងថៅហ្វាយនាយ និងកូនថៅ គ្មានការបង្ខិតបង្ខំពីមជ្ឈដ្ឋានផ្សេងទៀត គឺសំដៅដល់ការព្រមព្រៀងដែលកើតពីឆន្ទៈសេរី គ្មានវិការៈនៃការព្រមព្រៀង។ ម្យ៉ាងវិញទៀតយើងអាចធ្វើការសិក្សាវិភាគ អំពីកិច្ចសន្យាការងារដោយផ្អែកលើគោលការណ៍នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧[60] ដោយធ្វើការបកស្រាយដូចខាងក្រោម៖

តាមមាត្រាខាងលើនេះយើងអាចកំណត់បានថា កិច្ចសន្យាការងារ គឺសំដៅទៅលើការសន្យារបស់គូភាគី កំណត់ថាកម្មករនិយោជិតសន្យាថាធ្វើពលកម្មឲ្យនិយោជកដោយប្តូរមកវិញនូវប្រាក់ឈ្នួល លើកិច្ចការពលកម្មដែលកម្មវត្ថុការងារពលកម្ម និយោជកត្រូវតែកំណត់ជាក់លាក់ ករណីខុសពីការសន្យា កម្មករនិយោជិតមានសិទ្ធិរំលាយកិច្ចសន្យាការងារភ្លាមៗបាន។

ម្យ៉ាងវិញទៀតតាមខ្លឹមសារក្រមរដ្ឋប្បវេណីកម្ពុជា បានកំណត់ថាកិច្ចសន្យាការងារគឺជាប្រភេទកិច្ចសន្យា ដែលមានភាពផ្តាច់មុខលើបុគ្គលនៃកិច្ចសន្យាការងារ តើមូលហេតុអ្វី ? ការបង្កើតកិច្ចសន្យាការងារ គឺផ្អែកលើគុណវុឌ្ឍរបស់បុគ្គល លក្ខណៈសម្បត្តិ របស់បុគ្គលលើការងារពលកម្ម និងត្រូវកំណត់ពីការទទួលខុសត្រូវរបស់បុគ្គលក្នុងកិច្ចសន្យាការងារ ដូចនេះករណីគ្មានការអនុញ្ញាតិពីនិយោជក កម្មករនិយោជិត មិនអាចធ្វើអនុប្បទាន

[60] ម.៦៦៤, និង៦៦៨ ៦៦៥,៦៦៦,៦៦៧ , ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

សិទ្ធិរបស់ខ្លួនឲ្យតតិយជន ឬផ្ទេរការងាររបស់ខ្លួនឲ្យតតិយជនអនុវត្តជំនួស បានទេ។ លើសពីនេះភាគីនិយោជក ត្រូវមានករណីយកិច្ចទទួលខុសត្រូវ លើសុវត្ថិភាពរបស់កម្មករនិយោជិត ចំពោះកិច្ចការពលកម្មដែលបានសន្យា ដោយរក្សាសុខភាពរូបកាយរបស់កម្មករនិយោជិត ដែលករណីខាងលើនេះ មានបញ្ញត្តិលំអិតនៅក្នុងច្បាប់ការងារកម្ពុជា។

ដូចនេះការបង្កើតកិច្ចសន្យាការងារ គឺតម្រូវឲ្យមានសំណើ និង ស្ទីការត្រូវគ្នា និងមានសុពលភាពនៅពេលមានកម្មវត្ថុ មូលហេតុស្របច្បាប់ ស្របទៅនឹងសណ្តាប់ធ្នាប់ សាធារណៈនិងទំនៀមទម្លាប់ដ៏ល្អប្រពៃ ត្រូវ មានសមត្ថភាពគតិយុត្ត និងបង្កើតដោយការព្រមព្រៀងគ្មាន វិការៈនៃការ ព្រមព្រៀង។

## តើអ្វីទៅជាវិការៈនៃការព្រមព្រៀង?

ជាទូទៅវិការៈនៃការព្រមព្រៀង យើងធ្វើការបកស្រាយទៅតាមការ វិវត្តន៍នៃវិធានគតិយុត្តិ រួមមានគោលការណ៍នៃក្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ច សន្យានិងការទទួលខុសត្រូវនៅក្រៅកិច្ចសន្យា និងគោលការណ៍ដែលបាន បញ្ញត្តិតាមមាត្រានៃក្រមរដ្ឋប្បវេណី។វិការៈនៃការព្រមព្រៀង គឺជាទណ្ឌកម្ម ចំពោះលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា ភាគីចំពោះករណីវិការៈនៃការ ព្រមព្រៀងអាចធ្វើអះអាងអំពីការលុបចោល ឬមោឃភាពកិច្ចសន្យា។

វិការៈនៃការព្រមព្រៀង គេអាចធ្វើការបកស្រាយដោយធៀបជាមួយ នឹងគោលការណ៍ស្វ័យភាពនៃឆន្ទៈសេរីរបស់បុគ្គលឯកជន មានន័យថា បុគ្គលត្រូវមានសិទ្ធិសេរីភាពពេញលេញក្នុងការសម្រេចចិត្ត ជាពិសេសដើម្បី

បង្កើតទំនាក់ទំនងគតិយុត្តិ ដោយក្នុងការបង្កើតកិច្ចសន្យាការងារភាគីនៃកិច្ចសន្យាការងារ គឺត្រូវតែពេញចិត្ត និងយល់ព្រមស្ម័គ្រចិត្តដោយគ្មានមន្ទិលសង្ស័យ មិនមានភាពស្ទាក់ស្ទើរ ក្នុងការសម្រេចចិត្តលើលក្ខខណ្ឌការងារ កិច្ចការងារពលកម្ម និងកម្មវត្ថុនៃកិច្ចសន្យាការងារ។ ករណីមានចំណុចណាមួយមិនប្រក្រតី ជាមន្ទិលក្នុងការសម្រេចចិត្តគេចាត់ទុកថាមានវិការៈដែលនាំឲ្យភាគីអាចធ្វើអះអាងអំពីមោឃភាពកិច្ចសន្យា។ ដើម្បីសិក្សាអំពីខ្លឹមសារវិការៈនៃការព្រមព្រៀងឲ្យបានលំអិត យើងអាចធ្វើការសិក្សាប្រៀបធៀបអំពីខ្លឹមសារវិការៈនៃការព្រមព្រៀង តាមគោលការណ៍នៃក្រឹត្យច្បាប់លេខ៣៨ស្តីពីកិច្ចសន្យានិងការទទួលខុសត្រូវនៅក្រៅកិច្ចសន្យា និងវិការៈនៃការព្រមព្រៀងតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជា។

## ១. វិការៈនៃការព្រមព្រៀងតាមខ្លឹមសារក្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវនៅក្រៅកិច្ចសន្យា

**<u>វិការៈនៃការព្រមព្រៀង</u>៖** គឺជាមូលហេតុធ្វើឲ្យការព្រមព្រៀងគ្មាន សុពលភាព និងជាមូលហេតុនៃការមោឃភាពកិច្ចសន្យា ចំពោះគ្រប់រាល់កិច្ចសន្យាទាំងឡាយដែលការបង្កើតមានវិការៈនៃការព្រមព្រៀង។

បន្ថែមពីនេះ យោងតាមក្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវនៅក្រៅកិច្ចសន្យា ជាតុវិការៈ នៃការព្រមព្រៀង រួមមានការភាន់ច្រលំ ការបន្លំបោកប្រាស់ និងការប្រើប្រាស់ហិង្សា។[61]

---

[61] ក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច. ឆ្នាំ១៩៨៨។

**<u>ការភាន់ច្រលំ៖</u>** គឺសំដៅគ្រប់រាល់ការបកស្រាយទាំងអស់ ដែលមិនច្បាស់លាស់រឺមិនពិតប្រាកដ ត្រូវបានចាត់ទុកថាជាការភាន់ច្រលំ។ ជាទូទៅការភាន់ច្រលំជាមូលហេតុនៃការមោឃភាពកិច្ចសន្យា ប៉ុន្តែការភាន់ច្រលំមិនចាប់បង្ខំឲ្យភាគីត្រូវតែមោឃភាពកិច្ចសន្យានោះទេ ពីព្រោះការភាន់ច្រលំមួយចំនួន មិនមែនជាការភាន់ច្រលំចំណុចសំខាន់ ទ្រទ្រង់លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា ម្យ៉ាងទៀតគឺផ្អែកទៅលើឆន្ទៈសេរីរបស់ភាគី ថាតើភាគីយល់ព្រម ឬមិនយល់ព្រមទទួលយកនូវការភាន់ច្រលំ។

**<u>ការបន្លំបោកប្រាស់៖</u>** រាល់សកម្មភាពទាំងឡាយ ដែលស្តែងចេញពីទង្វើរបស់បុគ្គល ដែលបុគ្គលអាចជាភាគី ឬជាតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍ទៅនឹងភាគីនៃកិច្ចសន្យា តាមរយៈនោះបុគ្គលបានប្រើប្រាស់គ្រប់កលល្បិចកលវិធី ដើម្បីឲ្យភាគីម្ខាងទៀតព្រមចុះកិច្ចសន្យា។ ការបន្លំបោកប្រាស់ជាមូលហេតុដែលធ្វើឲ្យកិច្ចសន្យាគ្មានសុពលភាព និងភាគីអាចមានសិទ្ធិសុំមោឃភាព។

**<u>ការប្រើប្រាស់ហិង្សារឺការគំរាមកំហែង៖</u>** ទាក់ទងទៅនឹងអំពើមួយចំនួនដែលបានបង្កឡើង សំដៅបង្ខំភាគីឲ្យយល់ព្រមចុះកិច្ចសន្យាជាមួយ។

ករណីនៃការប្រើប្រាស់ហិង្សារឺការគំរាមកំហែង ដូចជាការប្រើប្រាស់ហិង្សាដោយបំពាន ទៅលើសេរីភាពរបស់ភាគីតាមគ្រប់រូបភាពដោយផ្ទាល់ ឬដោយប្រយោលក្តីត្រូវ បានចាត់ទុកថាជាការប្រើប្រាស់ហិង្សា។

ដូចនេះរាល់ការព្រមព្រៀងទាំងឡាយដែលមានវិការៈ គឺការព្រមព្រៀងគ្មានសុពលភាព និងគ្រប់កិច្ចសន្យាទាំងឡាយដែលកើតចេញពីការព្រមព្រៀងដែលមានវិការៈ ចាត់ទុកថាកិច្ចសន្យានោះគ្មានសុពលភាព។

## ២.វិការៈនៃការព្រមព្រៀងតាមគោលការណ៍នៃក្រមរដ្ឋប្បវេណីកម្ពុជា

ជាទូទៅវិការៈនៃការព្រមព្រៀង គឺជាទណ្ឌកម្មចំពោះលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា និងភាគីនៃកិច្ចសន្យាអាចលើកមូលហេតុអំពីវិការៈនៃការព្រមព្រៀងដើម្បីអះអាងអំពីការលុបចោលកិច្ចសន្យា។[62] បន្ថែមពីនេះការសិក្សាអំពីវិការៈនៃការព្រមព្រៀង ភាគីអាចធ្វើការសិក្សាវិភាគនិងការកំណត់អំពីជាតផ្សំនៃវិការៈនៃការព្រមព្រៀង ដោយផ្អែកលើខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧។

វិការៈនៃការព្រមព្រៀង បើយោងតាមគោលគំនិតនៃមាត្រា៣៤៥នៃក្រមរដ្ឋប្បវេណីកម្ពុជា ភាគីនៃកិច្ចសន្យា អាចលុបចោលកិច្ចសន្យាបានដោយមូលហេតុនៃការបង្ហាញឆន្ទៈមានវិការៈ។ ទាំងនេះមានន័យថានៅក្នុងទំនាក់ទំនងកិច្ចសន្យា ទោះបីជាភាគីស្ថិតក្នុងស្ថានភាពទុច្ចរិតឬសុច្ចរិត ក៏ករណីវិការៈនៃការបង្ហាញឆន្ទៈ គឺ ភាគីអាចមានសិទ្ធិអះអាងអំពីលុបចោលកិច្ចសន្យា។ ផ្អែកតាមខ្លឹមសារមាត្រានៃក្រមរដ្ឋប្បវេណីកម្ពុជាខាងលើជាតុវិការៈនៃការបង្ហាញឆន្ទៈរួមមាន៖ ការបង្ហាញឆន្ទៈត្រូវធ្វើឡើងដោយការភាន់ច្រលំ, ការបង្ហាញឆន្ទៈធ្វើឡើងដោយការឆបោកឬការគម្រាមកំហែង ឬការ

---

[62] ម៣៤៥. ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

បង្ហាញការមិនពិតរបស់ភាគីម្ខាងទៀត និងការបង្ហាញឆន្ទៈដែលត្រូវបានធ្វើឡើងដោយអំពីនៃការកេងយកចំណេញហួសហេតុ។

បញ្ញត្តិអំពីវិការៈនៃការព្រមព្រៀងស្របតាមខ្លឹមសារក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ គឺមានខ្លឹមសារលំអិតជាងគោលការណ៍ដែលបានកំណត់នៅក្នុងខ្លឹមសារនៃក្រឹត្យច្បាប់លេខ៣៨ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវនៅក្រៅកិច្ចសន្យា អាចឲ្យយើងធ្វើការសិក្សាវិភាគដូចខាងក្រោម៖

## ៣. អំពីការភាន់ច្រឡំតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណី

ជាទូទៅរាល់ការបកស្រាយទាំងឡាយណា ដែលមិនច្បាស់លាស់ត្រូវបានចាត់ទុកថាជាការភាន់ច្រឡំ ប៉ុន្តែបញ្ហាចោទចំពោះការបកស្រាយអំពីការភាន់ច្រឡំនៅទីនេះ ដោយផ្អែកតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជា គឺមានការសិក្សាបែងចែកអំពីប្រភេទផ្សេងនៃការភាន់ច្រឡំដោយប្រែប្រួលទៅតាមប្រភេទនៃករណីសិក្សានីមួយៗ[63]។

បន្ថែមពីនេះ យោងតាមគោលការណ៍នៃក្រមរដ្ឋប្បវេណីកម្ពុជា ការភាន់ច្រឡំ យើងអាចធ្វើការបែងចែកដូចជាការភាន់ច្រឡំចំណុចសំខាន់ ការភាន់ច្រឡំចំណុចដែលភាគីយល់ឃើញថាសំខាន់ និងការភាន់ច្រឡំរួម។

### ៣.១. ការភាន់ច្រឡំចំណុចសំខាន់

នៅក្នុងទំនាក់ទំនងគតិយុត្តិ គេអាចធ្វើការបកស្រាយបានថា ចំណុចសំខាន់នៃកិច្ចសន្យា គឺជាចំណុចដែលទ្រទ្រង់ចំពោះលក្ខខណ្ឌសុពលភាព

[63]ម.៣៤៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

នៃការបង្កើតកិច្ចសន្យា និងមានទំនាក់ទំនងទៅនឹងការអនុវត្តកិច្ចសន្យា។ ដូចនេះចំពោះកិច្ចសន្យាការងារ ករណីភាគីមានការភាន់ច្រឡំចំពោះប្រភេទនៃកិច្ចការពលកម្ម និងការកំណត់ប្រាក់ឈ្នួល គេក៏អាចចាត់ទុកថាជាការភាន់ច្រឡំចំណុចសំខាន់ ដែលភាគីអាចអះអាងអំពីការលុបចោលកិច្ចសន្យាដោយហេតុថាវិការៈនៃការព្រមព្រៀង។

## ៣.២. ការភាន់ច្រឡំចំណុចដែលភាគីយល់ឃើញថាសំខាន់

ជាទូទៅចំណុចដែលភាគីយល់ឃើញថាសំខាន់ ត្រូវបានចាត់ទុកថាជាចំណុចបន្ទាប់បន្សំក្នុងកិច្ចសន្យា។ ដូចនេះសម្រាប់ស្ថានភាពទូទៅ បុគ្គលផ្សេងទៀតគេអាចមើលឃើញថា ការភាន់ច្រឡំ ចំណុចដែលភាគីយល់ឃើញថាសំខាន់ ត្រូវបានគេសន្មតថា គឺជាចំណុចបន្ទាប់បន្សំ និងមូលហេតុអះអាងអំពីការលុបចោលកិច្ចសន្យាអាស្រ័យតាមឆន្ទៈគូភាគី មានន័យថាភាគីអាចទទួលយកឬមិនទទួលយកការភាន់ច្រលំចំណុចបន្ទាប់បន្សំនៃកិច្ចសន្យា។

ប៉ុន្តែយោងតាមមាត្រានៃក្រមរដ្ឋប្បវេណី ចំពោះការភាន់ច្រលំចំណុចដែលភាគីយល់ឃើញថាសំខាន់ អាចអះអាងអំពីការលុបចោល គឺទាមទារឲ្យបំពេញនូវលក្ខខណ្ឌច្បាប់លាស់ ទើបភាគីអាចអះអាងអំពីការលុបចោលដោយនៅពេលបង្កើតកិច្ចសន្យា ភាគីត្រូវតែបង្ហាញថាចំណុចបន្ទាប់បន្សំ ឬចំណុចនៃកិច្ចសន្យា គឺសំខាន់សម្រាប់ភាគីនៅក្នុងទំនាក់ទំនងកិច្ចសន្យា ហើយភាគីម្ខាងទៀតបានដឹងថាជា ចំណុចនៃកិច្ចសន្យាមានភាពសំខាន់សម្រាប់ភាគីម្ខាងទៀត។ ករណីខាងលើនេះ គេមិនបានចាប់អារម្មណ៍លើទស្សនៈ និងការយល់ឃើញរបស់បុគ្គលផ្សេងទៀតឬ ទស្សនៈយល់ឃើញនៃ

សង្គមជាទូទៅទេ តែគេធ្វើការសិក្សាវិភាគទៅលើការបង្ហាញឆន្ទៈរបស់ភាគី ពេលបង្កើតទំនាក់ទំនងគតិយុត្តិ ថាតើអ្វីដែលភាគីចង់បាន និងកំណត់នៅក្នុងកិច្ចសន្យា ដូចនេះការភាន់ច្រលំចំណុចដែលភាគីយល់ឃើញថាសំខាន់ គឺមានមូលហេតុដើម្បីអះអាងអំពីការលុបចោល។

ឧទាហរណ៍ នៅក្នុងទំនាក់ទំនងនៃកិច្ចសន្យាការងារ គេអាចសង្កេតឃើញថាក្រៅពីលក្ខខណ្ឌនៃការងារពលកម្ម អាចនៅមានទីតាំងការងារផ្សេងទៀត សំដៅដល់ទីតាំងបំពេញការងារពលកម្ម ដែលគូភាគីបានសន្មតនៅពេលបង្កើតកិច្ចសន្យា ហើយអះអាងថាចំណុចនេះគឺសំខាន់នៅពេលបង្កើតកិច្ចសន្យា។

ដូចនេះកិច្ចសន្យាការងារ ករណីមានការភាន់ច្រលំចំណុចដែលភាគីយល់ឃើញថាសំខាន់ គឺមានសិទ្ធិអះអាងអំពីការលុបចោល។

## ៣.៣. ការភាន់ច្រឡំរួម

ការភាន់ច្រឡំរួម តាមខ្លឹមសារក្រមរដ្ឋប្បវេណីគេសង្កេតឃើញថា ភាគីនៃកិច្ចសន្យាអាចមានការភាន់ច្រឡំរួមគ្នា នៅពេលបង្កើតកិច្ចសន្យា ភាគីអាចកំណត់លក្ខខណ្ឌ ដែលភាគីមានការយល់ឃើញខុសគ្នា និងធ្វើការបកស្រាយខុសគ្នាក្នុងការបង្កើតកិច្ចសន្យា។ ករណីនេះភាគីមិនចាំបាច់បង្ហាញថា ភាគីម្ខាងទៀតបានដឹងអំពីការភាន់ច្រឡំទេ គឺភាគីអាចអះអាងអំពីការលុបចោល។ ឧទាហរណ៍ នៅក្នុងទំនាក់ទំនងនៃកិច្ចសន្យាការងារ ភាគីអាចមានការភាន់ច្រឡំរួមគ្នាក្នុងការកំណត់លក្ខខណ្ឌការងារ ទីតាំងការងារ និងប្រភេទការងារពលកម្ម។ ដូចនេះករណីខាងលើ ភាគីអាចអះអាងអំពីការ

លុបចោល ដោយមូលហេតុនៃការភាន់ច្រឡំរួម និងភាគីករណីនៃការភាន់ច្រឡំរួមនេះអាចអះអាងបកស្រាយតាមមាត្រា៣៤៦.១នៃក្រមរដ្ឋប្បវេណីក៏បាន ដោយបង្ហាញភស្តុតាងថា មានការភាន់ច្រឡំចំណុចសំខាន់នៃកិច្ចសន្យានិងជាចំណុចសំខាន់ដែលទ្រទ្រង់ចំពោះលក្ខខណ្ឌសុពលភាពនៃការបង្កើតកិច្ចសន្យា។

ដូចនេះយោងតាមគោលគំនិតនៃក្រមរដ្ឋប្បវេណីកម្ពុជា ចំពោះការបកស្រាយលើការភាន់ច្រឡំ បើធៀបទៅនឹងគោលគំនិតដែលបានកំណត់នៅក្នុងក្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យានិងការទទួលខុសត្រូវនៅក្រៅកិច្ចសន្យា គឺគេសង្កេតឃើញថា ក្រមរដ្ឋប្បវេណីកម្ពុជាបានកំណត់លក្ខណៈវិនិច្ឆ័យលំអិតជាងគោលគំនិតនៃក្រឹត្យច្បាប់លេខ៣៨ដោយក្រមរដ្ឋប្បវេណីកំណត់អំពីលក្ខណៈនៃការភាន់ច្រឡំ ដែលជាធាតុវិការៈនៃការបង្ហាញឆន្ទៈក្នុងកិច្ចសន្យា។

## កថាខណ្ឌ២.កិច្ចសន្យាការងារត្រូវតែមានកម្មវត្ថុស្របច្បាប់ និងអាចអនុវត្តបាន

កម្មវត្ថុជាលក្ខខណ្ឌដែលធ្វើឲ្យកិច្ចសន្យាមានសុពលភាព ដូច្នេះត្រូវកំណត់អំពីអ្វីដែលភាគីចង់បាន ជាកម្មវត្ថុនៃកិច្ចសន្យាការងារ ដូចជាការផ្តត់ផ្គង់នូវសេវាការងារ ដែលមានលក្ខណៈស្របច្បាប់ អាចសន្មតបានថាជាកម្មវត្ថុនៃកាតព្វកិច្ច ឬជាតាវកាលិកដែលភាគីសន្យាថានឹងអនុវត្ត និងបំពេញក្រោមក្របខណ្ឌនៃច្បាប់ការងារកម្ពុជា។ ដូចនេះ ចំពោះកិច្ចសន្យាការងារទាំងឡាយណាដែលកម្មវត្ថុកិច្ចសន្យានោះមិនស្របច្បាប់និងទំនៀមទម្លាប់ដ៏ល្អប្រពៃត្រូវចាត់ទុកជាមោឃៈ។

## កថាខណ្ឌ៣. មូលហេតុរបស់ភាគីនៃកិច្ចសន្យាការងារ

ដូចម្ដេចដែលហៅថាមូលហេតុ បើធៀបទៅនឹងកម្មវត្ថុនៃកិច្ចសន្យាការងារ? មូលហេតុ គឺសំដៅទៅលើបំណងរបស់ភាគី ថាហេតុអ្វីបានជាគេយល់ព្រមចុះកិច្ចសន្យាការងារ។ ឧទាហរណ៍ចំពោះសកម្មភាពរៀបចំដំណើរការសកម្មភាពពាណិជ្ជកម្ម រោងចក្រ សហគ្រាស និយោជកតែងត្រូវការប្រើប្រាស់កម្លាំងពលកម្ម ឬការផ្ដត់ផ្គង់នូវសេវាបច្ចេកទេសពីអ្នកជំនាញពីភាគីនិយោជិត ហើយភាគីនិយោជិត រឺកម្មករនិយោជិត មានបំណងប្រើប្រាស់នូវកម្លាំងពលកម្ម រឺសមត្ថភាពជំនាញរបស់ខ្លួនក្នុងគោលដៅដើម្បីប្ដូរមកវិញនូវប្រាក់កម្រៃ ឬដើម្បីបំពេញសេចក្ដីត្រូវការនៃជីវភាពរស់នៅប្រចាំថ្ងៃ។ទាំងអស់នេះអាចសន្និដ្ឋានបានថា មូលហេតុនៃការបង្កើតកិច្ចសន្យាការងារត្រូវតែឆ្លើយតបនឹងមូលហេតុនៃកាតព្វកិច្ចនិងបុគ្គលត្រូវតែអនុវត្ត។

## កថាខណ្ឌ៤. សមត្ថភាពរបស់ភាគីនៃកិច្ចសន្យាការងារ

តើបុគ្គលត្រូវមានលក្ខណៈយ៉ាងដូចម្ដេចដែលអាចក្លាយជាភាគីនៃកិច្ចសន្យា និងមានសមត្ថភាពចុះកិច្ចសន្យាការងារ? បុគ្គលជាភាគីនៃកិច្ចសន្យាត្រូវមានសមត្ថភាពតាមផ្លូវច្បាប់ក្នុងការចុះកិច្ចសន្យា សំដៅទៅលើសមត្ថជន ជនមានសមត្ថភាព ជានីតិជនដែលមានអាយុចាប់ពី១៨ឆ្នាំ និងមិនមានបញ្ហាវិបាល្លាសខាងបញ្ញាស្មារតី ឬជាអនីតិជនមានអត្តាធិនភាព ជាអនីតិជនដែលទទួលបានសិទ្ធិតាមរយៈការស្នើសុំ។

ម្យ៉ាងទៀតយោងតាមបទបញ្ញត្តិស្ដីពីការងារ អាយុអប្បបរមាអាចបំពេញការងារបាន គឺជាកម្មករនិយោជិត និងកណត់អាយុចាប់ពី១៥ឆ្នាំ ក្នុង

លក្ខខណ្ឌទទួលបានការការពារសុខភាព សន្តិសុខ សីលធម៌ និងទទួលបាននូវការអប់រំពិសេសត្រឹមត្រូវ ឬការបណ្តុះបណ្តាលវិជ្ជាជីវៈផ្នែកសកម្មភាពដែលពាក់ព័ន្ធ។

បន្ថែមពីនេះទៀត កុមារអនុញ្ញាតឲ្យធ្វើការងារស្រាលបាន គឺត្រូវមានអាយុអប្បរមាត្រឹម១២ឆ្នាំ ហើយការងារមិនបណ្តាលឲ្យខូចសុខភាព ឬជាការងារដែលអភិវឌ្ឍន៍ផ្លូវចិត្ត ឬរូបកាយកុមារ ប៉ុន្តែការងារនេះមិនត្រូវប៉ះពាល់ដល់ការសិក្សារបស់កុមារឡើយ។ ម្យ៉ាងទៀតករណីភាគីកិច្ចសន្យា ការងារជាកុមារដែលមានអាយុតិចជាង១៨ឆ្នាំគឺតម្រូវឲ្យនិយោជកត្រូវមានកិរិយាមាយាទល្អ និង ហាមដាច់ខាតចំពោះការរំលោភគ្រប់ប្រភេទ។

ដូចនេះបុគ្គលដែលមានសិទ្ធិចុះហត្ថលេខាការងារ គឺជានីតិជន និងអនីតិជនដែលទទួលបានសិទ្ធិតាមរយៈការស្នើសុំឬដោយមានការអនុញ្ញាតពីឪពុកម្តាយ អ្នកអាណាព្យាបាល។ ក្រៅពីបំពេញលក្ខខណ្ឌគ្រឹះ កិច្ចសន្យាការងារតម្រូវឲ្យបំពេញនូវទម្រង់បែបបទមួយចំនួន ដោយប្រែប្រួលទៅតាមប្រភេទនៃកិច្ចសន្យាការងារ ដូចជា ការសរសេរជាលិខិតលាយលក្ខណ៍អក្សរ និងការធ្វើដោយផ្ទាល់មាត់ដែលត្រូវធ្វើការបកស្រាយក្រោមប្រធានបទផ្សេងស្តីពីប្រភេទនៃកិច្ចសន្យាការងារ។

ជារួមការបង្កើតកិច្ចសន្យាការងារមួយឲ្យមានសុពលភាព តម្រូវឲ្យភាគីត្រូវគោរពនូវលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់ដែលជាលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា ដែលតម្រូវឲ្យមាននូវការព្រមព្រៀងដោយគិតប្រាកដនិងសេរី គ្មានវិការៈនៃការព្រមព្រៀង មានសមត្ថភាពចុះកិច្ចសន្យា មានកម្មវត្ថុ និងមូលហេតុស្របច្បាប់ និងទំនៀមទម្លាប់ដ៏ល្អប្រពៃ។

បន្ថែមពីនោះការបង្កើតកិច្ចសន្យាការងារ អាស្រ័យតាមលក្ខខណ្ឌការងារ ឬប្រភេទការងារកិច្ចសន្យាការងារ អាចត្រូវបានបង្កើតដោយការព្រមព្រៀងផ្ទាល់រវាងគូភាគីឬទម្រង់អាចត្រូវបានទាមទាររួមមាន ការទាមទារឲ្យរៀបចំជាលិខិតលាយលក្ខណ៍អក្សរ និងស្ថិតនៅក្រោមការគ្រប់គ្រងនៃច្បាប់ការងារកម្ពុជា។

ដូចនេះកិច្ចសន្យាការងារទាំងឡាយ ដែលការបង្កើតមិនគោរពលក្ខខណ្ឌខាងលើត្រូវចាត់ទុកមោឃៈ។

## ផ្នែកទី២. អំពីអានុភាពនៃកិច្ចសន្យាការងារ

អ្វីទៅជាអានុភាពនៃកិច្ចសន្យាការងារ? តើកិច្ចសន្យាការងារមួយបង្កើតអានុភាពនៅពេលណា? អានុភាពនៅទីនេះ គឺសំដៅទៅលើអានុភាពគតិយុត្តិ ជាកម្លាំងចាប់បង្ខំតាមផ្លូវច្បាប់ឲ្យបុគ្គលត្រូវតែប្រតិបត្តិ ទៅតាមខដែលបានសន្យានៅក្នុងកិច្ចសន្យា។ ជាទូទៅកិច្ចសន្យាការងាមានអានុភាពគឺអនុវត្តបាន ប៉ុន្តែពេលខ្លះភាគីបានព្រមព្រៀងកំណត់ពេលផ្សេង ដើម្បីអនុវត្តកិច្ចសន្យា និងគោលការណ៍កំណត់អានុភាពផ្អែកទៅលើលក្ខខណ្ឌសុពលភាពនៃការបង្កើតកិច្ចសន្យា គេសង្កេតទៅលើការបង្កើតកិច្ចសន្យាស្របទៅតាមប្បញ្ញត្តិច្បាប់ ស្របទៅតាមលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់ជាលក្ខខណ្ឌសុពលភាព នៃការបង្កើតកិច្ចសន្យា។

លើសពីនេះទៅទៀតអនុលោមតាមមាត្រា២២នៃក្រឹត្យច្បាប់លេខ៣៨ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យាបញ្ញត្តិថា កិច្ចសន្យាត្រូវតែកើតចេញពីឆន្ទៈសេរីរបស់គូភាគី ដោយសន្មតជាច្បាប់របស់គូរភាគី

ដូចនេះអានុភាពគតិយុត្តដែលកើតចេញពីកិច្ចសន្យា គឺមានអានុភាពដាក់កាតព្វកិច្ចចំពោះគូភាគីនៃកិច្ចសន្យា រឺអាចសំដៅដល់អានុភាពចាប់បង្ខំតាមផ្លូវច្បាប់ ដែលភាគីមិនអាចបដិសេធបាន ប៉ុន្តែដោយសារទំនាក់ទំនងផលប្រយោជន៍ កិច្ចសន្យាអាចមានអានុភាពចំពោះតតិយជន ដូចករណីដែលគូភាគីបានកំណត់ថាកិច្ចសន្យាមានអានុភាពចំពោះតតិយជន មានន័យថា ខនៃកិច្ចសន្យា កំណត់អំពីអានុភាពចំពោះតតិយជន ឬអាចមានមូលហេតុផ្សេងដែលភាគីយល់ឃើញថា ការកំណត់ពីសិទ្ធិរបស់តតតិយជននៅក្នុងកិច្ចសន្យា អាចជាលក្ខខណ្ឌជម្រុញឲ្យកិច្ចសន្យាប្រតិបត្តិបានដោយរលូន ឬករណីមានវិវាទចំពោះការមិនប្រតិបត្តិកិច្ចសន្យា គឺ តតិយជនអាចមានសិទ្ធិចូលរួមអន្តរាគមន៍ដើម្បីសម្របសម្រួលទំនាក់ទំនងគូភាគីនៃកិច្ចសន្យាបាន ដូចនេះគេសង្កេតឃើញថាមានមូលហេតុជាច្រើន ដែលអាចជាវត្ថុបំណងរបស់គូភាគី ដែលកំណត់ថាកិច្ចសន្យាមានអានុភាពចំពោះតតិយជន ឬករណីដែលបណ្ដាលមកពីការអនុវត្តកិច្ចសន្យាមិនបានល្អ រឺអាចជាការព្រមព្រៀងផ្សេងៗ ទៀតដែលកើតចេញពីតម្រូវការនិងឆន្ទៈសេរីរបស់គូភាគី។

អនុវត្តដូចគ្នាចំពោះកិច្ចសន្យាការងារ ដោយសារតែការព្រមព្រៀងរវាងគូភាគី បានបង្កើតសិទ្ធិ និងកាតព្វកិច្ចអាស្រ័យតាមការព្រមព្រៀង និងលក្ខខណ្ឌការងារដោយស្របទៅតាមវិធាននៃច្បាប់ការងារកម្ពុជា។ ដូចនេះអានុភាពនៃកិច្ចសន្យាការងារ កើតមាននៅពេលអនុវត្តកិច្ចសន្យាការងារ មានន័យថាតាមរយៈខ្លឹមសារនៃកិច្ចសន្យាការងារ និយោជិតបានយល់ព្រមនិងសន្យាថាបំពេញការងារជូននិយោជក ក្នុងនាមនិយោជកដើម្បីប្ដូរមកវិញនូវប្រាក់កម្រៃ មានន័យថា គ្រប់រាល់កិច្ចព្រមព្រៀងដែលបង្កើតឡើងដោយភាគី គឺត្រូវតែស្របទៅតាមវិធានសន្មត់ដោយគូភាគី ដែលវាមានអានុភាព

គ្រប់គ្រាន់ឲ្យភាគីមានសិទ្ធិទាមទារបង្ខំឲ្យអនុវត្ត ដោយសំអាងថា កិច្ចសន្យាគឺជាច្បាប់របស់គូភាគី និងស្របតាមបញ្ញត្តិដែលគូភាគីចង់បាន។

ដូចនេះអានុភាពនៃកិច្ចសន្យាការងារ កើតមាននៅពេលដែលគេកំណត់ ថាកិច្ចសន្យាមានសុពលភាព មានន័យថាសុពលភាពនៃកិច្ចសន្យាគឺមិនផ្អែកតែទៅលើការព្រមព្រៀងរបស់គូភាគីតែមួយផ្នែកនោះទេ ក៏តម្រូវឲ្យស្របទៅនឹងវិធាននៃច្បាប់ការងារកម្ពុជា។ ទាំងនេះយើងអាចធ្វើការសិក្សាពីអានុភាពនៃកិច្ចសន្យាការងារដោយធ្វើការបែងចែក អានុភាពចំពោះគូភាគី អានុភាពចំពោះតតិយជននិង អានុភាពចំពោះចៅក្រម។

## ១. អានុភាពចំពោះគូភាគី

អនុលោមតាមបទប្បញ្ញត្តិស្តីពីការងារកម្ពុជា និងក្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យា ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ បានកំណត់ថា កិច្ចសន្យា គឺជាច្បាប់របស់គូភាគី មានន័យថា ភាគីត្រូវតែប្រតិបត្តិកិច្ចសន្យា ដោយគោរពគោលការណ៍សុច្ចរិត និងភាពស្មោះត្រង់។

### ១.១. បង្ខំឲ្យគូភាគីត្រូវតែប្រតិបត្តិ

កិច្ចសន្យាការងារ មានអានុភាពចាប់បង្ខំឲ្យគូភាគីត្រូវតែប្រតិបត្តិ មានន័យថា កិច្ចសន្យាការងារបានដាក់កាតព្វកិច្ចឲ្យគូភាគីនៃកិច្ចសន្យា ត្រូវតែប្រតិបត្តិដោយស្របទៅតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងកិច្ចសន្យាករណីនេះ ភាគីនិយោជិត មានកាតព្វកិច្ចត្រូវតែប្រតិបត្តិយ៉ាងណាឲ្យស្របទៅតាមខសន្យា ហើយគេអាចធ្វើការសន្និតបានថា ជាតាវកាលិកដែលកូនបំណុលត្រូវតែបំពេញដោយខានមិនបាន។

ដូចនេះកិច្ចសន្យាការងារ ដែលការបង្កើតមានលក្ខខណ្ឌការងារស្របទៅនឹងបទប្បញ្ញត្តិច្បាប់ការងារកម្ពុជា គឺគេអាចកំណត់ថាកិច្ចសន្យាការងារនោះមានអានុភាព និងតម្រូវឲ្យគូភាគីត្រូវតែប្រតិបត្តិ ករណីភាគីមិនប្រតិបត្តិ រឺប្រតិបត្តិដែរតែមិនគ្រប់ជ្រុងជ្រោយ, មានការធ្វេសប្រហែសក្នុងការប្រតិបត្តិកិច្ចសន្យា គឺភាគីម្ខាងទៀងមានសិទ្ធិអនុវត្តបង្ខំ និងករណីធ្វើឲ្យភាគីខូចខាតផលប្រយោជន៍ គឺមានសិទ្ធិទាមទារសំណងនៃការខូចខាត។

## ១.២. គូភាគីប្រតិបត្តិក្នុងនាមឪពុកគំរូ,គូភាគីត្រូវប្រតិបត្តិដោយគោលការណ៍សុច្ចរិត និងភាពស្មោះត្រង់

ភាគីនៃកិច្ចសន្យាការងារត្រូវប្រតិបត្តិក្នុងនាមឪពុកគំរូ ឬត្រូវគោរពគោលការណ៍សុច្ចរិត និងភាពស្មោះត្រង់ មានន័យថា នៅក្នុងក្របខណ្ឌនៃច្បាប់ស្តីពីការងារកម្ពុជា,ក្រមរដ្ឋប្បវេណី គន្លឺស្តីពីកិច្ចសន្យា និងខ្លឹមសារកិច្ចសន្យាការងារដែលបង្កើតឡើងដោយការព្រមព្រៀងរវាងគូរភាគី ដោយភាគីនិយោជិត ត្រូវបញ្ចេញគ្រប់រាល់សកម្មភាពវិជ្ជាជីវៈរបស់ខ្លួនដើម្បីបម្រើផលប្រយោជន៍សហគ្រាស មានន័យថា កម្មករ និយោជិត មានកាតព្វកិច្ចត្រូវធ្វើការងារ ដែលគេជួលស្របតាមលក្ខខណ្ឌ និងខ្លឹមសារនៃកិច្ចសន្យាការងារ គឺអនុវត្តការងារនោះដោយខ្លួនឯង និង យកចិត្តទុកដាក់។[64]

បន្ថែមពីនេះភាគីនិយោជិត ឬកម្មករនិយោជិត ត្រូវគិតថាទោះបីជាសេវាការងារដែលខ្លួនបំពេញ គឺដើម្បីជាផលប្រយោជន៍ដល់ភាគីនិយោជក ឬក្នុងនាមនិយោជកក៏ដោយ ប៉ុន្តែខ្លួនត្រូវប្រតិបត្តិឲ្យបានល្អ និងចាត់ទុកដូច

[64] ម. ៦៩ ច្បាប់ការងារ ឆ្នាំ១៩៩៧។

ជាទ្រព្យឬប្រយោជន៍របស់ខ្លួនផ្ទាល់ ពីព្រោះទាំងនេះ គឺជាកាតព្វកិច្ចស្រប ច្បាប់ និងអាចកំណត់ថាជាតាវកាលិកនៃកិច្ចសន្យាការងារ ដែលនិយោជិត ត្រូវតែបំពេញដោយខានមិនបាន។

លើសពីនេះទៅទៀត ករណីធ្វេសប្រហែសដែលកើតចេញពីទង្វើរ រឺ សកម្មភាពណាមួយដែលបង្កឲ្យមានព្យសនកម្ម និងនាំឲ្យខូចប្រយោជន៍ ដល់ក្រុមហ៊ុន រោងចក្រ សហគ្រាស គឺភាគីនិយោជកមានសិទ្ធិទាមទារឲ្យ ភាគីនិយោជិតទទួលខុសត្រូវចំពោះទង្វើរដែលកើតចេញពីកំហុសខ្លួន។

បន្ថែមពីនេះទៀតក្រៅពីម៉ោងធ្វើការកម្មករនិយោជិតទាំងនោះអាច ធ្វើសកម្មភាពខាងវិជ្ជាជីវៈបាន និងមិនប្រណាំងប្រជែងនឹងសហគ្រាសដែល ខ្លួនកំពុងបំរើការ ឬធ្វើឲ្យខូចដល់ដំណើរការ ដែលភាគីបានព្រមព្រៀងនិង លើកលែងចំពោះករណីមានការព្រមព្រៀងផ្ទុយពីនេះ។

អនុវត្តដូចគ្នាចំពោះភាគីនិយោជក ដែលមានកាតព្វកិច្ចត្រូវផ្តល់ ប្រាក់កម្រៃ ផ្តល់ប្រាក់ឧបត្ថម្ភផ្សេងៗ ក្នុងការលើកទឹកចិត្តដែលជាថ្នូរទៅនឹង ការផ្គត់ផ្គង់នូវសេវាការងាររបស់និយោជិត រឺ កម្មករនិយោជិត ដោយមិនកេង ប្រវ័ញ្ចទៅលើកម្លាំងពលកម្មរបស់ភាគីកូនចៅ និងមិនអនុវត្តផ្ទុយទៅនឹងបទ ប្បញ្ញត្តិការងារកម្ពុជា ក៏ដូចជាលក្ខខណ្ឌការងារដែលអនុវត្តនៅក្នុងគ្រឹះស្ថាន ឬ សហគ្រាសរបស់ខ្លួន។

ការប្រតិបត្តិក្នុងនាមឪពុកគំរូនេះ កើតចេញពីការសន្មតរបស់ភាគី គឺជាវិធានដែលកើតចេញពីឆន្ទៈសេរីរបស់គូភាគី និងស្របទៅនឹងប្បញ្ញត្តិ ច្បាប់ការងារកម្ពុជា។

## ១.៣. គូភាគីត្រូវប្រតិបត្តិដោយមិនអាចប្រកែកបាន

ករណីនេះ យើងអាចធ្វើការបកស្រាយតាមទ្រឹស្តីស្វ័យភាពនៃឆន្ទៈរបស់គូភាគី ក្នុងការបង្កើតកិច្ចសន្យាការងារ គេស្វែងរកបាននូវឆន្ទៈព្រមព្រៀងមួយដោយពិតប្រាកដថា ភាគីនឹងស្រុះស្រួលគ្នាថានឹងទទួលយកនូវលក្ខខណ្ឌការងារចំពោះការបង្កើតកិច្ចសន្យាការងារ គឺបន្ទាប់ពីកិច្ចសន្យាមានអានុភាព ភាគីទទួលនូវកាតព្វកិច្ចប្រតិបត្តិដោយមិនអាចប្រកែកបាន។

ប៉ុន្តែស្ថានភាពនេះ អាចប្រែប្រួលប្រសិនបើមានការព្រមព្រៀងផ្សេងពីនេះ ឬនៅក្នុងករណីខ្លះ មានការកំណត់ផ្សេង ថាភាគីមានសិទ្ធិកែរប្រែកិច្ចសន្យាដោយឯកតោភាគី និងមិនត្រូវការឆន្ទៈព្រមព្រៀងជាឯកឆន្ទៈ។

## ២. អានុភាពចំពោះតតិយជន

តតិយជនគឺជាជនទី៣ ឬមិនមែនជាភាគី នៃកិច្ចសន្យា។ មូលហេតុអ្វី? និងយោងតាមគោលការណ៍ទូទៅ នៃការបង្កើតកិច្ចសន្យា កិច្ចសន្យាគឺជាការព្រមព្រៀងរវាងបុគ្គលពីរ ឬច្រើន ក្នុងគោលដៅដើម្បីបង្កើត កែរប្រែ ឬរំលត់សិទ្ធិ និងកាតព្វកិច្ចមួយចំនួនដែលទាក់ទិនទៅនឹងគូភាគី។ យោងតាមអត្ថន័យនេះសន្មតថាកិច្ចសន្យាជាច្បាប់របស់ភាគី ដូចនេះតតិយជន គឺជាបុគ្គលនៅក្រៅកិច្ចសន្យា និងមិនមានផលប្រយោជន៍ពាក់ព័ន្ធទៅនឹងកិច្ចសន្យា។ ប៉ុន្តែនៅក្នុងស្ថានភាពមួយចំនួន តាមរយៈការ ព្រមព្រៀងរបស់គូភាគី តើតតិយជនអាចក្លាយជាភាគីពាក់ព័ន្ធ និងមានសិទ្ធិអន្តរាគមន៍នៅក្នុងកិច្ចសន្យា? ហើយអ្វីដែលជាបញ្ហាចោទនៅទីនេះ គេបានធ្វើការចោទសួរថា តើកិច្ចសន្យាការងារបង្កើតអានុភាពចំពោះតតិយជនបានយ៉ាងដូចម្តេចនៅក្នុងទំនាក់ទំនងកិច្ចន្យាការងារ?

ជាទូទៅ បើយើងធ្វើការបកស្រាយទៅតាមទ្រឹស្ដីស្វ័យភាពនៃឆន្ទៈសេរីរបស់បុគ្គលឯកជន ការដែលកំណត់ឲ្យតតិយជនមានសិទ្ធិអន្តរាគមន៍នៅក្នុងកិច្ចសន្យាការងារ គឺអាចកើតមានដោយសារឆន្ទៈសេរីរបស់គូភាគីដែលបានសន្មត និងអនុញ្ញាតិឲ្យជនទីបីមានសិទ្ធិពាក់ព័ន្ធទៅនឹងកិច្ចសន្យា ឬជនទីបីអាចទទួលបានសិទ្ធិតាមបទប្បញ្ញត្តិច្បាប់ ឬក្នុងគោលបំណងដើម្បីបម្រើផលប្រយោជន៍រួម ឬ ផលប្រយោជន៍សាធារណៈនៅក្នុងសង្គម។

**ឧទាហរណ៍៖** ដូចជាកិច្ចសន្យាការងារដែលបញ្ជូនពលករទៅបម្រើរការងារនៅបរទេសមួយ ដែលធ្វើឡើងដោយមានការទទួលដឹងលឺពីគណៈកម្មាការបណ្ដុះបណ្ដាលបញ្ជូនពលករទៅបរទេស(MTSOB) និងនិយោជកនៃក្រុមហ៊ុនបរទេស។ ក្នុងទំនាក់ទំនងខាងលើនេះគេសង្កេតឃើញថាអ្នកទទួលបានផលប្រយោជន៍ គឺ និយោជកនៃក្រុមហ៊ុនបរទេស និងពលករដែលត្រូវបានជ្រើសរើសឲ្យទៅបម្រើការងារនៅបរទេស ប៉ុន្តែផ្អែកតាមគោលការណ៍រដ្ឋធម្មនុញ្ញដែលបានចែងថា រដ្ឋ គឺជាអាណាព្យាបាលរបស់ប្រជាពលរដ្ឋ។ ដូចនេះកាតព្វកិច្ចក្នុងគោលបំណងដើម្បីបម្រើផលប្រយោជន៍រួមផង និងស្ថាប័នមានសមត្ថកិច្ចបានដើរតួរនាទីសំខាន់ជាអាណាព្យាបាល និងអ្នកទទួលដឹងលឺ ហើយមានសិទ្ធិនៅក្នុងកិច្ចសន្យាការងារ។

ដូចនេះគេអាចសន្និដ្ឋានបានថាកិច្ចសន្យា គឺជាបាតុភូតសង្គមដែលតាមកិច្ចសន្យា គឺអាចនាំឲ្យមានការផ្លាស់ប្ដូរស្ថានភាពគតិយុត្តណាមួយ និងច្បាប់អាចអនុញ្ញាតឲ្យតតិយជនមានសិទ្ធិជំទាស់ទៅនឹងកិច្ចសន្យាបាន ក្នុងករណីដែលការអនុវត្តកិច្ចសន្យាមិនគោរពច្បាប់។

## ៣. អានុភាពចំពោះចៅក្រម

យោងតាមនិយមន័យកិច្ចសន្យាដែលសន្មតថាជាច្បាប់របស់គូភាគី ចៅក្រមត្រូវបានចាត់ទុកថាជាបុគ្គលនៅក្រៅកិច្ចសន្យា ប៉ុន្តែបញ្ហាចោទនៅនេះ ថាតើកិច្ចសន្យាមានអានុភាពចំពោះចៅក្រមយ៉ាងដូចម្តេច?ទោះបីជាចៅក្រមមិនមែនជាភាគីនៃកិច្ចសន្យា កិច្ចសន្យា ត្រូវបានសន្មត់ថាមានអានុភាពចំពោះចៅក្រមក្នុងករណីយកិច្ចសន្យានោះមានវិវាទកើតឡើង។

មូលហេតុអ្វីការកំណត់កិច្ចសន្យាមានអានុភាពចំពោះចៅក្រម ឬអនុញ្ញាតចៅក្រមឲ្យមានសិទ្ធិចូលរួមអន្តរាគមន៍ ដើម្បីធ្វើការបកស្រាយកិច្ចសន្យា ក្នុងគោលដៅដើម្បីការពារផលប្រយោជន៍របស់គូភាគី ជៀងវៀងការបកស្រាយដែលធ្វើឲ្យភាគីទទួលរងនូវការខូចខាតផលប្រយោជន៍។

តើចៅក្រមចូលរួមអន្តរាគមន៍ដើម្បីធ្វើការបកស្រាយកិច្ចសន្យាក្នុងលក្ខខណ្ឌបែបណា? ទោះបីជាកំណត់ថាកិច្ចសន្យាមានអានុភាពចំពោះចៅក្រម និងផ្តល់សិទ្ធិឲ្យចៅក្រមចូលរួមអន្តរាគមន៍នៅក្នុងការបកស្រាយកិច្ចសន្យាករណីយកិច្ចសន្យាមានវិវាទកើតឡើងក៏ដោយ ប៉ុន្តែជាលទ្ធផលចៅក្រមក៏មិនមានសិទ្ធិក្នុងការកែប្រែ ឬផ្លាស់ប្តូរនូវលក្ខខណ្ឌណាមួយនៃកិច្ចសន្យាទេពីព្រោះកិច្ចសន្យា គឺកើតចេញពីឆន្ទៈព្រមព្រៀងគិតប្រាកដរបស់គូភាគី ប៉ុន្តែចៅក្រមមានសិទ្ធិអន្តរាគមន៍ក្នុងការបកស្រាយកិច្ចសន្យា ករណីដែលមានវិវាទ ចំពោះការបកស្រាយកិច្ចសន្យាដោយផ្អែកទៅតាមឆន្ទៈសេរីរបស់គូភាគី ចៅក្រមមានសិទ្ធិដើម្បីសិក្សាវិភាគអំពីតម្រូវការ និងវត្ថុបំណងរបស់គូភាគីនៅពេលបង្កើតកិច្ចសន្យា។

ដូចនេះការកែប្រែកិច្ចសន្យា មិនអាចសម្រេចបានដោយចៅក្រមទេ លើកលែងតែការព្រមព្រៀងរបស់គូភាគីខុសច្បាប់ ឬជាការព្រមព្រៀងមួយដែលផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈ សណ្តាប់ធ្នាប់របៀបរៀបរយ ឬទំនៀមទម្លាប់ដ៏ល្អប្រពៃ។ ជារួមអានុភាពនៃកិច្ចសន្យាការងារបានកើតមាននៅពេលដែលកិច្ចសន្យាការងារនោះមានសុពលភាព និងដោយមិនផ្ទុយទៅនឹងអត្ថន័យនៃច្បាប់ការងារកម្ពុជា។

## ផ្នែកទី៣.អំពីប្រភេទនិងលក្ខណៈពិសេសនៃកិច្ចសន្យាការងារ

កិច្ចសន្យាការងារ គឺជាការព្រមព្រៀងដែលកើតចេញពីឆន្ទៈសេរី និងគិតប្រាកដក្នុងគោលបំណងដើម្បីបង្កើតសិទ្ធិ និងកាតព្វកិច្ចការងាររវាងភាគីចៅហ្វាយនាយ( និយោជក ) និងកូនចៅ( និយោជិត, កម្មករនិយោជិត ) តាមយៈនោះភាគីនិយោជិតបានសន្យាថាបំពេញការងារជូននិយោជក ដើម្បីផលប្រយោជន៍និយោជក ដោយប្តូរមកវិញនូវប្រាក់ឈ្នួលពីនិយោជក។

### កថាខណ្ឌ១.លក្ខណៈពិសេសនៃកិច្ចសន្យាការងារ

ច្បាប់ការងារកម្ពុជាឆ្នាំ១៩៩៧ បានកំណត់និយមន័យនៃកិច្ចសន្យាការងារដែរថា៖ កិច្ចសន្យាការងារបានបង្កើតទំនាក់ទំនងផ្នែកការងារ រវាងកម្មករនិយោជិត និង និយោជកដែលមានលក្ខណៈពិសេស ជាប្រភេទនៃកិច្ចសន្យាមូលា កិច្ចសន្យាអញ្ញមញ្ញ កិច្ចសន្យាដែលប្រតិបត្តិបន្ត កិច្ចសន្យាដែល

ឈរលើការរាប់អានបុគ្គល កិច្ចសន្យាដែលប៉ះពាល់ទៅលើសិទ្ធិបុគ្គល និងជាកិច្ចសន្យាសជ្ឈៈកម្ម។[65]

## ១. កិច្ចសន្យាការងារមានលក្ខណៈជាកិច្ចសន្យាមូលា

ជាកិច្ចសន្យាដែលមិនអាចគិតជាសាច់ប្រាក់បាន ឬអាចគិតបានតែខូចខាតផលប្រយោជន៍សេដ្ឋកិច្ច និងការចាត់ទុកកិច្ចសន្យាការងារជាប្រភេទកិច្ចសន្យាមូលា មានន័យថា តាវកាលិកកើតចេញពីកិច្ចសន្យាការងារគឺមិនអាចគិតគូរជាសាច់ប្រាក់បាន ប៉ុន្តែជាតាវកាលិកដែលនិយោជិត កម្មករនិយោជិត ឬនិយោជិត ត្រូវតែបំពេញចំពោះថៅហ្វាយនាយ ឬនិយោជកគឺជាតម្លៃតបស្នងត្រូវតែបំពេញ ដើម្បីជាប្រយោជន៍និយោជក ក្នុងគោលបំណងប្តូរមកវិញនូវប្រាក់កម្រៃប្រចាំខែ។

## ២. កិច្ចសន្យាការងារមានលក្ខណៈជាកិច្ចសន្យាអញ្ញមញ្ញ

កិច្ចសន្យាអញ្ញមញ្ញ គឺជាប្រភេទកិច្ចសន្យាដែលបង្កើតនូវកាតព្វកិច្ចទៅវិញទៅមក រវាងគូភាគីនៃកិច្ចសន្យា និងកិច្ចសន្យាការងារត្រូវបានចាត់ទុកជាកិច្ចសន្យាអញ្ញមញ្ញ ពីព្រោះកិច្ចសន្យាការងារបានបង្កើតនូវកាតព្វកិច្ចទៅវិញទៅមក រវាងភាគីនិយោជកនិង និយោជិត ក្នុងនោះនិយោជិតមានកាតព្វកិច្ចត្រូវបំពេញការងារជូននិយោជកតាមការសន្យា និងនិយោជកមានកាតព្វកិច្ចត្រូវផ្តល់នូវប្រាក់ខែគ្រប់ចំនួន ដែលជាតម្លៃតបស្នងនៃការងារជូនភាគីនិយោជិត ឬកម្មករនិយោជិត។

---

[65]ម. ៦៥ កថាខណ្ឌទី១ ច្បាប់ការងារ ឆ្នាំ១៩៩៧។

## ៣. កិច្ចសន្យាការងារមានលក្ខណៈជាកិច្ចសន្យាប្រតិបត្តិបន្ត

ជាប្រភេទនៃកិច្ចសន្យាដែលមានកំណត់ថិរវេលា ដោយតាវកាលិករបស់គូភាគីកំណត់ថិរវេលា និងការរំលាយនៃកិច្ចសន្យាមិនមានអានុភាពប្រតិសកម្ម។កិច្ចសន្យាការងារ ជាកិច្ចសន្យាប្រតិបត្តិបន្ត មានន័យថាតាវកាលិកដែលកើតចេញពីភាគីនៃកិច្ចសន្យាមាននៅក្នុងកាលវេលា ហេតុនេះមោឃភាពនៃកិច្ចសន្យាការងារគ្មានអានុភាពប្រតិសកម្មទេ។

## ៤.កិច្ចសន្យាការងារមានលក្ខណៈជាប្រភេទកិច្ចសន្យារាប់អានបុគ្គល

កិច្ចសន្យារាប់អានបុគ្គល គឺជាប្រភេទកិច្ចសន្យាដែលបង្កើតឡើងដោយផ្អែកទៅលើគុណវុឌ្ឍរបស់បុគ្គល មានន័យថាលក្ខណៈសម្បត្តិរបស់បុគ្គល គឺចំណុចសំខាន់ចំពោះលក្ខខណ្ឌសុពលភាពនៃការបង្កើតកិច្ចសន្យាជាពិសេសនៅក្នុងកិច្ចសន្យាការងារ ចំពោះការជ្រើសរើសកម្មករនិយោជិត គឺផ្តោតសំខាន់ទៅលើសមត្ថភាពការងារ គុណវុឌ្ឍរបស់បុគ្គលនៅពេលបង្កើតកិច្ចសន្យា មានន័យថានៅពេលកិច្ចសន្យាការងារកំណត់អានុភាព គឺកម្មករនិយោជិតត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយមិនអាចផ្ទេរឲ្យបុគ្គលផ្សេង។

## ៥. កិច្ចសន្យាការងារមានលក្ខណៈជាកិច្ចសន្យាដែលប៉ះពាល់ទៅលើសិទ្ធិបុគ្គល

មានន័យថា ភាគីទាំងសងខាងនៃកិច្ចសន្យាត្រូវធ្វើការឆ្លើយតប នឹងលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា គោរពច្បាប់ការងារ និងរាល់លិខិតបទដ្ឋាននៃវិស័យការងារមានលក្ខណៈជាសេចក្តីបង្គាប់សាធារណៈ។

## ៦. កិច្ចសន្យាការងារមានលក្ខណៈជាកិច្ចសន្យាសញ្ញៈកម្ម

កិច្ចសន្យាសញ្ញៈកម្មជាប្រភេទកិច្ចសន្យា ដែលក្នុងនោះភាគីម្ខាងគ្មានសិទ្ធិជជែកតវ៉ា ឬដាក់ខស្នើ ចំពោះលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាទេ គឺភាគីមានសិទ្ធិឆ្លើយតបថាយល់ព្រម និងមិនយល់ព្រម ទៅតាមលក្ខខណ្ឌស្នើរបស់ភាគីម្ខាងទៀត។ អនុវត្តដូចគ្នាចំពោះកិច្ចសន្យាការងារដែលភាគីជានិយោជិតចាំតែឆ្លើយតបទៅតាមខស្នើរបស់ភាគីនិយោជក ។

## កថាខណ្ឌ២. ប្រភេទនៃកិច្ចសន្យាការងារ

កិច្ចសន្យាការងារ យោងតាមមាត្រា៦៦នៃច្បាប់ស្តីពីការងារកម្ពុជាឆ្នាំ១៩៩៧បានកំណត់ថាៈ កិច្ចសន្យាការងារមានពីរប្រភេទ គឺកិច្ចសន្យាការងារមានថិរវេលាកំណត់ និងកិច្ចសន្យាការងារគ្មានកំណត់ថិរវេលា។

## ១. កិច្ចសន្យាការងារមានថិរវេលាកំណត់

កិច្ចសន្យាការងារមានថិរវេលាកំណត់ គឺជាប្រភេទកិច្ចសន្យាដែលកើតពីការព្រមព្រៀងដោយសេរី និងពិតប្រាកដ ក្នុងការផ្គត់ផ្គង់សេវាការងារដោយភាគីនិយោជិត និងផ្តល់នូវប្រាក់កម្រៃដោយភាគីនិយោជក និងមានកំណត់កាលបរិច្ឆេទនៃការចាប់ផ្តើមនិងបញ្ចប់ច្បាស់លាស់។ កិច្ចសន្យាប្រភេទនេះ តម្រូវឲ្យធ្វើជាលិខិតលាយលក្ខណ៍អក្សរ។ យោងតាមមាត្រា៦៦នៃច្បាប់ការងារឆ្នាំ១៩៩៧ កិច្ចសន្យាការងារមានកំណត់ថិរវេលាបានបែងចែកជាពីរ គឺកិច្ចសន្យាមានកំណត់ថិរវេលាពិតប្រាកដ និងកិច្ចសន្យាមិនមានកំណត់ថិរវេលាមិនពិតប្រាកដ។

## ១.១ កិច្ចសន្យាការងារមានថិរវេលាពិតប្រាកដ

ជាទូទៅកិច្ចសន្យាការងារមានថិរវេលាពិតប្រាកដបើយោងតាមខ្លឹមសារច្បាប់ការងារកម្ពុជាឆ្នាំ១៩៩៧ ការកំណត់ថិរវេលាពិតប្រាកដ គឺច្បាប់តម្រូវឲ្យគូភាគីបញ្ញត្តិនៅក្នុងកិច្ចសន្យា អំពីកាលបរិច្ឆេទនៃការបង្កើតនិងបញ្ចប់កិច្ចសន្យា ប៉ុន្តែមិនអាចមានរយៈពេលកំណត់លើស២ឆ្នាំបានទេនិងអាចបន្តសាជាថ្មីបាន ដោយការបន្តនេះមានរយៈពេលមិនលើស២ឆ្នាំ ដែលកិច្ចសន្យាការងារប្រភេទនេះ គឺតម្រូវឲ្យធ្វើជាលិខិតលាយលក្ខណ៍អក្សរ។

## ១.២. កិច្ចសន្យាការងារមានថិរវេលាមិនពិតប្រាកដ

កិច្ចសន្យាការងារមានថិរវេលាមិនពិតប្រាកដ គឺជាកិច្ចសន្យាមានថិរវេលាពិតប្រាកដ តែលក្ខខណ្ឌនៃការបញ្ចប់មិនច្បាស់លាស់ ពោលគឺប្រែប្រួលទៅតាមប្រភេទនៃកិច្ចសន្យា ឧទាហរណ៍ ដូចជាកិច្ចសន្យាធានារ៉ាប់រងជំនួសកម្មករនិយោជិតណាម្នាក់ដែលអវត្តមាន ជាកិច្ចសន្យាមានរយៈពេលមួយរដូវ និងធ្វើកិច្ចសន្យាតាមកំណើននៃការងារ ឬសកម្មភាពខុសធម្មតារបស់សហគ្រាស ដោយកិច្ចសន្យាប្រភេទនេះអាចបន្តថ្មីច្រើនដង។

## ២. កិច្ចសន្យាការងារគ្មានកំណត់ថិរវេលា

កិច្ចសន្យាការងារគ្មានកំណត់ថិរវេលា ជាប្រភេទកិច្ចសន្យាដែលមានចែងពីថិរវេលានៃការចាប់ផ្តើមកិច្ចសន្យា ដោយពុំមានចែងអំពីកាលបរិច្ឆេទនៃការបញ្ចប់ ឬក៏មានដែរប៉ុន្តែមិនច្បាស់លាស់។

ម្យ៉ាងទៀត តាមមាត្រា៦៧នៃច្បាប់ស្តីពីការងារកម្ពុជាឆ្នាំ១៩៩៧បានកំណត់ថា កិច្ចសន្យាការងារមួយចំនួន គឺជាប្រភេទកិច្ចសន្យាការងារដែលគ្មានកំណត់ថិរវេលា ដូចជាកិច្ចសន្យាការងារធ្វើដោយផ្ទាល់មាត់ និងកិច្ចសន្យាការងារធ្វើជាលិខិតលាយលក្ខណ៍អក្សរ ដែលពុំមានកំណត់អំពីកាលបរិច្ឆេទនៃការបញ្ចប់ និងចំណុចដែលគួរធ្វើការកត់សម្គាល់ គឺកិច្ចសន្យាការងារដែលមានថិរវេលាកំណត់ អាចក្លាយទៅជាកិច្ចសន្យាការងារគ្មានកំណត់ថិរវេលានៅពេលការអនុវត្តបញ្ចប់កិច្ចសន្យាបានមកដល់ ប៉ុន្តែគូភាគីស្ងៀមស្ងាត់មិនអើពើប្រែមិនចរចា ដើម្បីរៀបចំកិច្ចសន្យាថ្មី មិនមានជូនដំណឹងពីការកែប្រែ ឬបង្កើតថ្មីនោះ ទាំងនេះគឺជាគុណសម្បត្តិនៃកិច្ចសន្យា

ការងារដែលមានថិរវេលាកំណត់ និងត្រូវក្លាយទៅជាកិច្ចសន្យាការងារគ្មានកំណត់ថិរវេលាដោយស្វ័យប្រវត្តិ។

ដូចនេះកិច្ចសន្យាការងារមានលក្ខណៈពិសេសផ្សេងៗគ្នា ប្រែប្រួលទៅតាមកម្មវត្ថុនៃការងារពលកម្ម និងផ្តល់សិទ្ធិសេរីភាពពេញលេញដល់គូភាគី ក្នុងការសម្រេចចិត្តជ្រើសរើសប្រភេទនៃកិច្ចសន្យា ដោយផ្អែកតាមបទប្បញ្ញត្តិនៃវិស័យការងារ និងច្បាប់ការងារកម្ពុជាឆ្នាំ១៩៩៧ ដូចជាកិច្ចសន្យាការងារគ្មានកំណត់ថិរវេលា និងកិច្ចសន្យាការងារមានកំណត់ថិរវេលា។

## កថាខណ្ឌ៣. អំពីការទទួលខុសត្រូវនៃកិច្ចសន្យាការងារ

អ្វីទៅជាទំនួលខុសត្រូវនៃកិច្ចសន្យាការងារ? តើទំនួលខុសត្រូវទាំងអស់នោះកើតមាននៅពេលណា? ទំនួលខុសត្រូវកើតចេញពីកិច្ចសន្យាជាប់កាតព្វកិច្ច ដែលស្តែងចេញពីទង្វើរចេតនា អចេតនារបស់បុគ្គលបង្កឲ្យ

មានព្យៈសនកម្ម។ បើយោងតាមមាត្រា៣០៨នៃក្រមរដ្ឋប្បវេណីកម្ពុជាបាន កំណត់ថាកាតព្វកិច្ចគឺជាទំនាក់ទំនងគតិយុត្ត ដែលចងបុគ្គលពីរនាក់ ដោយឲ្យបុគ្គលម្នាក់ដែលបានកំណត់ថាមានករណីយកិច្ចមួយចំនួនចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត។

ទាំងនេះបញ្ជាក់ថាការទទួលខុសត្រូវនៃកិច្ចសន្យា កើតមាននៅពេលកិច្ចសន្យាមានសុពលភាព និងភាគីចាប់ផ្តើមប្រតិបត្តិកិច្ចសន្យា ដែលការអនុវត្តកាតព្វកិច្ចរបស់ភាគីយ៉ាងណាឲ្យស្របតាមខ្លឹមសារនៃកិច្ចសន្យាដោយគោលការណ៍នៃភាពសុច្ចរិត និងភាពស្មោះត្រង់។

ម្យ៉ាងទៀតការទទួលខុសត្រូវអាចនឹងកើតមាន ករណីដែលបុគ្គលបង្កឲ្យមានការខូចខាតដល់អ្នក ដទៃដែលមិនមែនជាទង្វើរកើតពីកាតព្វកិច្ចនៃកិច្ចសន្យា ប៉ុន្តែជាការទទួលខុសត្រូវក្រៅកិច្ចសន្យា[66]។ ចំពោះទំនួលខុសត្រូវនៃកិច្ចសន្យាការងារ គឺជាការទាមទារឲ្យភាគី និយោជកនិងនិយោជិតអនុវត្តកាតព្វកិច្ចស្របទៅតាមខ្លឹមសារនៃកិច្ចសន្យា ដោយគោលការណ៍នៃភាពសុច្ចរិត និងភាពស្មោះត្រង់។

ដូចនេះការទទួលខុសត្រូវនៃកិច្ចសន្យា គឺសំដៅទៅលើការទទួលខុសត្រូវរដ្ឋប្បវេណីរបស់ភាគីណាមួយ ក្នុងចំណោមភាគីនៃកិច្ចសន្យា ជាការទទួលខុសត្រូវចំពោះទង្វើរដែលបង្កឲ្យមានការខូចខាត ដែលកើតចេញពីការមិនប្រតិបត្តិកិច្ចសន្យា ករណីភាគីប្រតិបត្តិមិនពេញលេញ យឺតយ៉ាវក្នុង

[66] ម. ១២១ ក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច. ឆ្នាំ១៩៨៨ បានចែងថា៖ ជនណាបានធ្វើឲ្យមាន ការខូចខាតដល់អ្នកដទៃដោយកំហុសរបស់ខ្លួនជននោះត្រូវជួសជុលការខាតនោះ។ ទោះបីការខូចខាតកើតចេញពីអំពើប្រព្រឹត្ត ដោយអចេតនា ដូចជាការធ្វេសប្រហែស ឬការខ្វះការប្រុងប្រយ័ត្នក្នុងការត្រួតមើល ថៃទាំក៏ដោយ ក៏ជនល្មើសត្រូវជួសជុលការ ខូចខាតនោះដែរ។

ការប្រតិបត្តិឬអលទ្ធភាពក្នុងការប្រតិបត្តិ និងករណីនេះផ្តល់សិទ្ធិឲ្យភាគីម្ខាងទៀតទាមទារអនុវត្តកាតព្វកិច្ច ឬអាចបង្ខំអនុវត្តតាមផ្លូវតុលាការតាមរយៈការចេញដីការបង្គាប់ឲ្យអនុវត្តកាតព្វកិច្ចដោយតុលាការ។

**តើលក្ខខណ្ឌណាខ្លះដែលភាគីអាចទាមទារឲ្យមានការទទួលខុសត្រូវនៃកិច្ចសន្យា ?**

ជាទូទៅលក្ខខណ្ឌទាមទារ ឲ្យមានការទទួលខុសត្រូវនៃកិច្ចសន្យាជាគោលការណ៍ គឺសិក្សាវិភាគទៅលើទង្វើរបស់ភាគីនៃកិច្ចសន្យាបង្កឲ្យមានព្យសនកម្មនៅពេលអនុវត្តកិច្ចសន្យាដោយប្រែប្រួលទៅតាមករណីនីមួយៗដូចជា[67]៖

- **ករណីយកិច្ចរបស់កូនបំណុលក្នុងការអនុវត្តកាតព្វកិច្ច**

នៅក្នុងទំនាក់ទំនាក់នៃកិច្ចសន្យា ការអនុវត្តកាតព្វកិច្ច បុគ្គលតែងតែវិភាគទៅលើកាតព្វកិច្ចរបស់ភាគីពីរ គឺម្ចាស់បំណុលនឹងកូនបំណុលទៅតាមប្រភេទនៃកាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យានីមួយៗ។ អនុវត្តដូចគ្នាចំពោះកិច្ចសន្យាការងារដែលម្ចាស់បំណុលនៃកាតព្វកិច្ច គឺជានិយោជក និងកូនបំណុលនៃកាតព្វកិច្ច គឺជានិយោជិត តាមរយៈកិច្ចសន្យាការងារបានបង្កើតនូវកាតព្វកិច្ចអញ្ញមញ្ញ ឬជាកាតព្វកិច្ចទៅវិញទៅមក ដែលតម្រូវឲ្យគូភាគីត្រូវតែបំពេញចំពោះគ្នា ដូចជាការផ្តត់ផ្គង់នូវសេវាការងារដើម្បីប្តូរមកវិញនូវប្រាក់កម្រៃប្រចាំខែ និងការធានារ៉ាប់រងផ្សេងៗចំពោះនិយោជិតដែលសន្យាចំពោះភាគីនិយោជកស្របតាមបទប្បញ្ញត្តិការងារ។

---

[67] ជំពូកទី៣ការអនុវត្តកិច្ចសន្យានៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧

ករណីយកិច្ចកូនបំណុល ចំពោះការអនុវត្តកាតព្វកិច្ច មានន័យថា កិច្ចសន្យាការងារមានសុពលភាព គឺតម្រូវឲ្យនិយោជិតត្រូវតែប្រតិបត្តិកាតព្វកិច្ចឲ្យស្របទៅតាមខ្លឹមសារនៃកិច្ចសន្យា និងគោលការណ៍សុច្ចរិតភាព និងភាពស្មោះត្រង់ ក្នុងករណីដែលនិយោជិតមិនបានអនុវត្តកាតព្វកិច្ច និយោជកមានសិទ្ធិទាមទារសំណងខូចខាត ដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ចនោះបាន។[68] ប៉ុន្តែនៅក្នុងករណីខាងលើ បើសិនជាភាគីនិយោជិតអាចបង្ហាញភស្តុតាងបានថា ខ្លួនគ្មានកំហុសចំពោះការមិនអនុវត្តកាតព្វកិច្ច គឺភាគីនិយោជិត ត្រូវរួចផុតពីការទទួលខុសត្រូវក្នុងការសងសំណងខូចខាត។

ម្យ៉ាងទៀតក្នុងករណីដែលនិយោជិត បានផ្ទេរកិច្ចការរបស់ខ្លួនឲ្យអ្នកដទៃធ្វើជំនួស ករណីមានការខូចខាតកើតមានឡើងនិយោជិតត្រូវទទួលខុសត្រូវដូចគ្នាពីព្រោះកិច្ចការទាំងអស់នោះជាបន្ទុករបស់និយោជិត។ ប៉ុន្តែនិយោជិតអាចរួចផុតពីការទទួលខុសត្រូវករណីមានភស្តុតាងបញ្ជាក់ថាខ្លួនគ្មានកំហុសក្នុងការជ្រើសតាំងនិងការត្រួតពិនិត្យអ្នកជំនួយហើយអ្នកជំនួយនោះក៏គ្មានកំហុសដែរ។

- **សិទ្ធិរបស់ម្ចាស់បំណុលក្នុងការទាមទារឲ្យអនុវត្តកាតព្វកិច្ច**

ជាទូទៅនៅក្នុងកិច្ចសន្យាការងារ ម្ចាស់បំណុល គឺគេសំដៅទៅលើភាគីនិយោជក ដោយនៅក្នុងទំនាក់ទំនងនៃកិច្ចសន្យាការងារគេបានសង្កេតឃើញថា អ្នកមានសិទ្ធិទាមទារឲ្យភាគីអនុវត្តកាតព្វកិច្ច គឺជានិយោជក ដូចនេះម្ចាស់បំណុលនៅក្នុងទំនាក់ទំនងនៃកិច្ចសន្យាការងារ អាចអនុវត្តសិទ្ធិ

[68] ម.៣៩៨ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ស្តីពីលក្ខខណ្ឌទទួលខុសត្រូវក្នុងការសងសំណងខូចខាត។

ទាមទាររបស់ខ្លួននៅពេលកិច្ចសន្យាការងារបានកំណត់អានុភាព ដោយត្រូវទទួលស្គាល់ថាមានសិទ្ធិបង្ខំឲ្យកូនបំណុលឬជានិយោជិតត្រូវតែប្រតិបត្តិកិច្ចសន្យា។ ករណីភាគីមិនប្រតិបត្តិកាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យា ភាគីនិយោជក ឬជានាយក ឬជាម្ចាស់បំណុលអាចទាមទារឲ្យសងសំណងខូចខាតជំនួសឲ្យការទាមទារឲ្យអនុវត្តកាតព្វកិច្ច និងអាចទាមទារឲ្យអនុវត្តកាតព្វកិច្ចបន្ថែមក្នុងទំហំមិនមានភាពផ្ទុយគ្នា។[69]

- **ការតវ៉ាឲ្យអនុវត្តព្រមគ្នា**

ជាទៅកិច្ចសន្យាការងារ ជាប្រភេទកិច្ចសន្យា ដែលបង្កើតនូវកាតព្វកិច្ចអញ្ញមញ្ញ ឬទៅវិញទៅមករវាងភាគីនិយោជក និងនិយោជិត ដោយក្នុងនោះគេសង្កេតឃើញថាមានការផ្តត់ផ្គង់នូវសេវាការងារ និងក៏ដូចជាការផ្តល់នូវកម្រៃប្រចាំខែតបវិញ ជាតម្លៃតបស្នងទៅនឹងលក្ខខណ្ឌការងារ និងស្របនឹងខ្លឹមសារនៃកិច្ចសន្យាការងារ។ការតវ៉ាឲ្យអនុវត្តព្រមគ្នាបានផ្តល់លទ្ធភាពឲ្យគូភាគីនីមួយៗនៃកិច្ចសន្យាអញ្ញមញ្ញ អាចប្រកែកមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន រហូតដល់ពេលដែលភាគីម្ខាងទៀតផ្តល់នូវការអនុវត្តកាតព្វកិច្ចស្របតាមខ្លឹមសារ នៃកិច្ចសន្យា មានន័យថា ករណីយកិច្ចសន្យាការងារ ដែលនិយោជកបានជំពាក់ប្រាក់កម្រៃប្រចាំខែរបស់និយោជិត គឺនិយោជកគ្មានសិទ្ធិបង្ខំឲ្យនិយោជិតបំពេញការងារឲ្យខ្លួនទៅតាមពេលវេលាកំណោត់នៃកិច្ចសន្យាបានទេ ករណី នេះ ភាគីនិយោជិត មានសិទ្ធិបដិសេធមិនអនុវត្តកាតព្វកិច្ចតបវិញ ដើម្បីបង្ខំភាគីនិយោជកបើកប្រាក់ឈ្នួល ឬសងប្រាក់ខែដែលជំពាក់គ្រប់ចំនួន។[70]

---

[69] ម ៣៩៧.ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ស្តីពីទំនាក់ទំនងរវាងការទាមទារឲ្យអនុវត្តកាតព្វកិច្ច និងមធ្យោបាយ ផ្សេងៗ និង ម. ៣៨៥ ស្តីពីសិទ្ធិរបស់ម្ចាស់បំណុល ក្នុងការទាមទារឲ្យអនុវត្តកាតព្វកិច្ច។

[70] ម.៣៨៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ដូចនេះដើម្បីទាមទារឲ្យមានការទទួលខុសត្រូវបានលុះត្រាតែមានការខូចខាត ដែលកើតចេញពីទង្វើរចេតនាឬអចេតនារបស់បុគ្គលដែលបង្កឲ្យមានព្យៈសនកម្ម និងចំណងទាក់ទងរវាងហេតុនិងផលដែលកើតចេញពីកាតព្វកិច្ចនៃកិច្ចសន្យាការងារ ដោយការបង្ហាញភស្តុតាងនៅតែជាចំណុចសំខាន់ដែលទាមទារឲ្យ ភាគីត្រូវតែបំពេញ។

ក្រោយពីយើងសិក្សា អំពីការទទួលខុសត្រូវរបស់និយោជកចំពោះលក្ខខណ្ឌទូទៅដោយប្រៀបធៀបទៅនិងប្រភេទការងារដែលមានលក្ខខណ្ឌការងារដោយឡែក តើនិយោជកមានការទទួលខុសត្រូវដូចម្តេច?

## ១. អំពីការទទួលខុសត្រូវរបស់និយោជកចំពោះលក្ខខណ្ឌទូទៅនៃការងារ

អនុលោមតាមគោលការណ៍ទូទៅនៃកិច្ចសន្យា ដែលកំណត់ថា កិច្ចសន្យា គឺជាច្បាប់របស់គូភាគី ដូចនេះកិច្ចសន្យាមួយមានសុពលភាពបានបង្កើតនូវអានុភាពគតិយុត្តចំពោះគូភាគី មានន័យថាមានអានុភាពចាប់បង្ខំតាមផ្លូវច្បាប់ឲ្យគូភាគីត្រូវតែប្រតិបត្តិដោយប្រែប្រួលទៅតាមប្រភេទផ្សេងៗនៃកិច្ចសន្យា។ អនុវត្តដូចគ្នាចំពោះកិច្ចសន្យាការងារសុពល ក្នុងនោះគូភាគីទាំងសងខាងនៃកិច្ចសន្យា ក្រៅពីការប្រតិបត្តិកិច្ចសន្យា គឺមានសិទ្ធិទាមទារឲ្យមានការទទួលខុសត្រូវផ្សេងៗគ្នា ករណីមិនប្រតិបត្តិប្រតិបត្តិកិច្ចសន្យាប្រតិបត្តិមិនពេញលេញ យឺតយ៉ាវក្នុងការប្រតិបត្ត ឬជាការធ្វេសប្រហែសដែលកើតមានចំពោះលក្ខខណ្ឌទូទៅ និងដោយឡែកនៃការងារ។

**តើអ្វីទៅជាទំនួលខុសត្រូវរបស់និយោជកចំពោះលក្ខខណ្ឌទូទៅ និងដោយឡែកនៃការងារ?** ជាទូទៅកិច្ចសន្យាការងារគឺជាការព្រមព្រៀងបង្កើតឡើងរវាងភាគីពីរ រួមមានម្ខាងជាភាគីនិយោជក ឬថៅហ្វាយនាយ និងម្ខាងទៀតជាភាគីនិយោជិត ឬកូនចៅ ក្នុងនោះភាគីនិយោជិតបានសន្យាថាបំពេញការងារជូននិយោជកក្នុងនាមនិយោជក និងដើម្បីផលប្រយោជន៍និយោជកដោយប្តូរមកវិញនូវប្រាក់កម្រៃប្រចាំខែ។ ផ្អែកតាមអត្ថន័យនេះទំនួលខុសត្រូវដែលមាន គឺជាការប្រតិបត្តិការងារដោយនិយោជិត និងការផ្តត់ផ្គង់ផ្តល់ប្រាក់កម្រៃការងារចំពោះភាគីកូនចៅជាបន្ទុករបស់និយោជក។

ដូចនេះទំនួលខុសត្រូវចំពោះលក្ខខណ្ឌទូទៅ និងដោយឡែកនៃការងារគឺ ជាការទទួលខុសត្រូវដែលកើតពីកិច្ចសន្យាការងារ និងជាបន្ទុករបស់ភាគីនិយោជក និងនិយោជិតដែលត្រូវតែបំពេញការងារឲ្យឆ្លើយតបទៅតាមប្រភេទ និងលក្ខខណ្ឌនៃការងារទូទៅ និងដោយឡែកនៃការងារ។

## ១.១. ទំនួលខុសត្រូវនិយោជកចំពោះលក្ខខណ្ឌទូទៅនៃកិច្ចសន្យាការងារ

បើធ្វើការសិក្សាវិភាគ អំពីវត្ថុបំណងនិងកម្មវត្ថុរបស់ភាគី ក្នុងការបង្កើតកិច្ចសន្យាការងារ នោះគេសង្កេតឃើញថា ភាគីអាចមានតម្រូវការផ្សេងគ្នា តែមានឆន្ទៈរួមគ្នាក្នុងការសម្រេចគោលបំណងដើម្បីនូវបង្កើតកិច្ចសន្យាការងារ។ មានន័យថា ភាគីនិយោជកត្រូវការឲ្យមាននូវការបំពេញការងារ ឬតម្រូវការការងារពលកម្ម និងភាគីកូនចៅ ឬ និយោជិតត្រូវការប្រាក់កម្រៃ ឬប្រាក់ឈ្នួលដើម្បីបំពេញសេចក្តីត្រូវការផ្ទាល់ខ្លួនដែលជាថ្នូរទៅនឹងការបំពេញសេវាការងារជូនភាគីថៅហ្វាយនាយ។

ដូចនេះករណីដែលកូនចៅ ឬនិយោជិតបានប្រើប្រាស់កម្លាំងកាយ កម្លាំងចិត្តនិងកម្លាំងប្រាជ្ញាដើម្បីបំពេញការងារជូននិយោជក ភាគីនិយោជកមានកាតព្វកិច្ចត្រូវផ្តល់នូវប្រាក់កម្រៃជូននិយោជិតតាមខ្លឹមសារនៃកិច្ចសន្យាការងារ។ ទាំងនេះគឺជាទំនួលខុសត្រូវនិយោជកចំពោះលក្ខខណ្ឌទូទៅនៃកិច្ចសន្យាការងារ ប៉ុន្តែបញ្ហាចោទថាតើនិយោជកគួរផ្តល់ប្រាក់កម្រៃកម្រិតណាទើបសមរម្យ ស្របនឹងការផ្តត់ផ្គង់នូវសេវាការងារ ឬការងារពលកម្មរបស់ភាគីនិយោជិត។

## ១.១.១.ទំនួលខុសត្រូវរបស់និយោជកចំពោះការកំណត់ប្រាក់ឈ្នួល

មានន័យថាលក្ខខណ្ឌទូទៅនៃកិច្ចសន្យាការងារ និយោជកមិន អាចលើកមូលហេតុ ដើម្បីបដិសេធមិនផ្តល់ប្រាក់ឈ្នួលដល់ភាគីនិយោជិត ដែលបានប្រឹងប្រែងអស់កម្លាំងកាយ កម្លាំងចិត្ត និង កម្លាំងប្រាជ្ញាដើម្បីផ្គត់ផ្គង់សេវាការងារជូននិយោជក ឬបំពេញការងារពលកម្មក្នុងនាមនិយោជក និងដើម្បីផលប្រយោជន៍និយោជក។ ផ្ទុយទៅវិញចំពោះការបដិសេធ អាចធ្វើបានក្នុងករណីដែលកូនឈ្នួលឬភាគីនិយោជិត មានកំហុសធ្ងន់ធ្ងរក្រៅពីនេះនិយោជកក៏គ្មានមូលហេតុផ្សេង ក្នុងការបដិសេធមិនផ្តល់នូវប្រាក់ឈ្នួលជូនភាគីនិយោជិតទេ។[71] លើសពីនេះទៅទៀតនិយោជកត្រូវបញ្ញត្តិទុកជាមុននូវលក្ខខណ្ឌការងារ និងប្រាក់កម្រៃដែលត្រូវផ្គត់ផ្គង់ចំពោះភាគីនិយោជកទៅតាមប្រភេទការងារផ្សេងៗ ឲ្យឆ្លើយតបទៅនឹងសកម្មភាពការងារ មានជាអាទិ៍ដូចមានចែងក្នុងមាត្រា១០៣នៃច្បាប់ការងារ។[72]

---

[71] ម១០២. ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧។

[72] ម.១០៣ ច្បាប់ស្តីការងារ ឆ្នាំ១៩៩៧ បានចែងថាប្រាក់ឈ្នួលមានជាអាទិ៍ដូចតទៅៈ

ក្រៅពីនេះនិយោជិតត្រូវបញ្ញត្តិបន្ថែម អំពីគោលការណ៍លើកទឹកចិត្តចំពោះលក្ខខណ្ឌការងារដែលបំពេញដោយនិយោជិត។

## ១.១.២.ទំនួលខុសត្រូវនិយោជកចំពោះប្រាក់ឈ្នួលអតិប្បរមាត្រូវធានា

អនុលោមតាមបញ្ញត្តិស្ដីពីការងារកម្ពុជា និយោជកមិនអាចអនុវត្តសិទ្ធិក្នុងការកំណត់ប្រាក់ឈ្នួលទាបហួសហេតុពេក ដែលមិនអាចធានាចំពោះលក្ខខណ្ឌជីវិតរបស់និយោជិត ឬកម្មករនិយោជិតបានពោល គឺប្រាក់ឈ្នួលយ៉ាងតិចណាស់ ក៏ត្រូវឲ្យស្មើនឹងប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានារ៉ាប់រងដល់កម្មករនិយោជិតគ្រប់រូប ឲ្យមានកម្រិតជីវភាពសមរម្យទៅតាមសេចក្ដីថ្លៃថ្នូរបស់មនុស្ស។[73]

---

- ប្រាក់ឈ្នួលសុទ្ធសាធ
- ប្រាក់បន្ថែមម៉ោង
- កំរៃជើងសារ
- បុព្វលាភ និងប្រាក់បំណាច់
- ភាគកម្មក្នុងប្រាក់ចំណេញ
- ប្រាក់ដែលបើកជារង្វាន់
- តំលៃអត្ថប្រយោជន៍ជាវត្ថុ
- វិភាជន៍គ្រួសារសំរាប់ភាគីដែលលើសពីទឹកប្រាក់ត្រឹមត្រូវតាមច្បាប់
- វិភាជន៍សំរាប់ការឈប់សម្រាក ឬបំណាច់សំរាប់ទូទាត់ការឈប់សំរាក
- ចំនួនទឹកប្រាក់ដែលនិយោជកត្រូវផ្ដល់ឲ្យក្នុងពេលបាត់បង់សមត្ថភាពពលកម្ម និងក្នុងពេលលំហែមាតុភាពមិនត្រូវរាប់បញ្ចូលជាមួយប្រាក់ឈ្នួល៖ ការព្យាបាលសុខភាពវិភាជន៍គ្រួសារតាមច្បាប់ សោហ៊ុយធ្វើដំណើរ និង អត្ថប្រយោជន៍ដែលផ្ដល់ឲ្យជាពិសេសចំពោះកម្មករនិយោជិតដើម្បីសំរួលការបំពេញមុខងារ។

[73] ម.១០៤ ច្បាប់ស្ដីពីការងារ ឆ្នាំ១៩៩៧។

លើសពីនេះភាគីនិយោជក ក៏មានកាតព្វកិច្ចត្រូវអនុវត្តគោលការណ៍មិនរើសអើងចំពោះភាគីនិយោជិត កម្មករនិយោជិត លើគ្រប់រូបភាពចំពោះលក្ខខណ្ឌការងារ ភាពប៉ិនប្រសព្វខាងវិជ្ជាជីវៈ ផលប្រយោជន៍ និងប្រាក់ឈ្នួលត្រូវផ្តល់ឲ្យស្មើគ្នាៗ ដល់កម្មករនិយោជិតទាំងអស់ដោយមិនមានរើសអើងគ្រប់រូបភាព ទោះបីជាដើមកំណើត ភេទ ឬអាយុក៏ដោយ។[74]

### ១.១.៣.ទំនួលខុសត្រូវនិយោជិតចំពោះការធានានិងឯកសិទ្ធិនៃប្រាក់ឈ្នួលដែលនៅជំពាក់

និយោជកមានកាតព្វកិច្ចធានា ចំពោះការទូទាត់ប្រាក់ឈ្នួលក្នុងនាមជាសហគ្រិន ដែលសម្រេចទទួលការងារ និងមិនអាចឃាត់ទុក ឬជំទាស់មិនឲ្យទូរទាត់ប្រាក់ឈ្នួល ឬធ្វើឲ្យយឺតយ៉ាវពេលវេលាក្នុងការបើកប្រាក់ឈ្នួលដល់និយោជិត ឬកម្មករនិយោជិត។ ម្យ៉ាងវិញទៀតនិយោជកមានកាតព្វកិច្ចបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតនូវរាល់មុនការទូទាត់បំណុលផ្សេងៗ។[75]

### ១.១.៤. ទំនួលខុសត្រូវនិយោជកចំពោះការកាត់ប្រាក់ឈ្នួល

និយោជិត កម្មករនិយោជិត ត្រូវទទួលបាននូវការការពារ ចំពោះរាល់ការកាត់ប្រាក់ឈ្នួលដោយគ្មានមូលហេតុសមស្រប ដូចជាការកាត់ប្រាក់ឈ្នួលក្នុងគោលបំណងឲ្យអ្នកទទួលរកការងារឲ្យធ្វើ ទោះបីជាសកម្មភាពទាំងនោះធ្វើឡើងដោយផ្ទាល់ឬដោយប្រយោលក្តីត្រូវហាមឃាត់។[76] ក្រៅពីនេះនិយោជិត ក៏ទទួលបាននូវការការពារផ្សេងទៀតចំពោះការទូទាត់ ដែលធ្វើឡើងដើម្បីជាប្រយោជន៍ដល់ភាគីនិយោជក រវាងប្រាក់ឈ្នួលត្រូវបើកឲ្យ

---

[74] ម.១០៥ ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧។

[75] ម.១២១ម. ,២២ និងម.១២៤ ច្បាប់ការងារ ឆ្នាំ១៩៩៧។

[76]ម.១២៦ ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧។

កម្មករនិយោជិត និងប្រាក់ឈ្នួលដែលកម្មករនិយោជិតត្រូវសងទៅភាគីនិយោជកចំពោះការផ្គត់ផ្គង់សំភារៈផ្សេងៗ។ ប៉ុន្តែនិយោជិតអាចអនុវត្តវិធានការទូទាត់ និងការកាត់ប្រាក់ឈ្នួលក្នុងករណីមួយចំនួន ដូចជាការផ្គត់ផ្គង់គ្រឿងសម្ភារៈ ឧបករណ៍ចាំបាច់សំរាប់ការចំពេញការងារ និងករណីកម្មករនិយោជិតឈប់បំពេញការងារ មិនអាចទាមទារឲ្យប្រគល់ឲ្យវិញចំពោះវត្ថុធាតុដើម សម្ភារៈដែលកម្មករនិយោជិតទទួលបន្ទុកនិងប្រើប្រាស់ និងករណីមួយចំនួនទៀតដូចមានចែងក្នុងមាត្រា១២៧នៃច្បាប់ស្តីពីការងារ។ ក្រៅពីនេះក្នុងករណីដែលនិយោជកបានបើកប្រាក់ឈ្នួលឲ្យកម្មករនិយោជិតខ្ចីមុន និយោជកអាចអនុវត្តនីតិវិធីកាត់សង រំលោះក្នុងភាគប្រាក់ដែលអាចផ្ទេរ ឬរឹបអូសបាននិងលើកលែងដែលអនុវត្តចំពោះអនុសញ្ញារួមដែលអនុញ្ញាតឲ្យដកហូតលើប្រាក់ឈ្នួល។[77]

## ១.១.៥.ទំនួលខុសត្រូវរបស់និយោជកចំពោះប្រាក់ធនានុគ្រោះ

អនុលោមតាមមាត្រា១៣៤ នៃបទប្បញ្ញត្តិស្តីពីការងារប្រាក់ធនានុគ្រោះ គឺជាកម្រៃដែលអតិថិជនឲ្យទៅបុគ្គលិកនៃសហគ្រាស ឬគ្រឹះស្ថានខ្លះ ដូចជាសណ្ឋាគារ ភោជនាគារ ផ្ទះកាហ្វេ ផ្ទះលក់ភេសជ្ជៈ ផ្ទះសម្រាប់កាត់សក់ជាដើម ហើយដែលនិយោជកបានទទួលភាគរយ ដែលត្រូវបន្ថែមលើកំណត់ទារប្រាក់ពី អតិថិជនក្រោមចំណារសំគាល់សំរាប់សេវា។ ប្រាក់ធនានុគ្រោះនេះ និយោជកត្រូវប្រមូលបើកឲ្យបុគ្គលិក ដែលទាក់ទងនឹងអតិថិជននោះទាំងអស់។

[77] ម.១២៨ ម.១២៩ ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧។

## ១.១.៦.ទំនួលខុសត្រូវនិយោជកចំពោះថិរវេលាធ្វើការ ថិរវេលាប្រចាំថ្ងៃ និងប្រចាំសប្តាហ៍

អនុលោមតាមប្បញ្ញត្តិស្តីពីការងារកម្ពុជាឆ្នាំ១៩៩៧ គ្រឹះស្ថានប្រភេទណាក៏ដោយ ទោះបីជាគ្រឹះស្ថាននោះមានលក្ខណៈជាការសិក្សាវិជ្ជាជីវៈ ឬជាកិច្ចកុសលព្រមទាំងនៅក្នុងវិជ្ជាជីវៈសេរីក៏ដោយ គឺថិរវេលាធ្វើការពេញលេញនៃកម្មករនិយោជិតទាំងពីរភេទ មិនត្រូវលើសពី៨ម៉ោងក្នុងមួយថ្ងៃឬ៤៨ម៉ោងក្នុងមួយអាទិត្យ។ ករណីមានកិច្ចការប្រញាប់ខុសធម្មតា តម្រូវឲ្យនិយោជិតធ្វើការបន្ថែមម៉ោងពីក្រៅម៉ោងធម្មតា ដោយភាគីនិយោជកត្រូវតែគិតប្រាក់ថែមម៉ោងជូនភាគីនិយោជិត។[78]

## ២.ការទទួលខុសត្រូវរបស់និយោជកចំពោះលក្ខខណ្ឌដោយឡែកនៃការងារ

ក្រៅពីលក្ខខណ្ឌទូទៅនៃការងារនិយោជិតផ្អែកតាមទ្រឹស្តីស្វ័យភាពនៃឆន្ទៈសេរីនៅក្នុងទំនាក់ទំនងនៃកិច្ចសន្យាការងារ បុគ្គលអាចបង្កើតការព្រមព្រៀងផ្សេងទៀតដែលកំណត់អំពីសិទ្ធិ និងកាតព្វកិច្ច និងការទទួលខុសត្រូវដោយឡែកបន្ថែមលើលក្ខខណ្ឌទូទៅនៃការងារ ដែលជាទំនួលខុសត្រូវរបស់និយោជកចំពោះលក្ខខណ្ឌដោយឡែកនៃការងារមានដូចជាការងារនៅក្នុងវិជ្ជាជីវៈកសិកម្ម ឬការផលិតឱសថ។

អនុលោមតាមបទបញ្ញត្តិស្តីពីការងារ ចំពោះលក្ខខណ្ឌដោយឡែកនៃការងារ ឬការងារខាងវិជ្ជាជីវៈកសិកម្មបានអនុវត្តចំពោះកម្មករនិយោជិតនៃវិជ្ជាជីវៈខាងកសិកម្ម មានន័យថា ចំពោះកម្មករនិយោជិតទាំងឡាយណា

[78] ម.១៣៧ ,ម.១៣៨ ,ម.១៣៩ ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧។

ដែលធ្វើការងារខាងចំការ ដូចជាអាជីវកម្មខាងកសិកម្មដាំដំណាំ និងចិញ្ចឹមសត្វ អាជីវកម្មព្រៃឈើ និងអាជីវកម្មនេសាទ ត្រូវទទួលបាននូវការធានា និងការការពារជាពិសេសអំពីថិរវេលានៃការងារ ភាគឈ្នួលជាវត្ថុ ការផ្តល់វត្ថុឲ្យសម្រាប់គ្រួសារ គេហដ្ឋាន ប្រាក់បំណាច់ គេហដ្ឋានទឹក ការផ្តល់ភស្តុភារបង្កន់ កន្លែងផ្ញើរក្មេង និងមរណភាព ការរំលាយសព និង លក្ខខណ្ឌទាំងអស់នេះអាចទទួលបាន លុះត្រាតែកម្មវត្ថុនៃកិច្ចសន្យាការងារ ជាការងារនៃវិជ្ជាជីវៈខាងកសិកម្ម។[79]

តើអ្វីទៅជាវិជ្ជាជីវៈខាងកសិកម្ម? ជាទូទៅការងារខាងវិជ្ជាជីវៈកសិកម្មត្រូវទទួលបាននូវការធានានិងការការពារជាពិសេស គឺសំដៅទៅលើប្រភេទនៃកិច្ចការងារខាងចំការមានដូចជា ប្រភេទអាជីវកម្មខាងកសិកម្មដែលបានប្រើអ្នកធ្វើការយកឈ្នួលជាទៀងទាត់ ហើយដែលមានដាំដំណាំ ឬផលិតផលសំខាន់សម្រាប់ធ្វើជំនួញដូចកាហ្វេ តែ អំពៅ កៅស៊ូ ចេក ដូងសណ្តែកដី ថ្នាំជក់ ក្រូច ដូងប្រេង កាំងគីណា ម្នាស់ កប្បាស ក្រចៅ និងដំណាំឧស្សាហ៍កម្មផ្សេងទៀត ជាសកម្មភាពការងារទាំងឡាយ នៃអាជីវកម្មខាងកសិកម្ម ដាំដំណាំ និងចិញ្ចឹមសត្វ អាជីវកម្មព្រៃឈើ និងអាជីវកម្មនេសាទ។[80]

## ២.១. ទំនួលខុសត្រូវនិយោជកចំពោះថិរវេលាធ្វើការ

នៅក្នុងកិច្ចសន្យាកាងារ ភាគីចៅហ្វាយនាយ ឬនិយោជកត្រូវតែបញ្ញត្តិឲ្យបានច្បាស់លាស់ អំពីថិរវេលាការងារនៃកម្មករនិយោជិតខាងអាជីវកម្មកសិកម្ម ដាំដំណាំ និងចិញ្ចឹមសត្វ អាជីវកម្មព្រៃឈើ និងអាជីវកម្ម

[79] ម.១៩៥ រហូតដល់ម.២២៦ ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧។

[80] ម១៩៣. ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧។

នេសាទនូវថិរវេលាកម្រិតត្រឹមតែ៨ម៉ោងក្នុងមួយថ្ងៃ ឬ៤៨ម៉ោងក្នុងមួយសប្តាហ៍។ ថិរវេលាធ្វើការធម្មតានេះអាចដល់៩ម៉ោងក្នុងមួយថ្ងៃប៉ុន្តែមិនអាចឲ្យលើស៤៨ម៉ោងក្នុងមួយសប្តាហ៍។

ម្យ៉ាងវិញទៀតសម្រាប់កម្មករនិយោជិតត្រូវធ្វើការទៀងទាត់ និងស្នាក់នៅក្នុងសហគ្រាសពេលវេលាចាំបាច់ ដើម្បីចេញពីផ្ទះសម្បែងទៅធ្វើការ និងត្រឡប់មកវិញត្រូវគិតបញ្ចូលក្នុងពេលធ្វើការចំពោះភាគី លើសពី១ម៉ោង និង សំរាប់កម្មករនិយោជិតដែលធ្វើការទៀងទាត់ ហើយមិនស្នាក់នៅក្នុងសហគ្រាស និងកម្មករនិយោជិត ធ្វើការម្តងម្កាលមានថិរវេលាធ្វើការប្រចាំថ្ងៃគឺគិតតាមម៉ោងកំណត់ធ្វើការ។

ករណីសហគ្រាសមានបន្ថែមម៉ោងការងារលើសពី២ម៉ោងក្នុងមួយថ្ងៃ និងពេលវេលានោះ គឺជាពេលវេលាបង្ហាញខ្លួននៅកន្លែងការងារ គឺភាគីកម្មករនិយោជិត ត្រូវទទួលបាននូវការការពារចំពោះសេរីភាពនៃការប្រើប្រាស់ពេលវេលាជាប្រចាំការជាពេលវេលាផ្ទាល់ខ្លួន និងដោយមិនត្រូវបង្ខំឲ្យបំពេញការងារអ្វីឡើយប៉ុន្តែ បញ្ញត្តិនេះអាចអនុវត្តបានចំពោះបញ្ជីនៃមុខរបរកំណត់ដោយប្រកាសនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ករណីសហគ្រាសមានកំណត់ថិរវេលាធ្វើការលើសពី៨ម៉ោង និយោជកត្រូវចេញប្រាក់ឈ្នួលតាមអត្រាម៉ោងបន្ថែម ប៉ុន្តែករណីបន្ថែមម៉ោងការងារនេះ គឺមិនអាចលើសដល់១០ម៉ោងក្នុងមួយថ្ងៃទេ និងលើកលែងក្នុងករណីបង្ការ ឬជួសជុលការខូចខាតដោយមហន្តរាយណាមួយ។

## ២.២.ទំនួលខុសត្រូវរបស់និយោជកចំពោះភាគឈ្នួលនៃវត្ថុ

ជាទូទៅនៅពេលកិច្ចសន្យាការងារមានសុពលភាព គឺបានបង្កើតសិទ្ធិ និងករណីយកិច្ចសម្រាប់គូភាគីរួមមាននិយោជិក កម្មករនិយោជិត និង

និយោជក ដែលក្នុងនោះភាគីជាថៅហ្វាយនាយឬនិយោជកមានកាតព្វកិច្ចត្រូវបើកប្រាក់កម្រៃជូនភាគីកូនថៅ ឬកម្មករនិយោជិត។ បន្ថែមពីនេះ អនុលោមតាមបទប្បញ្ញត្តិស្តីពីការងារកម្ពុជាឆ្នាំ១៩៩៧ ក្រៅពីភាគឈ្នួលជាប្រាក់ គឺគូភាគីនៃកិច្ចសន្យាការងារ អាចមានការព្រមព្រៀងផ្សេងទៀតក្នុងការកំណត់ប្រាក់ឈ្នួលជាវត្ថុ។[81]

ករណីមានការព្រមព្រៀងកំណត់ប្រាក់ឈ្នួលជាវត្ថុ និយោជកអាចសន្មតបានថាក្នុងនោះភាគីថៅហ្វាយនាយ បានផ្តល់ឲ្យកម្មករនិយោជិតដែលធ្វើការទៀងទាត់ម្នាក់ៗនូវអង្ករចំនួន៩០០ក្រាមក្នុងមួយថ្ងៃ និងបើសិនជាមានការព្រៀងរវាភាគី គឺអាចដោះដូរអង្ករជាឈ្នួលមកជាសាច់ប្រាក់វិញក៏បាន។ ប៉ុន្តែទោះបីជាអនុវត្តក្នុងករណីណាក៏ស្មើតម្លៃប្រាក់នៃភាគឈ្នួល និងការបើកប្រាក់ថែមម៉ោងវិញត្រូវតែគិតគូរឲ្យបានត្រឹមត្រូវហើយចុះបញ្ជីការ។

## ២.៣.ទំនួលខុសត្រូវនិយោជកចំពោះការផ្តល់វត្ថុឲ្យសម្រាប់គ្រួសារ

ក្រៅពីភាគឈ្នួលដែលមានកំណត់នៅក្នុងកិច្ចសន្យាការងារក្នុងវិជ្ជាជីវៈខាងកសិកម្ម កម្មករនិយោជិតអាចទទួលបាននូវការផ្តល់ឲ្យជាពិសេសចំពោះក្រុមគ្រួសារ ក្នុងនាមជាកម្មករនិយោជិតធ្វើការទៀងទាត់ក្នុងចំការគ្រប់រូបមានសិទ្ធិត្រូវបានវត្ថុសម្រាប់ប្រពន្ធ និងកូនដែលជាអនីតិជននៅក្នុងបន្ទុក ទោះបីមានខាន់ស្លា ឬគ្មានខាន់ស្លារក៏ដោយឲ្យតែកូនមានអាយុតិចជាង១៦ឆ្នាំត្រូវទទួលបានអង្ករប្រចាំថ្ងៃតាមចំនួនកម្រិតដូច ខាងក្រោម[82]៖

---

[81] ម.១៩៨ ម.១៩៩ ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧។

[82] ម.២០០ ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧។

- ✓ ៨០០ក្រាមសម្រាប់ប្រពន្ធ
- ✓ ២០០ក្រាមសម្រាប់កូនម្នាក់ដែលមានអាយុតិចជាង២ឆ្នាំ
- ✓ ៤០០ក្រាមសម្រាប់កូនម្នាក់ដែលមានអាយុពី២ឆ្នាំទៅ៦ឆ្នាំ
- ✓ ៦០០ក្រាមសម្រាប់កូនម្នាក់ដែលមានអាយុពី៦ឆ្នាំទៅ១៦ឆ្នាំ
- ✓ ៧៥០ក្រាមសម្រាប់កូនម្នាក់ដែលមានអាយុពី១០ឆ្នាំទៅ១៦ឆ្នាំ

នេះគឺជាតាវកាលិក ដែលផ្គត់ផ្គង់ដោយភាគីនិយោជក ដល់កម្មករនិយោជិតជាមេគ្រួសាររាល់ថ្ងៃធ្វើការ ដោយទទួលនូវសិទ្ធិបានប្រាក់ឈ្នួល ករណីនេះអនុវត្តដូចគ្នាចំពោះកម្មករនិយោជិតដែលព្យួរការងារបណ្តាលមកពីការដេកពេទ្យ ឬមានជំងឺដែលបានបញ្ជាក់ត្រឹមត្រូវ។ ករណីកម្មករនិយោជិតមានកូនអាយុច្រើនជាង១៦ឆ្នាំ ហើយតិចជា២១ឆ្នាំ សិក្សានៅគ្រឹះស្ថានសាធារណៈខាងមធ្យមសិក្សា ឬឧត្តមសិក្សា ឬគ្រឹះស្ថានឯកជនខាងមធ្យមសិក្សា ឬឧត្តមសិក្សាដែលបានអនុញ្ញាតត្រឹមត្រូវ ឬកូនដែលគេឲ្យសិក្សា ឬធ្វើការ ត្រូវទទួលបានសិទ្ធិដូចគ្នា និងកូនជាអនីតិជនអាយុ១៦ឆ្នាំ។ លើសពីនេះទៅទៀតអ្នកទទួលបានផលប្រយោជន៍តម្រូវឲ្យបំពេញលក្ខខណ្ឌមួយចំនួនដូចជាការផ្តល់វត្ថុសម្រាប់គ្រួសារ និងអាចទទួលបាន ក្នុងករណីប្រពន្ធមិនបានប្រកបរបរអាជីវកម្មអ្វីមិនមានប្រាក់ឈ្នួល និងកូនជាអនីតិជនស្ថិតនៅក្នុងបន្ទុក មានន័យថាកូនជាអនីតិជនស្នាក់នៅជាមួយមេគ្រួសារ ករណីកូនសិក្សានៅសាលាឆ្ងាយ គឺតម្រូវឲ្យមានឯកសារបញ្ជាក់ត្រឹមត្រូវ។

## តើការផ្តល់វត្ថុសម្រាប់គ្រួសារនេះកម្មករនិយោជិតអាចទទួលបាននៅពេលណា?

អនុលោមតាមបទប្បញ្ញត្តិស្តីពីការងារកម្ពុជា កម្មករនិយោជិតទទួលបានការផ្តល់វត្ថុសម្រាប់គ្រួសារចាប់តាំងពីកាលបរិច្ឆេទចូលធ្វើការ គឺនៅ

ក្រោយពេលដែលនិយោជិកទទួលបានលិខិត និងភស្តុតាងត្រឹមត្រូវតាមច្បាប់គ្រប់ចំនួនដូចជា៖

- ✓ សម្រង់លិខិតអាពាហ៍ពិពាហ៍
- ✓ សម្រង់លិខិតកំណើតនៃកូននីមួយៗ
- ✓ សេចក្តីប្រកាសអំពីមេគ្រួសារបញ្ជាក់ដោយទទួលខុសត្រូវថាប្រពន្ធមិនបានធ្វើការមានប្រាក់ឈ្នួលទេ
- ✓ លិខិតបញ្ជាក់ការសិក្សា ឬរៀនវិជ្ជាជីវៈផ្សេងៗ

## ២. ៤. ទំនួលខុសត្រូវនិយោជកចំពោះគេហដ្ឋាន និងប្រាក់បំណាច់

**គេហដ្ឋាន៖** កម្មករនិយោជិតធ្វើការងារទៀងទាត់ជាប់លាប់មួយកន្លែងមានសិទ្ធិទទួលបានគេហដ្ឋានស្នាក់នៅដោយមិនគិតថ្លៃ ជាគេហដ្ឋានធំនិងសាខា ដែលជាកាតព្វកិច្ចនិយោជក អនុលោមទៅតាមលក្ខខណ្ឌដូចមានកំណត់ក្នុងប្រកាសរបស់ក្រសួងទទួលបន្ទុកវិស័យការងារ។

**តើគេហដ្ឋានធំនិងសាខា ដែលផ្តល់ឲ្យភាគីកម្មករនិយោជិតជាគេហដ្ឋានប្រភេទណា?**

អនុលោមតាមបទប្បញ្ញត្តិស្តីពីការងារ និយោជកមានកាតព្វកិច្ចត្រូវផ្តល់គេហដ្ឋានដោយមិនគិតថ្លៃដល់ភាគីកម្មករនិយោជិត ក្នុងការរស់នៅជួបជុំប្តីប្រពន្ធ ឬក្រុមគ្រួសារត្រូវមានក្រឡាផ្ទៃអប្បរមាមានទំហំ២៤ម៉ែត្រទ្វេរគុណ។ ករណីនេះអនុវត្តដូចគ្នា ចំពោះកម្មករនិយោជិតនៅលីវទាំងពីរភេទ

ដូចគ្នា ប៉ុន្តែអាចស្នាក់នៅយ៉ាងច្រើនចំនួន៤នាក់ក្នុងផ្ទះនីមួយៗ[83]។ម្យ៉ាងទៀតការសាងសង់គេហដ្ឋានដល់ភាគីកម្មករនិយោជិត តម្រូវឲ្យនិយោជិតអនុវត្តគោរពតាមបទដ្ឋាន ដែលអនុញ្ញាតិដោយអាជ្ញាធរមានសមត្ថកិច្ចគឺត្រូវសាងសង់តាមបទបញ្ញាអនាម័យ និងសុខភាពសាធារណៈស្របតាមប្លង់បង្គុំសំណង់ និងប្លង់ស្ថាបត្យកម្មដែលផ្តល់ដោយស្ថាប័នមានសមត្ថកិច្ច។

**តើកម្មករនិយោជិតទទួលបានប្រាក់បំណាច់គេហដ្ឋានពេលណា?**

ករណីម្ចាស់ចំការ ឬភាគីនិយោជកមិនអាចផ្តល់គេហដ្ឋាន និងមិនអាចឲ្យកម្មករនិយោជិតធ្វើការទៀងទាត់ជាប់លាប់មួយកន្លែងទេ និយោជកមានកាតព្វកិច្ចត្រូវផ្តល់ប្រាក់បំណាច់គេហដ្ឋានប្រចាំខែ តាមលក្ខខណ្ឌដូចកំណត់ក្នុងប្រកាសនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈដោយផ្អែកតាមយោបល់គណៈកម្មការប្រឹក្សាការងារ។

## ២.៥. ទំនួលខុសត្រូវនិយោជកចំពោះការផ្គត់ផ្គង់ទឹកស្អាត

និយោជកមានកាតព្វកិច្ចត្រូវផ្គត់ផ្គង់ទឹកស្អាត ជូនដល់កម្មករនិយោជិតប្រើប្រាស់តាមត្រូវការឲ្យបានគ្រប់គ្រាន់និងគ្រប់រដូវតាមលក្ខខណ្ឌសមរម្យបំផុត។ ករណីទឹកមានប្រភពគួរឲ្យសង្ស័យថាមានគ្រោះថ្នាក់ ភាគីនិយោជកត្រូវចាត់វិធានការចាំបាច់ ដោយសួរយោបល់ពេទ្យសាធារណៈដូចជាការសំអាត ណែនាំឲ្យប្រុងប្រយ័ត្ន និងដាំទឹកឲ្យបានឆ្អិនមុននឹងបរិភោគ ឬការប្រើជាតិគីមីដើម្បីសំអាតទឹកនោះជាដើម។

---

[83] ម.២០៤ និងម.២០៦ ច្បាប់ការងារ ឆ្នាំ១៩៩៧។

## ២.៦.ទំនួលខុសត្រូវរបស់និយោជកចំពោះការផ្គត់ផ្គង់ភស្តុភារ

និយោជកមានកាតព្វកិច្ចផ្គត់ផ្គង់ភស្តុភារ ជូនដល់កម្មករនិយោជិត ក្នុងករណីដែលចំការឬការដ្ឋានស្ថិតនៅឆ្ងាយពីផ្សារធម្មតា ហើយដែលគ្មានគ្រឿងប្រើប្រាស់គ្រប់គ្រាន់ ដូចជាការបង្កើតឲ្យមាននូវអាគារូបដ្ឋានមួយដែលមានភស្តុភារចាំបាច់ដូចជា អង្ករ ត្រីងៀត ត្រីឆ្អើ អំបិល តែ។ល។

## ២.៧. ទំនួលខុសត្រូវនិយោជកចំពោះការផ្គត់ផ្គង់បង្គន់អនាម័យ

និយោជកមានកាតព្វកិច្ចត្រូវផ្គត់ផ្គង់នូវបង្គន់អនាម័យ ដល់កម្មករនិយោជិតយ៉ាងតិចចំនួន១/៤នៃគេហដ្ឋានដោយមានលក្ខណៈសមរម្យនិងត្រឹមត្រូវ ហើយត្រូវពិនិត្យឲ្យមានអនាម័យជានិច្ច។

ទាំងអស់នេះអនុវត្តដូចគ្នាចំពោះការគ្រប់គ្រងនូវកាកសំណល់គ្រប់ប្រភេទ ដោយត្រូវដាក់ក្នុងរណ្ដៅ នៅឲ្យឆ្ងាយពីផ្លូវទឹក និង ផ្ទះសម្បែង។[84]

## ២.៨. ទំនួលខុសត្រូវនិយោជកចំពោះមរណៈភាពនិងការរំលាយ សាកសពរបស់កម្មករនិយោជិត

ករណីមានកម្មករនិយោជិតមរណៈភាព និងនិយោជកមានកាតព្វកិច្ចអនុញ្ញាតិឲ្យមានការពិនិត្យធ្វើកោសល្យវិច្ច័យពីមន្ត្រីមានសមត្ថកិច្ច និងការរំលាយសាកសពត្រូវអនុវត្តតាមលក្ខខណ្ឌច្បាប់ជាធរមាន។

[84] មនិង២១៦ ២១៥ ,២១៤. ច្បាប់ស្ដីពីការងារ ឆ្នាំ១៩៩៧។

ករណីកម្មករនិយោជិតទទួលមរណៈភាព និងកម្មករនិយោជិតនោះកាលនៅរស់ជាបុគ្គលគំរូបានធ្វើការទៀងទាត់ និយោជកមានកាតព្វកិច្ចត្រូវផ្ដល់នូវក្ដារម្ឈូស សំពត់ដល់សព និងធ្យោបាយដឹកនាំក្ដារម្ឈូស ទៅដល់ទីសមសាន្ត ឬប៉ាឆា ហើយទទួលបន្ទុកនូវសោហ៊ុយធ្វើបុណ្យក្នុងតម្លៃ មិនតិចជាងប្រាក់ឈ្នួលមួយខែនៃសពកម្មករនិយោជិតនេះទេ។[85]

## ២.៩. ទំនួលខុសត្រូវនិយោជកចំពោះកន្លែងផ្ញើក្មេង

ករណីសហគ្រាសមានប្រើកម្មករនិយោជិតជាប់លាប់ជាស្ត្រី និងមានទីលំនៅក្នុងចំការចំនួនពី១០០នាក់ឡើង ដោយអនុលោមទៅតាមបទប្បញ្ញត្តិស្ដីពីការងារ អធិការការងារអាចចាត់បង្គាប់ឲ្យនិយោជកសាងសង់រៀបចំឬកន្លែងថែទាំផ្ញើក្មេងមួយនៅជិតគេហដ្ឋានតាមយោបល់នៃក្រុមពេទ្យ និង អភិបាលរាជធានីខេត្ត។

ក្រៅពីនោះ និយោជកម្ចាស់ចំការមានកាតព្វកិច្ចផ្គត់ផ្គង់នូវភស្តុភារចាំបាច់ដូចជាអង្ករ និងទឹកដោះគោតាមចំនួនក្មេងដែលផ្ញើ។

## ២.១០.ទំនួលខុសត្រូវនិយោជកចំពោះសាលារៀន

ករណីនៅចំការមានក្មេងអាយុ៦ឆ្នាំពេញចំនួនយ៉ាងតិច២០នាក់ជាកូនរបស់កម្មករនិយោជិតដែលធ្វើការជាប់លាប់ និងស្នាក់នៅនឹងចំការ និយោជកមានកាតព្វកិច្ច ត្រូវសាងសង់សាលាបឋមសិក្សានៅជិតគេហដ្ឋានរបស់កម្មករនិយោជិតទាំងនោះ ដោយចំនួនសមស្របតាមសេចក្ដីត្រូវការ

---

[85] មនិង២១៨ ២១៧. ច្បាប់ស្ដីពីការងារ ឆ្នាំ១៩៩៧។

និងស្របទៅតាមលិខិបទដ្ឋានដែលមានជាធរមាន និងសម្រាប់ប្រាក់ឈ្នួលបុគ្គលិកបង្រៀនជាបន្ទុករបស់សហគ្រាស។

ករណីមានសាលារៀនឆ្ងាយពីភូមិជាង១៥០០ម៉ែត្រ និយោជកមានកាតព្វកិច្ចត្រូវទទួលបន្ទុកផ្តល់សោហ៊ុយក្នុងការបញ្ជូនដឹកនាំកូនសិស្សទាំងនោះទៅសាលារៀន។[86] ដូចនេះកម្មករនិយោជិតការងារខាងវិជ្ជាជីវៈកសិកម្មទទួលបានការគាំពារពិសេសពីនិយោជិតដោយផ្អែកតាមបទប្បញ្ញត្តិស្តីពីការងារ។

## កថាខណ្ឌ៤. សិក្សាអំពីកិច្ចសន្យាការងារហ្វឹកហ្វឺនកូនជាង

អនុលោមតាមគោលការណ៍ទូទៅនៃការបង្កើតកិច្ចសន្យា បានកំណត់ថា កិច្ចសន្យាគឺជាការព្រមព្រៀងរវាងបុគ្គលពីរ ឬច្រើនដើម្បីបង្កើតកែប្រែរំលត់សិទ្ធិ និងកាតព្វកិច្ចមួយ ចំនួនដែលទាក់ទិន និងគូភាគី។

ចំពោះការហ្វឹកហ្វឺនកូនជាង អនុលោមតាមបទប្បញ្ញត្តិស្តីពីការងារ គឺជាកាតព្វកិច្ចរបស់និយោជក ដែលត្រូវតែផ្តល់ការហ្វឹកហ្វឺនវិជ្ជាជីវៈទៅកូនជាង ក្នុងនោះតាមរយៈការហ្វឹកហ្វឺនកូនជាង កម្មករនិយោជិត ដែលគ្មានជំនាញត្រូវទទួលបានការហ្វឹកហ្វឺនដំបូងនិងបន្ទាប់ពីការបញ្ចប់ការហ្វឹកហ្វឺននេះដោយជោគជ័យ ពួកគេនឹងរំពឹងថា នឹងក្លាយជាកម្មករនិយោជិតសាកល្បង និងបន្ទាប់មកទៀតក៏ក្លាយជាកម្មករនិយោជិតពេញសិទ្ធិ។ ដូចនេះកិច្ចសន្យាហ្វឹកហ្វឺនកូនជាង គឺជាប្រភេទកិច្ចសន្យាដែលកើតចេញពីការព្រមព្រៀង មានភាគីម្ខាងជានាយកគ្រឹះស្ថានឧស្សាហ៍កម្ម ពាណិជ្ជកម្ម សិប្បករ

---

[86] ម.២២២ម. ,២២៣ម. ,២២៥ និងម.២២៦ ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧។

ឬជាជាងម្នាក់ទទួល ឬប្រគល់ភារៈអប់រំវិជ្ជាជីវៈឲ្យបានពេញលេញ និងតាមរបៀបបច្ចេកទេសទៅឲ្យភាគីម្ខាងទៀត ដោយក្នុងនោះភាគីម្ខាងទៀត បានសន្យាថានឹងជួយធ្វើការក្នុងឋានៈជាកូនជាងតាមលក្ខខណ្ឌ និងថិរវេលាដែលបានព្រមព្រៀងគ្នាដោយមានកំណត់មិនឲ្យលើសពីរឆ្នាំ។[87]

លើសពីនេះទៅទៀតដើម្បីឲ្យកិច្ចសន្យាហ្វឹកហ្វឺនកូនជាងមួយមានសុពលភាព បុគ្គលតម្រូវឲ្យបំពេញនូវលក្ខខណ្ឌអ្វីខ្លះ? តើការបង្កើតកិច្ចសន្យាហ្វឹកហ្វឺនកូនជាងដូចគ្នាទៅនឹងការបង្កើតកិច្ចសន្យាទូទៅដែរឬទេ? និង អ្នកណាជាភាគីនៃកិច្ចសន្យាហ្វឹកហ្វឺនកូនជាង?

## ១. របបគតិយុត្តនៃកិច្ចសន្យាហ្វឹកហ្វឺនកូនជាង

### ១.១.លក្ខខណ្ឌសុពលភាពនៃការបង្កើតកិច្ចសន្យាហ្វឹកហ្វឺនកូនជាង

កិច្ចសន្យាហ្វឹកហ្វឺនកូនជាង ជាប្រភេទកិច្ចសន្យាមួយដែលបង្កើតឡើងដោយការព្រមព្រៀងរវាងបុគ្គលពីរ ឬច្រើន ក្នុងលក្ខខណ្ឌនៃការបណ្ដុះបណ្ដាលវិជ្ជាជីវៈតាមជំនាញ ដើម្បីឆ្លើយតបតម្រូវការក្រុមហ៊ុន រោងចក្រសហគ្រាស។ កិច្ចសន្យាហ្វឹកហ្វឺនកូនជាង ត្រូវបានបង្កើតឡើងដោយភាគីម្ខាងជានាយក ឬអ្នកទទួលបានសិទ្ធិជាតំណាង ឬបំពេញការងារក្នុងនាមជានាយក បានចុះកិច្ចសន្យាជាមួយនឹងភាគីម្ខាងទៀតជានិយោជិតឬកម្មករនិយោជិតដែលជាកូនចៅ ដោយតាមរយៈនោះ ភាគីរំពឹងថានឹងក្លាយទៅជា

[87] ប្រការ១ ប្រកាសលេខ០០៤ សកបយ ស្តីពីការហ្វឹកហ្វឺនកូនជាងចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០០។

កម្មករនិយោជិតសាកល្បង កម្មករនិយោជិតពេញសិទ្ធិ ក្រោយពេលការបណ្តុះបណ្តាលបញ្ចប់ ឬដោយទទួលជោគជ័យ។

ទាំងអស់នេះបានកើតចេញពីការសន្មតរបស់គូភាគី ដែលកំណត់បានថាជាច្បាប់របស់គូភាគី ដូចនេះបើយើងធ្វើការបកស្រាយដោយផ្អែកលើវិធាននៃច្បាប់កិច្ចសន្យា ដែលលក្ខខណ្ឌសុពលភាពបង្កើតកិច្ចសន្យា គឺតម្រូវឲ្យគោរពនូវលក្ខខណ្ឌគ្រឹះ និង លក្ខខណ្ឌទម្រង់។ ដូចនេះការបង្កើតកិច្ចសន្យាហ្វឹកហ្វឺនកូនជាង តម្រូវឲ្យភាគីត្រូវតែគោរពនូវលក្ខខណ្ឌគ្រឹះ រួមមានការព្រមព្រៀងដែលគ្មានវិការៈ គឺគ្មានការភាន់ច្រលំ ការបន្លំបោកប្រាស់ និងការប្រើប្រាស់ហិង្សា នឹងតម្រូវឲ្យបង្កើតឡើងពីបុគ្គលដែលមានសមត្ថភាពចុះកិច្ចសន្យា គឺជានីតិជនដែលមានសមត្ថភាពមានអាយុចាប់ពី១៨ឆ្នាំឡើង

ឬជាអនីតិជនដែលមានអត្តាធិនភាព តាមរយៈនោះ ភាគីមានកម្មវត្ថុនៃកិច្ចសន្យា ជាការបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលអនុលោមតាមបទប្បញ្ញត្តិច្បាប់ស្តីពីការងារកម្ពុជា និងវត្ថុបំណងនៃការបង្កើតត្រូវតែស្របច្បាប់ស្របទៅនឹងរបៀបរៀបរយនិងទំនៀមទម្លាប់ដ៏ល្អប្រពៃ។ បន្ថែមពីនេះកិច្ចសន្យាហ្វឹកហ្វឺនកូនជាងតម្រូវឲ្យគូភាគីត្រូវធ្វើជាលិខិតលាយលក្ខណ៍អក្សរជាច់ខាត។[88]

## ១.២. ភាគីនៃកិច្ចសន្យាហ្វឹកហ្វឺនកូនជាង

ក្រៅពីនីតិជនដែលមានសមត្ថភាពចុះកិច្ចសន្យា និងអនីតិជនមានអត្តាធិនភាព តើបុគ្គលតម្រូវឲ្យបំពេញនូវលក្ខខណ្ឌអ្វីទៀត ដើម្បីទទួលបានសិទ្ធិកាតព្វកិច្ច និងលក្ខណៈសម្បត្តិជាភាគីនៃកិច្ចសន្យាហ្វឹកហ្វឺនកូនជាង?

---

[88]ប្រការ២ ប្រកាសលេខ០០៤សកបយស្តីពីការហ្វឹកហ្វឺនកូនជាង ចុះថ្ងៃទី០៥ខែមករា ឆ្នាំ២០០០។

ជាទូទៅអនុលោមតាមមាត្រានៃក្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា បុគ្គលដែលជាភាគីនៃកិច្ចសន្យាត្រូវតែជានីតិជនដែលមានសមត្ថភាព។ មានន័យថា នីតិជនដែលគ្មានបញ្ហាខាងស្មារតី មិនមានវិបាល្លាសខាងស្មារតី ឬជាអនីតិជនមានអត្តាធិនភាពជាអនីតិជនដែលទទួលបានសិទ្ធិតាមរយៈការស្នើសុំ។ ទាំងនេះជាសមត្ថភាពស្របច្បាប់ដែលភាគីទទួលបាននូវការការពារ។

ម្យ៉ាងទៀតចំពោះលក្ខខណ្ឌ និងប្រភេទផ្សេងនៃកិច្ចសន្យា បុគ្គលអាចតម្រូវឲ្យបំពេញនូវលក្ខខណ្ឌបន្ថែមដើម្បីទទួលបានសិទ្ធិជាភាគីនៃកិច្ចសន្យា។ អនុវត្តដូចគ្នាចំពោះកិច្ចសន្យាហ្វឹកហ្វឺនកូនជាង អនុលោមតាមមាត្រា៥១នៃច្បាប់ស្តីពីការងារ កម្ពុជាឆ្នាំ១៩៩៧ បានកំណត់ថាបុគ្គលជាភាគីនៃកិច្ចសន្យាហ្វឹកហ្វឺនកូនជាងត្រូវតែជានាយកគ្រឹះស្ថានឧស្សាហ៍កម្ម ពាណិជ្ជកម្ម សិប្បករ ឬជាងម្នាក់ដែលបានទទួល ឬប្រគល់ភារៈអប់រំវិជ្ជាជីវៈឲ្យបានពេញលេញ និងតាមរបៀបបច្ចេកទេសដល់បុគ្គលម្នាក់ទៀតដែលបានចុះកិច្ចសន្យាថានឹងជួយបំពេញការងារក្នុងឋានៈជាកូនជាង ស្របតាមលក្ខខណ្ឌ និងចិរវេលាដែលបានព្រមព្រៀងគ្នា។

ដូចនេះលក្ខខណ្ឌ ដែលទាមទារចំពោះភាគីនៃកិច្ចសន្យាហ្វឹកហ្វឺនកូនជាងគឺ ត្រូវតែជានីតិជនមានបុគ្គលភាពគតិយុត្តិ ជាបុគ្គលដែលទទួលបានសិទ្ធិ និងកាតព្វកិច្ចស្របច្បាប់ជានិយោជក ឬជាអ្នកតំណាងស្របច្បាប់របស់និយោជក ក្នុងការផ្ទេរបច្ចេកទេសជំនាញ ឬជាវិជ្ជាជីវៈស្របច្បាប់ឲ្យទៅភាគីម្ខាងទៀតជាកូនជាង ដោយបុគ្គលនោះយើងអាចសន្មត់ថាជាគ្រូដែលទទួលភារៈហ្វឹកហ្វឺនកូនជាង។បន្ថែមទៀតចំពោះការហ្វឹកហ្វឺនវិជ្ជាជីវៈ ដល់ក្មេងធ្វើការងារក្រោមដី ជាក្មេងដែលមានអាយុពី១៦ឆ្នាំដល់ក្រោម១៨ឆ្នាំ

អាចអនុវត្តបានក្នុងគោលបំណងហ្វឹកហ្វឺនវិជ្ជាជីវៈ និងជួយឲ្យក្មេងនោះមានទម្លាប់នឹងមុខរបរនាពេលអនាគតប៉ុណ្ណោះក្នុងលក្ខខណ្ឌមួយយ៉ាងតឹងរឹងបំផុត។[89]

## ១.៣ ភាតព្វកិច្ចរបស់គ្រូទទួលភារៈហ្វឹកហ្វឺនកូនជាង

គ្រូដែលមានភារកិច្ចហ្វឹកហ្វឺនកូនជាងអាចជានិយោជក ឬជាភាគីនៃកិច្ចសន្យា ឬជាអ្នកដែលទទួលភារកិច្ចបន្តពីនិយោជក ក្នុងការហ្វឹកហ្វឺនកូនជាងខាងផ្នែកបច្ចេកទេស វិជ្ជាជីវៈជំនាញដទៃផ្សេងទៀត ស្របតាមតម្រូវការរបស់គ្រឹះស្ថានឧស្សាហ៍កម្ម ពាណិជ្ជកម្ម សិប្បកម្ម។ ដូចនេះគ្រូត្រូវតែជាបុគ្គលម្នាក់ដែលមានចរិយាដូចជា ឪពុកដ៏ល្អក្នុងគ្រួសារចំពោះកូនជាង គឺជាអ្នកឃ្លាំមើលចរិយា កិរិយាមារយាទ ទោះក្នុងផ្ទះក្តី ក្រៅផ្ទះក្តី ហើយបើបានឃើញកូនជាងប្រព្រឹត្តនូវកំហុសធ្ងន់ណាមួយ ឬប្រព្រឹត្តលំអៀងគន្លងធម៌ ត្រូវតែប្រាប់ទៅឪពុកម្តាយ ឬតំណាងឪពុកម្តាយកូនជាងឲ្យបានដឹងដើម្បីធ្វើអន្តរាគមន៍កុំឲ្យយឺតយូរ។[90] គ្រូត្រូវមានភារកិច្ចប្រើកូនជាងមិនឲ្យហួសកំលាំង និងចំពោះតែការងារ ឬសេវាណាដែលទាក់ទងនឹងការប្រកបវិជ្ជាជីវៈរបស់ខ្លួនប៉ុណ្ណោះ។ ម្យ៉ាងទៀតគ្រូត្រូវបង្រៀនកូនជាងឲ្យបានរីកចំរើន និងសព្វគ្រប់នូវរបរស្របតាមខ្លឹមសារ និងកម្មវត្ថុកិច្ចសន្យា និងមានភារៈត្រូវសម្រួលដល់កូនជាង បើកូនជាងមានបំណងចូលរៀនសាលាអប់រំវិជ្ជាជីវៈ។

---

[89] ប្រការ១ ប្រកាសលេខ១៤៥សកបយ ស្តីពីការហ្វឹកហ្វឺនវិជ្ជាជីវៈដល់ក្មេងសំរាប់ធ្វើការក្រោមដី ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២។

[90] ម.៥៨ ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧។

## ១.៤.សិទ្ធិនិងភាតព្វកិច្ចរបស់កូនជាងចំពោះកិច្ចសន្យាហ្វឹកហ្វឺនកូនជាង

អនុលោមតាមប្រការ១នៃប្រកាសលេខ004សកបយ ស្តីពីការហ្វឹកហ្វឺនកូនជាងចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០០ កូនជាង គឺជាជនដែលបានចុះកិច្ចសន្យាសិក្សាវិជ្ជាជីវៈជាមួយនឹងនិយោជក ឬសិប្បករណាម្នាក់ដែលក្នុងនោះនិយោជក ត្រូវតែបង្រៀនវិជ្ជាជីវៈដល់កូនជាង ហើយកូនជាងត្រូវធ្វើការឲ្យនិយោជកស្របតាមខ្លឹមសារ និងលក្ខខណ្ឌនៃកិច្ចសន្យា។ កូនជាងជាភាគីនៃកិច្ចសន្យាហ្វឹកហ្វឺនកូនជាង ត្រូវមានកាតព្វកិច្ចអនុវត្តយកទៅតាមប្រការនៃកិច្ចសន្យា មានន័យថាកូនជាងត្រូវស្តាប់បង្គាប់និងគោរពគ្រូក្នុងក្របខណ្ឌនៃការហ្វឹកហ្វឺនកូនជាង ត្រូវជួយគ្រូបំពេញការងារតាមសមត្ថភាព និងកម្លាំងខ្លួន ហើយត្រូវរក្សាទុកនូវអាថកំបាំងផ្សេងៗ ក្នុងវិជ្ជាជីវៈ។[91] ដូចនេះមានន័យថា កូនជាង ត្រូវមានសិទ្ធិទទួលបានការហ្វឹកហ្វឺនមុខជំនាញការងារ សមស្របទៅតាមកិច្ចសន្យាហ្វឹកហ្វឺនកូនជាង និងមានសិទ្ធិបញ្ចេញមតិយោបល់ក្នុងនាមផលប្រយោជន៍រួម។ ក្រៅពីនេះកូនជាងមានកាតព្វកិច្ចត្រូវខិតខំយកចិត្តទុកដាក់ ក្នុងការហ្វឹកហ្វឺនកូនជាង ដោយអនុវត្តទៅតាមកាលវិភាគនៃការហ្វឹកហ្វឺន និងគោរពអនុវត្តវិធានការផ្នែកអនាម័យ និងសុវត្ថិភាពការបង្ការគ្រោះថ្នាក់ការងារនិងជម្ងឺវិជ្ជាជីវៈក្នុងសហគ្រាស។

## ១.៥. ការរំលាយកិច្ចសន្យាហ្វឹកហ្វឺនកូនជាង

កិច្ចសន្យាហ្វឹកហ្វឺនកូនជាងអាចរំលាយ ដោយមូលហេតុច្រើនយ៉ាងដូចជាការទទួលមរណៈភាពគ្រូ ឬកូនជាង ជាភាគីនៃកិច្ចសន្យាមាន

[91] ម.៦០ ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧។

ន័យថាកិច្ចសន្យាមិនអាចអនុវត្តបាន ដោយភាគីណាមួយបានស្លាប់បាត់បង់ជីវិត។ ម្យ៉ាងទៀតកិច្ចសន្យា នឹងមិនអាចប្រតិបត្តិបានដូចគ្នា ករណីភាគីនៃកិច្ចសន្យាជាប់កាតព្វកិច្ចកងទ័ព ឬភាគីមានទោសជាប់ពន្ធនាគារ ដោយប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈឹម ឬ អាចបណ្តាលមកពីមូលហេតុនៃការ បិទសកម្មភាពរោងជាង ឬសហគ្រាស។[92] អនុវត្តដូចគ្នាករណីមានធន្ទះព្រមព្រៀង ដោយភាគីនៃកិច្ចសន្យាហ្វឹកហ្វឺនកូនជាងថានឹងរំលាយតាមពាក្យសុំនៃភាគីទាំងសងខាងឬភាគីម្ខាង ឬអាចរំលាយកិច្ចសន្យាបានដោយសារភាគីនៃកិច្ចសន្យាមិនគោរពតាមខ្លឹមសារនៃកិច្ចសន្យា ករណីមានបទល្មើស ករណីមានកំហុស ករណីមិនគោរពបទបញ្ជាផ្ទៃក្នុង និងក្នុងករណីដែលគ្រូហ្វឹកហ្វឺនត្រូវផ្លាស់ប្តូរផ្ទះទៅនៅក្នុងសង្កាត់ឬឃុំណាមួយ ក្រៅពីសង្កាត់ឬឃុំដែលខ្លួនស្ថិតនៅពេលចុះកិច្ចសន្យា ដោយលក្ខខណ្ឌតែរយៈពេលបីខែចាប់តាំងពីថ្ងៃដែលគ្រូបានផ្លាស់ទីលំនៅ។[93]

ការរំលាយកិច្ចសន្យាហ្វឹកហ្វឺនកូនជាង ភាគីអាចទាមទារឲ្យមានការទទួលខុសត្រូវលើសំណងនៃការខូចខាត ករណីការខូចខាតកើតមានដែល បណ្តាលមកពីការមិនអនុវត្តកិច្ចសន្យា និងមានការខូចខាតផលប្រយោជន៍ តែភាគីម្ខាងទៀតនៃកិច្ចសន្យា ត្រូវបង្ហាញភស្តុតាងពីកំហុសនៃការខូចខាត ដើម្បីទាមទារសំណងខូចខាតដែលកើតមាន។

---

[92] ម.៦៣ ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧។

[93] ម.៦៤ ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧។

## ២. កាតព្វកិច្ចនិយោជកចំពោះកិច្ចសន្យាហ្វឹកហ្វឺនកូនជាង

និយោជក ជានាយកគ្រឹះស្ថាននឹងជាភាគីនៃកិច្ចសន្យាហ្វឹកហ្វឺនកូនជាង មានកាតព្វកិច្ចដោយអនុលោមទៅតាមប្រកាសលេខ០០៤ ស្តីពីការហ្វឹកហ្វឺនកូនជាង ចុះថ្ងៃទី០៥ខែមករាឆ្នាំ២០០០ ដោយត្រូវហ្វឹកហ្វឺនកូនជាងឲ្យពេញលេញស្របតាមទៅតាមលក្ខណៈបច្ចេកទេសនៃមុខរបរ និងប្រភេទការងាររបស់សហគ្រាស គ្រឹះស្ថាន រោងចក្រទាំងនោះ។

## ២.១. កាតព្វកិច្ចនិយោជកចំពោះក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

សហគ្រាស គ្រឹះស្ថាន រោងចក្រទាំងឡាយ ដែលមានជួលនិង ប្រើប្រាស់កម្មករនិយោជិតច្រើនជាង៦០នាក់ ត្រូវមានកូនជាងតាមការកំណត់ដូចខាងក្រោម៖[94]

1. ១០%ចំពោះសហគ្រាសដែលមានកម្មករនិយោជិតចាប់ពី៦១នាក់ដល់ ២០០នាក់
2. ៨%ចំពោះសហគ្រាសដែលមានកម្មករនិយោជិតចាប់ពី២០១នាក់ដល់៥០០នាក់
3. បន្ថែម៤%រាល់ពេលដែលមានចំនួនកម្មករនិយោជិតចាប់ពី៥០០នាក់បន្ថែមទៀតចំពោះសហគ្រាសដែលមានកម្មករនិយោជិតចាប់ពី៥០១នាក់ឡើង

[94] ប្រការ៣ ប្រកាសលេខ០០៤ សកបយ ស្តីពីការហ្វឹកហ្វឺនកូនជាងចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០០ និងម.៥៧នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧។

4. ចំនួនអតិបរមានៃកូនជាង ត្រូវធ្វើការហ្វឹកហ្វឺនកំណត់ត្រឹម១១០ នាក់ ក្នុង១ឆ្នាំទោះជាសហគ្រាស គ្រឹះស្ថាន រោងចក្រនោះមានកម្ម ករនិយោជិត ចំនួនច្រើនយ៉ាងណាក៏ដោយ។

លើសពីនេះទៀតចំពោះសហគ្រាស គ្រឹះស្ថាន រោងចក្រ ដែលបើកថ្មី មានកាតព្វកិច្ច ត្រូវអនុវត្តការហ្វឹកហ្វឺនយ៉ាងយូរបំផុត៣ខែក្រោយថ្ងៃដែល សហគ្រាស គ្រឹះស្ថានរោងចក្រ ចាប់ផ្តើម ដំណើរការជាផ្លូវការ។

## ២.២. ការត្រួតពិនិត្យការហ្វឹកហ្វឺនកូនជាង

ដើម្បីធានាគុណភាពការហ្វឹកហ្វឺនកូនជាង សហគ្រាស គ្រឹះស្ថាន រោងចក្រ ទាំងអស់ត្រូវរៀបចំការចាត់តាំងការត្រួតពិនិត្យ ការហ្វឹកហ្វឺនជា រៀងរាល់ខែ ត្រីមាសឆមាស និងការប្រលងបញ្ចប់វគ្គដោយមានរបាយ ការណ៍ជាអក្សរច្បាស់លាស់ពីការរីកចំរើន ប្រែប្រួលរបស់កូនជាងទាំងផ្នែក ទ្រឹស្តី និងការប្រតិបត្តិផ្ទាល់។[95]ក្នុងករណីសហគ្រាស គ្រឹះស្ថាន រោងចក្រ ណាដែលគ្មានលទ្ធភាព និងរៀបចំការហ្វឹកហ្វឺនកូនជាងបាននោះ ត្រូវធ្វើ សំណើមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីធ្វើការសុំបង់ពន្ធ អាករជំនួសវិញ។

ពន្ធអាករ សហគ្រាសត្រូវបង់តាមអត្រាកំណត់ចំនួន១%លើប្រាក់ ឈ្នួលប្រចាំឆ្នាំនៃចំនួនសរុបរបស់កម្មករ និយោជិតទាំងអស់របស់សហ គ្រាសជារៀងរាល់ឆ្នាំ។ ការបង់ពន្ធហ្វឹកហ្វឺនកូនជាងត្រូវធ្វើឲ្យបានមុនថ្ងៃ បំណាច់ត្រីមាស នីមួយៗជារៀងរាល់ឆ្នាំ ឬអាចបង់មុនជាសរុបប្រចាំឆ្នាំតែ

[95] ប្រការ៦ ប្រកាសលេខ០០៤ សកបយ ស្តីពីការហ្វឹកហ្វឺនកូនជាងចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០០។

ម្តងក៏បានទៅបេឡាបណ្តុះបណ្តាលវិជ្ជាជីវៈនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងត្រូវជូនដំណឹងទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័នពាក់ព័ន្ធ។[96] ករណីមិនបង់ពន្ធអាករហ្វឹកហ្វឺនកូនជាងនេះនឹងត្រូវទទួលការផាកពិន័យដូចមានចែងក្នុងជំពូកទី១៦ច្បាប់ស្តីពីការងារ។

[96] ប្រការ៨ ប្រកាសលេខ០០៤ សកបយ ស្តីពីការហ្វឹកហ្វឺនកូនជាងចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០០។

## មេរៀនទី៤

# អំពីភតិសន្យា

ក្រៅពីកិច្ចសន្យាលក់ទិញ ដែលកើតឡើងជារាងរាល់ថ្ងៃមិនថា ទាំងកិច្ចរដ្ឋប្បវេណី និង ពាណិជ្ជកិច្ចនោះទេ ភតិសន្យា ក៏ជាកិច្ចសន្យា មួយដែលកើតមានឡើងជាប្រចាំ ដោយកម្មសិទ្ធិករនៃវត្ថុទាញយក ផលស៊ីវិលពីវត្ថុនោះតាមរយៈភតិសន្យា ឬក៏កិច្ចសន្យាជួល។ ដោយសារ តែប្រភេទវត្ថុមានច្រើន រួមទាំងការទាញប្រយោជន៍ពីវត្ថុទៅតាមផ្នែក នីមួយៗ ដូចជាផ្នែកស៊ីវិល ផ្នែកពាណិជ្ជកម្ម ឬផ្នែកកសិកម្ម ដែលជាកត្តា នាំឲ្យភតិសន្យាមានច្រើនទម្រង់ ជាពិសេសគឺមានវិធានពិសេសៗ ដើម្បី ឆ្លើយតបនឹងភាពចាំបាច់ ក្នុងសង្គមនីមួយៗជាពិសេស នៅកម្ពុជាក៏មាន ប្រភេទភតិសន្យាមួយចំនួន ដូចជាករណីភតិកៈជាកម្មករ ឬនិស្សិតដែល ត្រូវបានស្ថិតនៅក្រោមបទប្បញ្ញត្តិពិសេសបន្ថែមពីលើក្រមរដ្ឋប្បវេណី។

ក្រៅពីផ្នែកដែលមានទំនាក់ទំនងជាមួយនឹងភតិសន្យា កម្មវត្ថុនៃ ភតិសន្យាក៏ធ្វើឲ្យឃើញមានភាពចម្រុះផងដែរ ដូចជាចលនវត្ថុរូបីយ ចលនវត្ថុអរូបីយ ឬក៏អចលនវត្ថុជាដើម ដែលវិធានគ្រប់គ្រងទំនាក់ទំនង កិច្ចសន្យា មានភាពប្រែប្រួលទៅតាមប្រភេទវត្ថុនៃកិច្ចសន្យា។

យោងតាមរយៈមាត្រា៥៩៦ក្រមរដ្ឋប្បវេណី ភតិសន្យា គឺជាកិច្ចសន្យាដែលភាគីម្ខាង ដែលហៅថា ភតិបតី ធ្វើការប្រគល់វត្ថុ ផ្ទេរសិទ្ធិ ប្រើប្រាស់ និង សិទ្ធិអាស្រ័យផល ទៅភាគីម្ខាងទៀតដែលហៅថាភតិកៈ ដោយភតិកៈមានករណីយកិច្ចធ្វើការបង់ប្រាក់ឈ្នួលតបស្នងមកវិញ។

បើប្រៀបធៀបជាមួយនឹងកិច្ចសន្យា លក់ទិញ គឺគេឃើញភាពខុសប្លែក រវាងកិច្ចសន្យាទាំងពីរនៅត្រង់ការផ្ទេរសិទ្ធិ ដែលកិច្ចសន្យាលក់ទិញ គឺមាន ការផ្ទេរសិទ្ធិកម្មសិទ្ធិ និង សិទ្ធិផ្សេងដទៃទៀតជុំវិញវត្ថុ ចំណែក ភតិសន្យាវិញ គឺគ្រាន់តែមានការផ្ទេសិទ្ធិផលុភោគតែប៉ុណ្ណោះ ដែលជា មូលហេតុនាំឲ្យនៅពេលបញ្ចប់ភតិសន្យា ភតិកៈត្រូវធ្វើបដិទានត្រឡប់វិញ នូវវត្ថុ និងសិទ្ធិផលុភោគលើវត្ថុទៅឲ្យ ភតិបតីវិញ។ អាចនិយាយបានថា កម្មសិទ្ធិករនៃវត្ថុបានធ្វើការប្រគល់វត្ថុឲ្យបុគ្គលម្នាក់កាន់កាប់ ដោយផ្តល់ នូវសិទ្ធិ និងករណីយកិច្ចមួយចំនួនទៅលើវត្ថុនោះ និងកម្មសិទ្ធិករនៃវត្ថុ មានសិទ្ធិទាមទារឲ្យធ្វើការប្រគល់វត្ថុនោះត្រលប់ មកវិញ។

ភតិសន្យាខុសពីកិច្ចសន្យាដែលកម្មវត្ថុជាសេវាកម្ម ដោយសារតែ ភតិសន្យាគឺផ្តោតសំខាន់ទៅលើវត្ថុ និងមិនផ្តោតទៅការងារដែលធ្វើដោយ ហត្ថកម្មរបស់បុគ្គល។ ភតិសន្យាក៏ខុសពីប្រភេទកិច្ចសន្យាដែលមាន ការផ្ទេរសិទ្ធិកម្មសិទ្ធិផងដែរ ដោយសារតែភតិសន្យាត្រូវធ្វើប្រគល់វត្ថុនៅ ស្ថានភាពដើមដូចថ្ងៃដែលប្រគល់ឲ្យកាន់កាប់។

ភតិសន្យាកើតចេញពីធាតុផ្សំពីរដ៏សំខាន់គឺៈផលុភោគលើវត្ថុ ជាថ្នូលនឹងតម្លៃឈ្នួល

ភតិបតិត្រូវធ្វើផ្ទេរផលុបភោគទៅឲ្យភតិកៈ ដោយភតិកៈជាអ្នក កាន់កាប់វត្ថុជួលនោះ និងអាចប្រើប្រាស់វត្ថុនោះដើម្បីជាប្រយោជនរបស់ ខ្លួន។ ការផ្ទេរសិទ្ធិផលុភោគនេះ គឺប្រើបានគ្រប់ប្រភេទនៃវត្ថុមិនថា អចលនវត្ថុ ចលនវត្ថុរូបីយ ឬ ចលនវត្ថុអរូបីយ ដូចជាមូលនិធិពាណិជ្ជកម្ម (មាត្រា៥៩៦ក្រមរដ្ឋប្បវេណី)។ ប៉ុន្តែភតិសន្យាមិនអាចធ្វើទៅលើ វត្ថុដែល ស្ថិតក្រៅពាណិជ្ជកម្មដូច

ជាៈ សិទ្ធិក្រៅបេតិកភណ្ឌ ឬ ខយគមទ្រព្យ ដោយសារតែភតិសន្យាត្រូវធ្វើបដិទានត្រលប់មកវិញ គឺការប្រគល់វត្ថុ នៅពេលបញ្ចប់ភតិសន្យា បើមិនដូច្នោះទេកិច្ចសន្យានោះមិនមែនជា ភតិសន្យានោះ ទេ វាអាចជាកិច្ចសន្យាខ្ចីបរិភោគ ឬក៏កិច្ចសន្យាលក់ទិញ។

ផលុភោគ គឺជាការយល់ព្រមឲ្យប្រើប្រាស់ក្នុងរយៈពេលណាមួយ ជាថ្នូលនឹងការបង់នូវតម្លៃណាមួយ ដែលអាចជា សាច់ប្រាក់ ឬ ការប្រគល់ វត្ថុផ្សេង។ តម្លៃអាចជាការផ្ទេរនូវវត្ថុអ្វីមួយ ឬ ការផ្តល់ជាសេវា (មើលថៃទាំ កូន)។ ភតិសន្យាត្រូវតែកិច្ចសន្យាមូលា មិនអាចជាកិច្ចសន្យាមុធាបាន នោះទេ ប្រសិនជាកិច្ចសន្យាមុធា មានន័យថាជាកិច្ចសន្យាខ្ចីប្រើប្រាស់។ បទបញ្ញាត្តិដែលទាក់ទងនឹងផលុបភោគនៃទ្រព្យ អាចធ្វើការបែងចែក ភតិសន្យាជាមួយកិច្ចសន្យាដែលស្រដៀងគ្នា ដូចជាៈ

ភតិសន្យាជួលបន្ទប់ក្នុងអគាសហាកម្មសិទ្ធិ(ខន់ដូ) ដែលមាន បំពាក់សម្ភារៈ និងកិច្ចសន្យាស្នាក់នៅក្នុងសណ្ឋាគារ ដែលកិច្ចសន្យាបន្ទប់ ក្នុងខន់ដូគឺតម្រូវឲ្យមានប្រាក់កក់ជាថ្នូរនឹងការប្រគល់សោរ និងជាពិសេស គឺមានការចែងពីការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិក្នុងបន្ទប់ជួល និង ការថៃទាំរួមទាំងការសម្អាតដែលជាបន្ទុករបស់ភតិកៈ។

គ្រប់ភតិសន្យា ទោះបីកម្មវត្ថុនៃកិច្ចសន្យាជាអ្វីក៏ដោយ ភតិសន្យាមូលនិធិពាណិជ្ជកម្ម ភតិសន្យាជីកសិកម្ម ភតិសន្យាស្នាក់នៅ កិច្ចសន្យា ទាំងអស់នេះគឺបំពេញនូវធាតុផ្សំគតិយុត្តិដូចគ្នា ប៉ុន្តែវានឹងវិធានពិសេសៗ មួយចំនួនទៅតាមប្រភេទភតិសន្យានីមួយៗ។

## ផ្នែកទី១៖ លក្ខណៈបង្កើតភតិសន្យា

ភតិសន្យា គឺជាកិច្ចសន្យាដែលកើតឡើងពីការព្រមព្រៀង អាចជា កិច្ចសន្យាមូលា កិច្ចសន្យាអនុវត្តបន្តបន្ទាប់ និងកិច្ចសន្យាអញ្ញមញ្ញ។

### កថាខណ្ឌ១៖ ភតិសន្យាគឺជាកិច្ចសន្យាកើតឡើងពី ការព្រមព្រៀង

នៅក្នុងកថាខណ្ឌនេះភតិសន្យាគឺកិច្ចសន្យាដែលកើតឡើងពីការព្រមព្រៀង មកពីចំណុចទីមួយទាក់ទងនឹង លក្ខខណ្ឌក្នុងការបង្កើត និង ភស្តុតាងនៃកិច្ចសន្យា(១) ចំណុចទីពីទាក់ទងនឹងការបុះកិច្ចសន្យា (២)។

#### ១. ការបង្កើត និង ភស្តុតាងនៃភតិសន្យា

***ភតិសន្យាសរសេរ ឬផ្ទាល់មាត់៖*** ភតិសន្យាបង្កើតឡើងតាម រយៈជំនួបឆន្ទៈគូភាគីទាំងពីរមុនពេល កាន់កាប់វត្ថុ និងគ្មានការទាមទារ ទម្រង់ណាមួយបានន័យថាជំនួបឆន្ទៈគូភាគីនេះ គឺធ្វើឡើងតាមរយៈ ការចរចារវាងភតិកៈ និងភតិបតី។ ដូច្នេះភតិសន្យាត្រូវគោរពនូវវិធានរួម នៃកិច្ចសន្យាដែលមានដូចជា៖ ឆន្ទៈគូភាគី សមត្ថភាព និង កម្មវត្ថុ។ គេអាច ធ្វើការលុបចោល ដោយផ្អែកលើវិការៈនៃការព្រមព្រៀង ដូចជា ការភ័ន្តច្រឡំ ការឆបោក ការគម្រាមកំហែង ឬការផ្តល់ព័ត៌មានមិនពិតរបស់ភាគី ម្ខាងទៀត ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការឆ្លៀតឱកាស ដែលមានគោលបំណងកេងយកចំណេញហួសហេតុ (មាត្រា៣៤៥ ក្រមរដ្ឋប្បវេណី) ឧទាហរណ៍ភតិសន្យាត្រូវបាន លុបចោល

ដោយសារតែ ការឆបោករបស់ភតិក: ដែលភតិបតីមិនបានដឹងពីព័ត៌មានទាក់ទងនឹង ភតិក: ដែលបានយកវត្ថុខុសច្បាប់ចូលមកទីតាំងជួល។

តាមរយៈមាត្រា៥៩៩ក្រមរដ្ឋប្បវេណី ភតិសន្យាអាចធ្វើឡើង ដោយផ្ទាល់មាត់ ឬក៏លាយលក្ខណ៍អក្សរ ប៉ុន្តែត្រូវតែ ឆន្ទៈរបស់កម្មសិទ្ធិករ ត្រូវតែច្បាស់លាស់ និង ត្រូវធ្វើការប្រគល់ការកាន់កាប់ទៅឲ្យភតិក: ដោយប្តូរមកវិញគឺការបង់ថ្លៃឈ្នួល។

ភស្តុតាងនៃភតិសន្យា៖ ជាទូទៅដើម្បីជាសរៀងពីបញ្ហាដែល កើតឡើងប្រការណាមួយ កិច្ចសន្យាត្រូវ តាក់តែងជា លាយលក្ខណ៍អក្សរ។ ដូចដែលមានចែងក្នុងមាត្រា៣៣៦ក្រមរដ្ឋប្បវេណី កិច្ចសន្យាមាន អានុភាពគ្រប់គ្រាន់ គឺនៅពេលដែលសំណើ និង ស្ទីការត្រូវគ្នា លុះត្រាកិច្ចសន្យានោះពាក់ព័ន្ធនឹងការធ្វើអនុប្បទានអចលនវត្ថុ ទើមតម្រូវឲ្យមានធ្វើជាលិខិត យថាភូត។ ភស្តុតាងតាមរយៈការសរសេរជាលាយលក្ខណ៍អក្សរសម្រាប់ ភតិសន្យា គឺមានអត្ថប្រយោជន៍សម្រាប់គូភាគីក្នុងការតតាំង ដូចជាករណី ភតិសន្យាមានកំណត់អំឡុងពេល ដោយក្រមរដ្ឋប្បវេណី តម្រូវឲ្យធ្វើជា លាយក្ខណ៍អក្សរ[97] ភតិក: ឬ ភតិបតីមិនអាចធ្វើការរំលាយកិច្ចសន្យា ដោយឯកតោភាគី នៅពេលដែលរយៈពេលកំណត់ក្នុងកិច្ចសន្យាមិនទាន់ មកដល់។

អត្ថប្រយោជន៍ជាច្រើនផ្សេងទៀតអាចបង្ហាញ តាមរយៈលិខិតជាលាយលក្ខណ៍អក្សរដូចជា តម្លៃឈ្នួល រយៈពេលចរចាក្នុងការកែប្រែ ខ្លឹមសារនៃកិច្ចសន្យារួមទាំង ខសន្យាមួយចំនួនផ្សេងទៀតដែលមាន ចែងក្នុងកិច្ចសន្យា។

---

[97] ម. ៥៩៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ក្នុងករណីយកិច្ចសន្យាធ្វើឡើងដោយផ្ទាល់មាត់ ការតតាំងអាច ធ្វើតាមមធ្យោបាយផ្សេងទៀតទាក់ទងនឹងថ្លៃឈ្នួល និង រយៈពេលនៃ កិច្ចសន្យា។ សម្រាប់តម្លៃឈ្នួល ភាគីអាចបង្ហាញតាមរយៈ ការផ្ទេរបង់ប្រាក់ តាមរយៈគណនីយ្យធនាគារផ្សេងៗ ចំណែករយៈពេលភតិសន្យា ក្នុងករណី ភតិសន្យាធ្វើដោយផ្ទាល់មាត់ ត្រូវចាត់ទុកថាជាប្រភេទ ភតិសន្យាដែល ពុំមានកំណត់អំឡុងពេល[98] ដូច្នេះភាគីណាមួយ ក្នុងចំណោមភាគី អាចធ្វើការរំលាយកិច្ចសន្យាបានគ្រប់ពេលវេលា គ្រាន់តែភាគីគោរពនូវ រយៈពេលនៃការជូនដំណឹងដល់ភាគីម្ខាងទៀតដែលច្បាប់បានកំណត់។[99]

## ២. ការចុះភតិសន្យា

### ២.១. សមត្ថភាពគូភាគី

ជាគោលការណ៍ ការចុះភតិសន្យាពុំមានទាមទារនូវលក្ខខណ្ឌ ពិសេសទាក់ទងនឹងសមត្ថភាពនោះទេ ដោយសារតែ ភតិសន្យាជាកិច្ច គ្រប់គ្រង ដូច្នេះ អ្នកអាណាព្យាបាលសម្រាប់អនីតិជនមានសិទ្ធិតំណាង ឲ្យ អនីតិជនចុះភតិសន្យាបាន។ ក្នុងករណីអសមត្ថជនដែលស្ថិតក្រោម របបហិតូបត្ថម្ភវិញ គឺគាត់អាចចុះភតិសន្យាក្នុងនាមជាភតិបតី ឬក៏ជា ភតិកៈបានដោយពុំចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈ ប្រសិនបើ រយៈពេលនៃភតិសន្យានោះ ក្រោមរយៈពេលដែលមាត្រា៣៣ក្រមរដ្ឋប្ប- វេណីបានកំណត់ដូចជា ៣ឆ្នាំចុះក្រោម សម្រាប់ដីធ្លី២ឆ្នាំចុះក្រោមសម្រាប់ អគារ និង ៦ខែចុះក្រោមសម្រាប់ចលនវត្ថុ។

---

[98] ម. ៥៩៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[99] ម. ៦១៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

## ២.២. ករណីទ្រព្យរួម

ចំពោះករណីដែលសហព័ទ្ធម្ខាង យកទ្រព្យរួមមកដាក់ជាកម្មវត្ថុនៃ ភតិសន្យាអាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពីសហព័ទ្ធ ម្ខាងទៀត ប្រសិនបើជាសហព័ទ្ធម្ខាងទៀតមិនយល់ព្រមយកទ្រព្យរួម ដាក់ជួលនោះទេ សហព័ទ្ធដែលមានចេតនាចង់យកវត្ថុរួមដាក់ជួលអាច ស្នើសុំទៅតុលាការ ដើម្បីឲ្យធ្វើការចាត់ចែងចំពោះ ការគ្រប់គ្រង និង ប្រើប្រាស់ទ្រព្យសម្បត្តិរួមនេះ។[100]

## ២.៣. ករណីវត្ថុអ្នកដទៃ

ភតិបតីមិនអាចយកវត្ថុអ្នកដទៃ មកធ្វើជាកម្មវត្ថុនៃភតិសន្យាបាននោះទេដែលខុសពីកិច្ចសន្យាលក់ទិញ ដែលអ្នកលក់អាចធ្វើការលក់វត្ថុ អ្នកដទៃបានឲ្យតែ កម្មសិទ្ធិករយល់ព្រមធ្វើការផ្ទេរសិទ្ធិកម្មសិទ្ធិទៅឲ្យ អ្នកទិញ។ ចំណែកនៅក្នុងបទប្បញ្ញត្តិទាក់ទងនឹងភតិសន្យាវិញ គេឃើញ មានចែងពីករណី ភតិសន្យាបន្ត ដែលភតិកៈ អាចយកវត្ថុជួល មកជួលបន្ត បានលុះត្រាតែមានការយល់ព្រមពីភតិបតិជាមុនសិន។[101]

## កថាខណ្ឌ២៖ ភតិសន្យាគឺជាកិច្ចសន្យាមូលា

**ភាពចាំបាច់ថ្លៃឈ្នួល៖** ភតិសន្យាគឺជាកិច្ចសន្យាមូលាដែល ផលុបភោគីនៃវត្ថុនោះ ត្រូវយល់ព្រមនៅលើតម្លៃមួយ ដែលឲ្យឈ្មោះថា៖ «ថ្លៃឈ្នួល»។

---

[100] ម. ៩៧៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[101] ម. ៦០៨ និង ៦០៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

តាមរយៈមាត្រា៥៩៧ក្រមរដ្ឋប្បវេណី ភតិសន្យាត្រូវមានអានុភាព ដោយភតិបតីប្រគល់វត្ថុឲ្យភតិកៈប្រើប្រាស់ និង អាស្រ័យផល លើវត្ថុណាមួយដោយភតិកៈសន្យាថាបង់ថ្លៃឈ្នួលចំពោះវត្ថុនោះ។

ក្នុងករណីពុំបង់ថ្លៃឈ្នួល កិច្ចសន្យាដែលធ្វើឡើងពុំមែនជា ភតិសន្យានោះទេ វាអាចជាកិច្ចសន្យាខ្ចីប្រើប្រាស់ ឬ ប្រទានកម្ម។ ដូច្នេះ តម្លៃត្រូវតែជាក់លាក់ បើមិនដូច្នោះទេ ភតិសន្យាពុំមានសុពលភាពនោះទេ ប៉ុន្តែតម្លៃអាចគ្រាន់តែអាចកំណត់បាននៅក្នុងកិច្ចសន្យា។

**មធ្យោបាយកំណត់ថ្លៃឈ្នួល៖** ការកំណត់ថ្លៃឈ្នួលជាគោលការណ៍ត្រូវតែធ្វើឡើងដោយសេរី ដោយពុំមានវិការៈនៃការព្រមព្រៀង។ ភាគីអាចព្រមព្រៀងគ្នាធ្វើការបង់ជាវត្ថុ ឬក៏ជាសាច់ប្រាក់។ ជាទូទៅ ថ្លៃឈ្នួល អាចធ្វើការបង់តាមការព្រមព្រៀងរវាងគូភាគីដូចជា ការបង់ ជាម៉ោង ជាប្រចាំថ្ងៃ ជាសប្តាហ៍ ជាខែ ជាឆ្នាំ ឬនៅពេលចុងរដូវកាល ប្រមូលផងជាដើម។

## កថាខណ្ឌ៣៖ ភតិសន្យាជាកិច្ចសន្យាអនុវត្តបន្តបន្ទាប់

**កិច្ចសន្យាអនុវត្តបន្តបន្ទាប់៖** លក្ខណៈបន្តបន្ទាប់ គឺមានន័យ ការអនុវត្តភតិសន្យាផ្តោតទៅលើរយៈពេលមួយ ដែលកំណត់គូភាគី ឬពុំបានកំណត់។ កាតព្វកិច្ចគូភាគីទាំងសងខាង ត្រូវបានអនុវត្តនៅក្នុងរយៈពេលជួលដូចជា៖ ផ្ទេរសិទ្ធិប្រើប្រាស់ និងអាស្រ័យផលនៃវត្ថុជួល ឲ្យទៅភតិកៈ និង ការបង់ថ្លៃឈ្នួលសម្រាប់ ភតិកៈ។

**ការកំណត់អំឡុងពេលភតិសន្យា៖** ភតិសន្យាអាចមានកំណត់ អំឡុងពេល ឬ ពុំមានកំណត់អំឡុងពេល។

នៅក្នុងក្រមរដ្ឋប្បវេណី៖ រយៈពេលនៃភតិសន្យា គឺត្រូវបានកំណត់ដោយសេរីតាមការព្រមព្រៀងរវាងគូភាគីជាពិសេសភតិសន្យា ត្រូវបានបន្តដោយតណ្ហីភាពនៅពេលដែលអំឡុងពេលកំណត់បានមកដល់ ហើយភាគី នៅតែបន្តអនុវត្តកាតព្វកិច្ចរៀងៗខ្លួន។[102] ប្រសិនជាភាគីចង់ធ្វើការកំណត់ អំឡុងពេលនៃភតិសន្យា លក្ខខណ្ឌដែលត្រូវបំពេញក្រៅពីលក្ខខណ្ឌគ្រឹះ គឺភាគីត្រូវធ្វើតាក់តែងជាលាយលក្ខណ៍អក្សរ បើមិនដូច្នោះទេច្បាប់ សន្មតថាជាប្រភេទភតិសន្យាដែលមិនកំណត់អំឡុងពេល។[103]

ចំណែកច្បាប់ស្តីពីភតិសន្យាពិសេសឆ្នាំ២០១៥ កំណត់ ជាពិសេសទៅលើរយៈពេលនៃការជួលរបស់និស្សិត និង កម្មករ ដែលមាន រយៈពេលអត្តិភាពតាមច្បាប់អប្បបរមាចំនួន២ឆ្នាំ ក្នុងគោលដៅការពារ ប្រយោជន៍ដល់ភតិកៈ ដែលមានស្ថានភាពសេដ្ឋកិច្ចទន់ខ្សោយ។

ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍វិញតាមរយៈក្រមរដ្ឋប្បវេណី គឺមានរយៈពេលអប្បបរមា១៥ឆ្នាំ និង អតិបរិមា៥០ឆ្នាំ ហើយអាចបន្តបានទៀត ដែលមិនឲ្យលើសពី៥០ឆ្នាំ។[104]

## កថាខណ្ឌ៤៖ ភតិសន្យាគឺជាកិច្ចសន្យាអញ្ញមញ្ញ

ភតិសន្យាគឺជាកិច្ចសន្យាអញ្ញមញ្ញដោយហេតុថា ភតិបតីត្រូវ ធ្វើការប្រគល់វត្ថុឲ្យភតិកៈកាន់កាប់ដើម្បី ប្រើប្រាស់ និងអាស្រ័យផល នៅលើវត្ថុដែល

---

[102] ម. ៦១៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[103] ម. ៥៩៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[104] ម. ២៤៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ជួល (ដែលត្រូវមានកាតព្វកិច្ចធ្វើបដិទានប្រគល់វត្ថុត្រឡប់ទៅវិញ) និង ថែរក្សាវត្ថុឲ្យបានល្អ (តាមស្ថានភាពវត្ថុដែលបានទទួល កាន់កាប់)។ ភតិបតីត្រូវធានាពីការរំខានតតិយជន និង ធានាវិការៈ អាថ៌កំបាំងនៃវត្ថុ ដើម្បីឲ្យភតិកៈ អាចប្រើប្រាស់សិទ្ធិរបស់ខ្លួនបានពេញ បរិបូរណ៍។ ចំណែកភតិកៈ ត្រូវបង់ថ្លៃឈ្នួលវត្ថុដែលកំពុងកាន់កាប់។ ក្នុង ករណីមិនអនុវត្តកាតព្វកិច្ចម្ចាស់បំណុល (ភតិកៈ ឬ ភតិបតី) អាចលើក ពីការតវ៉ាឲ្យអនុវត្តព្រមគ្នា និងស្នើសុំរំលាយកិច្ចសន្យាអញ្ញមញ្ញនោះ។

## ១. ករណីយកិច្ចរបស់ភតិបតី

ករណីយកិច្ចសំខាន់របស់ភតិបតីគឺធានាពីការប្រើប្រាស់ និង អាស្រ័យផលដោយសន្តិវិធីនៃវត្ថុជួលជូនចំពោះភតិកៈ។ ករណីយកិច្ច មួយនេះគឺមានរហូតក្នុងអំឡុងពេលជួលវត្ថុ។ ករណីយកិច្ចនេះ គឺរួមបញ្ចូល ទាំងករណីយកិច្ចប្រគល់វត្ថុ ធានាលើវត្ថុ និងថែរក្សាជួសជុលវត្ថុផងដែរ។ ករណីយកិច្ចនេះអាចត្រូវបានបកស្រាយមួយទៀតគឺការប្រគល់វត្ថុ ដែល ស្ថិតក្នុងស្ថានភាពល្អដែលពុំមានវិការៈអាថ៌កំបាំង។

### ១.១. ករណីយកិច្ចប្រគល់វត្ថុ

**ការប្រគល់វត្ថុជួល៖** មាត្រា៦០០ក្រមរដ្ឋប្បវេណីចែងថា៖ ភតិកៈ មានសិទ្ធិ និង ករណីយកិច្ចលើការប្រើប្រាស់ និង អាស្រ័យផលលើវត្ថុជួល ដោយផ្អែកទៅតាមវិធីប្រើប្រាស់ ដែលត្រូវបានកំណត់នៅក្នុងកិច្ចសន្យា ឬ តាមលក្ខណៈនៃវត្ថុជួលនោះ។ តាមរយៈមាត្រានេះមានន័យថាភតិបតី ត្រូវធ្វើការប្រគល់

វត្ថុ ដែលជាប្រភេទ ករណីយកិច្ចដំបូងគេ ក្នុងការចាប់ផ្តើម អនុវត្តកាតព្វកិច្ចទៅតាមខ្លឹមសារនៃកិច្ចសន្យា។

ចំណែកនៅក្នុងកថាខណ្ឌ៣ មាត្រាដដែលបានចែងថា៖ ភតិបតី មិនត្រូវធ្វើឲ្យរាំងស្ទះក្នុងការប្រើប្រាស់ និង អាស្រ័យផលដែលភតិកៈ ធ្វើដោយផ្អែកតាមវិធីប្រើប្រាស់ឡើយ។ នៅក្នុងចំណុចនេះអាចបញ្ជាក់ បានថា ភតិបតីត្រូវធានាការប្រើប្រាស់វត្ថុដោយសន្តិវិធី ជាពិសេសខសន្យា ទាំងឡាយណាដែលចែងផ្ទុយពីនេះ អាចត្រូវបានចាត់ទុក ថាមោឃៈ។

ក្នុងករណីយកិច្ចប្រគល់វត្ថុនេះ អាចនាំឲ្យភតិបតីទទួលខុសត្រូវចំពោះភតិកៈតាមរយៈការជួលជុលសំណាងជំងឺចិត្ត ដោយសារតែការ ប្រគល់វត្ថុមានការយឺតយ៉ាវ ជាហេតុធ្វើឲ្យភតិកៈទទួលរងព្យសនកម្ម ពីការយឺតយ៉ាវនេះ ដូចជាភតិកៈមិនទាន់បានចាកចេញពីទីតាំងជួលនេះ ជាដើម។

ក្នុងករណីមួយទៀត ដែលនាំឲ្យភតិបតីមានការទទួលខុសត្រូវ ចំពោះភតិកៈ នៅពេលដែលភតិបតីយកវត្ថុដែលកំពុងជួលឲ្យតតិយជន មកជាធ្វើកម្មវត្ថុនៃភតិសន្យា។

## ការប្រគល់វត្ថុដែលមានស្ថានភាពល្អពុំមានវិការៈអាថ៌កំបាំង៖

នៅក្នុងក្រមរដ្ឋប្បវេណីពុំបានបញ្ជាក់ពីករណីយកិច្ច ដែល ប្រគល់វត្ថុដែលស្ថានភាពល្អនោះទេ តែមានបញ្ជាក់ពីបញ្ហាវិការៈ អាថ៌កំបាំងនៃវត្ថុ។ មាត្រា៦០៥-២ ក្រមរដ្ឋប្បវេណី៖ នៅក្នុងករណីដែល វត្ថុជួលមានវិការៈអាថ៌កំបាំង បើភតិកៈមិនបានដឹងអំពីវិការៈនោះទេ ភតិកៈអាច ទាមទារឲ្យជួលជុលវិការៈនោះ ឬឲ្យដូរវត្ថុ ដែលគ្មានវិការៈ និង អាចទាមទារសំណងនៃ

ការខូចខាតបាន។ មាត្រាខាងលើនេះអាច បញ្ជាក់បានថា ភតិបតីត្រូវប្រគល់វត្ថុដែលស្ថិតក្នុងស្ថានភាពល្អ ដែល ភតិកៈ អាចប្រើប្រាស់បានដើម្បីសម្រេចគោលដៅនៃការជួល។ ប្រសិន ជាវត្ថុមានវិការៈអាចរាំងកំបាំង វាជាករណីយកិច្ចរបស់ភតិបតីដែលត្រូវ ធ្វើការជួសជុលវត្ថុនោះ។

## ករណីយកិច្ចជួលជុល និង ថែទាំវត្ថុ៖

នៅក្នុងអំឡុងពេលជួល ករណីយកិច្ចប្រគល់វត្ថុ គឺវាស្រប ជាមួយនឹងករណីយកិច្ចជួសជុលវត្ថុជួលផងដែរ។ មាត្រា៦០២ក្រម- រដ្ឋប្បវេណីបានចែងថា៖ ភតិបតីមានករណីយកិច្ចធ្វើការជួលជុលដែល ចាំបាច់សម្រាប់ការប្រើប្រាស់ និង អាស្រ័យផលនៃវត្ថុជួលនោះ។ ចំណែកមាត្រា ៦០៣-១ បានចែងថា ក្នុងករណីភតិបតី មានបំណងចង់ អនុវត្តសកម្មភាពដែលចាំបាច់ក្នុង ការថែរក្សាវត្ថុជួល ភតិកៈមិនអាច បដិសេធបានឡើយ។ នៅក្នុងអត្ថន័យ មាត្រា៦០២ និង ៦០៣ នេះ គឺសំដៅទៅលើ ការជួលជុលធំៗ និងការថែរក្សាវត្ថុ ដែលទាក់ទង នឹងទ្រង់ទ្រាយវត្ថុជួល។ ការងារជួលជុល និងថែទាំវត្ថុទាំងនោះ អាចជាការងារទាក់ទងនឹងជម្រាបទឹកនៅលើពិដាន ឬតាមជញ្ជាំង ដែលវាប៉ះពាល់ទៅដល់ស្ថានវត្ថុជួល។

ប្រសិនជាភតិបតីមិនបានជួសជុល នាំឲ្យភតិបតីមានទំនួល ខុសត្រូវក្នុងកិច្ចសន្យា ដោយសារតែភតិកៈ បានធ្វើចំណាត់ការចាំបាច់ ដើម្បីថែរក្សាវត្ថុជួលនោះ។ មាត្រា៦០៤បានចែងយ៉ាងច្បាស់ពីទំនួល ខុសត្រូវរបស់ភតិបតីដោយសង្កត់អត្ថន័យថា «បើភតិកៈបានចំណាយ សោហ៊ុយ**ចាំបាច់ដែលត្រូវជាបន្ទុករបស់ភតិបតី** ចំពោះវត្ថុជួល ភតិកៈអាច ទាមទារសំណងនោះពីភតិបតីជាបន្ទាន់បាន»។

បញ្ហាទាក់ទងនឹងខសន្យា ស្តីពីការកាត់បន្ថយការទទួលខុសត្រូវរបស់ភតិបតីចំពោះការជួលជុល និងថែទាំវត្ថុ អាចជាបញ្ហាក្នុងការ បកស្រាយដោយសារតែបទប្បញ្ញត្តិខាងលើពុំមានលក្ខណៈជាសណ្តាប់ធ្នាប់សាធារណៈ។ អ្វីដែលភតិកៈអាចធ្វើការស្នើសុំទាមទារបានមានតែ ការកាត់បន្ថយថ្លៃឈ្នួល ឬ រំលាយកិច្ចសន្យាក្នុងលក្ខខណ្ឌចាំបាច់មួយ គឺការមិនអាចសម្រេចគោលបំណងនៃការជួលបាន។[105]

## ១.២. ករណីយកិច្ចធានា

ករណីយកិច្ចធានានេះទៅការធានាលើវិការៈអាថ៌កំបាំង និង ការធានាពីការរំខានផ្សេងៗ។ ការធានាលើវិការៈអាថ៌កំបាំងនៃវត្ថុជួល គឺ គ្របដណ្តប់គ្រប់ប្រភេទវិការៈអាថ៌កំបាំង ទោះបីជាក្រោយពេលចុះ កិច្ចសន្យា ដែលធ្វើឲ្យភតិកៈនោះ មិនអាចប្រើប្រាស់ និង អាស្រ័យផល បាន។ ការធានានេះមិនទាក់ទងលើវិការៈខាងក្រៅដែលមើលឃើញនឹង ភ្នែកទទេនោះទេ។

ឧទាហរណ៍៖ ភតិកៈ បានជូនដំណឹងដល់ភតិបតីឲ្យធ្វើការជួលជុល ព្យសនកម្មលើរូបរាង្គកាយដែលទទួលរង ដោយសារតែភតិកៈជួប គ្រោះថ្នាក់នៅក្នុងបន្ទប់ជួល។ ភតិកៈបានត្រូវរបួសដោយសារតែ ពិដានធ្លាក់សង្កត់លើគាត់ជាដើម ដែលតាមពិតទៅពិដាននោះពុំមាន ស្នាមជ្រាបទឹក ឬ ស្នាមប្រេះនោះទេ តែវាស្រាប់តែធ្លាក់មកដោយមិនដឹង ពីមូលហេតុ។

យោងតាមមាត្រា៦០៥ ករណីយកិច្ចធានាវិការៈអាថ៌កំបាំងនេះ គឺ ទោះបីជាភតិបតីសុចរិតក៏ដោយ ក៏ភតិបតីត្រូវទទួលខុសត្រូវនៅគ្រប់ផលវិបាក

---

[105] ម. ៦០៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ដែលបណ្តាលពីវិការៈទាំងនោះ គឺការជួយជុលសំណងខូចខាត ទៅដល់ភតិកៈ (មាត្រា៦០៥-២៖ នៅក្នុងករណីដែលវត្ថុជួលមានវិការៈ អាចកំបាំង បើភតិកៈមិនបានដឹងពីវិការៈនោះទេ ភតិកៈអាចទាមទារឲ្យ ជួលជុលវិការៈនោះ ឬឲ្យដូរវត្ថុដែលគ្មានវិការៈ និង **អាចទាមទារសំណងនៃ ការខូចខាតបាន។**)

មធ្យោបាយដែលធ្វើឲ្យភតិបតីអាចរួចផុតពីការទទួលខុសត្រូវបាន គឺក្នុងករណី**ប្រធានសក្តិ**។ ភតិបតីត្រូវ បង្ហាញនូវធាតុផ្សំប្រធានសក្តិ ដូចជា **មិនអាចដឹងមុនបាន មិនអាចទប់ទល់បាន កើតក្រៅឆន្ទៈរបស់ភតិកៈ**។ នៅក្នុងសាលដិកាតុលាការបារាំងថ្ងៃទី២៦ តុលា ១៩៧៧ បានទទួល ស្គាល់ករណីប្រធានសក្តិ ក្នុងករណីដែរភតិកៈ ទទួលរងសារធាតុពុល ពីបំពង់ទឹកក្តៅដែលខូច ដែលបណ្តាលមកពីការតម្លើងបំពង់ទឹកក្តៅខុស បច្ចេកទេស។ ក្នុងករណីមួយទៀតតុលាការបារាំង បានច្រានចោលករណី ប្រធានសក្តិ ដែលនៅក្នុងអង្គហេតុភតិកៈធក់អគ្គីសនីនៅពេលគាត់បញ្ចូល ខ្យល់ចូលអាងទឹកធ្វើពីផ្លាស្ទិកនៅក្នុងសួន ជាមួយម៉ាស៊ីនបញ្ចូលខ្យល់ ដែលភ្ជាប់ជាមួយព្រីភ្លើងនៅក្នុងផ្ទះ។ តុលាការបារាំងបានលើកឡើងថា ភតិបតីនៅពេលដែលយកភូមិគ្រឹះដាក់ជួលមិនដែលសូម្បីតែមួយដង ធ្វើការថែទាំ ជួសជុល និងមិនដែលត្រួតពិនិត្យពីបច្ចេកទេសផ្សេងៗ នៅមុន ពេលកើតមានឧបទ្ទវហេតុនេះ។[106]

ចំពោះករណីយកិច្ចធានាលើការរំខានពីតតិយជន គឺក្នុងគោលដៅដើម្បីឲ្យភតិកៈចូលកាន់កាប់ ប្រើប្រាស់ដោយសន្តិវិធីចំពោះវត្ថុកាន់កាប់ ដូចជា៖

---

[106] សាលដិការតុលាការកំពូល ថ្ងៃទី៩ វិច្ឆិកា ២០១១។

ការជានាពីការំខានពីភាគីនៃកិច្ចសន្យាដូចជា ករណីហាមឃាត់មិនឲ្យអនុវត្តសកម្មភាពពាណិជ្ជកម្មរបស់ភតិកៈនៅទីតាំងជួល។

ការជានាពីការំខានដោយតតិយជនៈ តតិយជនធ្វើការទាមទារឲ្យប្រគល់វត្ថុមកវិញដោយសារតែវត្ថុដែលភតិកៈ កាន់កាប់ជាកម្មសិទ្ធិរបស់ តតិយជន។

## ២. ករណីយកិច្ចភតិកៈ

## ២.១. ការគ្រប់គ្រងវត្ថុដោយសុចរិត

**ករណីយកិច្ចគ្រប់គ្រងវត្ថុដោយសុចរិតៈ** ភតិកៈ ត្រូវគ្រប់គ្រងវត្ថុ ដោយប្រុងប្រយ័ត្នក្នុងការគ្រប់គ្រងវត្ថុដោយសុចរិត ដោយភាសានៅក្នុង ក្រមរដ្ឋប្បវេណីចាស់ គេប្រើប្រាស់ពាក្យ «**ប្រើប្រាស់វត្ថុដោយដូចឪពុកគម្រូ ក្នុងគ្រួសារ**» ។ ករណីយកិច្ចគ្រប់គ្រង ដោយប្រុងប្រយ័ត្ន ដោយសុចរិត គឺជាករណីយកិច្ចដែលមិនអាចថែងផ្ទុយ ឬ កែប្រែបានឡើយ ដូចជាករណី ដែល ភតិកៈយកម៉ាស៊ីនកាត់កញ្ចក់ឆ្លងកាត់ផ្ទះធ្វើឲ្យខូចឥដ្ឋការ៉ូ ឬ យកបង្រ្គានធ្យូងចំអិននៅចំកណ្តាលផ្ទះ ដែលមិនមែនចំអិននៅចង្ក្រាន បាយធ្វើឲ្យផ្ទះជួលខូចខាតយ៉ាងដំណំ។

ករណីយកិច្ចនេះ គឺជាករណីយកិច្ចដែលភតិកៈមិនអាចបំពាន ក្នុងការប្រើប្រាស់ និង អាស្រ័យផលពីវត្ថុជួល។ ម្យ៉ាងទៀតភតិកៈ ត្រូវមានករណីយកិច្ចប្រើប្រាស់វត្ថុដោយផ្អែកតាម វិធីប្រើប្រាស់នៃ ស្ថានភាពវត្ថុ ដូចជានៅក្នុងការចុះកិច្ចសន្យា ភតិកៈ និងភតិបតីបាន ព្រមព្រៀងគ្នាថាជាភតិសន្យាអគារស្នាក់នៅ តែភតិកៈបែជាយកទៅតាំង ជួលស្នាក់នៅមកធ្វើជាកន្លែងបើក

អាជីវកម្ម ដែលផ្ទុយពីខ្លឹមសារនៃ កិច្ចសន្យា។ យោងតាមរយៈមាត្រា៦០០ក្រមរដ្ឋប្បវេណី គឺតម្រូវឲ្យភតិកៈ ប្រើប្រាស់ដោយផ្អែកតាមវិធីប្រើប្រាស់ ដែលបានកំណត់ក្នុងកិច្ចសន្យា ឬ តាមលក្ខណៈនៃវត្ថុជួល។ ទណ្ឌកម្ម គឺភតិបតីមានសិទ្ធិអាចរំលាយ កិច្ចសន្យាបាន ដោយសារជាកំហុសរបស់ភតិកៈមិនគោរពនូវករណីយកិច្ច ខាងលើ។

**ករណីយកិច្ចថែរក្សាវត្ថុជួល៖** យោងតាមមាត្រា៦០២ក្រមរដ្ឋប្បវេណី ភតិបតីមានករណីយកិច្ចធ្វើការ**ជួលជុលដែលចាំបាច់**សម្រាប់ ការប្រើប្រាស់ និងអាស្រ័យផលនៃវត្ថុជួល បានន័យថាការជួលជុលដែល មិនស្ថិតក្នុងស្ថានភាពចាំបាច់ គឺជាបន្ទុករបស់ភតិកៈដោយសារតែភតិកៈ ត្រូវមានករណីយកិច្ចគ្រប់គ្រងវត្ថុឲ្យល្អ[107] ហេតុដូច្នេះភតិកៈត្រូវទទួល បន្ទុករាល់ការជួលជុលវត្ថុជួល ដែលមិនចូល ក្នុងការជួសជុលដែលចាំបាច់ របស់ភតិបតី វាអាចជាការជួលជុលដែលមិនប៉ះពាល់ដល់ស្ថានភាពនៃវត្ថុ ដូចជាការជួលម៉ូតូដែលក្នុងអំឡុងពេលប្រើប្រាស់ កង់ម៉ូតូត្រូវបានបែក ភតិកៈត្រូវទទួលបន្ទុកប៉ះកង់ជាដើម។

**ករណីយកិច្ចភតិកៈតាមរយៈខសន្យា៖** ក្នុងខ្លឹមសារកិច្ចសន្យា ភាគីអាចចងទាក់ទងទៅនឹងករណីយកិច្ចគូភាគីផ្សេង បន្ថែមពីលើច្បាប់សារធាតុ ដូចជាភតិកៈមិនត្រូវធ្វើឲ្យមានការរំខានដល់អ្នកជិតខាងនៅក្នុង អគារស្នាក់នៅរួម ដែលជាទូទៅគឺតម្រូវឲ្យរក្សាសណ្តាប់ធ្នាប់ និង ភាពស្ងប់ស្ងាត់នៅក្នុងអគារជាដើម។ ករណីយកិច្ចមួយទៀតអាច ជាការ ទទួលខុសត្រូវដែលបណ្តាលមកពីអគ្គិភ័យ ដែលជាទំនួលខុសត្រូវដែល របស់ភតិកៈទោះដោយចេតនា ឬការ

[107] ម. ៦០១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ធ្វេសប្រហែសរបស់ភតិកៈ លុះត្រាតែ អគ្គីភ័យនោះកើតចេញពីករណីប្រធានសក្តិ វិការៈនៃការសាងសង់ ឬក៏ អគ្គីភ័យនោះចេញពីផ្ទះអ្នកជិតខាង ទើបភតិកៈអាចរួចផុតពីការទទួល ខុសត្រូវ។ វាជាបន្ទុកដ៏ធ្ងន់ធ្ងរសម្រាប់ភតិកៈនៅពេលដែលភតិកៈមិនអាច បង្ហាញពីប្រភពដើមនៃអគ្គីភ័យ។

## ២.២. ការខូចខាត

ជាទូទៅភតិកៈត្រូវទទួលខុសត្រូវចំពោះការបាត់បង់ និង ការខូចខាតដែលបានកើតឡើង ក្នុងអំឡុងពេលប្រើប្រាស់ និង អាស្រ័យ លើវត្ថុជួល។ នៅក្នុងមាត្រា៦០០ និង មាត្រា៦២១ អាចត្រូវបាន បកស្រាយពីការខូចខាតបណ្តាលមកពីការប្រើប្រាស់ របស់ភតិកៈ ដែលការ ខូចខាតបណ្តាលមកពីការប្រើប្រាស់ខុសលក្ខណៈនៃវត្ថុ។ ការខូចខាតនេះ ត្រូវតែជាកំហុសចេតនា ឬ អចេតនារបស់ភតិកៈដែលមិនមែនជា កំហុសរបស់តតិយជន។ ក្នុងអត្ថន័យនេះអាចត្រូវយកមកសិក្សាជា សម្មតិកម្មផងដែរ ក្នុងករណីដែលតតិយជនដែលធ្វើឲ្យខូចខាតនោះមាន ទំនាក់ទំនងជាមួយភតិកៈ ដូចជាករណីភតិសន្យាអចលនវត្ថុស្នាក់នៅ កូនរបស់ភតិកៈបានបំផ្លាញទ្រព្យសម្បត្តិ ហើយធ្វើឲ្យខូចខាតដល់វត្ថុជួល ដែលជាមូលហេតុនាំឲ្យភតិកៈត្រូវទទួលខុសត្រូវចំពោះ ភតិបតី។

តុលាការនៅប្រទេសបារាំង បានកំណត់ពីលក្ខខណ្ឌនៃការ ប្រើប្រាស់ខូចខាតដែលនាំឲ្យភតិកៈត្រូវទទួលខុសត្រូវ ចំពោះករណី ភតិសន្យាអចលនវត្ថុ គឺជាការខូចខាតបណ្តាលមកពី «បុគ្គលដែលស្នាក់ នៅក្នុងលំនៅដ្ឋានជួល»។ តុលាការបានប្រានចោល ការទទួលខុសត្រូវ របស់ភតិកៈ ក្នុងករណីភតិកៈបានអញ្ជើញភ្ញៀវមកចូលរួមក្នុងកម្មវិធី ហើយ ភ្ញៀវនោះបានធ្វើឲ្យខូចខាតវត្ថុជួល។ តុលាការបានចាត់ទុកថា ភ្ញៀវដែល អញ្ជើញមក មិនត្រូវបាន

ចាត់ទុកជាបុគ្គលដែលស្នាក់នៅក្នុងលំនៅដ្ឋានដូច្នេះវាមិនមែនជាកំហុសរបស់ភតិកៈ។[108]

## ២.៣. ការបង់ថ្លៃឈ្នួលភតិកៈ

ថ្លៃឈ្នួល គឺជាការផលស៊ីវិលរបស់ភតិបតីដែលទាញប្រយោជន៍ ពីវត្ថុដែលជាកម្មសិទ្ធិរបស់ភតិបតីផ្ទាល់។ ថ្លៃឈ្នួល គឺជាបន្ទុករបស់ភតិកៈ ដែលមានសិទ្ធិកាន់កាប់វត្ថុរបស់អ្នកដទៃ។ ការបង់ថ្លៃឈ្នួល គឺត្រូវធ្វើ ទៅតាមពេលវេលា ដែលបានកំណត់ក្នុងកិច្ចសន្យា។ ដូច្នេះថ្លៃឈ្នួល គឺជាកាតព្វកិច្ចធានារបស់ភតិកៈចំពោះវត្ថុដែលកំពុងកាន់កាប់ ក្នុងករណី មិនគោរពករណីយកិច្ចនេះ ជាមូលហេតុដែលនាំឲ្យមានការរំលាយ ភតិសន្យា និង ទាមទារឲ្យធ្វើបដិទាននូវការប្រគល់វត្ថុត្រឡប់មកវិញ ឬ បណ្តេញភតិកៈចេញពីទីតាំងដួល។

មាត្រា៦១០ក្រមរដ្ឋប្បវេណី ចែងពីពេលវេលានៃការបង់ថ្លៃឈ្នួល នៅពេលដែលភាគីពុំបានចែងពីពេលវេលា នៃការបង់ថ្លៃឈ្នួលនៅក្នុង កិច្ចសន្យា។ ពេលវេលានៃការបង់ថ្លៃឈ្នួលដែលកំណត់ក្នុងមាត្រា៦១០ អាចកើតចេញពីទំនៀមទំលាប់ដែលធ្លាប់អនុវត្តពីមុនមក ដូចជាការជួលដី ប្រមូលផលគឺ ត្រូវបង់ថ្លៃឈ្នួលនៅពេលប្រមូលផលរួច ចំណែកការជួលដីធ្លី ដើម្បីអាជីវកម្មគេតែងតែបង់ជារៀងរាល់ដើមខែ ប៉ុន្តែច្បាប់បានចែងថា បើភាគីមិនបានកំណត់ទេ ការបង់ថ្លៃឈ្នួលគឺត្រូវធ្វើជារៀងរាល់ចុងឆ្នាំ ចំណែកចលនវត្ថុ ផ្ទះ អគារ ត្រូវបង់នៅរៀងរាល់ចុងខែ។

108 តុលាការកំពូលបារាំង ថ្ងៃទី១៦ មិថុនា ២០០៤។

## ៣. ការមិនអនុវត្តករណីយកិច្ចក្នុងភតិសន្យា

**មូលហេតុនៃការរំលាយភតិសន្យា៖** ភតិកៈជាប់បន្ទុកក្នុងបង់ ថ្លៃឈ្នួលក្នុងករណីមានវិវាទកើតឡើង ភតិកៈជាអ្នកបញ្ជាក់ស្តុតាង ពីការបង់ប្រាក់ឈ្នួលរបស់ខ្លួន ប្រសិនបើជាមិនអាចមានបញ្ជាក់ភស្តុតាង បានទេ ភតិបតីមានសិទ្ធិក្នុងរំលាយភតិសន្យា។

**អានុភាពនៃការរំលាយភតិសន្យា៖** ការរំលាយភតិសន្យា គឺមានអានុភាពឆ្ពោះទៅអនាគតតែប៉ុណ្ណោះ (មាត្រា៦១៧ក្រមរដ្ឋប្បវេណី)។ ដូច្នេះ ភតិបតីត្រូវធ្វើការផ្ទេរប្រាក់កក់ទៅឲ្យភតិកៈ ចំណែកភតិកៈត្រូវសង ការខូចខាតដែលបណ្តាលមកពីការបង់ប្រាក់យឺតយ៉ាវដល់ភតិបតី ជាទូទៅ ក្នុងការអនុវត្ត ភាគីទាំងសងខាងអាចចរចាគ្នារកដំណោះស្រាយ តាមរយៈ «ការទូទាត់» ដែលជារូបមន្តមួយក្នុងការទូទាត់បំណុលមានចែងក្នុង ក្រមរដ្ឋប្បវេណី។[109]

## ៤. ឧបាទេសកម្មភាគីនៃកិច្ចសន្យា

**ឧបាទេសកម្មភតិបតី៖** នៅក្នុងករណីដែលភតិបតីបានលក់ ឬ អនុប្បទានសិទ្ធិលើវត្ថុជួលទៅឲ្យអ្នកទិញ ឬ អនុប្បទានិក នាំឲ្យភតិសន្យា ត្រូវបានផ្ទេរទៅជាមួយផងដែរ។ នៅក្នុងអត្ថន័យមាត្រា៥១៥ ក្រមរដ្ឋប្ប- វេណីបានបញ្ជាក់យ៉ាងច្បាស់ គឺអ្នកលក់មានករណីយកិច្ចត្រូវ ផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិទៅឲ្យអ្នកទិញ។ «សិទ្ធិផ្សេងទៀត»ដែល មាត្រា៥១៥ បានកំណត់ គឺពាក់ព័ន្ធនឹងការធ្វើឧបាទេសកម្មភតិសន្យាដែល អ្នកទិញនឹងត្រូវ

---

109 ម. ៤៦៤ និងបន្តបន្ទាប់ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ក្លាយទៅជាភតិបតីថ្មីជំនួសអ្នកលក់។ ដូច្នេះរាល់ខ្លឹមសារ ដែលមានចែងនៅក្នុងភតិសន្យា ត្រូវធ្លាក់បន្ទុកទៅលើអ្នកទិញដែលត្រូវ អនុវត្តបន្តពីអ្នកលក់។

**ការផ្លាស់ប្តូរភតិកៈ៖** វាអាចជាករណីអនុប្បទានសិទ្ធិ ឬជា ភតិសន្យាបន្ត។ ចំពោះករណីអនុប្បទានសិទ្ធិ ភតិកៈមិនអាចធ្វើអនុប្បទាន សិទ្ធិជួលនេះទៅឲ្យតតិយជននោះទេ ក្នុងករណីមានខសន្យាហាមឃាត់ពី ការធ្វើអនុប្បទាន ឬ ប្រសិនពុំមានខសន្យាហាមឃាត់តែភតិបតីនូវតែមាន សិទ្ធិបដិសេធចំពោះការធ្វើអនុប្បទាននេះ។ ប្រសិនភតិកៈបានធ្វើ អនុប្បទានដោយភតិបតីមិនបានដឹងពីការធ្វើអនុប្បទានសិទ្ធិ ភតិបតីមាន សិទ្ធិរំលាយភតិសន្យាបានទៅតាមខ្លឹមសារដែលមានចែងក្នុងច្បាប់។[110]

ការធ្វើអនុប្បទានអាចប្រព្រឹត្តិទៅបាន ដោយពុំចាំបាច់មាន ការយល់ព្រមពីភតិបតី ក្នុងករណីដែលភតិកៈទទួលមរណភាពហើយ សន្តតិជនរបស់ភតិកៈមានឆន្ទៈក្នុងការបន្តភតិសន្យាមួយនោះ[111] ឬ ភតិសន្យានោះជាប្រភេទកិច្ចសន្យាជួលអចិន្ត្រៃយ៍ ការធ្វើអនុប្បទាន សិទ្ធិជួលអចិន្ត្រៃយ៍គឺធ្វើទៅដោយសេរី ដោយពុំចាំបាច់មានការយល់ព្រម ពីអ្នកឲ្យជួលអចិន្ត្រៃយ៍។[112]

**ភតិសន្យាបន្ត៖** ដូចទៅនឹងករណីអនុប្បទានសិទ្ធិជួល ភតិសន្យា បន្តអាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពីភតិបតីជាមុន។[113] បញ្ហា ដែលត្រូវចោទនៅក្នុងភតិសន្យាបន្ត គឺទំនាក់ទំនងរវាង ភតិបតី និង ភតិកៈបន្ត។ ហេតុដូច្នេះមាត្រា៦០៩បានកំណត់យ៉ាងច្បាស់ដោយ ភតិកៈបន្ត ត្រូវមាន

---

[110] ម. ៦០៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[111] ម. ៦២០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[112] ម. ៦០៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[113] ម. ៦០៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ករណីយកិច្ចដោយផ្ទាល់ជាមួយភតិបតី ជាពិសេស ភតិបតីមានសិទ្ធិក្នុងទាមទារឲ្យបង់ថ្លៃឈ្នួលពីភតិកៈបន្ត ដែលភតិកៈបន្ត មិនអាចធ្វើការតតាំងដោយសំអាងថាខ្លួនបានបំពេញតាវកាលិកជាមួយ ភតិកៈរួចហើយក៏ដោយ។

## ផ្នែកទី២. ភតិសន្យាពិសេស

នៅក្នុងផ្នែកទី២នេះ គឺជាការសិក្សាទៅលើភតិសន្យាមួយចំនួនដែលមានលក្ខខណ្ឌមួយចំនួនខុសពីអ្វី ដែលបានសិក្សានៅផ្នែកទី១ខាងលើ ដោយសារតែមានបទប្បញ្ញត្តិពិសេសមួយចំនួនមាននៅក្រៅក្រមរដ្ឋប្បវេណីផង និង មួយចំនួនទៀតមាននៅក្នុងក្រមរដ្ឋប្បវេណី។

## កថាខណ្ឌ១៖ កិច្ចសន្យាជួលបន្ទប់ស្នាក់នៅកម្មករ សិស្ស និស្សិត

សិទ្ធិស្នាក់នៅ គឺជាសិទ្ធិមួយត្រូវបានការពារដោយរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។ យោងតាមមាត្រា៤០រដ្ឋធម្មនុញ្ញ ចែងថា៖ « សេរីភាពក្នុងការធ្វើដំណើរឆ្ងាយជិត និង តាំងទីលំនៅក្នុងស្ថានភាព ស្របច្បាប់របស់ប្រជាពលរដ្ឋត្រូវបានគោរព។ ការស្នាក់នៅគឺជាបន្ទុក សេដ្ឋកិច្ច និងហិរញ្ញវត្ថុដ៏ធ្ងន់ធ្ងរ សម្រាប់គ្រួសារដែលមានប្រាក់ចំណូល ទាប ជាពិសេស គឺកម្មករ សិស្ស និង និស្សិតដែលមកសិក្សានៅភ្នំពេញ ហេតុដូច្នេះហើយទើបនៅឆ្នាំ២០១៥ មានច្បាប់ពិសេសមួយមាន គោលដៅការពារទៅដល់ពួកគាត់ តាមរយៈច្បាប់ស្តីពីភតិសន្យាពិសេស។

## ១. វិធានគ្រប់គ្រងភតិសន្យាស្នាក់នៅ

ច្បាប់ស្តីពីភតិសន្យាពិសេសឆ្នាំ២០១៥ គឺជាវិធានដែលមាន អត្តចរិតជា«សណ្តាប់ធ្នាប់សាធារណៈ» ជាមូលហេតុនាំឲ្យសិទ្ធិសេរីភាព គូភាគីត្រូវបានកាត់បន្ថយ ជាពិសេសទាក់ទងនឹងខសន្យាទាំងឡាយ ដែលចែងមកមានប្រៀបជាងភាគីម្ខាងទៀត ក្នុងន័យនេះគឺចង់សំដៅ ទៅលើភតិបតី ដោយសារតែភតិកៈមានស្ថានភាពទន់ខ្សោយជាងនៅក្នុង ស្ថានភាពមួយចំនួនមិនថានៅក្នុងដំណាក់កាលនៃការចរចា ឬក៏ដំណាក់ កាលនៃការអនុវត្តកាតព្វកិច្ចរបស់គូភាគី។[114]

នៅក្នុងមាត្រា១នៃច្បាប់នេះ បញ្ជាក់យ៉ាងច្បាស់ពីចេតនារបស់ អ្នកនីតិនិពន្ធ ក្នុងគោលដៅការពារភតិកៈដោយមាត្រា១ចែងថា៖ «ច្បាប់នេះ មានគោលបំណងធានាការពារសិទ្ធិ និងផលប្រយោជន៍របស់ភតិកៈ»។ វត្ថុបំណងនៃច្បាប់ស្តីពីភតិសន្យាពិសេសមួយនេះ គឺមានអត្តចរិតជាវិធាន គ្រប់គ្រងការពារសណ្តាប់ធ្នាប់សាធារណៈដែលជាកត្តានាំឲ្យសេរីភាពគូភាគីត្រូវបានកាត់បន្ថយក្នុងគោលដៅការពារជាពិសេសដល់ភតិកៈ។

### ១.១ លក្ខខណ្ឌគូភាគី

ក្រៅពីវិធានទូទៅដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីទាក់ទងនឹងសមត្ថភាពគូភាគី ដូចជាសមត្ថភាពធ្វើសកម្មភាព ច្បាប់ពិសេសនេះទាមទារឲ្យគូភាគីមានសមត្ថភាពពិសេសបន្ថែមពីលើសមត្ថភាពទូទៅ។

---

[114] ម. ១ ច្បាប់ស្តីពីភតិសន្យាពិសេស ឆ្នាំ២០១៥។

### ១.១.១. ភតិបតី

ភតិបតីមិនត្រឹមតែជានីតិជន ឬ អនីតិជនដែលមាន អត្តាធិនភាពប៉ុណ្ណោះទេ គឺទាមទារឲ្យភតិបតីជា«**អ្នកអាជីព**»[115] ដើម្បីឲ្យ វិធានច្បាប់ពិសេសមួយនេះមានវិសាលភាពគ្រប់ដណ្តប់។ **អ្នកអាជីព** គឺសំដៅទៅលើដំណើរធ្វើការរបរចិញ្ចឹមជីវិត មានន័យថាភតិបតីត្រូវមាន ចេតនាបង្កើតមុខរបរនៃការជួលផ្ទះស្នាក់នៅ ដែលជាមុខរបរចិញ្ចឹមជីវិត របស់គាត់ ឬអាចនិយាយម្យ៉ាងទៀតថា ការជួលផ្ទះស្នាក់នៅគឺជាការ ប្រកបអាជីវកម្មសម្រាប់ភតិបតី។

អាជីពរបស់ភតិបតី អាចត្រូវបានចាត់ថ្នាក់ចូលនៅក្នុងក្របខណ្ឌ ជាពាណិជ្ជករ ដែលបានកំណត់ក្នុងច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជី ពាណិជ្ជកម្មឆ្នាំ១៩៩៩។ ក្នុងច្បាប់នេះបានចែងថា ពាណិជ្ជករគឺបុគ្គល ដែលធ្វើពាណិជ្ជកិច្ចជាការលក់ទិញ ឬសេវា ដែលជាមុខរបរប្រចាំថ្ងៃ និង ស្វែងរកប្រាក់ចំណេញ។[116] សកម្មភាពដែលត្រូវចាត់ទុកជាពាណិជ្ជកិច្ច អាចជាសគ្រាសជួលជាដើម។[117]

### ១.១.២. ភតិកៈ

តាមរយៈច្បាប់ស្តីពីភតិសន្យាពិសេស ភតិកៈមិនត្រឹមតែជា នីតិជន ឬអនីតិជនដែលមានអត្តាធិនភាពប៉ុណ្ណោះទេភតិកៈត្រូវបំពេញនូវលក្ខខណ្ឌ

---

[115] ម. ៣ ច្បាប់ស្តីពីភតិសន្យាពិសេស ឆ្នាំ២០១៥។

[116] ម. ១ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ឆ្នាំ១៩៩៩។

[117] ម. ២ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ឆ្នាំ១៩៩៩។

២ គឺជាបុគ្គលពិសេស (កម្មករ ឬ សិស្ស និស្សិត) និង ត្រូវមានស្ថានភាពសេដ្ឋកិច្ចដែលទាក់ទងនឹងប្រភពចំណូលទាប។

### ១.១.២.១. លក្ខខណ្ឌចំពោះបុគ្គល

កម្មករដែលជាភតិក: អាចជាកម្មករក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ដែលជាបុគ្គលធ្វើការដោយប្រើប្រាស់កម្លាំងកាយ ស្ថិតក្រោមការដឹកនាំ របស់និយោជក ឬអ្នកតំណាងនិយោជក។

នៅក្នុងវាក្យសព្ទដែលមានចែងក្នុងឧបសម្ព័ន្ធ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ២០១៩ បានឲ្យនិយមន័យពាក្យ កម្មករនិយោជិត នៃវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធសំដៅដល់ជនគ្រប់ប្រភេទ និង គ្រប់សញ្ជាតិ ដែលបានចុះកិច្ចសន្យាធ្វើការយកប្រាក់ឈ្នួលក្រោមការដឹកនាំ និង គ្រប់គ្រងរបស់និយោជកម្នាក់ ឬច្រើននាក់ ដែលមានទីតាំងនៅ ព្រះរាជាណាចក្រកម្ពុជា ដោយមិនគិតដល់ប្រភេទទម្រង់ និងសុពលភាព នៃកិច្ចសន្យាការងារ ឬប្រភេទ និងចំនួនប្រាក់ឈ្នួល។

ចំណែកកម្មករ និយោជិតនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ សំដៅ ដល់ជនគ្រប់ភេទដែលធ្វើការងារសេរី យកថ្លៃ ឈ្នួលភ្លាមៗ តាមសាច់ការ ឬទំហំការងារ ឬតាមការតថ្លៃដាក់ស្តែងដោយភាគីដែលផ្តល់ថ្លៃឈ្នួល មិនមានកាតព្វកិច្ចទទួលខុសត្រូវដូចនិយោជកឡើយ។

ចំណែកប្រកាស អន្តរក្រសួងលេខ៤០៤ ក.ប./ប្រ.ក.ប.ស.ស. បានឲ្យនិយមន័យថា កម្មករក្រៅប្រព័ន្ធគឺសំដៅទៅលើកម្មករដែលចុះ កិច្ចសន្យាការងារមួយ ដែលមានរយៈពេលមិលលើសពី៨ម៉ោងក្នុងមួយសប្តាហ៍ ធ្វើ

ការងារមួយពេលៗ ធ្វើឈប់ៗ ឬធ្វើការងារមួយរដូវៗ ហើយ ដែលបានចុះបញ្ជីក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.)។[118]

សម្រាប់ភតិកៈ សិស្ស និស្សិត គឺជារូបវន្តបុគ្គលដែលសិក្សានៅ តាមសាលាវិជ្ជាជីវៈ ឬ មហាវិទ្យាល័យ ឬ សាកលវិទ្យាល័យ។

## ១.១.២.២. លក្ខខណ្ឌសេដ្ឋកិច្ច

កម្មករក្នុងប្រព័ន្ធក្តី ឬកម្មករក្រៅប្រព័ន្ធក្តីអាចជាភតិកៈ ប្រសិនជាប្រាក់កំរៃការងារគោលប្រចាំខែ ទាបជាងប្រាក់កំរៃដែល កំរិត ដោយអនុក្រឹត្យ។[119] យោងតាមប្រភពព័ត៌មានរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២០ គឺ១៩០ដុល្លាអាមេរិក ចំពោះកម្មករនិយោជិតក្នុងវិស័យវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង។[120]

[118] ប្រការ៤ ប្រកាសអន្តរក្រសួង លេខ ៤០៤កប/ប្រ.ក.ប.ស.ស. ស្តីពីការអនុវត្តថែទាំសុខភាព តាមប្រព័ន្ធមូលនិធិសមធម៌ សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាល កូន ឆ្នាំ២០១៧។

[119] ម. ៤ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ឆ្នាំ១៩៩៩។

[120] "ប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតក្នុងវិស័យ វាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០២០ ឡើងដល់ ១៩០ដុល្លារ," ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, accessed March 3, 2021, http://www.mlvt.gov.kh/។

ចំពោះសិស្ស និស្សិតដែលជាភតិក: គឺច្បាប់ផ្តោតទៅលើ ស្ថានភាពសេដ្ឋកិច្ចទន់ខ្សោយដែលលំបាកខ្លាំង ក្នុងការទ្រទ្រង់ជីវភាព ដោយសារតែការបង់ប្រាក់ឈ្នួលផ្ទះស្នាក់នៅ។[121]

ស្ថានភាពសេដ្ឋកិច្ចរបស់ភតិក: ដែលច្បាប់ខាងលើបានចែង អាចធ្វើការបកស្រាយបានថា ភតិក:គឺស្ថិតនៅស្ថានភាពលំបាកខ្លាំង ក្នុងទ្រទ្រង់ប្រាក់ឈ្នួលផ្ទះ ព្រោះភតិក:ត្រូវមានបន្ទុកចំណាយ ផ្សេងទៀតដែលចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃ ដូចជាម្ហូបអាហារ ទឹកភ្លើងជាដើម ហេតុដូច្នេះ ប្រសិនជាប្រាក់ឈ្នួលស្នាក់នៅខ្ពស់ គឺជាកត្តាដែលនាំឲ្យភតិក:ដែលជាកូនបំណុល អាចអលទ្ធភាពក្នុងការ បំពេញតាវកាលិករបស់ខ្លួន។

## ១.២. លក្ខខណ្ឌទាក់ទងនឹងវត្ថុ

សម្រាប់ភតិសន្យាទូទៅ វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា អាចជាចលនវត្ថុ ឬ អចលនវត្ថុ[122] ប៉ុន្តែសម្រាប់ភតិសន្យាពិសេស វត្ថុដែលជាកម្មវត្ថុ នៃកិច្ចសន្យាត្រូវតែជាអចលនវត្ថុ។ អចលនវត្ថុដែលកម្មវត្ថុនៃភតិសន្យា គឺ មិនមែនជាដីធ្លី ឬអគារទូទៅនោះទេ គឺត្រូវតែជាបន្ទប់ស្នាក់នៅ។[123]

ភាពខុសគ្នារវាងភតិសន្យាទូទៅ និង ភតិសន្យាពិសេសនេះ គឺទៅលើវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ដោយសារតែវត្ថុដែលកំណត់ដោយ ច្បាប់ពិសេសនេះ គឺបានតែបន្ទប់ស្នាក់នៅតែប៉ុណ្ណោះ មានន័យថា ទោះបីភតិក:ជា

---

[121] ម. ៤ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ឆ្នាំ១៩៩៩។

[122] ម. ៥៩៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[123] ម. ៣ ច្បាប់ស្តីពីភតិសន្យាពិសេស ឆ្នាំ២០១៥។

កម្មករក្តី ឬជានិស្សិតក្តី ប្រសិនវត្ថុជួលជាផ្ទះទាំមូល ដែលមិនមែនជាបន្ទប់ស្នាក់នៅនោះទេ វិធាននៃភតិសន្យាពិសេសដែល មានចែងក្នុងច្បាប់ពិសេសនេះ មិនមានអានុភាពក្នុងការអនុវត្តនោះទេ។

នៅក្នុងច្បាប់មួយនេះ នៅមានភាពខ្វះចន្លោះមួយចំនួនទាក់ទង នឹងការកំណត់អំពីមាត្រដ្ឋាននៃខ្នាតបន្ទប់ស្នាក់នៅ រួមទាំងស្ថានភាពនៃ បន្ទប់ស្នាក់នៅ ថាតើចាំបាច់ត្រូវទំហំចន្លោះពីប៉ុន្មានមែត្រការ៉េ និងសម្ភារៈ មួយចំនួនដូចជា បន្ទប់ទឹក និង បង្គន់សម្រាប់ការរស់នៅប្រចាំថ្ងៃ។

## ១.៣. ថិរៈវេលានៃភតិសន្យា

ជាធម្មតាថិរៈវេលាភតិសន្យាមាន២ប្រភេទ គឺមានអំឡុងពេល កំណត់ និងពុំមានអំឡុងពេលកំណត់។ គូភាគីដែលជ្រើសរើសយក ភតិសន្យាដែលមានកំណត់អំឡុងពេល ក្រមរដ្ឋប្បវេណីតម្រូវឲ្យភាគីធ្វើជា លាយល័ក្ខណ៍អក្សរ។[124] អ្វីដែលក្រមរដ្ឋប្បវេណីមិនបានចែង គឺរយៈពេល អប្បបរមាសម្រាប់ភតិសន្យា ដោយទុកលទ្ធភាពឲ្យគូភាគីជាអ្នកកំណត់ អំពីអំឡុងពេលនៃការជួល។

ចំណែកភតិសន្យាពិសេស សម្រាប់ការជួលបន្ទប់ស្នាក់នៅរបស់កម្មករ សិស្ស និងនិស្សិត គឺច្បាប់តម្រូវឲ្យរយៈពេលនៃការជួលអប្បបរមា គឺមានរយៈពេល២ឆ្នាំ ទោះបីជាភតិសន្យានោះមាន កំណត់អំឡុងពេល ឬ ពុំមានកំណត់អំឡុងពេលក៏ដោយ។[125] ទោះបីជាគូភាគីកំណត់រយៈពេល តិចជាង២ឆ្នាំក៏ដោយ ក៏ភតិកៈមានអត្ថិភាពក្នុងការជួលបន្ទប់ស្នាក់នៅ រយៈពេល២ឆ្នាំ

---

[124] ម. ៥៩៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[125] ម. ៦ ច្បាប់ស្តីពីភតិសន្យាពិសេស ឆ្នាំ២០១៥។

យ៉ាងតិច លុះត្រាតែភតិកៈបានប្រព្រឹត្តកំហុសណាមួយ ដែលមានកំណត់ក្នុងច្បាប់ពិសេសនេះ ទើភតិបតីមានសិទ្ធិធ្វើការរំលាយ ភតិសន្យាពិសេសនេះមុនកាលកំណត់បាន។

## ១.៤. លក្ខខណ្ឌតតាំង

នៅពេលមានជំនួបសំណើ និងស្ទីការ នាំឲ្យកិច្ចសន្យាមានសុពលភាព ក៏ដូចជាអានុភាពសម្រាប់គូភាគីក្នុងអនុវត្តតាវកាលិក លើកលែងតែមានការព្រមព្រៀងរវាងគូភាគី ឬច្បាប់តម្រូវឲ្យកិច្ចសន្យាត្រូវ ធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ក្រោមទម្រង់ជាលិខិតយថាភូត ប្រសិន ជាវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាជាអចលនវត្ថុ និងកិច្ចសន្យានោះទាក់ទង នឹងការធ្វើលទ្ធកម្មសិទ្ធិកម្មសិទ្ធិលើអចលនវត្ថុ ដូចជាកិច្ចសន្យាលក់ទិញ អចលនវត្ថុជាដើម។[126]

សម្រាប់ភតិសន្យាក៏ដូចគ្នាផងដែរ គូភាគីអាចធ្វើផ្ទាល់មាត់ ឬ លាយល័ក្ខណ៍អក្សរ គ្រាន់តែភតិសន្យាមិនអាចកំណត់អំឡុងពេលបាន នោះទេ ប្រសិនគូភាគីពុំបានធ្វើជាលាយល័ក្ខណ៍អក្សរ។[127] ចំណែក ករណី ការជួលបន្ទប់ស្នាក់នៅសម្រាប់កម្មករ សិស្ស និស្សិត គឺច្បាប់តម្រូវឲ្យ កិច្ចសន្យាធ្វើឡើងជាលាយល័ក្ខណ៍អក្សរ។

ដើម្បីជាប្រយោជន៍ដល់គូភាគីទាំងសងខាង រវាងភតិកៈ និង ភតិបតី ច្បាប់ស្តីពីភតិសន្យាពិសេស បានបន្ថែមលក្ខខណ្ឌតតាំងបន្ថែមពី លើលក្ខខណ្ឌទម្រង់ខាងលើ។ លក្ខខណ្ឌតតាំងដែលច្បាប់ពិសេស កំណត់ គឺការ

---

[126] ម. ៣៣៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[127] ម. ៥៩៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

បញ្ជាក់របស់មេឃុំ ឬ ចៅសង្កាត់ នៅលើភតិសន្យាពិសេស មួយនេះ។[128] ការបញ្ជាក់របស់មេឃុំ ឬ ចៅសង្កាត់លើភតិសន្យានេះ គឺជាបន្ទុករបស់ភតិបតី មានន័យថាភតិបតីដែលជាអ្នកជំនាញ ត្រូវយក កិច្ចសន្យាជួលនេះក្រោយពេលភតិកៈបានចុះហត្ថលេខា ឬស្នាមមេដៃរួច យកទៅឃុំសង្កាត់នៃទីតាំងដែលអចលនវត្ថុតាំងនៅ។

ក្នុងករណីភតិបតីមិនបានយកទៅបញ្ជាក់កិច្ចសន្យា នៅឃុំ សង្កាត់នោះទេ ច្បាប់នៅតែផ្តល់អត្ថិភាពទៅដល់ភតិកៈដែលជាកម្មករ សិស្ស និស្សិត ដោយឲ្យភតិកៈមានជម្រើសរវាងវិធានដែលមានចែងក្នុង ច្បាប់ភតិសន្យាពិសេសនេះ ឬជ្រើសរើសយកវិធានទូទៅនៃភតិសន្យាដែល មានចែងក្នុងក្រមរដ្ឋប្បវេណី។

## ២. សិទ្ធិ និង ករណីយកិច្ចរបស់អ្នកជំនាញ និង កម្មករ សិស្ស និស្សិត

នៅពេលដែលអ្នកជំនាញដែលកម្មសិទ្ធិករនៃបន្ទប់ បានចុះ ភតិសន្យាជាមួយនឹងកម្មករ សិស្ស ឬនិស្សិត នាំឲ្យសិទ្ធិ និង ករណីយកិច្ច គូភាគីបានបង្កើតឡើងដែលសិទ្ធិ និង ករណីយកិច្ចគូភាគី ទាំងសងខាង មានដូចជា៖ ករណីយកិច្ចប្រគល់វត្ថុប្រើប្រាស់ ករណីយកិច្ចបង់ថ្លៃឈ្នួល ករណីយកិច្ចគ្រប់គ្រងវត្ថុ ករណីយកិច្ចជួលជុល ក៏ដូចជាករណីយកិច្ច រក្សាសណ្តាប់ធ្នាប់នៃបន្ទប់ជួល។ សិទ្ធិ និង ករណីយកិច្ចទាំងនេះ គឺមានចែងក្នុងវិធានរួមនៃភតិសន្យាដែលមាននៅក្នុងក្រមរដ្ឋប្បវេណី។

---

[128] ម. ៥ ច្បាប់ស្តីពីភតិសន្យាពិសេស ឆ្នាំ២០១៥។

## ២.១. ការប្រគល់វត្ថុ និង ការបង់ថ្លៃឈ្នួល

### ២.១.១. ការប្រគល់វត្ថុ

ជាគោលការណ៍ ភតិបតីដែលជាអ្នកជំនាញត្រូវធ្វើការប្រគល់វត្ថុ ឲ្យភតិកៈធ្វើការកាន់កាប់ និងអាស្រ័យផលពីវត្ថុជួល ចំណែកភតិកៈ ត្រូវមានករណីយកិច្ចធ្វើការបង់ប្រាក់ឈ្នួលបន្ទប់ ដូចដែលមានកំណត់ នៅក្នុងក្រមរដ្ឋប្បវេណី។

នៅក្នុងបទប្បញ្ញត្តិពិសេសពុំបានកំណត់ពី ករណីយកិច្ចទាក់ទង នឹងការប្រគល់វត្ថុរបស់ភតិបតី ជាពិសេសករណីយកិច្ចធានាវិការៈ អាថ៌កំបាំងនៃវត្ថុជួល។ ហេតុដូច្នេះ ក្នុងករណីដែលមានវិការៈអាថ៌កំបាំង នៃវត្ថុបានកើតឡើង ភតិកៈដែលជាកម្មករ សិស្ស និស្សិត អាចលើក បទប្បញ្ញត្តិដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ទាមទារឲ្យភតិបតីដែលជា ជំនាញធ្វើការទទួលខុសត្រូវចំពោះវត្ថុដែលមានវិការៈនោះ ដែលមានដូចជា ការជួលជុលវត្ថុ កាត់បន្ថយថ្លៃឈ្នួល ឬរំលាយភតិសន្យាជាដើម។[129]

### ២.១.២. ការបង់ថ្លៃឈ្នួល

ចំពោះការបង់ថ្លៃឈ្នួល គឺជាករណីយកិច្ចរបស់ភតិក ដែលត្រូវ ធ្វើការបង់ទៅតាមកាលកំណត់នៅក្នុងកិច្ចសន្យា។ អ្វីដែលពិសេសទាក់ទង នឹងថ្លៃឈ្នួលសម្រាប់ភតិសន្យាពិសេស ដែលជាប្រភេទនៃការជួលបន្ទប់ ឲ្យកម្មករ

---

[129] ម. ៦០៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

សិស្សនិស្សិតដោយសារតែតម្លៃឈ្នួលដែលបានកំណត់នៅពេល ចុះកិច្ចសន្យា មិនអាចត្រូវបានកែប្រែក្នុងអំឡុងពេលអនុវត្តកាតព្វកិច្ច គូភាគីនោះឡើយ។

ខុសពីភតិសន្យាទូទៅ ដែលជាប្រភេទកាតព្វកិច្ចបន្តបន្ទាប់ ភាគីម្ខាង ក្នុងចំណោមភាគីទាំងសងខាង អាច ធ្វើការស្នើសុំចរចា តម្លៃឈ្នួលឡើងវិញបាន។ បទប្បញ្ញត្តិទាក់ទងនឹងតម្លៃឈ្នួលនៃកិច្ចសន្យា ជួលបន្ទប់កម្មករ សិស្ស និស្សិតនេះ គឺមានលក្ខណៈដាច់ខាត វាទាក់ទង នឹងសណ្តាប់ធ្នាប់សាធារណៈ គឺមកពីស្ថានភាពសេដ្ឋកិច្ចរបស់ភតិកៈមាន ភាពទន់ខ្សោយជាងភតិបតី។[130]

## ២.២. ករណីយកិច្ចគ្រប់គ្រងវត្ថុ ថែរក្សាវត្ថុ និង រក្សាសណ្តាប់ធ្នាប់

### ២.២.១. ការគ្រប់គ្រងវត្ថុ

អ្នកកាន់កាប់ គឺត្រូវមានភារកិច្ចក្នុងគ្រប់គ្រងវត្ថុទោះស្ថិតក្រោម ទម្រង់កិច្ចសន្យាណាក៏ដោយ ជាពិសេសនៅក្នុងភតិសន្យា គឺជាបន្ទុក របស់ភតិកៈ ដែលជាអ្នកកាន់កាប់វត្ថុ ត្រូវទទួលបន្ទុកក្នុងការគ្រប់គ្រងវត្ថុឲ្យ ត្រឹមត្រូវឲ្យដូចឪពុកគម្រូនៅក្នុងគ្រួសារ ឬអ្នកគ្រប់គ្រងដោយប្រុងប្រយ័ត្ន និង សុចរិត។[131] ចំពោះកិច្ចសន្យាជួលស្នាក់នៅរបស់កម្មករ សិស្ស និស្សិត ក៏បានកំណត់ពីលក្ខខណ្ឌក្នុងការគ្រប់គ្រង និង ការប្រើប្រាស់ឲ្យស្របទៅ តាមវត្ថុជួលផងដែរ។ មាត្រា៧នៃច្បាប់ស្តីពីភតិសន្យាពិសេសបានចែងថា ក្នុងករណីដែលភតិកៈ

---

[130] ម.៨ ច្បាប់ភតិសន្យាពិសេស ឆ្នាំ២០១៥ ៖ «ក្នុងអំឡុងពេលដែលភតិសន្យាពិសេសមាន អានុភាពអនុវត្ត**<u>ភតិបតីមិនអាចតម្លើង ថ្លៃឈ្នួលបានឡើយ</u>**»។

[131] ម. ៦០១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ប្រើប្រាស់ និង អាស្រ័យផលខុសពីគោលបំណងនៃ ការជួល គឺជាមូលហេតុដែលនាំឲ្យភតិបតីមានសិទ្ធិរំលាយភតិសន្យា។

### ២.២.២. ការថែរក្សាវត្ថុ

ក្រៅពីការគ្រប់គ្រងវត្ថុ ការថែរក្សាវត្ថុគឺជាចំណុចសំខាន់ដើម្បីរក្សាតម្លៃវត្ថុ ជាពិសេសកុំឲ្យវត្ថុទ្រុឌទ្រោមដោយសារការប្រើប្រាស់វត្ថុជួល។ ជាគោលការណ៍ ភតិបតីគឺភាគីទទួលបន្ទុកក្នុងការជួលជុលវត្ថុជួលដែល ចាំបាច់ដើម្បីរក្សាស្ថានភាពវត្ថុជាដើម។ ក្រមរដ្ឋប្បវេណីបានកំណត់ពី ករណីយកិច្ចរបស់ភតិកៈ គឺមិនត្រូវរារាំង ឬបដិសេធដល់ភតិបតីក្នុងការ ជួលជុលវត្ថុ។[132]

ការជួសជុលថែរក្សាវត្ថុ ក៏អាចជាមូលហេតុនៃការរំលាយកិច្ចសន្យាជួលស្នាក់នៅកម្មករ សិស្ស និស្សិត សម្រាប់ភតិបតី ប្រសិនជាការ ជួសជុលនោះមានលក្ខណៈធំដំ ឬ សាង់សង់ថ្មីឡើងវិញដើម្បីឲ្យត្រឹមត្រូវ តាមស្តង់ដាដែលកំណត់ដោយអាជ្ញាធរជម្នានុរូប។[133]

### ២.២.៣. ការរក្សាសណ្តាប់ធ្នាប់

លក្ខណៈពិសេសនៃភតិសន្យា ដូចដែលបានរៀបរាប់ខាងលើគឺវត្ថុដែលជាកម្មវត្ថុនៃការជួល គឺជាលក្ខណៈបន្ទប់ស្នាក់នៅដែលភតិបតី ជាម្ចាស់អគារមានបន្ទប់ជាច្រើនសម្រាប់ជួលឲ្យកម្មករ សិស្ស និស្សិត ហេតុដូច្នេះការរក្សាសណ្តាប់ធ្នាប់នៅបរិវេណនៃអគារជួល គឺជារឿងមួយ ដ៏សំខាន់សម្រាប់ភតិកៈផ្សេងដទៃទៀត ការបង្កសំឡេងរំខាន ឬ អាកប្បកិរិយាមិនគម្បីណាមួយ

---

[132] ម. ៦០២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[133] ម.៧ ច្បាប់ភតិសន្យាពិសេស ឆ្នាំ២០១៥។

ដែលធ្វើឲ្យអ្នកជិតខាងដែលជាភតិកៈ នៃអគារមិនអាចស្នាក់នៅបាន គឺជាទំនួលខុសត្រូវរបស់ភតិកៈដែលបង្ក ការរំខានដោយសារទង្វើរបស់ខ្លួន។

ទោះបីជាក្នុងភតិសន្យាមិនបានចែង ឬបទបញ្ញាផ្ទៃក្នុងនៃអគារ ជួលក៏ច្បាប់អនុញ្ញាតិឲ្យភតិបតីអាចធ្វើការរំលាយភតិសន្យា ដោយសារតែ កំហុសរបស់ភតិកៈ ដែលបានធ្វើឲ្យអសន្តិសុខនៅជុំវិញបរិវេណនៃបន្ទប់ ជួលស្នាក់នៅ។

មាត្រា៧បានចែងថា៖ ភតិបតីអាចធ្វើការរំលាយភតិសន្យាបាន ប្រសិនភតិកៈមានចេតនាធ្វើឲ្យប៉ះពាល់សណ្តាប់ធ្នាប់ច្រើនលើក និងបង្ក ឲ្យមានឥទ្ធិពលដល់ការរស់នៅជាប្រក្រតីរបស់អ្នករស់នៅជុំវិញ។ តាមរយៈ មាត្រា៧ តម្រូវឲ្យមានលក្ខខណ្ឌជាច្រើន ដើម្បីឈានទៅរកការរំលាយ កិច្ចសន្យាជួលបន្ទប់ស្នាក់នៅ កម្មករ សិស្ស និស្សិត ដែលមានដូចជា៖ កំហុសរបស់ភតិកៈ និង ផលប៉ះពាល់ដល់អ្នករស់នៅជុំវិញបរិវេណ បន្ទប់ជួល។ កំហុសដែលភតិកៈប្រព្រឹត្ត គឺជាប្រភេទកំហុសដ៏ធ្ងន់ធ្ងរ ដោយសារតែបង្កភាពអសន្តិសុខដែលបណ្តាលមកពីភតិកៈ គឺមានភាព ដដែលៗដែលជាករណីមិនរាងចាល។

## ៣. ការរំលាយកិច្ចសន្យាជួលបន្ទប់ស្នាក់នៅ

មានមូលហេតុជាច្រើន ដែលនាំឲ្យភតិសន្យាត្រូវបានរំលាយ ដែលអាចបណ្តាលពីកំហុសរបស់ភាគីណាមួយ ឬ មិនមែនជាកំហុស របស់ភាគីទាំងពីរ ដែលវាមានអានុភាពចំពោះគូភាគី។

## ៣.១. មូលហេតុនៃការរំលាយកិច្ចសន្យា

ដោយសារតែកតិសន្យា គឺជាប្រភេទកិច្ចសន្យាបន្តបន្ទាប់ដែល ជាមូលហេតុនាំឲ្យភាគីណាមួយ ក្នុងចំណោមភាគីអាចធ្វើការរំលាយ ដោយឯកតោភាគី ដោយគោរពនូវវិធានដែលមានចែងនៅក្នុងច្បាប់។ ក្នុងករណីកតិសន្យាកំណត់អំឡុងពេល ការរំលាយកតិសន្យាអាចធ្វើទៅ បាន នៅពេលដែលពេលវេលានោះនឹងមកដល់តាមការកំណត់ដែល មានចែងក្នុងកិច្ចសន្យា ឬ ដែលមានកំណត់ក្នុងច្បាប់សារធាតុ។

### ៣.១.១. ពេលវេលាមកដល់

នៅក្នុងកតិសន្យាដែលមានកំណត់អំឡុងពេល កតិសន្យានឹងបញ្ចប់នៅពេលដែលអំឡុងពេលនោះមកដល់។ ភាគីណាមួយដែលមានចេតនាចង់បន្តកតិសន្យា ត្រូវជូនដំណឹងដល់ភាគីម្ខាងទៀត។ តាមរយៈក្រមរដ្ឋប្បវេណី ក្នុងករណីភាគីម្ខាងពុំបានបង្ហាញឆន្ទៈបដិសេធក្នុងការ បន្តជាថ្មី ក្នុងរយៈពេលបីខែ សម្រាប់ផ្ទះ អគារ មុនអំឡុងពេលមកដល់ ច្បាប់ត្រូវបានសន្មត់ថាភាគីព្រមបន្តកតិសន្យាទៀត។[134]

លក្ខណៈពិសេស ទាក់ទងនឹងអំឡុងពេលនៃការជួលបន្ទប់ ស្នាក់នៅសម្រាប់ កម្មករ សិស្ស និស្សិត គឺរយៈពេលនៃការជួលអប្បរមា តាមច្បាប់គឺ២ឆ្នាំ ដូច្នេះទោះបីជាកតិបតីបានកំណត់អំឡុងពេលតិចជាងនេះ ក៏កតិកៈ

[134] ម. ៦១៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

នៅតែមានសិទ្ធិបន្តការកាន់កាប់ រហូតដល់រយៈពេលដែលច្បាប់បាន កំណត់។[135]

### ៣.១.២. ការរំលាយដោយភតិបតី

ដោយសារតែការជួលបន្ទប់ស្នាក់នៅកម្មករ សិស្ស និស្សិត ជាភតិសន្យាពិសេសមួយការពារខ្លាំងចំពោះភតិកៈ ទើបភតិបតីមិនអាច ធ្វើការរំលាយមុនកាលកំណត់បានទេ ប្រសិនបើភតិកៈពុំបានប្រព្រឹត្តនៅ កំហុសណាមួយ ដែលមានចែងក្នុងមាត្រា៧នៃច្បាប់ស្ដីពីភតិសន្យា ពិសេស។

មាត្រា៧នៃច្បាប់នេះចែងថា៖ ភតិបតីមានសិទ្ធិរំលាយភតិសន្យាពិសេស បានតែក្នុងករណីណាមួយដូចខាងក្រោម៖

- ភតិកៈមិនបង់ថ្លៃឈ្នួល២(ពីរ)ដង ជាបន្តបន្ទាប់ដោយគ្មាន មូលហេតុសមស្រប។
- ភតិកៈប្រើប្រាស់ និងអាស្រ័យផលលើវត្ថុជួលខុសពីគោលបំណង នៃការជួល។
- ភតិកៈមានចេតនាធ្វើឲ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់ច្រើនលើក និង បង្កឲ្យមានឥទ្ធិពលធ្ងន់ធ្ងរ ដល់ជីវភាពរស់នៅជាប្រក្រតីរបស់អ្នករស់នៅជុំវិញ។
- បន្ទប់ជួលស្នាក់នៅត្រូវជួសជុលធំៗ ឬ សាងសង់ជាថ្មីតាមបញ្ជា របស់អាជ្ញាធរជម្នាន់រូប។

---

[135] ម.៦ ច្បាប់ភតិសន្យាពិសេស ឆ្នាំ២០១៥។

ដូច្នេះភតិបតីដែលមានបំណងចង់ធ្វើការរំលាយភតិសន្យា ត្រូវ លើកយកមូលហេតុណាមួយក្នុងចំណោមមូលហេតុដែលបានរៀបរាប់ខាងលើនេះ។

### ៣.១.៣. ការរំលាយដោយភតិកៈ

ជាគោលការណ៍ការរំលាយកិច្ចអាចប្រព្រឹត្តទៅបាន លុះត្រាតែ មានការព្រមព្រៀងគូភាគីនៃកិច្ចសន្យា ដូចដែលបានកំណត់ក្នុង មាត្រា ៣១១ក្រមរដ្ឋប្បវេណី «កិច្ចសន្យាគឺជាកិរិយាដែលបុគ្គល២នាក់ ឬ ច្រើននាក់មានឆន្ទៈត្រូវគ្នា ព្រមបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច។

ចំណែកភតិសន្យាដែលមិនកំណត់អំឡុង ភាគីម្ខាងអាចធ្វើការស្នើសុំរំលាយបាន លុះត្រាតែមានការជូនដំណឹងដល់ភាគីម្ខាងទៀត ដោយគោរពនូវលក្ខខណ្ឌនៃការជូនដំណឹង ដែលច្បាប់បានកំណត់សម្រាប់អចលនវត្ថុ មានន័យថាភាគីដែលស្នើសុំរំលាយត្រូវជូនដំណឹងជាមុន ៣ខែ។[136]

ចំពោះការជួលបន្ទប់ស្នាក់នៅសម្រាប់កម្មករ សិស្ស និស្សិត គឺមានលក្ខណៈពិសេស ដោយតែមាត្រា៩នៃច្បាប់ស្តីពីភតិសន្យាចែងថា៖ «ភតិកៈមានសិទ្ធិរំលាយភតិសន្យាពិសេសនៅពេលណាក៏បាន»។

បញ្ហាសម្រាប់មាត្រាមួយនេះ គឺទាក់ទងនឹងការជូនដំណឹងនៃ ការរំលាយភតិសន្យា ដោយសារតែក្នុងច្បាប់នេះពុំបានកំណត់អំពីអំឡុង ពេលនៃការជូនដំណឹងទៅដល់ភតិបតី។

---

[136] ម. ៦១៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

មាត្រា៣នៃច្បាប់ស្តីពីភតិសន្យាពិសេស ចែងថា៖ «បទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្ត លើកលែងតែមានកំណត់ផ្សេងក្នុងច្បាប់នេះ»។ ដោយសារតែមាត្រា៩នៃច្បាប់នេះ បានកំណត់ថាភតិកៈអាច **ធ្វើការរំលាយនៅពេលណាក៏បាន** ជាមូលហេតុដែលនាំឲ្យ ករណីយកិច្ចជូន ដំណឹងដែលមានចែងក្នុងក្រមរដ្ឋប្បវេណី មិនត្រូវបានយកអនុវត្តឡើយ នាំឲ្យមានព្យសនៈកម្មទៅដល់ភតិបតីផងដែរ។

## ៣.២. អានុភាពនៃការរំលាយកិច្ចសន្យា

នៅក្នុងច្បាប់ពិសេសឆ្នាំ២០១៥ ពុំបានកំណត់អំពីអានុភាពនៃ ការរំលាយភតិសន្យា ហេតុដូច្នេះក្រមរដ្ឋប្បវេណីត្រូវបានយកអនុវត្ត[137] ដើម្បីដោះស្រាយជុំវិញបញ្ហាទាក់ទងនឹងអានុភាពនៃ ការរំលាយភតិសន្យា ដែលមានដូចជា ករណីយកិច្ចប្រគល់វត្ថុជួល សិទ្ធិរុះរើវត្ថុជួល រួមទាំង អាជ្ញាយុកាលនៃការទាមទារ សំណងខូចខាតបណ្តាលពីការប្រើប្រាស់ របស់ភតិកៈ។

### ៣.២.១. ករណីយកិច្ចប្រគល់វត្ថុជួល

ទោះបីជាច្បាប់ស្តីពីភតិសន្យាពិសេសនេះ ពុំបានចែងក៏ដោយ រាល់ប្រភេទកិច្ចសន្យាបន្តបន្ទាប់ នៅពេលដែលមានការបញ្ចប់កិច្ចសន្យា គឺភាគីម្ខាងត្រូវធ្វើបដិទានវត្ថុត្រឡប់មកវិញ ហើយអានុភាពនៃការរំលាយ កិច្ចសន្យាពុំមានអានុភាពប្រតិសកម្មដូចប្រភេទកិច្ចសន្យាភ្លាមៗនោះទេ។

---

[137] ម.៣ ច្បាប់ភតិសន្យាពិសេស ឆ្នាំ២០១៥។

យោងតាមក្រមរដ្ឋប្បវេណី៖ បើភតិសន្យាត្រូវបានបញ្ចប់ហើយ ភតិកៈមានករណីយកិច្ចធ្វើបដិទានវត្ថុជួលប្រគល់ឲ្យភតិបតីវិញជាបន្ទាន់។ដោយសារតែភតិបតី គឺកម្មសិទ្ធិករនៃទ្រព្យដែលបានដាក់ជួល ចំណែក ភតិកៈ បានបញ្ចប់សិទ្ធិរបស់ខ្លួនក្នុងការកាន់កាប់ និងគ្រប់គ្រងវត្ថុដែលជា មូលហេតុដែលនាំឲ្យភតិកៈ ត្រូវមានករណីយកិច្ចប្រគល់វត្ថុទៅភតិបតី ដែលជាកម្មសិទ្ធិករនៃវត្ថុនោះ។[138]

## ៣.២.២. សិទ្ធិរុះរើសចេញនូវអចលនវត្ថុដោយភ័ព្វព្រេងវាសនា

នៅក្នុងអំឡុងពេលជួល ភតិកៈជួនកាលបានយកចលនវត្ថុទៅ ភ្ជាប់ជាមួយនឹងអចលនវត្ថុ ដែលវត្ថុនោះបានប្រែទៅជាអចលនវត្ថុតាម ភ័ព្វព្រេងវាសនា។ ភាពខុសគ្នារវាងភតិសន្យា និងសិទ្ធិជួលអចិន្ត្រៃយ៍ នៅត្រង់ភតិសន្យាភតិកៈអាចរុះរើចេញនូវវត្ថុ ដែលបានភ្ជាប់ជានឹងវត្ថុជួលនោះបាន នៅពេលបញ្ចប់ភតិសន្យា។[139] សម្រាប់ការជួលបន្ទប់ស្នាក់នៅ កម្មករ សិស្ស និស្សិត ភតិកៈក៏មានសិទ្ធិរុះរើបានយកវត្ថុដែលបានភ្ជាប់ ជាមួយនឹងបន្ទប់ជួល។

## ៣.២.៣. សិទ្ធិទាមទារសំណងខូចខាត

ក្នុងអំឡុងពេលនៃការជួល ប្រសិនជាភតិកៈមានធ្វើឲ្យបាក់បែកខូចខាតវត្ថុជួលខុសពីការប្រើប្រាស់ធម្មតា គឺជាបន្ទុករបស់ភតិកៈក្នុងការ ជួសជុល

[138] ម. ៦១៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[139] ម. ៦១៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

វត្ថុជួលដែលខ្លួនបានធ្វើឲ្យបែកបាក់ខូចខាត ឬ ត្រូវមាន ករណីយកិច្ចសងសំណងនៃការខូចខាតនៃវត្ថុជួលនោះ។[140]

ភតិបតីមានសិទ្ធិទាមទារសំណងខូចខាត ដែលបណ្ដាលមកពី ភតិកៈប្រើប្រាស់ និងអាស្រ័យផលវត្ថុជួល ដែលផ្ទុយនឹងអត្ថន័យដើម នៃកិច្ចសន្យា។ សិទ្ធិទាមទាមសំណងខូចខាតនេះ គឺមានអាជ្ញាយុកាល រយៈពេល១ឆ្នាំគិតចាប់ពីពេលដែលភតិបតីបានទទួលការសងវត្ថុជួល នោះវិញ។[141]

## កថាខណ្ឌ២៖កិច្ចសន្យាជួលរយៈពេលវែងឬសិទ្ធិជួលអចិន្ត្រៃយ៍

ក្រៅពីភតិសន្យា និង ភតិសន្យាពិសេសដែលហៅម្យ៉ាងទៀតថា កិច្ចសន្យាជួលបន្ទប់កម្មករ សិស្ស និស្សិត នៅមានកិច្ចសន្យាជួល មួយប្រភេទទៀតដែលមានលក្ខណៈខុសពីភតិសន្យាទាំងពីរ ដោយសារតែ កិច្ចសន្យានោះមានវិធានពិសេសដែលមានចែងក្នុងក្រមរដ្ឋប្បវេណីដែល ឲ្យឈ្មោះថា «សិទ្ធិជួលអចិន្ត្រៃយ៍»។

មាត្រា ២៤៤ ក្រមរដ្ឋប្បវេណី៖ «សិទ្ធិជួលអចិន្ត្រៃយ៍ គឺសំដៅ ទៅលើសិទ្ធិជួលអចលនវត្ថុរយៈពេលវែង ចាប់ពី១៥ឆ្នាំឡើងទៅ»។ តាមរយៈមាត្រាខាងលើនេះ គឺបានបង្ហាញពីលក្ខណៈពិសេសខុសពីភតិសន្យាទាំងលក្ខខណ្ឌ ក៏ដូចជាអានុភាពនៃសិទ្ធិជួលនេះផងដែរ។

140 ម. ៦១៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

141 ម. ៦២១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

## ១. លក្ខខណ្ឌសុពលភាពនៃសិទ្ធិជួលអចិន្ត្រៃយ៍

ផ្ទុយពីភតិសន្យាពិសេស ឬ កិច្ចសន្យាជួលបន្ទប់ស្នាក់នៅកម្មករ សិស្ស និស្សិត សិទ្ធិជួលអចិន្ត្រៃយ៍ មិនមែនជាប្រភេទកិច្ចសន្យា ដែលយកបុគ្គលជាធំ ឬទាមទារឲ្យមានលក្ខណៈពិសេសនោះទេ សិទ្ធិជួល អចិន្ត្រៃយ៍ ទាមទារនូវលក្ខខណ្ឌពិសេសមួយចំនួនដូចជា៖ វត្ថុដែលជា កម្មវត្ថុនៃកិច្ចសន្យា លក្ខខណ្ឌជាលក្ខណ៍អក្សរ លក្ខខណ្ឌតតាំង រួមទាំង រយៈពេលការរំលាយផងដែរ។

### ១.១. វត្ថុនៃសិទ្ធិជួលអចិន្ត្រៃយ៍

កម្មវត្ថុនៃភតិសន្យា ជាទូទៅអាចជា ចលនវត្ថុ ឬអចលនវត្ថុ ប៉ុន្តែសម្រាប់សិទ្ធិជួលអចិន្ត្រៃយ៍ក៏ដូចជា កិច្ចសន្យាជួលបន្ទប់ស្នាក់នៅ កម្មករ សិស្ស និស្សិត កម្មវត្ថុនៃកិច្ចសន្យាគឺត្រូវតែជា«**អចលនវត្ថុ**»។ អចលនវត្ថុ ដែលជាកម្មវត្ថុនៃសិទ្ធិជួលអចិន្ត្រៃយ៍ មានលក្ខណៈទូលាយជាង កម្មវត្ថុនៅក្នុងភតិសន្យាពិសេស ដែលវត្ថុជួលគឺបានតែបន្ទប់ស្នាក់នៅ តែប៉ុណ្ណោះ។

ពាក្យ «**អចលនវត្ថុ**» ដែលប្រើនៅក្នុងមាត្រា២៤៤ក្រមរដ្ឋប្បវេណី ដែលវត្ថុនៃកម្មវត្ថុសិទ្ធិជួលអចិន្ត្រៃយ៍ គឺអាចជាដីធ្លី ឬអគារតូច ឬធំ។ ក្នុងការអនុវត្តជាក់ស្តែងប្រភេទសិទ្ធិជួលអចិន្ត្រៃយ៍ គឺផ្តោតទៅលើដីធ្លី ជាជាងអគារ។

មូលហេតុដ៏សំខាន់សម្រាប់អ្នកឲ្យជួលសិទ្ធិជួលអចិន្ត្រៃយ៍ គឺ នៅពេលបញ្ចប់សិទ្ធិជួលអចិន្ត្រៃយ៍ អ្នកឲ្យជួលនឹងក្លាយជាទៅកម្មសិទ្ធិករនៃវត្ថុ

ដែលបានធ្វើការកែលម្អ ឬ សំណង់ទាំងមូល[142] ដូចបានកំណត់ នៅក្នុងទ្រឹស្តី«បន្ទាប់បន្សំត្រូវទៅតាមគោល» ដូចដែលមានចែងក្នុង មាត្រា១២២ក្រមរដ្ឋប្បវេណីស្តីពីសមាសភាពនៃដី គឺវត្ថុដែលនៅជាប់នឹងដី ឬ វត្ថុដែលក្លាយជាភាគមួយនៃដី ជាពិសេសអគារ ឬសំណង់ដែលសង់នៅ លើដីហើយមិនអាចប្តូរកន្លែងបាន... គឺជាសមាសភាគនៃដី លុះត្រាតែមិន បំបែកចេញពីដី ហើយមិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិឯករាជ្យបានឡើយ ...»។

## ១.២. រយៈពេលនៃសិទ្ធិជួលអចិន្ត្រៃយ៍

ក្រៅពីវត្ថុរយៈពេលក៏ជាលក្ខខណ្ឌចាំបាច់សម្រាប់សិទ្ធិជួលអចិន្ត្រៃយ៍ផងដែរ។ កតិសន្យា កតិសន្យាពិសេស ឬ កិច្ចសន្យាជួល បន្ទប់កម្មករ សិស្សនិស្សិត រយៈពេលនៃការជួល អាចមានអំឡុងពេល កំណត់ ឬពុំមានអំឡុងពេលកំណត់។ ប៉ុន្តែសម្រាប់សិទ្ធិជួលអចិន្ត្រៃយ៍ ដាច់ខាតត្រូវតែគូភាគីកំណត់អំឡុងពេល បើមិនដូច្នោះទេច្បាប់សន្មត់ ថាជាកតិសន្យាទូទៅដែលមានកំណត់ចាប់ពីមាត្រា៥៩៦ និងបន្តបន្ទាប់។

លក្ខណៈពិសេសមួយទៀតសម្រាប់សិទ្ធិជួលអចិន្ត្រៃយ៍ គឺច្បាប់ បានកំណត់អំពីអំឡុពេលអប្បបរមា និង អតិបរមានៃសិទ្ធិជួលនេះ។ តាមរយៈមាត្រា២៤៤ក្រមរដ្ឋប្បវេណី រយៈពេលនៃសិទ្ធិជួលអចិន្ត្រៃយ៍ ត្រូវបានកើតឡើងនៅពេលដែលរយៈនៃការជួល គឺមានរយៈពេលវែងចាប់ពី ១៥ឆ្នាំឡើងទៅ។

---

[142] ម. ២៥៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

គេអាចធ្វើការបកស្រាយម្យ៉ាងទៀតបានថា សម្រាប់ រយៈពេលអតិបរមានៃភតិសន្យាទូទៅត្រូវ មានរយៈពេលក្រោម១៥ឆ្នាំ។[143]

ចំណុចសំខាន់មួយទៀតនៃសិទ្ធិជួយអចិន្ត្រៃយ៍ គឺរយៈពេល អតិបរមាដែលច្បាប់បានកំណត់។ លក្ខណៈពិសេសនៃសិទ្ធិជួលអចិន្ត្រៃយ៍ គឺច្បាប់បានកំណត់រយៈពេលអតិបរមានៃសិទ្ធិជួល គឺមានត្រឹម៥០ឆ្នាំ តែប៉ុណ្ណោះ។ ទោះបីជាឆន្ទៈរបស់គូភាគីបានកំណត់រយៈពេលលើសពីអ្វី ដែលច្បាប់បានកំណត់ក៏ដោយ ក៏មិនអាចយកឆន្ទៈរួមមកតតាំងបានឡើយ មានន័យថារយៈពេលនៃសិទ្ធិជួលនឹងបន្ថយមកត្រឹម៥០ឆ្នាំ ទោះជាគូភាគី ទាំងសងខាងកំណត់លើសពីនេះក៏ដោយ។

ម្យ៉ាងវិញទៀត រយៈពេលនៃសិទ្ធិជួលអចិន្ត្រៃយ៍នេះគឺច្បាប់ អនុញ្ញាតិឲ្យគូភាគីអាចបន្តរយៈពេលនៃសិទ្ធិជួលអចិន្ត្រៃយ៍នេះសាជាថ្មី។ ក្រមរដ្ឋប្បវេណី មិនបានកំណត់ពីចំនួនដងនៃការបន្តសាជាថ្មីនោះទេ គឺបានត្រឹមតែកំណត់រយៈពេលបន្តសាជាថ្មី ដែលរយៈពេលនោះមានត្រឹម ៥០ឆ្នាំ មានន័យថាគូភាគីអាចបន្តសាជាថ្មីបានច្រើនដង អ្វីដែរសំខាន់ គឺយកថ្ងៃចាប់ផ្តើមដំបូងនៃសិទ្ធិជួលអចិន្ត្រៃយ៍ ធ្វើជាចំណុចគោលក្នុងការ គណនា រយៈពេលនៃការសិទ្ធិជួលអចិន្ត្រៃយ៍ដែលរយៈពេលសរុបទាំងលើក ដំបូងរហូតដល់ការបន្តសាជាថ្មី គឺមានរយៈពេលសរុប១០០ឆ្នាំ។

143 ម. ១០១នៃក្រឹត្យច្បាប់លេខ៣៨ ឆ្នាំ១៩៨៨ បានកំណត់រយៈពេលនៃកិច្ចសន្យាជួល ឬ ភតិសន្យាត្រឹមតែ១២ឆ្នាំតែប៉ុណ្ណោះ។

## ១.៣. ភស្តុតាងបញ្ជាក់អត្ថិភាពនៃសិទ្ធិជួលអចិន្ត្រៃយ៍

ដោយសារតែសិទ្ធិជួលអចិន្ត្រៃយ៍ ជាប្រភេទកិច្ចសន្យាដែល កំណត់អំឡុងពេល និងវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាជាអចលនវត្ថុ ដែល ជាមូលហេតុនាំឲ្យ គូភាគីដែលបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍នេះ ដាច់ខាត ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ[144] ដើម្បីបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិ និងករណីយកិច្ចរបស់អ្នកឲ្យជួលអចិន្ត្រៃយ៍ និង អ្នកជួលអចិន្ត្រៃយ៍។

ការទាមទារឲ្យមានលិខិតជាលាយល័ក្ខណ៍អក្សរ គឺដើម្បីជា ភស្តុតាងមួយដ៏សំខាន់សម្រាប់គូភាគីទាំងសងខាង ជាពិសេសគឺទាក់ទង នឹងលក្ខខណ្ឌនៃការតតាំងជាមួយតតិយជន ដែលជាមូលហេតុតម្រូវឲ្យ មានកិច្ចគតិយុត្តមួយក្រោមទម្រង់ជាលាយល័ក្ខណ៍អក្សរនេះឡើង។

ចំណុចពិសេសមួយទៀតនៃទម្រង់សិទ្ធិជួលអចិន្ត្រៃយ៍ គឺត្រូវធ្វើជាលាយល័ក្ខណ៍អក្សរក្រោមទម្រង់ជា«លិខិតយថាភូត»[145] ដោយសារតែ វត្ថុនៃកម្មវត្ថុនៃសិទ្ធិជួលអចិន្ត្រៃយ៍ គឺជាអចលនវត្ថុ និង សិទ្ធិជួលអចិន្ត្រៃយ៍ មានការធ្វើអនុប្បទានសិទ្ធិកម្មសិទ្ធិ[146] ដែលខុសពីភតិសន្យាទូទៅដែល មានត្រឹមតែការផ្ទេរសិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យផលតែប៉ុណ្ណោះ។

---

[144] ម. ២៤៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[145] តាមរយៈកថាខណ្ឌ២នៃមាត្រា ម. ៣៣៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧៖ កិច្ចសន្យាដែលភាគីម្ខាងទទួលករណីយកិច្ចធ្វើ អនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬ ករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិ លើអចលនវត្ថុនឹងមានអានុភាព លុះត្រាតែបានធ្វើ លិខិតយថាភូត។

[146] ម. ២៥២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ក្នុងករណី គូភាគីមិនបានធ្វើជាលាយលក្ខណ៍អក្សរនោះទេ កិច្ចសន្យាជួលនោះនៅតែមានសុពលភាពដដែល ប៉ុន្តែគូភាគីមិនអាចយក បទប្បញ្ញត្តិសិទ្ធិជួលអចិន្ត្រៃយ៍មកតតាំងបានឡើយ។ ក្នុងករណីនេះច្បាប់ បានសន្មត់ថា ភាគីទាំងសងខាងព្រមព្រៀងចុះភតិសន្យាដែលពុំមានកំណត់ អំឡុងពេល[147] វិធានទាក់ទងនឹងភតិសន្យាទូទៅនឹងគ្របដណ្តប់ ដល់គូភាគី ដែលមានចែងចាប់ពីមាត្រា៥៩៦និងបន្តបន្ទាប់ក្រមរដ្ឋប្បវេណី។

ដូច្នេះគូភាគីម្ខាងក្នុងចំណោមភាគីទាំងពីរ អាចធ្វើការស្នើសុំ បញ្ឈប់ភតិសន្យាពេលណាក៏បាន ដោយគោរពនូវរយៈពេលជូនដំណឹង ដែលច្បាប់បានកំណត់ គឺ៣ខែសម្រាប់អគារ និង ១ឆ្នាំសម្រាប់ដី។[148]

## ១.៤. អត្ថិភាពនៃសិទ្ធិតតាំងជាមួយតតិយជន

ការធ្វើជាលាយលក្ខណ៍អក្សរក្រោមទម្រង់ ជាលិខិតយថាភូត គឺគ្រប់គ្រាន់សម្រាប់គូភាគី តែពុំមានអានុភាពអាចតតាំងពីតតិយជនបាន ដែលខុសពីភតិសន្យាអចលនវត្ថុ នៅពេលដែលភតិកៈបានកាន់កាប់វត្ថុ ច្បាប់បើកសិទ្ធិឲ្យភតិកៈក្នុងការតតាំងពីការរំខានរបស់តតិយជន។

មាត្រា៥៩៨ក្រមរដ្ឋប្បវេណីបានចែងថា៖ «ដោយយោងតាម លទ្ធកម្មនៃការកាន់កាប់ និង ការប្រើប្រាស់និងអាស្រ័យផលជាបន្តបន្ទាប់ នូវវត្ថុជួល

---

[147] ម. ២៤៥ កថាខណ្ឌ២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧៖ «សិទ្ធិជួលអចិន្ត្រៃយ៍ដែលត្រូវបានបង្កើត ឡើងដោយពុំបានធ្វើជាលាយលក្ខណ៍អក្សរ ត្រូវចាត់ទុកថាជា**ភតិសន្យាដែលពុំមានកំណត់អំឡុង ពេល** ហើយអាចត្រូវបានបញ្ឈប់ ដោយភាគីម្ខាងនៅពេលក៏បាន ដោយផ្អែកតាមបញ្ញត្តិ នៃមាត្រា ៦១៥( ការស្នើសុំឲ្យរំលាយភតិសន្យាដែលពុំមានកំណត់អំឡុពេល )នៃក្រមនេះ»។

[148] ម. ៦១៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ភតិកៈនៃភតិសន្យាអចលនវត្ថុ អាចតតាំងចំពោះជនដែលបាន ធ្វើលទ្ធកម្មនូវសិទ្ធិប្រត្យក្សលើអចលនវត្ថុ នៅក្រោយពេលដែលភតិកៈបាន ទទួលការកាន់កាប់បាន»។

ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ ការកាន់កាប់ ប្រើប្រាស់ និង អាស្រ័យផលរបស់អ្នកជួលអចិន្ត្រៃយ៍ គឺពុំគ្រប់គ្រាន់ក្នុងការតតាំងជាមួយ តតិយជនឡើយ ច្បាប់តម្រូវឲ្យមានការចុះបញ្ជីបន្ថែមពីលើការសរសេរជា លាយល័ក្ខណ៍អក្សរនៃសិទ្ធិជួលអចិន្ត្រៃយ៍។[149]

ក្រោយពីបានចុះបញ្ជីលើសិទ្ធិជួលអចិន្ត្រៃយ៍ ច្បាប់ការពារសិទ្ធិ អ្នកជួលអចិន្ត្រៃយ៍ ដោយអាចតតាំងនឹងអនុប្បទានិកនៃកម្មសិទ្ធិដីដែលជា កម្មវត្ថុនៃសិទ្ធិជួលអចិន្ត្រៃយ៍បាន ទោះបីជាកម្មសិទ្ធលើដីនោះត្រូវបានធ្វើ អនុប្បទានក៏ដោយ។

ក្នុងករណីដែលសិទ្ធិជួលអចិន្ត្រៃយ៍មិនបានចុះបញ្ជី កថាខណ្ឌ៣ មាត្រា២៤៦នៃក្រមរដ្ឋប្បវេណី បានផ្តល់សិទ្ធិដល់អ្នកជួលអចិន្ត្រៃយ៍ ដូច ក្នុងករណីភតិកៈនៃភតិសន្យាអចលនវត្ថុ ដែលមានចែងក្នុងមាត្រា៥៩៨ នៃក្រម។ ការទាមទារឲ្យបញ្ឈប់ការរំខានពីតតិយជនក្នុងការប្រើប្រាស់ និង អាស្រ័យផលពីវត្ថុជួលគឺមានតែត្រឹមរយៈពេល១៥ឆ្នាំប៉ុណ្ណោះ គិតចាប់ពី ថ្ងៃទទួលបានសិទ្ធិជួលអចិន្ត្រៃយ៍ ទោះបីជាសិទ្ធិជួលអចិន្ត្រៃយ៍មាន រយៈពេលលើសពី១៥ឆ្នាំក៏ដោយ។

---

149 ម. ២៤៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

## ២. អានុភាពនៃសិទ្ធិជួលអចិន្ត្រៃយ៍

នៅពេលដែលអ្នកឲ្យជួលអចិន្ត្រៃយ៍ និងអ្នកជួលអចិន្ត្រៃយ៍បាន បំពេញនូវលក្ខខណ្ឌដែលបានរៀបរាប់ ក្នុងចំណុច«ក»ខាងលើ នាំឲ្យសិទ្ធិ និង ករណីយកិច្ចគូភាគីទាំងសងខាងត្រូវបានកើតឡើង ដូចជាៈ ការប្រគល់ វត្ថុ ការ ផ្ទេសិទ្ធិកម្មសិទ្ធិ ការបង់ថ្លៃឈ្នួល ការធ្វើអនុប្បទានសិទ្ធិជួល អចិន្ត្រៃយ៍ រួមទាំង ការធ្វើប្រាតិភោគសិទ្ធិជួលអចិន្ត្រៃយ៍ ដូចដែលមានចែង ក្នុងក្រមរដ្ឋប្បវេណី។

## ២.១. ការផ្ទេរការកាន់កាប់ និងសិទ្ធិកម្មសិទ្ធិ

នៅពេលដែលការព្រមព្រៀងបានកើតឡើង រួមទាំងគូភាគីបាន ចុះ បញ្ជីនៃសិទ្ធិជួលអចិន្ត្រៃយ៍រួចរាល់ អ្នកឲ្យជួលអចិន្ត្រៃយ៍ត្រូវមាន ករណីយកិច្ច ប្រគល់វត្ថុ ទៅឲ្យអ្នកជួលអចិន្ត្រៃយ៍ធ្វើការកាន់កាប់ដូចជា ជាកម្មសិទ្ធិករនៃវត្ថុ ក្នុងអំឡុងពេលអត្ថិភាពនៃសិទ្ធិជួលអចិន្ត្រៃយ៍។

មាត្រា២៥៣នៃក្រមរដ្ឋប្បវេណីបានចែងថាៈ «អ្នកជួលអចិន្ត្រៃយ៍ អាចអនុវត្តសិទ្ធិទាមទារឲ្យប្រគល់វិញ សិទ្ធិទាមទារឲ្យបញ្ឈប់ការរារាំង និង សិទ្ធិ ទាមទារឲ្យបង្ការជាមុននូវការរារាំង ចំពោះការបំពានសិទ្ធិជួល អចិន្ត្រៃយ៍ ដូច សិទ្ធិដែលកម្មសិទ្ធិករមាន»។ យោងតាមមាត្រានេះ គឺអ្នកឲ្យ ជួលអចិន្ត្រៃយ៍ គឺ មិនត្រឹមតែមានករណីយកិច្ចប្រគល់វត្ថុប៉ុណ្ណោះទេ អ្នកឲ្យ ជួលអចិន្ត្រៃយ៍ត្រូវ ធ្វើការផ្ទេរសិទ្ធិកម្មសិទ្ធិទៅឲ្យអ្នកជួលអចិន្ត្រៃយ៍ ប៉ុន្តែ វាខុសពីកិច្ចសន្យាលក់ ទិញ នៅត្រង់ថាសិទ្ធិជួលអចិន្ត្រៃយ៍ជាប្រភេទនៃ ការផ្ទេរសិទ្ធិកម្មសិទ្ធិដែល មានលក្ខខណ្ឌរំលាយ បានន័យថានៅពេលដែល អំឡុងពេលមកដល់ គឺ លក្ខខណ្ឌរំលាយបានមកដល់ ជាមូលហេតុនាំឲ្យ អ្នកជួលអចិន្ត្រៃយ៍ ត្រូវធ្វើ

បដិទានសិទ្ធិកម្មសិទ្ធិត្រលប់មកអ្នកឲ្យជួល អចិន្ត្រៃយ៍វិញ នៅពេលដែលសិទ្ធិជួលអចិន្ត្រៃយ៍ត្រូវបានបញ្ចប់។

## ២.២. ការបង់ថ្លៃឈ្នួល

ក្រៅពីមានសិទ្ធិគ្រប់គ្រង កាន់កាប់វត្ថុជួល អ្នកជួលអចិន្ត្រៃយ៍ មានករណីយកិច្ចដ៏សំខាន់គឺ ការបង់ថ្លៃឈ្នួល ដើម្បីរក្សាសិទ្ធិកាន់កាប់ ប្រើប្រាស់ និង អាស្រ័យផលលើវត្ថុជួល។ កាលបរិច្ឆេទ ឬពេលវេលានៃ ការបង់ថ្លៃឈ្នួល ជាគោលការណ៍ គឺអនុវត្តទៅតាមការព្រមព្រៀងគូភាគី។

លក្ខណៈពិសេស នៃការបង់ថ្លៃឈ្នួលនៅក្នុងសិទ្ធិជួលអចិន្ត្រៃយ៍ មានភាពស្រដៀងនឹងភតិសន្យា ដែលរយៈពេលនៃការបង់ថ្លៃឈ្នួលកំណត់ ដោយច្បាប់មានភាពប្រែប្រួលទៅលើវត្ថុជួលដូចជា៖ ចលនវត្ថុ ផ្ទះ ឬអគារ គឺត្រូវបង់ជារាងរាល់ចុងខែ សម្រាប់ដីធ្លីវិញគឺជារាងរាល់ចុងឆ្នាំ ចំណែកដី ប្រមូលផលគឺនៅពេលផុតរដូវប្រមូលផល។[150]

ចំពោះសម្រាប់សិទ្ធិជួលអចិន្ត្រៃយ៍វិញ ក្នុងករណីគូភាគីមិនបានកំណត់ពីពេលវេលានៃការបង់ថ្លៃឈ្នួលទេ ច្បាប់បានកំណត់ពីការបង់ថ្លៃ ឈ្នួលគឺធ្វើឡើងជារៀងរាល់ដំណាច់ឆ្នាំសម្រាប់អចលនវត្ថុទូទៅ ចំណែកដី សម្រាប់កសិកម្មដែលទាក់ទងនឹងរដូវប្រមូលផល ការបង់ថ្លៃឈ្នួលនឹងធ្វើ ឡើងនៅក្រោយពេលរដូវប្រមូលផលរួចដោយគ្មានការយឺតយ៉ាវ។[151]

---

[150] ម. ៦១០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[151] ម. ២៤៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ដោយសារតែការជួលមានរយៈពេលវែង ដែលតម្រូវឲ្យគូភាគី ទាំងសង មានសិទ្ធិជជែកពិភាក្សាអំពីតម្លៃឈ្នួលឡើងវិញ នៅក្នុងអំឡុង ពេលដែលសិទ្ធិជួលអចិន្ត្រៃយ៍នៅមានសុពលភាព។ ការចរចាតម្លៃឈ្នួល អាចមានពីរករណី ទៅតាមស្ថានភាពសេដ្ឋកិច្ច និងសង្គមគឺអាចជាការស្នើ សុំតម្លើងថ្លៃឈ្នួល ឬ បន្ថយថ្លៃឈ្នួល។[152] ការស្នើសុំណាមួយ គឺវាពឹងផ្អែក ទៅលើកត្តាតម្លៃទីផ្សារ រយៈពេល ឬ ក៏ស្ថានភាពសង្គម ដូចជាបរិបទក្នុង សម័យកាលកូវិត១៩ ធ្វើឲ្យមានឱនភាពសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរដែលជា មូលហេតុនាំឲ្យកូនបំណុលជាច្រើន អលទ្ធភាព ក្នុងការបំពេញតាវកាលិក របស់ខ្លួន។ ការបាត់បង់ការងារ ការធ្លាក់ចុះភ្ញៀវទេសចរណ៍ ការធ្លាក់ចុះ នៃចរន្តលក់ទិញ បណ្ដាលមកពីជំងឺរាតត្បាតនេះហើយដែលបណ្ដាលឲ្យ អ្នកជួលអចិន្ត្រៃយ៍ទទួលរងផលប៉ះពាល់ពីជំងឺមួយនេះផងដែរ ជាមូលហាតុ នាំឲ្យអ្នកជួលអចិន្ត្រៃយ៍អាចធ្វើការស្នើសុំបន្ថយតម្លៃឈ្នួលទៅកាន់ អ្នកឲ្យ ជួលអចិន្ត្រៃយ៍។

ការស្នើសុំបន្ថយតម្លៃ ឬ តម្លើងតម្លៃឈ្នួល គឺត្រូវធ្វើឡើងនៅ តុលាការក្នុងករណីបើការ ចរចាគូភាគីមិនអាចស្វែងរកចំណុចរួមណាមួយ ក្នុងបន្ថយ ឬ តម្លើងតម្លៃឈ្នួល។ ភាគីដែលស្នើសុំទៅតុលាការ ត្រូវបង្ហាញ ពីភាពមិនសមរម្យនៃតម្លៃ ដោយប្រៀបធៀបជាមួយនឹងស្ថានភាពផ្សេងៗ។

ជាគោលការណ៍តុលាការ ពុំមានសិទ្ធិទៅកែប្រែខ្លឹមសារនៃ កិច្ចសន្យាដែលច្បាប់គូភាគីនោះទេ តុលាការមានសិទ្ធិត្រឹមតែបកស្រាយ ខ្លឹមសារនៃកិច្ចសន្យា នៅពេលដែលខ្លឹមសារមានភាពស្រពិចស្រពិល ប៉ុន្តែក្នុងករណីពិសេសដូចជាករណីភាពប្រែប្រួល តម្លៃឈ្នួលសិទ្ធិជួល អចិន្ត្រៃយ៍នេះ គឺត្រូវបានក្រម

[152] ម. ២៤៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

រដ្ឋប្បវេណីផ្តល់អំណាចជូនតុលាការក្នុង សម្រេចអនុញ្ញាត ឬ មិនអនុញ្ញាតិឲ្យមានការបន្ថយ ឬតម្លើងតម្លៃឈ្នួល។

ដើម្បីឲ្យតុលាការអាចធ្វើការកែប្រែតម្លៃបាន លុះត្រាតែតម្លៃឈ្នួលមានភាពមិនសមរម្យជាមួយស្ថានភាពផ្សេងៗ។[153] ស្ថានភាពផ្សេងៗដែល ក្រមរដ្ឋប្បវេណីបានចែង អាចធ្វើការបកស្រាយដូចអ្វីដែលបានរៀបរាប់ ខាងលើ ដូចជាករណីជំងឺរាលត្បាតកូវិត១៩ដែលធ្វើឲ្យអ្នកជួលអចិន្ត្រៃយ៍ ទទួលរងផលប៉ះពាល់ដោយផ្ទាល់ពីជំងឺនេះ ដែលបណ្តាលឲ្យអ្នកជួល អចិន្ត្រៃយ៍ពុំអាចមានលទ្ធភាពក្នុងការបង់ថ្លៃឈ្នួល ដែលបានកំណត់ក្នុង កិច្ចសន្យា។

## ២.៣. អនុប្បទានសិទ្ធិជួលអចិន្ត្រៃយ៍

លក្ខណៈពិសេសនៃសិទ្ធិជួអចិន្ត្រៃយ៍មួយទៀត គឺការធ្វើ អនុប្បទានសិទ្ធិជួលអចិន្ត្រៃយ៍ ពីអ្នកជួលអចិន្ត្រៃយ៍ទៅឲ្យតតិយជន។ សម្រាប់ភតិសន្យា ការធ្វើអនុប្បទានសិទ្ធិ ឬភតិសន្យាបន្តមិនអាចធ្វើទៅ បានឡើយ ប្រសិនជាគ្មានការយល់ព្រមពីភតិបតី បើមិនដូច្នេះទេភតិបតី មានសិទ្ធិធ្វើការរំលាយភតិសន្យាបាន។[154] ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍វិញ ការធ្វើអនុប្បទានសិទ្ធិគឺធ្វើទៅបានដោយសេរី ពុំចាំបាច់មានការអនុញ្ញាត ពីអ្នកឲ្យជួលអចិន្ត្រៃយ៍នោះទេ។

---

[153] ម. ២៤៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[154] ម. ៦០៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ការធ្វើអនុប្បទានសិទ្ធិជួលអចិន្ត្រៃយ៍នេះ អាចធ្វើតាមរយៈ កិច្ចសន្យាមុជា ឬក៏កិច្ចសន្យាមូលាដែលមានដូចជា កិច្ចសន្យាលក់ទិញ ប្រទានកម្ម ជួលបន្ត ឬ សន្តតិកម្ម។[155]

សម្រាប់អនុប្បទានសិទ្ធិជួលអចិន្ត្រៃយ៍តាមការលក់ទិញ អ្នកជួល អចិន្ត្រៃយ៍អាចអនុប្បទានសិទ្ធិជួលអចិន្ត្រៃយ៍នេះ ដោយពុំចាំបាច់មានការ យល់ព្រមពីអ្នកឲ្យជួលអចិន្ត្រៃយ៍ អនុប្បទាយីក្លាយទៅជាអ្នកជួល អចិន្ត្រៃយ៍ថ្មីបន្តសិទ្ធិ និង ករណីយកិច្ចរបស់អ្នកជួលអចិន្ត្រៃយ៍ចាស់។

អ្នកជួលអចិន្ត្រៃយ៍ក៏អាចធ្វើអនុប្បទានសិទ្ធិរបស់ខ្លួន តាមរយៈ ការធ្វើប្រទានកម្មទៅឲ្យនរណាម្នាក់ ដែលនាំឲ្យបដិគ្គាហកក្លាយទៅជា អ្នកជួលអចិន្ត្រៃយ៍ថ្មីទទួលយកនូវសិទ្ធិ និង ករណីយកិច្ចពីទាយកដែល ជាអ្នកជួលអចិន្ត្រៃយ៍ចាស់។ ក្រៅពីការលក់ទិញ និងប្រទានកម្ម សិទ្ធិជួលអចិន្ត្រៃយ៍ អ្នកជួលអចិន្ត្រៃយ៍ មានសិទ្ធិយកវត្ថុជួលអចិន្ត្រៃយ៍ ទៅជួលបន្តបានផងដែរ ដោយពុំចាំបាច់មានការយល់ព្រមពីអ្នកឲ្យជួល អចិន្ត្រៃយ៍។ អ្នកជួលបន្តនៃសិទ្ធិអចិន្ត្រៃយ៍ ពុំមានករណីយកិច្ចផ្ទាល់ ជាមួយនឹងអ្នកឲ្យជួលអចិន្ត្រៃយ៍ ដែលខុសពីភតិកៈបន្តដែលត្រូវមាន ករណីយកិច្ចផ្ទាល់ជាមួយភតិបតី។[156]

ក្រៅពីការរៀបរាប់ខាងលើង ការធ្វើអនុប្បទានសិទ្ធិជួលអចិន្ត្រៃយ៍ ដែលមានចែងក្នុងមាត្រា២៥២ក្រមរដ្ឋប្បវេណី គឺសិទ្ធិជួលអចិន្ត្រៃយ៍ អាចជាកម្មវត្ថុនៃសន្តតិកម្ម មានន័យថាសន្តតិជនរបស់អ្នកជួលអចិន្ត្រៃយ៍ នឹងមកធ្វើឧបាទេសកម្មកន្លែងរបស់អ្នកជួលអចិន្ត្រៃយ៍ ជាហេតុនាំឲ្យសិទ្ធិ និង

[155] ម. ២៥២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[156] ម. ៦០៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ករណីយកិច្ចរបស់អ្នកជួលអចិន្ត្រៃយ៍ទាំងប៉ុន្មាន ត្រូវផ្ទេរទៅឲ្យ សន្តតិជនតាមរូបមន្តសន្តតិកម្មតាមច្បាប់ ឬសន្តតិកម្មមានបណ្តាំដែល មានចែងក្នុងក្រមរដ្ឋប្បវេណី។

## ២.៤. ប្រាតិភោគសិទ្ធិជួលអចិន្ត្រៃយ៍

គោលការណ៍នៃការធ្វើប្រាតិភោគ មានកំណត់យ៉ាងច្បាស់នៅក្នុងក្រមរដ្ឋប្បវេណី គឺរាល់វត្ថុ ឬសិទ្ធិ ទាំងឡាយណាដែលអាចធ្វើអនុប្បទាន បានទើបអាចក្លាយជាកម្មវត្ថុនៃការធ្វើប្រាតិភោគប្រត្យក្សបាន។[157] នៅក្នុង ចំណុច ២.៣ខាងលើ គឺបានបង្ហាញពីសិទ្ធិរបស់អ្នកជួលអចិន្ត្រៃយ៍ក្នុង ការធ្វើអនុប្បទានសិទ្ធិជួលចិន្ត្រៃយ៍ ដែលជាមូលហេតុដែលនាំឲ្យសិទ្ធិជួល អចិន្ត្រៃយ៍ដូចកម្មសិទ្ធិករ ដែលជាមូលហេតុនាំឲ្យអ្នកជួលអចិន្ត្រៃយ៍ អាច ធ្វើប្រាតិភោគប្រត្យក្សបាន តាមបទបញ្ញត្តិដែលមានកំណត់នៅក្នុងក្រម រដ្ឋប្បវេណី។

ទោះបីជាអ្នកជួលអចិន្ត្រៃយ៍ មិនមែនជាកម្មសិទ្ធិករនៃវត្ថុក៏ដោយ ក៏ក្រមរដ្ឋប្បវេណីអនុញ្ញាតិឲ្យ សិទ្ធិជួលអចិន្ត្រៃយ៍ក្លាយជាកម្មវត្ថុនៃការធ្វើ ប្រាតិភោគប្រត្យក្សតាមរយៈហ៊ីប៉ូតែកបានដែរ។[158] ការដាក់ហ៊ីបូតែកសិទ្ធិ ជួលអចិន្ត្រៃយ៍ប្រព្រឹត្តទៅដូចករណីសិទ្ធិកម្មសិទ្ធិ មានន័យថាកិច្ចសន្យា ហ៊ីបូតែកត្រូវធ្វើក្រោមទម្រង់ជាលិខិតយថាភូត និងត្រូវចុះបញ្ជីនៅក្នុង សៀវភៅបញ្ជីដីធ្លី ដើម្បី

[157] ម. ៧៦៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[158] ម. ៨៤៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ឲ្យម្ចាស់បំណុលហ៊ីប៉ូតែកមានអត្ថិភាព ក្នុងតតាំង ជាមួយនឹងតតិយជនផ្សេងទៀត ដែលជាម្ចាស់បំណុលរបស់អ្នកជួល អចិន្ត្រៃយ៍។[159]

ក្នុងករណីដែលអ្នកជួលអចិន្ត្រៃយ៍ បានដាក់ហ៊ីប៉ូតែកលើសិទ្ធិ ជួលអចិន្ត្រៃយ៍ជាមួយម្ចាស់បំណុលជាច្រើន នៅក្នុងដោះស្រាយលំដាប់ អត្ថិភាពម្ចាស់បំណុលហ៊ីប៉ូតែក គឺផ្អែកទៅតាមពេលវេលាដែលបានចុះបញ្ជី។[160]

ចំពោះករណីសិទ្ធិជួលអចិន្ត្រៃយ៍នៃដីធ្លី ហើយដីធ្លីនោះមាន អគារដែលម្ចាស់កម្មសិទ្ធិករគឺជាតតីយជន ដែលអ្នកជួលអចិន្ត្រៃយ៍នៃដី បានយកសិទ្ធិជួលអចិន្ត្រៃយ៍នោះដាក់ហ៊ីប៉ូតែក ហ៊ីប៉ូតែកដែលបានធ្វើនោះ គឺមានអានុភាពតែនៅលើដីធ្លីតែប៉ុណ្ណោះ ចំណែកអគារដែលជាកម្មសិទ្ធិរបស់ តតីយជនពុំជាប់ហ៊ីប៉ូតែ។[161]

ក្នុងករណីអនុប្បទានសិទ្ធិជួលអចិន្ត្រៃយ៍ ដែលមានជាប់ហ៊ីប៉ូតែក ម្ចាស់បំណុលហ៊ីប៉ូតែក នឹងត្រូវរលត់សិទ្ធិទាមទារនៅពេល តតិយជនជា អនុប្បទាយីនៃសិទ្ធិជួលអចិន្ត្រៃយ៍ដែលមានជាប់ហ៊ីប៉ូតែក បានសង បំណុលទៅម្ចាស់បំណុលហ៊ីប៉ូតែកនៃសិទ្ធិជួលអចិន្ត្រៃយ៍នោះ។[162]

---

159 ម. ៨៤៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

160 ម. ៨៥១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

161 ម. ៨៤៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

162 ម. ៨៦៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ជាគោលការណ៍ រយៈពេលនៃហ៊ីប៉ូតែកមិនត្រូវ លើសពីរយៈពេល នៃសិទ្ធិជួលអចិន្ត្រៃយ៍នោះឡើយ ដោយសារតែនៅពេលបញ្ចប់សិទ្ធិជួលអចិន្ត្រៃយ៍ អ្នកជួលអចិន្ត្រៃយ៍ត្រូវធ្វើបដិទានប្រគល់វត្ថុជួលទៅ អ្នកឲ្យជួលអចិន្ត្រៃយ៍វិញ។

យោងតាមមាត្រា៨៦៦នៃក្រមរដ្ឋប្បវេណី៖ «ពេលដែលបុគ្គល ក្រៅពីកូនបំណុល ឬក្រៅពីអ្នកដែលបានបង្កើតហ៊ីប៉ូតែក បានកាន់កាប់ អចលនវត្ថុហ៊ីប៉ូតែក ដោយមានលក្ខខណ្ឌចាំបាច់សម្រាប់អាជ្ញាយុកាល នៃការទទួលសិទ្ធិ ហ៊ីប៉ូតែកនោះត្រូវរលត់»។ ក្នុងករណីនេះអាចធ្វើការ បកស្រាយបានថា សិទ្ធិជួលអចិន្ត្រៃយ៍គឺជាប្រភេទសិទ្ធិដែលអនុញ្ញាតិឲ្យ អ្នកជួលអចិន្ត្រៃយ៍មានសិទ្ធិកាន់កាប់ ប៉ុន្តែសិទ្ធិនេះគឺមានអាជ្ញាយុកាល តាមរយៈកិច្ចសន្យា ដែលជាមូលហេតុដែលនាំឲ្យនៅពេលបញ្ចប់សិទ្ធិជួល អចិន្ត្រៃយ៍ ហ៊ីប៉ូតែកនោះក៏ត្រូវរលត់ដូចគ្នា។

## ៣. ការបញ្ចប់សិទ្ធិជួលអចិន្ត្រៃយ៍

ការបញ្ចប់សិទ្ធិជួលអចិន្ត្រៃយ៍ប្រព្រឹត្តទៅ ដោយមានមូលហេតុ ជាច្រើនផ្សេងទៀត ក្រៅពីរយៈពេលនៃសិទ្ធិជួលអចិន្ត្រៃយ៍ត្រូវបានមក ដល់ចំណែកអានុភាពនៃការបញ្ចប់សិទ្ធិនេះវិញ គឺដូចគ្នាទោះបីជា មូលហេតុនៃការបញ្ចប់ខុសគ្នាក៏ដោយ។

## ៣.១. មូលហេតុនៃការបញ្ចប់សិទ្ធិជួលអចិន្ត្រៃយ៍

ក្នុងចំណោមមូលហេតុទាំងឡាយ នៃការបញ្ចប់សិទ្ធិអចិន្ត្រៃយ៍ គឺមានពាក់ព័ន្ធនឹងពេលវេលាដែល ដូចទៅនឹងភតិសន្យាដទៃទៀត នៅពេលដែលពេលវេលា បានមកដល់តាមការកំណត់ក្នុងកិច្ចសន្យា។ ក្រៅពីពេលវេលា នៅមានមូលហេតុមួយចំនួនទៀតដូចជា អលទ្ធភាពក្នុង ការបំពេញតាវកាលិករបស់អ្នកជួលអចិន្ត្រៃយ៍ ឬ ពាក់ព័ន្ធនឹងការទាញ យកប្រយោជន៍ពីវត្ថុជួលអចិន្ត្រៃយ៍។

### ៣.១.១. ពេលវេលា

ដូចបានរៀបរាប់ខាងលើ ទាក់ទងនឹងលក្ខខណ្ឌនៃការបង្កើត សិទ្ធិជួលអចិន្ត្រៃយ៍ រយៈពេលនៃសិទ្ធិជួលអចិន្ត្រៃយ៍គឺជាលក្ខខណ្ឌសំខាន់ ក្នុងបង្កើតសិទ្ធិ ពេលវេលាក៏ជាមូលហេតុនៃការបញ្ចប់សិទ្ធិជួលអចិន្ត្រៃយ៍ ផងដែរ។

តាមរយៈមាត្រា ២៤៦ និង ២៤៧ក្រមរដ្ឋប្បវេណី ពេលវេលាដែលកំណត់ដោយគូភាគី ត្រូវស្ថិតនៅក្នុងចន្លោះដែលច្បាប់បានកំណត់រវាង អំឡុងពេលនៃសិទ្ធិជួលអចិន្ត្រៃយ៍អប្បបរមា និងអតិបរមា គឺមានន័យថា ការបញ្ចប់អំឡុងពេលសិទ្ធិជួល មានរយៈពេលពី១៥ឆ្នាំរហូតដល់៥០ឆ្នាំ និង លទ្ធភាពនៃការបន្តរបស់គូភាគីអាចធ្វើរហូតដល់៥០ឆ្នាំម្តងទៀត។ ចំណុចសំខាន់នៃសិទ្ធិជួលអចិន្ត្រៃយ៍ គឺជាប្រភេទសិទ្ធិដែលមានកំណត់ អំឡុងពេលច្បាស់លាស់ ដូច្នេះគូភាគីមិនអាចធ្វើការបញ្ចប់មុនកាល កំណត់បានឡើយ លុះត្រាតែមានមូលហេតុណាមួយដែលមានកំណត់ នៅក្នុងច្បាប់សារជាតុ។

## ៣.១.២. អលទ្ធភាពក្នុងការបង់ថ្លៃឈ្នួល

ក្រៅពីអំឡុងពេលនៃសិទ្ធិជួលអចិន្ត្រៃយ៍ អលទ្ធភាពក្នុងការបង់ថ្លៃឈ្នួលរបស់អ្នកជួលអចិន្ត្រៃយ៍ ក៏ជាមូលហេតុនៃការបញ្ចប់សិទ្ធិជួល អចិន្ត្រៃយ៍នេះ ទោះបីជាអំឡុងពេលដែលបានកំណត់ក្នុងកិច្ចសន្យាមិន ទាន់បានមកដល់ក៏ដោយ។

អលទ្ធភាពក្នុងការបង់ថ្លៃឈ្នួលនេះ គឺដូចនៅក្នុងករណីភតិសន្យាពិសេសកម្មករ សិស្ស និស្សិតផងដែរ គ្រាន់តែរយៈពេលនៃការមិនបង់ ថ្លៃឈ្នួលក្នុងសិទ្ធិជួលអចិន្ត្រៃយ៍មានរយៈពេលវែងជាងភតិសន្យា និង ភតិសន្យាពិសេស។

សម្រាប់ភតិសន្យាពិសេស គឺភតិកៈមិនបានបង់ថ្លៃឈ្នួល២ដង ជាបន្តបន្ទាប់ដោយគ្មានមូលហេតុសមរម្យ គឺជាមូលហេតុនៃការបញ្ចប់ ភតិសន្យា។ ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍វិញ អ្នកឲ្យជួលអចិន្ត្រៃយ៍ អាចរំលាយសិទ្ធិជួលអចិន្ត្រៃយ៍នេះបាន លុះត្រាតែអ្នកជួលអចិន្ត្រៃយ៍មិន បង់ថ្លៃឈ្នួលដែលបានកំណត់ក្នុងអំឡុងពេល៣ឆ្នាំ។[163] រយៈពេលដែល បានកំណត់សម្រាប់សិទ្ធិជួលអចិន្ត្រៃយ៍គឺមានអំឡុងពេលវែងខ្លាំង ដែលធ្វើឲ្យអ្នកឲ្យជួលអចិន្ត្រៃយ៍ខូចប្រយោជន៍សេដ្ឋកិច្ចយ៉ាងខ្លាំង ពីអលទ្ធភាព ក្នុងការបង់របស់កូនបំណុល។

[163] ម. ២៥០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ៣.១.៣. ផលចំណេញសម្រាប់អ្នកជួលអចិន្ត្រៃយ៍ទាបជាងថ្លៃឈ្នួល

ការធ្លាក់ចុះនៃប្រភពចំណូល គឺជាបញ្ហាសំខាន់សម្រាប់កូន បំណុល ដែលជាមូលហេតុសម្រាប់កូនបំណុលក្នុងការបំពេញតាវកាលិក ដោយសារតែ ការទាញប្រយោជន៍ពីវត្ថុដែលប្រើប្រាស់ នេះគឺជាទំនាក់ទំនង រវាងហេតុនិង ផល ដែលជាកត្តានាំឲ្យច្បាប់បានផ្តល់ដំណោះស្រាយឲ្យ កូនបំណុល អាចធ្វើ ការស្នើសុំរំលាយកិច្ចសន្យាបាន។

មូលហេតុនៃការធ្លាក់ផលចំណេញសម្រាប់ អ្នកជួលអចិន្ត្រៃយ៍ គឺស្រ ដៀងនឹងករណីភតិសន្យាផងដែរ ច្បាប់កំណត់ពីលក្ខខណ្ឌក្នុងការ ស្នើសុំ រំលាយកិច្ចសន្យាមុនកាលកំណត់។យោងតាមមាត្រា២៥១នៃក្រមរដ្ឋប្បវេណី៖ «ក្នុងករណីដែលអ្នកជួលអចិន្ត្រៃយ៍មិនបានទទួលចំណេញ សោះពីអចលនវត្ថុ ក្នុងអំឡុងពេល៣ (បី)ឆ្នាំ ដោយសារស្ថានភាពដែល មិនអាចព្យាករទុកជាមុន បាន ឬ ដោយសារប្រធានសក្តិ ឬ ក្នុងករណី ដែលប្រាក់ចំណេញប្រចាំឆ្នាំ ដែល នឹងមកពីអចលនវត្ថុនៅពេលអនាគត ពុំមានលទ្ធភាពអាចលើស ថ្លៃឈ្នួល សម្រាប់មួយឆ្នាំបាន ដោយសារការ ខូចខាតផ្នែកណាមួយនៃអចលនវត្ថុនោះ អ្នកជួលអចិន្ត្រៃយ៍អាចរំលាយ ការជួលអចិន្ត្រៃយ៍នោះបាន»។ តាមរយៈមាត្រា ២៥១ អ្នកជួលអចិន្ត្រៃយ៍ អាចស្នើសុំការរំលាយសិទ្ធិជួលអចិន្ត្រៃយ៍នេះ មុន កាលកំណត់បានដោយ ត្រូវបំពេញលក្ខខណ្ឌមួយចំនួន៖

លក្ខខណ្ឌទីមួយ គឺទាក់ទងនឹងអំឡុងពេល៖ លុះត្រាតែរយៈពេល នៃ ការខាតបង់ពីការជួលអចិន្ត្រៃយ៍រយៈពេល៣ឆ្នាំជាប់គ្នា។បើប្រៀបធៀប ជាមួយ ភតិសន្យាសម្រាប់ដី គឺក្រមរដ្ឋប្បវេណីកំណត់ត្រឹមតែ២ឆ្នាំ ប៉ុណ្ណោះ ដោយ

មាត្រា៦០៦ ចំណុច២ បានកំណត់ថា «ការទទួលផលពីដីជួលបាន តិចជាងថ្លៃឈ្នួលត្រឹមតែ ២ឆ្នាំជាបន្តបន្ទាប់»។

លក្ខខណ្ឌទីពីរ គឺទាក់ទងនឹងមូលហេតុ៖ អ្នកជួលអចិន្ត្រៃយ៍ត្រូវបង្ហាញពីមូលហេតុមួយក្នុងចំណោម មូលហេតុ៣ដែលនាំឲ្យមានការខាត បង់ក្នុងរយៈពេល៣ឆ្នាំគឺ៖

- មូលហេតុទី១គឺ ស្ថានភាពមិនអាចព្យាករទុក ជាមុនបាន
- មូលហេតុទី២គឺ ជាករណីប្រធានសក្តិដូចទៅនឹង ភតិសន្យាសម្រាប់ដី[164]
- មូលហេតុទី៣គឺ ប្រាក់ចំណេញប្រចាំឆ្នាំដែលនឹងបានពីអចលនវត្ថុ នៅពេលអនាគតពុំមានលទ្ធភាពអាចលើសថ្លៃឈ្នួលសម្រាប់មួយឆ្នាំបាន។

លក្ខខណ្ឌទីបី គឺពាក់ព័ន្ធនឹងវត្ថុជួល៖ «គឺការខូចខាតផ្នែកណាមួយនៃអចលនវត្ថុ»។

អ្នកជួលអចិន្ត្រៃយ៍អាចលើកមូលហេតុមួយ ក្នុងចំណោម មូលហេតុទាំងបីខាងលើបាន លុះត្រាតែមូលហេតុទាំងនោះមានជាប់ ពាក់ព័ន្ធផ្ទាល់ជាមួយនឹងវត្ថុជួល ប្រសិនវាជាព្រឹត្តិការណ៍ខាងក្រៅពុំ ពាក់ព័ន្ធនឹងវត្ថុជួល ក៏អ្នកជួលអចិន្ត្រៃយ៍មិនអាចធ្វើការស្នើសុំរំលាយសិទ្ធិ ជួលអចិន្ត្រៃយ៍នេះបានដែរ។

[164] ម. ៦០៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ក្នុងកាលៈទេសៈបច្ចុប្បន្ន នៃសម័យកាលជំងឺរាលត្បាតកូវីត១៩ វាជាគឺកត្តាដែលនាំឲ្យអាជីវកម្ម មួយចំនួនប្រឈមមុខនឹងការធនក្ស័យ ដូចជាអាជីវកម្មទេសចរណ៍ដែលរងផលប៉ះពាល់ពីកូវីត១៩ ធ្វើឲ្យអាជីវករ ពុំមានលទ្ធភាពក្នុងការបង់ថ្លៃឈ្នួលអគារ។ ត្រង់ចំណុចនេះគេអាចនិយាយ បានថា អ្នកជួលអចិន្ត្រៃយ៍ពុំអាចព្យាករទុកជាមុនអំពីស្ថានការដែលបាន កើតឡើង ប៉ុន្តែជំងឺរាលត្បាតនេះមិនបានធ្វើឲ្យខូចខាតនៃអចលនវត្ថុដែល ជាកម្មវត្ថុនៃសិទ្ធិជួលអចិន្ត្រៃយ៍ ជាមូលហេតុនាំឲ្យអ្នកជួលអចិន្ត្រៃយ៍ មិនអាចលើកយកកត្តាខាងក្រៅនេះ មកស្នើសុំរំលាយសិទ្ធិជួលអចិន្ត្រៃយ៍។

## ៣.២. អានុភាពនៃការបញ្ចប់សិទ្ធិជួលអចិន្ត្រៃយ៍

អានុភាពនៃការបញ្ចប់សិទ្ធិជួលអចិន្ត្រៃយ៍ គឺមានចែងក្នុងមាត្រា ២៥៤ និង ២៥៥ក្រមរដ្ឋប្បវេណី។ ការបញ្ចប់សិទ្ធិជួលអចិន្ត្រៃយ៍ គឺដូចនឹងភតិសន្យាដែលតម្រូវឲ្យអ្នកជួលអចិន្ត្រៃយ៍ ត្រូវបដិទានត្រលប់ មកវិញនៅវត្ថុដែលបានកាន់កាប់។[165]

ភាពខុសគ្នារវាងភតិសន្យា និង សិទ្ធិជួលអចិន្ត្រៃយ៍ គឺវត្ថុបន្ទាប់ បន្សំដែលភ្ជាប់នឹងវត្ថុជួល សម្រាប់ភតិសន្យាភតិកៈមានសិទ្ធិរុះរើចេញ នូវវត្ថុដែលភ្ជាប់ទៅវត្ថុដែលជួលនោះបាន[166] ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ អ្នកជួលអចិន្ត្រៃយ៍ពុំមានសិទ្ធិរុះរើវត្ថុដែលភ្ជាប់ឡើយ។ មាត្រា២៥៤-២បានចែងថា៖ «ពេលបញ្ចប់ការជួលអចិន្ត្រៃយ៍ អ្នកឲ្យជួលអចិន្ត្រៃយ៍ អាចទទួលបានកម្មសិទ្ធិលើការកែលំអ ឬ សំណង់ជាអាទិ៍ ដែលអ្នកជួលអចិន្ត្រៃយ៍បានធ្វើ

[165] ម. ២៥៥ និង ម. ៦១៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[166] ម. ៦១៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ចំពោះអចលនវត្ថុ ដោយគ្មានសងប្រាក់សំណងទៅ អ្នកជួលអចិន្ត្រៃយ៍»។ មូលហេតុដែលអាចបកស្រាយ គឺទ្រឹស្តីគោល និង បន្ទាប់បន្សំ ដោយសារតែក្នុងអំឡុងពេលជួលអចិន្ត្រៃយ៍ សិទ្ធិកម្មសិទ្ធិត្រូវ បានផ្ទេរទៅឲ្យអ្នកជួលអចិន្ត្រៃយ៍ ទើបអ្នកជួលអចិន្ត្រៃយ៍មានសិទ្ធិធ្វើ អនុប្បទាន ឬធ្វើការកាយ្យ កែលំអ ឬ សាងសង់សំណង់នៅលើដីជួល អចិន្ត្រៃយ៍ដោយពុំចាំបាច់មានការអនុញ្ញាត ពីអ្នកឲ្យជួលអចិន្ត្រៃយ៍ ដូច្នេះនៅពេលបញ្ចប់សិទ្ធិជួលអចិន្ត្រៃយ៍ សិទ្ធិកម្មសិទ្ធិនៃវត្ថុជួលត្រូវ បានបដិទានមកកាន់អ្នកឲ្យជួលអចិន្ត្រៃយ៍ ដែលជាកត្តាដែលនាំឲ្យវត្ថុ ដែលភ្ជាប់ជាមួយវត្ថុជួលទាំងប៉ុន្មានត្រូវផ្ទេរទៅជាមួយវត្ថុជួលផងដែរ។

ចំពោះការជួលជុលវត្ថុជួលវិញ ក៏មានភាពខុសគ្នារវាង ភតិសន្យា និងសិទ្ធិជួលអចិន្ត្រៃយ៍ផងដែរ។ សម្រាប់ភតិសន្យា ភតិកៈ អាចរួចផុតពីករណីយកិច្ចជួសជុលវត្ថុ ប្រសិនជាការខូចខាតគឺកើតឡើង ដោយសារការប្រើប្រាស់ជាធម្មតាតែប៉ុណ្ណោះ រាល់ការខូចខាតផ្សេងៗ ក្រៅពីការប្រើប្រាស់ធម្មតា ភតិកៈត្រូវទទួលបន្ទុកជួលជុល ឬ សំណង នៃការខូចខាតនោះទៅភតិបតី។[167] ចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ អ្នកឲ្យ ជួលអចិន្ត្រៃយ៍អាចទាមទារឲ្យធ្វើបដិទានបាន លុះត្រាតែអ្នកជួល អចិន្ត្រៃយ៍បានបំផ្លាញអចលនវត្ថុ ឬបានបំប្លែងជាសារវន្តនូវលក្ខណៈ នៃអចលនវត្ថុ។[168] ផ្ទុយទៅវិញការប្រើប្រាស់ដែលបានធ្វើឲ្យខូចខាតទៅ លើវត្ថុជួល អ្នកជួលអចិន្ត្រៃយ៍ពុំមានករណីយកិច្ចជួលជុល ឬសង សំណងខូចខាតនោះឡើយ។

---

[167] ម. ៦១៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[168] ម. ២៥៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

# មេរៀនទី៥

## អំពីកិច្ចសន្យាម៉ៅការ

កិច្ចសន្យាម៉ៅការ ក៏ជាប្រភេទកិច្ចសន្យាដែលប្រើប្រាស់ច្រើន នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដែល ប្រភេទកិច្ចសន្យានេះស្ថិតនៅក្នុង ចំណោមប្រភេទកម្មវត្ថុកិច្ចសន្យាជាសេវាកម្ម។ មាត្រា៦៥២ក្រមរដ្ឋប្បវេណី បានឲ្យនិយមន័យកិច្ចសន្យាម៉ៅការ «គឺជាប្រភេទកិច្ចសន្យាមួយដែលភាគី ម្ខាងមានករណីយកិច្ចសម្រេចការងារដែលបានព្រមព្រៀង ហើយភាគី ម្ខាងទៀតមានករណីយកិច្ចផ្តល់កម្រៃចំពោះលទ្ធផលនៃការងារ ដែលបាន ធ្វើនោះ»។ ប្រសិនជាក្រលែកមើលនិយមន័យមួយនេះ គេនឹងរកឃើញភាព ស្រដៀងគ្នាកិច្ចសន្យាម៉ៅការនេះជាមួយកិច្ចសន្យាមួយចំនួនទៀត ដូចជា កិច្ចសន្យាការងារ ឬអាណត្តិជាដើម។

ក្រឹត្យច្បាប់លេខ៣៨ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅ កិច្ចសន្យា ឆ្នាំ១៩៨៨ បានប្រើប្រាស់ឈ្មោះថា «កិច្ចសន្យាសហគ្រាស» ដែលក្រមរដ្ឋប្បវេណីបច្ចុប្បន្នបានប្តូរមកជា កិច្ចសន្យាម៉ៅការ។ មាត្រា ៧២ នៃក្រឹត្យច្បាប់នេះបានចែងថា៖«កិច្ចសន្យាសហគ្រាស ជាកិច្ចសន្យាដែល បុគ្គលមួយទទួលបន្ទុកធ្វើការងារអ្វីមួយឲ្យបុគ្គលមួយទៀត ដោយយកថ្លៃ សមស្របនឹងទំហំនៃការងារនោះ។» ពាក្យកិច្ចសន្យាសហគ្រាស គឺជាពាក្យ ដែលពុំសូវបានគេយកប្រើប្រាស់នោះទេ ដោយសារតែពាក្យសហគ្រាស គឺគេតែងតែផ្តោតទៅលើក្រុមហ៊ុន ឬ អាចមានការភ័ន្តច្រឡំជាមួយនឹង កិច្ចសន្យាក្រុមហ៊ុនដែល មានចែងក្នុងក្រមរដ្ឋប្បវេណី។

កិច្ចសន្យាម៉ៅការ ឬកិច្ចសន្យាសហគ្រាស អាចមានច្រើនទម្រង់ ច្រើនសណ្ឋាន ដែលភាគច្រើនគេតែងតែផ្សាភ្ជាប់កិច្ចសន្យាម៉ៅការនេះ ជាមួយនឹងការសាងសង់សំណង់ ប៉ុន្តែកិច្ចសន្យាម៉ៅការនេះ គឺលាតសន្ធឹង ច្រើនជាងនេះ ដែលមុខរបរជាច្រើនមានទំនាក់ទំនងជាមួយកិច្ចសន្យា ម៉ៅការនេះដែលមានដូចជា៖ ជាងជួលជុលស្បែកជើង កាបូប ជាងសំណង់ ជាងជួលជុលយានយន្ត ជាងឈើ ជាងកាត់ដេរ រួមទាំងមុខរបរផ្សេងទៀត ដែរពាក់ព័ន្ធនឹងការប្រើប្រាស់បញ្ញា ស្ថាបត្យករ វិស្វករ គ្រូពេទ្យ...។ល។

តាមរយៈការបង្ហាញខាងលើ គេឃើញថាកិច្ចសន្យាម៉ៅការ ឬ កិច្ចសន្យាសហគ្រាស គឺជាប្រភេទកិច្ចសន្យាមួយដែលមានភាពចាំបាច់ ដូចនឹងកិច្ចសន្យាលក់ទិញផងដែរ គឺតម្រូវឲ្យវិធានច្បាប់ដែលមាន ការវិវត្ត ជាពិសេសតម្រូវឲ្យមានវិធានពិសេស សម្រាប់កិច្ចសន្យាម៉ៅការមួយចំនួន បន្ថែមទៀត ដើម្បីការពារផលប្រយោជន៍ភាគីទាំងសងខាង ជាពិសេសគឺ អ្នកប្រើប្រាស់ដែលមិនមែនជាអ្នកជំនាញ។

ដោយសារតែកិច្ចសន្យាម៉ៅការ ឬកិច្ចសន្យាសហគ្រាសមានភាព ស្រដៀងគ្នាជាមួយកិច្ចសន្យាដទៃទៀត ការសិក្សាជាដំបូងគឺផ្តោតទៅលើ ចំណាត់ថ្នាក់កិច្ចសន្យាម៉ៅការ មុននឹងធ្វើការសិក្សាទៅលើលក្ខខណ្ឌ សុពលភាព អានុភាព ក៏ដូចជាការបញ្ចប់កិច្ចសន្យាម៉ៅការផងដែរ។

## ផ្នែកទី១. ចំណាត់ថ្នាក់កិច្ចសន្យាម៉ៅការ

លក្ខណៈពិសេសនៃកិច្ចសន្យាម៉ៅការ គឺអ្នកម៉ៅការត្រូវសម្រេចការងារដែលអ្នកបញ្ជាការបានប្រគល់ឲ្យ ដោយការសម្រេចការងារមាន លក្ខណៈឯករាជ្យ ដោយប្តូមកវិញនៅការទទួលបានប្រាក់កម្រៃការងារ។ ដូច្នេះកិច្ចសន្យាម៉ៅការគឺជាកិច្ចសន្យាមូលាដែលបង្កើតឲ្យមាន «កាតព្វកិច្ច ឲ្យធ្វើ»។

ទោះបីជាក្រមរដ្ឋប្បវេណីមិនបានបញ្ជាក់ថា កិច្ចសន្យាម៉ៅការជាប្រភេទកិច្ចសន្យាមូលាក៏ដោយ ក៏ពុំដែលមានកិច្ចសន្យាម៉ៅការណាមួយ ធ្វើការដោយពុំយកកម្រៃការងារនោះទេ ម្យ៉ាងវិញទៀតនៅក្នុងនិយមន័យ ដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ក៏បានប្រើពាក្យ«កម្រៃ[169]»ផង ដែរ។ មានតែអាណ្ណត្តិទេដែលអាចធ្វើ ការងារដោយយកកម្រៃ ឬ ពុំយក កម្រៃពីការងារដែលសម្រេច។

ភាពខុសគ្នាជាមួយនឹងកិច្ចសន្យាលក់ទិញ កិច្ចសន្យាម៉ៅការ មិនអាចធ្វើការលុបចោល ដោយសារតែមិនអាចកំណត់តម្លៃបាននោះទេ ដែលជាមូលហេតុនាំឲ្យកិច្ចសន្យាម៉ៅការមានធាតុផ្សំបីយ៉ាង៖ កាតព្វកិច្ច ឲ្យធ្វើ សម្រេចការងារ និង ដោយឯករាជ្យ។

### កថាខណ្ឌ១. កាតព្វកិច្ចឲ្យធ្វើ

អ្នកម៉ៅការ**ត្រូវបំពេញការងារដែលវិជ្ជមាន** មានន័យថាអ្នកម៉ៅការ ត្រូវទទួលបន្ទុកសាងសង់ ជួលជុល បង្កើតអ្វីមួយ។ កិច្ចសន្យាម៉ៅការ ឬ កិច្ចសន្យា

[169] ម. ៦៥២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

សហគ្រាស មិនមែនជាប្រភេទកាតព្វកិច្ចមិនឲ្យធ្វើនោះទេ លើកលែងតែវាមាន ផ្សារភ្ជាប់ជាមួយកិច្ចបន្ទាប់បន្សំ ដូចជាករណីយកិច្ច រក្សាការសម្ងាត់ ករណីយកិច្ចមិនប្រកួតប្រជែង។ ការទាមទារនូវកាតព្វកិច្ច ឲ្យធ្វើ គឺត្រូវបានធ្វើ ការបែងចែកជាមួយកិច្ចសន្យាមួយចំនួនដែលស្រដៀង គ្នាដូចជា ភតិសន្យា បញ្ញើរ ឬ លក់ទិញ។

## ១. កិច្ចសន្យាម៉ៅការ និង ភតិសន្យា

អ្នកម៉ៅការត្រូវសម្រេចការងារ ចំណែកភតិបតិត្រូវប្រគល់វត្ថុឲ្យ ភតិកៈ កាន់កាប់ និងអាស្រ័យផល។ គេឃើញថាការបំពេញតាវកាលិក នៅក្នុងកិច្ចសន្យាទាំងពីរគឺមានភាពខុសគ្នាឆ្ងាយ។ ប៉ុន្តែវាមានបញ្ហាមួយ ទាក់ទងនឹងការ ធ្វើចំណាត់ថ្នាក់ ប្រសិនបើការអាស្រ័យផលនោះភ្ជាប់មក ជាមួយសេវាកម្មមួយចំនួន ដូចក្នុងករណីភតិសន្យាអចលនវត្ថុដែលជារោង សំដែង។ ផលប្រយោជន៍នៃការបែងចែកភាពខុសគ្នាវាងមានច្រើន៖

**ចំពោះសុពលភាពនៃកិច្ចសន្យា៖** ប្រសិនជាកិច្ចនោះជាភតិសន្យា តម្លៃ ត្រូវតែកំណត់ឲ្យបាន ប៉ុន្តែប្រសិនជាកិច្ចនោះជាកិច្ចសន្យាម៉ៅការ តម្លៃអាចមិន ត្រូវបានកំណត់នៅពេលចុះកិច្ចសន្យា។

**ចំពោះការទទួលខុសត្រូវ៖** សម្រាប់ភតិសន្យា គឺលទ្ធផលចេញ មកពី ការមិនអនុវត្តករណីយកិច្ចប្រគល់វត្ថុដើម្បីអាស្រ័យផល ចំណែក កិច្ចសន្យាម៉ៅការ គឺទាក់ទងនឹងករណីយកិច្ចសម្រេចការងារ។

លក្ខណៈនៃការបែងចែងភាពខុសគ្នាគឺធ្វើទៅលើ៖

**ទ្រឹស្តីគោល និង បន្ទាប់បន្សំ៖** ប្រសិនគោល គឺជាការងារ នាំឲ្យកិច្ចនោះជាកិច្ចសន្យាម៉ៅការ ប្រសិនគោលជាការប្រគល់វត្ថុនាំឲ្យវាជា ភតិសន្យា។

**ម្ចាស់នៃវត្ថុ៖** ប្រសិនជាភតិសន្យានោះអតិថិនជនគឺកាន់កាប់វត្ថុ ដូចជាករណីជួលឡានដែលមានតែកុងឡានមកជាមួយ គឺមានការប្រគល់ វត្ថុទៅឲ្យភតិកៈដែលមានតែកុងឡានមកជាមួយ។ ប្រសិនជាកិច្ចសន្យា ម៉ៅការដោយសារតែអ្នកផ្តល់សេវាគឺនៅមើលថែទាំវត្ថុ ដូចជាពេលដែល ឡានខូចម្ចាស់ឡានយកឡានឲ្យជាងជួសជុល ដែលអ្នកជួសជុលមាន ករណីយកិច្ចមើលថែទាំវត្ថុផងដែរ។

**ការងារ៖** ប្រសិនជាក្រុមហ៊ុនមួយបានប្រគល់សម្ភារៈទៅឲ្យ អ្នកម៉ៅការ និង បានផ្តល់បុគ្គលិកទទួល បន្ទុកក្នុងការប្រើប្រាស់សម្ភារៈ ទាំងនេះ នាំឲ្យគាត់គឺជាភតិកៈ ដោយសារតែគាត់មិនបានប្រើប្រាស់ផ្ទាល់ ទៅលើវត្ថុនោះមានន័យថាគាត់មិនមែនជាម្ចាស់ការងារនោះ។

## ២. កិច្ចសន្យាម៉ៅការ និង កិច្ចសន្យាបញ្ញើ

បញ្ញើ គឺជាប្រភេទកិច្ចសន្យាដែលមានការប្រគល់វត្ថុចំណែក កិច្ចសន្យាម៉ៅការ គឺការងារត្រូវតែសម្រេច។ លក្ខណៈវាយតម្លៃទៅលើ កិច្ចសន្យាទាំងពីរ នេះមានភាពងាយស្រួល ដោយសារតែកិច្ចសន្យាម៉ៅការ គឺអ្នកម៉ៅការត្រូវធ្វើការលើវត្ថុមួយ ចំណែកបញ្ញើវាគ្រាន់តែមានការបដិទាន វត្ថុមកវិញតែប៉ុណ្ណោះ។

ដូចជាករណីដែលម្ចាស់ឆ្កែ ប្រគល់ឲ្យឆ្កែទៅបុគ្គលម្នាក់ទៀត មើលថែទាំ នាំឲ្យវាជាកិច្ចសន្យាបញ្ញើ ប៉ុន្តែប្រសិនជាអ្នកទទួលសត្វឆ្កែនោះ បង្វឹតបង្ហាត់សត្វឆ្កែវាលែងជាកិច្ចសន្យាបញ្ញើទៀត ទង្វើនេះគឺត្រូវបាន ចាត់ទុកជាកិច្ចសន្យាម៉ៅការវិញ។

ការបែងចែកភាពខុសគ្នារវាងកិច្ចសន្យាទាំងពីរ ពុំសូវមាន ផលប្រយោជន៍ប៉ុន្មានក្នុងការអនុវត្តជាក់ស្តែង ដោយសារតែការគ្រប់គ្រងវត្ថុ ឲ្យបានល្អ វាជាទូទៅជាករណីយកិច្ចមួយនៅក្នុងកិច្ចសន្យាម៉ៅការផងដែរ។

## ៣. កិច្ចសន្យាម៉ៅការ និង កិច្ចសន្យាលក់ទិញ

លក្ខណៈនៃកិច្ចសន្យាម៉ៅការ គឺមានពុំមានចំណងអធិភាព ដែលខុសពីកិច្ចសន្យាការងារ និង ពុំមានការតំណាង ដែលខុសពីអាណ្ណត្តិ។ អ្នកម៉ៅការសម្រេចការងារតាមអ្នកបញ្ជាការ ដែលមានលក្ខណៈឯករាជ្យ។

ចំណែកភាពខុសគ្នារវាងកិច្ចសន្យាម៉ៅការ និង កិច្ចសន្យាលក់ ទិញក៏មានដែរៈ អ្នកម៉ៅការគឺសម្រេចការងារ ចំណែកអ្នកលក់ត្រូវប្រគល់ វត្ថុ។ អ្វីដែលពិបាកក្នុងការបែកចែងគឺទាក់ទងនឹងវត្ថុនាពេលអនាគត។

បុគ្គលម្នាក់គាត់បញ្ជាទិញវត្ថុ ដែលត្រូវការផលិតដូចជារទេះរុញ តុទូកៅអី ឬចលនវត្ថុផ្សេងទៀត តើវាជាកិច្ចសន្យាលក់ទិញ ឬ ជាកិច្ចសន្យាម៉ៅការ? បុគ្គលដែសាងសង់អគារះ តើវាជាកិច្ចសន្យាម៉ៅការ ឬ កិច្ចសន្យាលក់ផ្ទះដែលត្រូវសាងសង់?

វាមិនពិបាកក្នុងការបែងចែកទេ ប្រសិនបើអតិថិជនគាត់គឺម្ចាស់វត្ថុដែលគាត់បញ្ជាទិញ ឬគាត់ជាអ្នកប្រគល់សម្ភារៈវាប្រាកដជាកិច្ចសន្យា ម៉ៅការ ហើយក៏មិនមានបញ្ហាក្នុងការចាត់ថ្នាក់ជាកិច្ចសន្យាលក់ទិញ ប្រសិន ជាកិច្ចសន្យាលក់ទិញនោះ គឺជាការលក់វត្ថុដែលត្រូវផលិតដែលតម្រូវឲ្យ មានរយៈពេលមួយក្នុងការប្រគល់វត្ថុ។ ភាពមិនច្បាស់លាស់នៅពេលដែល អ្នកម៉ៅការគាត់ជាម្ចាស់សម្ភារៈ ដែលគាត់ត្រូវផលិតវត្ថុសម្រេចមួយៈ តើវាជា កិច្ចសន្យាលក់ ឬម៉ៅការ? ឧទាហរណ៍ បុគ្គលម្នាក់ទៅកន្លែងជាងកាត់ដេរ ដែលជាងកាត់ដេរជាម្ចាស់ក្រណាត់ ដែលត្រូវកាត់សម្លៀកបំពាក់។

## ៣.១. ផលប្រយោជន៍នៃការបែងចែកកិច្ចសន្យាទាំងពីរ

ផលប្រយោជន៍នៃការបែងចែក គឺមិនមែនត្រឹមតែទាក់ទងនឹង ការបង្កើតកិច្ចសន្យាប៉ុណ្ណោះទេ គឺថែមទាំងមានទំនាក់ទំនងនឹងការអនុវត្ត កិច្ចសន្យាផងដែរ។

ក្នុងដំណាក់កាលបង្កើតកិច្ចសន្យា កិច្ចសន្យាម៉ៅការចំពោះការងារលើចលនវត្ថុ អាចចុះកិច្ចសន្យាដោយពុំចាំបាច់កំណត់ច្បាស់លាស់ពីតម្លៃនោះទេ ដោយសារតែតម្លៃការងារមួយចំនួនវាពិបាកហ្នឹងកំណត់ ដែលជា មូលហេតុនាំឲ្យកិច្ចសន្យានេះ មិនអាចលុបចោលបានដោយសារមូលហេតុ នៃការមិនកំណត់តម្លៃ។ អតិថិជនមិនអាចស្នើសុំតម្លៃមុនបាន និងត្រូវមាន ទំនុកចិត្តលើសប្បិករ ឬជាងជួសជុលដែលជាអ្នកម៉ៅការ។ ផ្ទុយទៅវិញ កិច្ចសន្យាលក់ទិញនឹងលុបចោល ប្រសិនបើជាតម្លៃនៃវត្ថុមិនអាចកំណត់ បាននៅថ្ងៃចុះកិច្ចសន្យា។

ចំពោះអចលនវត្ថុ កិច្ចសន្យាម៉ៅការគឺមានភាពប្រែប្រួលដោយ តម្លៃការងារខុសពីតំលៃដែលបានកំណត់ដំបូង លើកលែងតែគូភាគីធ្វើការ កំណត់តម្លៃជាសរុប។ ទោះជាយ៉ាងណា អ្នកម៉ៅការត្រូវព្យាយាម គោរពទៅ តាមតម្លៃដើមដែលកំណត់ពីដំបូង។ ចំណែកកិច្ចសន្យាលក់ទិញ អចលនវត្ថុ តម្លៃត្រូវតែកំណត់ ឬអាចកំណត់បានតាំងពីពេលចុះ កិច្ចសន្យា។

ចំពោះការអនុវត្តតាវកាលិករបស់គូភាគី ក៏មិនមានលក្ខណៈ ដូចគ្នាទាំងស្រុងដែរ។ ចំពោះកិច្ចសន្យាម៉ៅការ ការបំពេញការងាររបស់ អ្នកម៉ៅការ គឺជាកាតព្វកិច្ចលទ្ធផលដែលលទ្ធផលដាច់ខាតត្រូវតែវិជ្ជមាន។ អ្នកម៉ៅការសន្យាអនុវត្តការងារ និង ការអនុវត្តការងារនេះត្រូវតែស្របតាម ទៅតាមខ្លឹមសារដែលបានចែង ឬ តាមរយៈទំនៀមទំលាប់។ ការរួចផុតពី ការទទួលខុសត្រូវ គឺអាចបានលុះត្រាតែក្នុងការងារដែលមិនអនុវត្តនោះ មានចែងនៅក្នុងកិច្ចសន្យា។

អ្នកម៉ៅការត្រូវទទួលខុសត្រូវក្នុងការប្រគល់វត្ថុ ដែលខ្លួនបាន សម្រេច ឬ/និងផ្តល់ប្រឹក្សាដល់អ្នកបញ្ជាការ។ អ្នកម៉ៅការ ត្រូវជានាលើ វិការៈការងារដែលអ្នកម៉ៅការបានបំពេញ។ ចំណែកអ្នកលក់ត្រូវធានា ទៅលើវិការៈនៃវត្ថុ។ ចំពោះហានិភ័យ កិច្ចសន្យាម៉ៅការទាក់ទងនឹងការ ប្រគល់សម្ភារៈ ឬ/និង វត្ថុមានន័យថាអ្នកម៉ៅការដែលផលិតនូវវត្ថុ គឺត្រូវ ទទួលយកហានិភ័យ ចំណែកអ្នកលក់នៅពេលប្រគល់វត្ថុ គឺអ្នកលក់ផ្ទេរ ហានិភ័យទៅអ្នកទិញ។

## ៣.២. លក្ខណៈនៃការបែងចែករវាងកិច្ចសន្យាលក់ទិញ និង កិច្ចសន្យាម៉ៅការ

ការបែងចែកភាពខុសគ្នា គឺអាស្រ័យទៅលើស្ថានភាពជាក់ស្តែង និង ចំណុចសំគាល់ដែលត្រូវបង្ហាញពីការសម្រេចការងារ។

សម្មតិកម្មទី១៖ បើសម្ភារៈប្រគល់ដោយម្ចាស់ការ នៅពេលដែល សម្រេចការងារលើវត្ថុមួយរួច ហើយត្រូវប្រគល់ស្នាដៃ និងសម្ភារៈទៅ ឲ្យម្ចាស់ ការ វាមិនមែនជាកិច្ចសន្យាលក់ទិញនោះទេ ដោយសារតែ អ្នកម៉ៅការគ្រាន់តែ បំពេញការងារទៅតាមអ្វីដែលម្ចាស់ការបានប្រាប់។

ឧទាហរណ៍៖ ការជួសជុលគ្រឿងសង្ហារឹមដែលម្ចាស់ការ បាន ប្រគល់វត្ថុឲ្យជួសជុល ឬនៅពេលដែលកម្មវត្ថុនៃកិច្ចសន្យាគឺជាការ សាងសង់ អគារនៅលើដីដែលម្ចាស់ការគឺជាកម្មសិទ្ធិករ នាំឲ្យការងារដែល សម្រេចនោះ ត្រូវបានចាត់ថ្នាក់ជាកិច្ចសន្យាម៉ៅការ។

សម្មតិកម្មទី២៖ សម្ភារៈដែលត្រូវបានផលិត គឺជាសម្ភារៈរបស់ អ្នកម៉ៅ ការ គឺនាំឲ្យមានកិច្ចសន្យាដល់ទៅពីរ ទាំងកិច្ចសន្យាលក់ទិញ និង កិច្ចសន្យា ម៉ៅការ។ មូលហេតុ៖ អំឡុងពេលនៃការអនុវត្តការងារ គឺត្រូវបាន ចាត់ទុកថាជា កិច្ចសន្យាម៉ៅការ និង ចំណែកកិច្ចសន្យាលក់ទិញ គឺនៅ ក្រោយពេលប្រគល់ វត្ថុ។

## កថាខណ្ឌ២. ភាតព្វកិច្ចឲ្យធ្វើកិច្ចសម្ភារៈ

កិច្ចសន្យាម៉ៅការ គឺស្តែងតាមរយៈការអនុវត្តកិច្ចសម្ភារៈ និងមិន មែនជាកិច្ចគតិយុត្ត។ ការអនុវត្តកិច្ចសម្ភារៈ គឺជាទូទៅធ្វើដោយដៃដូចជា៖ ការជួសជុល ការសាងសង់។ ប៉ុន្តែការអនុវត្តកិច្ចនោះ អាចជាការប្រើបញ្ញា ដូចជា៖ ការគណនា និង គូសប្លង់ដោយវិស្វករ, ការផ្តល់ប្រឹក្សាមេធាវី ក៏ដូចជាការព្យាបាលរបស់គ្រូពេទ្យ។

ការទាមទារឲ្យបំពេញកិច្ចសម្ភារៈ គឺអនុញ្ញាតិឲ្យមានការបែងចែកជាមួយនឹងកិច្ចសន្យាអាណ្ណត្តិ ដែលជួនកាលអ្នកជំនាញអនុវត្តបូកបញ្ចូល គ្នារវាងកិច្ចសន្យាទាំងពីរនេះ។

## ១. ការបែងចែកកិច្ចសន្យាម៉ៅការ និង អាណ្ណត្តិ

ម្ចាស់ការ គឺមិនមានទំនាក់ទំនងជាមួយនឹងកិច្ចដែលអ្នកម៉ៅការ បានចុះជាមួយតតិយជននោះទេ ដូចជាការទិញសម្ភារៈនានា។ តតិយជន ចង់ទាមទារការទទួលខុសត្រូវគឺត្រូវប្តឹងទៅអ្នកម៉ៅការ ដែលនាំឲ្យមាន ភាពខុសគ្នារវាង អាណិត្ត និងម៉ៅការ៖

- ការកាត់បន្ថយម៉ោងសេវារបស់អាណ្ណត្តិគាហក តែមិន មានការកាត់បន្ថយសម្រាប់អ្នកម៉ៅការនោះទេ
- ការរំលាយមុនកាលកំណត់ អាចធ្វើបានចំពោះ អាណ្ណត្តិគាហក ប៉ុន្តែអ្នកម៉ៅការមិនអាចរំលាយមុន កាលកំណត់បានឡើង

- ការទទួលខុសត្រូវគឺមានភាពខុសគ្នាផងដែរ ដោយសារ តែអ្នកម៉ៅការគឺគាត់មានកាតព្វកិច្ចលទ្ធផល ចំណែក អាណ្ណត្តិគាហកគឺមានកាតព្វកិច្ចមធ្យោបាយ។
- អាណ្ណត្តិគាហកធ្វើដើម្បីប្រយោជន៍ និងក្នុងនាមឲ្យ អាណ្ណត្តិទាយក ចំណែកអ្នកម៉ៅការគឺគាត់សម្រេច កិច្ចសម្ភារៈឲ្យម្ចាស់ការដោយគ្មានការតំណាង។

លក្ខណៈវាយតម្លៃមានការលំបាក ដោយសារតែអ្នកដែលបំពេញតាវកាលិក អនុវត្តកិច្ចសម្ភារៈមុននឹងចុះកិច្ចគតិយុត្ត ឧទាហរណ៍៖ ភ្នាក់ងារអចលនទ្រព្យបាននាំអតិថិជនមកមើលទីតាំងជួល ឬលក់។

ត្រង់ចំណុចនេះត្រូវបានចាត់ទុកថាជាអាណ្ណត្តិ លុះត្រាតែឈ្មួញកណ្តាលបានចុះកិច្ចគតិយុត្តមុននឹងអនុវត្តសកម្មភាពរបស់ខ្លួន បើមិន ដូច្នេះទេកិច្ចដែលបានធ្វើត្រូវបាន ចាត់ទុកថាជាកិច្ចសន្យាម៉ៅការ។

## ២. ការបញ្ចូលគ្នារវាងកិច្ចសន្យាម៉ៅការ និង អាណ្ណត្តិ

អ្នកជំនាញម្នាក់ ជួនកាលអាចបូកបញ្ចូលកិច្ចសន្យាទាំងពីរដើម្បីសម្រេចការងាររបស់ខ្លួន។ ដូច្នេះគេត្រូវការវាយតម្លៃកិច្ចទាំងនោះដើម្បីយកវិធានពាក់ព័ន្ធមកអនុវត្ត។

មេធាវីដែលផ្តល់ប្រឹក្សាទៅកាន់អតិថិជនរបស់ខ្លួន រៀបចំឯកសារ (កិច្ចសន្យាម៉ៅការ) និង ការពារក្តីឲ្យកូនក្តីរបស់ខ្លួន(អាណ្ណត្តិ)។

អ្នកម៉ៅការសំណង(កិច្ចសន្យាម៉ៅការ) បានជួយបំពេញនីតិវិធីរដ្ឋបាលសម្រាប់ទទួលបានអាជ្ញាប័ណ្ណសាងសង់ ពីអាជ្ញាធរមានសមត្ថកិច្ច (អាណ្ណត្តិ)។

ស្ថាបត្យករដែលបានគូសប្លង់(កិច្ចសន្យាម៉ៅការ) ចុះកិច្ចសន្យាជាមួយក្រុមហ៊ុនសាងសង់សំណង់ ដើម្បីជាប្រយោជន៍ និង ក្នុងនាមឲ្យ អតិថិជនរបស់ខ្លួន(អាណ្ណត្តិ)។

## កថាខណ្ឌ៣. ភាគព្វកិច្ចឲ្យធ្វើកិច្ចសម្ភារៈដោយគ្មានចំណងអធិនភាព

អ្នកម៉ៅការ គឺជាបុគ្គលដែលធ្វើការដោយឯករាជ្យ គាត់មិនបាន ស្ថិតក្រោមចំណងអធិនភាពនៃម្ចាស់ការ។ វាជាមូលហេតុដែលនាំឲ្យមាន ការបែងចែងយ៉ាងច្បាស់រវាងកិច្ចសន្យាម៉ៅការ និង កិច្ចសន្យាការងារ។

ការជាប់ចំណងអធិនភាព គឺកើតឡើងចំពោះកម្មករនិយោជិត ដែលជាលក្ខណៈសំគាល់នៃកិច្ចសន្យាការងារ។ ជាតុផ្សំនេះហើយដែល ឲ្យមានការផ្តាច់ចេញយ៉ាងច្បាស់រវាងកិច្ចសន្យាម៉ៅការ និង កិច្ចសន្យា ការងារ ប៉ុន្តែលក្ខណៈសំគាល់ខាងលើនេះពេលខ្លះគឺពិបាកក្នុងការអនុវត្ត ដោយសារតែកម្មករនិយោជិតមួយចំនួនអាចរៀបចំការងារដោយខ្លួនឯង ចំណែកឯអ្នកម៉ៅត្រូវទទួលការបញ្ជាច្បាស់លាស់ពីម្ចាស់ការ។

អត្ថប្រយោជន៍នៃការបែងចែករវាងកិច្ចសន្យាទាំងពីរ គឺកម្មករនិយោជិតទទួលបាន អត្ថប្រយោជន៍ពិសេសដែលមានចែងក្នុងច្បាប់ ការងារ ក៏ដូចជាបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យការងារ។ ចំពោះផលប្រយោជន៍ឯកជន គេឃើញថាហានិភ័យនៃការងារត្រូវជាបន្ទុក របស់អ្នកម៉ៅការនៅពេលដែលការងារមានវិការៈ ប៉ុន្តែកម្មករនិយោជិតវិញ មិនទទួលបន្ទុកហានិភ័យនេះទេ។ ចំណែកការទទួលខុសត្រូវ គឺអ្នកម៉ៅការ មានកាតព្វកិច្ចលទ្ធផល ចំណែកកម្មករនិយោជិតទទួលខុសត្រូវតែចំពោះ កំហុសណាដែលជា កំហុសធ្ងន់ធ្ងរតែប៉ុណ្ណោះ។

## ផ្នែកទី២. ការកកើតកិច្ចសន្យាម៉ៅការ

កិច្ចសន្យាម៉ៅការ គឺជាប្រភេទកិច្ចសន្យាចរចាដែលគោរពនូវ វិធានរួមនៃនីតិកាតព្វកិច្ចដូចទៅ គឺត្រូវមានជំនួបសំណើ និងស្វីការ ដែលជាលក្ខខណ្ឌចាំបាច់ក្នុងការបង្កើតកិច្ចសន្យា ដោយរួមជាមួយនឹង ការកំណត់តម្លៃការងារផងដែរ។

## កថាខណ្ឌ១. ជំនួបឆន្ទៈគូភាគី

កិច្ចសន្យាម៉ៅការ បង្កើតឡើងតាមរយៈជំនួបសំណើ និង ស្វីការ។ ប៉ុន្តែរយៈពេលបុព្វកិច្ចសន្យាអាចមានរយៈពេលយូ ដោយសារ តែនៅក្នុងដំណាក់កាលបុព្វកិច្ចសន្យា ភាគីទាំងពីរត្រូវចំណាយ ពេលវេលាក្នុងការចរចា ជាពិសេសម្ចាស់ការ ឬ អតិថិជន ស្នើសុំឲ្យ អ្នកម៉ៅការធ្វើតារាងប៉ាន់ស្មានតម្លៃ(Quotation) ជាមុនដែលជាការប៉ាន់ស្មាន តម្លៃពីការចំណាយទៅលើការងារ។

តើអំឡុងពេលបុព្វកិច្ចសន្យាមានអានុភាពគតិយុត្តិដែរ ឬទេ? អតិថិជន ឬ ម្ចាស់ការមិនត្រូវបានទទួលខុសត្រូវចំពោះការស្នើ តារាងប៉ាន់ស្មានតម្លៃ(Quotation) និងត្រូវបង់ប្រាក់សគុណចំពោះ កិច្ចការវាយតម្លៃនោះទេ លើកលែងតែមានកំណត់ថាត្រូវបង់ប្រាក់ ចំពោះការងារសម្រាប់តារាងប៉ាន់ស្មានតម្លៃនោះ ឧទាហរណ៍៖ ម្ចាស់ការ ចង់ឲ្យស្ថាបត្យករ ប៉ាន់ស្មានតម្លៃពីការតុបតែងបន្ទប់ មានន័យថាភាគី ទាំងសងខាងមិនទាន់ទៅដល់ការ ចុះកិច្ចសន្យាម៉ៅការនៅឡើយ ដែលជួនកាលពេលខ្លះម្ចាស់ការអាច ប្តូរចិត្តឈប់ធ្វើការតុបតែងវិញ ដែលជាមូលហេតុនាំឲ្យភាគីម្ខាងទៀតចំណាយពេលធ្វើការវាយតម្លៃទៅ លើការងារដោយមិនបានទទួលផលពីការងារនោះ។ ដូច្នេះ ស្ថាបត្យករ អាចមានសិទ្ធិស្នើសុំប្រាក់សគុណ សម្រាប់ការគូសប្លង់ដែលអតិថិជន បានស្នើសុំ ដោយសារតែតួនាទីរបស់ស្ថាបត្យករគឺជាអ្នកប្រឹក្សាទៅលើ ប្លង់តុបតែង ឬ កែលម្អ។

តារាងប៉ាន់ស្មានតម្លៃ គឺត្រូវបានចាត់ទុកថាជាការសន្យា ឯកតោភាគីរបស់អ្នកម៉ៅការ។ នៅពេលដែលតារាងប៉ាន់ស្មានតម្លៃ ត្រូវបានទទួលយកដោយភាគីម្ខាងទៀត កិច្ចសន្យាត្រូវបានកកើតឡើង ដោយមានជំនួបសំណើ និង ស្នីការ។

ចំពោះនីតិវិធីនៃការបង្កើតកិច្ចសន្យាម៉ៅការ ជួនកាលមានការប្រកួតប្រជែងគ្នារវាងអ្នកម៉ៅការ ដោយសារមានការដាក់ដេញថ្លៃ ដែលអ្នកម៉ៅការធ្វើសំណើដែលមានតម្លៃទាប ដូចជានីតិវិធីដេញថ្លៃក្នុង លទ្ធកម្មសំណង់របស់រដ្ឋាភិបាលជាដើម។ ការដាក់ដេញថ្លៃលទ្ធកម្ម សាធារណៈបែបនេះ គឺគេនឹងឃើញថាកិច្ចសន្យានឹងបានបង្កើតនៅ ពេលភាគី ដែលជាអ្នក

ម៉ៅការណាមួយបានដាក់តម្លៃទាបជាងគេ។ ចំណែក អ្នកម៉ៅការផ្សេងទៀត ពុំអាចទាមទារតម្លៃការងារទៅលើតារាង ប៉ាន់ស្មានវាយតម្លៃ។

## កថាខណ្ឌ២. ការកំណត់តម្លៃ

ការកំណត់តម្លៃ ជាទូទៅគឺមិនអាចកំណត់បានសម្រាប់ កិច្ចសន្យាម៉ៅការ ប៉ុន្តែគេអាចកំណត់អំពីវិធីកំណត់តម្លៃ មុននឹងឈាន ទៅដល់ការចុះកិច្ចសន្យាម៉ៅការ។

## ១. តម្លៃមិនអាចកំណត់បាន

តាមរយៈក្រមរដ្ឋប្បវេណី កិច្ចសន្យាម៉ៅការ គឺសំដៅទៅលើឆន្ទៈនៃការព្រមព្រៀងរវាងភាគីទាំងពីរ ដែលអ្នកម៉ៅការត្រូវសម្រេចការងារដែល បានកំណត់ក្នុងកិច្ចសន្យា ចំណែកម្ចាស់ការត្រូវមានករណីយកិច្ច ផ្តល់កម្រៃចំពោះលទ្ធផលនៃការងារដែលបានធ្វើនោះ។[170]

ចំណុចសំខាន់នៃកិច្ចសន្យាដែលនាំឲ្យមានសុពភាព គឺទាក់ទង នឹងកម្រៃការងារ ដែលក្រមរដ្ឋប្បវេណី បានកំណត់អំពីពេលវេលាដែល ត្រូវបង់កម្រៃការងារ ប៉ុន្តែពុំបានចែងពីលក្ខខណ្ឌទាក់ទងនឹងការកំណត់ តម្លៃការងារឡើយ។[171] ចំណែកក្រឹត្យច្បាប់លេខ៣៨ឆ្នាំ១៩៨៨បាន កំណត់ថា៖

[170] ម. ៦៥២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[171] ម. ៦៥៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ប្រសិនបើថ្លៃការងារមិនបាន កំណត់ក្នុងកិច្ចសន្យា តុលាការត្រូវវិនិច្ឆ័យកំណត់ថ្លៃទៅតាមទំលាប់នៃកន្លែងធ្វើការនោះ។[172]

ដូចដែលបានលើកឡើងខាងលើ គឺក្រមរដ្ឋប្បវេណីមិនបាន កំណត់លក្ខខណ្ឌពីតម្លៃដូចនឹងកិច្ចសន្យាលក់ទិញនោះទេ ដោយសារតែ នៅក្នុងកិច្ចសន្យាម៉ៅការភាគច្រើន អតិថិជនមិនអាចសួរតម្លៃសរុបបាន ជាមុន ដោយមានទំនុកចិត្តទៅលើអ្នកម៉ៅការ ដូចជាការជួសជុលរថយន្ត ជាដើម ដែលអ្នកម៉ៅការ ជួសជុលឡានពិបាកនឹង ប៉ាន់ស្មានតម្លៃ ទៅលើការជួសជុល លុះត្រាតែដល់ពេលអនុវត្តកិច្ចសន្យាទើបអ្នកម៉ៅការ អាចធ្វើការកំណត់តម្លៃបាន ដូចជាតម្លៃពលកម្មជួលជុលរថយន្ត ឬក៏ ប្រាក់ម៉ោងប្រឹក្សារបស់មេធាវីជាដើម។ ដូច្នេះគេមិនអាចស្នើសុំលុបចោល កិច្ចសន្យាដោយសារតែការមិនបានកំណត់តម្លៃនោះទេ។

ចំណុចដែលលំបាកសម្រាប់កិច្ចសន្យាម៉ៅការ គឺការកំណត់តម្លៃដែលមានការបំពារបំពារដល់ភាគីម្ចាស់ការ ដោយការកំណត់តម្លៃជ្រុល ហួសហេតុបើប្រៀបធៀបទៅនឹងភាពជាក់ស្តែងនៃការងារ។ នៅក្នុង ករណីនេះអតិថិជនដែលជាម្ចាស់ការ មានសិទ្ធិស្នើសុំទាមទារឲ្យបន្ថយថ្លៃ ទៅតាមភាពជាក់ស្តែងនៃការងារ នោះ។[173]

---

[172] ម. ៧៣ ក្រឹត្យច្បាប់លេខ៣៨ ក្រ.ច. ឆ្នាំ១៩៨៨។

[173] ម. ៦៥៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

## ២. របៀបនៃការកំណត់តម្លៃ

នៅក្នុងរបបម៉ៅការសរុប តម្លៃត្រូវបានកំណត់បែបម៉ៅសរុប ដែលមានលក្ខណៈទូទៅ និង ចុងក្រោយបំផុតនៅពេលចុះកិច្ចសន្យា។ តាមរយៈទ្រឹស្តីកិច្ចសន្យា មានន័យថាតម្លៃម៉ៅសរុបគឺមិនអាចធ្វើការកែប្រែបាន ឡើយ។[174] សម្រាប់ម្ចាស់ការដឹងថាករណីយកិច្ចបង់ប្រាក់របស់គាត់មាន ចំនួនប៉ុន្មាន ចំណែកឯអ្នកម៉ៅការគឺទទួលយកហានិភ័យនៅពេលតម្លៃ ជាក់ស្តែងលើពីអ្វីដែលបានកំណត់ក្នុងកិច្ចសន្យា។

ដើម្បីជៀសវាងហានិភ័យសម្រាប់អ្នកម៉ៅការ គឺត្រូវមានចែង ខសន្យាកំណត់តម្លៃស្តីពីបម្រែបម្រួលតម្លៃទៅតាមផលគុណ នៅពេលអនុវត្ត ការងាររបស់អ្នកម៉ៅការ។ ម្យ៉ាងវិញទៀត ម្ចាស់ការអាចយល់ព្រមពីការផ្លាស់ ប្តូតម្លៃនេះបាន ក្នុងលក្ខខណ្ឌសរសេរជាលាយលក្ខណ៍អក្សព្រមព្រៀងរវាង គូភាគីទាំងពីរទៅលើការកែប្រែតម្លៃនេះ ជាជាងការយល់ព្រមដោយ ផ្ទាល់មាត់ដែលអាចមានវិវាទនៅពេលបង់ប្រាក់កម្រៃ។

ក្រៅពីរបបម៉ៅការសរុប នៅមានវិធីសាស្ត្រក្នុងការកំណត់តម្លៃ មួយទៀតទោះបីជាវាមានតម្លៃសរុប ប៉ុន្តែគេកំណត់តម្លៃតាមមុខនីមួយៗ ដោយពឹងផ្អែកទៅលើប្រភេទនីមួយៗនៃការងារដែលត្រូវសម្រេច។ ប្រសិន បើមានការងារថ្មី ដែលចាំបាច់ម្ចាស់ការគឺពុំមានការទទួលខុសត្រូវលើ ការងារបន្ថែមថ្មី លុះត្រាតែម្ចាស់ការយល់ព្រមបន្ថែមតម្លៃទៅលើការងារថ្មី។

---

[174] ម. ៣១១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

## ផ្នែកទី៣. អានុភាពនៃកិច្ចសន្យាម៉ៅការ

កិច្ចសន្យាម៉ៅការបង្កើត ករណីយកិច្ចភាគីទាំងសងខាង ដោយ ជួនកាលវាមានបញ្ហាទៅលើ ការទទួលយកហានិយភ័យផ្សេងៗ ជួនកាលទៀត អ្នកម៉ៅការមិនអនុវត្តផ្ទាល់ដោយខ្លួនឯង ប៉ុន្តែដោយ អ្នកម៉ៅការបន្ត ជាមូល ហេតុដែលនាំឲ្យមានការផ្លាស់ប្តូទំនាក់ទំនងរវាង គូភាគីទាំងសងខាង។

## កថាខណ្ឌ១. ករណីយកិច្ចគូភាគី

ករណីយកិច្ចអ្នកម៉ៅការ និង ម្ចាស់ការ កើតឡើងនៅពេលជំនួប ឆន្ទៈ គូភាគីបានព្រមព្រៀងទៅលើខ្លឹមសារទាំងមូល នៃកិច្ចសន្យាម៉ៅការ រួមទាំងខ សន្យាផ្សេងៗដែលអាចនាំឲ្យភាគីរួចផុតពីការទទួលខុសត្រូវ។

### ១. ករណីយកិច្ចរបស់អ្នកម៉ៅការ

ករណីយកិច្ចរបស់អ្នកម៉ៅការ គឺការអនុវត្តការងារទៅតាម ខ្លឹមសារ នៃកិច្ចសន្យាបានចែង។ ករណីយកិច្ចនេះ គឺជាករណីយកិច្ច ដែលអ្នកម៉ៅ ការត្រូវអនុវត្តដោយពេញលេញ និង គ្មានវិការៈ។

### ១.១. ការងារគ្មានវិការៈរបស់អ្នកម៉ៅការ

ត្រូវបានចាត់ទុកថាការងារគ្មានវិការៈ ប្រសិនបើការងារដែលធ្វើ ដោយ អ្នកម៉ៅការមានលក្ខណៈ ដូចទៅនឹងអ្វីដែលគូភាគីទាំងសងខាង បានព្រម ព្រៀងគ្នានៅពេលចុះកិច្ចសន្យា។

ត្រូវចាត់ទុកថាការងារគ្មានវិការៈផងដែរ ក្នុងករណីដែលការប្រើប្រាស់វត្ថុមានលក្ខណៈត្រឹមត្រូវ ដោយសារនៅពេលចុះកិច្ចសន្យាភាគី ពុំបានកំណត់អំពីលក្ខណៈវត្ថុដែលត្រូវប្រគល់។

ក្នុងករណីមួយទៀតដែលចាត់ទុកថាការងារគ្មានវិការៈ ប្រសិនបើការងារនោះលក្ខណៈប្រក្រតី ដោយសារតែគូភាគីមិនបានកំណត់ពីការ ប្រើប្រាស់នៃវត្ថុ។[175]

ឧទាហរណ៍៖ ជាងកាត់សក់ ប្រសិនជាបើអតិថិជនមិនបានបញ្ជាក់ ពីម៉ូត្រសក់ទេ ជាងកាត់សក់គឺអាចកាត់សក់តាមទម្លាប់អតិថិជនដែលធ្លាប់ មកពីកន្លងមក ការងារដែលសម្រេចចេញគឺត្រូវបានចាត់ទុកថាគ្មានវិការៈ ប្រសិនបើការកាត់នោះមិនធ្វើខូចជើងសក់ ឬកាត់ពុំត្រឹមត្រូវ។

អ្នកម៉ៅការអាចរួចផុតពីការទទួលខុសត្រូ វចំពោះវិការៈនៃការងារ បានប្រសិនវាជាកំហុសរបស់ម្ចាស់ការ មានន័យថាការងារដែលបំពេញនោះ បានបង្កឲ្យមានវិការៈដោយសារតែម្ចាស់ការជាអ្នកផ្តល់សម្ភារៈ ដែលមាន វិការៈ ឬដោយសារតែការបញ្ជារបស់ម្ចាស់ការដែលនាំឲ្យកើតមានវិការៈ ការងារ។ ក្នុងក្រមរដ្ឋប្បវេណីបានបញ្ជាក់ពីពាក្យ«បញ្ជារបស់ម្ចាស់ការ» គឺសំដៅទៅលើការប្រើប្រាស់ពាក្យជាលក្ខណៈបញ្ជាឲ្យធ្វើ ផ្ទុយទៅវិញ ការសំដែងប្រាប់ដែលជាគ្រាន់តែជាបំណងរបស់ម្ចាស់ការ ពុំត្រូវបានចាត់ ទុកជាការបញ្ជាឡើយ។[176]

---

175 ម. ៦៥៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

176 ម. ៦៦០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

## ១.២. ការខារពេញលេញ

ក្រៅពីការធានាវិការៈលើការងារ អ្នកម៉ៅការគឺត្រូវបំពេញកិច្ចឲ្យបានពេញលេញស្របតាមមាត្រា៦៥៥ក្រមរដ្ឋប្បវេណី។ ករណីយកិច្ចនេះគឺ ប្រែប្រួលទៅតាមការងារដែលត្រូវបំពេញ៖ អាចជាផ្តល់តាវកាលិក ជាបញ្ញា ឬ ការងារដោយប្រើកំលាំងទៅលើវត្ថុណាមួយ។

- ការអនុវត្តការងារដោយប្រើប្រាស់បញ្ញា

ចំពោះតាវកាលិកជាបញ្ញា គឺជាការងារដែលត្រូវអនុវត្ត ដែលការងារត្រូវបំពេញមិនមែលទៅលើវត្ថុទេ អ្នកម៉ៅការត្រូវមាន **ករណីយកិច្ចប្រុងប្រយ័ត្ន និង ដោយយកចិត្តទុកដាក់**ដូចជា៖ ភ្នាក់ងារ អចលនទ្រព្យ ការិយាល័យផ្តល់ប្រឹក្សាផ្នែកច្បាប់ ម្ចាស់ការត្រូវបង្ហាញថា អ្នកម៉ៅការមិនបានយកចិត្តទុកដាក់លើការងារចាំបាច់របស់ខ្លួន ដើម្បី អាចឲ្យម្ចាស់ការទាមទារការទទួលខុសត្រូវពីអ្នកម៉ៅការបាន។

ករណីយកិច្ចប្រុងប្រយ័ត្ន និង ដោយយកចិត្តទុកដាក់គឺជាករណីយកិច្ចគោល ដែលមានករណីយកិច្ចបន្ទាប់បន្សំដូចជា **ករណីយកិច្ចសុវត្ថិភាព** ដូចជាជាងធ្វើសក់ត្រូវប្រុងប្រយ័ត្នក្នុងពេលលាយពណ៌សក់ឲ្យអតិថិជន ឬ អ្នករៀបចំទស្សនីយភាពសាធារណៈ ត្រូវធានាពីសុវត្ថិភាពដល់ ទស្សនិកជនដែលចូលទស្សនាកម្មវិធីតន្ត្រី ឬ កម្មវិធីសិល្បៈវប្បធម៌ ជាដើម។

ការងារពេញលេញរបស់អ្នកម៉ៅការ ត្រូវចាត់ចូលក្នុងករណីយកិច្ចមួយទៀត គឺករណីយកិច្ចប្រឹក្សាដូចជា វិស្វករសំណង់ត្រូវផ្តល់ប្រឹក្សា ដល់

ម្ចាស់ការជុំវិញការងារសាងសង់ ឬមេធាវីត្រូវត្រួតពិនិត្យពីស្ថានភាព វត្ថុដែលមាន ឬពុំមានជាប់ហ៊ីប៉ូតែឲ្យអតិថិជនរបស់ខ្លួន។

ចំពោះករណីគ្រូពេទ្យព្យាបាលជំងឺ ជាធម្មតាគាត់មានកាតព្វកិច្ចមធ្យោបាយតែប៉ុណ្ណោះ មានន័យថា គ្រូពេទ្យមានករណីយកិច្ចព្យាបាល ប៉ុន្តែមិនមែនជាធានាអះអាងនឹងព្យាបាលជាសះស្បើយ។ ការបំពេញ តាវកាលិករបស់គ្រូពេទ្យបែបនេះ គឺជាបញ្ហាដ៏លំបាកសម្រាប់អ្នកជំងឺដើម្បី ស្វែងរកកំហុសរបស់គ្រូពេទ្យ។ ការងារបំពេញឲ្យបានពេញលេញសម្រាប់ គ្រូពេទ្យតាមរយៈមាត្រា៦៥៥ក្រមរដ្ឋប្បវេណី គឺជាប្រភេទករណីយកិច្ច ដែលឲ្យឈ្មោះថា **ករណីយកិច្ចផ្តល់ព័ត៌មាន**ទៅអ្នកជំងឺរបស់ខ្លួន ដោយ តម្រូវឲ្យគ្រូពេទ្យធ្វើការវិនិច្ឆ័យរោគសញ្ញា និង ធ្វើការព្យាបាលឲ្យស្រប ទៅតាមទិន្នន័យទទួលបានពីបច្ចេកវិទ្យាវិទ្យាសាស្ត្រ។

ករណីយកិច្ចផ្តល់ព័ត៌មានដល់អ្នកជំងឺ គឺជាភាពចាំបាច់ដែល គ្រូពេទ្យត្រូវបង្ហាញគាត់បានបំពេញករណីយកិច្ចរបស់ខ្លួន។ ដូច្នេះការ បង្ហាញភស្តុតាងគឺជាបន្ទុករបស់គ្រូពេទ្យ ដែលថាខ្លួនបានបំពេញ ករណីយកិច្ចផ្តល់ព័ត៌មានទៅអ្នកជម្ងឺ ឬក្រុមគ្រួសារអ្នកជម្ងឺ ហើយក៏ មិនមែនជាបន្ទុករបស់អ្នកព្យាបាលជំងឺដែលត្រូវបង្ហាញភស្តុតាងនោះទេ។

- ការអនុវត្តការងារដោយប្រើប្រាស់កម្លាំងទៅលើវត្ថុ

អ្នកម៉ៅការត្រូវអនុវត្តការងារឲ្យបានពេញលេញ ទៅលើវត្ថុមួយ ដែលជា**កាតព្វកិច្ចលទ្ធផល**។ អ្នកម៉ៅការសន្យាអនុវត្តការងាររបស់ខ្លួន និងការងារដែលត្រូវបំពេញនោះត្រូវតែស្របទៅតាមអ្វីដែលបាន កំណត់នៅ ក្នុងកិច្ចសន្យា ឬដោយសារការប្រើប្រាស់ ឬដោយវិធានវិជ្ជាជីវៈ។ អ្នកម៉ៅការត្រូវមាន

ទំនួលខុសត្រូវ តាមរយៈកិច្ចសន្យានៅពេលដែលការងារ នោះមិនស្របទៅតាមអ្វីដែលបានចែងក្នុងកិច្ចសន្យា ដូចជាម្ចាស់ការបញ្ជារ ឲ្យធ្វើតុឈើ ដែលលទ្ធផលខុសពីអ្វីដែលបានជជែកគ្នាពីដំបូង។

ដើម្បីអោយអ្នកម៉ៅការរួចផុតពីការទទួលខុសត្រូវ លុះត្រាតែ អ្នកម៉ៅការបង្ហាញថាខ្លួន ពុំមានប្រព្រឹត្តកំហុសណាមួយក្នុងពេលបំពេញ ការងាររបស់ខ្លួន។

ករណីយកិច្ចគោល នៃការអនុវត្តការងាររបស់អ្នកម៉ៅការគឺការ ប្រគល់វត្ថុ(ជាកាតព្វកិច្ចលទ្ធផល) នៅក្នុងស្ថានភាពដូចដែលមានចែងក្នុង កិច្ចសន្យា និងត្រូវថែរក្សាវត្ថុនេះរហូតដល់ថ្ងៃប្រគល់វត្ថុ (ជាកាតព្វកិច្ច មធ្យោបាយ)។

កាតព្វកិច្ចត្រួតស៊ីគ្នានេះ គឺមានបញ្ហាមួយចំនួនសម្រាប់ អ្នកម៉ៅការ ដោយសារតែវត្ថុនោះខូចខាត ដូច្នេះគេត្រូវកំណត់ពេលឲ្យពិតប្រាកដពីការ ខូចខាតនោះ។

- ប្រសើនបើវត្ថុនោះខូចខាតដោយអ្នកម៉ៅការ ក្នុងអំឡុ-ពេល អនុវត្តការងាររបស់ខ្លួន នាំឲ្យវាជាករណីកាតព្វកិច្ច លទ្ធផលកំហុសគឺស្វែងបានយ៉ាងស្រួលសម្រាប់ការ ទទួលខុសត្រូវរបស់អ្នកម៉ៅការ។
- ប្រសិនបើវត្ថុនោះខូចខាត ដោយអ្នកម៉ៅការនៅពេល ថែរក្សាវត្ថុ នេះជាកាតព្វកិច្ចមធ្យោបាយដែលចាំបាច់ត្រូវ ស្វែងរកកំហុសរបស់អ្នកម៉ៅការ។

អ្នកម៉ៅការត្រូវមានករណីយកិច្ចសុវត្ថិភាព និងទទួលខុសត្រូវ ទៅលើព្យសនកម្មដែលបង្កឡើងអំឡុងពេលអនុវត្តការងារ។ អ្នកម៉ៅការ ត្រូវមានករណីយកិច្ចផ្តល់ប្រឹក្សាផងដែរ។

## ២. ករណីយកិច្ចរបស់ម្ចាស់ការ

បើធៀបនឹងអ្នកម៉ៅការ ម្ចាស់ការពុំមានករណីយកិច្ចច្រើននោះទេ ម្ចាស់ការមានករណីយកិច្ច ស្រដៀងនឹងអ្នកទិញដែលមានករណីយកិច្ច ចំនួន៣ដែលមានដូចខាងក្រោម៖

### ២.១. ករណីយកិច្ចទទួលយកវត្ថុ

ម្ចាស់ការត្រូវទទួលយកវត្ថុ ដែលប្រគល់នៅអំឡុងពេលដែលបានកំណត់តាមកិច្ចសន្យា។ តាមរយៈក្រឹត្យច្បាប់លេខ៣៨ ឆ្នាំ១៩៨៨ បានកំណត់ថាការបង់ថ្លៃឈ្នួល គឺស្មើនឹងទទួលយល់ព្រមការងារដែល អ្នកម៉ៅការបានបំពេញ។[177]

### ២.២. ករណីយកិច្ចទទួលយកការងារ

ម្ចាស់ការត្រូវទទួលយកការងារ ប្រសិនបើការងារនោះពេញលេញ និងមិនមានវិការៈ។ ការទទួលយកការងារ មិនត្រូវមានការភ័ន្តច្រឡំ ជាមួយនឹងការប្រគល់វត្ថុនោះទេ។

[177] ម. ៨០ ក្រឹត្យច្បាប់លេខ៣៨ ក្រ.ប. ឆ្នាំ១៩៨៨។

ការទទួលយកការងារ គឺសំដៅទៅលើការយល់ព្រម ឬ ការទទួលស្គាល់ពីការងារនោះដោយម្ចាស់ការ។ ម្ចាស់ការមិនអាចធ្វើការទាមទារ ការទទួលខុសត្រូវ ពីបញ្ហាខូចខាតវត្ថុខាងក្រៅដែលមើលឃើញនោះទេ ក្រោយពេលទទួលស្គាល់ការងារនោះរួច លើកលែងការងារនោះមានវិការៈ អាចកំបាំង ទើបម្ចាស់ការមានសិទ្ធិទាមទារជួលជុលសំណងដែល បណ្តាល មកពីវិការៈនៃវត្ថុនោះ។[178]

សិទ្ធិក្នុងការទាមទារសំណងនេះដែរ គឺមានអាជ្ញាយុកាល១ឆ្នាំ គិតចាប់ពីពេលដែលម្ចាស់ការបានដឹង ឬ គួរបានដឹងអំពីអត្ថិភាពនៃវិការៈ នោះ។[179] ចំណែក ក្នុងក្រឹត្យច្បាប់៣៨ដែលនិរាកណ៍បានទុករយៈពេល ដល់ទៅ៣ឆ្នាំ គិតចាប់ពីថ្ងៃដែលបានទទួលការងារ។[180]

## ២.៣. ករណីយកិច្ចបង់ប្រាក់

ម្ចាស់ការត្រូវបង់ថ្លៃការងារឲ្យទៅអ្នកម៉ៅការ នៅពេលប្រគល់ ឬ ទទួលយកការងារនោះ។ ជួនកាលម្ចាស់ការ ត្រូវបង់មុនពេលចាប់ផ្តើម ការងារក៏មានអាស្រ័យទៅលើការព្រមព្រៀងគូភាគី។

តាមរយៈក្រមរដ្ឋប្បវេណី ការបង់ប្រាក់កម្រៃការងារសម្រាប់ ប្រភេទម៉ៅការជាការប្រើប្រាស់កម្លាំង គឺម្ចាស់ការត្រូវបង់កម្រៃឲ្យទៅ អ្នកម៉ៅការដំណាលគ្នានឹងការប្រគល់វត្ថុ។ ចំពោះករណីពុំមានការចាំបាច់ ក្នុងការប្រគល់វត្ថុ ក្រោយពីបានសម្រេចការងាររួច ម្ចាស់ការត្រូវបង់កម្រៃ ទៅឲ្យអ្នកម៉ៅការ

---

178 ម. ៦៥៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

179 ម. ៦៦១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

180 ម. ៨១ ក្រឹត្យច្បាប់លេខ៣៨ ក្រ.ច. ឆ្នាំ១៩៨៨។

ដែលជាប្រភេទកិច្ចសន្យាម៉ៅការខាងផ្នែកបញ្ញា ដូចជា មេធាវីដែលបានផ្តល់ប្រឹក្សារួចរាល់ អតិថិនជនត្រូវបង់កម្រៃការងារ ជាដើម។[181]

នៅក្នុងករណីតម្លៃការងារមានតម្លៃខ្ពស់ដូចជាការសាងសង់ផ្ទះ ឬ អគារ អ្នកម៉ៅការទាមទារឲ្យមានការធានាដើម្បីរំលត់ការបារម្ភចំពោះ លទ្ធភាពក្នុងការបង់ប្រាក់របស់ម្ចាស់ការ ទោះបីជាបទបញ្ញត្តិកិច្ចសន្យា ម៉ៅការពុំមានចែងក៏ដោយ ក៏អ្នកម៉ៅការអាចធ្វើការតវ៉ាដោយមានការបារម្ភ តាមរយៈវិធានរួមនៃនីតិកាតព្វកិច្ច ដោយប្រកែកមិនព្រមអនុវត្តកាតព្វកិច្ច របស់ខ្លួនបាន ក្នុងករណីដែលមានការបារម្ភដែលគួរឲ្យកត់សម្គាល់ថា ម្ចាស់ការនឹងមិនអនុវត្តតាមខ្លឹមសារនៃកាតព្វកិច្ច។ ប្រសិនជាម្ចាស់ការ បានដាក់ប្រាតិភោគ ឬ ចាត់ចែងវិធានការផ្សេងទៀតដើម្បីរំលត់ការបារម្ភ អ្នកម៉ៅការត្រូវតែចាប់ផ្តើមបំពេញការងាររបស់ខ្លួន។[182]

## កថាខណ្ឌ២. ហានិភ័យក្នុងកិច្ចសន្យាម៉ៅការ

តាមរយៈក្រមរដ្ឋប្បវេណី ហានិភ័យគឺមានចែងនៅក្នុងវិធានរួម ដែលអនុវត្តគ្រប់កិច្ចសន្យា៖ ហានិភ័យគឺ ធ្លាក់ទៅលើកូនបំណុលសម្រាប់ កិច្ចសន្យាអញ្ញមញ្ញ ក្នុងករណីវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាត្រូវបាន បាត់បង់ ឬខូចខាតដោយគ្មានកំហុសរបស់ភាគីទាំងសងខាង មានន័យថា អ្នកម៉ៅការជាគោលការណ៍ គឺជាកូនបំណុលត្រូវទទួលយកហានិភ័យ ដែលបានកើតឡើង។[183]

---

181 ម. ៦៥៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

182 ម. ៣៨៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

183 ម. ៤១៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ដូចជាករណីអ្នកម៉ៅការទស្សនីយភាពសាធារណៈ មិនអាចរៀបចំ កម្មវិធីបានដោយសារតែសិល្បករមានជម្ងឺមិនអាចសំដែងបាន ដូច្នេះ អ្នកម៉ៅត្រូវសងថ្លៃសំបុត្រចូលទស្សនាទៅទស្សនិកជន។

អ្នកម៉ៅការសំណង់អគារ ដែលប្រើប្រាស់សម្ភារៈរបស់ខ្លួន មិនមែនជាការផ្តល់សម្ភារៈដោយម្ចាស់ការ ឬ មានការបញ្ជាពីម្ចាស់ការ អ្នកម៉ៅការត្រូវទទួលយកហានិភ័យនូវពេលដែលខូចខាត ឬបាត់បង់ក្នុង អំឡុងពេលបំពេញកិច្ចរបស់ខ្លួន អ្នកម៉ៅការមិនអាចស្នើសុំឲ្យ ម្ចាស់ការ បង់ប្រាក់ចំពោះសម្ភារៈដែលបាត់បង់នោះទេ។ អ្នកម៉ៅការរួចផុតពី ហានិភ័យបាន លុះត្រាតែអ្នកម៉ៅការបានប្រគល់ការងាររួចរាល់ពេញលេញ និង មិនមានវិការៈឲ្យទៅម្ចាស់ការ។[184]

## កថាខណ្ឌ៣. ការអនុវត្តកិច្ចសន្យាដោយអ្នកម៉ៅការបន្ត

តើកិច្ចសន្យាម៉ៅការ គឺជាប្រភេទកិច្ចសន្យាដែលយកបុគ្គលជាធំ ដែរឬទេ? ព្រោះករណីយកិច្ចអនុវត្តការងារ គឺផ្តោតទៅលើបុគ្គល ដោយសារតែកិច្ចសន្យាម៉ៅការ គឺផ្តោតទៅលើទំនុកចិត្ត ដូចនៅក្នុងក្រឹត្យ- ច្បាប់លេខ៣៨បានបញ្ជាក់ទៀតថា បើអ្នកម៉ៅការជារូបវន្តបុគ្គល ទទួលមរណភាពនាំឲ្យកិច្ចសន្យាត្រូវបានរំលាយ។[185] ឧទាហរណ៍៖ ករណី ជាងកាត់សក់ ឬ ជាងកាត់សំលៀកបំពាក់ ម្ចាស់ការគឺមានទំនុកទៅលើ អ្នកម៉ៅការបានជាព្រមចុះកិច្ចសន្យាម៉ៅការជាមួយ។

[184] ម. ៤១៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[185] ម. ៨២ ក្រឹត្យច្បាប់លេខ៣៨ ក្រ.ច. ឆ្នាំ១៩៨៨។

ប៉ុន្តែករណីខ្លះ ក៏គេឃើញមានការព្រមព្រៀងរវាងអ្នកម៉ៅការ និង អ្នកម៉ៅការបន្តដើម្បីសម្រេចការងារ មួយចំនួនជាពិសេសខាងផ្នែក សំណង់។ សម្រាប់ការសាងសង់អគារ អ្នកម៉ៅការគោលបានហៅក្រុមហ៊ុន ផ្សេងៗដូចជាក្រុមហ៊ុនលាយបាយអក ក្រុមហ៊ុនខួងដី ជាងភ្លើង ជាងទឹក ជាងកំបោរ ។ល។ ដើម្បីសម្រេច ការងារសាងសង់អគារ។

កិច្ចសន្យាម៉ៅការបន្ត គឺជាការផ្ទេរការងារមួយចំនួនទៅឲ្យ អ្នកម៉ៅការបន្ត ប៉ុន្តែទំនួលខុសត្រូវគឺ ធ្វើឡើងរវាងអ្នកម៉ៅការគោល និង ម្ចាស់ការតែប៉ុណ្ណោះ។ កិច្ចសន្យាគោល គឺជាកិច្ចសន្យាម៉ៅការដែលមាន មកជាមួយនូវ កិច្ចសន្យាបន្ទាប់បន្សំមកជាមួយជាពិសេសគឺកិច្ចសន្យា ម៉ៅការបន្ត។

## ផ្នែកទី៤. ការបញ្ចប់កិច្ចសន្យាម៉ៅការ

អាចមានមូលហេតុមួយចំនួន ដែលនាំឲ្យមានការបញ្ចប់ កិច្ចសន្យាម៉ៅការ ដោយសារតែកំហុសរបស់ភាគីណាម្ខាងដែលនាំឲ្យ មានទំនួលខុសត្រូវចំពោះភាគីម្ខាងទៀត។

### កថាខណ្ឌ១. មូលហេតុនៃការបញ្ចប់កិច្ចសន្យាម៉ៅការ

មូលហេតុដែលនាំឲ្យបញ្ចប់កិច្ចសន្យាម៉ៅការ នៅពេលដែលភាគី ទាំងសងខាងបានបំពេញតាវកាលិករបស់ខ្លួន។ ចំណែកករណីមួយទៀត គឺជាសិទ្ធិរបស់ម្ចាស់ការ ក្នុងការសម្រេចចិត្តបញ្ចប់កិច្ចសន្យាម៉ៅការ ដោយសារតែ

កំហុសរបស់អ្នកម៉ៅការ ឬជួលកាលទោះបីជាគ្មានកំហុស របស់អ្នកម៉ៅការ ក៏ម្ចាស់ការអាចសម្រេចបញ្ចប់កិច្ចសន្យាម៉ៅការបាន ផងដែរ។[186]

## ១. កំហុសរបស់អ្នកម៉ៅការ

ក្រមរដ្ឋប្បវេណី កំណត់ពីប្រភេទកំហុសរបស់អ្នកម៉ៅការដែល ឈានទៅរកការរំលាយកិច្ចសន្យាម៉ៅការ។ មូលហេតុទាំងនោះមាន ដូចជា[187]៖

- វិការៈនៃការងាររបស់អ្នកម៉ៅការដែលបានបំពេញ
- ការបំពេញការងារមិនបានពេញលេញ
- ការងារមិនបានសម្រេចទៅតាមការព្រមព្រៀងរវាងភាគីទាំងសង
- ទោះជាការងារបានបំពេញក៏ពិតមែន ប៉ុន្តែការវាយតម្លៃការងារ នោះធ្វើឲ្យខូចប្រយោជន៍ដោយមិនត្រឹមត្រូវចំពោះម្ចាស់ការ
- ចំពោះសំណង់វិញ បើការសាងសង់ដែលបំពេញដោយអ្នកម៉ៅការ គឺមានការវិការៈធ្ងន់ធ្ងរពេល ដែលនាំឲ្យសំណង់ដែលសាងសង់ ពុំមានតម្លៃនឹងប្រើប្រាស់។

## ២. ការរំលាយដោយគ្មានមូលហេតុរបស់ម្ចាស់ការ

ក្រៅពីមូលហេតុខាងលើ ម្ចាស់ការនូវមានសិទ្ធិមួយទៀតក្នុង ការរំលាយកិច្ចសន្យាទោះបីជា អ្នកម៉ៅការមិនបានប្រព្រឹត្តនូវកំហុស ណាមួយ

[186] ម. ៦៦៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[187] ម. ៦៥៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ដែលមានចែងនៅក្នុងមាត្រា៦៥៧ក្រមរដ្ឋប្បវេណី គឺម្ចាស់ការ អាចរំលាយកិច្ចសន្យាម៉ៅការនៅពេលណាក៏បាន។[188]

បញ្ហាគឺការទទួលរងព្យសនកម្មទៅដល់អ្នកម៉ៅការ ដោយសារតែ អ្នកម៉ៅការកំពុងតែចាប់ផ្តើមអនុវត្តការងាររបស់ខ្លួន ជាមូលហេតុដែលនាំ ឲ្យក្រមរដ្ឋប្បវេណីតម្រូវឲ្យការសងសំណងខូចខាត ទៅដល់អ្នកម៉ៅការ ដោយធ្វើការគណនាសំណងខូចខាត គិតចាប់ពីថ្ងៃដែលរំលាយរហូតដល់ ពេលដែលអ្នកម៉ៅការត្រូវសម្រេចការងារនោះ។

## កថាខណ្ឌ២. អានុភាពនៃការបញ្ចប់កិច្ចសន្យាម៉ៅការ

ជាគោលការណ៍ នៅពេលដែលគូភាគីបំពេញតាវកាលិកទាំងមូល ជាមូលហេតុនាំឲ្យសិទ្ធិ និង ករណីយកិច្ច គូភាគីទាំងសងខាងត្រូវបញ្ចប់។ ផ្ទុយទៅវិញនៅពេលកូនបំណុល បានប្រព្រឹត្តនូវកំហុសណាមួយ ជា មូលហេតុឲ្យមានព្យសនកម្មដល់ម្ចាស់បំណុល ដូច្នេះម្ចាស់បំណុល មានសិទ្ធិទាមទារឲ្យមានការទទួលខុសត្រូវ។

ក្រមរដ្ឋប្បវេណីបានចែងពីសិទ្ធិរបស់ម្ចាស់ការ ក្នុងការទាមទារការទទួលខុសត្រូវពីអ្នកម៉ៅការ ដូចជាសិទ្ធិទាមទារឲ្យបន្ថយតម្លៃ សិទ្ធិទាមទារសំណងនៃការខូចខាត ដោយម្ចាស់សិទ្ធិដែលជាម្ចាស់ការត្រូវធ្វើការទាមទារ

[188] ម. ៦៦៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ក្នុងអំឡុងពេល១ឆ្នាំ គិតចាប់ពីពេលដែលម្ចាស់ការបានដឹង ឬ គួរបានដឹង អំពីអត្ថិភាពនៃវិការៈ។[189]

ចំពោះសិទ្ធិទាមទារឲ្យបន្ថយតម្លៃរបស់ម្ចាស់ការ[190] គឺដោយសារ មានវិការៈនៃការងារ ឬ ការងារមិនបានពេញលេញ មិនបានសម្រេច ឬការងារដែលពេញលេញ ប៉ុន្តែការវាយតម្លៃការងារនោះធ្វើឲ្យខូច ប្រយោជន៍ដល់ម្ចាស់ការ ដូច្នេះម្ចាស់ការធ្វើទាមទារនៅក្រោយពេលដែល អំឡុងពេលសមរម្យដែលបានកំណត់ ដើម្បីអនុវត្តការងារឲ្យពេញលេញ នោះបានកន្លងផុត។

គោលការណ៍ដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ក្នុងការបន្ថយកម្រៃការងារ គឺត្រូវធ្វើតាមរូបមន្តសមាមាត្រនៃតម្លៃការងារដែលមានភ្ជាប់ នូវវិការៈ ជាមួយនឹងតម្លៃនៃការងារដែលគ្មានវិការៈនោះ។

ចំពោះសំណងខូចខាតដែលកើតឡើងដោយវិការៈការងារ ឬ ការងារមិនពេញលេញរបស់អ្នកម៉ៅការ ម្ចាស់ការអាចទាមទារនូវសំណង នៃផលប្រយោជន៍ពីការអនុវត្តដែលខ្លួនត្រូវទទួលបានដោយកិច្ចសន្យានោះ ហើយអាចទាមទារផងដែរនូវចំណាយ ដែលគ្មានប្រយោជន៍ដោយសារ តែការមិនអនុវត្ត និង ចំណាយ ឬ បន្ទុកដែលបង្កើតឡើងដោយសារ ការអនុវត្តការងារមិនពេញលេញ ឬវិការៈ។[191]

រាល់ខសន្យាផ្សេងៗដែលបានអំពីការអនុគ្រោះ ឬ កម្រិតការទទួលខុសត្រូវរបស់អ្នកម៉ៅការក៏ដោយ ចំពោះហេតុដែលបានដឹងហើយតែមិន

---

[189] ម. ៦៦១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[190] ម. ៦៥៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[191] ម. ៤០០ និង ម.៦៥៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

រាយការណ៍ អ្នកម៉ៅការមិនអាចរួចផុតពីការទទួលខុសត្រូវ ឬ ការកម្រិតការទទួលខុសត្រូវបានឡើយ។[192]

អ្នកម៉ៅការអាចរួចផុតពីការទទួលខុសត្រូវបាន លុះត្រាតែវិការៈ នៃការងារនោះកើតឡើងពី លក្ខណៈនៃសម្ភារៈដែលបានផ្តល់ដោយ ម្ចាស់ការ ឬ ដោយការបញ្ជារបស់ម្ចាស់ការនោះ។ ផ្ទុយមកវិញប្រសិនបើ អ្នកម៉ៅការបានដឹងអំពីសភាពនៃសម្ភារៈ ឬ ភាពមិនត្រឹមត្រូវនៃការបញ្ជា នោះតែមិនបានផ្តល់ដំណឹង ឬ ផ្តល់ប្រឹក្សានោះទេនាំឲ្យអ្នកម៉ៅការ ទទួលខុសត្រូវចំពោះវិការៈដែលបានកើតឡើង។[193]

[192] ម. ៦៦២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[193] ម. ៦៦០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

# មេរៀនទី៦

## អំពីកិច្ចសន្យាដឹកជញ្ជូន

នៅក្នុងបច្ចុប្បន្នភាពសម័យកាលកូវិត១៩ ការដឹកជញ្ជូនទំនិញ គឺមានសភាពញឹកញាប់ខ្លាំង ដោយសារតែការបំលាស់ទីរបស់បុគ្គលត្រូវ បានកាត់បន្ថយ ជាពិសេសទំនាក់ទំនងរវាងអ្នកលក់ និង អ្នកទិញ នូវតែកើតមាន ឡើង ដោយសារតែមានសេវាកម្មដឹកជញ្ជូនទំនិញ ពីទីកន្លែង របស់អ្នកលក់ទៅទីកន្លែងរបស់អ្នកទិញ។ ទន្ទឹមនឹងការកើនឡើងនៃ ការដឹកជញ្ជូនទំនិញ ការដឹកជញ្ជូនអ្នកដំណើរត្រូវបានធ្លាក់ចុះយ៉ាងខ្លាំង ជាពិសេស សេវាដឹកជញ្ជូនតាមផ្លូវអាកាសដោយសារតែបញ្ហាការរាលត្បាត នៃមេរោគកូវិត១៩។

ពិនិត្យមើលក្រមរដ្ឋប្បវេណី គេពុំឃើញមានបទបញ្ញត្តិណាមួយ ចែងទាក់ទងនឹងកិច្ចសន្យាដឹកជញ្ជូនមិនថាទំនិញ ឬបុគ្គលឡើយ។ ហេតុដូច្នេះហើយបានជា នៅក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី មាត្រា៧៩ចែងថា៖ «ក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច ត្រូវបាត់បង់អានុភាព ចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត លើកលែងតែមាត្រា៨៣ ដល់មាត្រា៨៨ នៃក្រឹត្យ-ច្បាប់លេខ៣៨ក្រ.ច នោះនៅតែមានអានុភាពនៅក្រោយ កាលបរិច្ឆេទនៃការអនុវត្ត រហូតដល់ពេលដែលកំណត់ផ្សេងដោយ ច្បាប់។» មាត្រា៨៣ដល់មាត្រា៨៨នៃក្រឹត្យ-ច្បាប់នេះគឺបញ្ញត្តិទាក់ទងនឹង កិច្ចសន្យាដឹកជញ្ជូន ដោយសារតែក្រមរដ្ឋប្បវេណីពុំបានចែងវិធានទាក់ទង នឹងកិច្ចសន្យាដឹកជញ្ជូន។

យោងតាមមាត្រា៨៣ ក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច កិច្ចសន្យា ដឹកជញ្ជូន ជាកិច្ចសន្យាដែលអ្នកដឹកជញ្ជូន សន្យាដឹកអ្នកដំណើរ ភារៈវត្ថុ ឬទំនិញ

ពីកន្លែងមួយទៅកន្លែងមួយទៀតដោយយកថ្លៃតាមការព្រមព្រៀង ឬ តាមថ្លៃកំណត់របស់រដ្ឋ។ តាមរយៈនិយមន័យមាត្រានេះ ការសិក្សា កិច្ចសន្យាដឹកជញ្ជូន គឺនឹងសិក្សាពីលក្ខណៈនៃកិច្ចសន្យានេះដោយធ្វើការ ប្រៀបធៀបជាមួយកិច្ចសន្យាផ្សេងទៀត លក្ខខណ្ឌសុពភាព រួមទាំង អានុភាពនៃកិច្ចសន្យាដឹកជញ្ជូន។

## ផ្នែកទី១. ចំណាត់ថ្នាក់កិច្ចសន្យាដឹកជញ្ជូន

តាមរយៈ៨៣ក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច កិច្ចសន្យាដឹកជញ្ជូន គឺអ្នកដឹកជញ្ជូនសន្យាបំពេញតាវកាលិកផ្លាស់ប្តូវត្ថុ ឬបុគ្គលពីទីតាំងមួយ ទៅទីតាំងកំណត់ជាក់លាក់ ដោយប្តូរជាមួយនឹងការបង់ប្រាក់។

## កថាខណ្ឌ១. កិច្ចសន្យាអញ្ញមញ្ញ កិច្ចសន្យាមូលា

កិច្ចសន្យាដឹកជញ្ជូន គឺជាដំបូងជាកិច្ចសន្យាអញ្ញមញ្ញ និងចរចាដោយបង្កើតឡើងតាមរយៈជំនួបឆន្ទៈគូភាគីទាំងសងខាង អ្នកដឹកជញ្ជូន និងអ្នកបញ្ជូនដែលត្រូវបំពេញតាវកាលិកទៅវិញទៅមក។ ជាទូទៅ កិច្ចសន្យាដឹកជញ្ជូនមិនមែនជាប្រភេទកិច្ចសន្យាឱឡារិក គ្រាន់តែវាអាចជាកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ក្រោមទម្រង់ជា លិខិតឯកជន។

ម្យ៉ាងវិញទៀតនៅក្នុងការអនុវត្ត កិច្ចសន្យាដឹកជញ្ជូនជាប្រភេទកិច្ចសន្យាមូលា ដែលអ្នកដឹកជញ្ជូនជាអ្នកជំនាញត្រូវទទួលកម្រៃពី សេវាកម្មដែលបានផ្តល់។

## កថាខណ្ឌ២. ពាណិជ្ជកិច្ច និង កិច្ចចម្រុះ

សហគ្រាសដឹកជញ្ជូន គឺជាពាណិជ្ជករ ដែលមានចែងក្នុងច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្មឆ្នាំ១៩៩៥ ដែលសកម្មភាព របស់សហគ្រាសដឹកជញ្ជូន[194] គឺធ្វើឡើងជាលក្ខណៈពាណិជ្ជកិច្ច។ អ្នកដំណើរ ឬ អ្នកបញ្ជូនវិញ គឺអាចជាពាណិជ្ជករ ឬ មិនមែនជាពាណិជ្ជករ ដែលជាមូលហេតុ នាំឲ្យប្រតិបត្តិការដឹកជញ្ជូនអាចជាពាណិជ្ជកិច្ច ឬ ក៏កិច្ច ចម្រុះ។

ការដឹកជញ្ជូនទំនិញ ជាទូទៅគឺជាពាណិជ្ជកិច្ចដោយសារ តែភាគីទាំងសងខាង ទាំងអ្នកដឹកជញ្ជូន និង អ្នកបញ្ជូនគឺជាពាណិជ្ជករនាំឲ្យ ប្រតិបត្តិការដែលធ្វើឡើងជាពាណិជ្ជកិច្ច អ្នកបញ្ជូនជាទូទៅអាចជា អ្នកលក់ អ្នកផលិត អ្នកលក់បោះដុំ អ្នកចែកចាយទំនិញ ឬ អ្នកលក់ តាមអនឡាញ។ ប៉ុន្តែក៏មានករណីខ្លះអ្នកបញ្ជូន គឺជាបុគ្គលស៊ីវិលដែលធ្វើ កិច្ចការមិនមានលក្ខណៈជាប្រចាំ ឬ/និង ស្វែងរកប្រាក់ចំណេញ។

ចំពោះការដឹកជញ្ជូនបុគ្គល គឺផ្ទុយពីការដឹកជញ្ជូនទំនិញ ដោយសារតែអ្នកដំណើរភាគច្រើនធ្វើដំណើរ ក្នុងគោលដៅសម្រាប់ការ កំសាន្ត ឬលំហែរកាយ ឬ ក្នុងគោលដៅជួបជុំគ្រួសារ ដែលមិនទាក់ទងនឹង សកម្មភាពពាណិជ្ជកម្មដែលជាមូលហេតុនាំឲ្យកិច្ចសន្យាដឹកជញ្ជូនបុគ្គល គឺជាកិច្ចចម្រុះដោយភាគីម្ខាង ជាពាណិជ្ជករគឺអ្នកដឹកជញ្ជូន ចំណែកភាគី ម្ខាងទៀតមិនមែនជាពាណិជ្ជករគឺជាអ្នកដំណើរ។

[194] ម. ២ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម ឆ្នាំ១៩៩៥។

## កថាខណ្ឌ៣. កិច្ចសន្យាម៉ៅការពិសេស

មូលហេតុដែលក្រមរដ្ឋប្បវេណី ពុំបានចែងពីកិច្ចសន្យា ដឹកជញ្ជូន ដោយសារតែកិច្ចសន្យាដឹកជញ្ជូន តាមពិតទៅគឺជាផ្នែកមួយ នៃកិច្ចសន្យាម៉ៅការ ព្រោះកិច្ចសន្យាម៉ៅការមានលក្ខណៈពហុចម្រុះ អាចទាក់ទងនឹងការសាងសង់ ឬផ្តល់សេវាកម្ម។ តាមខ្លឹមសារនៃ កិច្ចសន្យាម៉ៅការ អ្នកម៉ៅការត្រូវបំពេញការងាររបស់ខ្លួនដោយឯករាជ្យ ក្នុងការប្រើប្រាស់មធ្យោបាយដើម្បីសម្រេចការងារឲ្យម្ចាស់ការ។ អ្វីដែល សំខាន់គឺលទ្ធផលវិជ្ជមានរបស់អ្នកម៉ៅការ គឺជាចំណុចសំខាន់ នៃកិច្ចសន្យា។ តាមរយៈចំណុចនេះបាន ន័យថា អ្នកម៉ៅការ គឺជាអ្នក ដឹកជញ្ជូនទំនិញ ឬវត្ថុ ទៅតាមការបញ្ជារបស់អ្នកបញ្ជូន ដែលជា ម្ចាស់ការ ឲ្យសម្រេចការដឹកជញ្ជូនពីទីតាំងមួយទៅទីតាំងមួយទៀត ដោយអ្នកបញ្ជូន ឬម្ចាស់ការត្រូវមានករណីយកិច្ចបង់ប្រាក់ទៅតាមការ ព្រមព្រៀងគូភាគី។

## កថាខណ្ឌ៤. ការបែងចែងភាពខុសគ្នារវាងកិច្ចសន្យា ដឹកជញ្ជូន និង កិច្ចសន្យាដទៃទៀត

### ១. កិច្ចសន្យាម៉ៅការទូទៅ

ទោះបីជាការបង្ហាញខាងលើថា កិច្ចសន្យាដឹកជញ្ជូនគឺជា កិច្ចសន្យាម៉ៅការពិសេស ដោយសារតែវាមានវិធានផ្ទាល់ខ្លួនដែលមាន ចែងក្នុងក្រឹត្យ-ច្បាប់លេខ៣៨ក្រ.ច. ជួនកាលវាអាចមានការភ័ន្តច្រឡំ ជាមួយនឹងកិច្ចសន្យាម៉ៅការទូទៅ ដោយសារតែអ្នកដឹកជញ្ជូនអាចផ្តល់ សេវាបន្ថែមដល់អតិថិជនដូចជា៖ ការគ្រប់គ្រង ការរក្សាទុក ការដាក់ទុក ក្នុងឃ្លាំងជាដើម។ ការផ្តល់តាវកាលិកនៃការដឹកជញ្ជូនមួយចំនួន គឺវាពិបាកនឹងផ្តាច់ចេញដែលជាសេវាកម្មផ្តល់ជូនអតិថិជន សំណួរ ទាក់ទងនឹងចំណាត់ថ្នាក់នៃកិច្ចសន្យាត្រូវបានលើកឡើង ដោយផ្អែក ទៅលើការផ្តល់តាវកាលិកគោល ឬ បកស្រាយឲ្យងាយយល់គឺគេពិនិត្យ មើលទៅលើកាតព្វកិច្ចគោល ដែលបុគ្គលនោះបានផ្តល់សេវាកម្ម។

ប្រសិនកាតព្វកិច្ចគោល គឺជាការបំលាស់ទីនាំឲ្យវាជាកិច្ចសន្យា ដឹកជញ្ជូន ដែលមានកិច្ចបន្ទាប់បន្សំមកជាមួយ។ បើកាតព្វកិច្ចគោល មិនមែនជាការបំលាស់ទីនោះទេ វាជាកិច្ចសន្យាម៉ៅការដែលនាំឲ្យវិធាន ដែលមានចែងក្នុងក្រមរដ្ឋប្បវេណីត្រូវបានយកមកអនុវត្ត។

## ២. កិច្ចសន្យាបញ្ញើ

តាមរយៈមាត្រា៦៦៩ក្រមរដ្ឋប្បវេណី គឺអ្នកទទួលបញ្ញើត្រូវរក្សាទុកឲ្យបានគង់វង្ស ហើយត្រូវប្រគល់វត្ថុផ្ញើនោះទៅឲ្យអ្នកផ្ញើវិញនៅពេលដែលអំឡុងពេលផ្ញើត្រូវបានបញ្ចប់។ បើធ្វើការប្រៀបធៀបជាមួយ កិច្ចសន្យាដឹកជញ្ជូនវាសឹងតែមិនដូចគ្នា ដោយសារតែកិច្ចសន្យាបញ្ញើ ជាប្រភេទកិច្ចសន្យាប្រត្យក្ស ចំណែកកិច្ចសន្យាដឹកជញ្ជូនបុគ្គល គឺមិនមែនជាការប្រគល់បុគ្គលម្នាក់ឲ្យមានការគ្រប់គ្រងនោះទេ។

ផ្ទុយទៅវិញសម្រាប់ការដឹកជញ្ជូនវត្ថុ ភាពកន្តច្រឡំអាចនឹង កើតមានឡើង ដោយសារតែវាជាប្រភេទកិច្ចសន្យាប្រត្យក្សផងដែរ។ ប្រសិន ជាយកមាត្រា៦៦៩ក្រមរដ្ឋប្បវេណីមកវិភាគ គឺការដឹកជញ្ជូនទំនិញតម្រូវ ឲ្យមានការប្រគល់វត្ថុទៅអ្នកដឹកជញ្ជូន បំលាស់ទី (បញ្ញើគឺជាកិច្ចបន្ទាប់ បន្សំនៃការដឹកជញ្ជូន)។ នៅក្នុងការប្រើប្រាស់ពាក្យសាមញ្ញសម្រាប់ការ ដឹកជញ្ជូនទំនិញ គឺគេតែងតែប្រើពាក្យ«ផ្ញើទំនិញ» ពីទីកន្លែងមួយទៅ ទីកន្លែងមួយទៀត ជាពិសេសបើពិនិត្យមើលរយៈពេលនៃការដឹកជញ្ជូន ទំនិញ ការរក្សាទុកទំនិញរបស់អ្នកដឹកជញ្ជូនអាចមានរយៈពេលយូ។

## ៣. ភតិសន្យា

ភិសន្យាចលនវត្ថុយានយន្ត (រថយន្ត នាវា) ដោយមានមកជាមួយ តៃកុងឡាន (ឬនាវិក) វាមិនមែនជាកិច្ចសន្យាដឹកជញ្ជូននោះទេ ដោយសារ តែភតិបតី បានព្រមព្រៀងផ្គត់ផ្គង់ទាំងសម្ភារៈ និង បុគ្គល (តៃកុងឡាន)។ ប្រសិនបើភតិបកៈបង្គាប់បញ្ជាទៅអ្នកប្រតិបត្តិការ មានន័យថាការបញ្ជាទៅ

កាន់អ្នកបើកបរឡាន នាំឲ្យអ្នកបើកបរក្លាយទៅជាអ្នកដឹកជញ្ជូន។ នៅក្នុងកិច្ចសន្យាដឹកជញ្ជូនទំនិញ អ្នកដឹកជញ្ជូនត្រូវមានករណីយកិច្ច ធានាទៅលើការបាត់បង់វត្ថុ ចំណែកភតិសន្យាចលនវត្ថុយានយន្តវិញ ភតិបតី គឺមានកាតព្វកិច្ចត្រឹមតែប្រគល់វត្ថុឲ្យភតិកៈប្រើប្រាស់តែប៉ុណ្ណោះ។

ក្នុងករណីដឹកជញ្ជូនទំនិញតាមសមុទ្រ កាលដែលអ្នកដឹកជញ្ជូន បានផ្តល់កុងទ័ន័រឲ្យផ្ទុកទំនិញ ដោយប្តូរជាសាច់ប្រាក់ និង ករណីយកិច្ច បដិទាននូវកុងទ័ន័រវិញនេះគឺជាភតិសន្យាចលនវត្ថុ ទោះបីជាភតិបតី ជាអ្នក គ្រប់គ្រងរក្សាកុងទ័ន័រ លើកដាក់ក្នុងនាវាដើម្បីយកដឹកទៅគោលដៅចុង ក្រោយ។

## ៤. អន្តរការី

កិច្ចសន្យាដឹកជញ្ជូននាពេលបច្ចុប្បន្ន គឺមានភាពបន់បែនដោយ សារតែបច្ចេកវិទ្យា ដែលមានតួអង្គដ៏សំខាន់មួយទៀតចូលរួមជា អន្តរការី នាំឲ្យកើតមានទំនាក់ទំនងការដឹកជញ្ជូនអ្នកដំណើរ និង ទំនិញកើតឡើង។ ក្រុមហ៊ុនទាំងនោះ គឺផ្តល់នូវសេវាអន្តរការីភ្ជាប់ទំនាក់ទំនង អ្នកដឹកជញ្ជូន និង អ្នកដំណើរ ឬ អ្នកដឹកជញ្ជូន និងអ្នកបញ្ជូន។ អ្នកដឹកជញ្ជូន គឺអនុវត្ត ដោយឯករាជ្យដោយមិនមានចំណងធិនភាពជាមួយនឹងក្រុមហ៊ុន អន្តរការី។ ក្រុមហ៊ុនអន្តរការីខាងផ្នែកដឹកជញ្ជូន គឺផ្តល់ជាមធ្យោបាយ ផ្សេងៗដើម្បីឲ្យទំនាក់ទំនងដឹកជញ្ជូនបានកើតឡើងដូចជា កក់សំបុត្រ សម្រាប់អ្នកដំណើរ ស្វែងរកអ្នកដឹកជញ្ជូនឲ្យអ្នកដំណើរ ផ្តល់ព័ត៌មានដល់ អ្នកទិញដែលជាអ្នកទទួល និង អ្នកលក់ដែលជាអ្នកបញ្ជូនរួមទាំងភ្ជាប់ ទំនាក់ទំនងជាអ្នកដឹកជញ្ជូន។

ក្រុមហ៊ុនដឹកជញ្ជូន អ្នកលក់ អ្នកទិញ អ្នកដំណើរ សុទ្ធតែចាំ បាច់ត្រូវការសេវាអន្តរការីនេះ ដែលជាកត្តាដែលនាំឲ្យការផ្គត់ផ្គង់តម្រូវ ផ្សេងៗគឺមានភាពងាយជាងមុន។ សហគ្រាសអន្តរការីដែល កម្រែដើងសារ គឺធ្វើក្រោមទម្រង់ជាកម្មវិធីក្នុងទូរស័ព្ទដៃសម្រាប់ការដឹកជញ្ជូនទំនិញ និង អ្នកដំណើរ ដែលគេឃើញមានក្រុមហ៊ុនផ្តល់សេវាកម្មអន្តរការីមួយចំនួន នៅកម្ពុជាដូចជាៈ PassApp Grab Nham24។ល។

## ផ្នែកទី២. កិច្ចសន្យាដឹកជញ្ជូនទំនិញ

ទោះបីជាកិច្ចសន្យាដឹកជញ្ជូនទំនិញ និង ដឹកជញ្ជូនបុគ្គលស្ថិត នៅក្នុងប្រភេទនៃកិច្ចសន្យាដឹកជញ្ជូនតែមួយក៏ពិតមែន ប៉ុន្តែលក្ខខណ្ឌ សុពលភាព រួមទាំងអានុភាពនៃកិច្ចសន្យា គឺមានភាពខុសគ្នាមួយចំនួន ដោយសារតែកម្មវត្ថុនៃកិច្ចសន្យាខុសគ្នា។

## កថាខណ្ឌ១. លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាដឹកជញ្ជូនទំនិញ

ប្រសិនជាពិនិត្យនៅក្នុងខ្លឹមសារមាត្រា៨៣ ដល់ មាត្រា៨៨ ក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច. គឺឃើញថាអ្នកនីតិនិពន្ធគឺផ្តោតសំខាន់ តែទៅលើការដឹកជញ្ជូនទំនិញ ទោះបីជាក្នុងមាត្រា៨៣បានបែងចែក កម្មវត្ថុនៃកិច្ចសន្យាដឹកជញ្ជូនជាពីរប្រភេទក៏ដោយ គឺការដឹកជញ្ជូន ទំនិញ និង ការដឹកជញ្ជូនបុគ្គល។ នៅក្នុង ក្រឹត្យ-ច្បាប់លេខ៣៨ ពុំបាន កំណត់ពីប្រភេទមធ្យោបាយនៃការដឹកជញ្ជូន ដូចជាផ្លូវគោក ផ្លូវដែក ផ្លូវទឹក ឬ ផ្លូវអាកាស។

## ១. ភាគីនៃកិច្ចសន្យា

នៅក្នុងទំនាក់ទំនងនៃកិច្ចសន្យាដឹកជញ្ជូន គឺមានទំនាក់ទំនង ភាគីចំនួនដល់ទៅ៣គឺ អ្នកបញ្ជូន អ្នកដឹកជញ្ជូន និង អ្នកទទួល។

### ១.១. អ្នកដឹកជញ្ជូន និង អ្នកបញ្ជូន

អ្នកដឹកជញ្ជូន អាចជាអ្នកបើកបរឡានដែលហៅថាតៃកុងឡាន សម្រាប់ការដឹកជញ្ជូនផ្លូវគោក ឬនាវិក សម្រាប់ការដឹកជញ្ជូនតាមនាវា។ អ្នកដឹកជញ្ជូនជាទូទៅ គឺជាបុគ្គលជំនាញដែលមានវិជ្ជាជីវៈក្នុងការ ដឹកជញ្ជូនដែលមានទំនាក់ទំនងជាមួយអ្នកបញ្ជូន និងអ្នកទទួល។

ចំណែកអ្នកបញ្ជូន គឺជាបុគ្គលដែលយកវត្ថុ ទំនិញទៅផ្ញើឲ្យ អ្នកដឹកជញ្ជូនទៅគោលដៅណាមួយតាមការព្រមព្រៀងគូភាគី។

នៅក្នុងការលក់ទិញដែលមានទំនាក់ទំនងនឹង ការដឹកជញ្ជូន បន្ទុកជាទូទៅនៃការដឹកជញ្ជូនគឺជាបន្ទុករបស់អ្នកទិញ ដែលជាអ្នក ទទួលទំនិញ ប៉ុន្តែភាគីដែលចុះកិច្ចសន្យាដឹកជញ្ជូនគឺធ្វើឡើងរវាង អ្នកលក់ដែលជាអ្នកបញ្ជូន និងអ្នកដឹកជញ្ជូន។

### ១.២. អ្នកទទួល

អ្នកទទួលទំនិញ មិនមែនជាភាគីនៃកិច្ចសន្យាដឹកជញ្ជូន ប៉ុន្តែត្រូវជាប់ពាក់ព័ន្ធនៅក្នុងកិច្ចសន្យា ដឹកជញ្ជូន នៅពេលអ្នកទទួលទទួលយក ឬបដិសេធមិនទទួលយកទំនិញនៅពេលដែលការដឹកជញ្ជូននោះ មានការយឺត

យ៉ាវ ឬ ទំនិញនោះខូចខាត បែកបាក់។ នៅក្នុងក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច. ពុំបានចែងពីទំនាក់ទំនងអ្នកទទួលនៅក្នុងកិច្ចសន្យាដឹកជញ្ជូន ដែលជាមូលហេតុនាំឲ្យអ្នកទទួល ទោះបីជាបដិសេធមិនព្រមទទួលវត្ថុ ដោយសារតែវត្ថុនោះមានការយឺតយ៉ាវ ឬខូចខាត ពុំមានសិទ្ធិតតាំងជាមួយ អ្នកដឹកជញ្ជូនបានឡើយ ទោះបីជាសោហុយនៃការដឹកជញ្ជូនជាបន្ទុក របស់អ្នកទទួល។ ដូច្នេះ អ្នកទទួល ត្រូវធ្វើការតតាំងជាមួយអ្នកបញ្ជូន ដើម្បីឲ្យអ្នកបញ្ជូន ទាមទារការទទួលខុសត្រូវតាមរយៈកិច្ចសន្យាដឹកជញ្ជូន ដែលមានចែងនៅក្នុងក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច.។

## ២. ឯកសារដឹកជញ្ជូន

ជាទូទៅឯកសារដឹកជញ្ជូន គេតែងតែត្រូវធ្វើក្រោមទម្រង់ជា សំណុំក្រដាសដោយភ្ជាប់យ៉ាង៣ច្បាប់៖ អ្នកបញ្ជូនត្រូវរក្សាទុក មួយច្បាប់ មួយច្បាប់ទៀតគឺសម្រាប់អ្នកដឹកជញ្ជូន ចំណែកមួយច្បាប់ចុងក្រោយ ប្រគល់ទៅឲ្យអ្នកទទួល។ ជាគោលការណ៍អ្នកដឹកជញ្ជូន គឺទទួលបន្ទុក រៀបចំឯកសារនៅមុនពេលចាប់ផ្តើមដឹកជញ្ជូន ក្រោមទម្រង់ជាលិខិត ប្រគល់ដែលត្រូវផ្តល់ទៅអ្នកបញ្ជូន។

ឯកសារដឹកជញ្ជូន គឺមានសារៈសំខាន់សម្រាប់គូភាគី ដែលជាភស្តុតាងក្នុងការយកមកតតាំង ជាពិសេសនៅក្នុងកិច្ចសន្យាពាណិជ្ជកម្ម ឬ កិច្ចចម្រុះ ភាគីមានសេរីភាពក្នុងការបង្ហាញភស្តុតាងចំពោះការដឹកជញ្ជូន។ ឯកសារដឹកជញ្ជូន អាចត្រូវបានយកមកប្រើសម្រាប់ទំនាក់ទំនងក្នុងការ ដឹកជញ្ជូនសម្រាប់ អ្នកបញ្ជូន អ្នកដឹកជញ្ជូន និង អ្នកទទួល។ នៅពេល ដែលទំនិញដែលត្រូវបញ្ជូន មានលក្ខណៈផុយស្រួយ ឬគ្រោះថ្នាក់ ឬទាមទារឲ្យរក្សាក្នុងសីតុណ្ហា

ភាពពិសេស អ្នកបញ្ជូនត្រូវតែបញ្ជាក់ឲ្យបាន ច្បាស់ពីវត្ថុនោះ និងត្រូវកត់ត្រាលើឯកសារដឹកជញ្ជូន។

## ៣. តម្លៃ

តាមរយៈក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច គឺបានបញ្ជាក់ពីលក្ខខណ្ឌទាក់ទងនឹងតម្លៃនៅក្នុងកិច្ចសន្យាដឹកជញ្ជូន ដោយតម្លៃត្រូវបានកំណត់តាមការព្រមព្រៀងគូភាគី ឬ តាមរយៈការកំណត់តំម្លៃដោយរដ្ឋ។

ចំពោះការកំណត់តម្លៃតាមរយៈការព្រមព្រៀងគូភាគី គឺជាទូទៅកើតចេញពីឆន្ទៈគូភាគីទាំងសងដែលបានព្រមព្រៀងគ្នា ដោយភាគីម្ខាង ជាអ្នកធ្វើសំណើជាពិសេសគឺអ្នកដឹកជញ្ជូន និង ភាគីម្ខាងទៀតធ្វើស្ទីការ ទៅលើតម្លៃនោះអាចជា អ្នកបញ្ជូន ឬអ្នកទទួល។[195]

ចំពោះតម្លៃដែលកំណត់ដោយរដ្ឋ អាចត្រូវបានបកស្រាយជាពីរសម្មតិកម្មៈ

សម្រាប់ករណីទីមួយគឺ មធ្យោបាយដឹកជញ្ជូនមួយចំនួនគឺជាមធ្យោបាយសាធារណៈ ដែលក្រុមហ៊ុនដឹកជញ្ជូនជាសហគ្រាសរបស់រដ្ឋ ឬចម្រុះរវាងរដ្ឋ និង ឯកជន ដែលជាហេតុនាំឲ្យរដ្ឋមានសិទ្ធិកំណត់តម្លៃ ដោយមិនផ្ទុយទៅនឹងគោលការណ៍ ដែលមានកំណត់រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ទាក់ទងនឹងគោលការណ៍សេដ្ឋកិច្ចទីផ្សារសេរី។[196]

---

195 ម. ៨៣ ក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច. ឆ្នាំ១៩៨៨។

196 ម. ៥៦ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

សម្រាប់សម្មតិកម្មទីពីរគឺ ទាក់ទងនឹងកាលបរិច្ឆេទនៃការអនុម័តក្រឹត្យ-ច្បាប់លេខ៣៨មួយនេះ ដោយសារតែឆ្នាំអនុម័តនៅឆ្នាំ១៩៨៨ ដែលកម្ពុជា នៅពេលនោះក្នុងស្ថិតបរិបទនយោបាយបែបសង្គមនិយម។ រដ្ឋធម្មនុញ្ញក្នុងរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជាឆ្នាំ១៩៨១[197] គឺបែប លក្ខណៈជាសេដ្ឋកិច្ចផែនការ ដោយរដ្ឋមានអំណាចក្នុងការកំណត់តម្លៃ ផ្សេងៗ ដែលជាមូលហេតុនាំឲ្យក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ចបានចែងពី អំណាចរបស់រដ្ឋ ក្នុងការកំណត់តម្លៃនៅក្នុងទំនាក់ទំនងរវាងបុគ្គលឯកជន និង បុគ្គលឯកជន ដូចជាកិច្ចសន្យាដឹកជញ្ជូនជាដើម។

នៅក្នុងកិច្ចសន្យាម៉ៅការទូទៅ គឺតម្លៃអាចត្រូវបានកំណត់ នៅពេលអនុវត្តកិច្ចសន្យាចំណែកកិច្ចសន្យាដឹកជញ្ជូនវិញ ដែលជា កិច្ចសន្យាម៉ៅការពិសេស ដាច់ខាតត្រូវតែកំណត់តម្លៃនៅថ្ងៃចុះកិច្ចសន្យា។ ជាគោលការណ៍ការបង់កម្រៃត្រូវធ្វើឡើងនៅមុនពេលដឹកជញ្ជូន តែក៏អាច ធ្វើឡើងក្រោយពេលដល់គោលដៅ ប្រសិនជាកិច្ចសន្យាបានកំណត់។ ដូច្នេះបន្ទុកនៃការបង់កម្រៃដឹកជញ្ជូន អាចជាបន្ទុកអ្នកបញ្ជូន ឬ ជាបន្ទុក របស់អ្នកទទួល។

ប្រសិនជាការដឹកជញ្ជូននោះ មានទំនាក់ទំនងជាមួយនឹង កិច្ចសន្យាលក់ទិញ ក្រមរដ្ឋប្បវេណីបានកំណត់អំពីការចំណាយសោហ៊ុយ ក្នុងការប្រគល់វត្ថុ គឺជាបន្ទុករបស់អ្នកលក់ដែលជាអ្នកបញ្ជូន លើកលែងតែ មានការព្រមព្រៀងគ្នាពិសេសដោយឲ្យអ្នកទិញ ជាអ្នកទទួលបន្ទុកចេញ សោហ៊ុយក្នុងទទួលយកវត្ថុ។[198]

[197] ម. ១១ រដ្ឋធម្មនុញ្ញនៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ឆ្នាំ១៩៨១។

[198] ម. ៥៤៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

នៅក្នុងការអនុវត្តមួយចំនួន ការបង់ប្រាក់ គឺត្រូវធ្វើនៅពេលដែលទំនិញមកដល់អ្នកទទួល ដោយអ្នកទទួលមិនត្រឹមតែបង់ប្រាក់សម្រាប់ ថ្លៃដឹកជញ្ជូនប៉ុណ្ណោះទេ តែត្រូវបង់ថ្លៃទំនិញទៅកាន់អ្នកដឹកជញ្ជូន ដែលជាមូលហេតុនាំឲ្យអ្នកដឹកជញ្ជូនក្លាយជា អាណ្ណត្តិគាហកក្នុងការ ទទួលយកប្រាក់ក្នុងនាម និងផលប្រយោជន៍ឲ្យអាណ្ណត្តិទាយកដែលជា អ្នកលក់ផងដែរ។

ទំនៀមទំលាប់ពាណិជ្ជកម្មមួយចំនួនទៀត គឺតម្រូវឲ្យអ្នកទិញ ធ្វើការបង់ប្រាក់ជាមុនរួមបញ្ចូលទាំងថ្លៃដឹកទៅឲ្យអ្នកលក់ ទើបអ្នកលក់ ធ្វើការបញ្ជូនទំនិញទៅឲ្យអ្នកទិញតាមរយៈអ្នកដឹកជញ្ជូន។

## កថាខណ្ឌ២. អានុភាពនៃកិច្ចសន្យាដឹកជញ្ជូនទំនិញ

នៅពេលកិច្ចសន្យាដឹកជញ្ជូនបានត្រូវបានបង្កើតនាំឲ្យសិទ្ធិ និងករណីយកិច្ចរបស់គូភាគីត្រូវចាប់ផ្ដើមអនុវត្ត។

## ១. នីតិវិធីក្នុងដឹកជញ្ជូន

### ១.១. តួនាទីរបស់អ្នកបញ្ជូន

មុននឹងប្រគល់ទំនិញទៅអ្នកដឹកជញ្ជូន អ្នកបញ្ជូនត្រូវរៀបចំ ទំនិញឲ្យបានត្រឹមត្រូវ មានន័យថាត្រូវវិចខ្ចប់ឲ្យបានត្រឹមត្រូវទៅតាម ប្រភេទវត្ថុដែលមិនបង្កគ្រោះថ្នាក់ដល់អ្នកដឹកជញ្ជូន ឬ យានយន្ត អ្នកដឹកជញ្ជូន ឬបង្កឲ្យហានិភ័យដល់ទំនិញផ្សេងទៀតដែលត្រូវដឹកជាមួយ។ អ្នកបញ្ជូនត្រូវបញ្ជាក់អំពីអត្តសញ្ញាណនៃវត្ថុដូចជា ការបិទ លក្ខណៈសំគាល់ថារបស់នោះផុយស្រួយ ឬ គ្រោះថ្នាក់ជាដើម។

## ១.២. ដំណាក់កាលការប្រគល់វត្ថុ

ប្រតិបត្តិការដឹកជញ្ជូន អាចទៅបានលុះត្រាតែអ្នកបញ្ជូនប្រគល់ វត្ថុទៅកាន់អ្នកដឹកជញ្ជូន។ ការទទួលខុសត្រូវរបស់អ្នកដឹកជញ្ជូន គឺនៅចាប់ពីពេលដែលបានទទួលវត្ថុ។ ជាគោលការណ៍ អ្នកដឹកជញ្ជូនត្រូវធ្វើការ ត្រួតពិនិត្យវត្ថុ និងផ្តល់លិខិតដឹកជញ្ជូនទៅអ្នកបញ្ជូន រួមទាំងធ្វើការកត់ សំគាល់អំពីស្ថានភាពវត្ថុ នៅពេលទទួលវត្ថុដូចជាការវេចខ្ចប់មិនត្រឹមត្រូវ ឬ ក៏មានការបែកបាក់ជាដើម។

នៅក្នុងដំណាក់កាលនេះ ក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច. មានចែងពី ការទទួលខុសត្រូវរបស់អ្នកបញ្ជូន ដោយបញ្ជាក់ពីសិទ្ធិរបស់អ្នកដឹកជញ្ជូន មានសិទ្ធិតម្រូវឲ្យជួលជុលការខាតបង់ ឬរំលាយកិច្ចសន្យាក្នុងករណីដែល អ្នកបញ្ជូនមានការយឺតយ៉ាវក្នុងការភារៈវត្ថុ ឬ ទំនិញដែលត្រូវដឹក។[199] ក្នុងករណីនេះអាចជាករណីការដឹកជញ្ជូនបន្ត ដែលអ្នកបញ្ជូនគឺជា អ្នកដឹកជញ្ជូនទីមួយមានការយឺតយ៉ាវ ជាមូលហេតុអ្នកដឹកជញ្ជូនបន្ត ទទួលរងព្យសនកម្មពីការយឺតយ៉ាវក្នុងប្រគល់វត្ថុដល់អ្នកទទួល។ ដូច្នេះ អ្នកដឹកបញ្ជូនបន្ត គឺមានសិទ្ធិទាមទារការទទួលខុសត្រូវពីអ្នកបញ្ជូន ដែលផ្ទុកផ្តាក់ទំនិញមានការយឺតយ៉ាវ។

## ១.៣. ការរក្សាទុកវត្ថុក្នុងអំឡុងពេលដឹកជញ្ជូន

នៅក្នុងអំឡុងពេលនៃការផ្លាស់ទី គឺចន្លោះពេលពីការទទួលវត្ថុ និងការប្រគល់វត្ថុ អ្នកដឹកជញ្ជូនត្រូវរក្សាវត្ថុដែលត្រូវដឹកដែលទទួល បាន។

---

[199] ម. ៨៥ ក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច. ឆ្នាំ១៩៨៨។

ការទទួលខុសត្រូវ គឺចាប់ផ្តើមកើតឡើងដោយការទទួលខុសត្រូវ រដ្ឋប្បវេណីមានពីរសម្រាប់អ្នកដឹកជញ្ជូន៖

- ទីមួយ ការទទួលខុសត្រូវក្នុងកិច្ចសន្យាចំពោះ អ្នកបញ្ជូន និង អ្នកទទួល
- ទីពីរ ការទទួលខុសត្រូវអំពើរអនីត្យានុកូលចំពោះ តតិយជន ក្នុងអំឡុងពេលដឹកជញ្ជូននៅពេលដែលមាន ការបង្កព្យសនកម្មដល់តតិយជន។

## ១.៤. ការប្រគល់វត្ថុ

ការប្រគល់វត្ថុ គឺជាការបញ្ចប់នូវកិច្ចសន្យាដឹកជញ្ជូន។ ការប្រគល់ វត្ថុ គឺជាផ្តល់នូវទំនិញពីអ្នកដឹកជញ្ជូនទៅសិទ្ធិវន្តដែលទទួលយកវត្ថុនោះ និងត្រូវត្រួតពិនិត្យស្ថានភាពនៃវត្ថុនោះ មុននឹងទទួលយកមកកាន់កាប់។ កិច្ចសម្ភារៈនៃការប្រគល់វត្ថុ គឺត្រូវបានបំពេញដោយកិច្ចគតិយុត្តតាមរយៈ ការទទួលយកទំនិញ ដែលជាមូលហេតុនាំឲ្យមានការដោះបន្ទុកសម្រាប់ អ្នកដឹកជញ្ជូន។ ការដោះបន្ទុកនេះ នឹងមិនអាចរួចផុតពីការទទួលខុសត្រូវ ក្នុងករណីដែលទំនិញនោះមានការខូចខាត ឬ មិនស្របតាមទម្រង់នៃការ វិចខ្ចប់ទូទៅ។

នៅក្នុងក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច. មានចែងពីការទទួលខុសត្រូវរបស់អ្នកដឹកជញ្ជូន ក្នុងករណីដែលវត្ថុត្រូវបានបាត់បង់ ឬ ខូចខាត ប្រសិនបើ

មិនមែនជាករណីប្រធានសក្តិ ឬវិការៈអាចកំបាំងនៃវត្ថុនោះ (ដោយក្នុង ក្រឹត្យ-ច្បាប់នោះ ប្រើប្រាស់ពាក្យវិបត្តិផ្ទាល់នៃវត្ថុ)។[200]

## ២. ទំនួលខុសត្រូវរបស់អ្នកដឹកជញ្ជូន

នៅក្នុងក្រឹត្យ-ច្បាប់លេខ៣៨ក្រ.ច. បានកំណត់យ៉ាងច្បាស់ពី ប្រភេទករណីយកិច្ចរបស់អ្នកដឹកជញ្ជូន គឺជាប្រភេទកាតព្វកិច្ចលទ្ធផល ដែលជាមូលហេតុនាំឲ្យ អ្នកដឹកជញ្ជូនពិបាកនឹងរួចផុតពីការទទួលខុសត្រូវ នូវពេលដែលលទ្ធផលគឺអវិជ្ជមាន។

មូលហេតុដែលនាំឲ្យអ្នកដឹកជញ្ជូន មានកាតព្វកិច្ចលទ្ធផល ដោយសារតែអ្នកដឹកជញ្ជូនជាទូទៅ គឺជាអ្នកជំនាញបន្ថែមពីលើនេះគឺដោយសារតែអ្នកដឹកជញ្ជូនគឺជាពាណិជ្ជករ ចំណែកអ្នកបញ្ជូន ប្រសិនជាពាណិជ្ជករ ជាហេតុនាំឲ្យទំនាក់ទំនងដែលកើតឡើងជាពាណិជ្ជកិច្ច សេរីភាពនៃភស្តុតាងក្នុងការដាក់បន្ទុកទៅលើអ្នកដឹកជញ្ជូន គឺអាចបង្ហាញ ដោយសេរីដូចជាការបង្ហាញពីលិខិតដឹកជញ្ជូនដែលមានកំណត់ពី កាលបរិច្ឆេទនៃការដឹកជញ្ជូន និង អំឡុងពេលនៃការដឹកជញ្ជូន ឬ ក៏ភស្តុតាងជាក់ស្តែង ដូចជាវត្ថុដែលទៅដល់ដៃអ្នកទទួលមានការខូចខាត បាក់បែក ឬ បាត់បង់ជាដើម។

## ២.១. សច្ចធានទទួលខុសត្រូវរបស់អ្នកដឹកជញ្ជូន

យោងតាមរយៈក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច. អ្នកដឹកជញ្ជូនត្រូវទទួលខុសត្រូវចំពោះការយឺតយ៉ាវក្នុងការដឹកជញ្ជូន អ្នកបញ្ជូនមានសិទ្ធិ

[200] ម. ៨៧ ក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច. ឆ្នាំ១៩៨៨។

ទាមទារការទទួលខុសត្រូវ ចំពោះការយឺតយ៉ាវក្នុងដឹកជញ្ជូនទំនិញ។ នៅត្រង់ចំណុចនេះគឺក្រឹត្យ-ច្បាប់លេខ៣៨បានកំណត់ អំពីសច្ចធាក្នុង ការទទួលខុសត្រូវរបស់អ្នកដឹកជញ្ជូន ដោយគ្រាន់តែមានការយឺតយ៉ាវ ក្នុងការដឹកជញ្ជូន ត្រូវបានសន្មត់ថាមានកំហុស។ អ្នកបញ្ជូមមានសិទ្ធិ ដូចជា[201]៖

- ធ្វើការស្នើសុំរំលាយកិច្ចសន្យា
- ធ្វើបដិទានត្រឡប់មកវិញនូវ សោហ៊ុយចំណាយក្នុង ការលើកដាក់ និង ប្រាក់ដែលបានបង់រួចហើយទៅឲ្យ អ្នកដឹកជញ្ជូនផ្សេងទៀត។
- ទាមទារការជួលជុលសំណងខូចខាត ដែលបណ្តាល មកពីការយឺតយ៉ាវក្នុងករណីបាត់ ឬ ខូចសំភារៈវត្ថុ ឬ ទំនិញ ដែលត្រូវដឹកជញ្ជូន ឬការចុះតំលៃបណ្តាលមក ពីការយឺតយ៉ាវ។

សិទ្ធិក្នុងការទាមទារការទទួលខុសត្រូវ គឺមានអាជ្ញាយុកាល ១ឆ្នាំ គិតចាប់ពីថ្ងៃ ដែលម្ចាស់របស់បានដឹងថាបាត់ ឬខូខាត។[202] នៅត្រង់ចំណុចពាក្យម្ចាស់របស់ដែលក្រឹត្យច្បាប់បានប្រើប្រាស់ គឺមាន ភាពស្រពិចស្រពិល ដែលអាចជាអ្នកបញ្ជូន ឬ អ្នកទទួល។

---

201 ម. ៨៤ ក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច. ឆ្នាំ១៩៨៨។

202 ម. ៨៨ ក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច. ឆ្នាំ១៩៨៨។

ប្រសិនជាករណីលក់ទិញ ម្ចាស់របស់គឺជាអ្នកទិញគិតចាប់ពី ថ្ងៃចុះកិច្ចសន្យា ដូច្នេះអ្នកទិញដែលជាអ្នកទទួលមានសិទ្ធិប្ដឹងទៅ អ្នកដឹកជញ្ជូនឲ្យទទួលខុសត្រូវលើការបាត់បង់ ឬ ខូចខាតវត្ថុនោះ។

ប្រសិនបើជាករណីភតិសន្យា ភតិកៈគ្រាន់តែជាអ្នកកាន់កាប់ ព្រោះសិទ្ធិកម្មសិទ្ធនៅតែជារបស់ភតិបតី ដូច្នេះភតិបតីដែលជាអ្នក បញ្ជូន គឺត្រូវធ្វើការទាមទារឲ្យអ្នកដឹកជញ្ជូនទទួលខុសត្រូវលើការ ខាតបង់ ឬ បាក់បែកវត្ថុដែលដឹកជញ្ជូននោះ។

## ២.២. ព្រឹត្តិការណ៍ខាងក្រៅ និង ប្រធានសក្តិ

ការកំណត់ព្រឹត្តិការណ៍ផ្សេងៗ ដែលនាំឲ្យចាត់ទុកថាជាករណីប្រធានសក្តិ គឺវាផ្សាភ្ជាប់ជាមួយស្ថានភាពអង្គហេតុជាពិសេស ទៅលើលក្ខខណ្ឌប្រធានសក្តិ។ តាមរយៈប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានឲ្យនិយមន័យ ប្រធានសក្តិ គឺសំដៅទៅលើបាតុភូត ឬ ជាព្រឹត្តិការណ៍ដែលកើតឡើង ដោយមិនដឹងជាមុន មិនអាចប៉ាន់ស្មាន ជាមុនបាន និងមិនអាចជំនះបាន ដូចជាគ្រោះធម្មជាតិ( ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី ) សង្គ្រាម កុបកម្ម អគ្គីភ័យ ឬ គ្រោះមហន្តរាយជាយថាហេតុ។[203]

អ្នកដឹកជញ្ជូន ត្រូវបានរួចផុតពីការទទួលខុសត្រូវក្នុងការដឹក ជញ្ជូន ប្រសិនបើការយឺតយ៉ាវក្នុងការដឹកជញ្ជូន ឬ វត្ថុបាក់បែក ឬ បាត់បង់ ដោយសារតែករណីប្រធានសក្តិ មានន័យថាព្រឹត្តិការណ៍ដែលកើតក្រៅ ឆន្ទៈគូភាគី មិន

[203] ប្រការ ៤ ប្រកាសស្តីពីការប្រមូលពន្ធប្រថាប់ត្រា លេខ៥០៧ សហវ.ប្រក ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឆ្នាំ២០១៧។

អាចប៉ាន់ស្មានជាមុនបាន និងមិនអាចជំនះបាន[204]។ ករណីមួយចំនួនមិនត្រូវបានចាត់ទុកជាប្រធានសក្តិ ដូចជាករណីលួច ឬ ក៏ប្លន់ (ក្នុងក្រមព្រហ្មទណ្ឌចាត់ទុកថាជាការលួចមានស្ថានទម្ងន់ទោស ដោយប្រើហឹង្សា) ព្រោះទង្វើខាងលើនេះ អ្នកដឹកជញ្ជូនអាចព្យាករណ៍ ឬ ប្រើប្រាស់មធ្យោបាយការពារ ក្នុងអំឡុងពេលដឹកជញ្ជូន។

សម្រាប់ស្ថានភាពបច្ចុប្បន្ន ទាក់ទងនឹងជំងឺរាលត្បាតកូវិត១៩ មិនត្រូវបានចាត់ទុកជាមូលហេតុ ប្រធានសក្តិសម្រាប់ការដឹកជញ្ជូននោះទេ ព្រោះដោយសារតែការដឹកជញ្ជូន គឺជាវិស័យអត្ថិភាពដែលរាជរដ្ឋាភិបាល លើកទឹកចិត្តឲ្យមានចរាចរណ៍ក្នុងការដឹកទំនិញ។ ហេតុដូច្នេះ អ្នកដឹកជញ្ជូនមិនអាចយក មូលហេតុជំងឺរាលត្បាតកូវីត១៩ជាមូលហេតុ នៃការរួចផុតពីការទទួលខុសត្រូវបានឡើយ។

## ផ្នែកទី៣. កិច្ចសន្យាដឹកជញ្ជូនអ្នកដំណើរ

ភាពខុសគ្នារវាងកិច្ចសន្យាដឹកជញ្ជូនទំនិញ និង អ្នកដំណើរ គឺទាក់ទងនឹងភាគីនៃកិច្ចសន្យា ព្រោះក្នុងកិច្ចសន្យាដឹកជញ្ជូនទំនិញ មានភាគីចំនួនបីដែលពាក់ព័ន្ធនឹងការដឹកជញ្ជូន គឺអ្នកបញ្ជូន អ្នកដឹកជញ្ជូន និង អ្នកទទួល ចំណែកនៅក្នុងកិច្ចសន្យាដឹកជញ្ជូនអ្នកដំណើរ ភាគីមានតែ ចំនួនពីរប៉ុណ្ណោះ គឺអ្នកដំណើរ និង អ្នកដឹកជញ្ជូន។

នៅក្នុងបច្ចុប្បន្នភាព ការដឹកជញ្ជូនអ្នកដំណើរ គឺមានការធ្លាក់ចុះយ៉ាងខ្លាំងដោយសារតែបញ្ហាជំងឺឆ្លងកូវិត១៩ មិនថាមធ្យោបាយដឹកជញ្ជូន ផ្លូវ

[204] ម. ៨៦ ក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច. ឆ្នាំ១៩៨៨។

គោក ផ្លូវដែក ផ្លូវទឹក ឬក៏ផ្លូវអាកាសនោះទេ។ ក្រុមហ៊ុន សហគ្រាស ឬ បុគ្គលឯកជនដែលប្រកបវិជ្ជាជីវៈដឹកជញ្ជូន បានផ្លាស់ប្តូទម្លាប់ពីការ ដឹកជញ្ជូនអ្នកដំណើរ ទៅជាការដឹកជញ្ជូនទំនិញ។

ចំពោះលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា សម្រាប់ការដឹកជញ្ជូន អ្នកដំណើរ គឺអនុវត្តតាមវិធានរួមនៃនីតិកាតព្វកិច្ចដែលមានដូចជា៖ ការព្រមព្រៀងគូភាគី សមត្ថភាពអ្នកដឹកជញ្ជូន និង អ្នកដំណើរ រួមទាំងកម្មវត្ថុនៃកិច្ចសន្យា គឺតម្លៃដែលគូភាគីព្រមព្រៀង និងការផ្លាស់ទីពី ទីកន្លែងមួយទៅទីកន្លែងមួយទៀត។ ការសិក្សា ទៅលើកិច្ចសន្យា ដឹកជញ្ជូនអ្នកដំណើរ គឺផ្តោតសំខាន់ទៅលើសិទ្ធិ និង ករណីយកិច្ចរបស់ អ្នកដំណើរ និង អ្នកដឹកជញ្ជូន។

## កថាខណ្ឌ១. ការទទួលខុសត្រូវអ្នកដឹកជញ្ជូន

នៅក្នុងការដឹកជញ្ជូនអ្នកដំណើរ ក្រឹត្យ-ច្បាប់លេខ៣៨ បានកំណត់ពីករណីយកិច្ចធំៗចំនួនរបស់អ្នកដឹកជញ្ជូន៖ ករណីយកិច្ច សុវត្ថិភាពសម្រាប់អ្នកដំណើរ និង ករណីយកិច្ចធានាដឹកជញ្ជូនកុំឲ្យមាន ការយឺតយ៉ាវ។

## ១. ករណីយកិច្ចសុវត្ថិភាពអ្នកដំណើរ

នៅក្នុងករណីដឹកជញ្ជូនអ្នកដំណើរ អ្នកដឹកជញ្ជូនគឺមាន ករណីយកិច្ចធានាសុវត្ថិភាព ដែលជាកាតព្វកិច្ចលទ្ធផលដូចទៅនឹងការ ដឹកជញ្ជូនទំនិញផងដែរ។ ក្នុងអំឡុងពេលដឹកជញ្ជូនអ្នកដំណើរ ប្រសិនជា មានឧបទ្ទវហេតុណា

មួយកើតឡើង គឺជាកំហុសរបស់អ្នកដឹកជញ្ជូន ព្រោះ អ្នកដឹកជញ្ជូនត្រូវមានករណីយកិច្ចត្រួតពិនិត្យយានយន្ត មុនពេលចាប់ ផ្ដើមចេញដំណើរ។

ករណីយកិច្ចសុវត្ថិភាពនេះ គឺត្រូវបានកំណត់ក្នុង ក្រឹត្យ-ច្បាប់ លេខ ៣៨ ដោយតម្រូវឲ្យអ្នកដឹកជញ្ជូនទទួលខុសត្រូវ រាល់ការបង្ក គ្រោះថ្នាក់ដល់អ្នកដំណើរ ដោយអ្នកដំណើរមានសិទ្ធិទាមទារការទទួល ខុសត្រូវ ក្នុងកិច្ចសន្យាក្នុងករណីដែលដឹកជញ្ជូនធ្វេសប្រហែស។[205]

## ២. ករណីយកិច្ចដឹកជញ្ជូនឲ្យទាន់ពេលវេលា

ក្រៅពីករណីយកិច្ចសុវត្ថិភាព គឺនៅមានករណីយកិច្ចមួយទៀត ដែលជាប្រភេទកាតព្វកិច្ចលទ្ធផល គឺការយឺតយ៉ាវក្នុងការដឹកជញ្ជូន ដោយសារតែអ្នកដឹកជញ្ជូនគឺជាអ្នកជំនាញ ដូច្នេះអ្នកជំនាញអាចធ្វើការ ព្យាករណ៍ពីពេលវេលានៃការដឹកជញ្ជូន។ ការដឹកជញ្ជូនអ្នកដំណើរយឺត គឺបង្កព្យសនកម្មទៅដល់អ្នកដំណើរ ដោយជួនកាលអ្នកដំណើរត្រូវប្រើ ប្រាស់មធ្យោបាយធ្វើដំណើរមួយផ្សេងទៀត ដើម្បីទៅដល់គោលដៅចុង ក្រោយ ឧទាហរណ៍៖ អ្នកដំណើរត្រូវជិះឡានក្រុងដើម្បីមកព្រលាន យន្តហោះ ការយឺតយ៉ាវរបស់ឡានក្រុង គឺមានពន្យសនកម្មដល់អ្នកធ្វើ ដំណើរដែលគាត់ពុំអាចបន្តដំណើរឲ្យទាន់ពេលសម្រាប់ការជិះ យន្តហោះ។

ការយឺតយ៉ាវ គឺមានព្យសនកម្មដល់អ្នកដំណើរទោះបីជាគាត់ មិនត្រូវបន្តទៅមធ្យោបាយធ្វើដំណើរមួយទៀតក៏ដោយ ប៉ុន្តែអ្នកដំណើរ ត្រូវខកខាន

---

[205] ម. ៨៦ ក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច. ឆ្នាំ១៩៨៨។

ការណាត់ជួបដៃគូពាណិជ្ជកម្ម ដែលបណ្តាលមកពីការធ្វេស ប្រហែសរបស់អ្នកដឹកជញ្ជូន។

ក្រឹត្យ-ច្បាប់លេខ៣៨ក្រ.ច. បានកំណត់ពីលក្ខខណ្ឌក្នុងការទទួលខុសត្រូវដោយសារការយឺតយ៉ាវរបស់អ្នកដឹកជញ្ជូន ដោយអ្នកដំណើរត្រូវបង្ហាញថាការយឺតយ៉ាវនោះ គឺគ្មានមូលហេតុសមស្របនៅពេល ដឹកជញ្ជូន។[206]

## ៣. អាជ្ញាយុកាលនៃការទាមទារសំណងព្យសនកម្ម

ក្នុងករណីដែលអ្នកដឹកជញ្ជូនមានការយឺតយ៉ាវក្នុងដឹកជញ្ជូន ឬ ធ្វេសប្រហែសដែលបណ្តាលឲ្យអ្នកធ្វើដំណើរមានគ្រោះថ្នាក់ អ្នកដឹក ជញ្ជូនត្រូវជួសជុលព្យសនកម្ម ដូចជាសងប្រាក់ ដែលបានបង់រួចហើយ ទៅឲ្យអ្នកដឹកជញ្ជូនផ្សេងទៀត ឬ ជួសជុលការអន្តរាយដែលបណ្តាល មកពីគ្រោះថ្នាក់ ឬ បញ្ចុះតម្លៃដែលបណ្តាលមកពីការយឺតយ៉ាវ។[207]

សិទ្ធិទាមទារឲ្យជួសជុលព្យសនកម្មខាងលើនេះគឺមានរយៈពេល ១ឆ្នាំ គិតចាប់ពីពេល អ្នកដំណើរបានទទួលរងគ្រោះថ្នាក់ ដោយសារការដឹកជញ្ជូន។[208]

---

206 ម. ៨៧ ក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច. ឆ្នាំ១៩៨៨។

207 ម. ៨៤ ក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច. ឆ្នាំ១៩៨៨។

208 ម. ៨៨ ក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច. ឆ្នាំ១៩៨៨។

## កថាខណ្ឌ២. ការរួចផុតពីការទទួលខុសត្រូវ

នៅក្នុងអត្ថបទច្បាប់ដែលមាននៅក្នុងពេលបច្ចុប្បន្ន ក៏មានចែងពី ការរួចផុតពីការទទួលខុសត្រូវរបស់ អ្នកដឹកជញ្ជូនផងដែរទោះបីជាអ្នក ដឹកជញ្ជូនគឺមានកាតព្វកិច្ចលទ្ធផលចំពោះការដឹកជញ្ជូនក៏ដោយ។ មូលហេតុដែលនាំឲ្យរួចផុតពីការទទួលខុសត្រូវចំពោះអ្នកដំណើរ គឺមាន ពីរៈ ករណីប្រធានសក្តិ និង កំហុសរបស់ជនរងគ្រោះ។[209]

## ១. ករណីប្រធានសក្តិ

ដូចទៅនឹងការដឹកជញ្ជូនទំនិញ អ្នកដឹកជញ្ជូនអ្នកដំណើរ ត្រូវ បង្ហាញនូវធាតុផ្សំ៣យ៉ាងដែលច្បាប់កំណត់ គឺព្រឹត្តិការណ៍ដែលធ្វើឲ្យ គ្រោះថ្នាក់ដល់អ្នកដំណើរ ឬធ្វើអោយការដឹកជញ្ជូនមានការយឺតយ៉ាវ គឺជាព្រឹត្តិការណ៍ ដែលកើតចេញពីបាតុភូតិធម្មជាតិ (ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី) សង្គ្រាម កុបកម្ម អគ្គីភ័យ ហើយព្រឹត្តិការណ៍នោះមិនអាច ព្យាករណ៍ទុកមុនបាន មិនអាចជៀសបានដោយប្រើប្រាស់អស់គ្រប់ មធ្យោបាយដើម្បីបញ្ជៀសព្រឹត្តិការណ៍នោះ។[210]

សម្រាប់ករណីបាតុភូតិធម្មជាតិ ជាទូទៅគេអាចដឹងបានពេលខ្លះដោយសារតែបច្ចេកវិទ្យាបច្ចុប្បន្ន តាមមធ្យោបាយឧត្តុនិយម។ ប៉ុន្តែ បាតុភូតិធម្មជាតិមួយចំនួន មិនអាចជំនះបានដូចជារលកស្ទូណាមិជាដើម ដែលជាកត្តាដែលនាំឲ្យអ្នកដឹកជញ្ជូនអាចរួចផុតពីការទទួលខុសត្រូវ។

---

[209] ម. ៨៦ ក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច. ឆ្នាំ១៩៨៨។

[210] ប្រការ ៤ ប្រកាសស្តីពីការប្រមូលពន្ធប្រថាប់ត្រា លេខ៥០៧ សហវ.ប្រក ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឆ្នាំ២០១៧។

## ២. កំហុសអ្នកដំណើរ

ក្រៅពីករណីប្រធានសក្តិ ក្រឹត្យ-ច្បាប់លេខ៣៨ក្រ.ច. បានចែង ករណីកំហុសអ្នកដំណើរដែលមានគ្រោះថ្នាក់ ក្នុងអំឡុងពេលដឹកជញ្ជូន។ កំហុសរបស់អ្នកដំណើរទោះចេតនាក្តី ឬ អចេតនាក្តីគឺជាមូលហេតុ ដែលនាំឲ្យអ្នកដឹកជញ្ជូនរួចផុតពីការទទួលខុសត្រូវ។[211] នៅក្នុងក្រឹត្យ-ច្បាប់លេខ៣៨ បានប្រើប្រាស់ពាក្យ «ការធ្វេសប្រហែស» អ្នកដំណើរ ដែលអាចបកស្រាយបានថាជាកំហុសអចេតនា។

នៅក្នុងសម្មតិកម្ម ដែលអ្នកដឹកជញ្ជូនបានណែនាំអំពីវិធាន សុវត្ថិភាពក្នុងអំឡុងពេលធ្វើដំណើរ ដូចជាការដាក់ខ្សែក្រវ៉ាត់សុវត្ថិភាព ពីពាក់អាវពោងការពារនៅពេលធ្វើដំណើរតាមទឹក តែអ្នកដំណើរគោរព ទៅតាមគោលការណ៍ណែនាំស្តីពីសុវត្ថិភាពក្នុងការធ្វើដំណើរ ដូច្នេះនៅ ពេលដែលមានព្យសនកម្មកើតឡើង ហើយបណ្តាលឲ្យអ្នកដំណើរមាន គ្រោះថ្នាក់ ជាហេតុធ្វើឲ្យអ្នកដំណើរ ឬ សិទ្ធិវន្តរបស់គាត់ពុំអាចធ្វើការ ស្នើសុំការទទួលខុសត្រូវ ដោយសារតែការធ្វេសប្រហែសរបស់ខ្លួន។

---

211 ម. ៨៦ ក្រឹត្យ-ច្បាប់លេខ៣៨ ក្រ.ច. ឆ្នាំ១៩៨៨។

# មេរៀនទី៧
# អំពីអាណត្តិ

អាណត្តិ គឺជាប្រភេទកិច្ចសន្យាមួយក្នុងចំណោមកិច្ចសន្យាដែល ប្រើប្រាស់សេវាកម្មដោយកំលាំងកាយ ឬកំលាំងបញ្ញាមនុស្ស មានន័យថា ភាគីម្ខាងយល់ព្រមផ្តល់សេវាកម្មទៅឲ្យភាគីម្ខាងទៀត ដោយយកកម្រៃ ឬ មិនយកកម្រៃ។ នៅក្នុងប្រភេទកិច្ចសន្យាទាំងនេះ គឺមានសម្មតិកម្មជាច្រើន ដូចជាកិច្ចសន្យា ខ្ចីបរិភោគ (ខ្ចីប្រាក់) ខ្ចីប្រើ ការផលិត ឬជួសជុលវត្ថុ ឬ ក៏ភ្នាក់ងារអចលទ្រព្យ ។ល។

កិច្ចសន្យាទាំងនេះ គឺមានចែងនៅក្នុងក្រមរដ្ឋប្បវេណីដែលមាន ដូចជា កិច្ចសន្យាម៉ៅការ អាណត្តិ និង បញ្ញើ។ ប៉ុន្តែចំពោះប្រភេទកិច្ចសន្យា ដែលផ្តល់សេវាកម្មដោយមិនយកការតបស្នងជាសាច់ប្រាក់ អាចមាន ដូចជា អាណត្តិ ឬ បញ្ញើ។ សកម្មភាពទាំងនេះ ក៏ជាសកម្មភាពមួយសំខាន់ ចាំបាច់នៅក្នុងជីវភាពរស់នៅ ប្រចាំថ្ងៃ និង បម្រើផលប្រយោជន៍នៅក្នុង សកម្មភាពសេដ្ឋកិច្ចជាតិផងដែរ។

កិច្ចសន្យាទាំងឡាយណាដែលតាវកាលិកជាសេវាកម្ម គឺនាំឲ្យ កើតមាននូវកាតព្វកិច្ចត្រូវធ្វើ ចំណែកកិច្ចសន្យាទាំងឡាយណាដែលមាន អនុប្បទានសិទ្ធិកម្មសិទ្ធិ គឺនាំឲ្យកើតមាននូវកាតព្វកិច្ចឲ្យ។ គេអាចធ្វើ ចំណាត់ថ្នាក់កិច្ចសន្យា ទៅតាមស្ថានភាពភាពនៃសេវកម្មដែលផ្តល់ជូនទៅ ភាគីម្ខាងទៀត៖

ជួនកាលគេចាត់ទុកការងាររបស់មនុស្សសំខាន់៖ កម្មវត្ថុនៃ កាតព្វកិច្ចគឺសេវកម្មដោយមនុស្សដូចជា កិច្ចសន្យាការងារ។

ជូនកាលគេចាត់ទុកវត្ថុសំខាន់ ការប្រើប្រាស់វត្ថុគឺវាចាំបាច់ ដូចជា ភតិសន្យា គឺជាប្រភេទកិច្ចសន្យាដែលមានកម្មវត្ថុក្នុងផ្តល់ការប្រើប្រាស់ និងអាស្រ័យផលទៅតតិយជន។

នៅក្នុងកិច្ចសន្យាដែលតាវកាលិកជាសេវាកម្មដោយមនុស្ស គឺមាន បីប្រភេទធំៗ ដែលក្រមរដ្ឋប្បវេណីបានតាក់តែងឡើងនៅក្នុងបទបញ្ញត្តិ បន្តបន្ទាប់ដែលមានដូចជា៖

**កិច្ចសន្យាអាណត្តិ** សំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាង ហៅថាអាណត្តិទាយក ប្រគល់សិទ្ធិអំណាចឲ្យភាគីម្ខាងទៀត ហៅថា អាណត្តិគាហកធ្វើការចាត់ចែងកិច្ចការដើម្បីអាណត្តិទាយក។[212]

**កិច្ចសន្យាម៉ៅការ** គឺសំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាង មានករណីយកិច្ចសម្រេចការងារដែលបានព្រមព្រៀង ហើយភាគីម្ខាង ទៀតមានករណីយកិច្ចផ្តល់កម្រៃ ចំពោះលទ្ធផលនៃការងារដែលបាន ធ្វើនោះ។[213]

**កិច្ចសន្យាការងារ** ត្រូវបានបង្កើតឡើងដោយការសន្យារបស់ ភាគីម្ខាងធ្វើពលកម្មឲ្យភាគីម្ខាងទៀត ហើយភាគីម្ខាងទៀតផ្តល់ប្រាក់ ឈ្នួលទៅលើកិច្ចការពលកម្មនោះ។[214]

---

212 ម. ៦៣៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

213 ម. ៦៥២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

214 ម. ៦៦៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ការបែងចែករវាងកិច្ចសន្យាការងារ និង កិច្ចសន្យាម៉ៅការ គឺ អវត្តមាននៃចំណងធិនភាពរបស់អ្នកម៉ៅការ ចំណែកកិច្ចសន្យាម៉ៅការ និង អាណត្តិ គឺ អនុវត្តកិច្ចសម្ភារៈ និងមិនមែនជាការតំណាងដើម្បីចុះកិច្ច គតិយុត្តិ។

កិច្ចសន្យាអាណត្តិ គឺមានចែងក្នុងមាត្រា៦៣៧ រហូតដល់មាត្រា ៦៥១ក្រមរដ្ឋប្បវេណីដោយប្រតិបត្តិការនៃអាណត្តិគឺមានបុគ្គលចំនួនបី៖

អាណត្តិទាយក គឺជាបុគ្គលដែលផ្តល់អំណាចទៅឲ្យបុគ្គលម្នាក់ ទៀត ដើម្បីចុះកិច្ចគតិយុត្ត

អាណត្តិគាហក គឺជាបុគ្គលដែលទទួលអំណាច

តតិយជន គឺជាបុគ្គលដែលចុះកិច្ចគតិយុត្តិជាមួយអាណត្តិគាហក ធ្វើ ក្នុងនាមអាណត្តិទាយក។



ទោះបីជាប្រតិបត្តិការនេះមានបុគ្គលបីនាក់ក៏ដោយ ក៏កិច្ចសន្យាអាណត្តិនៅតែទ្វេភាគីដដែល ជូនកាលអាណត្តិទាយកជាអ្នកផ្តល់អំណាចជូនកាលអាណត្តិគាហក ជាភ្នាក់ងារអន្តរការីដូចជាភ្នាក់ងារអចលនទ្រព្យ ។

ប្រភពដើមនៃអាណត្តិ គឺជាត្រូវបានចាត់ទុកជាសេវាកម្មគ្រួសារ ឬ មិត្តភក្រ្តដែលមិនយកកម្រៃ ហើយបន្ទាប់មកទៀតអាណត្តិបានបំលែងទៅ ជាកិច្ចសន្យាធុរកិច្ច។ គេអាចនិយាយថា ប្រភពដំបូងនៃអាណត្តិគឺជា ប្រភេទកិច្ចសន្យាដែលយកបុគ្គលជាធំ និងត្រូវបានសន្មតមិនយកកម្រៃ ប្រសិនបើភាគីមិនបានបង្ហាញឆន្ទៈ។[215]

## ផ្នែកទី១. លក្ខណៈទូទៅនៃអាណត្តិ

លក្ខណៈទូទៅនៃអាណត្តិ គឺមានលក្ខណៈពិសេសខុសពី កិច្ចសន្យាដទៃដូចដែលបានរៀបរាប់ខាងលើ គឺមានភាគីចំនួន៣នៅក្នុង ទំនាក់ទំនងអាណត្តិ ជាមូលហេតុនាំឲ្យការសិក្សាផ្តោតទៅលើ នីតិវិធីនៃ ការដំណើរ និង ការប្រព្រឹត្តទៅសម្រាប់ការចុះកិច្ចគតិយុត្ត និង ការអនុវត្តបេសកម្មរបស់អាណត្តិគាហក ដែលមានលក្ខណៈឯករាជ្យ ខុសពីកិច្ចសន្យាការងារ។

[215] ម. ៦៣៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

## កថាខណ្ឌ១. ការប្រព្រឹត្តទៅនៃការតំណាងសម្រាប់ការចុះ កិច្ចគតិយុត្ត

ការតំណាងគឺជាភាពចាំបាច់សម្រាប់អាណត្តិ។ អាណត្តិ គឺជាស្ថិតក្នុងប្រភេទនៃការតំណាងតាមកិច្ចសន្យា ដែលខុសពីតំណាងតាមច្បាប់ (ដែលមានដូចជា អាណាព្យាបាលសម្រាប់អនីតិជន អាណាព្យាបាលទូទៅ ឬក៏ហិតូបម្ភក) និង តំណាងតាមសេចក្ដីសម្រេចរបស់តុលាការ។

អាណត្តិគាហក ត្រូវធ្វើកិច្ចគតិយុត្តក្នុងនាមផលប្រយោជន៍ឲ្យ អាណិត្តទាយក និង គ្រប់អានុភាពទាំងឡាយនៃអាណត្តិ គឺមានចំពោះ តែអាណត្តិទាយកតែប៉ុណ្ណោះ ប្រសិនបើអាណត្តិគាហក មិនធ្វើហួសពីអ្វី ដែលអាណត្តិទាយកបានផ្ដល់ឲ្យ។ អាណត្តិគាហក គឺជាបុគ្គលដែលបាន ចុះកិច្ចគតិយុត្តផ្សេងៗ (លក់ទិញ ប្ដូរ ម៉ៅការ)។

អាណត្តិគាហក គឺតាមរូបភាពខាងក្រៅជាបុគ្គលដែលចុះកិច្ច គតិយុត្ត ប៉ុន្ដែអានុភាពនៃកិច្ចគតិយុត្តទាំងនោះ មិនមានអានុភាពចំពោះ អាណត្តិគាហកឡើយ។

អាណត្តិគាហក គឺអវត្តមានតាមអង្គច្បាប់ ដោយសារតែតតិយជន ដឹងច្បាស់ថាអាណត្តិគាហកដែលបានចុះកិច្ចជាមួយ គឺគ្រាន់តែជា អ្នកតំណាងតែប៉ុណ្ណោះ។

អាណត្តិគាហក ត្រូវចុះកិច្ចគតិយុត្តក្នុងនាមឲ្យអាណត្តិទាយក មានន័យថា គាត់ទទួលបានអំណាចដើម្បីអនុវត្តសកម្មភាពដែលទទួល បានពីអាណត្តិ។

ជូនកាលអាណត្តិទាយកផ្តល់អំណាចឲ្យទៅអាណត្តិគាហក មាន លក្ខណៈទូទៅដើម្បីក្នុងនាមខ្លួន គេហៅថាអាណត្តិទូទៅ។ ផ្ទុយទៅវិញ គេហៅថាអាណត្តិពិសេស នៅពេលអំណាចដែលផ្តល់ឲ្យគឺកំណត់បញ្ជាក់ ច្បាស់ ជាពិសេសទៅលើកិច្ចអ្វីមួយ អ្នកតំណាងដែលអាណត្តិគាហក អាចចុះតែកិច្ចអ្វីដែលបានកំណត់តែប៉ុណ្ណោះ។

ទោះបីជាអាណត្តិទូទៅ ឬ ពិសេសក៏ដោយ អាណត្តិគឺអាច យកកម្រៃ ឬ មិនយកកម្រៃ។ សម្រាប់ភ្នាក់ងារ អចលនទ្រព្យ ឬ ភ្នាក់ងារ ទេសចរណ៍ គឺជាប្រភេទអាណត្តិដែលយកកម្រៃដោយសារពួកគាត់គឺជា ពាណិជ្ជករ ដែលសកម្មភាពរបស់ពួកគាត់គឺស្វែងរកប្រាក់ចំណេញ។[216]

អាណត្តិគាហកអនុវត្តបេសកម្មរបស់ខ្លួនដោយឯករាជ្យ។ អាណត្តិគាហកមិនស្ថិតក្រោម ចំណងធិនភាពរបស់អាណត្តិទាយកនោះឡើយ។ អាណត្តិគាហក ទទួលបញ្ជាក្នុងការអនុវត្តបេសកម្មណាមួយ តែមាន សេរីភាពក្នុងការជ្រើសរើសមធ្យោបាយដើម្បីសម្រេចលទ្ធផល ដូចជាក្នុង ករណីភ្នាក់ងារលក់អចលនទ្រព្យ អាចជ្រើសរើសការផ្សព្វផ្សាយពាណិជ្ជកម្មតាមរយៈបណ្តាញសង្គម ឬ តាមកាសែត ឬបិទផ្សាយជាដើម។

អាណត្តិបង្ហាញពីភាពខុសគ្នាជាមួយកិច្ចសន្យាការងារ ដែលមាន ជាប់នូវចំណងធិនភាព រវាងកម្មករ និយោជិត ជាមួយនឹងនិយោជក ហើយអាណត្តិគឺស្រដៀងទៅនឹងកិច្ចសន្យាម៉ៅការ ដោយសារតែអ្នកម៉ៅការ ធ្វើការដោយឯករាជ្យដូចនឹងអាណត្តិគាហកផងដែរ។

---

[216] ម. ១ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម ឆ្នាំ១៩៩៩។

ការបែងចែកភាពខុសគ្នារវាងកិច្ចសន្យាអាណត្តិ និង កិច្ចសន្យា ការងារ មិនមានភាពងាយស្រួល ដោយសារមានមូលហេតុពីរយ៉ាង៖

មូលហេតុទីមួយ៖ អ្នកតំណាងមួយចំនួនតាមពិតទៅគឺជានិយោជិត។ នៅក្នុងសហគ្រាសមួយចំនួន និយោជិតមានសេរីភាពក្នុង រៀបចំមធ្យោបាយ ដើម្បីសម្រេចការងារ ដូចជាការងារស្វែងរកអតិថិជន។ ជួនកាលពេលខ្លះ ពួកគាត់អាចតំណាងឲ្យក្រុមហ៊ុនផ្សេងៗគ្នា។

មូលហេតុទីពីរ៖ ជួនកាលកិច្ចសន្យាទាំងពីរ ត្រូវបានបញ្ចូលគ្នា និយោជិត អាចក្លាយជាអភិបាលក្នុងក្រុមហ៊ុន ដែលមានន័យថាគាត់ជា អាណ្ណគាហកឲ្យក្រុមហ៊ុន។

## កថាខណ្ឌ២. ការបង្កើតកិច្ចសន្យា

ដូចកិច្ចសន្យាដទៃទៀត អាណត្តិគឺទាមទារឲ្យមានជំនួបឆន្ទៈគូភាគី និងមានវិធានពិសេសសម្រាប់សមត្ថភាពគូភាគី។

### ១. ឆន្ទៈគូភាគី

នៅក្នុងជំនួបឆន្ទៈគូភាគី គឺអាចមានទម្រង់២នៃការបង្កើត អាណត្តិ គឺ៖ ការបង្កើតលក្ខណៈទូទៅ និង ការងបង្កើតក្រោមលក្ខខណ្ឌ ពិសេស។

#### ១.១. ការបង្កើតអាណត្តិក្រោមលក្ខណៈទូទៅ

ការបង្កើតកិច្ចសន្យាអាណត្តិ គឺទាមទារឲ្យមានជំនួបសំណើ និង ស្ទីការ។ សំណើមិនត្រូវបានទាមទារឲ្យមានបំពេញទម្រង់ពិសេស នោះទេ

សំណើអាចធ្វើឡើងដោយផ្ទាល់មាត់។ ប្រសិនជាសំណើ ធ្វើក្រោមទម្រង់ ជាលាយលក្ខណ៍អក្សរ គឺអាចជាលិខិតឯកជន ឬ យថាភូតិទៅតាមការចរចា គ្នារវាងគូភាគី។[217]

ក្នុងករណីមួយចំនួនអាណត្តិ ត្រូវតែតាក់តែងជាលាយលក្ខណ៍ អក្សរ ដូចជា អាណត្តិគាហកដែលជាភ្នាក់ងារអចលនវត្ថុ។ សំណើរត្រូវ ចង្អុលបង្ហាញពីឈ្មោះរបស់អាណត្តិគាហក និង កម្មវត្ថុនៃអាណត្តិ។

នៅពេលដែលអាណត្តិទាយក មិនបានបញ្ជាក់ពីកម្មវត្ថុនៃ អាណត្តិទេ ប្រត្តិបត្តិការនេះមានហានិភ័យណាស់សម្រាប់អាណត្តិទាយក ដែលជាមូលហេតុនាំឲ្យកម្មវត្ថុដែលមិនបញ្ជាក់ច្បាស់លាស់ គឺត្រូវកំណត់ តែជាកិច្ចគ្រប់គ្រងតែប៉ុណ្ណោះ ដោយមិនអនុញ្ញត្តិឲ្យធ្វើកិច្ចចាត់ចែង ដែលគ្រោះថ្នាក់សម្រាប់អាណត្តិទាយក។ ប្រសិនកម្មវត្ថុនៃកិច្ចដែលឲ្យ ធ្វើខុសច្បាប់ នាំឲ្យអាណត្តិត្រូវចាត់ទុកមោឃៈដូចគ្នា (ទ្រឹស្តីគោល និង បន្ទាប់បន្សំ)។

ចំណែកស្វីការវិញ គឺមានសារៈសំខាន់ក្នុងការបង្កើតអាណត្តិ។ ស្វីការក៏ដូចគ្នានឹងសំណើ ផងដែរដោយពុំចាំបាច់ទាមទារឲ្យមានទម្រង់ ជាលាយលក្ខណ៍អក្សរនោះទេ។

[217] ម. ៦៣៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

## ១.២. ការបង្កើតអាណត្តិក្រោមលក្ខខណ្ឌពិសេស

**អាណត្តិដោយតណ្ហីភាព៖** ការធ្វើស្ទីការនៃអាណត្តិ អាចជាករណីតណ្ហីភាព ដោយសារតែកើតចេញពីការបំពេញតាវកាលិករបស់អាណត្តិគាហក។

ដូចជានៅក្នុងកិច្ចគ្រប់គ្រងទ្រព្យរបស់សហព័ទ្ធ ឬ ទាក់ទងនឹងបំណុលគ្រួសារ សហព័ទ្ធម្ខាងអាចធ្វើកិច្ចគ្រប់គ្រងនោះតាំងនាមឲ្យ សហព័ទ្ធម្ខាងទៀតនៅក្នុងជីវភាពប្រចាំថ្ងៃ និង ដើម្បីផលប្រយោជន៍ គ្រួសារ។[218]

នៅក្នុងករណីទ្រព្យអវិភាគ អវិភាគីណាម្ខាងបានធ្វើកិច្ចគ្រប់គ្រង លើទ្រព្យអវិភាគដែលជាអាណត្តិដោយតណ្ហីភាព។

**អាណត្តិដែលមានលក្ខណៈជារូបភាព**[219]**៖** បុគ្គលម្នាក់បានចុះកិច្ច គតិយុត្តិជាមួយតតិយជនដោយ គាត់ពុំទទួលបានអាណត្តិក៏ដោយ ហើយតតិយជនយល់ច្រឡំថា បុគ្គលដែលបានចុះកិច្ចជាមួយគឺជាអាណត្តិ គាហក អាចនិយាយបានថា តតិយជនត្រូវមានការប្រុងប្រយ័ត្នទៅលើ អាណត្តិដែលមិនស្របច្បាប់ ពីព្រោះបុគ្គលដែលចុះកិច្ចគតិយុត្តជាមួយ ពុំមានសិទ្ធិពិតប្រាកដជាអាណត្តិគាហក។

[218] ម. ៩៧៤ និង ម. ៩៧៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[219] ម. ៣៧២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ដូចជាតតិយជនយល់ច្រឡំថា កូនរបស់ម្ចាស់បំណុលមក ទាមទារ ឲ្យតតិយជនដែលជាកូនបំណុល សងលុយព្រោះដល់ពេលកំណត់ ត្រូវបំពេញតាវកាលិក។

ដូច្នេះកូនបំណុល ដែលជាតតិយជនយល់ឃើញ ថាកូនរបស់ម្ចាស់បំណុលជាអាណត្តិគាហក ត្រូវបង្ហាញពីការភ័ន្តច្រឡំ របស់ខ្លួន ដើម្បីតតិយជនដែលជាកូនបំណុលនោះបានរួចពីកាតព្វកិច្ច ដែលបានបំពេញ ដោយសារតែកូនរបស់ម្ចាស់បំណុលពុំទទួលបាន អាណត្តិពីម្ចាស់បំណុលមកទាមទារអនុវត្តកាតព្វកិច្ច។

អាណត្តិគាហក ដែលមានលក្ខណៈជារូបភាពដែលភ័ន្តច្រឡំ ត្រូវទទួលខុសត្រូវចំពោះភាគី ទាំងសងខាង៖

**ចំពោះតតិយជន៖** អាណត្តិគាហកមិនត្រូវបានទទួលខុសត្រូវ តាមរយៈកិច្ចសន្យា ដោយសារតែអាណត្តិគាហកតាមរូបភាពខាងក្រៅ (ឬក្លែងក្លាយ) មិនទទួលបានអាណត្តិ។ ប៉ុន្តែការទទួលខុសត្រូវអំពើ អនីត្យានុកូលត្រូវបានធ្វើឡើង ដោយសារតែអាណត្តិគាហកក្លែងក្លាយ បានប្រព្រឹត្តកំហុសដែលបង្កព្យសនកម្មដល់តតិយជន។

**ចំពោះអាណត្តិទាយក៖** អាណត្តិគាហកក្លែងក្លាយពុំមាន សិទ្ធិតំណាងអោយអាណត្តិទាយក គឺពួកគាត់ទាំងពីរពុំបានចុះកិច្ចសន្យា ជាមួយគ្នា។ ប៉ុន្តែអាណត្តិគាហកក្លែងក្លាយ ត្រូវទទួលខុសត្រូវចំពោះ អាណត្តិទាយកតាមរូបមន្តការទទួលខុសត្រូវអំពើអនីត្យានុកូល ដោយសារ តែអាណត្តិគាហកពុំបានទទួលសិទ្ធិក្នុងការតំណាង។

ផ្ទុយទៅវិញប្រសិន ជាមានកិច្ចសន្យា តែអាណត្តិគាហកធ្វើហួសពីព្រំដែនសិទ្ធិដែលទទួលបាន នាំឲ្យការទទួលខុសត្រូវនោះជាការទទួលខុសត្រូវនៃកិច្ចសន្យា។

អាណត្តិទាយក ក៏អាចធ្វើសច្ចានុម័តទៅលើកិច្ចដែលបានធ្វើរួចដោយអាណត្តិគាហកតាមរូបភាពខាងក្រោមនេះបានផងដែរ នាំឲ្យកិច្ច ដែលបានធ្វើទាំងប៉ុន្មានមានសុពលភាព និង មានអានុភាពចំពោះ អាណត្តិទាយកជាមួយនឹងតតីយជន។

## ២. សមត្ថភាព

នៅក្នុងកិច្ចសន្យាអាណត្តិមិនខុសពីកិច្ចសន្យាដទៃ ភាគីទាំងពីរទាំងអាណត្តិទាយក និង អាណត្តិគាហកត្រូវមានសមត្ថភាព។

## ២.១. អាណត្តិទាយក

អាណត្តិទាយកត្រូវមានសមត្ថភាពធ្វើសកម្មភាព និង សមត្ថភាពទទួលសិទ្ធិ ដើម្បីឲ្យអំណាចដែលផ្ទេរទៅអាណត្តិគាហកមានសុពលភាព។

អាណត្តិសម្រាប់ការលក់៖ អាណត្តិទាយកត្រូវមានសិទ្ធិ ក្នុងការចាត់ចែង ព្រោះកិច្ចសន្យាលក់ទិញគឺទាមទារឲ្យមានការផ្ទេរសិទ្ធិ កម្មសិទ្ធិ។

អាណត្តិសម្រាប់ភតិសន្យា៖ អាណត្តិទាយកត្រូវមានសិទ្ធិ គ្រប់គ្រងដូចជាករណីទ្រព្យរួមរបស់សហព័ទ្ធ។

ការវាយតម្លៃអំពីសមត្ថភាព គឺធ្វើឡើងនៅថ្ងៃដែលអាណត្តិ ត្រូវបានបង្កើតឡើង។ អាណត្តិទាយក មិនអាចធ្វើការលុបចោលអាណត្តិ ដោយសារមូលហេតុអសមត្ថភាព នៅក្រោយពេលចុះកិច្ចសន្យាអាណត្តិ ។

## ២.២. អាណត្តិគាហក

សមត្ថភាពរបស់អាណត្តិគាហក ត្រូវធ្វើការវាយតម្លៃចំពោះ អាណត្តិទាយកផង និងចំពោះតតិយជនដែលចុះកិច្ចជាមួយផង។

ចំពោះអាណត្តិទាយកៈ អាណត្តិគាហកត្រូវមានសមត្ថភាព ធ្វើសកម្មភាព បើមិនដូច្នេះទេអាណត្តិត្រូវបានលុបចោល មានន័យថា អាណត្តិគាហក មិនមែនជាអនីតិជន ឬ នីតិជនដែលស្ថិតក្រោមរបប អាណាព្យាបាលទូទៅ ឬ របបហិតូបត្ថម្ភ។

នៅក្នុងបទបញ្ញាត្តិអាណត្តិ ពុំមានចែងពីអសមត្ថភាពទទួលសិទ្ធិ ប៉ុន្តែប្រសិនជាពិនិត្យមើលអ្នកតំណាងតាមច្បាប់ ដូចជាអ្នកអាណាព្យាបាល សម្រាប់អនីតិជន ក្រមរដ្ឋប្បវេណីបានដកហូតសិទ្ធិបុគ្គលមួយចំនួនមិនឲ្យ ក្លាយជាអ្នកតំណាងតាមច្បាប់បានដូចជា ជនដែលក្ស័យធន ឬជនដែលគ្មាន ដំណឹងអំពីទីរស់នៅ។[220]

ចំពោះតតិយជនៈ សមត្ថភាពរបស់អាណត្តិគាហក ក៏មិនខុសពីអ្វីដែលបង្ហាញសម្រាប់អាណត្តិទាយកនោះទេ មានន័យថាអាណត្តិគាហក ត្រូវតែជាជនដែលមានសមត្ថភាពធ្វើសកម្មភាព។

---

[220] ម. ១០៧៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

លទ្ធផលគឺ អាណត្តិទាយក ត្រូវទទួលខុសត្រូវចំពោះតតិយជន ក្នុងករណីអាណត្តិគាហកគឺជាអសមត្ថជន។

ចំណុចកត់សំគាល់ដ៏សំខាន់មួយទៀត គឺអាណត្តិគាហកមិនអាចដើរតួនាទីពីរក្នុងពេលតែមួយ មានន័យថាអាណត្តិគាហកមិនអាចចុះកិច្ច គតិយុត្តក្នុងនាមខ្លួន នៅពេលដែលគាត់ទទួលបានអាណត្តិ ដូចជាករណី អាណត្តិគាហកទទួលអាណត្តិក្នុងការស្វែរកអ្នកទិញអចលនទ្រព្យ ដោយ ភ្នាក់ងារអចលនទ្រព្យដើរតួជាពីរក្នុងពេលតែមួយ តំណាងឲ្យអាណត្តិ គាហកផង និងជាអ្នកទិញផង។

## ផ្នែកទី២. អានុភាពនៃអាណត្តិ

លក្ខណៈពិសេសនៃអាណត្តិ គឺត្រូវធ្វើការវិភាគទំនាក់ទំនង ត្រីភាគី រវាងអាណត្តិទាយក និង អាណត្តិគាហក អាណត្តិទាយក ជាមួយតតិយជន និង អាណត្តិគាហកជាមួយតតិយជន រួមទាំង ការបញ្ចប់អាណត្តិ។



## កថាខណ្ឌ១. ទំនាក់ទំនងរវាងអាណត្តិទាយក និង អាណត្តិគាហក

នៅពេលដែលមានជំនួបសំណើ និង ស្វីការ នាំឲ្យទំនាក់ទំនង អាណ្ណាត្តិទាយក និង អាណត្តិគាហក បង្កើតបានជាសិទ្ធិ និង ករណីយកិច្ចទៅវិញទៅមក។

## ១. ករណីយកិច្ចរបស់អាណត្តិគាហក

ករណីយកិច្ចរបស់អាណត្តិគាហក គឺត្រូវបានកំណត់ដោយ ក្រមរដ្ឋប្បវេណីដែលមានដូចជា ករណីយកិច្ចប្រុងប្រយ័ត្ន រាយការណ៍ ប្រគល់។

### ១.១. អាណត្តិគាហកត្រូវអនុវត្តអាណត្តិ

ករណីយកិច្ចរបស់អាណត្តិគាហក គឺប្រែប្រួលទៅតាមបេសកម្ម របស់ខ្លួន។ ជាគោលការណ៍អាណត្តិគាហក គឺជាមានករណីយកិច្ច ប្រុងប្រយ័ត្ន។ អាណត្តិគាហកត្រូវប្រើប្រាស់គ្រប់មធ្យោបាយ ដើម្បីចុះកិច្ច គតិយុត្តដែលជាផលប្រយោជន៍ឲ្យអាណត្តិទាយក។

ករណីយកិច្ចប្រុងប្រយ័ត្ន ដែលក្រមរដ្ឋប្បវេណីបានកំណត់ គឺសំដៅទៅលើកិច្ចដែលធ្វើឡើង ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ដោយផ្អែកទៅតាមខ្លឹមសារនៃអាណត្តិ។[221] ក្នុងអត្ថន័យនេះ ករណីយកិច្ច ប្រុងប្រយ័ត្ន គឺជា

---

[221] ម. ៦៤០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ប្រភេទកាតព្វកិច្ចលទ្ធផលនៅពេលអនុវត្តភារកិច្ចរបស់ ខ្លួន ដូចជាករណីយកិច្ចគ្រប់គ្រងវត្ថុឲ្យបានគង់វង្សមិនឲ្យកើតមានអគ្គីភ័យ ជាដើម។

ករណីយកិច្ចនេះ មានភាពប្រែប្រួលទៅតាមប្រភេទអាណត្តិ ដោយសារតែអាណត្តិអាចជាកិច្ចសន្យាមុជា ឬ មូលា។

ប្រសិនជាអាណត្តិ ដែលផ្តល់ឲ្យអ្នកជំនាញដោយយកកម្រៃ អាណត្តិគាហកត្រូវបង្ហាញពីសមត្ថភាពរបស់ខ្លួន ដែលការវាយតម្លៃមាន លក្ខណៈសត្យានុម័ត ដូចជាករណីភ្នាក់ងារអចលនទ្រព្យ។

ប្រសិនជាអាណត្តិពុំយកកម្រៃ អាណត្តិគាហកត្រូវបានវាយតម្លៃដោយយកបុគ្គលជាធំ។

ករណីយកិច្ចប្រុងប្រយ័ត្ន ត្រូវបានវាយតម្លៃដោយលក្ខណៈ ច្រើនយ៉ាង៖

**ការអនុវត្តភារកិច្ចត្រូវតែជាលក្ខណៈបុគ្គល៖** ជាគោលការណ៍ ការជ្រើសរើសអាណត្តិគាហក គឺផ្អែកលើគោលការណ៍«ការយកបុគ្គល ជាធំ» សម្រាប់អាណត្តិទាយក ដោយសារតែអាណត្តិគាហកត្រូវបំពេញ ភារកិច្ចដែលប្រគល់ឲ្យ។

**ការអនុវត្តភារកិច្ចត្រូវតែច្បាស់លាស់៖** នៅក្នុងខ្លឹមសារអាណត្តិត្រូវកំណត់ឲ្យបានជាក់លាក់ពីភារកិច្ចរបស់អាណត្តិគាហក ឧទាហរណ៍៖ អាណត្តិគាហកមិនអាចលក់ក្រោមតម្លៃអប្បបរមា ដែលបានកំណត់ដោយ អាណត្តិទាយក ឬ អាណត្តិគាហកទទួលយកមធ្យោបាយបង់ប្រាក់ផ្សេងពីអ្វី ដែអាណត្តិ

ទាយកបានកំណត់។ នៅក្នុងករណីនេះអាណត្តិគាហកធ្វើ លើសពីភារកិច្ចរបស់ខ្លួនដែលជាមូលហេតុនាំឲ្យមានការទទួលខុសត្រូវ។

**ការអនុវត្តភារកិច្ចត្រូវតែប្រុងប្រយ័ត្ន និង សុចរិតៈ** ការប្រុងប្រយ័ត្នរបស់អាណត្តិគាហក គឺការឃើតយ៉ាវក្នុងការអនុវត្តភារកិច្ចនាំឲ្យមាន ព្យសនកម្មអាណត្តិទាយក។

ភាពសុចរិតរបស់អាណត្តិគាហក គឺ ត្រូវធ្វើក្នុងនាម និងផលប្រយោជន៍របស់អាណត្តិទាយក។ អាណត្តិគាហក មិនអាចអនុវត្តភារកិច្ច ដើម្បីផលប្រយោជន៍របស់ខ្លួន។ ឧ៖ អាណត្តិគាហក ទទួលបន្ទុក ក្នុងការលក់អាណត្តិទាយកបានទិញវត្ថុ ដែលគាត់ត្រូវតំណាងក្នុង ការលក់។ ប្រត្តិបត្តិការនេះ គឺមានភាពគ្រោះថ្នាក់ដោយសារតែអាណត្តិ គាហក អាចធ្វើឡើងក្នុងផលប្រយោជន៍របស់ខ្លួន។

ភាពសុចរិតមួយទៀត អាចធ្វើការបកស្រាយក្នុងសម្មតិកម្មដែលអាណត្តិគាហកធ្វើការប្រកួតប្រជែងមិនស្មោះត្រង់ ដូចជាការលក់ផលិតផលប្រកួតប្រជែងនឹងអាណត្តិទាយក ដែលបានប្រគល់អាណត្តិក្នុងការលក់។

ករណីយកិច្ចសុចរិត គឺអាចធ្វើការពង្រឹងតាមរយៈការចែងខសន្យា ស្តីពីការមិនប្រកួតប្រជែងក្រោយពេលបញ្ចប់កិច្ចសន្យា ដើម្បីការពារ ផលប្រយោជន៍ឲ្យអាណត្តិទាយក។ ប៉ុន្តែការចែងខសន្យានេះ អាចប៉ះពាល់ ដល់សេរីភាពវិជ្ជាជីវៈរបស់អាណត្តិគាហក ក្រោយពេលបញ្ចប់អាណត្តិ ដូច្នេះត្រូវមាន សំណងទៅដល់អាណត្តិគាហកដែលមានជាប់នូវកាតព្វកិច្ច មិនឲ្យធ្វើក្រោយពេលអានុភាពនៃកិច្ចសន្យាអាណត្តិត្រូវបានបញ្ចប់។

មានប្រតិបត្តិការមួយប្រភេទទៀត គឺអាណាត្តិគាហកចុះកិច្ចសន្យាដើងសាធានាបំណុលរបស់កូនបំណុល ដូចជាអាណាត្តិគាហក ធានាការ អនុវត្តតាវកាលិករបស់អ្នកទិញក្នុងការបង់ប្រាក់ទៅអ្នកលក់ ឬធានាការ អនុវត្តតាវកាលិករបស់ភតិកៈក្នុងការបង់ថ្លៃឈ្នួល។ ការធានារបស់អាណាត្តិ គាហក គឺប្តូរនឹងកម្រៃជើងសារនៃការធានា មានន័យថាបើកូនបំណុល អលទ្ធភាពក្នុងការបំពេញតាវកាលិក គឺអាណាត្តិគាហក ជាអ្នកបំពេញ តាវលិកជំនួស។ នៅក្នុងប្រតិបត្តិការនេះ អាណាត្តិគាហក គឺជាអ្នកជំនាញ ដែលសិក្សាពីលទ្ធភាពរបស់កូនបំណុល មុននឹងចុះកិច្ចសន្យាកម្រៃជើងសា ធានាកូនបំណុលដែលជាអាណាត្តិទាយក។

## ១.២. គណនេយ្យភាពរបស់អាណាត្តិទាយក

តាមរយៈក្រមរដ្ឋប្បវេណី អាណាត្តិគាហកត្រូវរាយការណ៍អំពី ស្ថានភាពនៃកិច្ចការចាត់ចែងអាណាត្តិ ទោះបីនៅពេលណាក៏ដោយ ឬត្រូវរាយការណ៍អំពីហេតុការណ៍នោះ ដោយគ្មានការយឺតយ៉ាវនៅក្រោយពេល បញ្ចប់អាណាត្តិ។[222]

ករណីយកិច្ចនេះត្រូវបានច្បាប់កំណត់ ដោយអំឡុងពេលអាណាត្តិ អាណាត្តិគាហកត្រូវជូនដំណឹងទៅ អាណាត្តិទាយកពីការងារដែលបានធ្វើ។ នៅពេលបញ្ចប់អាណាត្តិ អាណាត្តិគាហកត្រូវបង្ហាញពីលទ្ធផល ដែលគាត់ បានបំពេញដោយប្រុងប្រយ័ត្ន ដូចជាមេធាវីត្រូវផ្តល់ព័ត៌មានទៅកូនក្តី របស់គាត់ពីការងារដែលបានសម្រេចជាដើម។

[222] ម. ៦៤១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ម្យ៉ាងវិញទៀត អាណត្តិគាហកត្រូវមានករណីយកិច្ចបដិទាននូវអ្វីដែលបានទទួលក្នុងអំឡុងពេលបំពេញភារកិច្ច (ដូចជា៖ ឯកសារ សម្ភារៈ ផ្សេងៗ...)។ ប្រសិនជាអាណត្តិគាហក មិនធ្វើបដិទានត្រឡប់នូវសម្ភារៈ ដែលបានទទួល គឺអាណត្តិគាហក អាចនឹងមានទំនួលខុសត្រូវខាងផ្នែក ព្រហ្មទណ្ឌ ពីបទល្មើសរំលោភលើសេចក្តីទំនុកចិត្ត។

តាមរយៈក្រមរដ្ឋប្បវេណី អាណត្តិគាហកត្រូវប្រគល់ប្រាក់ និងវត្ថុ ផ្សេងៗទៀតដែលទទួលបានតាមការចាត់ចែងកិច្ចការអាណត្តិ ឲ្យទៅ អាណត្តិទាយក។ អាណត្តិគាហក ក៏ត្រូវប្រគល់ផលដែលប្រមូលបានឲ្យទៅ អាណត្តិទាយកផងដែរ។ ជាពិសេសចំពោះការធ្វើលទ្ធកម្មសិទ្ធិ អាណត្តិ គាហកដែលបានលទ្ធកម្មសិទ្ធិ នៅក្នុងនាមជាអាណត្តិគាហកត្រូវធ្វើការផ្ទេរ សិទ្ធិនេះឲ្យទៅអាណត្តិទាយក។[223]

ប៉ុន្តែអាណត្តិគាហក អាចប្រើប្រាស់សិទ្ធិឲ្យអនុវត្តព្រមគ្នានូវពេលដែលអាណត្តិទាយកមិនទាន់ទូទាត់កម្រៃការងារដែលបានធ្វើ ដោយលើក ពីគោលការណ៍នៃការតវ៉ាដោយមានការបារម្ភ ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី។[224]

## ១.៣. ករណីយកិច្ចផ្តល់ប្រឹក្សា

នៅក្នុងក្រមរដ្ឋប្បវេណី ពុំបានចែងពីករណីយកិច្ចផ្តល់ប្រឹក្សា របស់អាណត្តិគាហកនោះទេ ប៉ុន្តែប្រសិនជាពិនិត្យទៅលើស្ថានភាព ជាក់ស្តែង គេ

---

[223] ម. ៦៤១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[224] ម. ៣៨៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ឃើញថាអាណត្តិគាហកគឺជាអ្នកជំនាញ ដូចជាភ្នាក់ងារ អចលនទ្រព្យ ភ្នាក់ងារទេសចរណ៍ មេធាវីជាដើម ជាការអនុវត្ត អ្នកជំនាញតែងតែផ្តល់ប្រឹក្សាទៅអតិថិជនរបស់ខ្លួន មុននឹងចុះកិច្ចគតិយុត្ត ដូចជាផ្តល់ប្រឹក្សាទៅតម្លៃដែលត្រូវលក់ អំពីឱកាសនៅក្នុងរឿងក្តីដែលមាន វិវាទ។

ចំណែកអាណត្តិគាហកដែលមិនមែនជាអ្នកជំនាញ ក៏មាន សមត្ថភាពអ្វីផ្សេងក្នុងការផ្តល់ជាយោបល់ ទៅកាន់អាណត្តិទាយកផងដែរ។ ករណីយកិច្ចមួយនេះ ត្រូវបានចាត់ទុកជាប្រភេទកាតព្វកិច្ចមធ្យោបាយ។

## ២. ករណីយកិច្ចរបស់អាណត្តិទាយក

ជាទូទៅករណីយកិច្ច របស់អាណ្ណត្តិទាយកពុំមានច្រើននោះទេ នៅក្នុងក្រមរដ្ឋប្បវេណី បានកំណត់ពីករណីយកិច្ចបង់ប្រាក់របស់អាណត្តិ ទាយកតែប៉ុណ្ណោះ។

ដើម្បីសម្រេចភារកិច្ចរបស់អាណត្តិគាហក អាណត្តិគាហកអាចទាមទារឲ្យបង់សោហ៊ុយជាមុន សម្រាប់ការចាត់ចែងកិច្ចអាណត្តិក្នុង ករណីដែលចាំបាច់។[225] អាណត្តិគាហកអាចចំណាយសោហ៊ុយជាមុនបាន រួចធ្វើការទាមទារនៅពេលក្រោយពីអាណត្តិទាយកនូវសោហ៊ុយ និង ការប្រាក់ដោយគិតចាប់ពីក្រោយថ្ងៃដែលបានចំណាយសោហ៊ុយ នោះ។[226]

---

[225] ម. ៦៤៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[226] ម. ៦៤៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ក្រៅពីការបង់សោហ៊ុយដើម្បីសម្រេចភារកិច្ច អាណត្តិគាហក ក៏មានសិទ្ធិទាមទារកម្រៃការងារបានផងដែរ ប៉ុន្តែលក្ខខណ្ឌត្រូវមានកំណត់ នៅក្នុងកិច្ចសន្យា បើមិនដូច្នោះទេច្បាប់ចាត់ទុកថាជាអាណត្តិមិនយក កម្រៃ។ ការយកកម្រៃការងារនេះក្រមរដ្ឋប្បវេណីបានកំណត់ជាបីករណី[227]៖

- ប្រសិនបើការកំណត់កម្រៃតាមអំឡុងពេល អាណត្តិគាហកមាន សិទ្ធិទាមទារឲ្យអាណត្តិទាយក បង់កម្រៃនៅក្រោយពេលដែល អំឡុងពេលបានកន្លងផុត។
- ប្រសិនបើកិច្ចសន្យា ពុំបានកំណត់អំពីកម្រៃតាមអំឡុងពេល នោះទេ អាណត្តិគាហកអាចទាមទារបាន លុះត្រាតែអាណត្តិ គាហកបានបំពេញភារកិច្ចរួចរាល់។
- ចំពោះការបញ្ចប់តួនាទីរបស់អាណត្តិគាហក នៅពាក់កណ្តាលទី អាណត្តិគាហកអាចទាមទារឲ្យ អាណត្តិទាយកធ្វើការបង់កម្រៃ ចំពោះការងារដែលបានធ្វើរួចរាល់ តាមគោលការណ៍សមមាត្រ ចំពោះភាគដែលបានធ្វើរួច លុះត្រាតែការបញ្ចប់ពាក់កណ្តាលទី មិនមែនជាកំហុសរបស់អាណត្តិគាហក។

## កថាខណ្ឌ២. អានុភាពនៃអាណត្តិចំពោះទំនាក់ទំនង រវាង គូភាគី និង តតិយជន

អានុភាពនៃអាណត្តិ គឺវាបង្កើតអានុភាពរវាងតតិយជនជាមួយ នឹងអាណត្តិទាយក មិនមែនជាមួយអាណត្តិគាហកនោះទេ។

---

227 ម. ៦៤៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

## ១. ទំនាក់ទំនងរវាង អាណត្តិទាយក និង តតិយជន

អណត្តិទាយក គឺមានទំនាក់ទំនងជាមួយតតិយជនតាមរយៈ កិច្ចសន្យាអាណត្តិ ដូចដែលបានកំណត់នៅក្នុងមាត្រា៦៣៧ក្រមរដ្ឋប្ប- វេណី អាណត្តិទាយក ប្រគល់សិទ្ធិអំណាចឲ្យអាណត្តិគាហកធ្វើការ ចាត់ចែងកិច្ចការដើម្បីអាណត្តិទាយក ជាមូលហេតុនាំឲ្យអាណត្តិទាយ ក្លាយជាកូនបំណុល ឬម្ចាស់បំណុលជាមួយនឹងតតិយជនដែលអាណត្តិ- គាហកបានចុះកិច្ច ជាមូលហេតុនាំឲ្យអាណត្តិទាយកក្លាយជាភាគី នៃកិច្ចសន្យា។[228]

នៅក្នុងសម្មតិកម្មអាណត្តិនៃការលក់ទិញៈ

- អាណត្តិទាយក ត្រូវធ្វើការផ្ទេរសិទ្ធិកម្មសិទ្ធិ ប្រគល់វត្ថុ និង ធានាវិការៈលើវត្ថុចំពោះតតិយជន
- អាណត្តិទាយក មានសិទ្ធិទទួលយកការបង់ប្រាក់របស់អ្នកទិញ ដែលជាតតិយជន
- អាណត្តិទាយក ត្រូវទទួលខុសត្រូវចំពោះខុសត្រូវចំពោះ តតិយជនក្នុងករណីដែលអាណត្តិគាហក បានចុះកិច្ចជាមួយ តតិយជន។ ការទទួលខុសត្រូវគឺត្រឹមកម្រិតដែល អាណត្តិទាយក បានផ្ទេរអំណាចឲ្យ ប្រសិនអាណត្តិគាហកធ្វើហួសព្រំដែនដែល បានផ្តល់ អាណត្តិគាហកជាអ្នកទទួលខុសត្រូវចំពោះកំហុសដែល បានកើតឡើង។

ក្នុងករណីដែល អាណ្ណត្តិគាហកតាមរូបភាពខាងក្រៅ ពុំទទួលបានសិទ្ធិតំណាង គឺនាំឲ្យទំនាក់ទំនងរវាងអាណត្តិទាយកជាមួយតតិយជន

[228] ម. ៣៦៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ពុំបង្កើតនូវអានុភាពឡើយ។ ដូច្នេះការទទួលខុសត្រូវគឺធ្លាក់ទៅលើ អាណត្តិគាហកដែលគ្មានសិទ្ធិ។[229]

ប្រសិនបើអាណត្តិទាយក បានធ្វើសច្ចានុមតិ ចំពោះកិច្ចដែលអាណត្តិគាហកដែលធ្វើគ្មានសិទ្ធិ ឬ ធ្វើលើសពីព្រំដែនអំណាចដែល ផ្តល់ឲ្យនាំឲ្យកិច្ចនោះមានសុពលភាពដោយសច្ចានុមតិតាំងពីពេលដែល អំពើនោះត្រូវបានធ្វើឡើង។[230]

ក្រមរដ្ឋប្បវេណីក៏បានការពារផលប្រយោជន៍តតិយជន ក្នុងករណីដែលការផ្តល់សច្ចានុមតិធ្វើឲ្យខូចប្រយោជន៍ដល់តតិយជន មានន័យថាអានុភាពនៃអាណត្តិពុំមានអានុភាពប្រតិសកម្មទេ ប្រសិនបើការផ្តល់ សច្ចានុមតិនោះធ្វើឲ្យខូចប្រយោជន៍ដល់តតិយជន អានុភាពនៃអាណត្តិ គឺចាប់មានអានុភាពចាប់ពីពេលផ្តល់សច្ចានុមតិតែប៉ុណ្ណោះ។

តតិយជនដែលមានទំនាក់ទំនងជាមួយអាណត្តិ អាចធ្វើការ លុបចោលអាណត្តិគ្មានសិទ្ធិបាន នៅមុនពេលដែលអាណត្តិទាយកធ្វើការ ផ្តល់សច្ចានុមតិ។[231]

## ២. ទំនាក់ទំនងរវាងអាណត្តិគាហក និង តតិយជន

តាមរយៈអាណត្តិ អាណត្តិគាហក និង តតិយជន ពុំមាន ទំនាក់ទំនងគតិយុត្តជាមួយគ្នានោះទេ។ ជាមូលហេតុនាំឲ្យកិច្ចនោះ ចង ភ្ជាប់ករណីយកិច្ច

[229] ម. ៣៦៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[230] ម. ៣៦៩ និង ម.៣៧០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[231] ម. ៣៧០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

រវាងអាណត្តិទាយក និងតតិយជនតែប៉ុណ្ណោះ លើកលែង ករណីអាណត្តិដែលពុំមានសិទ្ធិ អាណត្តិគាហកពុំមានសិទ្ធិ គឺធ្វើកិច្ច ក្នុងនាមខ្លួន ជាមូលហេតុនាំឲ្យមានការទទួលខុសត្រូវទៅកិច្ចដែល បានធ្វើ។

ក្រមរដ្ឋប្បវេណីបានបញ្ជាក់ថា ក្នុងករណីដែលអាណត្តិគាហក មានឆន្ទៈក្នុងការធ្វើកិច្ចការសម្រាប់អាណត្តិទាយក តែមិនបានបង្ហាញថា ធ្វើសម្រាប់អាណត្តិទាយក តតិយជនអាចអះអាង តែកិច្ចសន្យានោះដែល បានបង្កើតឡើងជាមួយនឹងអាណត្តិគាហក គឺមានអានុភាពតែជាមួយ អាណត្តិគាហកតែប៉ុណ្ណោះ។[232]

## កថាខណ្ឌ៣. ការបញ្ចប់អាណត្តិ

អាណត្តិ គឺជាប្រភេទកិច្ចសន្យាដែលយកបុគ្គលជាធំ។ ការបញ្ចប់អាណត្តិ ត្រូវបានធ្វើឡើងនៅពេលដែលមានព្រឹត្តិការណ៍ណាមួយធ្ងន់ធ្ងរ ដែលប៉ះពាល់ដល់គូភាគី។ ក្រមរដ្ឋប្បវេណីបានកំណត់ពីមូលហេតុនៃ ការបញ្ចប់អាណត្តិដោយស្វ័យប្រវត្តិ ឬ នៅពេលភាគីណាមួយចង់ ធ្វើការបញ្ចប់ដោយឯកតោភាគី។

## ១. ការបញ្ចប់អាណត្តិដោយស្វ័យប្រវត្តិ

មូលហេតុដែលនាំឲ្យមានការបញ្ចប់អាណត្តិដោយស្វ័យប្រវត្តិមានដូចជា[233]៖

---

[232] ម. ៣៧៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[233] ម. ៣៦៨ និង ម. ៦៤៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

**មរណភាពនៃភាគីណាមួយ** អាចជាអាណត្តិទាយក ឬ អាណត្តិគាហក ប៉ុន្តែអាណត្តិគាហក ត្រូវបន្តអាណត្តិរបស់ខ្លួន ប្រសិនជា កិច្ចសន្យា បានចែងពីខសន្យាដែលមិនបញ្ចប់អាណត្តិដោយសារមរណភាព របស់អាណត្តិទាយក។

**ក្នុងករណីធនក្ស័យរបស់ភាគីណាមួយ** ក៏ជាមូលហេតុនៃការ បញ្ចប់ផងដែរ លើកលែងតែខសន្យាចែងផ្ទុយដោយអនុញ្ញតិឲ្យបន្ត អាណត្តិ។

**នៅពេលដែលភាគីណាមួយក្លាយជាអសមត្ថជន** ស្ថិតក្រោមរបប អាណាព្យាបាលទូទៅ ឬ ហិតូបត្ថម្ភ លើកលែងតែសន្យាចែងថាបន្ត សុពលភាពអាណត្តិសម្រាប់ករណីដែលអាណត្តិទាយក ត្រូវបានស្ថិតរបប ក្រោមរបបតំណាងដោយច្បាប់។

ការបញ្ចប់អាណត្តិផងដោយសារតែ អាណត្តិទាយក ឬ អាណត្តិ- គាហកដែលជានីតិបុគ្គលបានរលាយ ឬ បានបញ្ចូលជាមួយនីតិបុគ្គល ផ្សេងទៀត។

ភាគីក៏អាចចែងពី មូលហេតុផ្សេងទៀតនៃការបញ្ចប់ដោយស្វ័យ- ប្រវត្តិនៅក្នុងកិច្ចសន្យាអាណត្តិ។

## ២. ការបញ្ចប់អាណត្តិដោយឯកតោភាគី

ក្រៅពីការបញ្ចប់ដោយស្វ័យប្រវត្តិនៃអាណត្តិ ច្បាប់ក៏អនុញ្ញតិឲ្យ ភាគីធ្វើការសម្រេចចិត្តបញ្ចប់អាណត្តិ មុនអំឡុងពេលអាណត្តិដោយ ឯកតោភាគី

មានន័យថាទាំងអាណត្តិទាយក ឬ អាណត្តិគាហក អាចរំលាយ កិច្ចសន្យាអាណត្តិនៅពេលណាក៏បាន។[234]

ការបញ្ចប់មុនអំឡុងពេលអាណត្តិមកដល់ គឺអាចបង្កព្យសនកម្ម ដល់ភាគីម្ខាងទៀត ហេតុដូច្នេះ ភាគីដែលសម្រេចចិត្តរំលាយអាណត្តិ ត្រូវសងសំណងនៃការខូចខាតនេះដល់ភាគីម្ខាងទៀតដែល ខូចប្រយោជន៍ ដោយសារការរំលាយនេះ លើកលែងតែមានមូលហេតុជាក់លាក់ដែលធ្វើ ឲ្យភាគីស្នើសុំរំលាយនោះ មិនអាចជៀសវាងពីការរំលាយនោះបាន ទើបពុំមានការសងសំណងដល់ភាគីម្ខាងទៀត ដូចជាអាណត្តិទាយក ពុំមានលទ្ធភាពក្នុងការបន្តបង់កម្រៃដល់អណត្តិគាហក។

ការរំលាយអាណត្តិ គឺពុំមានអានុភាពប្រតិសកម្មឡើយព្រោះ កិច្ចសន្យាអាណត្តិគឺជាប្រភេទកិច្ចសន្យាបន្តបន្ទាប់។ សម្រាប់កំហុសក្នុង រំលាយកិច្ចសន្យា ភាគីរងគ្រោះដោយសារការរំលាយនូវតែមានសិទ្ធិទាមទារ សំណងនៃការខូខាតចំពោះការរំលាយកិច្ចសន្យាអាណត្តិនោះបាន។[235]

234 ម. ៦៤៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

235 ម. ៦៤៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

# ឯកសារពិគ្រោះ

## ១. វិធានគតិយុត្តដែលនៅជាធរមាន

- ច្បាប់ស្តីពីកតិសន្យាពិសេស, លេខ នស/រកម/០៧១៥/០០៩. ២៩ កក្កដា ២០១៥
- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/ ០០៧, ៣១ ឧសភា ២០១១
- ក្រមរដ្ឋប្បវេណី, លេខ សន/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦
- ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១
- ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម, លេខ នស/រកម/ ០៦៩៥/០៤, ១៨ វិច្ឆិកា ១៩៩៥
- ច្បាប់ស្តីពីការងារ, លេខ ជស/រកម/០៣៩៧/០១, ១៣ មិនា ១៩៩៧
- ប្រកាសអន្តរក្រសួង ស្តីពីការអនុវត្តថែទាំសុខភាពតាមប្រព័ន្ធ មូលនិធិសមធម៌ សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅ ប្រព័ន្ធ និង ការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិត ជាស្ត្រី នៅពេលសម្រាលកូន, លេខ ៤០៤កប/ប្រ.ក.ប.ស.ស., ១១ តុលា ២០១៧

## ២. វិធានគតិយុត្តដែលនិរាករណ៍

- ច្បាប់ភូមិបាល(ចាស់), លេខ/១០០ ក្រ, ១០ សីហា ១៩៩២
- ក្រឹត្យច្បាប់ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅ កិច្ចសន្យា, លេខ៣៨ ក្រ.ច., ២៨ តុលា១៩៨៨
- ក្រមរដ្ឋប្បវេណី(ចាស់), ១៩២០

## ៣. សៀវភៅ

- Alain, Bénabent. Droit des obligations. Lgdj. 18e. Precis Domat, 2019.
- Tourneau, Philippe Le. Droit de la responsabilité et des contrats 2014/2015 - 10e éd. (Chapitre 1 - Agissements fautifs - Œuvre collective sous la direction de Phillipe Le Tourneau - Jérôme Julien). 10e édition. Paris: Dalloz, 2014.

## ៤. គេហទំព័រ

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ. "ប្រាក់ឈ្នួល អប្បបរមា របស់កម្មករនិយោជិតក្នុងវិស័យ វាយនភណ្ឌ កាត់ដេរ និង ផលិតស្បែកជើងសម្រាប់ឆ្នាំ២០២០ឡើងដល់១៩០ ដុល្លារ." ចូលមើល ថ្ងៃទី ៣ ខែមីនា ២០២១, http://www.mlvt.gov.kh/



**លោកស្រី ប៉ូលី បញ្ញា** ជាអតីតនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រពីរភាសា បារាំង-ខ្មែរនៅឆ្នាំ២០០៣ និងបញ្ចប់ថ្នាក់អនុបណ្ឌិត ផ្នែកនីតិសហប្រតិបត្តិការសេដ្ឋកិច្ចនៅ សាកលវិទ្យាល័យ ហ្សង់មូឡាំង លីយ៉ុង៣ នៅឆ្នាំ២០០៥។ បន្ទាប់មក លោកស្រីទទួលបាន ការបណ្តុះបណ្តាលបន្តអំពី កិច្ចរដ្ឋបាល ជាមួយអគ្គលេខាធិការរង នៃរាជរដ្ឋាភិបាលនៅ ទីស្តីការគណៈរដ្ឋមន្ត្រី និងចាប់ផ្តើមការងារបង្រៀន នៅឆ្នាំ២០០៦ គឺជាគ្រូបង្រៀនមុខវិជ្ជា សេចក្តីផ្តើមនីតិ និងច្បាប់អនុវត្តប្រចាំថ្ងៃនៅព្រះរាជាណាចក្រកម្ពុជា នៅមណ្ឌលសិក្សា បច្ចេកទេសធនាគារ និងក៏ជាទីប្រឹក្សាច្បាប់ ជូនក្រុមហ៊ុនអភិវឌ្ឍន៍ទីក្រុងរណបមួយនៅរាជធានីភ្នំពេញផងដែរ។ នៅឆ្នាំ២០០៧ លោកស្រីបានចូលបម្រើការងាររាជការជាគ្រូបង្រៀនកម្រិតឧត្តមជំនាន់ទី១ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដោយទទួលបន្ទុកបង្រៀនមុខវិជ្ជានីតិនគរូបនីយកម្ម និងសំណង់, នីតិវិនិយោគ, ប្រព័ន្ធនីតិអាស៊ាន, ប្រវត្តិរដ្ឋបាលសាធារណៈ និងនីតិសេដ្ឋកិច្ចសាធារណៈ។ នៅឆ្នាំ២០០៩-២០១០ លោកស្រី ទទួលបានអាហារូបករណ៍ទៅសិក្សាថ្នាក់អនុបណ្ឌិតនៅ Toronto ប្រទេសកាណាដានៅ York University, Osgoode Hall law school ជំនាញនីតិពាណិជ្ជកម្មអន្តរជាតិ នៅប្រទេសកាណាដា លោកស្រី មានឱកាសទទួលបានការបណ្តុះបណ្តាលប្រព័ន្ធច្បាប់Common law និងហ្វឹកហាត់ការងារនៅការិយាល័យមេធាវី Bennett Gastle Professional Corporation របស់សាស្ត្រាចារ្យ Charles M. Gastle។ នៅឆ្នាំ២០១៥-២០១៩ លោកស្រីទទួលបានការបណ្តុះបណ្តាលជាគ្រូបង្គោលក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ក្រោមគម្រោងJICAនៃក្រសួងយុត្តិធម៌។ លោកស្រីបច្ចុប្បន្នជាអនុប្រធានការិយាល័យស្រាវជ្រាវ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាគ្រូទទួលបន្ទុកមុខវិជ្ជានីតិនគរូបនីយកម្ម និងសំណង់ និងនីតិកិច្ចសន្យាពិសេស។ លោកស្រីមានអត្ថបទស្រាវជ្រាវមួយចំនួននៅសាកលវិទ្យាល័យបរទេសក៏ដូចជានៅ ស.ភ.ន.វ.ស. ផងដែររួមមានសៀវភៅនីតិប្រៀបធៀប នីតិការងារ នីតិវិនិយោគ និងសៀវភៅនីតិកិច្ចសន្យាពិសេសភាគ១នេះដែលទើបបោះពុម្ពថ្មីក្នុងឆ្នាំសិក្សា២០២១។



**លោកបណ្ឌិត ព្រុំ រិទ្ធី** ជាគ្រូបង្រៀនច្បាប់(តាំងពីឆ្នាំ២០០៧)និងជាអនុប្រធានដេប៉ាតឺម៉ង់ទំនាក់ទំនងអន្តរជាតិ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច (ស.ភ.ន.វ.ស.) នៅរាជធានីភ្នំពេញ ដែលនៅទីនោះ លោកក៏ជាអតីតនិស្សិតដែលបាន បញ្ចប់បរិញ្ញាបត្រនីតិសាស្ត្រឆ្នាំ២០០៣ផងដែរ។ គាត់ទទួលបានសញ្ញាបត្របណ្ឌិតជំនាញនីតិឯកជនពីសាកលវិទ្យាល័យ ហ្សង់មូឡាំង លីយ៉ុង៣(ប្រទេសបារាំង)នៅខែតុលា ឆ្នាំ២០១៥។ គាត់ជា សមាជិកក្រុមប្រឹក្សាវិទ្យាសាស្ត្រនៅ ស.ភ.ន.វ.ស. រួមទាំង សមាគមសាលាត្រាជូផងដែរ។ គាត់បង្រៀន នីតិអន្តរជាតិឯកជននីតិបេតកភណ្ឌ និងគ្រួសារក៏ដូចជា នីតិកិច្ចសន្យាពិសេស។ គាត់ជាអ្នកនិពន្ធអត្ថបទ ស្រាវជ្រាវមួយចំនួននៅ ស.ភ.ន.វ.ស ក៏ដូចជាសាកលវិទ្យាល័យបរទេស។ ស្នាដៃអត្ថបទស្រាវជ្រាវរបស់គាត់រួមមាននីតិបេតិកភណ្ឌ និងគ្រួសារ អត្រានុកូលដ្ឋាន នៅកម្ពុជា ឋានៈបវេណីនៅក្នុងនីតិគ្រួសារ។

**សៀវភៅសិក្សាស្តីពី នីតិកិច្ចសន្យាពិសេសភាគ១**

នឹងធ្វើការសិក្សាស៊ីជម្រៅទៅលើរបបគតិយុត្តនៃកិច្ចសន្យា ជាពិសេសគឺផ្តោតទៅលើកិច្ចសន្យាសំខាន់ៗមួយចំនួន ដោយផ្អែកទៅលើខ្លឹមសារនៃច្បាប់សារជាតុ និងវិធានពិសេសជុំវិញការបង្កើត និងការអនុវត្តកិច្ចសន្យា។ បន្ថែមពីនេះសៀវភៅសិក្សាគោលស្តីពី នីតិកិច្ចសន្យាពិសេសភាគ១នេះ គឺបានផ្តល់នូវគុណប្រយោជន៍ សម្រាប់អ្នកសិក្សា អ្នកស្រាវជ្រាវផ្នែកច្បាប់ អ្នកវិជ្ជាជីវៈ និងសៀវភៅនេះ ក៏មានភាពចាំបាច់ នៅក្នុងជីវភាពនៃការរស់នៅប្រចាំថ្ងៃរបស់អ្នកប្រើប្រាស់ ក៏ដូចជាពាណិជ្ជករ ដោយធ្វើការសិក្សាបែងចែកអំពី៖

- មេរៀនទី១ របបគតិយុត្តនៃកិច្ចសន្យា
- មេរៀនទី២ កិច្ចសន្យាលក់ទិញ
- មេរៀនទី៣ កិច្ចសន្យាការងារ
- មេរៀនទី៤ ភតិសន្យា
- មេរៀនទី៥ កិច្ចសន្យាម៉ៅការ
- មេរៀនទី៦ កិច្ចសន្យាអាណត្តិ
- មេរៀនទី៧ កិច្ចសន្យាដឹកជញ្ជូន